# អនុសញ្ញាអង្គការសហប្រជាជាតិ
# ស្តីពី
# ច្បាប់សមុទ្រ

## មាតិកា

ផ្នែកទី១៖ សេចក្តីផ្តើម ........ ៨

ផ្នែកទី២៖ ព្រំដែនសមុទ្រ និងតំបន់ត្រួត ........ ១០

ជំពូកទី១៖ បញ្ញាត្តិទូទៅ ........ ១០

ជំពូកទី២៖ ព្រំប្រទល់ដែនសមុទ្រ ........ ១០

ជំពូកទី៣៖ ការឆ្លងកាត់ដោយគ្មានចេតនាអាក្រក់ក្នុងបូរណភាពដែនសមុទ្រ ........ ១៨

ជំពូករងក៖ វិធានអនុវត្តចំពោះនាវាគ្រប់ប្រភេទ ........ ១៨

ជំពូករងខ៖ វិធានដែលអនុវត្តលើនាវាពាណិជ្ជករ និងនាវារដ្ឋាភិបាលដែលប្រតិបត្តិការក្នុងគោលបំណងពាណិជ្ជកម្ម ........ ២៤

ជំពូករងគ៖ វិធានអនុវត្តចំពោះនាវាចម្បាំង និងនាវារដ្ឋាភិបាលដទៃទៀតដែលប្រតិបត្តិការមិនដើម្បីគោលបំណងពាណិជ្ជកម្ម ........ ២៦

ជំពូកទី៤៖ តំបន់ជាប់គ្នា ........ ២៧

ផ្នែកទី៣៖ ច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ ........ ២៩

ជំពូកទី១៖ បទបញ្ញត្តិទូទៅ ........ ២៩

ជំពូកទី២៖ ច្រកឆ្លងកាត់ ........ ៣០

ជំពូកទី៣៖ ការឆ្លងកាត់មិនបំពាន ........ ៣៦

ផ្នែកទី៤៖ បណ្តារដ្ឋប្រជុំកោះ ........ ៣៨

ផ្នែកទី៥៖ តំបន់សេដ្ឋកិច្ចផ្តាច់មុខ ........ ៤៦

ផ្នែកទី៦៖ តំបន់ខ្ពង់រាបបាតសមុទ្រ ........ ៦៦

ផ្នែកទី៧៖ ដែនសមុទ្រអន្តរជាតិ ........ ៧៤

ជំពូកទី១៖ បទបញ្ញត្តិទូទៅ ........ ៧៤

ជំពូកទី២៖ កិច្ចអភិរក្ស និងការគ្រប់គ្រងធនធានមានជីវិតនៅដែនសមុទ្រអន្តរជាតិ ........ ៩១

ផ្នែកទី៨៖ របបកោះ ........ ៩៥

ផ្នែកទី៩៖ សមុទ្រហ៊ុំព័ទ្ធ ឬពាក់កណ្ដាលហ៊ុំព័ទ្ធ ........ ៩៦

ផ្នែកទី១០៖ សិទ្ធិក្នុងការចេញចូលដែនសមុទ្រ និងសេរីភាពឆ្លងកាត់របស់រដ្ឋហ៊ុំព័ទ្ធដោយដីគោក ........ ៩៧

ផ្នែកទី១១៖ តំបន់ ........ ១០១

ជំពូកទី១៖ បទបញ្ញត្តិរួម ........ ១០១

ជំពូកទី២៖ គោលការណ៍គ្រប់ដណ្ដប់តំបន់ ........ ១០២

ជំពូកទី៣៖ ការអភិវឌ្ឍធនធានក្នុងតំបន់ ........ ១១១

ជំពូកទី៤៖ អាជ្ញាធរ ........ ១២៣

ជំពូករងក៖ បទបញ្ញត្តិទូទៅ ........ ១២៣

ជំពូករងខ៖ សន្និបាត ........ ១២៥

ជំពូករងគ៖ ក្រុមប្រឹក្សា ........ ១៣១

ជំពូករងឃ៖ លេខាធិការដ្ឋាន ........ ១៤៩

ជំពូករងង៖ សហគ្រាស ........ ១៥៣

ជំពូករងច៖ ផែនការហិរញ្ញវត្ថុរបស់អាជ្ញាធរ ........ ១៥៣

ជំពូករងឆ៖ ស្ថានភាពគតិយុត្តិបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ ........ ១៥៦

ជំពូករងជ៖ ការផ្អាកការអនុវត្តសិទ្ធិ និងឯកសិទ្ធិរបស់សមាជិក ........................................ ១៦១

ជំពូកទី៥៖ ការដោះស្រាយវិវាទ និង យោបល់ទីប្រឹក្សា........................................ ១៦២

ផ្នែកទី១២៖ការការពារ និង ការថែរក្សាបរិស្ថានសមុទ្រ ........................................ ១៦៩

ជំពូកទី១៖ បទបញ្ញត្តិរួម ........................................ ១៦៩

ជំពូកទី២៖ កិច្ចសហប្រតិបត្តិជាសកល និងក្នុងតំបន់ ........................................ ១៧២

ជំពូកទី៣៖ ជំនួយបច្ចេកទេស ........................................ ១៧៥

ជំពូកទី៤៖ ការតាមដាន និងការវាយតម្លៃបរិស្ថាន........................................ ១៧៦

ជំពូកទី៥៖ វិធានអន្តរជាតិ និង នីតិកម្មជាតិដើម្បីបង្ការ ........................................ ១៧៨

ជំពូកទី៦៖ ការពង្រឹងច្បាប់ ........................................ ១៨៦

ជំពូកទី៧៖ ការការពារ........................................ ១៩៦

ជំពូកទី៨៖ តំបន់គ្របដណ្តប់ដោយទឹកកក........................................ ២០៤

ជំពូកទី៩៖ ការទទួលខុសត្រូវ និងបន្ទុក ........................................ ២០៤

ជំពូកទី១០៖ អភ័យឯកសិទ្ធិរបស់រដ្ឋមានអធិបតេយ្យភាព ........................................ ២០៥

ជំពូកទី១១៖ កាតព្វកិច្ចក្រោមអនុសញ្ញាផ្សេងទៀតស្តីពីការការពារនិងការថែរក្សាបរិស្ថានសមុទ្រ ...២០៦

ផ្នែកទី១៣៖ ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ........................................ ២០៧

ផ្នែកទី១៤៖ ការអភិវឌ្ឍ និង ការផ្ទេរបច្ចេកវិទ្យាសមុទ្រ ........................................២២៥

ជំពូកទី១៖ បទបញ្ញត្តិទូទៅ........................................២២៥

ជំពូកទី២៖ កិច្ចសហប្រតិបត្តិការអន្តរជាតិ ........................................២២៩

ជំពូកទី៣៖ មជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសមុទ្រថ្នាក់ជាតិ និងថ្នាក់តំបន់........................................២៣១

ជំពូកទី៤៖ កិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការអន្តរជាតិ.......................................... ២៣៣

ផ្នែកទី១៥៖ ការដោះស្រាយវិវាទ ........................................................................ ២៣៤

ជំពូកទី១៖ បទបញ្ញត្តិទូទៅ........................................................................... ២៣៤

ជំពូកទី២៖ នីតិវិធីច្បាប់ស្តីពីអានុភាពនៃសេចក្តីសម្រេច ........................................... ២៣៨

ជំពូកទី៣៖ ដែនអនុវត្តន៍ និងអញ្ញត្រកម្មនៃការអនុវត្តជំពូកទី ២ ..................................... ២៤៨

ផ្នែកទី១៦៖ បទបញ្ញត្តិទូទៅ ........................................................................... ២៥៦

ផ្នែកទី១៧៖ អវសានប្បញ្ញត្តិ ........................................................................... ២៥៩

ឧបសម្ព័ន្ធ១៖ ពូជត្រីដែលផ្លាស់ជម្រកតាមរដូវកាលខ្លាំង............................................ ២៧៣

ឧបសម្ព័ន្ធ២៖ គណៈកម្មការកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្រ ................................. ២៧៤

ឧបសម្ព័ន្ធ៣៖ លក្ខខណ្ឌមូលដ្ឋាននៃការធ្វើបុរេសនា ការរុករក  និងការធ្វើអាជីវកម្មធនធានរ៉ែ........... ២៧៥

ឧបសម្ព័ន៤៖លក្ខន្តិកៈរបស់សហគ្រាស ........................................................... ៣១៩

ឧបសម្ព័ន្ធ៥៖ ការផ្សះផ្សា ........................................................................... ៣៣៦

ជំពូកទី១៖ នីតិវិធីផ្សះផ្សាអនុលោមតាមជំពូកទី ១ នៃផ្នែកទី១៥.................................... ៣៣៦

ជំពូកទី២៖ លក្ខខណ្ឌត្រូវចូលរួមនីតិវិធីផ្សះផ្សា អនុលោមតាមជំពូកទី ៣ នៃផ្នែកទី ១៥ ............... ៣៤២

ឧបសម្ព័ន្ធ៦៖ លក្ខន្តិកៈក្រុមប្រឹក្សាជំនុំជម្រះអន្តរជាតិសម្រាប់ច្បាប់សមុទ្រ ...................................... ៣៤៥

ជំពូកទី១៖ ការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ........................................................ ៣៤៥

ជំពូកទី២៖ យុត្តាធិការ ................................................................................ ៣៥៥

ជំពូកទី៣៖ នីតិវិធី ..................................................................................... ៣៥៧

ជំពូកទី៤៖ សភាវិវាទបាតសមុទ្រ ......... ៣៦៤

ជំពូកទី៥៖ វិសោធនកម្ម ......... ៣៦៧

ឧបសម្ព័ន្ធ៧៖ មជ្ឈត្តកម្ម ......... ៣៦៨

ឧបសម្ព័ន្ធ៨៖ មជ្ឈត្តកម្មពិសេស ......... ៣៧៦

ឧបសម្ព័ន្ធ៩៖ ការចូលរួមរបស់អង្គការអន្តរជាតិ ......... ៣៨២

រដ្ឋទាំងឡាយដែលជាភាគីនៃអនុសញ្ញានេះ

ដោយចេតនាចង់ដោះស្រាយរាល់បញ្ហាទាំងអស់ដែលពាក់ព័ន្ធដល់ច្បាប់សមុទ្រប្រកបដោយស្មារតីនៃការយោគយល់ និងសហការគ្នាទៅវិញទៅមក និងការយល់ដឹងអំពីសារៈសំខាន់ជាប្រវត្តិសាស្ត្រនៃអនុសញ្ញានេះ ដែលជាការរួមចំណែកដ៏សំខាន់មួយក្នុងការរក្សានូវសន្តិភាព យុត្តិធម៌ និងវឌ្ឍនធម៌ទុកសំរាប់ប្រជាជាតិទាំងអស់នៃពិភពលោក

ដោយសំគាល់ឃើញថា ការអភិវឌ្ឍចាប់តាំងពីសន្និសញ្ញានៃអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រដែលរៀបចំឡើងនៅទីក្រុងហ្សឺណែវ ក្នុងឆ្នាំ ១៩៥៨ និង១៩៦០ បានគូសបញ្ជាក់ពីសេចក្តីត្រូវការនូវអនុញ្ញាស្តីពីច្បាប់សមុទ្រថ្មីមួយ និងអាចទទួលយកបានជាទូទៅ

ដោយយល់ឃើញថា បញ្ហាមហាសមុទ្រជាបញ្ហា ដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតទៅវិញទៅមក និងចាំបាច់ត្រូវចាត់ទុកជាបញ្ហាសកលមួយ

ដោយទទួលស្គាល់នូវសេចក្តីប៉ងប្រាថ្នានៃការបង្កើតឡើងនូវរបៀបរបបច្បាប់សមុទ្រ និងមហាសមុទ្រតាមរយអនុសញ្ញានេះជាមួយនឹងការគោរពដល់បញ្ហាអធិបតេយ្យភាពនៃរដ្ឋទាំងអស់ ដែលនឹងសំរួលដល់ទំនាក់ទំនងអន្តរជាតិ និងជំរុញការប្រើប្រាស់សមុទ្រ និងមហាសមុទ្រប្រកបដោយសន្តិភាព ការប្រើប្រាស់សមភាព និងប្រសិទ្ធិភាពនូវធនធានសមុទ្រ ការអភិរក្សធនធានមានជីវិត និងការសិក្សា ការការពារ និងការអភិរក្សនូវបរិស្ថានសមុទ្រ

ដោយចងចាំថាសមិទ្ធិផលនៃគោលបំណងទាំងនេះនឹងរួមចំណែកដល់សមិទ្ធិកម្មនៃរបៀបរបបសេដ្ឋកិច្ចអន្តរជាតិប្រកបចដោយយុត្តិធម៌ និងសមធម៌ ដែលនឹងគិតគូរដល់ផលប្រយោជន៍ និងសេចក្តីត្រូវការនៃប្រទេសកំពុងអភិវឌ្ឍន៍ មិនថាជាប្រទេសជាប់សមុទ្រ ឬក៏អត់

ដោយបំណងអនុសញ្ញានេះចង់អភិវឌ្ឍនូវគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងសេចក្តីសំរេចលេខ ២៧៤៩(XXV) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧០ ដែលក្នុងនោះមានមហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាសចជាឧឡារិកថា តំបន់បាតសមុទ្រ និងផ្ទៃបាតសមុទ្រ និងស្រទាប់ដីក្រោមសមុទ្រ ដែនមិនស្ថិតនៅក្រោមដែនកំណត់នៃយុត្តិការជាតិ ព្រមទាំងធនធានសមុទ្រ គឺមរត៌កមនុស្ស

ជាតិរួម ការរុករក និងការធ្វើអាជីវកម្មគួរត្រូវធ្វើឡើងសំរាប់ផលប្រយោជន៍មនុស្សជាតិទាំងមូល ដោយមិនគិតពីទីតាំងភូមិសាស្ត្រនៃរដ្ឋ

ដោយជឿជាក់ថា ការចងជាក្រម និងការអភិវឌ្ឍជាលំដាប់នៃច្បាប់សមុទ្រដែលបានសំរេចក្នុងអនុសញ្ញានេះនឹងរួមចំណែកដល់ការពង្រឹងសន្តិភាព សន្តិសុខ កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងមិត្តភាពរវាងរដ្ឋទាំងអស់ ដោយអនុលោមតាមគោលការណ៍យុត្តិធម៌ និងសិទ្ធិស្មើគ្នា និងជំរុញនូវភាពជឿនលឿនផ្នែកសេដ្ឋកិច្ច និងសង្គមនៃប្រជាជាតិទាំងអស់ក្នុងពិភពលោក ដោយអនុលោមតាមគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ

ដោយអះអាងថា រាល់បញ្ហាទាំងឡាយដែលមិនបានសបញ្ញត្តិដោយអនុសញ្ញានេះនឹងបន្តគ្រប់គ្រងដោយវិធាន និងគោលការណ៍នៃនីតិអន្តរជាតិទូទៅ

បានព្រមព្រៀងគ្នាដូចខាងក្រោមៈ

## ផ្នែកទី១៖ សេចក្តីផ្តើម

## មាត្រា១៖ ការប្រើប្រាស់វាក្យស័ព្ទ និងវិសាលភាព

១. សម្រាប់គោលបំណងនៃអនុសញ្ញានេះ៖

(១)"តំបន់" មានន័យថា បាតសមុទ្រ និងផ្ទៃបាតសមុទ្រ និងដីស្រទាប់ក្រោមសមុទ្រ ដែលហួសពីយុត្តាធិការលើផ្ទៃប្រទេស។

(២) "អាជ្ញាធរ" មានន័យថា អាជ្ញាធរបាតសមុទ្រអន្តរជាតិ។

(៣) "សកម្មភាពក្នុងតំបន់" មានន័យថា រាល់សកម្មភាពរុករកធនធានក្នុងតំបន់។

(៤) "ការបំពុលបរិស្ថានសមុទ្រ" មានន័យថា ការបញ្ចេញសារធាតុ ឬថាមពលដោយមនុស្សដោយផ្ទាល់ ឬប្រយោលទៅក្នុងបរិស្ថានសមុទ្រ រាប់ទាំងដៃសមុទ្រដែលបណ្តាល ឬអាចបណ្តាលឲ្យមានផលបំផ្លិចបំផ្លាញ ដូចជាគ្រោះថ្នាក់ដល់ធនធានមានជីវិត និងសត្វសមុទ្រ គ្រោះថ្នាក់ដល់សុខភាពមនុស្ស ផលរំខានដល់សកម្មភាពនៅសមុទ្រ ដែលរួមមានការនេសាទនិងការប្រើប្រាស់សមុទ្រស្របច្បាប់ដទៃទៀត ការធ្វើឲ្យការប្រើប្រាស់ទឹកសមុទ្របាត់បង់គុណភាព និងធ្វើឲ្យសោភណភាពសមុទ្រ ថយចុះ។

(៥) (ក) "ការបោះចោលសំណល់" មានន័យថា៖

(i) ការបោះចោលកាកសំណល់ ឬវត្ថុដទៃទៀតដោយចេតនាពីនាវា យន្តហោះ ទីតាំងបូមប្រេង ឬសំណង់ដែលមនុស្សបង្កើតឡើងដទៃទៀតនៅសមុទ្រ។

(ii) ការបោះចោលនាវា យន្តហោះ ទីតាំងបូមប្រេង ឬសំណង់ដែលមនុស្សបង្កើតឡើងដទៃទៀតនៅសមុទ្រ ដោយចេតនា។

(ខ) "ការបោះចោលសំណល់" មិនរាប់បញ្ចូល៖

(i) ការបោះចោលកាកសំណល់ ឬវត្ថុធាតុដទៃទៀតដោយសារតែ ឬកើតចេញពីប្រតិបត្តិការជាធម្មតាររបស់នាវា យន្តហោះ ទីតាំងបូមប្រេង ឬសំណង់ដែលមនុស្សបង្កើតឡើងដទៃទៀតនៅសមុទ្រ និងគ្រឿងបរិក្ខារបស់នាវា យន្តហោះ ទីតាំងបូមប្រេង ឬសំណង់ដែលមនុស្សបង្កើតឡើងដទៃទៀតដោយអចេតនា លើកលែងកាកសំណល់ ឬវត្ថុធាតុដទៃទៀតដែលដឹកជញ្ជូនដោយ ឬទៅកាន់នាវា យន្តហោះ ទីតាំងបូមប្រេង ឬ សំណង់ដែលមនុស្សបង្កើតឡើងដទៃទៀតនៅ

សមុទ្រដែលធ្វើប្រតិបត្តិការបោះចោលវត្ថុធាតុនោះ ឬនៅក្នុងប្រតិបត្តិការ សម្អាតកាកសំណល់ ឬវត្ថុធាតុដទៃទៀត នៅលើនាវា យន្តហោះ ទីតាំងបូមប្រេង ឬសំណង់ដែលមនុស្សបង្កើតឡើងដទៃទៀត។

(ii) ការទុកដាក់វត្ថុធាតុក្នុងគោលបំណងណាមួយ ក្រៅពីគោលបំណងបោះចោល ក្នុងករណីដែលការទុកដាក់នោះមិនផ្ទុយនឹងអនុសញ្ញាតនេះ។

២. (១) "រដ្ឋភាគី" មានន័យថា ជារដ្ឋ ដែលបានយល់ព្រមចងកាតព្វកិច្ចក្រោមអនុសញ្ញានេះ ហើយដែលអនុសញ្ញានេះចូលជាធរមានសម្រាប់រដ្ឋនោះ។

(២) អនុសញ្ញា រួមបញ្ចូលទាំងច្បាប់វិសោធនកម្ម អនុវត្តលើគ្រប់អង្គភាពដូចមានចែងក្នុងមាត្រា ៣០៥ កឋាខណ្ឌ ថ (ក) (ខ) (គ) (ឃ) និង (ង) ដែលជាភាគីនៃអនុសញ្ញានេះ អនុលោមតាមលក្ខខណ្ឌពាក់ព័ន្ធនឹងអង្គភាពនីមួយៗ និងក្នុងកម្រិតដែល "រដ្ឋភាគី" សំដៅលើអង្គភាពទាំងនោះ។

## ផ្នែកទី២៖ ព្រំដែនសមុទ្រ និងតំបន់ត្រួត

### ជំពូកទី១៖ បញ្ញាត្តិទូទៅ

មាត្រា ២

ស្ថានភាពគតិយុត្តិនៃដែនសមុទ្រ លំហរអាកាស

លើដែនសមុទ្រ និងដីស្រទាប់ក្រោមសមុទ្រ

១. អធិបតេយ្យភាពរដ្ឋជាប់ឆ្នេរសមុទ្រត្រូវលាតសន្ធឹងពីដីគោក និងដែនទឹកខាងក្នុងរបស់រដ្ឋ ហើយក្នុងករណីជារដ្ឋប្រជុំកោះ ត្រូវលាតសន្ធឹងហួសពីផ្ទៃទឹកប្រជុំកោះរបស់រដ្ឋ រហូតដល់ខ្សែក្រវាត់សមុទ្រជាប់គ្នា ដែលហៅថាដែនសមុទ្រ។

២. អធិបតេយ្យភាពនេះលាតសន្ធឹងដល់លំហរអាកាសលើដែនសមុទ្រ ក៏ដូចជាបាត និងដីស្រទាប់ក្រោមសមុទ្រផងដែរ។

៣. អធិបតេយ្យភាពដែនសមុទ្រត្រូវអនុវត្ត អនុលោមតាមអនុសញ្ញានេះ និងវិធានដទៃទៀតនៃច្បាប់អន្តរជាតិ ។

### ជំពូកទី២៖ ព្រំប្រទល់ដែនសមុទ្រ

មាត្រា ៣

ប្រវែងនៃដែនសមុទ្រ

រាល់រដ្ឋទាំងអស់មានសិទ្ធិបង្កើតប្រវែងនៃដែនសមុទ្ររបស់ខ្លួន រហូតដល់ដែនកំណត់ដែលមិនលើសពីចម្ងាយ ១២ ម៉ាយល៍ (nautical mile) ដែលវាស់ពីខ្សែបន្ទាត់មូលដ្ឋានដែលកំណត់អនុលោមតាមអនុសញ្ញានេះ។

មាត្រា ៤

ព្រំប្រទល់ខាងក្រៅនៃដែនសមុទ្រ

ព្រំប្រទល់ខាងក្រៅនៃដែនសមុទ្រគឺជាខ្សែបន្ទាត់ ដែលរាល់ចំណុចលើខ្សែបន្ទាត់នោះស្ថិតក្នុងចម្ងាយពីចំណុចជិតបំផុតនៃខ្សែបន្ទាត់មូលដ្ឋាន ដែលស្មើនឹងប្រវែងនៃដែនសមុទ្រ។

មាត្រា ៥

ខ្សែបន្ទាត់មូលដ្ឋានធម្មតា

លើកលែងតែមានចែងផ្ទុយក្នុងអនុសញ្ញានេះ ខ្សែបន្ទាត់មូលដ្ឋានធម្មតាសម្រាប់វាស់ប្រវែងនៃដែនសមុទ្រ គឺខ្សែបន្ទាត់ទឹករាក់ នៅតាមបណ្តោយឆ្នេរសមុទ្រ ដូចដែលមានគូសនៅលើផែនទីសមុទ្រ ខ្នាតធំ ដែលបានទទួលស្គាល់ផ្លូវការដោយរដ្ឋជាប់ឆ្នេរសមុទ្រ។

មាត្រា ៦

ថ្មប៉ប្រះទឹក

ក្នុងករណីកោះស្ថិតលើកោះផ្កាថ្ម ឬកោះដែលមានថ្មប៉ប្រះទឹកនៅជាយ ខ្សែបន្ទាត់មូលដ្ឋានសម្រាប់វាស់ប្រវែងដែនសមុទ្រ គឺខ្សែបន្ទាត់ថ្មប៉ប្រះទឹករាក់បែរទៅសមុទ្រ ដូចដែលបង្ហាញដោយសញ្ញាសមស្រប នៅលើផែនទីដែលបានទទួលស្គាល់ជាផ្លូវការ ដោយរដ្ឋជាប់ឆ្នេរ។

មាត្រា ៧

ខ្សែបន្ទាត់មូលដ្ឋានត្រង់ស្មើ

១. នៅកន្លែងដែលខ្សែបន្ទាត់ឆ្នេរសមុទ្រចូលជ្រៅ និងស៊ីចូលក្នុង ឬប្រសិនបើមានជាយកោះនៅតាមឆ្នេរសមុទ្រ ក្នុងតំបន់ជិតខាង អាចប្រើប្រាស់វិធីខ្សែបន្ទាត់មូលដ្ឋានត្រង់ស្មើ ដែលតភ្ជាប់ចំណុចសមស្របនានា ដើម្បីគូសខ្សែបន្ទាត់មូលដ្ឋានដើម្បីវាស់ប្រវែងដែនសមុទ្រ។

២. ក្នុងករណីដីសណ្តរ និងស្ថានភាពធម្មជាតិដទៃទៀត ខ្សែបន្ទាត់ឆ្នេរសមុទ្រមានលក្ខណៈលំអៀងខ្លាំង ចំណុចសមស្របអាចត្រូវបានជ្រើសយក តាមចំណុចឆ្ងាយបំផុតទៅសមុទ្រនៃខ្សែបន្ទាត់ទឹករាក់ និងបើទោះបីជាខ្សែបន្ទាត់ទឹករាក់ថយមកកន្លែងដើមវិញក៏ដោយ ប៉ុន្តែខ្សែបន្ទាត់ត្រង់ស្មើនៅតែមានប្រសិទ្ធិភាព រហូតទាល់តែផ្លាស់ប្តូរដោយរដ្ឋជាប់ឆ្នេរសមុទ្រ អនុលោមតាមអនុសញ្ញានេះ។

៣.  ការគូសខ្សែបន្ទាត់មូលដ្ឋានត្រង់ស្មើមិនត្រូវងាកទៅចំណុចណាមួយដែលអាចមើលឃើញពីទិសដៅទូទៅនៃឆ្នេរសមុទ្រ ហើយតំបន់សមុទ្រដែលស្ថិតក្នុងខ្សែបន្ទាត់ ត្រូវតភ្ជាប់គ្នាជិតល្មមទៅនឹងដីគោក ដើម្បីស្ថិតក្រោមរបបដែនទឹកខាងក្នុង។

៤. ខ្សែបន្ទាត់មូលដ្ឋានត្រង់ស្មើមិនត្រូវគូសគិតតាមកម្ពស់លំនាច ប្រសិនបើគ្មានសើនបញ្ចាំងភ្លើង ឬសំណង់មានលក្ខណៈស្រដៀងគ្នានៅពីលើកម្ពស់ទឹកសមុទ្រជានិច្ច ត្រូវបានសាងសង់ឡើងលើកម្ពស់លំនាចនោះទេ ឬលើកលែងតែចម្ងាយពីការគូសខ្សែបន្ទាត់មូលដ្ឋាននោះគិតតាមកម្ពស់លំនាចនោះត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។

៥. នៅពេលវិធីសាស្ត្រខ្សែបន្ទាត់មូលដ្ឋានត្រង់ស្មើត្រូវយកមកអនុវត្ត តាមកឋាខណ្ឌ ១ ក្នុងការកំណត់ខ្សែបន្ទាត់មូលដ្ឋានណាមួយ អាចត្រូវពិចារណាលើផលប្រយោជន៍សេដ្ឋកិច្ចដែលពិសេសចំពោះភូមិភាគពាក់ព័ន្ធ ការពិត និងសារៈសំខាន់ ដែលបានបញ្ជាក់យ៉ាងច្បាស់ដោយសារការប្រើប្រាស់ជាយូរមកហើយ។

៦. ប្រព័ន្ធនៃខ្សែបន្ទាត់មូលដ្ឋានត្រង់ស្មើមិនអាចយកមកអនុវត្តដោយរដ្ឋណាមួយ ក្នុងរបៀបណាមួយដើម្បីកាត់ចែកដែនសមុទ្ររបស់រដ្ឋមួយទៀតពីតំបន់សមុទ្រគ្មានការគ្រប់គ្រងដោយរដ្ឋណា មួយ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខទេ។

## មាត្រា ៨
## ដែនផ្ទៃទឹកខាងក្នុង

១. លើកលែងតែមានចែងក្នុងភាគទី ៤ ផ្ទៃទឹកទៅខាងដីគោកនៃខ្សែបន្ទាត់មូលដ្ឋាននៃបូរណភាពសមុទ្រគឺជាផ្នែកនៃដែនទឹកខាងក្នុងរបស់រដ្ឋ។

២. នៅពេលការកំណត់ខ្សែបន្ទាត់មូលដ្ឋានត្រង់ស្មើ អនុលោមតាមវិធីសាស្ត្រដែលចែងក្នុងមាត្រា ៧ ត្រូវមានអនុភាពដាក់បញ្ចូលតំបន់ដែនទឹកខាងក្នុង ដែលពីមុនមិនត្រូវបានចាត់ទុកបែបនេះ សិទ្ធិឆ្លងកាត់ដោយគ្មានចេតនាអាក្រក់ ដែលចែងក្នុងអនុសញ្ញានេះ នៅតែមានអត្ថិភាពក្នុងដែនទឹកនោះ។

មាត្រា ៩
មាត់ទន្លេ

ប្រសិនបើទន្លេមួយហូរទៅសមុទ្រផ្ទាល់ ខ្សែបន្ទាត់មូលដ្ឋានត្រូវជាខ្សែបន្ទាត់ត្រង់ស្មើកាត់មាត់ទន្លេរវាងចំណុចនានាលើខ្សែបន្ទាត់ទឹករាក់នៃច្រាំងទន្លេ។

មាត្រា ១០
ឆកសមុទ្រ

១. មាត្រានេះទាក់ទងតែឆកសមុទ្រ ដែលឆ្នេរនៃឆកសមុទ្រនេះជារបស់រដ្ឋតែមួយគត់។

២. ក្នុងគោលបំណងនៃអនុសញ្ញានេះ ឆកសមុទ្រ គឺជាផ្នែករឆេងរឆូងដែលកំណត់ច្បាស់ ដែលចូលទៅដីគោក ដែលមានទំហំស្មើនឹងទទឹងនៃមាត់ឆកសមុទ្រ ដើម្បីបង្កើតជាផ្ទៃទឹកមានដីគោកព័ទ្ធ និងបង្កើតជាកំណោងនៃឆ្នេរសមុទ្រ។ ប៉ុន្តែ ផ្នែករឆេងរឆូងមិនត្រូវចាត់ទុកជាឆកសមុទ្រទេ ប្រសិនបើផ្ទៃរបស់វាមិនធំស្មើ ឬធំជាងពាក់កណ្តាលរង្វង់ដែលមានអង្កត់ផ្ចិតជាខ្សែបន្ទាត់គូសកាត់មាត់នៃផ្នែករឆេងរឆូងនោះទេ។

៣. ក្នុងគោលបំណងវាស់វែង ផ្ទៃនៃផ្នែករឆេងរឆូងគឺស្ថិតក្នុងរវាងចំណុចទឹករាក់ជុំវិញច្រាំងនៃផ្នែករឆេងរឆូងនោះ និងខ្សែបន្ទាត់តភ្ជាប់ចំណុចទឹករាក់នៃច្រកចូលធម្មជាតិរបស់វា។ ដោយសារមានកោះ បើផ្នែករឆេងរឆូងមានមាត់ច្រើន ពាក់កណ្តាលរង្វង់ត្រូវគូសលើខ្សែបន្ទាត់ ដែលវែងស្មើនឹងប្រវែងសរុបនៃខ្សែបន្ទាត់កាត់មាត់ផ្សេងៗគ្នា។ កោះក្នុងផ្នែករឆេងរឆូងត្រូវរាប់បញ្ចូល ហាក់ដូចជាកោះនោះជាផ្នែកនៃផ្ទៃក្នុងនៃផ្នែករឆេងរឆូងដែរ។

៤. ប្រសិនបើចម្ងាយរវាងចំណុចទឹករាក់នៃច្រកចូលធម្មជាតិរបស់ឆកសមុទ្រមិនលើសពី ២៤ ម៉ាយល៍ទេនោះ ខ្សែបន្ទាត់បិទអាចគូសរវាងចំណុចទឹករាក់ពីរហើយផ្ទៃទឹកហ៊ុំព័ទ្ធដែលព័ទ្ធបញ្ចូលត្រូវចាត់ទុកជាដែនទឹកខាងក្នុង។

៥. នៅពេលចម្ងាយរវាងចំណុចទឹករាក់នៃច្រកចូលធម្មជាតិលើសពី ២៤ ម៉ាយល៍ ខ្សែបន្ទាត់មូលដ្ឋានត្រង់ស្មើដែលមានប្រវែង ២៤ ម៉ាយល៍ត្រូវគូសក្នុងឆកសមុទ្រ ក្នុងរបៀបយ៉ាងណាដើម្បីព័ទ្ធបញ្ចូលផ្ទៃទឹកអតិបរមា ដែលអាចធ្វើទៅបានជាមួយនឹងប្រវែងខ្សែបន្ទាត់នោះ។

៦. បញ្ញាត្តិទាំងឡាយខាងលើមិនត្រូវអនុវត្តចំពោះឆកសមុទ្រ "ជាប្រវត្តិសាស្ត្រ" ទេ ឬក្នុង ករណីដែលប្រព័ន្ធខ្សែបន្ទាត់ត្រង់ស្មើដែលមានចែងក្នុងមាត្រា ៧ ត្រូវបានយកមកអនុវត្ត។

មាត្រា ១១

កំពង់ផែ

ក្នុងគោលបំណងកំណត់ព្រំដែនបូរណភាពសមុទ្រ សំណង់កំពង់ផែអចិន្ត្រៃយ៍ផ្នែកក្រៅបំផុតដែលជាផ្នែកសំខាន់នៃប្រព័ន្ធកំពង់ផែ ត្រូវចាត់ទុកជាផ្នែកនៃឆ្នេរសមុទ្រ។ រចនាសម្ព័ន្ធនៅឆ្ងាយពីច្រាំងសមុទ្រ និងកោះសិប្បនិម្មិត មិនត្រូវចាត់ទុកជាសំណង់កំពង់ផែអចិន្ត្រៃយ៍ទេ។

មាត្រា ១២

ចំណតនាវា

ចំណតនាវា ដែលជាធម្មតាត្រូវបានប្រើប្រាស់សម្រាប់លើកដាក់ លើកចុះ និងចតនាវា ហើយដែលផ្នែកទាំងមូល ឬផ្នែកណាមួយនៃចំណតនាវាអាចស្ថិតនៅព្រំប្រទល់ខាងក្រៅនៃដែនសមុទ្រ ត្រូវបានរាប់ថានៅក្នុងដែនសមុទ្រ។

មាត្រា ១៣

កម្ពស់លំនាច

១. កម្ពស់លំនាចជាផ្ទៃដីដែលកកើតដោយធម្មជាតិ ដែលហ៊ុំព័ទ្ធដោយ និងផុសពីទឹកនៅពេលលំនាច ប៉ុន្តែលិចនៅពេលជំនោរ។ នៅពេលផ្នែកទាំងមូល ឬផ្នែកណាមួយនៃកម្ពស់លំនាចស្ថិតនៅចម្ងាយមិនលើសពីប្រវែងទទឹងនៃបូរណភាពសមុទ្រពីដីគោក ឬកោះ ខ្សែបន្ទាត់ទឹករាក់ នៅលើកម្ពស់លំនាចនោះ អាចយកមកប្រើប្រាស់ជាខ្សែបន្ទាត់មូលដ្ឋានដើម្បីវាស់ប្រវែងដែនសមុទ្រ។

២. នៅពេលផ្នែកទាំងមូលនៃកម្ពស់លំនាចស្ថិតនៅចម្ងាយដែលវែងជាងប្រវែងដែនសមុទ្រគិតពីដីគោក ឬកោះមួយ កម្ពស់លំនាចគ្មានបូរណភាពសមុទ្រទេ។

មាត្រា ១៤

ការបញ្ចូលវិធីសាស្ត្រកំណត់ខ្សែបន្ទាត់មូលដ្ឋាន

រដ្ឋជាប់ឆ្នេរសមុទ្រអាចកំណត់ខ្សែបន្ទាត់មូលដ្ឋាន ដោយវិធីសាស្ត្រណាមួយ ដែលមានចែងក្នុងមាត្រាខាងលើ ដើម្បីបំពេញតាមលក្ខខណ្ឌផ្សេងៗ។

មាត្រា ១៥

ការកំណត់ព្រំដែនបូរណភាពសមុទ្ររវាងរដ្ឋ
ដែលមានឆ្នេរសមុទ្រទល់មុខគ្នា ឬជាប់គ្នា

នៅពេលឆ្នេរសមុទ្រប្រទេសពីរទល់មុខគ្នា ឬជាប់គ្នា បើគ្មានការព្រមព្រៀងផ្ទុយរវាងរដ្ឋទាំងពីរនោះទេ គ្មានរដ្ឋណាមួយក្នុងចំណោមរដ្ឋទាំងពីរត្រូវមានសិទ្ធិពង្រីកបូរណភាពសមុទ្រឲ្យហួសពីចំណុចកណ្តាលដែលមានចម្ងាយស្មើគ្នារវាងចំណុចជិតបំផុតលើខ្សែបន្ទាត់មូលដ្ឋាន ដែលប្រើប្រាស់ដើម្បីវាស់ប្រវែងដែនសមុទ្រនៃរដ្ឋនីមួយៗក្នុងចំណោមរដ្ឋទាំងពីរ។ ប៉ុន្តែ បញ្ញាតិខាងលើមិនត្រូវយកមក អនុវត្តទេក្នុងករណីដោយមូលហេតុកម្មសិទ្ធិជាប្រវត្តិសាស្ត្រ ឬកាលៈទេសៈពិសេសដទៃទៀត ត្រូវកំណត់ព្រំដែនបូរណភាពសមុទ្ររបស់រដ្ឋទាំងពីរ ក្នុងរបៀបដែលផ្ទុយនឹងបញ្ញាត្តិនេះ។

មាត្រា ១៦

ផែនទី និងចំណុចនិយាមកាភូមិសាស្ត្រ

១. ខ្សែបន្ទាត់មូលដ្ឋានសម្រាប់វាស់ប្រវែងដែនសមុទ្រ ដែលបានកំណត់ក្នុងមាត្រា ៧ ៩ និង ១០ ឬដែនកំណត់ដែលបានពីការវាស់នោះ និងខ្សែបន្ទាត់ព្រំដែនដែលគូសអនុលោម តាមមាត្រា ១២ និង ១៥ ត្រូវបង្ហាញលើផែនទីដែលមានមាត្រដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ទីតាំងវា។ ឬ បញ្ជីនិយាមការភូមិសាស្ត្រនៃចំណុចនានា ដែលបញ្ជាក់ទិន្នន័យនៃការវាស់វែងផែនដី អាចយកមកប្រើប្រាស់ជំនួសបាន។

២. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវធ្វើការផ្សព្វផ្សាយផែនទីឬបញ្ជីនិយាមការភូមិសាស្ត្រឲ្យបានត្រឹមត្រូវ ហើយត្រូវដាក់តម្កល់ផែនទី ឬបញ្ជីនោះមួយច្បាប់នៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

ជំពូកទី៣៖ ការឆ្លងកាត់ដោយគ្មានចេតនាអាក្រក់ក្នុងបូរណភាពដែនសមុទ្រ

ជំពូករងក៖ វិធានអនុវត្តចំពោះនាវាគ្រប់ប្រភេទ

មាត្រា ១៧

សិទ្ធិឆ្លងកាត់ដោយគ្មានចេតនាអាក្រក់

ដោយអនុលោមតាមអនុសញ្ញានេះ នាវារបស់រដ្ឋទាំងអស់ ទោះរដ្ឋជាប់ឆ្នេរសមុទ្រ ឬរដ្ឋដីគោក ត្រូវទទួលបានសិទ្ធិឆ្លងកាត់ដែនសមុទ្រដោយគ្មានចេតនាអាក្រក់ ។

មាត្រា ១៨

អត្ថន័យនៃការឆ្លងកាត់

១. ការឆ្លងកាត់មានន័យថា ការធ្វើនាវាចរណ៍ឆ្លងកាត់ដែនសមុទ្រ ក្នុងគោលបំណង៖

(ក) ឆ្លងកាត់សមុទ្រនោះ ដោយមិនចូលដែនទឹកខាងក្នុង ឬការចតនៅចំណតនាវា ឬ កំពង់ផែ នៅខាងក្រៅផ្ទៃទឹកក្នុង។ ឬ

(ខ) បន្តចូលក្នុង ឬចេញពីដែនទឹកខាងក្នុង ឬការចតនៅចំណតនាវា ឬកំពង់ផែ។

២. ការឆ្លងកាត់ត្រូវបន្តឥតឈប់ និងឆាប់រហ័ស។ ប៉ុន្តែការឆ្លងកាត់ក៏រាប់បញ្ចូលការឈប់ និងសំចតផងដែរ ប៉ុន្តែដរាបណាការឈប់ និងសំចតនោះគឺជាសកម្មភាពបន្ទាប់បន្សំចំពោះការធ្វើនាវាចរណ៍ធម្មតា ឬចាត់ទុកថាចាំបាច់ ដោយសារករណីប្រធានសក្តិ ឬបញ្ហា ឬក្នុងគោលបំណងសង្គ្រោះមនុស្ស នាវា ឬយន្តហោះដែលស្ថិតក្នុងគ្រោះថ្នាក់ ឬមានបញ្ហា។

មាត្រា ១៩

អត្ថន័យនៃការឆ្លងកាត់ដោយគ្មានចេតនាអាក្រក់

១. ការឆ្លងកាត់គឺគ្មានចេតនាអាក្រក់ ដរាបណាវាមិនប៉ះពាល់ដល់សន្តិភាព សណ្តាប់ល្អ ឬសន្តិសុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រនោះទេ។ ការឆ្លងកាត់នោះត្រូវធ្វើឡើងអនុលោមតាមអនុសញ្ញានេះ និងវិធានដទៃទៀតនៃច្បាប់អន្តរជាតិ។

២. ការឆ្លងកាត់របស់នាវាបរទេសត្រូវចាត់ទុកថាប៉ះពាល់ដល់សន្តិភាព សណ្តាប់ធ្នាប់ល្អ ឬ សន្តិសុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ប្រសិនបើក្នុងដែនសមុទ្រ នាវាបរទេសនោះធ្វើសកម្មភាព ដូចខាងក្រោម៖

(ក) គំរាមកំហែង ឬប្រើប្រាស់កម្លាំងប្រឆាំងនឹងអធិបតេយ្យភាព បូរណភាពទឹកដី ឬ ឯករាជភាពនយោបាយរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ឬរបៀបផ្សេងទៀតដែលរំលោភគោលការណ៍ច្បាប់អន្តរជាតិ ដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ។

(ខ) ការធ្វើសមយុទ្ធ ឬហ្វឹកហាត់ដោយប្រើប្រាស់អាវុធប្រភេទណាក៏ដោយ។

(គ) សកម្មភាពណាមួយ ដែលមានគោលបំណងប្រមូលព័ត៌មានដែលប៉ះពាល់ដល់វិស័យការពារជាតិ ឬសន្តិសុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ឃ) សកម្មភាពឃោសនាដែលមានចេតនាធ្វើឲ្យប៉ះពាល់ដល់វិស័យការពារជាតិ ឬសន្តិសុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ង) ការបង្ហោះ ចុះចត ឬទទួលយន្តហោះ។

(ច) ការបង្ហោះ ចុះចត ឬទទួលឧបករណ៍យោធា។

(ឆ) ការផ្ទុក ឬលើកចុះទំនិញ រូបិយវត្ថុខុសច្បាប់ ឬជនល្មើសច្បាប់ និងបទបញ្ញត្តិផ្នែកគយ សារពើពន្ធ អន្តោប្រវេសន៍ ឬសុខាភិបាល របស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ជ) អំពើបំពុលធ្ងន់ធ្ងរ និងដោយចេតនា ដែលផ្ទុយនឹងអនុសញ្ញានេះ។

(ឈ) សកម្មភាពនេសាទ។

(ញ) ការធ្វើសកម្មភាពស្រាវជ្រាវ ឬអង្កេត។

(ដ) សកម្មភាពដែលមានគោលបំណងជ្រៀតជ្រែកប្រព័ន្ធទំនាក់ទំនង ឬអគារ ឬមូលដ្ឋានយោធាដទៃទៀតរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ឋ) សកម្មភាពដទៃទៀតដែលគ្មានទំនាក់ទំនងផ្ទាល់នឹងការឆ្លងកាត់។

មាត្រា ២០

នាវាមុជទឹក និងយានក្រោមទឹកដទៃទៀត

ក្នុងដែនសមុទ្រ នាវាមុជទឹក និងយានក្រោមទឹកដទៃទៀត ត្រូវធ្វើនាវាចរណ៍នៅលើផ្ទៃទឹក និងបង្ហាញទង់ជាតិរបស់ខ្លួន។

មាត្រា ២១

ច្បាប់ និងបទបញ្ញាតិរបស់រដ្ឋជាប់ឆ្នេរសមុទ្រទាក់ទងនឹងការឆ្លងកាត់ដោយគ្មានចេតនាអាក្រក់

១. រដ្ឋជាប់ឆ្នេរសមុទ្រអាចអនុម័តច្បាប់ និងបទបញ្ញាត្តិ អនុលោមតាមបញ្ញាត្តិនៃអនុសញ្ញានេះ និងវិធានដទៃទៀតនៃច្បាប់អន្តរជាតិ ទាក់ទងនឹងការឆ្លងកាត់ដែនសមុទ្រដោយគ្មានចេតនាអាក្រក់ ទាក់ទងនឹងចំណុចណាមួយ ឬទាំងអស់ ដូចខាងក្រោមៈ

(ក) សុវត្ថិភាពនៃការធ្វើនាវាចរណ៍ និងបទបញ្ញាត្តិធ្វើចរាចរណ៍លើផ្ទៃសមុទ្រ។

(ខ) ការការពារជំនួយឧបត្ថម្ភ និងមូលដ្ឋានសម្ភារនាវាចរណ៍ និង អាគារ ឬ បបនភណ្ឌដទៃទៀត។

(គ) ការការពារខ្សែកាប និងបំពង់បញ្ជូនប្រេង។

(ឃ) ការការអភិរក្សធនធានមានជីវិតក្នុងសមុទ្រ។

(ង) ការបង្ការការរំលោភបំពានលើច្បាប់ និងបទបញ្ញត្តិជលផលរបស់រដ្ឋជាប់ឆ្នេរ។

(ច) ការថែរក្សាបរិស្ថានរបស់រដ្ឋជាប់ឆ្នេរសមុទ្រ និងការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថាន។

(ឆ) ការស្រាវជ្រាវក្នុងសមុទ្រជាលក្ខណៈវិទ្យាសាស្ត្រ និងការអង្កេតបែបជលធារសាស្ត្រ។

(ជ) ការបង្ការការរំលោភបំពានលើច្បាប់ និងបទបញ្ញត្តិផ្នែកគយ សារពើពន្ធ អន្តោប្រវេសន៍ ឬសុខាភិបាលរបស់រដ្ឋជាប់ឆ្នេរ។

២.ច្បាប់ និងបទបញ្ញត្តិនោះមិនត្រូវអនុវត្តចំពោះប្លង់ ការសាងសង់ ការដាក់មនុស្សធ្វើការ ឬគ្រឿងបរិក្ខានៃនាវាបរទេសទេ ប្រសិនបើច្បាប់ និងបទបញ្ញត្តិនោះមិនផ្តល់ប្រសិទ្ធិភាពដល់វិធាន ឬស្តង់ដារដែលបានទទួលយកជាលក្ខណៈអន្តរជាតិ។

៣. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវធ្វើការផ្សព្វផ្សាយឲ្យបានសមស្របនូវរាល់ច្បាប់ និងបទបញ្ញត្តិទាំងអស់នោះ។

៤. នាវាបរទេស ដែលប្រើប្រាស់សិទ្ធិឆ្លងកាត់ដែនសមុទ្រដោយគ្មានបំណងអាក្រក់ ត្រូវគោរពតាមច្បាប់ និងបទបញ្ញត្តិទាំងអស់នោះ និងបទបញ្ញត្តិទាំងអស់ដែលត្រូវបានទទួលយកជាលក្ខណៈអន្តរជាតិទាក់ទងនឹងការបង្ការការប៉ះទង្គិចគ្នានៅសមុទ្រ។

មាត្រា ២២

ផ្លូវសមុទ្រ និងគម្រោងបែងចែកចរាចរណ៍ក្នុងដែនសមុទ្រ

១. ប្រសិនបើចាំបាច់ទាក់ទងនឹងសុវត្ថិភាពធ្វើនាវាចរណ៍ រដ្ឋជាប់ឆ្នេរសមុទ្រអាចតម្រូវឲ្យនាវាបរទេស ដែលប្រើប្រាស់សិទ្ធិឆ្លងកាត់ដែនសមុទ្រដោយគ្មានបំណងអាក្រក់ ប្រើប្រាស់ផ្លូវសមុទ្រ និងគម្រោងបែងចែកចរាចរណ៍ ដែលខ្លួនអាចកំណត់ ឬបង្គាប់ ដើម្បីគ្រប់គ្រងលើការឆ្លងកាត់របស់នាវា។

២. ជាពិសេស នាវាដឹកប្រេង នាវាប្រើថាមពលនុយក្លេអ៊ែរ និងនាវាដែលដឹកសារធាតុនុយក្លេអ៊ែរ ឬសារធាតុ ឬវត្ថុធាតុមិនល្អ ឬគ្រោះថ្នាក់ដទៃទៀត អាចត្រូវតម្រូវឲ្យកំណត់ការឆ្លងកាត់របស់ខ្លួន តាមផ្លូវសមុទ្រ។

៣. ក្នុងការកំណត់ផ្លូវសមុទ្រ និងបង្គាប់គម្រោងបែងចែកចរាចរណ៍ តាមមាត្រានេះ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវពិចារណាៈ

(ក) អនុសាសន៍របស់ស្ថាប័នអន្តរជាតិមានសមត្ថកិច្ច។

(ខ) ព្រែកដែលជាធម្មតាប្រើសម្រាប់ការធ្វើនាវាចរណ៍អន្តរជាតិ។

(គ) លក្ខណៈពិសេសរបស់នាវា និងព្រែក និង

(ឃ) ទំហំចរាចរណ៍។

៤. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវចង្អុលបង្ហាញផ្លូវសមុទ្រ និងគម្រោងបែងចែកចរាចរណ៍ឲ្យបានច្បាស់លាស់ លើផែនទី ដែលត្រូវផ្សព្វផ្សាយជាសាធារណៈ។

មាត្រា ២៣

នាវាបរទេសប្រើថាមពលនុយក្លេអ៊ែរ និងនាវាដែលដឹកសារធាតុនុយក្លេអ៊ែរ ឬសារធាតុមិនល្អ និងគ្រោះថ្នាក់ដទៃទៀត

នៅពេលប្រើប្រាស់សិទ្ធិឆ្លងកាត់ដែនសមុទ្រដោយគ្មានចេតនាអាក្រក់ នាវាបរទេសដែលប្រើថាមពលនុយក្លេអ៊ែរ និងនាវាដែលដឹកសារធាតុនុយក្លេអ៊ែរ ឬសារធាតុមិនល្អ ឬគ្រោះថ្នាក់ដទៃទៀតត្រូវមានឯកសារ និងគោរពវិធានការប្រុងប្រយ័ត្នពិសេស ដែលចែងសម្រាប់នាវានោះ ដោយកិច្ចព្រមព្រៀងអន្តរជាតិ។

មាត្រា២៤

ករណីកិច្ចរបស់រដ្ឋជាប់ឆ្នេរសមុទ្រ

១. រដ្ឋជាប់ឆ្នេរមិនត្រូវរារាំងការឆ្លងកាត់ដែនសមុទ្រដោយគ្មានចេតនាអាក្រក់របស់នាវាសមុទ្រ លើកលែងតែអនុលោមតាមអនុសញ្ញានេះ។ ជាពិសេស ក្នុងការអនុវត្តអនុសញ្ញានេះ ឬច្បាប់ និងបញ្ញត្តិណាមួយដែលបានអនុម័តអនុលោមតាមអនុសញ្ញានេះ រដ្ឋជាប់ឆ្នេរសមុទ្រមិនត្រូវ៖

(ក) ដាក់លក្ខខណ្ឌលើនាវាបរទេស ដែលក្នុងការអនុវត្តមានអនុភាពបដិសេធ ឬប៉ះពាល់សិទ្ធិឆ្លងកាត់ដោយគ្មានបំណងអាក្រក់។ ឬ

(ខ) រើសអើងតាមទម្រង់ ឬភាពជាក់ស្តែងលើនាវារបស់រដ្ឋណាមួយ ឬនាវាដែលដឹកទំនិញទៅកាន់ ពី ឬតាងនាមឲ្យរដ្ឋណាមួយឡើយ។

២. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវធ្វើការផ្សព្វផ្សាយសមស្របពីគ្រោះថ្នាក់ដល់ការធ្វើនាវាចរណ៍ ដែលរដ្ឋបានដឹង ក្នុងដែនសមុទ្ររបស់ខ្លួន។

មាត្រា ២៥

សិទ្ធិការពាររបស់រដ្ឋជាប់ឆ្នេរសមុទ្រ

១. រដ្ឋជាប់ឆ្នេរសមុទ្រអាចចាត់វិធានការចាំបាច់ក្នុងដែមសមុទ្ររបស់ខ្លួន ដើម្បីរារាំងការឆ្លងកាត់ដែលមានចេតនាអាក្រក់។

២.  ក្នុងករណីនាវាចូលដែនទឹកខាងក្នុង  ឬចតនៅកំពង់ផែនៅក្រៅដែនទឹកខាងក្នុង  រដ្ឋជាប់ឆ្នេរសមុទ្រក៏មានសិទ្ធិចាត់វិធានការចាំបាច់  ដើម្បីបង្ការការរំលោភបំពានលក្ខខណ្ឌដែលបានអនុញ្ញាតឲ្យនាវានោះចូលដែនទឹកខាងក្នុង ឬចត។

៣.  ដោយគ្មានការរើសអើងតាមទម្រង់ឬភាពជាក់ស្តែង  រដ្ឋជាប់ឆ្នេរសមុទ្រអាចផ្អាកជាបណ្តោះអាសន្នចំពោះការឆ្លងកាត់ដោយគ្មានចេតនាអាក្រក់របស់នាវាបរទេស  ក្នុងដែនសមុទ្រជាក់លាក់ ប្រសិនបើការផ្អាកនោះជាការចាំបាច់សម្រាប់ការការពារសន្តិសុខរបស់ខ្លួន  ដែលរួមមានការធ្វើសមយុទ្ធអាវុធ។ ការផ្អាកនេះត្រូវមានប្រសិទ្ធិភាព តែក្រោយពីការផ្សព្វផ្សាយត្រឹមត្រូវប៉ុណ្ណោះ។

មាត្រា ២៦

កម្រៃអាចកំណត់លើនាវាបរទេស

១. គ្មានកម្រៃអាចកំណត់លើនាវាបរទេស ដោយសារតែឆ្លងកាត់ដែនសមុទ្រនោះទេ។

២.  កម្រៃអាចកំណត់លើនាវាបរទេសដែលឆ្លងកាត់ដែនសមុទ្រ  ដែលជាការបង់ប្រាក់តែចំពោះសេវាជាក់លាក់ដែលផ្តល់ដល់នាវាប៉ុណ្ណោះ។ កម្រៃទាំងនេះត្រូវកំណត់ដោយគ្មានរើសអើងឡើយ។

ជំពូករងខ៖ វិធានដែលអនុវត្តលើនាវាពាណិជ្ជករ និងនាវារដ្ឋាភិបាលដែលប្រតិបត្តិការក្នុងគោលបំណងពាណិជ្ជកម្ម

មាត្រា ២៧

យុត្តាធិការព្រហ្មទណ្ឌលើនាវាបរទេស

១.  យុត្តាធិការព្រហ្មទណ្ឌរបស់រដ្ឋជាប់ឆ្នេរសមុទ្រមិនគួរយកមកប្រើប្រាស់លើនាវាបរទេស  ដែលឆ្លងកាត់ដែនសមុទ្រ  ដើម្បីចាប់ខ្លួនជនណាម្នាក់  ឬធ្វើការស៊ើបអង្កេតលើបទល្មើសដែលបានប្រព្រឹត្តលើនាវា ក្នុងអំឡុងពេលឆ្លងកាត់ឡើយ លើកលែងតែករណីដូចខាងក្រោម៖

(ក) ប្រសិនបើផលវិបាកនៃបទល្មើសបន្តប៉ះពាល់ដល់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ខ) ប្រសិនបើបទល្មើសជាប្រភេទបទល្មើសមួយដែលរំខានសន្តិភាពរបស់ប្រទេស ឬសណ្តាប់ធ្នាប់ល្អនៃដែនសមុទ្រ។

(គ) ប្រសិនបើមានការស្នើសុំជំនួយពីអាជ្ញាធរមូលដ្ឋានពីសំណាក់ម្ចាស់នាវា ឬភ្នាក់ងារការទូត ឬមន្ត្រីកុងស៊ុលរបស់រដ្ឋដែលមានទង់លើនាវា។ ឬ

(ឃ) ប្រសិនបើវិធានការនោះចាំបាច់ ដើម្បីបង្ក្រាបការជួញដូរថ្នាំណាកូទីន ឬសារធាតុប៉ះពាល់ផ្លូវចិត្តខុសច្បាប់។

២. បញ្ញាតិខាងលើមិនប៉ះពាល់សិទ្ធិរបស់រដ្ឋឆ្នេរជាប់សមុទ្រក្នុងការចាត់វិធានការណាមួយដែលអនុញ្ញាតដោយច្បាប់របស់ខ្លួន ក្នុងគោលបំណងចាប់ខ្លួន ឬស៊ើបអង្កេតលើនាវាបរទេសដែលឆ្លងកាត់ដែនសមុទ្ររបស់ខ្លួន បន្ទាប់ពីនាវាចាកចេញពីផ្ទៃទឹកក្នុង។

៣. ក្នុងករណីដែលចែងក្នុងកឋាខណ្ឌ ១ និង ២ ប្រសិនបើប្រធាននាវាស្នើសុំ រដ្ឋជាប់ឆ្នេរត្រូវជូនដំណឹងភ្នាក់ងារការទូត ឬមន្ត្រីកុងស៊ុលនៃរដ្ឋដែលមានទង់លើនាវា មុនពេលចាត់វិធានការណាមួយ និងត្រូវសម្រួលទំនាក់ទំនងរវាងភ្នាក់ងារការទូត ឬមន្ត្រីកុងស៊ុលនោះជាមួយនឹងនាវិក។ ក្នុងករណីបន្ទាន់ អាចប្រាស្រ័យទាក់ទងធ្វើការជូនដំណឹង ខណៈពេលកំពុងចាត់វិធានការ។

៤. ក្នុងការពិចារណាថាតើគួរធ្វើការចាប់ខ្លួនឬយ៉ាងណា ឬដោយរបៀបណា អាជ្ញាធរមូលដ្ឋានត្រូវគិតពីផលប្រយោជន៍នៃការធ្វើនាវាចរណ៍។

៥. លើកលែងតែមានចែងក្នុងភាគទី ១២ ឬទាក់ទងនឹងការល្មើសច្បាប់ និងបទបញ្ញត្តិដែលអនុម័តអនុលោមតាមភាគីទី ៥ រដ្ឋជាប់ឆ្នេរសមុទ្រមិនអាចចាត់វិធានការណាមួយលើនាវាបរទេស ដែលឆ្លងកាត់ដែនសមុទ្រ ដើម្បីចាប់ខ្លួនមនុស្សណាម្នាក់ ឬធ្វើការស៊ើបអង្កេតលើបទល្មើសដែលបានប្រព្រឹត្តមុនពេលនាវាចូលក្នុងដែនសមុទ្ររបស់ខ្លួន ប្រសិនបើនាវានោះដែលធ្វើដំណើរពីកំពុងផែ បរទេស គ្រាន់តែឆ្លងកាត់ដែនសមុទ្រ មិនបានចូលក្នុងដែនទឹកខាងក្នុងទេ។

### មាត្រា ២៨

### ដែនសមត្ថកិច្ចរដ្ឋប្បវេណីទាក់ទងនឹងនាវាបរទេស

១. រដ្ឋជាប់ឆ្នេរមិនគួរបញ្ឈប់ ឬបង្វែរនាវាបរទេសដែលឆ្លងកាត់ដែនសមុទ្ររបស់ខ្លួន ក្នុងគោលបំណងអនុវត្តយុត្តាធិការរដ្ឋប្បវេណី ទាក់ទងនឹងជនណាម្នាក់នៅលើនាវាឡើយ។

២. រដ្ឋជាប់ឆ្នេរមិនអាចអនុវត្តលើ ឬឃាត់នាវា ដើម្បីគោលបំណងនៃនីតិវិធីរដ្ឋប្បវេណីឡើយ លើកលែងតែកាតព្វកិច្ច ឬបំណុលដែលទទួលយក ឬជំពាក់ដោយនាវាផ្ទាល់ ក្នុងពេលធ្វើដំណើរ ឬក្នុងគោលបំណងឆ្លងកាត់ផ្ទៃទឹករបស់រដ្ឋជាប់ឆ្នេរ។

៣. កឋាខណ្ឌ ២ មិនប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រក្នុងការអនុវត្តលើ ឬឃាត់នាវាដោយអនុលោមតាមច្បាប់របស់ខ្លួន ក្នុងការអនុវត្តលើ ឬឃាត់នាវាដែលស្ថិតនៅក្នុងដែនសមុទ្រ ឬឆ្លងកាត់ដែនសមុទ្របន្ទាប់ពីចាកចេញផ្ទៃទឹកក្នុង ដើម្បីគោលបំណងនីតិវិធីរដ្ឋប្បវេណី។

### ជំពូករងគៈ វិធានអនុវត្តចំពោះនាវាចម្បាំង និងនាវារដ្ឋាភិបាលដទៃទៀតដែលប្រតិបត្តិការមិនដើម្បីគោលបំណងពាណិជ្ជកម្ម

មាត្រា ២៩

ការកំណត់និយមន័យនាវាចម្បាំង

ក្នុងគោលបំណងនៃអនុសញ្ញានេះ "នាវាចម្បាំង" មានន័យថា នាវាដែលជាកម្មសិទ្ធិរបស់កងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ដែលសញ្ញាផ្នែកខាងក្រៅសម្គាល់សញ្ជាតិរបស់នាវា ស្ថិតក្រោមបញ្ជារបស់មន្ត្រីដែលទទួលភារកិច្ចត្រឹមត្រូវពីរដ្ឋាភិបាលរបស់រដ្ឋ និងដែលមានឈ្មោះក្នុងបញ្ជីកងទ័ព ឬបញ្ជីសមាមាត្រាសមស្រប និងដែលមាននាវិកម្នាក់ជួយ ដែលស្ថិតក្រោមការហ្វឹកហាត់កងកម្លាំងប្រដាប់អាវុធជាប្រចាំ។

មាត្រា៣០

នាវាចម្បាំងមិនគោរពតាមច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋជាប់ឆ្នេរ

ប្រសិនបើនាវាចម្បាំងមិនគោរពតាមច្បាប់ និងបទបញ្ញាត្តិរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ទាក់ទងនឹងការឆ្លងកាត់ដែនសមុទ្រ និងមិនគោរពតាមសំណើសុំឲ្យគោរពតាមច្បាប់ និងបទបញ្ញាត្តិនោះ រដ្ឋជាប់ឆ្នេរអាចតម្រូវឲ្យនាវាចម្បាំងនោះចាកចេញពីដែនសមុទ្រភ្លាមៗ។

មាត្រា ៣១
ការទទួលខុសត្រូវរបស់រដ្ឋចុះបញ្ជីនាវា ចំពោះការខូចខាតដែលបង្កឡើងនាវាចម្បាំង ឬនាវាដទៃទៀតរបស់រដ្ឋាភិបាល ដែលប្រតិបត្តិការមិនមែនដើម្បីគោលបំណងពាណិជ្ជកម្ម

រដ្ឋចុះបញ្ជីនាវាត្រូវទទួលខុសត្រូវជាលក្ខណៈអន្តរជាតិចំពោះការខាតបង់ ឬការខូចខាតមកលើរដ្ឋជាប់ឆ្នេរ ដែលបណ្តាលមកពីនាវាចម្បាំង ឬនាវាដទៃទៀតរបស់រដ្ឋាភិបាលមិនគោរពតាមច្បាប់ និងបទបញ្ញាត្តិរបស់រដ្ឋជាប់ឆ្នេរ ទាក់ទងនឹងការឆ្លងកាត់ដែនសមុទ្រ ឬបញ្ញាតិនៃអនុសញ្ញានេះ ឬវិធានដទៃទៀតនៃច្បាប់អន្តរជាតិ។

មាត្រា ៣២
អភ័យឯកសិទ្ធិរបស់នាវាចម្បាំង និងនាវាដទៃទៀតរបស់រដ្ឋាភិបាល
ដែលប្រតិបត្តិការមិនមែនដើម្បីគោលបំណងពាណិជ្ជកម្ម

លើកលែងតែមានចែងក្នុងអនុផ្នែក ក និងក្នុងមាត្រា ៣០ និង ៣១ គ្មានប្រការណាមួយក្នុងអនុសញ្ញានេះប៉ះពាល់ដល់អភ័យឯកសិទ្ធិរបស់នាវាចម្បាំង និងនាវាដទៃទៀតរបស់រដ្ឋាភិបាលដែលប្រតិបត្តិការមិនមែនដើម្បីគោលបំណងពាណិជ្ជកម្មឡើយ។

## ជំពូកទី៤៖ តំបន់ជាប់គ្នា

មាត្រា ៣៣
តំបន់ជាប់គ្នា

១. ក្នុងតំបន់ដែលជាប់ដែនសមុទ្រ ដែលហៅតំបន់ជាប់គ្នា រដ្ឋជាប់ឆ្នេរអាចធ្វើការគ្រប់គ្រង ដែលចាំបាច់ដើម្បី៖

(ក) បង្ការការរំលោភបំពានលើច្បាប់ និងបទបញ្ញត្តិផ្នែកគយ សារពើពន្ធ អន្តោប្រវេសន៍ សុខាភិបាល ក្នុងទឹកដី ឬដែនសមុទ្ររបស់រដ្ឋនោះ។

(ខ) ផ្តន្ទាទោសលើការរំលោភបំពានច្បាប់ និងបទបញ្ញត្តិខាងលើ ដែលបានប្រព្រឹត្តក្នុងទឹកដី ឬដែនសមុទ្ររបស់ខ្លួន។

២. តំបន់ជាប់គ្នាមិនមែនលើសពីចម្ងាយ ២៤ ម៉ាយល៍ពីខ្សែបន្ទាត់មូលដ្ឋាន សម្រាប់វាស់ប្រវែងដែនសមុទ្រឡើយ។

## ផ្នែកទី៣៖ ច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ

## ជំពូកទី១៖ បទបញ្ញត្តិទូទៅ

មាត្រា ៣៤

ស្ថានភាពគតិយុត្តិនៃដែនសមុទ្រដែលបង្កើតបានជាច្រកសមុទ្រ
បម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ

១. វិធាននៃការឆ្លងកាត់តាមច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិកំណត់នៅក្នុងផ្នែកនេះ នឹងមិនមានអានុភាពក្នុងលក្ខណៈណាមួយលើស្ថានភាពគតិយុត្តិនៃដែនសមុទ្រដែលបង្កើតបានច្រកសមុទ្របែបនោះ ឬការអនុវត្តន៍របស់រដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រនៅក្នុងអធិបតេយ្យភាព ឬយុត្តាធិការរបស់ពួក គេលើដែនសមុទ្រនោះ និងលំហអាកាស បាតសមុទ្រ និងដីស្រទាប់ក្រោមរបស់វាឡើយ។

២. អធិបតេយ្យភាព ឬយុត្តាធិការរបស់រដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រត្រូវអនុវត្តអនុលោមទៅតាមផ្នែកនេះ និងវិធានដទៃទៀតនៃច្បាប់អន្តរជាតិ។

មាត្រា ៣៥

វិសាលភាពនៃផ្នែកនេះ

គ្មានចំណុចណាមួយនៅក្នុងផ្នែកនេះមានអានុភាពលើ ៖

(ក) រាល់តំបន់ដែនទឹកខាងក្នុងនៅក្នុងច្រកសមុទ្រ លើកលែងតែការកំណត់នូវខ្សែបន្ទាត់មូលដ្ឋានត្រង់ស្មើ ដែលបានធ្វើឡើង អនុលោមតាមវិធីសាស្ត្រដែលចែងក្នុងមាត្រា ៧ មានអានុភាពដាក់បញ្ចូលតំបន់ ទឹកខាងក្នុងជាតំបន់ដែលពីមុនមកមិនត្រូវបានចាត់ទុកជាតំបន់បែបនោះ។

(ខ) ស្ថានភាពគតិយុត្តិនៃដែនទឹកក្រៅបូរណភាពដែនសមុទ្ររបស់រដ្ឋដែលមានព្រំដែនជាប់ច្រកសមុទ្រ ជាតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬតំបន់សមុទ្រអន្តរជាតិ ឬ

(គ) វិធានគតិយុត្តិនៃច្រកសមុទ្រ ដែលមានចែងទាំងស្រុង ឬដោយផ្នែកនៅក្នុងអនុសញ្ញាអន្តរជាតិចាស់ៗដែលចូលជាធរមាន អំពីការឆ្លងកាត់ និងដែលទាក់ទងយ៉ាងជាក់លាក់ទៅនឹងដែសមុទ្របែបនោះ។

មាត្រា ៣៦

ផ្លូវក្នុងសមុទ្រអន្តរជាតិ ឬផ្លូវឆ្លងកាត់តំបន់សេដ្ឋកិច្ចផ្តាច់មុខ ឆ្លងកាត់ច្រកសមុទ្រ
ដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ

ផ្នែកនេះមិនអនុវត្តលើច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណអ័ន្តរជាតិនោះទេ ប្រសិនបើតាមច្រកសមុទ្រ ទាំងនោះមានផ្លូវឆ្លងកាត់សមុទ្រអន្តរជាតិ ឬឆ្លងកាត់តំបន់សេដ្ឋកិច្ចផ្តាច់មុខ ដែលមានភាពងាយស្រួលប្រហាក់ប្រហែលគ្នា ទាក់ទិននឹងលក្ខណៈនាវាចរណ៍ និងជលធារសាស្ត្រ។ ចំពោះផ្លូវទាំងនោះ ផ្នែកពាក់ព័ន្ធផ្សេងទៀតក្នុងអនុសញ្ញានេះ រាប់បញ្ចូលទាំងបញ្ញត្តិស្តីពីសេរីភាពនាវាចរណ៍ និងការហោះហើរពីលើគឺត្រូវអនុវត្ត។

ជំពូកទី២៖ ច្រកឆ្លងកាត់

មាត្រា ៣៧
វិសាលភាពនៃជំពូកនេះ

ជំពូកនេះអនុវត្តចំពោះច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ រវាងផ្នែកមួយនៃសមុទ្រអន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងផ្នែកមួយផ្សេងទៀតនៃសមុទ្រអន្តរជាតិ ឬ តំបន់សេដ្ឋកិច្ចផ្តាច់មុខ។

មាត្រា ៣៨
សិទ្ធិដឹកជញ្ជូនឆ្លងកាត់

១. ចំពោះច្រកសមុទ្រដែលចែងក្នុងមាត្រា ៣៧ នាវា និងអាកាសយានទាំងអស់មានសិទ្ធិដឹកជញ្ជូនឆ្លងកាត់ ដោយមិនការរារាំងអ្វីទាំងអស់ លើកលែងតែថា ប្រសិនបើច្រកសមុទ្រនោះកើតឡើងពីកោះរបស់រដ្ឋដែលមាន ព្រំប្រទល់ជាប់ច្រកសមុទ្រ និងដីគោករបស់វា នោះច្រកដឹកជញ្ជូនមិនត្រូវអនុវត្តនោះទេ ប្រសិនបើដីបែរទៅរកសមុទ្រ របស់កោះមានផ្លូវឆ្លងកាត់សមុទ្រអន្តរជាតិ ឬឆ្លងកាត់តំបន់សេដ្ឋកិច្ចផ្តាច់មុខដែលមានភាពងាយស្រួលប្រហាក់ប្រហែលគ្នា ឮទាក់ទិនទៅនឹងលក្ខខណ្ឌនាវាចរណ៍ និងជលធារសាស្ត្រ។

២. ការដឹកជញ្ជូនឆ្លងកាត់ មានន័យថាការអនុវត្តន៍អនុលោមតាមផ្នែកនេះនូវសេរីភាពក្នុងការធ្វើនាវាចរណ៍ និងការហោះហើរ តែក្នុងគោលបំណងដឹកជញ្ជូនមិនឈប់ និងដោយរហ័សតាមច្រកសមុទ្រនៅចន្លោះផ្នែកមួយនៃសមុទ្រអន្តរជាតិ ឬ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងផ្នែកមួយផ្សេងទៀតនៃសមុទ្រអន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ ប៉ុន្តែលក្ខខណ្ឌ នៃការបន្ត និងការពន្លឿនដល់ការដឹកជញ្ជូនមិនអនុវត្តលើការឆ្លងកាត់តាមច្រកសមុទ្រ ដើម្បីចេញចូល ឬត្រឡប់ ពីរដ្ឋដែលមានព្រំប្រទល់ជាប់ច្រកសមុទ្រដែលអនុលោមតាមលក្ខខណ្ឌក្នុងការចូលក្នុងរដ្ឋនោះទេ។

៣. រាល់សកម្មភាព ដែលមិនមែនជាការប្រើប្រាស់សិទ្ធិដឹកជញ្ជូនឆ្លងកាត់តាមច្រកសមុទ្រត្រូវរក្សាគ្រប់គ្រងដោយបញ្ញត្តិជាធរមានផ្សេងទៀតនៃអនុសញ្ញានេះ។

មាត្រា ៣៩

កាតព្វកិច្ចរបស់នាវា និងអាកាសយានក្នុងពេលដឹកឆ្លងកាត់

១. ក្នុងពេលប្រើប្រាស់សិទ្ធិដឹកជញ្ជូនឆ្លងកាត់ នាវា និងអាកាសយានត្រូវៈ

(ក) ដឹកជញ្ជូនតាម ឬពីលើច្រកសមុទ្រ ដោយគ្មានការយឺតយ៉ាវ។

(ខ) ជៀសវាងបង្កការគំរាមកំហែង ឬប្រើប្រាស់កម្លាំងប្រឆាំងនឹងអធិបតេយ្យភាព បូរណភាពឯករាជ្យភាពនយោបាយរបស់រដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រ ឬក្នុងលក្ខណៈណាមួយដែលបំពានទៅលើគោលការណ៍ច្បាប់អន្តរជាតិដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ។

(គ) ជៀសវាងធ្វើសកម្មភាពផ្សេងពីសកម្មភាពដែលជាទម្រង់តាមធម្មតានៃការដឹកជញ្ជូនមិនឈប់ និងរហ័ស លើកលែងតែត្រូវធ្វើឡើងយ៉ាងចាំបាច់ដោយសារករណីប្រធានស័ក្តិ ឬស្ថានភាព គ្រោះថ្នាក់។

(ឃ) គោរពតាមបញ្ញត្តិពាក់ព័ន្ធផ្សេងទៀតដែលមានចែងក្នុងផ្នែកនេះ។

២. នាវាដែលដឹកជញ្ជូនឆ្លងកាត់ត្រូវៈ

(ក) គោរពតាមបទបញ្ជា នីតិវិធី និងនិយាមអន្តរជាតិដែលមានការទទួលយកជាទូទៅដើម្បីសុវត្ថិភាពក្នុងសមុទ្រ ដោយរាប់បញ្ចូលទាំងបទបញ្ជាអន្តរជាតិសម្រាប់បង្ការការប៉ះទង្គិចនាវានៅក្នុងសមុទ្រ។

(ខ) គោរពតាមបទបញ្ជា នីតិវិធី និងនិយាមអន្តរជាតិដែលមានការទទួលជាទូទៅ ដើម្បីការពារ កាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា។

៣. អាកាសយានដែលដឹកជញ្ជូនឆ្លងកាត់ត្រូវៈ

(ក) គោរពវិធានស្តីពីដែនអាកាសបង្កើតឡើងដោយអង្គការអាកាសចរស៊ីវិលអន្តរជាតិដែលអនុវត្តចំពោះអាកាសយានស៊ីវិល។ ជាធម្មតា អាកាសយានរដ្ឋត្រូវគោរព

ទៅតាមវិធានការដើម្បីសុវត្ថិភាពទាំងនេះ ហើយជានិច្ចកាលត្រូវប្រតិបត្តិការដោយយកចិត្តទុកដាក់ទៅលើសុវត្ថិភាពក្នុងការហោះហើរ។

(ខ) គ្រប់ពេលទាំងអស់ ពិនិត្យតាមដាន ប្រេកង់វិទ្យុដែលកំណត់ដោយអាជ្ញាធរត្រួតពិនិត្យចរាចរផ្លូវអាកាសមានសមត្ថកិច្ចដែលបានកំណត់ជាអន្តរជាតិ ឬប្រេកង់វិទ្យុសមស្របដែលមានការរំខានជាអន្តរជាតិ។

## មាត្រា ៤០
## សកម្មភាពស្រាវជ្រាវ និងការអង្កេត

ក្នុងអំឡុងពេលដឹកជញ្ជូនឆ្លងកាត់ នាវាបរទេស រាប់បញ្ចូលទាំង នាវាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក្នុងសមុទ្រ និងអង្កេតជលធារសាស្ត្រ មិនអាចអនុវត្តសកម្មភាពស្រាវជ្រាវ ឬអង្កេតណាមួយដោយគ្មានការអនុញ្ញាតជាមុនពីបណ្តារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រនោះឡើយ។

## មាត្រា ៤១
## គម្រោងបែងចែកចរាចរណ៍ និងផ្លូវសមុទ្រក្នុងច្រកសមុទ្រ ដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ

១. អនុលោមទៅតាមផ្នែកនេះ បណ្តារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រអាចកំណត់នូវផ្លូវសមុទ្រ និងរៀបចំគម្រោងបែងចែកចរាចរណ៍សម្រាប់ការធ្វើនាវាចរណ៍នៅក្នុងច្រកសមុទ្រតាមការចាំបាច់ ដើម្បីលើកកម្ពស់ការឆ្លងកាត់ប្រកបដោយសុវត្ថិភាពរបស់នាវា។

២. ក្នុងស្ថានភពាចាំបាច់ និងបន្ទាប់ពីធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងត្រឹមត្រូវហើយនោះ បណ្តារដ្ឋទាំងនេះអាចប្រើប្រាស់ផ្លូវសមុទ្រ ឬគម្រោងបែងចែកចរាចរណ៍ផ្សេងទៀត ជំនួសឱ្យផ្លូវសមុទ្រ ឬគម្រោងបែងចែកចរាចរណ៍ណាមួយដែលខ្លួនបានកំណត់ ឬរៀបចំកន្លងមក។

៣.	ផ្លូវសមុទ្រ និងគម្រោងបែងចែកចរាចរណ៍ទាំងនេះត្រូវមានលក្ខណៈស្របទៅតាមបទបញ្ញត្តិអន្តរជាតិដែលមានការទទួលយកជាទូទៅ។

៤.	មុននឹងធ្វើការកំណត់ ឬប្រើប្រាស់ផ្លូវសមុទ្រជំនួស ឬធ្វើការរៀបចំ ឬប្រើប្រាស់គម្រោងបែងចែកចរាចរណ៍ជំនួស បណ្ដារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រត្រូវលើកសំណើ អំពីការរៀបចំរបស់ខ្លួនទៅអង្គការអន្តរជាតិមានសមត្ថកិច្ច។ អង្គការអាចអនុម័តតែចំពោះផ្លូវសមុទ្រ និងគម្រោងបែងចែកចរាចរណ៍ណាដែលអាចទទួលបានការព្រមព្រៀងជាមួយនឹងបណ្ដារដ្ឋដែលមានព្រំប្រទល់ជាប់នឹង ច្រកសមុទ្រនោះប៉ុណ្ណោះ បន្ទាប់ពីបណ្ដារដ្ឋកំណត់ រៀបចំ ឬជំនួសវា។

៥.	ទាក់ទិនទៅនឹងច្រកសមុទ្រដែលមានគម្រោងបែងចែកចរាចរណ៍ ឬផ្លូវសមុទ្រតាមដែនសមុទ្ររបស់បណ្ដារដ្ឋ ដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រចំនួនពីរឡើងទៅកំពុងបានស្នើឡើង នោះបណ្ដារដ្ឋដែលពាក់ព័ន្ធត្រូវសហការក្នុងរៀបចំសំណើ ដោយប្រឹក្សាយោបល់ជាមួយនឹងអង្គការអន្តរជាតិមានសមត្ថកិច្ច។

៦.	បណ្ដារដ្ឋ ដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រត្រូវបង្ហាញយ៉ាងច្បាស់លាស់អំពីគម្រោងបែងចែកចរាចរណ៍ និងផ្លូវសមុទ្រទាំងអស់ដែលខ្លួនបានកំណត់ ឬបានរៀបចំនៅក្នុងតារាងដែលត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងត្រឹមត្រូវ។

៧.	នាវាដែលដឹកជញ្ជូនឆ្លងកាត់ត្រូវគោរពគម្រោងបែងចែកចរាចរណ៍ និងផ្លូវសមុទ្រជាធរមានដែលកំណត់អនុលោមទៅតាមមាត្រានេះ។

## មាត្រា ៤២

## ច្បាប់ និងបទបញ្ញត្តិរបស់បណ្ដារដ្ឋដែលមានព្រំប្រទល់ជាប់នឹង ច្រកសមុទ្រទាក់ទិននឹងការដឹកជញ្ជូនឆ្លងកាត់

១. អនុលោមទៅតាមបទបញ្ញត្តិនៃជំពូកផ្នែក បណ្តារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រអាចរៀបចំច្បាប់ និងបទបញ្ញត្តិស្តីពីការដឹកជញ្ជូនឆ្លងកាត់តាមច្រកសមុទ្រ ទាក់ទិនទៅនឹងចំណុចទាំងអស់ ឬចំណុចណាមួយខាងក្រោមនេះ៖

(ក) សុវត្ថិភាពក្នុងការធ្វើនាវាចរណ៍ និងបទបញ្ញត្តិស្តីពីចរាចរណ៍ជើងទឹក ដូចមានចែងក្នុងមាត្រា ៤១។

(ខ) ការបង្ការ ការកាត់បន្ថយ និង ការគ្រប់គ្រងការបំពុល តាមរយៈការផ្តល់អនុភាពដលើបទបញ្ញត្តិអន្តរជាតិជាធរមាន ទាក់ទិននឹងការបញ្ចេញប្រេងកាកសំណល់ជាតិប្រេង និងសារធាតុផ្តល់ទុក្ខទោសផ្សេងទៀតក្នុងច្រកសមុទ្រ។

(គ) ទាក់ទិនទៅនឹងទូកនេសាទ ការបង្ការផ្នែកនេសាទ រាប់បញ្ចូលទាំងការទុកដាក់ឧបករណ៍នេសាទ។

(ឃ) ការផ្ទុក ឬការបញ្ចេញនូវទំនិញ រូបិយប័ណ្ណ ឬមនុស្ស បុគ្គល ដោយរំលោភទៅនឹងច្បាប់ និង បទបញ្ញត្តិស្តីពីពន្ធគយ ពន្ធដារ អន្តោប្រវេសន៍ ឬអនាម័យរបស់បណ្តារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រ។

២. ច្បាប់ និង បទបញ្ញត្តិទាំងនេះមិនត្រូវមានការរើសអើងក្នុងទម្រង់ ឬតាមលក្ខណៈណាមួយ ក្នុងចំណោមនាវាបរទេស ឬ ក្នុងការអនុវត្តរបស់វា មានអានុភាពយ៉ាងជាក់ស្តែងក្នុងការបដិសេធរំខាន ឬ បន្ថយនូវសិទ្ធិដឹកជញ្ជូនឆ្លងកាត់ដូចបានកំណត់ក្នុងជំពូកនេះឡើយ។

៣. បណ្តារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងត្រឹមត្រូវអំពីច្បាប់ និងបទបញ្ញត្តិទាំងអស់នេះ។

៤. នាវាបរទេសដែលអនុវត្តសិទ្ធិដឹកជញ្ជូនឆ្លងកាត់ត្រូវគោរពទៅតាមច្បាប់ និងបទបញ្ញត្តិទាំងនេះ។

៥. រដ្ឋចុះបញ្ជីនាវា ឬរដ្ឋដែលបានបញ្ជីបញ្ជីអាកាសយានដែលសិទ្ធិទទួលបានអភ័យឯកសិទ្ធិរដ្ឋដែលអនុវត្តសកម្មភាពក្នុងលក្ខណៈមួយផ្ទុយពីច្បាប់ និង បទបញ្ញត្តិទាំងនេះ ឬបទបញ្ញត្តិ

ផ្សេងៗទៀតនៃផ្នែកនេះ ត្រូវមានការទទួលខុសត្រូវជាអន្តរជាតិលើរាល់ការបាត់បង់ ឬការខូចខាត ដែលកើតមានលើបណ្តារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រ។

មាត្រា ៤៣

ជំនួយផ្នែកនាវាចរណ៍ និងសុវត្ថិភាព ព្រមទាំង

បសិដ្ឋកម្មផ្សេងទៀត និងការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុល

តាមរយៈកិច្ចព្រមព្រៀង បណ្តារដ្ឋអនុវត្តសិទ្ធិ និងបណ្តារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រត្រូវសហប្រតិបត្តិការៈ

(ក) បង្កើត និងថែទាំជំនួយផ្នែកនាវាចរណ៍ និងសុវត្ថិភាពចាំបាច់ៗ ឬ បសិដ្ឋកម្មផ្សេងទៀត នៃជំនួយផ្នែកនាវាចរណ៍អន្តរជាតិ ក្នុងច្រកសមុទ្រ និង

(ខ) បង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា។

មាត្រា ៤៤

ភារកិច្ចរបស់បណ្តារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រ

បណ្តារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រមិនត្រូវរំខានការដឹកជញ្ជូនឆ្លងកាត់ និងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈសមស្របអំពីគ្រោះថ្នាក់នានានៃការធ្វើនាវាចរណ៍ ឬការហោះហើរក្នុង ឬពីលើច្រកសមុទ្រដែលខ្លួនបានដឹង។ ហាមរាល់ការការផ្អាកនូវការដឹកជញ្ជូនឆ្លងកាត់ណាមួយ។

ជំពូកទី៣ៈ ការឆ្លងកាត់មិនបំពាន

មាត្រា ៤៥

ការឆ្លងកាត់មិនបំពាន

១.	អនុលោមតាមផ្នែក ២ ជំពូកទី ៣ វិធាននៃការឆ្លងកាត់មិនបំពានត្រូវអនុវត្តនៅក្នុងច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិៈ

(ក)	ដកចេញពីការអនុវត្តវិធាននៃការដឹកជញ្ជូនឆ្លងកាត់ក្រោមមាត្រា ៣៨ កថាខណ្ឌទី ១ ឬ

(ខ)	ចន្លោះផ្នែកមួយនៃសមុទ្រអន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងសមុទ្រឆ្នេររបស់រដ្ឋបរទេស។

២.	ហាមរាល់ការការផ្អាកនូវការដឹកជញ្ជូនឆ្លងកាត់ណាមួយតាមច្រកសមុទ្រទាំងនេះ

## ផ្នែកទី៤៖ បណ្តារដ្ឋប្រជុំកោះ

### មាត្រា ៤៦
### ការប្រើប្រាស់វាក្យស័ព្ទ

សម្រាប់គោលបំណងនៃអនុសញ្ញានេះ៖

(ក) "រដ្ឋប្រជុំកោះ" មានន័យថា រដ្ឋមួយដែលកើតឡើងទាំងស្រុងដោយប្រជុំកោះមួយ ឬច្រើន និងអាចរាប់បញ្ចូលទាំងបណ្តាកោះផ្សេងទៀត។

(ខ) "ប្រជុំកោះ" មានន័យថា ក្រុមកោះ រាប់បញ្ចូលទាំងផ្នែកនៃកោះ ជាប់នឹងដែនសមុទ្រ និងធម្មជាតិផ្សេងទៀតដែលមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងបណ្តាកោះ ដែនសមុទ្រទាំងនេះ និងធម្មជាតិផ្សេងទៀតបង្កើតបានជាអង្គមួយដែលមានលក្ខណៈភូមិសាស្ត្រ សេដ្ឋកិច្ច និងនយោបាយពិសេសផ្ទាល់របស់វា ឬ ដែលជាប្រវត្តិសាស្ត្រត្រូវបានចាត់ទុកថាមានលក្ខណៈទាំងនេះ។

### មាត្រា ៤៧
### ខ្សែបន្ទាត់មូលដ្ឋាននៃប្រជុំកោះ

១. រដ្ឋប្រជុំកោះអាចគូសខ្សែបន្ទាត់មូលដ្ឋាននៃប្រជុំកោះត្រង់ដោយភ្ជាប់ចំណុចក្រៅបំផុតនៃបណ្តាកោះក្រៅបំផុត ទៅនិងថ្មប៉ប្រះទឹកស្ងួតនៃប្រជុំកោះ ក្នុងលក្ខខណ្ឌថានៅក្នុងខ្សែបន្ទាត់មូលដ្ឋានទាំងនេះបានបញ្ចូលនូវបណ្តាកោះសំខាន់ៗ និងតំបន់ដែលមានផលធៀបរវាងដែនសមុទ្រ និងផ្ទៃដីគោករាប់បញ្ចូលទាំងកោះផ្កាថ្ម មានតម្លៃស្មើនឹង ១ ទល់នឹង ១ និង ៩ ទល់នឹង ១។

២. ប្រវែងនៃខ្សែបន្ទាត់មូលដ្ឋានទាំងនេះ មិនត្រូវលើសពី ១០០ ម៉ែល៍សមុទ្រនោះទេ លើកលែងថារហូតដល់ ៣ ភាគរយនៃចំនួនខ្សែបន្ទាត់មូលដ្ឋានសរុបដែលព័ទ្ធជុំវិញប្រជុំកោះណាមួយអាចលើសពីប្រវែងនោះ រហូតដល់ប្រវែងអតិបរមា ១២៥ ម៉ែល៍សមុទ្រ។

៣.	ការគូសខ្សែបន្ទាត់មូលដ្ឋានទាំងនេះមិនត្រូវចេញឆ្ងាយ	ក្នុងវិសាលភាពសមស្រប ណាមួយ ពីការកំណត់រចនាសម្ព័ន្ធទូទៅរបស់ប្រជុំកោះឡើយ។

៤.	ខ្សែបន្ទាត់មូលដ្ឋានទាំងនេះមិនត្រូវគូសទៅ និងពីកម្ពស់លំនាចទេ លើកលែងតែសើន បញ្ចាំងភ្លើង ឬ ឋបនភ័ណ្ឌស្រដៀងគ្នាដែលស្ថិតនៅខ្ពស់ជាងនីវ៉ូសមុទ្រជាអចិន្ត្រៃយ៍ ត្រូវបានសាងសង់ នៅលើនោះ ឬលំនាចស្ថិតនៅទាំងស្រុង ឬដោយផ្នែក ក្នុងចម្ងាយមួយលើសពីទទឹងនៃសមុទ្រឆ្នេរពី កោះដែលជិតបំផុត។

៥.	ប្រព័ន្ធនៃខ្សែបន្ទាត់មូលដ្ឋានទាំងនេះមិនត្រូវបានអនុវត្តដោយរដ្ឋប្រជុំកោះក្នុងលក្ខណៈ មួយដើម្បីកាត់ចេញពីសមុទ្រអន្តរជាតិ ឬ តំបន់សេដ្ឋកិច្ចផ្តាច់មុខនូវសមុទ្រឆ្នេររបស់រដ្ឋមួយផ្សេងទៀត នោះទេ។

៦.	ប្រសិនបើផ្នែកមួយនៃដែនសមុទ្ររដ្ឋប្រជុំកោះ លាតសន្ធឹងចន្លោះផ្នែកពីរនៃរដ្ឋជិតខាង ដែលជាប់គ្នាដោយផ្ទាល់ នោះសិទ្ធិដែលមានស្រាប់ និងផលប្រយោជន៍ស្របច្បាប់ផ្សេងទៀតទាំងអស់ ដែលរដ្ឋចុងក្រោយនេះបានអនុវត្តជាប្រពៃណីក្នុងដែនសមុទ្រទាំងនេះ និងសិទ្ធិទាំងអស់ដែលបាន ចែងក្នុងកិច្ចព្រមព្រៀងរវាងបណ្តារដ្ឋទាំងនោះត្រូវបន្ត និងត្រូវបានគោរព។

៧.	ដើម្បីគណនាផលធៀបរវាងដែនសមុទ្រ និងដីគោកក្រោមកថាខណ្ឌទី ១ ផ្ទៃដីគោក ត្រូវបូកបញ្ចូលទាំងដែនសមុទ្រដែលលាតសន្ធឹងក្នុងថ្មប៉ប្រះទឹកតាមគែមនៃបណ្តាកោះ និងកោះផ្កាថ្ម ដោយរាប់បញ្ចូលទាំងផ្នែកនៃខ្ពង់រាបសមុទ្រច្រាំងចោតដែល ព័ទ្ធជុំវិញដោយ ឬស្ទើរតែព័ទ្ធជុំវិញដោយ ជួរកោះចុណ្ណីសិលា និងថ្មប៉ប្រះទឹកស្ងួតដែលលាតសន្ធឹងនៅតាមបរិវេណខ្ពង់រាប។

៨.	ខ្សែបន្ទាត់មូលដ្ឋានដែលបានគូសអនុលោមតាមមាត្រានេះត្រូវមានបង្ហាញយ៉ាង គ្រប់គ្រាន់នៅក្នុងតារាងមាត្រដ្ឋាន ដើម្បីបញ្ជាក់អំពីទីតាំងរបស់វា។ បើមិនដូច្នេះទេ អាចប្រើបញ្ជីស្តីពី ចំណុចកូអរឌីនេភូមិសាស្ត្រ ដែលបញ្ជាក់អំពីទិន្នន័យប្រចពីវិភាគជំនួសបាន។

៩.	រដ្ឋប្រជុំកោះត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងត្រឹមត្រូវអំពីតារាង ឬចំណុច និយាមកាភូមិសាស្ត្រទាំងនេះ និងត្រូវតំកល់ច្បាប់ចម្លងនៃតារាង ឬបញ្ជីនីមួយៗនៅអគ្គលេខាធិការ របស់អង្គការសហប្រជាជាតិ។

## មាត្រា ៤៨

## ការវាស់វែងទទឹងសមុទ្រឆ្នេរ តំបន់ជាប់ឆ្នេរសមុទ្រ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងខ្ពង់រាប

ទទឹងសមុទ្រឆ្នេរ តំបន់ជាប់ឆ្នេរសមុទ្រ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និង ខ្ពង់រាបត្រូវបានវាស់វែងពីខ្សែបន្ទាត់មូលដ្ឋាននៃប្រជុំកោះដែលបានគូសអនុលោមតាមមាត្រា ៤៧។

## មាត្រា ៤៩

## ស្ថានភាពគតិយុត្តិនៃដែនសមុទ្រប្រជុំកោះ នៃលំហរអាកាសពីលើដែនសមុទ្រប្រជុំកោះ និងនៃបាតសមុទ្រ និងដីស្រទាប់ក្រោមរបស់វា

១. អធិបតេយ្យភាពនៃរដ្ឋប្រជុំកោះលាតសន្ធឹងដល់ដែនសមុទ្រដែលព័ទ្ធជុំវិញដោយខ្សែបន្ទាត់មូលដ្ឋាននៃប្រជុំកោះដែលបានគូសអនុលោមតាមមាត្រា ៤៧ ដែលបានកំណត់ថាជាដែនសមុទ្រប្រជុំកោះ ដោយមិនគិតអំពីជម្រៅ ឬចម្ងាយរបស់វាពីឆ្នេរសមុទ្រឡើយ។

២. អធិបតេយ្យភាពនេះ លាតសន្ធឹងដល់លំហរអាកាសពីលើដែនសមុទ្រប្រជុំកោះ ក៏ដូចជាដល់បាតសមុទ្រ និងដីស្រទាប់ក្រោមរបស់វា និងធនធានដែលមាននៅក្នុងនោះ។

៣. អធិបតេយ្យភាពនេះត្រូវអនុវត្តអនុលោមទៅតាមផ្នែកនេះ។

៤. ទាក់ទិននឹងចំណុចផ្សេងទៀត វិធាននៃការឆ្លងកាត់តាមផ្លូវសមុទ្រប្រជុំកោះ ដែលកំណត់នៅក្នុងផ្នែកនេះមិនមានអានុភាពលើស្ថានភាពនៃដែនសមុទ្រប្រជុំកោះ រាប់បញ្ចូលទាំងផ្លូវសមុទ្រ ឬការអនុវត្តសិទ្ធិរបស់រដ្ឋប្រជុំកោះនូវអធិបតេយ្យភាពរបស់ខ្លួនលើដែនសមុទ្រទាំងនេះ និងលំហរអាកាស បាតសមុទ្រ និងដីស្រទាប់ក្រោមរបស់វា និងធនធានដែលមាននៅក្នុងនោះនោះទេ។

មាត្រា ៥០

ការកំណត់ព្រំដែននៃដែនទឹកខាងក្នុង

នៅក្នុងដែនសមុទ្រប្រជុំកោះរបស់ខ្លួន រដ្ឋប្រជុំកោះអាចគូសខ្សែបន្ទាត់បិទដើម្បីការកំណត់ព្រំដែនទឹកខាងក្នុង អនុលោមតាមមាត្រា ៩,១០ និង ១១។

មាត្រា ៥១

កិច្ចព្រមព្រៀងដែលមានស្រាប់ សិទ្ធិនេសាទជាប្រពៃណី និង ខ្សែកាប្លិ៍នៅក្រោមសមុទ្រដែលមានស្រាប់

១. ដោយមិនប៉ះពាល់ទៅដល់មាត្រា ៤៩ រដ្ឋប្រជុំកោះត្រូវគោរពកិច្ចព្រមព្រៀងដែលមានស្រាប់ជាមួយនឹងបណ្តារដ្ឋផ្សេងទៀត និងត្រូវទទួលស្គាល់សិទ្ធិនេសាទជាប្រពៃណី និងសកម្មភាពស្របច្បាប់ផ្សេងទៀត របស់បណ្តារដ្ឋជិតខាងដែលមានព្រំប្រទល់ជាប់គ្នាដោយផ្ទាល់ក្នុងតំបន់មួយចំនួនដែលស្ថិតក្នុងដែនសមុទ្រប្រជុំកោះ។ លក្ខខណ្ឌ និងប្រការចែងសម្រាប់ការអនុវត្តសិទ្ធិ និងសកម្មភាពទាំងនោះ រាប់បញ្ចូលទាំងធម្មជាតិ វិសាលភាព និងតំបន់ដែលត្រូវអនុវត្ត ទៅតាមសំណើរបស់រដ្ឋណាមួយដែលពាក់ព័ន្ធ ត្រូវកំណត់ដោយកិច្ចព្រមព្រៀងទ្វេភាគីរវាងពួកគេ។ សិទ្ធិនោះមិនត្រូវផ្ទេរទៅ ឬ បែងចែកជាមួយនឹងបណ្តារដ្ឋទីបី ឬប្រជាជាតិរបស់ពួកគេឡើយ។

២. រដ្ឋប្រជុំកោះត្រូវគោរពខ្សែកាប្លិ៍នៅក្រោមសមុទ្រដែលមានស្រាប់ដែលរាយដោយបណ្តារដ្ឋផ្សេងទៀត និងដែលឆ្លងកាត់ដែនសមុទ្ររបស់ខ្លួនដោយគ្មានការធ្វើឱ្យមានបាក់ដី។ រដ្ឋប្រជុំកោះត្រូវអនុញ្ញាតដល់ការថែទាំ និងផ្លាស់ប្តូរខ្សែកាប្លិ៍ទាំងនេះ នៅពេលបានទទួលការជូនដំណឹងត្រឹមត្រូវអំពីទីតាំងរបស់វា និងអំពីបំណងជួសជុល ឬផ្លាស់ប្តូរវា។

មាត្រា ៥២

សិទ្ធិឆ្លងកាត់មិនបំពាន

១. អនុលោមទៅតាមមាត្រា ៥៣ និងដោយមិនប៉ះពាល់ដល់មាត្រា ៥០ នាវារបស់បណ្ដារដ្ឋទាំងអស់មានសិទ្ធិឆ្លងកាត់មិនបំពាន តាមដែនសមុទ្រប្រជុំកោះ អនុលោមតាមផ្នែកទី ២ ជំពូកទី ៣។

២. ដោយគ្មានការរើសអើងក្នុងទម្រង់ ឬតាមលក្ខណៈណាមួយ ក្នុងចំណោមនាវាបរទេស រដ្ឋប្រជុំកោះអាច ផ្អាកជាបណ្ដោះអាសន្ននូវការឆ្លងកាត់មិនបំពានរបស់នាវាបរទេសក្នុងតំបន់ជាក់លាក់នៃដែនសមុទ្រប្រជុំកោះរបស់ខ្លួន ប្រសិនបើការផ្អាកទាំងនេះគឺត្រូវធ្វើឡើងយ៉ាងចាំបាច់ ដើម្បីការពារសន្តិសុខរបស់ខ្លួន។ ការផ្អាកទាំងនេះត្រូវមានប្រសិទ្ធភាពតែបន្ទាប់ពីបានបោះពុម្ពផ្សាយយ៉ាងត្រឹមត្រូវប៉ុណ្ណោះ។

មាត្រា ៥៣

សិទ្ធិក្នុងការឆ្លងកាត់តាមផ្លូវសមុទ្រប្រជុំកោះ

១. រដ្ឋប្រជុំកោះអាចកំណត់ផ្លូវសមុទ្រ និងខ្សែអាកាសខាងលើ ដែលមានលក្ខណៈស័ក្តិសមសម្រាប់ការឆ្លងកាត់ជាប់គ្នា និងរហ័សរបស់នាវាបរទេស និងអាកាសយានតាម ឬពីលើដែនសមុទ្រប្រជុំកោះរបស់ខ្លួន និងសមុទ្រឆ្នេរជាប់គ្នានោះ។

២. នាវា និង អាកាសយានទាំងអស់មានសិទ្ធិឆ្លងកាត់តាមផ្លូវសមុទ្រប្រជុំកោះក្នុងផ្លូវសមុទ្រ និង ខ្សែអាកាសទាំងនេះ។

៣. ការឆ្លងកាត់តាមផ្លូវសមុទ្រប្រជុំកោះ មានន័យថាជាការអនុវត្តអនុលោមតាមអនុសញ្ញានេះ នូវសិទ្ធិធ្វើនាវាចរណ៍ និងហោះហើរពីលើ តាមលក្ខណៈប្រក្រតី តែក្នុងគោលបំណងដឹកជញ្ជូនជាប់គ្នា រហ័ស និងគ្មានការរារាំងរវាងផ្នែកមួយនៃសមុទ្រអន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្ដាច់មុខ និងផ្នែកមួយផ្សេងទៀតនៃសមុទ្រអន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្ដាច់មុខប៉ុណ្ណោះ។

៤. ផ្លូវសមុទ្រ និងខ្សែអាកាសទាំងនេះត្រូវឆ្លងកាត់ដែនសមុទ្រប្រជុំកោះ និងសមុទ្រឆ្នេរជាប់គ្នានោះ និងត្រូវរាប់បញ្ចូលទាំងផ្លូវឆ្លងកាត់ធម្មតាទាំងអស់ដែលប្រើប្រាស់ជាផ្លូវសម្រាប់នាវាចរណ៍អន្តរជាតិ ឬការហោះហើរតាម ឬពីលើដែនសមុទ្រប្រជុំកោះ និងតាមផ្លូវទាំងនេះ ក្នុងវិសាលភាពមួយដែលទាក់ទិននឹងនាវា ផ្លូវនាវាចរណ៍ប្រក្រតីទាំងអស់ ក្នុងលក្ខខណ្ឌថា ការបង្កើតផ្លូវដូចគ្នាដែលមានភាពងាយស្រួលស្រដៀងគ្នាតភ្ជាប់រវាងចំណុចចូល និងចំណុចចេញគឺមិនចាំបាច់។

៥. ផ្លូវសមុទ្រ និងខ្សែអាកាសទាំងនេះត្រូវកំណត់ដោយខ្សែបន្ទាត់អ័ក្សជាប់ៗគ្នាជាបន្តបន្ទាប់ពី ចំណុចចូលរបស់ផ្លូវឆ្លងកាត់ទៅចំណុចចេញ។ នាវា និងអាកាសយានដែលឆ្លងកាត់តាមផ្លូវសមុទ្រប្រជុំកោះ មិនត្រូវងាកចេញពីគន្លងលើសពី ២៥ ម៉ៃល៍សមុទ្រទៅចំហៀងណាមួយនៃខ្សែបន្ទាត់អ័ក្សទាំងនេះក្នុងពេលឆ្លងកាត់ឡើយ ក្នុងលក្ខខណ្ឌថានាវា និងអាកាសយានទាំងនេះមិនចរក្បែរឆ្នេរសមុទ្រជាង ១០ ភាគរយនៃចម្ងាយរវាង ចំណុចដែលជិតបំផុតនៅលើបណ្ដាកោះដែលមានព្រំប្រទល់ជាប់នឹងផ្លូវសមុទ្រនោះ។

៦. រដ្ឋប្រជុំកោះដែលកំណត់ផ្លូវសមុទ្រក្រោមមាត្រានេះ ក៏អាចរៀបចំគម្រោងបែងចែកចរាចរណ៍សម្រាប់ការឆ្លងកាត់ប្រកបដោយសុវត្ថិភាពរបស់នាវា តាមច្រកឆ្លងកាត់ដ៏តូចចង្អៀតក្នុងផ្លូវសមុទ្រទាំងនេះផងដែរ។

៧. នៅពេលស្ថានភាពចាំបាច់បន្ទាប់ពីធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងត្រឹមត្រូវនោះ រដ្ឋប្រជុំកោះទាំងនេះអាចប្រើប្រាស់ផ្លូវសមុទ្រ ឬគម្រោងបែងចែកចរាចរណ៍ផ្សេងទៀត ជំនួសឱ្យផ្លូវសមុទ្រ ឬគម្រោងបែងចែកចរាចរណ៍ណាមួយដែលខ្លួនបានកំណត់ ឬរៀបចំកន្លងមក។

៨. ផ្លូវសមុទ្រ និងគម្រោងបែងចែកចរាចរណ៍ទាំងនេះត្រូវមានលក្ខណៈស្របទៅតាមបទបញ្ញត្តិអន្តរជាតិដែលមានការទទួលយកជាទូទៅ។

៩. ក្នុងការកំណត់ ឬប្រើប្រាស់ផ្លូវសមុទ្រជំនួស ឬធ្វើការរៀបចំ ឬប្រើប្រាស់គម្រោងបែងចែកចរាចរណ៍ជំនួស រដ្ឋប្រជុំកោះត្រូវលើកសំណើទៅ អង្គការអន្តរជាតិមានសមត្ថកិច្ច ទាក់ទិនទៅនឹងការរៀបចំរបស់ខ្លួន។ អង្គការអាចអនុម័តតែចំពោះផ្លូវសមុទ្រ និងគម្រោងបែងចែកចរាចរណ៍ណាដែលអាចទទួលបានការព្រមព្រៀងជាមួយនឹងបណ្ដារដ្ឋប្រជុំកោះនោះប៉ុណ្ណោះ បន្ទាប់ពីរដ្ឋប្រជុំកោះកំណត់ រៀបចំ ឬជំនួសវា។

១០. រដ្ឋប្រជុំកោះត្រូវបង្ហាញយ៉ាងច្បាស់លាស់អំពីអ័ក្សនៃផ្លូវសមុទ្រ និងគម្រោងបែងចែកចរាចរណ៍ដែលខ្លួនបានកំណត់ ឬបានរៀបចំនៅក្នុងតារាងដែលត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងត្រឹមត្រូវ។

១១. នាវាដែលឆ្លងកាត់ផ្លូវសមុទ្រប្រជុំកោះត្រូវគោរពគម្រោងបែងចែកចរាចរណ៍ និងផ្លូវសមុទ្រជាធរមានដែលកំណត់អនុលោមទៅតាមមាត្រានេះ។

១២. ប្រសិនបើរដ្ឋប្រជុំកោះមិនកំណត់អំពីផ្លូវសមុទ្រ ឬខ្សែបន្ទាត់លំហអាកាស នោះសិទ្ធិក្នុងការឆ្លងកាត់តាមផ្លូវសមុទ្រប្រជុំកោះអាចអនុវត្តតាមផ្លូវដែលប្រើប្រាស់ជាធម្មតាសម្រាប់នាវាចរណ៍អន្តរជាតិ។

មាត្រា ៥៤

ភារកិច្ចរបស់នាវា និងអាកាសយានក្នុងអំឡុងពេលនៃសកម្មភាពឆ្លងកាត់
អង្កេតស្រាវជ្រាវរបស់ខ្លួន ភារកិច្ចរបស់រដ្ឋប្រជុំកោះ ព្រមទាំងច្បាប់
និងបទបញ្ញត្តិរបស់រដ្ឋប្រជុំកោះ ទាក់ទិននឹងការឆ្លងកាត់តាមផ្លូវសមុទ្រប្រជុំកោះ

មាត្រា ៣៩,៤០,៤២ និង ៤៤ អនុវត្តចំពោះការឆ្លងកាត់តាមផ្លូវសមុទ្រប្រជុំកោះ ប្រសិនបើចាំបាច់។

## ផ្នែកទី៥៖ តំបន់សេដ្ឋកិច្ចផ្តាច់មុខ

*មាត្រា ៥៥*

*វិធានគតិយុត្តិជាក់លាក់របស់តំបន់សេដ្ឋកិច្ចផ្តាច់មុខ*

តំបន់សេដ្ឋកិច្ចផ្តាច់មុខគឺជាតំបន់ដែលលាតសន្ធឹងហួស និងជាប់នឹងសមុទ្រឆ្នេរ ដែលអនុលោមទៅតាមវិធានគតិយុត្តិជាក់លាក់ដែលបានកំណត់នៅក្នុងផ្នែកនេះ ដែលក្នុងនោះសិទ្ធិ និងយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរ ព្រមទាំងសិទ្ធិ និងសេរីភាពរបស់បណ្តារដ្ឋផ្សេងទៀតត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ។

*មាត្រា ៥៦*

*សិទ្ធិ យុត្តាធិការ និងភារកិច្ចរបស់រដ្ឋជាប់ឆ្នេរក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ*

១. ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ រដ្ឋជាប់ឆ្នេរមានៈ

(ក) សិទ្ធិអធិបតេយ្យក្នុងការរុករក និងធ្វើអាជីវកម្ម រក្សាទុក និងគ្រប់គ្រងនូវធនធានធម្មជាតិ មិនថាមានជីវិត ឬគ្មានជីវិត ក្នុងដែនសមុទ្រដែលនៅពីលើបាតសមុទ្រផ្ទាល់ និងក្នុងបាតសមុទ្រ និងដីស្រទាប់ក្រោមរបស់វា ព្រមទាំងទាក់ទិននឹងសកម្មភាពផ្សេងទៀតសម្រាប់ការធ្វើអាជីវកម្ម និងការរុករកផ្នែកសេដ្ឋកិច្ចក្នុងតំបន់នោះ ដូចជាផលិតកម្មថាមពលពីទឹក ចរន្ត និងខ្យល់ផងដែរ។

(ខ) យុត្តាធិការដែលបានចែងក្នុងបទបញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះទាក់ទិនទៅនឹងៈ

(i) ការបង្កើត និងការប្រើប្រាស់កោះសប្បនិម្មិត ឋបនភ័ណ្ឌ និងសំណង់។

(ii) ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក្នុងសមុទ្រ។

(iii) ការការពារ និងថែរក្សាបរិស្ថានសមុទ្រ។

(គ) សិទ្ធិ និងភារកិច្ចផ្សេងទៀតដែលមានចែងក្នុងអនុសញ្ញានេះ។

២. ក្នុងការអនុវត្តសិទ្ធិ និងភារកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ រដ្ឋជាប់ឆ្នេរត្រូវគោរពឱ្យបានត្រឹមត្រូវចំពោះសិទ្ធិ និងភារកិច្ចរបស់បណ្តារដ្ឋផ្សេងទៀត ព្រមទាំងត្រូវអនុវត្តក្នុងលក្ខណៈមួយស្របជាមួយនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ។

៣. សិទ្ធិដែលបានកំណត់នៅក្នុងមាត្រានេះ ទាក់ទិនទៅនឹងបាតសមុទ្រ និងដីស្រទាប់ក្រោមត្រូវអនុវត្តអនុលោមតាមផ្នែកទី ៦។

*មាត្រា ៥៧*

*រយៈទទឹងនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ*

តំបន់សេដ្ឋកិច្ចផ្តាច់មុខមិនត្រូវលាតសន្ធឹងហួសពី ២០០ ម៉ៃល៍សមុទ្រពីខ្សែបន្ទាត់មូលដ្ឋាន ដែលជាចំណុចចាប់ផ្តើមនៃសម្រាប់ការវាស់រយៈទទឹងសមុទ្រឆ្នេរនោះទេ។

*មាត្រា ៥៨*

*សិទ្ធិ និងភារកិច្ចរបស់បណ្តារដ្ឋផ្សេងទៀតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ*

១. នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ បណ្តារដ្ឋទាំងអស់ មិនថាមានឆ្នេរសមុទ្រ ឬ ហ៊ុំព័ទ្ធដោយដីគោកនោះទេ អនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ ត្រូវមានសេរីភាពដែលមានចែងក្នុងមាត្រា ៨៧ ស្តីពីការធ្វើនាវាចរណ៍ និងការហោះហើរពីលើ និងស្តីពីការរាយខ្សែកាប និងបំពង់នានានៅក្រោមសមុទ្រ និងការប្រើប្រាស់សមុទ្រដោយស្របច្បាប់អន្តរជាតិផ្សេងទៀត ទាក់ទិននឹងសេរីភាពទាំងនេះ ដូចជាការប្រើប្រាស់ពាក់ព័ន្ធនឹងប្រតិបត្តិការរបស់នាវា អាកាសយាន ខ្សែកាប្លិ៍ និងបំពង់នានានៅក្រោមសមុទ្រ ព្រមទាំងស្របទៅនឹងបទបញ្ញត្តិផ្សេងៗទៀតនៃអនុសញ្ញា នេះ។

២. មាត្រា ៨៨ ដល់ ១១៥ និងវិធានពាក់ព័ន្ធផ្សេងទៀតនៃច្បាប់អន្តរជាតិដែលអនុវត្តទៅលើតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដែលមិនមានលក្ខណៈផ្ទុយគ្នាជាមួយនឹងផ្នែកនេះ។

៣. ក្នុងការអនុវត្តសិទ្ធិ និងភារកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ បណ្តារដ្ឋត្រូវគោរពឱ្យបានត្រឹមត្រូវចំពោះសិទ្ធិ និងភារកិច្ចរបស់រដ្ឋជាប់ឆ្នេរ ព្រមទាំងត្រូវគោរពទៅតាមច្បាប់ និងបទបញ្ញត្តិដែលប្រើប្រាស់ដោយរដ្ឋជាប់ឆ្នេរ អនុលោមតាមបទបញ្ញត្តិនៃអនុសញ្ញានេះ និងវិធានដទៃទៀតនៃច្បាប់អន្តរជាតិ ក្នុងវិសាលភាពមួយដែលមិនផ្ទុយជាមួយនឹងផ្នែកនេះ។

*មាត្រា ៥៩*
*មូលដ្ឋានសម្រាប់ការដោះស្រាយវិវាទទាក់ទិននឹង*
*ការកំណត់អំពីចរិតលក្ខណៈនៃសិទ្ធិ និងយុត្តាធិការក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ*

ក្នុងករណីដែលអនុសញ្ញានេះមិនបានកំណត់អំពីចរិតលក្ខណៈនៃសិទ្ធិ ឬយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរ ឬបណ្តារដ្ឋផ្សេងទៀតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ហើយមានវិវាទកើតឡើងទាក់ទិននឹងផលប្រយោជន៍របស់រដ្ឋជាប់ឆ្នេរ និ រដ្ឋ ឬ បណ្តារដ្ឋផ្សេងទៀត នោះវិវាទនេះត្រូវដោះស្រាយដោយផ្អែកលើគោលការណ៍សមធម៌ជាមូលដ្ឋាន ហើយនៅក្នុងគ្រប់ស្ថានភាពពាក់ព័ន្ធទាំងអស់ ត្រូវគិតអំពីសារៈសំខាន់នីមួយៗនៃផលប្រយោជន៍ដែលពាក់ព័ន្ធចំពោះភាគីនៃវិវាទ ក៏ដូចជាចំពោះសហគមន៍អន្តរជាតិទាំងមូល។

*មាត្រា ៦០*
*កោះសប្បនិម្មិត បបនភ័ណ្ឌ និងសំណង់នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ*

១. នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ រដ្ឋជាប់ឆ្នេរត្រូវមានសិទ្ធិផ្តាច់មុខក្នុងការសាងសង់ និងក្នុងការអនុញ្ញាត និងធ្វើនិយ័តកម្មលើការសាងសង់ ប្រតិបត្តិការ និងការប្រើប្រាស់ ៖

(ក) កោះសប្បនិម្មិត។

(ខ) បបនភ័ណ្ឌ និងសំណង់នានាសម្រាប់គោលបំណងដែលមានចែងក្នុងមាត្រា ៥៦ និង សម្រាប់បុព្វហេតុសេដ្ឋកិច្ចផ្សេងទៀត ។

(គ) ឋបនភ័ណ្ឌ និងសំណង់ដែលអាចរំខានដល់ការអនុវត្តសិទ្ធិរបស់រដ្ឋជាប់ឆ្នេរនៅក្នុងតំបន់។

២. រដ្ឋជាប់ឆ្នេរត្រូវមានយុត្តាធិការផ្តាច់មុខលើកោះសប្បនិម្មិត ឋបនភ័ណ្ឌ និងសំណង់ទាំងនេះ រាប់បញ្ចូលទាំងយុត្តាធិការទាក់ទិនទៅនឹងច្បាប់ និង បទបញ្ញត្តិគយ សារពើពន្ធ សុខាភិបាល សុវត្ថិភាព និងអន្តោប្រវេសន៍។

៣. ការជូនដំណឹងត្រឹមត្រូវធ្វើឡើងស្តីពីការសាងសង់កោះសប្បនិម្មិត ឋបនភ័ណ្ឌ ឬ សំណង់ទាំងនេះ និង មធ្យោបាយអចិន្ត្រៃយ៍សម្រាប់ផ្តល់ការព្រមានឱ្យមានការថែទាំរចនាសម្ព័ន្ធទាំងនេះ។ រាល់ឋបនភ័ណ្ឌ ឬ សំណង់នានាដែលបោះបង់ចោល ឬឈប់ប្រើត្រូវរុះរើចេញដើម្បីធានាបាននូវសុវត្ថិភាពក្នុងការធ្វើនាវាចរណ៍ ដោយអនុលោមទៅតាមបទដ្ឋានអន្តរជាតិដែលមានការទទួលយកជាទូទៅ ដែលកំណត់ឡើងទាក់ទិននឹងបញ្ហានេះដោយអង្គការអន្តរជាតិមានសមត្ថកិច្ច។ ការរុះរើទាំងនេះក៏ត្រូវគោរពាឱ្យបានត្រឹមត្រូវចំពោះការនេសាទ ការការពារបរិស្ថានសមុទ្រ ព្រមទាំងសិទ្ធិ និងភារកិច្ចរបស់បណ្តារដ្ឋផ្សេងទៀតផងដែរ។ ការផ្សព្វផ្សាយជាសាធារណៈត្រឹមត្រូវអំពីជម្រៅ ទីតាំង និងវិមាត្ររបស់ឋបនភ័ណ្ឌ ឬសំណង់ដែលមិនបានរុះរើចេញទាំងស្រុងក៏ត្រូវមានការជូនដំណឹងជាសារធារណៈឱ្យបានត្រឹមត្រូវផងដែរ។

៤. ប្រសិនបើចាំបាច់ រដ្ឋជាប់ឆ្នេរអាចបង្កើតតំបន់សុវត្ថិភាពសមហេតុផលនៅជុំវិញកោះសប្បនិម្មិត ឋបនភ័ណ្ឌ និងសំណង់ទាំងនេះ ដែលក្នុងនោះខ្លួនអាចចាត់វិធានការសមស្របដើម្បីធានាបាននូវសុវត្ថិភាពក្នុងការធ្វើនាវាចរណ៍ និងសុវត្ថិភាពរបស់កោះសប្បនិម្មិត ឋបនភ័ណ្ឌ និងសំណង់ទាំងនោះ។

៥. ទទឹងនៃតំបន់សុវត្ថិភាពត្រូវកំណត់ដោយរដ្ឋជាប់ឆ្នេរ អនុលោមទៅតាមបទដ្ឋានអន្តរជាតិជាធរមាន។ តំបន់ទាំងនេះត្រូវបង្កើតឡើងដើម្បីធានាថា វាទាក់ទិនយ៉ាងសមហេតុផលទៅនឹងធម្មជាតិ និងមុខងាររបស់កោះសប្បនិម្មិត ឋបនភ័ណ្ឌ ឬ សំណង់ និងមិនត្រូវលើសពីចម្ងាយ ៥០០ ម៉ែត្រ ជុំវិញវា ដោយវាស់វែងពីចំណុចនីមួយៗនៃគែមខាងក្រៅរបស់វានោះទេ លើកលែងតែក្នុងករណីដែលបទដ្ឋានអន្តរជាតិដែលមានការទទួលយកជាទូទៅអនុញ្ញាត ឬតាមការណែនាំរបស់

អង្គការអន្តរជាតិមានសមត្ថកិច្ច។ ការជូនដំណឹងអំពីវិសាលភាពរបស់តំបន់សុវត្ថិភាពត្រូវធ្វើឡើងយ៉ាងត្រឹមត្រូវ។

៦. នាវាទាំងអស់ត្រូវគោរពតំបន់សុវត្ថិភាពទាំងនេះ និងត្រូវគោរពទៅតាមបទដ្ឋានអន្តរជាតិដែលទទួលស្គាល់ជាទូទៅ ទាក់ទិននឹងការធ្វើនាវាចរណ៍ ក្នុង បរិវេណកោះសប្បនិម្មិត ឋបនភ័ណ្ឌ សំណង់ និងតំបន់សុវត្ថិភាព។

៧. កោះសប្បនិម្មិត ឋបនភ័ណ្ឌ និងសំណង់ និង តំបន់សុវត្ថិភាពជុំវិញវាមិនអាចបង្កើតឡើងក្នុងលក្ខណៈដែលអាចរំខានដល់ការប្រើប្រាស់ផ្លូវសមុទ្រដែលបានទទួលស្គាល់ថាសំខាន់ចំពោះនាវាចរណ៍អន្តរជាតិឡើយ។

៨. កោះសប្បនិម្មិត ឋបនភ័ណ្ឌ និងសំណង់មិនមានស្ថានភាពជាកោះនោះទេ។ វាមិនមានសមុទ្រឆ្នេរផ្ទាល់របស់វា ហើយវត្តមានរបស់វាមិនមានផលប៉ះពាល់ដល់ការកំណត់ព្រំដែនរបស់សមុទ្រឆ្នេរ តំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬ ខ្ពង់រាបឡើយ។

*មាត្រា ៦១*

*ការអភិរក្សធនធានមានជីវិត*

១. រដ្ឋជាប់ឆ្នេរត្រូវកំណត់អំពីទិន្នផលធនធានមានជីវិតដែលអាចទទួលបាននៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន។

២. ដោយផ្អែកតាមភស្តុតាងផ្នែកវិទ្យាសាស្ត្រល្អបំផុតដែលខ្លួនមាន រដ្ឋជាប់ឆ្នេរត្រូវធានាតាមរយៈវិធានការអភិរក្ស និងគ្រប់គ្រងត្រឹមត្រូវ ថាការថែទាំធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខមិនត្រូវបានគំរាមកំហែងដោយការធ្វើអាជីវកម្មហួសកម្រិតឡើយ។ តាមដែលសមស្របរដ្ឋជាប់ឆ្នេរ និងអង្គការអន្តរជាតិមានសមត្ថកិច្ច មិនថាថ្នាក់អនុតំបន់ថ្នាក់តំបន់ ឬជាសកលនោះទេត្រូវសហប្រតិបត្តិការដើម្បីបុព្វហេតុនេះ។

៣. វិធានការទាំងនេះក៏ត្រូវបង្កើតឡើងដើម្បីថែរក្សា ឬស្តារនូវបរិមាណពូជមច្ឆាដែលបាននេសាទក្នុងកម្រិតដែលអាចផ្តល់នូវទិន្នផលអតិបរមាប្រកបដោយចិរភាព អនុលោមទៅតាមកត្តា

បរិស្ថាន និងសេដ្ឋកិច្ចដែលពាក់ព័ន្ធ រាប់បញ្ចូលទាំងតម្រូវការសេដ្ឋកិច្ចរបស់សហគមន៍នេសាទតាមតំបន់ឆ្នេរ និងលក្ខខណ្ឌពិសេសរបស់រដ្ឋកំពុងអភិវឌ្ឍន៍ ព្រមទាំងផ្អែកទៅលើទម្រង់នៃការនេសាទអន្តរនិស្សរភាពនៃស្តុក និងបទដ្ឋានអប្បបរមាជាអន្តរជាតិនានាដែលផ្តល់អនុសាសន៍ជាទូទៅ មិនថាថ្នាក់អនុតំបន់ ថ្នាក់តំបន់ ឬជាសកលនោះទេ។

៤. ក្នុងការអនុវត្តវិធានការទាំងនេះ រដ្ឋជាប់ឆ្នេរត្រូវពិចារណាអំពីផលប៉ះពាល់ទៅលើពូជមច្ឆាដែលពាក់ព័ន្ធនឹង ឬពឹងផ្អែកលើពូជមច្ឆាដែលនេសាទ ដើម្បីថែរក្សា ឬ ស្តារបរិមាណពូជមច្ឆាដែលពាក់ព័ន្ធ ឬពឹងផ្អែកទាំងនោះ ឱ្យបានលើកម្រិតដែលការបន្តពូជរបស់វាអាចរងការគំរាមកំហែងធ្ងន់ធ្ងរ។

៥. ព័ត៌មានវិទ្យាសាស្ត្រ ស្ថិតិស្តីពីទិន្នផល និងការនេសាទ និង ទិន្នន័យផ្សេងទៀតទាក់ទិនទៅនឹងការអភិរក្សស្តុកមច្ឆាត្រូវបានផ្តល់ និងចែករំលែកយ៉ាងទៀងទាត់តាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច មិនថាថ្នាក់អនុតំបន់ ថ្នាក់តំបន់ ឬជាសកលនោះទេ ក្នុងករណីដែលអាច និងដោយមានការចូលរួមពីបណ្តារដ្ឋទាំងអស់ដែលពាក់ព័ន្ធ រាប់បញ្ចូលទាំងបណ្តារដ្ឋដែលប្រជាជាតិខ្លួនត្រូវបានអនុញ្ញាតឱ្យធ្វើការនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ។

*មាត្រា ៦២*

*ការប្រើប្រាស់ធនធានមានជីវិត*

១. រដ្ឋជាប់ឆ្នេរ ត្រូវលើកកម្ពស់កម្មវត្ថុនៃការប្រើប្រាស់ឱ្យបានល្អបំផុតនូវធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដោយមិនឱ្យប៉ះពាល់ទៅដល់មាត្រា ៦១។

២. រដ្ឋជាប់ឆ្នេរ ត្រូវកំណត់អំពីសមត្ថភាពរបស់ខ្លួនក្នុងការប្រមូលផលធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ ក្នុងករណីរដ្ឋជាប់ឆ្នេរមិនមានសមត្ថភាពប្រមូលទិន្នផលដែលអាចទទួលបានទាំងស្រុង នោះតាមរយៈកិច្ចព្រមព្រៀង ឬការរៀបចំផ្សេងទៀត និងអនុលោមទៅតាមលក្ខខណ្ឌប្រការចែងច្បាប់ និងបទបញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌទី ៤ ខ្លួនត្រូវផ្តល់ជូនដល់បណ្តារដ្ឋផ្សេងទៀតនូវសិទ្ធិក្នុងការប្រមូលទិន្នផលដែលអាចទទួលបានលើសតម្រូវការ ដោយអនុលោមជាពិសេស

ទៅតាមបទបញ្ញត្តិនៃមាត្រា ៦៩ និង ៧០ ហើយជាពិសេសទាក់ទិនទៅនឹងរដ្ឋកំពុងអភិវឌ្ឍន៍ដែលមានចែងក្នុងមាត្រានោះ។

៣. ក្នុងការផ្តល់សិទ្ធិដល់បណ្តារដ្ឋផ្សេងទៀតក្នុងការចេញចូលតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួនក្រោមមាត្រានេះ រដ្ឋជាប់ឆ្នេរត្រូវពិចារណាទៅលើកត្តាពាក់ព័ន្ធទាំងអស់ ដែលមានជាអាទិ៍ សារៈសំខាន់នៃធនធានមានជីវិតរបស់តំបន់ចំពោះសេដ្ឋកិច្ចរបស់រដ្ឋជាប់ឆ្នេរដែលពាក់ព័ន្ធ និងផលប្រយោជន៍ជាតិផ្សេងទៀតរបស់ខ្លួន បទបញ្ញត្តិនៃមាត្រា ៦៩ និង ៧០ លក្ខខណ្ឌរបស់រដ្ឋកំពុងអភិវឌ្ឍន៍នៅក្នុង អនុតំបន់ ឬតំបន់ ទាក់ទិននឹងការប្រមូលផលលើសតម្រូវការ និង តម្រូវការក្នុងកាត់បន្ថយឱ្យនៅសល់តិចតួចបំផុត នូវភាពបែកខ្ញែកសេដ្ឋកិច្ចក្នុងបណ្តារដ្ឋដែលប្រជាជាតិមានទម្លាប់នេសាទនៅក្នុងតំបន់ ឬដែលបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងការស្រាវជ្រាវ និងកំណត់អត្តសញ្ញាណរបស់ស្តុក។

៤. ប្រជាជាតិនៃបណ្តារដ្ឋផ្សេងទៀតដែលនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ត្រូវគោរពទៅតាមវិធានការអភិរក្ស ព្រមទាំងលក្ខខណ្ឌ និងប្រការចែងផ្សេងទៀតដែលកំណត់នៅក្នុងច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋជាប់ឆ្នេរ។ ច្បាប់ និងបទបញ្ញត្តិទាំងនេះត្រូវស្របជាមួយនឹងអនុសញ្ញានេះ និងអាចជាអាទិ៍ ទាក់ទិនទៅនឹងចំណុចខាងក្រោមៈ

(ក) ការផ្តល់អាជ្ញាប័ណ្ណដល់ប្រជានេសាទ ទូកនេសាទ និងការប្រើប្រាស់សម្ភារបរិក្ខារ រាប់បញ្ចូលទាំងការបង់ថ្លៃ និងប្រាក់ក្នុងទម្រង់ផ្សេងទៀត ដែលក្នុងករណីរដ្ឋជាប់ឆ្នេរកំពុងអភិវឌ្ឍន៍ អាចមានផលតបស្នងគ្រប់គ្រាន់ក្នុងវិស័យហិរញ្ញប្បទាន សម្ភារបរិក្ខារ និងបច្ចេកវិទ្យាទាក់ទិននឹងវិស័យនេសាទ។

(ខ) ការកំណត់អំពីពូជមច្ឆាដែលអាចនេសាទបាន និងកំណត់អំពីកូតាទិន្នផល មិនថាទាក់ទិនទៅនឹងស្តុកជាក់លាក់ ឬចង្កោមស្តុក ឬទិន្នផលក្នុងមួយនាវាក្នុងអំឡុងពេលមួយ ឬទាក់ទិននឹងទិន្នផលនេសាទដោយប្រជាជាតិរបស់រដ្ឋណាមួយ ក្នុងអំឡុងពេលកំណត់មួយនោះឡើយ។

(គ) កំណត់អំពីរដូវ និងតំបន់នេសាទ ប្រភេទ ទំហំ និងចំនួនឧបករណ៍នេសាទ ព្រមទាំង ប្រភេទ ទំហំ និង ចំនួនទូកនេសាទដែលអាចប្រើប្រាស់បាន។

(យ) ការកំណត់អំពីអាយុ និងទំហំត្រី និងពូជមច្ឆាផ្សេងទៀតដែលអាចនេសាទ បាន។

(ង) ការកំណត់ជាក់លាក់អំពីព័ត៌មានចាំបាច់ស្ដីពីទូកនេសាទ រាប់បញ្ចូលទាំងស្ថិតិស្ដីពីទិន្នផល និងការចំណាយ ព្រមទាំងរបាយការណ៍ស្ដីពីស្ថានភាពរបស់នាវា។

(ច) ស្ថិតក្រោមការអនុញ្ញាត និងការត្រួតពិនិត្យរបស់រដ្ឋជាប់ឆ្នេរ ការទាមទារឱ្យមានកម្មវិធីស្រាវជ្រាវវិស័យជលផលតាមការកំណត់ និងការធ្វើនិយ័តកម្មលើការស្រាវជ្រាវទាំងនេះ រាប់បញ្ចូលទាំងការយកគំរូទិន្នផល ការសម្រេចអំពីគំរូ និងការរាយការណ៍ស្ដីពីទិន្នន័យផ្នែកវិទ្យាសាស្ត្រដែលពាក់ព័ន្ធ។

(ឆ) ការរៀបចំឱ្យមានអ្នកសង្កេតការណ៍ ឬសិក្ខាកាមនៅលើនាវាទាំងនេះដោយរដ្ឋជាប់ឆ្នេរ។

(ជ) ការចុះចតនាវាទំលាក់មួយផ្នែក ឬទាំងស្រុងនៅកំពង់ផែនៃរដ្ឋជាប់ឆ្នេរ។

(ឈ) លក្ខខណ្ឌ និងប្រការចែងទាក់ទិននឹងបុត្រសម្ព័ន្ធ ឬ កិច្ចសហប្រតិបត្តិការផ្សេងទៀត។

(ញ) លក្ខខណ្ឌសម្រាប់ការបណ្ដុះបណ្ដាលបុគ្គលិក និងការផ្ទេរបច្ចេកវិទ្យានេសាទ រាប់បញ្ចូល ទាំងការពង្រឹងសមត្ថភាពរបស់រដ្ឋជាប់ឆ្នេរក្នុងការអនុវត្តការស្រាវជ្រាវផ្នែកជលផល។

(ដ) នីតិវិធីពង្រឹង

៥. រដ្ឋជាប់ឆ្នេរត្រូវជូនដំណឹងឱ្យបានត្រឹមត្រូវស្ដីពីច្បាប់ និង បទបញ្ញត្តិស្ដីពីកិច្ចអភិរក្ស និងការគ្រប់គ្រង។

## មាត្រា ៦៣

*ស្តុកដែលមាននៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃរដ្ឋពីរ ឬច្រើនដែលមានឆ្នេរសមុទ្រ ឬនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខផង នៅក្នុងតំបន់លាសន្ទឹងហួសពី និងដែលនៅជាប់នឹងវាផង*

១. ក្នុងករណីដែលមានស្តុកពូជមច្ឆាដែលពាក់ព័ន្ធដូចគ្នានៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខពីរ ឬច្រើនមានឆ្នេរសមុទ្រ នោះបណ្តារដ្ឋទាំងនេះត្រូវព្យាយាមដោយផ្ទាល់ ឬតាមរយៈអង្គការអនុតំបន់ ឬថ្នាក់តំបន់សមស្រប យល់ព្រមទៅលើវិធានការចាំបាច់ដើម្បីសម្របសម្រួល និងធានាបាននូវការអភិរក្ស និងការអភិវឌ្ឍស្តុកទាំងនេះ ដោយមិនប៉ះពាល់ទៅដល់ បទបញ្ញត្តិផ្សេងៗទៀតនៃផ្នែកនេះ។

២. ក្នុងករណីដែលមានស្តុកពូជមច្ឆាដែលពាក់ព័ន្ធដូចគ្នាទាំងនៅក្នុងតំបន់សេដ្ឋកិច្ច ផ្តាច់មុខ និងនៅក្នុងតំបន់ហួសពី និងដែលនៅជាប់នឹងតំបន់នោះ រដ្ឋជាប់ឆ្នេរ និងរដ្ឋនេសាទស្តុកទាំងនេះនៅក្នុងតំបន់ជាប់នោះ ត្រូវព្យាយាមដោយផ្ទាល់ ឬតាមរយៈអង្គការអនុតំបន់ ឬថ្នាក់តំបន់សមស្រប យល់ព្រមទៅលើវិធានការចាំបាច់ដើម្បីសម្របសម្រួល និងធានាបាននូវការអភិរក្សស្តុកទាំងនេះនៅតំបន់ជាប់នោះ។

## *មាត្រា ៦៤*

*ពូជមច្ឆាដែលមានបំលាស់ទីខ្ពស់*

១. រដ្ឋជាប់ឆ្នេរ និងបណ្តារដ្ឋផ្សេងទៀតដែលមានប្រជាជាតិធ្វើការនេសាទក្នុងតំបន់នូវពូជមច្ឆាដែលមានបំលាស់ ទីខ្ពស់ ដូចមានរាយឈ្មោះក្នុងឧបសម្ព័ន្ធ ១ ត្រូវសហប្រតិបត្តិការដោយ ផ្ទាល់ ឬ តាមរយៈអង្គការអន្តរជាតិសមស្រប ធ្វើយ៉ាងណាមធានាឱ្យបាននូវការអភិរក្ស និងការលើកកម្ពស់កម្មវត្ថុនៃការប្រើប្រាស់ឱ្យបានល្អបំផុតនូវពូជមច្ឆាទាំងនេះនៅទូទាំងតំបន់ ទាំងក្នុង និងហួសពីតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ ក្នុងតំបន់ដែលពុំមានអង្គការអន្តរជាតិសមស្រប រដ្ឋជាប់ឆ្នេរ និងបណ្តារដ្ឋ

ផ្សេងទៀតដែលមានប្រជាជាតិធ្វើការនេសាទពូជមច្ឆាទាំងនេះ ក្នុងតំបន់ត្រូវសហប្រតិបត្តិការបង្កើតអង្គការទាំងនេះ និងចូលរួមក្នុងកិច្ចការរបស់អង្គការ។

២. បទបញ្ញត្តិនៃកថាខណ្ឌទី ១ ត្រូវអនុវត្តអនុវត្តបន្ថែមលើបទបញ្ញត្តិផ្សេងៗទៀតនៃផ្នែកនេះ។

*មាត្រា ៦៥*

*ថនិកសត្វសមុទ្រ*

គ្មានចំណុចណាមួយក្នុងផ្នែកនេះរារាំងដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរ ឬ សមត្ថកិច្ចរបស់អង្គការអន្តរជាតិ ប្រសិន បើសមស្រប ក្នុងការហាមឃាត់ ដាក់កម្រិត ឬធ្វើនិយតកម្មលើការធ្វើអាជីវកម្មថនិកសត្វសមុទ្រ ក្នុងកម្រិតមួយ តឹងរ៉ឹងជាង បទបញ្ញត្តិដែលមានចែងក្នុងផ្នែកនេះនោះទេ។ បណ្ដារដ្ឋត្រូវសហប្រតិបត្តិការធ្វើយ៉ាងណាអភិរក្សឱ្យ បាននូវថនិកសត្វសមុទ្រ និងក្នុងករណីត្រីផ្សោត ត្រូវអនុវត្តជាពិសេសតាមរយៈ អង្គការអន្តរជាតិសមស្រប ដើម្បីការអភិរក្ស ការគ្រប់គ្រង និងការសិក្សារបស់ខ្លួន។

*មាត្រា ៦៦*

*ស្តុកមច្ឆាមិនពងក្នុងសមុទ្រ*

១. បណ្ដារដ្ឋក្នុងដែលមានស្តុកមច្ឆាមិនពងក្នុងសមុទ្របង្កកំណើតក្នុងទន្លេត្រូវមានផលប្រយោជន៍ចម្បងនៅក្នុង និងត្រូវទទួលខុសត្រូវទៅលើស្តុកទាំងនេះ។

២. រដ្ឋប្រភពដើមរបស់ស្តុកមច្ឆាមិនពងក្នុងសមុទ្រត្រូវធានាឱ្យបាននូវការអភិរក្សរបស់ខ្លួនតាមរយៈការរៀបចំនូវវិធានការគ្រប់គ្រងសមស្របសម្រាប់ការនេសាទនៅក្នុងដែនសមុទ្រទាំងអស់ដែលបែរទៅរកដីគោកនៃព្រំដែនខាងនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ខ្លួន និងសម្រាប់ការនេសាទដែលមានចែងក្នុងកថាខណ្ឌទី ៣(ខ)។ បន្ទាប់ពីប្រឹក្សាជាមួយនឹងបណ្ដារដ្ឋផ្សេងទៀត ដែលមាន ចែងក្នុង

កថាខណ្ឌទី៣ និង ៤ រដ្ឋប្រភពដើម ដែលនេសាទស្តុកមច្ឆាទាំងនេះ អាចរៀបចំនូវទិន្នផលដែលអាចទទួលបានសរុបសម្រាប់ស្តុកមច្ឆាដែលមានដើមកំណើតក្នុងទន្លេរបស់ខ្លួន។

៣. (ក) ការនេសាទស្តុកមច្ឆាដែលមិនពងក្នុងសមុទ្រត្រូវធ្វើឡើងតែក្នុងដែលសមុទ្រដែលបែរទៅរកដីគោកនៃព្រំដែនខាងក្រៅរបស់តំបន់សេដ្ឋកិច្ចផ្តាច់មុខ ប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលបទបញ្ញត្តិនេះនាំឱ្យមានការបង្វែរ ទិសដៅសេដ្ឋកិច្ចនៃរដ្ឋក្រៅពីរដ្ឋដែលជាប្រភពស្តុកមច្ឆាប៉ុណ្ណោះ។ ទាក់ទិនទៅនឹងការនេសាទហួសពីព្រំដែនខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខនោះ បណ្តារដ្ឋដែលពាក់ព័ន្ធត្រូវរក្សាប្រឹក្សាគ្នាធ្វើយ៉ាងណាសម្រេចឱ្យបាននូវកិច្ចព្រមព្រៀងស្តីពីលក្ខខណ្ឌ និងប្រការចែងលើការនេសាទទាំងនេះ ដោយគោរពឱ្យបានត្រឹមត្រូវចំពោះលក្ខខណ្ឌអភិរក្ស និងតម្រូវការរបស់រដ្ឋប្រភពដើមទាក់ទិនទៅនឹងស្តុកមច្ឆាទាំងនេះ។

(ខ) រដ្ឋប្រភពដើមត្រូវសហការក្នុងការកាត់បន្ថយឱ្យនៅតិចតួចបំផុតនូវភាពបែកខ្ញែកសេដ្ឋកិច្ចក្នុងបណ្តារដ្ឋផ្សេងទៀតដែលនេសាទស្តុកមច្ឆាទាំងនេះ ដោយពិចារណាទៅលើទិន្នផលប្រក្រតី និងរបៀបប្រតិបត្តិការរបស់បណ្តារដ្ឋទាំងនេះ ព្រមទាំងតំបន់ទាំងអស់ដែលក្នុងនោះមានការនេសាទទាំងនេះ។

(គ) បណ្តារដ្ឋដែលមានចែងក្នុងកថាខណ្ឌរង (ខ) ដែលបានចូលរួមផ្អែកតាមកិច្ចព្រមព្រៀងជាមួយនឹងរដ្ឋប្រភពដើម ក្នុងការចាត់វិធានការស្តារឡើងវិញនូវស្តុកមច្ឆាមិនពងក្នុងសមុទ្រ ជាពិសេសតាមរយៈការចំណាយដើម្បីគោលបំណងនោះ ត្រូវទទួលបានការពិចារណាជាពិសេសពីរដ្ឋដែលជាប្រភពដើមនៃការនេសាទស្តុកមច្ឆាដែលមានប្រភពដើមនៅក្នុងទន្លេរបស់ខ្លួន។

(ឃ) ការពង្រឹងបទបញ្ញត្តិទាក់ទិននឹងស្តុកមច្ឆាមិនពងក្នុងសមុទ្រហួសពីតំបន់សេដ្ឋកិច្ចផ្តាច់មុខ ត្រូវធ្វើឡើងតាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋដែលជាប្រភពនៃស្តុកមច្ឆា និង បណ្តារដ្ឋផ្សេងទៀតដែលពាក់ព័ន្ធ។

៤. ក្នុងករណីដែលស្តុកមច្ឆាមិនពងក្នុងសមុទ្រ ផ្លាស់ទីលំនៅតាមរដូវទៅក្នុង ឬតាមដែនសមុទ្រដែលបែរទៅរកដីគោកនៃព្រំដែនខាងក្រៅរបស់តំបន់សេដ្ឋកិច្ចផ្តាច់មុខនៃរដ្ឋក្រៅពីរដ្ឋដែលជាប្រភពដើម នោះរដ្ឋនេះត្រូវសហប្រតិបត្តិការជាមួយនឹងរដ្ឋប្រភពដើម ទាក់ទិនទៅនឹងការអភិរក្ស និងការគ្រប់គ្រងស្តុកមច្ឆាទាំងនេះ។

៥. រដ្ឋប្រភពដើមនៃស្តុកមច្ឆាមិនពងក្នុងសមុទ្រ និង បណ្តារដ្ឋផ្សេងទៀតដែលនេសាទស្តុកមច្ឆាទាំងនេះត្រូវរៀបចំធ្វើការអនុវត្តបទបញ្ញត្តិនៃមាត្រានេះ ប្រសិនបើអាច តាមរយៈអង្គការថ្នាក់តំបន់។

*មាត្រា ៦៧*

*ពូជត្រីពងក្នុងសមុទ្រ*

១. រដ្ឋជាប់ឆ្នេរដែលពូជត្រីពងក្នុងសមុទ្រចំណាយជីវិតភាគច្រើនរបស់វានាំនៅក្នុងដែនសមុទ្រ របស់ខ្លួនត្រូវទទួលខុសត្រូវលើការគ្រប់គ្រងពូជមច្ឆាទាំងនេះ និងត្រូវធានាឱ្យបាននូវច្រកចេញចូលរបស់ពូជត្រីផ្លាស់ទីលំនៅតាមរដូវ។

២. ការនេសាទពូជត្រីពងក្នុងសមុទ្រត្រូវធ្វើឡើងតែក្នុងដែនសមុទ្រដែលបែរទៅរកដីគោក នៃព្រំដែនខាងក្រៅរបស់តំបន់សេដ្ឋកិច្ចផ្តាច់មុខប៉ុណ្ណោះ។ នៅពេលធ្វើឡើងក្នុងតំបន់សេដ្ឋកិច្ច ផ្តាច់មុខ ការនេសាទត្រូវអនុលោមទៅតាមមាត្រានេះ និងបទបញ្ញត្តិផ្សេងៗទៀតនៃអនុសញ្ញានេះពាក់ព័ន្ធទៅនឹងការនេសាទក្នុងតំបន់ទាំងនេះ។

៣. ក្នុងករណីដែលត្រីពងក្នុងសមុទ្រផ្លាស់ទីលំនៅតាមរដូវតាមតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋមួយផ្សេងទៀត មិនថាជាត្រីមិនទាន់ពេញវ័យ ឬពេញវ័យនោះទេ ការគ្រប់គ្រង រាប់បញ្ចូលទាំងការនេសាទត្រីទាំងនេះត្រូវគ្រប់គ្រង ដោយកិច្ចព្រមព្រៀងរវាងរដ្ឋដែលបានលើកឡើងក្នុង កថាខណ្ឌទី ១ និងបណ្តារដ្ឋផ្សេងទៀតដែលពាក់ព័ន្ធ។ កិច្ចព្រមព្រៀងទាំងនេះត្រូវធានាឱ្យបាននូវការគ្រប់គ្រងយ៉ាងសមហេតុផលនូវពូជមច្ឆា និងយកចិត្តទុកដាក់ទៅលើការទទួលខុសត្រូវរបស់រដ្ឋដែលបានលើកឡើងក្នុងកថាខណ្ឌទី ១ សម្រាប់ការថែទាំពូជមច្ឆាទាំងនេះ។

*មាត្រា ៦៨*

*ពូជមច្ឆារស់នៅមួយកន្លែង*

ផ្នែកនេះមិនអនុវត្តទៅលើពូជមច្ឆារស់នៅមួយកន្លែង ដូចបានកំណត់ក្នុងមាត្រា ៧៧ កថាខណ្ឌទី ៤ នោះទេ។

មាត្រា ៦៩

*សិទ្ធិរបស់បណ្តារដ្ឋហ៊ុំព័ទ្ធដោយដីគោក*

១. បណ្តារដ្ឋហ៊ុំព័ទ្ធដោយដីគោកត្រូវមានសិទ្ធិចូលរួម ផ្អែកលើមូលដ្ឋានសមធម៌ក្នុងការធ្វើអាជីវកម្មលើផ្នែកលើសតម្រូវការសមស្របនៃធនធានមានជីវិតនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរដែលស្ថិតនៅក្នុងអនុតំបន់ ឬតំបន់តែមួយ ដោយពិចារណាទៅលើ ស្ថានភាពសេដ្ឋកិច្ច និងភូមិសាស្ត្រពាក់ព័ន្ធរបស់រដ្ឋទាំងអស់ដែលពាក់ព័ន្ធ និងអនុលោមទៅតាមបទបញ្ញត្តិនៃមាត្រានេះ និងមាត្រា ៦១ និង ៦២។

២. លក្ខខណ្ឌ និងទម្រង់នៃការចូលរួមទាំងនេះត្រូវកំណត់ដោយបណ្តារដ្ឋដែលពាក់ព័ន្ធតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ថ្នាក់អនុតំបន់ ឬ ថ្នាក់តំបន់ ដោយពិចារណាជាអាទិ៍ទៅលើៈ

(ក) ភាពចាំបាច់ក្នុងការបញ្ចៀសផលប៉ះពាល់មិនល្អលើសហគមន៍នេសាទ ឬវិស័យនេសាទរបស់រដ្ឋជាប់ឆ្នេរ។

(ខ) វិសាលភាពដែលរដ្ឋហ៊ុំព័ទ្ធដោយដីគោក អនុលោមតាមបទបញ្ញត្តិនៃមាត្រានេះ កំពុងចូលរួម ឬមានសិទ្ធិចូលរួម ក្រោមកិច្ចព្រមព្រៀងទ្វេភាគី ថ្នាក់អនុតំបន់ ឬថ្នាក់តំបន់ដែលមានស្រាប់ ក្នុងការធ្វើអាជីវកម្មធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ របស់រដ្ឋជាប់ឆ្នេរផ្សេងទៀត។

(គ) វិសាលភាពដែលបណ្តារដ្ឋហ៊ុំព័ទ្ធដោយដីគោកផ្សេងទៀត និងបណ្តារដ្ឋដែលមានគុណវិបត្តិភូមិសាស្ត្រកំពុងចូលរួមក្នុងការធ្វើអាជីវកម្មធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរ និងបន្ទាប់ពីនោះ តម្រូវការក្នុងការបញ្ចៀងនូវបន្ទុកជាក់លាក់សម្រាប់រដ្ឋជាប់ឆ្នេរណាតែមួយ ឬផ្នែកមួយរបស់វា។

(ឃ) តម្រូវការអាហារូបត្ថម្ភរបស់ប្រជាជនរបស់បណ្តារដ្ឋនីមួយៗ។

៣. នៅពេលសមត្ថភាពនេសាទរបស់រដ្ឋជាប់ឆ្នេរឈានដល់ចំណុចមួយដែលអាចឱ្យខ្លួននេសាទបាននូវទិន្នផលដែលអាចទទួលបានទាំងមូលនៃធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន នោះរដ្ឋជាប់ឆ្នេរ និងបណ្តារដ្ឋផ្សេងទៀតដែលពាក់ព័ន្ធត្រូវសហការគ្នាធ្វើការរៀបចំមួយ

ប្រកបដោយសមធម៌ផ្អែកលើមូលដ្ឋានទ្វេភាគី ថ្នាក់អនុតំបន់ ឬថ្នាក់តំបន់ ដើម្បីអនុញ្ញាតដល់ការចូលរួមរបស់បណ្តារដ្ឋហ៊ុំព័ទ្ធដោយដីគោកដែលកំពុងអភិវឌ្ឍន៍នៅក្នុងអនុតំបន់ ឬតំបន់តែមួយក្នុងការធ្វើអាជីវកម្មធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរក្នុងអនុតំបន់ ឬតំបន់ តាមដែលអាច ក្នុងស្ថានភាព និងលក្ខខណ្ឌដែលជាទីពេញចិត្តរបស់ភាគីទាំងអស់។ ក្នុងការអនុវត្តបទបញ្ញត្តិនេះ ក៏ត្រូវពិចារណាទៅលើកត្តាដែលបានលើកឡើងក្នុងកថាខណ្ឌទី ២ ផងដែរ។

៤. ក្រោមបទបញ្ញត្តិនៃមាត្រានេះ បណ្តារដ្ឋអភិវឌ្ឍន៍ដែលហ៊ុំព័ទ្ធដោយដីគោកត្រូវមានសិទ្ធិចូលរួមក្នុងការធ្វើអាជីវកម្មធនធានមានជីវិតតែក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋអភិវឌ្ឍន៍ដែលមានឆ្នេរសមុទ្រក្នុងអនុតំបន់ ឬ តំបន់តែមួយ ផ្អែកទៅតាមវិសាលភាពដែលរដ្ឋជាប់ឆ្នេរ ក្នុងការផ្តល់សិទ្ធិដល់បណ្តារដ្ឋផ្សេងទៀតឱ្យធ្វើការនេសាទធនធានមានជីវិត ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន បានពិចារណាទៅលើតម្រូវការក្នុងការកាត់បន្ថយឱ្យនៅសល់តិចតួចបំផុតនូវផលប៉ះពាល់មិនល្អលើសហគមន៍នេសាទ និងភាពបែកខ្ញែកសេដ្ឋកិច្ចក្នុងបណ្តារដ្ឋដែលប្រជាជាតិមានទម្លាប់នេសាទក្នុង តំបន់។

៥. បទបញ្ញត្តិខាងលើមិនប៉ះពាល់ទៅដល់ការរៀបចំដែលបានព្រមព្រៀងនៅក្នុងអនុតំបន់ ឬ តំបន់ដែលរដ្ឋជាប់ឆ្នេរអាចផ្តល់ជូនបណ្តារដ្ឋហ៊ុំព័ទ្ធដោយដីគោកក្នុងអនុតំបន់ ឬ តំបន់តែមួយនូវសិទ្ធិស្មើគ្នា ឬសិទ្ធិអនុគ្រោះ សម្រាប់ការធ្វើអាជីវកម្មធនធានមានជីវិត ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនោះឡើយ។

*មាត្រា ៧០*

*សិទ្ធិរបស់បណ្តារដ្ឋដែលមានគុណវិបត្តិភូមិសាស្ត្រ*

១. បណ្តារដ្ឋដែលមានគុណវិបត្តិភូមិសាស្ត្រត្រូវមានសិទ្ធិចូលរួម ផ្អែកលើមូលដ្ឋានសមធម៌ក្នុងការធ្វើអាជីវកម្មលើផ្នែកលើសតម្រូវការសមស្របនៃធនធានមានជីវិតនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរដែលស្ថិតនៅក្នុងអនុតំបន់ ឬតំបន់តែមួយ ដោយពិចារណាទៅលើ ស្ថានភាព សេដ្ឋកិច្ច និងភូមិសាស្ត្រពាក់ព័ន្ធរបស់រដ្ឋទាំងអស់ដែលពាក់ព័ន្ធ និងអនុលោមទៅតាមបទបញ្ញត្តិនៃ មាត្រានេះ និងមាត្រា ៦១ និង ៦២។

២.	សម្រាប់គោលបំណងនៃផ្នែកនេះ "បណ្តារដ្ឋដែលមានគុណវិបត្តិភូមិសាស្ត្រ " មានន័យថា បណ្តារដ្ឋជាប់ឆ្នេរ រាប់បញ្ចូលទាំងបណ្តារដ្ឋដែលមានព្រំប្រទល់ជាប់នឹងសមុទ្របិទជិត ឬពាក់កណ្តាលបិទជិត ដែលមានស្ថានភាពភូមិសាស្ត្រធ្វើរដ្ឋទាំងនោះពឹងផ្អែកទៅលើការធ្វើអាជីវកម្មធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់បណ្តារដ្ឋផ្សេងទៀត ក្នុងអនុតំបន់ ឬ តំបន់ ដើម្បីទទួលបានទិន្នផលត្រីគ្រប់គ្រាន់សម្រាប់ជាអាហារូបត្ថម្ភរបស់ប្រជាជនខ្លួន ឬ ផ្នែកមួយនៃប្រជាជន នោះ និងរដ្ឋជាប់ឆ្នេរដែលមិនអាចបក្រាសអំពីតំបន់សេដ្ឋកិច្ចផ្តាច់មុខផ្ទាល់របស់ខ្លួន។

៣.	លក្ខខណ្ឌ និងទម្រង់នៃការចូលរួមទាំងនេះត្រូវកំណត់ដោយបណ្តារដ្ឋដែលពាក់ព័ន្ធតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ថ្នាក់អនុតំបន់ ឬ ថ្នាក់តំបន់ ដោយពិចារណាជាអាទិ៍ទៅលើៈ

(ក)	ភាពចាំបាច់ក្នុងការបញ្ចៀសផលប៉ះពាល់មិនល្អលើសហគមន៍នេសាទ ឬ វិស័យនេសាទរបស់រដ្ឋជាប់ឆ្នេរ។

(ខ)	វិសាលភាពដែលបណ្តារដ្ឋដែលមានគុណវិបត្តិភូមិសាស្ត្រ អនុលោមតាមបទបញ្ញត្តិនៃមាត្រានេះ កំពុងចូលរួម ឬមានសិទ្ធិចូលរួម ក្រោមកិច្ចព្រមព្រៀងទ្វេភាគី ថ្នាក់អនុតំបន់ ឬថ្នាក់តំបន់ដែលមានស្រាប់ ក្នុងការធ្វើអាជីវកម្មធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរផ្សេងទៀត។

(គ)	វិសាលភាពដែលបណ្តារដ្ឋដែលមានគុណវិបត្តិភូមិសាស្ត្រផ្សេងទៀត និងបណ្តារដ្ឋហ៊ុំព័ទ្ធដោយដីគោកកំពុងចូលរួមក្នុងការធ្វើអាជីវកម្មធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរ និងបន្ទាប់ពីនោះ តម្រូវការក្នុងការបញ្ចៀងនូវបន្ទុកជាក់លាក់សម្រាប់រដ្ឋជាប់ឆ្នេរណាតែមួយ ឬផ្នែកមួយរបស់វា។

(ឃ)	តម្រូវការអាហារូបត្ថម្ភរបស់ប្រជាជនរបស់បណ្តារដ្ឋនីមួយៗ។

៤.	នៅពេលសមត្ថភាពនេសាទរបស់រដ្ឋជាប់ឆ្នេរឈានដល់ចំណុចមួយដែលអាចឱ្យខ្លួននេសាទបាននូវទិន្នផលដែលអាចទទួលបានទាំងមូលនៃធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន នោះរដ្ឋជាប់ឆ្នេរ និងបណ្តារដ្ឋផ្សេងទៀតដែលពាក់ព័ន្ធត្រូវសហការគ្នាធ្វើការរៀបចំមួយប្រកបដោយសមធម៌ផ្អែកលើមូលដ្ឋានទ្វេភាគី ថ្នាក់អនុតំបន់ ឬថ្នាក់តំបន់ ដើម្បីអនុញ្ញាតដល់ការ

ចូលរួមរបស់បណ្ដារដ្ឋដែលមានគុណវិបត្តិភូមិសាស្ត្រដែលកំពុងអភិវឌ្ឍន៍នៅក្នុងអនុតំបន់ ឬតំបន់តែមួយក្នុងការធ្វើអាជីវកម្មធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់រដ្ឋជាប់ឆ្នេរក្នុងអនុតំបន់ ឬតំបន់តាមដែលអាចក្នុងស្ថានភាព និងលក្ខខណ្ឌដែលជាទីពេញចិត្តរបស់ភាគីទាំងអស់។ ក្នុងការអនុវត្តបទបញ្ញត្តិនេះ ក៏ត្រូវពិចារណាទៅលើកត្តាដែលបានលើកឡើងក្នុងកថាខណ្ឌទី ៣ ផងដែរ។

៥. ក្រោមបទបញ្ញត្តិនៃមាត្រានេះ បណ្ដារដ្ឋអភិវឌ្ឍន៍ដែលមានគុណវិបត្តិភូមិសាស្ត្រត្រូវមានសិទ្ធិចូលរួមក្នុងការធ្វើអាជីវកម្មធនធានមានជីវិតតែក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់រដ្ឋអភិវឌ្ឍន៍ដែលមានឆ្នេរសមុទ្រក្នុងអនុតំបន់ ឬតំបន់តែមួយផ្អែកទៅតាមវិសាលភាពដែលរដ្ឋជាប់ឆ្នេរ ក្នុងការផ្ដល់សិទ្ធិដល់បណ្ដារដ្ឋផ្សេងទៀតឱ្យធ្វើការនេសាទធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ខ្លួនបានពិចារណាទៅលើតម្រូវការក្នុងការកាត់បន្ថយឱ្យនៅសល់តិចតួចបំផុតនូវផលប៉ះពាល់មិនល្អលើសហគមន៍នេសាទ និងភាពបែកខ្ញែកសេដ្ឋកិច្ចក្នុងបណ្ដារដ្ឋដែលប្រជាជាតិមានទម្លាប់នេសាទក្នុងតំបន់។

៦. បទបញ្ញត្តិខាងលើមិនប៉ះពាល់ទៅដល់ការរៀបចំដែលបានព្រមព្រៀងនៅក្នុងអនុតំបន់ ឬតំបន់ដែលរដ្ឋ ជាប់ឆ្នេរអាចផ្ដល់ជូនបណ្ដារដ្ឋដែលមានគុណវិបត្តិភូមិសាស្ត្រក្នុងអនុតំបន់ ឬតំបន់តែមួយនូវសិទ្ធិស្មើគ្នា ឬ សិទ្ធិ អនុគ្រោះ សម្រាប់ការធ្វើអាជីវកម្មធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចនោះឡើយ។

*មាត្រា ៧១*

*ការមិនអាចឱ្យអនុវត្តបាននូវមាត្រា ៦៩ និង ៧០*

បទបញ្ញត្តិនៃមាត្រា ៦៩ និង ៧០ មិនត្រូវយកមកអនុវត្តក្នុងករណីដែលរដ្ឋជាប់ឆ្នេរមានសេដ្ឋកិច្ចពឹងផ្អែក យ៉ាងខ្លាំងក្លាទៅលើការធ្វើអាជីវកម្មធនធានមានជីវិតនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ខ្លួន។

*មាត្រា ៧២*

*ការដាក់កំហិតលើការផ្ទេរសិទ្ធិ*

១. សិទ្ធិដែលមានចែងក្នុងមាត្រា ៦៩ និង៧០ លើការធ្វើអាជីវកម្មធនធានមានជីវិត មិនត្រូវបានផ្ទេរទៅឱ្យ ភាគីរដ្ឋទីបី ឬពលរដ្ឋនៃរដ្ឋនោះ ទោះជាដោយផ្ទាល់ ឬដោយប្រយោល មិនថា ក្រោមភតិសន្យា ឬ ការ ផ្តល់អាជ្ញាប័ណ្ណ ដោយការបង្កើតសម្ព័ន្ធអាជីវកម្ម ឬតាមរូបភាពផ្សេងទៀត ដែលមានឥទ្ធិពលលើការ ផ្ទេរខាងលើឡើយ លុះត្រាតែមានការឯកភាពពីរដ្ឋដែលពាក់ព័ន្ធ។

២. បទបញ្ញត្តិខាងលើមិនត្រូវរារាំងដល់រដ្ឋដែលពាក់ព័ន្ធ ក្នុងការទទួលបានជំនួយផ្នែក បច្ចេកទេស ឬហិរញ្ញវត្ថុពីរដ្ឋទីបី ឬអង្គការអន្តរជាតិនានា ដើម្បីសម្រួយដល់ការអនុវត្តនូវសិទ្ធិ ដូចមានចែងស្របតាមមាត្រា ៦៩ និង៧០ កាលបើវាមិនបង្កើតឱ្យមានផលប៉ះពាល់ដូចដែលមាន ចែងក្នុងកថាខណ្ឌទី ១។

*មាត្រា ៧៣*

*ការពង្រឹងច្បាប់ និងបទបញ្ញត្តិនៃរដ្ឋជាប់ឆ្នេរ*

១. នៅក្នុងការអនុវត្តសិទ្ធិអធិបតេយ្យភាពរបស់ខ្លួននៅក្នុងការរុករក ការធ្វើអាជីវកម្ម ការអភិរក្ស និង គ្រប់គ្រងធនធានមានជីវិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ រដ្ឋជាប់ឆ្នេរអាចមាន ចំណាត់ការផ្សេងៗ មាន ជាអាទិ៍ ការត្រួតពិនិត្យលើនាវា ការធ្វើអធិការកិច្ច ការឃាត់ទុក និងបណ្តឹង តុលាការតាមករណីដែលចាំបាច់ ដើម្បីធានាបានការអនុវត្តតាមច្បាប់ និងបទបញ្ញត្តិដែលរដ្ឋពាក់ព័ន្ធ បង្កើតឡើងស្របតាមអនុសញ្ញានេះ។

២. នាវា និងក្រុមនាវិកបម្រើការលើនាវាដែលត្រូវបានឃាត់ទុក ត្រូវដោះលែងវិញជាបន្ទាន់ នៅពេលដែលមាន ការតម្កល់លិខិតធានា ឬវត្ថុធានាផ្សេងទៀតដែលសមស្រប។

៣. ការដាក់ពិន័យចំពោះរដ្ឋជាប់ឆ្នេរដែលរំលោភបំពានលើច្បាប់ និងបទបញ្ញត្តិស្តីពីការ នេសាទនៅក្នុងតំបន់ សេដ្ឋកិច្ចផ្តាច់មុខ អាចនឹងមិនរួមបញ្ចូលនូវទោសជាប់ពន្ធនាគារនោះឡើយ

ក្នុងករណីដែលរដ្ឋដែលពាក់ព័ន្ធ ពុំមាន ចុះកិច្ចព្រមព្រៀងផ្សេងទៀត ឬនូវទម្រង់ដទៃទៀតនៃការដាក់ទោសដល់អាយុជីវិតនោះឡើយ។

៤. ក្នុងករណីនាវាពីក្រៅប្រទេសត្រូវបានរឹបអូស ឬឃាត់ទុក រដ្ឋជាប់ឆ្នេរត្រូវជូនដំណឹងជាបន្ទាន់ទៅដល់រដ្ឋនៃ នាវានោះ តាមរយៈមធ្យោបាយដែលសមស្រប ដើម្បីឱ្យបានដឹងអំពីចំណាត់ការ និងទោសពិន័យដែលអាចនឹង ធ្វើឡើងជាយថាហេតុ។

*មាត្រា ៧៤*

*ការកំណត់ព្រំប្រទល់តំបន់សេដ្ឋកិច្ចផ្តាច់មុខរវាងរដ្ឋ*

*ដែលមានតំបន់ឆ្នេរទល់គ្នា ឬជាប់គ្នា*

១. ការកំណត់ពីព្រំប្រទល់តំបន់សេដ្ឋកិច្ចផ្តាច់មុខរវាងរដ្ឋដែលមានតំបន់ឆ្នេរទល់គ្នា ឬជាប់គ្នា អាចមាន សុពលភាពបានលុះត្រាតែមានការឯកភាពគ្នា ដោយឈរលើមូលដ្ឋានច្បាប់អន្តរជាតិដូចមានចែងក្នុង មាត្រា ៣៨ នៃច្បាប់លក្ខន្តិកៈស្តីពីតុលាការយុត្តិធម៌អន្តរជាតិ សម្រាប់ជាមូលដ្ឋានក្នុងការស្វែងរក ដំណោះស្រាយដោយឈរលើគោលការណ៍សមធម៌។

២. កាលបើពុំមានការឯកភាពគ្នានៅក្នុងរយៈពេលដែលបានកំណត់ នោះរដ្ឋដែលពាក់ព័ន្ធត្រូវអនុវត្តតាម នីតិវិធី ដែលមានចែងក្នុងផ្នែកទី១៥។

៣. ខណៈដែលរង់ចាំការឯកភាពគ្នាដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ រដ្ឋដែលពាក់ព័ន្ធត្រូវព្យាយាម ស្វែងរកដំណោះស្រាយជាបណ្តោះអាសន្នមួយដោយឈរលើស្មារតីនៃការយោគយល់ និងសហការគ្នា ផ្អែកតាមស្ថានភាពជាក់ស្តែង ហើយដែលនៅក្នុងរយៈពេលអន្តរកាលនេះ នឹងមិននាំឱ្យប៉ះពាល់ ឬរាំងស្ទះ ដល់ការឈានដល់កិច្ចព្រមព្រៀងជាចុងក្រោយនោះទេ។ ដំណោះស្រាយនេះនឹងមិនមានឥទ្ធិពលទៅលើ ការកំណត់ព្រំប្រទល់សម្រេចជាចុងក្រោយនោះទេ។

៤. ក្នុងករណីដែលកិច្ចព្រមព្រៀងរវាងរដ្ឋដែលពាក់ព័ន្ធ ចូលជាធរមាន នោះបញ្ហានានាដែលទាក់ទងនឹងការ កំណត់ព្រំប្រទល់តំបន់សេដ្ឋកិច្ចផ្តាច់មុខ នឹងត្រូវកំណត់ស្របទៅតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។

*មាត្រា ៧៥*

*ផែនទី និងបញ្ជីចំណុចនិយាមកាភូមិសាស្ត្រ*

១. នៅក្នុងផ្នែកនេះ ខ្សែបន្ទាត់ខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខ និងខ្សែបន្ទាត់ព្រំប្រទល់ដែលបានគូសស្របតាម មាត្រា ៧៤ ត្រូវបានបង្ហាញនៅលើផែនទីមាត្រាដ្ឋាន ឬមាត្រាដ្ឋានដែលអាចបញ្ជាក់ច្បាស់លាស់ពីចំណុច ទីតាំងរបស់វាបានគ្រប់គ្រាន់។ បញ្ជីចំណុចនិយាមកាភូមិសាស្ត្រដែលបញ្ជាក់ពីទិន្នន័យអំពីប្រថពីវិភាគ អាចនឹងត្រូវបានប្រើជំនួសគំនូសខ្សែបន្ទាត់ព្រំប្រទល់ខាងក្រៅ ឬខ្សែបន្ទាត់ព្រំបាន តាមករណីដែលសមស្រប។

២. រដ្ឋជាប់ឆ្នេរត្រូវប្រកាសផ្សាយឱ្យបានត្រឹមត្រូវនូវផែនទី ឬបញ្ជីចំណុចនិយាមកាភូមិសាស្ត្រទាំងនេះ និងត្រូវ តម្កល់ទុកច្បាប់ចម្លងនៃផែនទី ឬបញ្ជីទាំងនេះនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## ផ្នែកទី៦៖ តំបន់ខ្ពង់រាបបាតសមុទ្រ

*មាត្រា ៧៦*

*និយមន័យនៃតំបន់ខ្ពង់រាបបាតសមុទ្រ*

១. តំបន់ខ្ពង់រាបបាតសមុទ្រនៃរដ្ឋជាប់ឆ្នេរ គិតរួមទាំងតំបន់បាតសមុទ្រ និងដីស្រទាប់ក្រោមនៃតំបន់បាតសមុទ្រ ដែលលាតសន្ធឹងហួសពីដែនសមុទ្ររបស់ខ្លួនដោយការដុះ លយចេញជាលក្ខណៈធម្មជាតិនូវទឹកដីនៃរដ្ឋនោះ រហូត ដល់ជាយខាងក្រៅនៃខ្សែព្រំទ្វីប ឬលាតសន្ធឹងលើរយៈចម្ងាយប្រវែង ២០០ ម៉ែល៍សមុទ្រ ចាប់ពីខ្សែបន្ទាត់មូលដ្ឋាននៃរង្វាស់ផ្ទៃទទឹងនៃដែនសមុទ្រ ដែលជាយខាងក្រៅនៃខ្សែព្រំទ្វីបមិនលាតសន្ធឹងដល់ចំណុចនោះ។

២. តំបន់ខ្ពង់រាបបាតសមុទ្រនៃរដ្ឋជាប់ឆ្នេរមិនត្រូវលាតសន្ធឹងហួសពីព្រំប្រទល់ដែលបានកំណត់ក្នុងកថាខណ្ឌទី ៤ ដល់ទី៦ នោះឡើយ។

៣. ខ្សែព្រំទ្វីបគិតរួមទាំងផ្នែកលយចេញនៃផ្ទៃដីដែលលិចបាត់នៃរដ្ឋជាប់ឆ្នេរ និងរួមមានតំបន់បាតសមុទ្រ និង ដីស្រទាប់ក្រោមនៃតំបន់ខ្ពង់រាបបាតសមុទ្រ ទីចំណោត និងទីទួលបាតសមុទ្រ។ ដោយឡែក វាពុំគិតបញ្ចូលនូវ ផ្ទៃបាត សមុទ្រដែលមានទីទួល ឬដីស្រទាប់ក្រោមរបស់វានោះទេ។

៤. (ក) សម្រាប់គោលបំណងនៃអនុសញ្ញានេះ រដ្ឋជាប់ឆ្នេរត្រូវកំណត់ពីជាយខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រ ក្នុងករណីដែលតំបន់ខ្ពង់រាបបាតសមុទ្រនោះលាងសន្ធឹងលើប្រវែងហួសពី ២០០ ម៉ែល៍សមុទ្រ គិតចាប់ពីខ្សែបន្ទាត់ គោលនៃរង្វាស់ផ្ទៃទទឹងដែនសមុទ្រ ដែលកំណត់តាមមធ្យោបាយ ៖

(i) ខ្សែបន្ទាត់ដែលបានកំណត់ស្របតាមកថាខណ្ឌទី ៧ ដោយយោងទៅតាមចំណុចនឹងថ្កល់នៅផ្នែកខាងក្រៅ បំផុតដែលចំណុចនីមួយៗមានកម្រាស់ថ្មល្បាយភក់យ៉ាងតិច ១ភាគរយនៃរយៈចម្ងាយដែលជិតជាង គេគិតចាប់ពីចំណុចនោះដល់ជើងជម្រាលនៃទ្វីប ឬ

(ii) ខ្សែបន្ទាត់ដែលបានកំណត់ស្របតាមកថាខណ្ឌទី៧ យោងទៅតាមចំណុចនឹងថ្កល់ដែលមានចម្ងាយ លើសពី៦០ម៉ែល៍សមុទ្រគិតចាប់ជើងជម្រាលនៃទ្វីប។

(ខ) ក្នុងករណីដែលពុំមានភស្តុតាងផ្សេងពីនេះ នោះជើងជម្រាលនៃទ្វីបត្រូវបានកំណត់ទៅតាមចំណុច ជម្រាលដែលមានការប្រែប្រួលជាអតិបរមានៃបាតជម្រាលនោះ។

៥. ចំណុចនឹងថ្កល់ដែលរួមមានខ្សែបន្ទាត់ព្រំប្រទល់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រនៅខាងលើបាតសមុទ្រ ដែលបាន កំណត់ស្របតាមកថាខណ្ឌទី ៤(ក)(i)និង (ii)មិនត្រូវមានប្រវែងលើសពី ៣៥០ម៉ែល៍សមុទ្រ គិតចាប់ពីខ្សែបន្ទាត់មូលដ្ឋាននៃរង្វាស់ផ្ទៃទទឹងនៃដែនសមុទ្រ ឬមិនត្រូវលើសពីប្រវែង ១០០ម៉ែល៍សមុទ្រ គិតចាប់ពីផ្ទៃទឹកជម្រៅ ២៥០០ម៉ែត្រ ដែលមានខ្សែបន្ទាត់ភ្ជាប់នឹងជម្រៅ ២៥០០ម៉ែត្រ។

៦. បើទោះជាមានបញ្ញត្តិចែងនៅក្នុងកថាខណ្ឌទី៥ ខាងលើក៏ដោយ នៅលើផ្នែកទូលនៃតំបន់បាតសមុទ្រ ព្រំដែន ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រ មិនត្រូវលាតសន្ធឹងហួសពី ៣៥០ ម៉ែល៍សមុទ្រ គិតចាប់ពីចំណុចខ្សែបន្ទាត់ គោលនៃរង្វាស់ផ្ទៃទទឹងនៃដែនសមុទ្រ។ កថាខណ្ឌនេះមិនអនុវត្តចំពោះរយៈពេលកម្ពស់នៃតំបន់បាតសមុទ្រ ដែលតាមធម្មជាតិជាផ្នែកមួយនៃជាយទ្វីប ដូចជាតំបន់ខ្ពង់រាប ទីទួល គម្រប មាត់ច្រាំង និងផ្នែកលយ ចេញក្រៅរបស់វា។

៧. រដ្ឋជាប់ឆ្នេរត្រូវកំណត់ព្រំប្រទល់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ករណីដែលតំបន់ខ្ពង់រាបបាតសមុទ្រនោះលាត សន្ធឹងលើសពី ២០០ម៉ែល៍សមុទ្រ គិតចាប់ពីចំណុចខ្សែបន្ទាត់មូលដ្ឋាននៃរង្វាស់ផ្ទៃទទឹងនៃដែនសមុទ្រ ដោយ ខ្សែបន្ទាត់ត្រង់មិនត្រូវមានជម្រៅលើសពី ៦០ ម៉ែល៍នាវាចរណ៍ដែលភ្ជាប់ជាមួយចំណុចនឹងថ្កល់ កំណត់ទៅ តាមចំណុចនិយាមកាខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយ។

៨. រដ្ឋជាប់ឆ្នេរត្រូវបញ្ជូនព័ត៌មានស្តីពីព្រំប្រទល់តំបន់ខ្ពង់រាបបាតសមុទ្រដែលលាតសន្ធឹងលើសពី ២០០ ម៉ែល៍សមុទ្រ គិតចាប់ពីចំណុចខ្សែបន្ទាត់មូលដ្ឋាននៃរង្វាស់ផ្ទៃទទឹងនៃដែនសមុទ្រទៅឱ្យគណៈកម្មការកំណត់ព្រំប្រទល់តំបន់ខ្ពង់រាបបាតសមុទ្រដែលបានបង្កើតឡើងក្នុងឧបសម្ព័ន្ធ ២

សម្រាប់ជាមូលដ្ឋានក្នុងការធ្វើជាតំណាងតំបន់ភូមិសាស្ត្រ ប្រកបដោយសមធម៌។ គណៈកម្មការត្រូវផ្តល់អនុសាសន៍ដល់រដ្ឋជាប់ឆ្នេរ លើបញ្ហាដែលទាក់ទងនឹងការ កំណត់ព្រំប្រទល់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្ររបស់រដ្ឋទាំងនោះ។ ព្រំប្រទល់តំបន់ខ្ពង់រាបបាតសមុទ្រដែលបានកំណត់ ដោយរដ្ឋជាប់ឆ្នេរដោយឈរលើមូលដ្ឋាននៃអនុសាសន៍ទាំងនេះត្រូវចាត់ទុកជាបានការ និងចងភ្ជាប់កាតព្វកិច្ចរដ្ឋជាប់ឆ្នេរ។

៩. រដ្ឋជាប់ឆ្នេរត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវផែនទី និងព័ត៌មានដែលពាក់ព័ន្ធ រាប់បញ្ចូលទាំងទិន្នន័យផ្នែកប្រចពីវិភាគ ដែលបង្ហាញជាទៀងទាត់នូវព្រំប្រទល់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន។ អគ្គលេខាធិការត្រូវធ្វើការផ្សព្វផ្សាយឱ្យបានត្រឹមត្រូវនូវព័ត៌មានខាងលើ។

១០. បទបញ្ញត្តិនៃមាត្រានេះមិនត្រូវប៉ះពាល់ដល់បញ្ហានៃការកំណត់ព្រំប្រទល់នៃតំបន់ខ្ពង់រាបបាតសមុទ្ររវាងរដ្ឋដែល នៃតំបន់ឆ្នេរទល់គ្នា ឬជាប់គ្នានោះទេ។

*មាត្រា ៧៧*

*សិទ្ធិរបស់រដ្ឋជាប់ឆ្នេរលើតំបន់ខ្ពង់រាបបាតសមុទ្រ*

១. រដ្ឋតំបន់មានសិទ្ធិអធិបតេយ្យភាពលើតំបន់ខ្ពង់រាបបាតសមុទ្រ សម្រាប់គោលបំណងធ្វើការរុករក និងធ្វើអាជីវកម្មធនធានធម្មជាតិនៅក្នុងតំបន់ទាំងនេះ។

២. សិទ្ធិដូចមានចែងក្នុងកថាខណ្ឌទី១ ត្រូវបានលើកលែង ប្រសិនបើក្នុងករណីដែលរដ្ឋជាប់ឆ្នេរមិនធ្វើការរុករកនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ ឬមិនធ្វើអាជីវកម្មធនធានធម្មជាតិរបស់ខ្លួនគ្មានបុគ្គលណាមួយអាចអនុវត្តអនុវត្ត នូវសកម្មភាពទាំងនេះដោយពុំចាំបាច់មានការយល់ព្រមពីរដ្ឋជាប់ឆ្នេរ។

៣. សិទ្ធិរបស់រដ្ឋជាប់ឆ្នេរទៅលើតំបន់ខ្ពង់រាបបាតសមុទ្រមិនផ្អែកទៅលើការកាន់កាប់ មិនថាដោយមាន ប្រសិទ្ធភាព ឬដោយគ្រាន់តែទ្រឹស្តី ឬទៅលើការអះអាងដោយជាក់លាក់នោះទេ ។

៤. ធនធានធម្មជាតិដូចមានចែងនៅក្នុងផ្នែកនេះ រួមមានធនធានរ៉ែ និងធនធានមិនមានជីវិតដទៃទៀត ដែលមាននៅក្នុងបាតសមុទ្រ និងដីស្រទាប់ក្រោមរបស់វា រួមទាំងពពួកភាវរសទាំងឡាយដែលស្ថិតក្នុងប្រភេទ ល្បាយភក់ ពោលគឺ ពពួកសរីរាង្គនៅក្នុងដំណាក់កាលលូតលាស់អាចឱ្យប្រមូលយកបាន មិនអាចចល័តបានដែលរស់នៅលើ ឬ ក្រោមបាតសមុទ្រ ឬពុំអាចធ្វើចលនាបានវៀរលែងតែការទំនាក់ទំនងជារូបវន្តជាអចិន្ត្រៃយ៍ជាមួយបាតសមុទ្រ ឬ ដីស្រទាប់ក្រោម។

*មាត្រា ៧៨*

*ស្ថានភាពគតិយុត្តិនៃដែនទឹក និងលំហអាកាសខាងលើ ព្រមទាំងសិទ្ធិ និងសេរីភាពនៃរដ្ឋផ្សេងៗ*

១. សិទ្ធិរបស់រដ្ឋជាប់ឆ្នេរលើតំបន់ខ្ពង់រាបបាតសមុទ្រ មិនមានឥទ្ធិពលលើស្ថានភាពគតិយុត្តិនៃដែនទឹកផ្នែកខាងលើ ឬលំហអាកាសដែលស្ថិតនៅខាងលើដែនទឹកទាំងនេះឡើយ។

២. ការអនុវត្តនូវសិទ្ធិរបស់រដ្ឋជាប់ឆ្នេរលើតំបន់ខ្ពង់រាបបាតសមុទ្រ មិននាំឱ្យបំពានដល់ ឬនាំទៅដល់ការជ្រៀតជ្រែក ដោយពុំសមហេតុផលជាមួយនឹងការធ្វើនាវាចរណ៍ រួមទាំងសិទ្ធិ និងសេរីភាពផ្សេងៗរបស់រដ្ឋដទៃទៀតដូច មានចែងនៅក្នុងអនុសញ្ញានេះឡើយ។

*មាត្រា ៧៩*

*បណ្តាញខ្សែកាប្លិ៍នៅបាតសមុទ្រ និងបំពង់បញ្ជូនប្រេងនៅលើតំបន់ខ្ពង់រាបបាតសមុទ្រ*

១. គ្រប់បណ្តារដ្ឋទាំងអស់អាចមានសិទ្ធិដាក់ពង្រាយបណ្តាញកាប្លិ៍នៅបាតសមុទ្រ និងបំពង់បញ្ជូនប្រេងនៅលើ តំបន់ខ្ពង់រាបបាតសមុទ្របាន ស្របតាមបទបញ្ញត្តិនៃមាត្រានេះ។

២. អនុលោមតាមសិទ្ធិក្នុងការចាត់វិធានការដែលសមស្របសម្រាប់ការរុករកតំបន់ខ្ពង់រាបបាតសមុទ្រ ការធ្វើអាជីវកម្មធនធានធម្មជាតិរបស់ខ្លួន និងការបង្ការ ការកាត់បន្ថយ និងការទប់ស្កាត់ការបំពុលដោយបំពង់បញ្ជូន ប្រេង រដ្ឋជាប់ឆ្នេរពុំអាចបង្កការរាំងស្ទះដល់ការដាក់ពង្រាយ ឬតំហែទាំបណ្តាញកាប្លិ៍ ឬបំពង់បញ្ជូនប្រេងទាំងនេះឡើយ។

៣. ការកំណត់គន្លងផ្លូវសម្រាប់ការដាក់ពង្រាយនូវបំពង់បញ្ជូនប្រេងទាំងនេះនៅលើតំបន់ខ្ពង់រាបបាតសមុទ្រ ត្រូវមានការឯកភាពពីរដ្ឋជាប់ឆ្នេរ។

៤. គ្មានបទបញ្ញត្តិណាមួយនៅក្នុងផ្នែកនេះមានឥទ្ធិពលទៅលើសិទ្ធិរបស់រដ្ឋជាប់ឆ្នេរនៅក្នុងការបង្កើតលក្ខខណ្ឌ សម្រាប់ការដាក់ពង្រាយកាប្លិ៍ ឬបំពង់បញ្ជូនទាំងនេះទៅក្នុងដែនដីគោក ឬដែនសមុទ្ររបស់ខ្លួន ឬដែល ខ្លួនមានយុត្តាធិការលើការសាងសង់ ឬការប្រើប្រាស់បណ្តាញកាប្លិ៍ និងបំពង់បញ្ជូនប្រេងទាំងនេះសម្រាប់បម្រើ ដល់គោលបំណងនៃការរុករកតំបន់ខ្ពង់រាបបាតសមុទ្រ ឬការធ្វើអាជីវកម្មលើធនធានរបស់ខ្លួន ឬ កិច្ចប្រតិបត្តិការកោះសិប្បនិម្មិត ឋបនភណ្ឌ និងគ្រោងសំណង់នានាដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួននោះឡើយ។

៥. រដ្ឋនីមួយៗនៅពេលដាក់ពង្រាយបណ្តាញកាប្លិ៍ ឬបំពង់បញ្ជូនប្រេងនៅបាតសមុទ្រ ត្រូវធ្វើការពិចារណាឱ្យបាន ត្រឹមត្រូវទៅលើបណ្តាញកាប្លិ៍ ឬបំពង់បញ្ជូនដែលមានស្រាប់។ ជាពិសេស វាមិនត្រូវប៉ះពាល់ដល់លទ្ធភាពក្នុង ការជួសជុលបណ្តាញកាប្លិ៍ ឬបំពង់បញ្ជូនដែលមានស្រាប់នោះឡើយ។

*មាត្រា ៨០*

*កោះសិប្បនិម្មិត បបនកម្ម និងគ្រោងសំណង់នៅលើតំបន់ខ្ពង់រាបបាតសមុទ្រ*

មាត្រា ៦០ រួមទាំងវិសោធនកម្មរបស់វាផងដែរ ត្រូវយកមកអនុវត្តចំពោះកោះសិប្បនិម្មិត បបនកម្ម និង គ្រោងសំណង់នៅលើតំបន់ខ្ពង់រាបបាតសមុទ្រ។

*មាត្រា ៨១*

*ការជីកខួងនៅតំបន់ខ្ពង់រាបបាតសមុទ្រ*

រដ្ឋជាប់ឆ្នេរត្រូវមានសិទ្ធិទាំងស្រុងនៅក្នុងការផ្តល់សិទ្ធិ និងគ្រប់គ្រងលើសកម្មភាពជីកខួងគ្រប់ប្រភេទនៅលើ តំបន់ខ្ពង់រាបបាតសមុទ្រ។

*មាត្រា ៨២*

*ការបង់កម្រៃ និងវិភាគទានទាក់ទងនឹងការធ្វើអាជីវកម្មតំបន់ខ្ពង់រាបបាតសមុទ្រ ដែលលាតសន្ធឹងលើសពី ២០០ម៉ៃល៍សមុទ្រ*

១. រដ្ឋជាប់ឆ្នេរត្រូវបង់កម្រៃ ឬវិភាគទានតាមរូបភាពណាមួយលើការធ្វើអាជីវកម្មធនធានមិនមានជីវិតនៅក្នុង តំបន់ខ្ពង់រាបបាតសមុទ្រដែលលាតសន្ធឹងលើសពី ២០០ម៉ៃល៍សមុទ្រ គិតចាប់ពីចំណុចខ្សែបន្ទាត់មូលដ្ឋាននៃរង្វាស់ផ្ទៃទឹងដែនសមុទ្រ។

២. ការបង់កម្រៃ និងវិភាគទានទាំងនេះត្រូវធ្វើឡើងជារៀងរាល់ឆ្នាំសម្រាប់រាល់បរិមាណដែលបានផលិតបាននៅ នឹងទីតាំង បន្ទាប់ពីចាប់ផ្តើមដំណើរការផលិតកម្មរយៈពេលប្រាំឆ្នាំដំបូងនៅនឹងទីតាំង។ អត្រាបង់កម្រៃ ឬ វិភាគទាននៅឆ្នាំទីប្រាំមួយ នឹងត្រូវបានកំណត់ចំនួន ១ ភាគរយនៃតម្លៃ ឬបរិមាណធនធានដែលផលិតបាន នៅនឹងទីតាំង។ អត្រានេះនឹងត្រូវកើនឡើង ១ភាគរយជាងរៀង

រាល់ឆ្នាំនីមួយៗ រហូតដល់ឆ្នាំទីដប់ពីរ និង ត្រូវរក្សាដដែលក្នុងអត្រា ៧ ភាគរយនៅឆ្នាំបន្តបន្ទាប់។ ដំណើរការផលិតកម្មពុំរាប់បញ្ចូលធនធានសម្រាប់ ប្រើប្រាស់នៅក្នុងការធ្វើអាជីវកម្មនោះទេ។

៣. រដ្ឋកំពុងអភិវឌ្ឍន៍ ដែលនាំចូលសុទ្ធសាធនូវធនធានរ៉ែដែលទាញយកពីតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ត្រូវបានលើកលែងពីការបង់កម្រៃ ឬវិភាគទានលើការទាញយកធនធានរ៉ែទាំងនេះ។

៤. ការបង់កម្រៃ ឬវិភាគទានត្រូវធ្វើឡើងតាមរយៈអាជ្ញាធរដែលនឹងបែងកចែកទៅឱ្យបណ្តារដ្ឋភាគីនៃ អនុសញ្ញានេះ ផ្អែកតាមលក្ខខណ្ឌនៃការបែងចែកចំណែកដោយស្មើភាពក្នុងចំណោមរដ្ឋទាំងនេះ អាស្រ័យទៅ តាមផលប្រយោជន៍ និងតម្រូវការនៃរដ្ឋកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្តារដ្ឋដែលមានការអភិវឌ្ឍន៍តិចតួចបំផុត និងរដ្ឋតំបន់ហ៊ុំព័ទ្ធដោយដីគោក។

*មាត្រា ៨៣*

*ការកំណត់ព្រំប្រទល់តំបន់ខ្ពង់រាបបាតសមុទ្ររវាងរដ្ឋ*

*ដែលនៃតំបន់ឆ្នេរទល់គ្នា ឬជាប់គ្នា*

១. ការកំណត់ពីព្រំប្រទល់តំបន់ខ្ពង់រាបបាតសមុទ្ររវាងរដ្ឋដែលនៃតំបន់ឆ្នេរទល់គ្នា ឬជាប់គ្នា អាចមានសុពលភាព បានលុះត្រាតែមានការឯកភាពគ្នា ដោយឈរលើមូលដ្ឋានច្បាប់អន្តរជាតិដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់លក្ខន្តិកៈស្តីពីតុលាការយុត្តិធម៌អន្តរជាតិ សម្រាប់ជាមូលដ្ឋានក្នុងការស្វែងរកដំណោះស្រាយដោយឈរលើគោលការណ៍សមធម៌។

២. កាលបើពុំមានការឯកភាពគ្នានៅក្នុងរយៈពេលដែលបានកំណត់ នោះរដ្ឋដែលពាក់ព័ន្ធត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងផ្នែកទី ១៥។

៣. ខណៈដែលរង់ចាំការឯកភាពគ្នាដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ រដ្ឋដែលពាក់ព័ន្ធត្រូវព្យាយាម ស្វែងរកដំណោះស្រាយបណ្តោះអាសន្នមួយដោយឈរលើស្មារតីនៃការ យោគយល់ និងសហការគ្នា ផ្អែកតាមស្ថានភាពជាក់ស្តែង ហើយដែលនៅក្នុងរយៈពេលអន្តរកាលនេះ

នឹងមិននាំឱ្យប៉ះពាល់ ឬរាំងស្ទះ ដល់ការឈានដល់កិច្ចព្រមព្រៀងជាចុងក្រោយនោះទេ។ ដំណោះស្រាយនេះនឹងមិនមានឥទ្ធិពលទៅលើ ការកំណត់ព្រំប្រទល់សម្រេចជាចុងក្រោយនោះទេ។

៤. ក្នុងករណីដែលកិច្ចព្រមព្រៀងរវាងរដ្ឋដែលពាក់ព័ន្ធ ចូលជាធរមាន នោះបញ្ហានានាដែលទាក់ទងនឹងការ កំណត់ព្រំប្រទល់តំបន់សេដ្ឋកិច្ចផ្តាច់មុខ នឹងត្រូវកំណត់ស្របទៅតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។

*មាត្រា ៨៤*

*ផែនទី និងបញ្ជីចំណុចនិយាមកាភូមិសាស្ត្រ*

១. នៅក្នុងផ្នែកនេះ ខ្សែបន្ទាត់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រ និងខ្សែបន្ទាត់ព្រំប្រទល់ដែលបានគូសស្របតាមមាត្រា៨៣ ត្រូវបានបង្ហាញនៅលើផែនទីមាត្រាដ្ឋាន ឬមាត្រាដ្ឋានដែលអាចបញ្ជាក់ច្បាស់លាស់ពីចំណុចទីតាំងរបស់វាបានគ្រប់គ្រាន់។ បញ្ជីចំណុចនិយាមកាភូមិសាស្ត្រដែលបញ្ជាក់ពីទិន្នន័យអំពីប្រចពីរិភាគ អាចនឹងត្រូវបានប្រើជំនួសគំនូសខ្សែបន្ទាត់ព្រំប្រទល់ខាងក្រៅ ឬខ្សែបន្ទាត់ព្រំបាន តាមករណីដែលសមស្រប។

២. រដ្ឋជាប់ឆ្នេរត្រូវប្រកាសផ្សាយឱ្យបានត្រឹមត្រូវនូវផែនទី ឬបញ្ជីចំណុចនិយាមកាភូមិសាស្ត្រទាំងនេះ និងត្រូវតម្កល់ទុកច្បាប់ចម្លងនៃផែនទី ឬ បញ្ជីទាំងនេះនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

*មាត្រា ៨៥*

*ការជីករូងក្រោមដី*

ផ្នែកនេះមិននាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរ នៅក្នុងការធ្វើអាជីវកម្មលើដីស្រទាប់ ក្រោមតាមមធ្យោបាយនៃការជីករូងក្រោមដីនោះទេ ដោយមិនគិតដល់ជម្រៅទឹកខាងលើដីស្រទាប់ ក្រោម។

## ផ្នែកទី៧៖ ដែនសមុទ្រអន្តរជាតិ

### ជំពូកទី១៖ បទបញ្ញត្តិទូទៅ

*មាត្រា ៨៦*

*ការអនុវត្តបទបញ្ញត្តិនៃផ្នែកនេះ*

បទបញ្ញត្តិនៃផ្នែកនេះ ត្រូវបានអនុវត្តចំពោះផ្នែកទាំងអស់របស់សមុទ្រដែលមិនស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៅក្នុងដែនសមុទ្រ ឬនៅក្នុងដែនទឹកខាងក្នុងរបស់រដ្ឋមួយ ឬនៅក្នុងដែនទឹកនៃតំបន់ប្រជុំកោះនៃរដ្ឋប្រជុំកោះ។ មាត្រានេះមិនត្រូវនាំឱ្យរដ្ឋទាំងអស់បាត់បង់សិទ្ធិសេរីភាពនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ស្របតាមមាត្រា ៥៨ នោះឡើយ។

*មាត្រា ៨៧*

*សិទ្ធិសេរីភាពលើដែនសមុទ្រអន្តរជាតិ*

១. រដ្ឋទាំងអស់ត្រូវមានសិទ្ធិប្រើប្រាស់ដោយសេរីនូវដែនសមុទ្រអន្តរជាតិ មិនថារដ្ឋជាប់ ឆ្នេរ ឬរដ្ឋតំបន់ហ៊ុំព័ទ្ធ ដោយដីគោកនោះទេ។ សិទ្ធិសេរីភាពលើដែនសមុទ្រអន្តរជាតិ ត្រូវបានអនុវត្តស្របតាមលក្ខខណ្ឌដែលមាន ចែងក្រោមអនុសញ្ញានេះ និងក្រោមវិធានច្បាប់អន្តរជាតិផ្សេងៗ។ សិទិទាំងនេះសម្រាប់ទាំងរដ្ឋជាប់ឆ្នេរ និងរដ្ឋតំបន់ដីគោល មានដូចតទៅ ៖

(ក) សិទ្ធិក្នុងការធ្វើនាវាចរណ៍ដោយសេរី

(ខ) សិទ្ធិក្នុងការហោះហើរដោយសេរី

(គ) សិទ្ធិក្នុងការដាក់ពង្រាយបណ្តាញកាប្លិ៍ និងបំពង់បញ្ជូនប្រេងដោយសេរី ស្របតាមខ្លឹមសារនៃផ្នែកទី៦។

(ឃ) សិទ្ធិក្នុងការសាងសង់កោះសិប្បនិម្មិត និងបរិក្ខារផ្សេងទៀតដោយសេរីដែលច្បាប់អន្តរជាតិអនុញ្ញាត ស្របតាមខ្លឹមសារនៃផ្នែកទី៦ ។

(ង)	សិទ្ធិក្នុងការនេសាទដោយសេរី

ស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងជំពូកទី២ ។

២.	នៅក្នុងការប្រើប្រាស់នូវសិទ្ធិសេរីភាពលើដែនសមុទ្រអន្តរជាតិ បណ្តារដ្ឋទាំងអស់ត្រូវអនុវត្តនូវសិទ្ធិទាំងនេះ ដោយគោរពចំពោះផលប្រយោជន៍របស់រដ្ឋដទៃ ព្រមទាំងសិទ្ធិដូចដែលមានចែងនៅក្នុងអនុសញ្ញានេះចំពោះ ការអនុវត្តសកម្មភាពនានានៅក្នុងតំបន់។

*មាត្រា ៨៨*

*កិច្ចអភិរក្សដែនសមុទ្រអន្តរជាតិ*

*សម្រាប់គោលបំណងសន្តិភាព*

ដែនសមុទ្រអន្តរជាតិត្រូវបានអភិរក្សសម្រាប់គោលបំណងសន្តិភាព។

*មាត្រា ៨៩*

*អសុពលភាពនៃការទាមទារអធិបតេយ្យភាព*

*លើដែនសមុទ្រអន្តរជាតិ*

គ្មានរដ្ឋណាមួយអាចមានអានុភាពដាក់ឱ្យនៅក្រោមអធិបតេយ្យភាពរបស់ខ្លួននូវផ្នែកណាមួយនៃដែនសមុទ្រ អន្តរជាតិនោះឡើយ។

*មាត្រា ៩០*

*សិទ្ធិក្នុងការធ្វើនាវាចរណ៍*

បណ្ដារដ្ឋនីមួយៗទោះជារដ្ឋជាប់ឆ្នេរ ឬរដ្ឋហ៊ុំព័ទ្ធដោយដីគោក មានសិទ្ធិក្នុងការធ្វើនាវាចរណ៍ ដោយមាន បំពាក់ទង់ជាតិរបស់ខ្លួនបាននៅលើដែនសមុទ្រអន្តរជាតិ។

*មាត្រា ៩១*

*សញ្ជាតិរបស់នាវា*

១. បណ្ដារដ្ឋនីមួយៗត្រូវកំណត់ពីលក្ខខណ្ឌសម្រាប់ការផ្ដល់សញ្ជាតិនាវានៃប្រទេសរបស់ខ្លួន ព្រមទាំងការចុះ បញ្ជីនាវានៅក្នុងដែនដីរបស់ខ្លួន និងស្ដីពីសិទ្ធិក្នុងការដាក់ទង់ជ័យរបស់ខ្លួន។ នាវាត្រូវមានសញ្ជាតិនៃរដ្ឋ ដែលនាវានោះទទួលសិទ្ធិឱ្យចងទង់។ រដ្ឋ និងនាវាត្រូវមានទំនាក់ទំនងនឹងគ្នាដោយពិតប្រាកដ។

២. បណ្ដារដ្ឋនីមួយៗត្រូវផ្ដល់ដល់នាវាដែលទទួលសិទ្ធិឱ្យចងទង់ជាតិរបស់ខ្លួន នូវឯកសារដែលពាក់ព័ន្ធ។

*មាត្រា ៩២*

*ស្ថានភាពរបស់នាវា*

១. នាវាអាចប្រើទង់របស់រដ្ឋតែមួយប៉ុណ្ណោះនៅក្នុងការធ្វើនាវាចរណ៍ ហើយលើកលែងក្នុងករណីពិសេសដែលមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិនានា ឬនៅក្នុងអនុសញ្ញានេះ ត្រូវស្ថិតក្រោមយុត្តាធិការរបស់រដ្ឋនោះទាំងស្រុង ដែលមានលើដែនសមុទ្រអន្តរជាតិ។ នាវាមិនអាចផ្លាស់ប្ដូរទង់របស់ខ្លួនបានឡើយក្នុងអំឡុងពេលធ្វើនាវាចរណ៍ ឬខណៈដែលធ្វើការចុះចតនៅកំពង់ផែគោលដៅ

ណាមួយ វៀរលែងតែក្នុងករណីដែលមានការផ្ទេរកម្មសិទ្ធិ ឬការផ្លាស់ប្តូរបញ្ជីនាវាផ្អែកតាមករណីជាក់ស្តែងនីមួយៗ ។

២. នាវាដែលធ្វើនាវាចរណ៍ដោយប្រើទង់របស់រដ្ឋចំនួនពីរ ឬលើសពីនេះ ដើម្បីឱ្យមានភាពងាយស្រួលនោះ មិនអាចស្នើសុំយកសញ្ជាតិណាមួយនៃរដ្ឋម្ខាងទៀតបានឡើយ ដោយឡែកអាចប្រើសម្រាប់នាវាមួយ ដោយគ្មានសញ្ជាតិបាន។

*មាត្រា ៩៣*
*នាវាប្រើទង់របស់អង្គការសហប្រជាជាតិ*
*ទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ*
*និងទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ*

បណ្តាមាត្រាខាងលើមិនត្រូវមានឥទ្ធិពលលើការចោទសួរដល់នាវាដែលបម្រើការជាផ្លូវការរបស់អង្គការ សហប្រជាជាតិ ឬទីភ្នាក់ងារឯកទេសណាមួយរបស់អង្គការនេះ ឬរបស់ទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ ដែលប្រើទង់របស់អង្គការទាំងនេះឡើយ។

*មាត្រា ៩៤*
*តួនាទីនៃរដ្ឋចុះបញ្ជីនាវា*

១. បណ្តារដ្ឋនីមួយៗត្រូវអនុវត្តតាមយុត្តាធិការរបស់ខ្លួន និងគ្រប់គ្រងលើបញ្ហាផ្នែករដ្ឋបាល បច្ចេកទេស និង សង្គមកិច្ចប្រកបដោយប្រសិទ្ធភាពលើនាវាដែលប្រើទង់របស់ខ្លួន។

២. ជាពិសេស បណ្តារដ្ឋនីមួយៗត្រូវ ៖

(ក) ថែរក្សាទុកនូវបញ្ជីនាវាដែលត្រូវមានឈ្មោះ និងភិនភាគជាក់លាក់របស់នាវានៃរដ្ឋរបស់ខ្លួន លើកលែង តែនាវាខ្នាតតូចដែលស្ថិតក្រោមការលើកលែងក្រោមបទបញ្ញត្តិអន្តរជាតិដែលទទួលស្គាល់ជាទូទៅ និង

(ខ) ទទួលយកយុត្តាធិការក្រោមច្បាប់ផ្ទៃក្នុងរបស់ខ្លួនលើនាវានីមួយៗដែលប្រើទង់របស់រដ្ឋនោះ និងមាន នាវាបតី មន្ត្រីបុគ្គលិក និងក្រុមនាវិកនៃរដ្ឋរបស់ខ្លួនទាក់ទងនឹងផ្នែករដ្ឋបាល បច្ចេកទេស និងសង្គមកិច្ចដែលពាក់ព័ន្ធនឹងនាវានោះ។

៣. បណ្ដារដ្ឋនីមួយៗត្រូវចាត់វិធានការដែលចាំបាច់ចំពោះនាវាដែលប្រើទង់នៃរដ្ឋរបស់ខ្លួនដើម្បីធានាបាននូវ សុវត្ថិភាពនៃការធ្វើនាវាចរណ៍នៅដែនសមុទ្រ មានជាអាទិ៍ ៖

(ក) ផ្នែកសំណង់ ការបំពាក់គ្រឿងបរិក្ខារ និងលទ្ធភាពនៃការធ្វើនាវាចរណ៍របស់នាវា។

(ខ) ការប្រើប្រាស់កម្លាំងពលកម្មលើនាវា លក្ខណ្ឌការងារ និងការបំពាក់បំប៉នក្រុមនាវិក ដោយផ្អែកទៅលើ លិខិតបទដ្ឋានអន្តរជាតិដែលមានជាធរមាន ។

(គ) ការប្រើប្រាស់សញ្ញាសម្គាល់ ការរក្សាឱ្យមានប្រព័ន្ធទំនាក់ទំនង និងការការពារការប៉ះទង្គិចនាវា ។

៤. វិធានការទាំងនេះត្រូវធ្វើឡើងជាចាំបាច់ ដើម្បីធានាបានថា ៖

(ក) នាវានីមួយៗនៅមុនពេលចុះបញ្ជិកា និងនៅក្នុងអំឡុងពេលអន្តរកាលដែលសមស្រប ត្រូវធ្វើការពិនិត្យ អង្កេតដោយអ្នកមានជំនាញខាងពិនិត្យនាវា និងត្រូវមាននៅលើនាវា នូវរាល់ផែនទី ឯកសារបោះពុម្ពផ្សាយផ្នែក នាវាចរណ៍ សម្ភារ-ឧបករណ៍នាវាចរណ៍ដែលសមស្របសម្រាប់ការធ្វើនាវាចរណ៍ដោយសុវត្ថិភាពរបស់នាវា។

(ខ) នាវានីមួយៗស្ថិតក្រោមការគ្រប់គ្រងរបស់នាវាបតី ព្រមទាំងមន្ត្រីបុគ្គលិកដែលមានគុណវុឌ្ឍិសមស្រប ជាពិសេស ជំនាញបច្ចេកទេសខាងប្រតិបត្តិការនាវាផ្នែកនាវាចរណ៍ ប្រព័ន្ធទំនាក់ទំនង និងវិស្វកម្មខាងសមុទ្រ និង ដើម្បីធានាថាក្រុមនាវិកមានគុណវុឌ្ឍិ និងចំនួនគ្រប់គ្រាន់សមស្របទៅតាមប្រភេទ ទំហំគ្រឿងចក្រ និងគ្រឿង បរិក្ខាររបស់នាវា។

(គ) នាវាបតី មន្ត្រីបុគ្គលិក រួមទាំងក្រុមនាវិក ផ្អែកតាមករណីដែលសមស្រប ត្រូវមានការយល់ដឹងច្បាស់លាស់ និងត្រូវប្រតិបត្តិឱ្យបានត្រឹមត្រូវ តាមបទបញ្ញត្តិអន្តរជាតិទាក់ទងនឹងសុវត្ថិភាពនៃអាយុជីវិតនៅលើដែនសមុទ្រ ការការពារការប៉ះទង្គិចរវាងនាវា ការបង្ការ ការកាត់បន្ថយ និងទប់ស្កាត់ការបំពុលសមុទ្រ និងការរក្សាបាននូវ ប្រព័ន្ធវិទ្យុទំនាក់ទំនង។

៥. នៅក្នុងការចាត់វិធានការដូចមានចែងនៅក្នុងកថាខណ្ឌទី ៣ និង ៤ ខាងលើ បណ្តារដ្ឋនីមួយៗត្រូវគោរពទៅតាមបទបញ្ញត្តិ នីតិវិធី និងទម្លាប់អនុវត្តន៍ជាអន្តរជាតិ ដែលទទួលស្គាល់ជាទូទៅ និងត្រូវចាត់វិធានការដែលចាំបាច់ដើម្បីធានាបាននូវការប្រតិបត្តិតាម។

៦. រដ្ឋណាមួយមានមូលដ្ឋានច្បាស់លាស់ដែលអាចឱ្យជឿជាក់ថាយុត្តាធិការ និងការគ្រប់គ្រងលើនាវាមិនត្រូវ បានធ្វើឡើងត្រឹមត្រូវ នោះអាចរាយការណ៍ពីហេតុការណ៍ពិតដែលកើតឡើងទៅកាន់រដ្ឋចុះបញ្ជីនាវា។ រដ្ឋចុះបញ្ជីនាវានៅពេលដែលទទួលបានសេចក្តីរាយការណ៍នេះ ត្រូវធ្វើការ អង្កេតស្រាវជ្រាវអំពីបញ្ហានេះ និងត្រូវចាត់វិធានការដែលចាំបាច់ ដើម្បីស្វែងរកដំណោះស្រាយក្នុងស្ថានភាពនោះ តាមករណីដែលសមស្រប។

៧. បណ្តារដ្ឋនីមួយៗត្រូវចាត់ចែងឱ្យមានការអង្កេតស្រាវជ្រាវដែលធ្វើឡើងដោយ ឬនៅចំពោះមុខបុគ្គលណា ម្នាក់ ឬច្រើននាក់ដែលមានគុណវុឌ្ឍិស័ក្តសម អំពីចំនួនខូចខាតនៅសមុទ្រ ឬឧប្បត្តិហេតុនៃការធ្វើនាវាចរណ៍ នៅលើដែនសមុទ្រអន្តរជាតិ ដែលជាប់ពាក់ព័ន្ធនឹងនាវាដែលប្រើទង់របស់ខ្លួន និងដែលបណ្តាលឱ្យមានការ បាត់បង់អាយុជីវិត ឬបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋនៃរដ្ឋដទៃ ឬបង្កការខូចខាតធ្ងន់ធ្ងរដល់នាវា ឬ បបនកណ្ឌរបស់រដ្ឋដទៃ ឬដែលនាំឱ្យខូចខាតដល់បរិស្ថានសមុទ្រ។ រដ្ឋចុះបញ្ជីនាវា និងរដ្ឋដទៃទៀតត្រូវសហការ គានៅក្នុងការអង្កេតស្រាវជ្រាវដែលរដ្ឋម្ខាងទៀតចាត់ឡើង ដើម្បីកំណត់ពីចំនួនខូចខាតនៅសមុទ្រ ឬឧប្បត្តិ ហេតុនៃការធ្វើនាវាចរណ៍ ខាងលើ។

*មាត្រា ៩៥*

*អភ័យឯកសិទ្ធិនៃនាវាចម្បាំងដែលធ្វើដំណើរនៅលើដែនសមុទ្រអន្តរជាតិ*

នាវាចម្បាំងដែលធ្វើដំណើរនៅលើដែនសមុទ្រអន្តរជាតិត្រូវមានអភ័យឯកសិទ្ធិទាំងស្រុងពយុត្តាធិការនៃ រដ្ឋផ្សេងៗក្រៅពីរដ្ឋចុះបញ្ជីនាវា។

*មាត្រា ៩៦*

*អភ័យឯកសិទ្ធិនៃនាវាដែលប្រើសម្រាប់តែបំពេញ*

*មុខងារសាធារណៈមិនមែនគោលបំណងពាណិជ្ជកម្ម*

នាវាដែលជាកម្មសិទ្ធិ ឬបញ្ជាប្រតិបត្តិការដោយរដ្ឋាភិបាល ហើយដែលប្រើសម្រាប់តែបំពេញមុខងារ សាធារណៈមិនមែនសម្រាប់គោលបំណងពាណិជ្ជកម្មដែលធ្វើនាវាចរណ៍លើដែនសមុទ្រអន្តរជាតិ ត្រូវមានអភ័យ ឯកសិទ្ធិទាំងស្រុងពីយុត្តាធិការនៃរដ្ឋផ្សេងៗក្រៅពីរដ្ឋចុះបញ្ជីនាវា។

*មាត្រា ៩៧*

*យុត្តាធិការផ្នែកព្រហ្មទណ្ឌលើបញ្ហានៃការប៉ះទង្គិចនាវា*

*ឬឧប្បត្តិហេតុផ្សេងៗនៃការធ្វើនាវាចរណ៍*

១. ក្នុងករណីដែលមានការប៉ះទង្គិចគ្នារវាងនាវា ឬឧប្បត្តិហេតុផ្សេងៗនៃការធ្វើនាវាចរណ៍ទាក់ទងនឹងនាវានៅ ដែនសមុទ្រអន្តរជាតិ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬការដាក់ពិន័យចំពោះនាវាបតី ឬ បុគ្គលផ្សេងទៀតដែលធ្វើការនៅលើនាវា នោះករណីពុំអាចនាំទៅដល់បណ្តឹងព្រហ្មទណ្ឌ ឬឱ្យដាក់ពិន័យណា មួយមកលើបុគ្គលទាំងនេះឡើយ វៀរលែងតែធ្វើឡើងនៅចំពោះមុខអាជ្ញាធរតុលាការ ឬផ្នែករដ្ឋបាលនៃរដ្ឋចុះបញ្ជីនាវា ឬរដ្ឋដែលបុគ្គលនោះទទួលបានសញ្ជាតិ។

២. សម្រាប់បញ្ហាខាងដាក់ពិន័យ រដ្ឋដែលផ្តល់វិញ្ញាបនបត្រនាវាបតី ឬវិញ្ញាបនបត្របញ្ជាក់សមត្ថភាព ឬអាជ្ញាប័ណ្ណ ត្រូវមានសមត្ថកិច្ចតែមួយគត់ក្នុងការប្រកាសដកហូតវិញ្ញាបនបត្រទាំងនេះ

ស្របតាមនីតិវិធីច្បាប់ត្រឹមត្រូវ បើទោះជាសាមីខ្លួនមិនមែនជាប្រជាពលរដ្ឋនៃរដ្ឋដែលផ្តល់វិញ្ញាបនបត្រទាំងនេះក៏ដោយ។

៣. គ្មាននាវាណាមួយត្រូវបានចាប់យក ឬឃាត់ទុកសម្រាប់បម្រើដល់ការស៊ើបអង្កេតតាមការបង្គាប់បញ្ជាពី អាជ្ញាធរណាមួយក្រៅពីអាជ្ញាធរនៃរដ្ឋចុះបញ្ជីនាវានោះឡើយ។

*មាត្រា ៩៨*

*កាតព្វកិច្ចក្នុងការផ្តល់ជំនួយ*

១. បណ្តារដ្ឋនីមួយៗត្រូវតម្រូវឱ្យនាវាបតីនៃនាវាណាមួយដែលប្រើទង់នៃរដ្ឋនោះតាមលទ្ធភាពដែលអាចធ្វើទៅ បានដោយពុំបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់នាវា ឬឱ្យក្រុមនាវិក ឬអ្នកដំណើរលើនាវា ៖

(ក) ផ្តល់នូវជំនួយដល់បុគ្គលណាមួយដែលប្រទះឃើញនៅលើសមុទ្រ ស្ថិតក្នុងគ្រោះថ្នាក់ដោយការវង្វេងផ្លូវ។

(ខ) ដំណើរការជួយសង្គ្រោះមនុស្ស ដែលជួបវិបត្តិតាមលទ្ធភាពដែលឆាប់បំផុតកាលបើទទួលការពឹងពាក់ឱ្យជួយពីអ្នកទាំងនោះ ដោយផ្អែកទៅតាមកាលៈទេសៈជាក់ស្តែង។

(គ) ផ្តល់ជំនួយដល់នាវាម្ខាង រួមទាំងក្រុមនាវិក និងអ្នកដំណើរនៅលើនាវានោះក្រោយពីមានការប៉ះទង្គិចគ្នា និងប្រសិនបើអាចធ្វើទៅបាន ត្រូវជូនដំណឹងទៅដល់នាវាម្ខាងអំពីឈ្មោះនៃនាវារបស់ខ្លួន កំពង់ផែចុះបញ្ជីរបស់ខ្លួន និងកំពង់ផែដែលនៅជិតបំផុតសម្រាប់ទំនាក់ទំនង។

២. បណ្តារដ្ឋជាប់ឆ្នេរនីមួយៗត្រូវជំរុញដល់ការបង្កើតកិច្ចប្រតិបត្តិការ និងការរក្សាឱ្យមាននូវសេវាស្រាវជ្រាវ និងជួយសង្គ្រោះឱ្យបានគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាពទាក់ទងនឹងផ្នែកសុវត្ថិភាពលើដែនសមុទ្រ និងត្រូវផ្តល់ការសហការជាមួយបណ្តារដ្ឋជិតខាង តាមរយៈការចុះកិច្ច

ព្រមព្រៀងថ្នាក់តំបន់ទៅមវិញទៅមក សម្រាប់គោលដៅនេះ ដោយផ្អែកទៅតាមកាលៈទេសៈជាក់ស្តែងនីមួយៗ។

*មាត្រា ៩៩*
*ការហាមឃាត់លើការដឹកជញ្ជូនទាសករ*

បណ្តារដ្ឋនីមួយៗត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីបង្ការ និងផ្តន្ទាទោសចំពោះការដឹកជញ្ជូន ទាសករនៅក្នុងនាវាដែលទទួលបានការអនុញ្ញាតឱ្យប្រើទង់នៃរដ្ឋនោះ និងដើម្បីបង្ការទប់ស្កាត់ការលួចប្រើប្រាស់ដោយ ខុសច្បាប់នូវទង់នៃរដ្ឋនោះសម្រាប់អនុវត្តនូវគោលបំណងខាងលើ។ ទាសករដែលជ្រកកោននៅលើនាវា មិនថាជាទង់ នៃរដ្ឋនោះឬយ៉ាងណានោះទេ ត្រូវតែដោះលែងឱ្យមានសិទ្ធិសេរីភាពដោយផ្អែកទៅតាមកាលៈទេសៈជាក់ស្តែង។

*មាត្រា ១០០*
*កាតព្វកិច្ចសហប្រតិបត្តិការបង្ក្រាបអំពើចោរកម្មតាមសមុទ្រ*

បណ្តារដ្ឋទាំងអស់ ត្រូវចូលរួមសហការឱ្យអស់ពីលទ្ធភាពនៅក្នុងការបង្ក្រាបអំពើប្លន់នៅតាមដែនសមុទ្រ អន្តរជាតិ ឬនៅកន្លែងផ្សេងទៀតដែលស្ថិតនៅក្រៅវង្វង់នៃយុត្តាធិការរបស់រដ្ឋនោះ។

*មាត្រា ១០១*
*និយមន័យនៃអំពើចោរកម្មតាមសមុទ្រ*

អំពើចោរកម្មតាមសមុទ្រត្រូវមានធាតុផ្សំនៃបទល្មើសដូចតទៅ ៖

(ក) អំពើល្មើសច្បាប់ដោយហិង្សា ឬការឃុំឃាំងបង្ខាំងរូបកាយ ឬអំពើឆក់ប្លន់ណាមួយ ដែលធ្វើឡើងមកលើ បុគ្គលឯកជនដោយសមាជិកនាវិក ឬអ្នកដំណើរនៅលើនាវា ឬអាកាសយានឯកជនមួយ ហើយដែលធ្វើដំណើរក្នុងទិសដៅ ៖

(i) នៅលើដែនសមុទ្រអន្តរជាតិប្រឆាំងនឹងនាវា ឬអាកាសយានមួយផ្សេងទៀត ឬប្រឆាំងមកលើបុគ្គល ឬ ទ្រព្យសម្បត្តិនៅលើនាវា ឬអាកាសយានិកនោះ ។

(ii) ប្រឆាំងនឹងនាវា អាកាសយានិក បុគ្គល ឬទ្រព្យសម្បត្តិនៅកន្លែងផ្សេងស្ថិតនៅក្រៅវង្វង់នៃដែន យុត្តាធិការរបស់រដ្ឋនោះ ។

(ខ) អំពើចូលរួមដោយការស្ម័គ្រចិត្តនៅក្នុងការបញ្ជានាវា ឬអាកាសយាន ដោយដឹងច្បាស់ថាជានាវា ឬអាកាសយានដែលជាមុខសញ្ញាចោរកម្មតាមសមុទ្រ។

(គ) អំពើញុះញង់ ឬជួយសម្រួលដោយចេតនាដល់ការប្រព្រឹត្តិបទល្មើសដូចមានចែងក្នុងកថាខណ្ឌ(ក) ឬ (ខ)។

*មាត្រា ១០២*

*អំពើចោរកម្មតាមសមុទ្រដោយនាវាចម្បាំង នាវារដ្ឋាភិបាល*

*ឬអាកាសយានរដ្ឋាភិបាលដែលជនល្មើសជានាវិក*

សកម្មភាពចោរកម្មតាមសមុទ្រ ដូចមានកំណត់នៅក្នុងមាត្រា ១០១ ធ្វើឡើងដោយនាវាចម្បាំង ឬអាកាសយាន រដ្ឋាភិបាល ដែលជនល្មើសជានាវិក និងគ្រប់គ្រងនាវា ឬអាកាសយាន ត្រូវបានចាត់ទុកថា ស្មើនឹងសកម្មភាពដែលធ្វើឡើង ដោយនាវា ឬអាកាសយានចោរសមុទ្រ។

*មាត្រា ១០៣*

*និយមន័យនៃនាវា ឬអាកាសយានចោរសមុទ្រ*

នាវា ឬអាកាសយាន ត្រូវបានចាត់ទុកថាជានាវា ឬអាកាសយានចោរសមុទ្រ ប្រសិនបើបុគ្គលមានអំណាចគ្រប់គ្រង មានចេតនាប្រើប្រាស់ធ្វើសកម្មភាពណាមួយដូចមានចែងក្នុងមាត្រា ១០១។ ការកំណត់និយមន័យនេះធ្វើឡើងដូចគ្នា ក្នុងករណីដែលនាវា ឬអាកាសយានស្ថិតក្រោមការប្រើប្រាស់ធ្វើសកម្មភាព បែបនេះដោយពិរុទ្ធជន។

*មាត្រា ១០៤*
*ការរក្សា ឬបាត់បង់សញ្ជាតិនាវា ឬអាកាសយានចោរសមុទ្រ*

នាវា ឬអាកាសយាន នឹងអាចរក្សាបានសញ្ជាតិរបស់ខ្លួន ទោះបីក្លាយជានាវា ឬអាកាសយានចោរសមុទ្រ ហើយក៏ដោយ។ សញ្ជាតិនឹងត្រូវបានរក្សា ឬបាត់បង់តាមការកំណត់ដោយច្បាប់រដ្ឋដែលជាប្រភពនៃនាវា ឬ អាកាសយាននោះ។

*មាត្រា ១០៥*
*ការរឹបអូសនាវា ឬអាកាសយានចោរសមុទ្រ*

នៅដែនសមុទ្រអន្តរជាតិ ឬនៅតាមទីតាំងដែលស្ថិតនៅក្រៅយុត្តាធិការរដ្ឋណាមួយរដ្ឋទាំងអស់អាចនឹង រឹបអូសនាវា ឬអាកាសយានចោរសមុទ្រ ឬនាវា ឬអាកាសយានដែលត្រូវបានប្លន់ក្នុងសកម្មភាពចោរកម្មតាមសមុទ្រ ហើយដែលស្ថិតក្រោមការគ្រប់គ្រងរបស់ចោរសមុទ្រ ព្រមទាំងឃាត់ខ្លួនបុគ្គល និងរឹបអូសទ្រព្យសម្បត្តិដែលមាន។ តុលាការ នៃរដ្ឋដែលអនុវត្តការរឹបអូសនេះ មានសមត្ថកិច្ចសម្រេចដាក់ទោសពិន័យ ព្រមទាំងកំណត់អំពីចំណាត់ការ ដែលត្រូវអនុវត្តចំពោះនាវាអាកាសយាន អាស្រ័យទៅលើសិទ្ធិរបស់ភាគីទីបី ក្នុងការធ្វើសកម្មភាពដោយសុឆន្ទៈ។

*មាត្រា ១០៦*

*ការទទួលខុសត្រូវចំពោះការរឹបអូសដោយគ្មានមូលដ្ឋានច្បាស់លាស់*

ក្នុងករណីអនុវត្តការរឹបអូសនាវា ឬអាកាសយានដែលសង្ស័យថាស្ថិតក្នុងបទចោរកម្មតាមសមុទ្រដោយគ្មាន មូលដ្ឋានច្បាស់លាស់ រដ្ឋដែលអនុវត្តការរឹបអូសនេះ ត្រូវទទួលខុសត្រូវចំពោះរដ្ឋដែលជាម្ចាស់សញ្ជាតិនាវា ឬ អាកាសយានលើការខាតបង់ ឬភាពខូចខាតបណ្តាលមកពីសកម្មភាពរឹបអូសនេះ។

*មាត្រា ១០៧*

*ប្រភេទនាវា និងអាកាសយានត្រូវរឹបអូសក្នុងករណីចោរកម្មតាមសមុទ្រ*

ការរឹបអូសក្នុងករណីចោរកម្មតាមសមុទ្រ អាចនឹងត្រូវអនុវត្តដោយនាវាចម្បាំង ឬអាកាសយានយោធា ឬនាវា ឬអាកាសយានផ្សេងទៀត ដែលបង្ហាញ និងកំណត់យ៉ាងច្បាស់លាស់ថាកំពុងបំពេញបេសកកម្មជូនរដ្ឋាភិបាល និងដែលមានអំណាចអនុវត្តការរឹបអូសនេះ។

*មាត្រា ១០៨*

*ចរាចរណ៍ខុសច្បាប់នូវសារធាតុញៀន ណាកូទីក ឬឱសថសរសៃប្រសាទ*

១. រដ្ឋទាំងអស់ត្រូវសហការគ្នាក្នុងការទប់ស្កាត់ការចែកចាយសារធាតុញៀន ណាកូទីក និងឱសថសរសៃប្រសាទ តាមនាវានៅដែនសមុទ្រអន្តរជាតិ ដែលជាសកម្មភាពផ្ទុយពីអនុសញ្ញាអន្តរជាតិនេះ។

២. រដ្ឋណាមួយដែលមានមូលដ្ឋានច្បាស់លាស់ជឿជាក់ថា នាវាដែលចងទង់ជាតិខ្លួនចូលពាក់ព័ន្ធនឹងសកម្មភាព ចរាចរណ៍ខុសច្បាប់ថ្នាំណាកូទីន ឬសារធាតុពង្វក់សតិ អាចស្នើសុំការសហការពីរដ្ឋផ្សេងៗទៀតធ្វើការបង្ក្រាប សកម្មភាពចែកចាយនេះ។

*មាត្រា ១០៩*

*ការប្រកាសព័ត៌មានដោយគ្មានការអនុញ្ញាតពីដែនសមុទ្រអន្តរជាតិ*

១. រដ្ឋទាំងអស់ត្រូវសហការក្នុងការទប់ស្កាត់ការប្រកាសព័ត៌មានដោយគ្មានការអនុញ្ញាតពីដែនសមុទ្រអន្តរជាតិ។

២. ក្នុងអនុសញ្ញានេះ "ការប្រកាសព័ត៌មានដោយគ្មានការអនុញ្ញាត" មានន័យថា ការបញ្ជូនសម្លេងវិទ្យុ ទូរទស្សន៍ពីនាវា ឬឋបនភណ្ឌនៅដែនសមុទ្រអន្តរជាតិដោយចេតនាដើម្បីទទួលបានការចាប់អារម្មណ៍ពីសាធារណជនដែលផ្ទុយពី បទបញ្ញត្តិអន្តរជាតិ វៀរលែងតែការប្រកាសក្នុងករណី បន្ទាន់។

៣. ចំពោះបុគ្គលពាក់ព័ន្ធនឹងការប្រកាសព័ត៌មានដោយគ្មានការអនុញ្ញាត អាចនឹងត្រូវផ្តន្ទាទោស នៅចំពោះមុខតុលាការនៃ ៖

(ក) រដ្ឋចុះបញ្ជីនាវា

(ខ) រដ្ឋនៃឋបនភណ្ឌបានចុះបញ្ជី

(គ) រដ្ឋនៃសញ្ជាតិបុគ្គលនោះ

(ឃ) រដ្ឋជាគោលដៅទទួលបានរលកបញ្ជូនព័ត៌មាននោះ ឬ

(ង) រដ្ឋដែលរលកវិទ្យុទាក់ទងស្របច្បាប់រងការរំខាន។

៤. បណ្តារដ្ឋក្នុងដែលមានយុត្តាធិការនៅដែនសមុទ្រអន្តរជាតិមានចែងក្នុងកថាខណ្ឌទី ៣ អាចឃាត់ខ្លួនបុគ្គល ឬនាវា ដែលជាប់ពាក់ព័ន្ធនឹងការបញ្ជូនដំណឹង និងការរឹបអូសបរិក្ខារបញ្ជូនដំណឹងនេះ ដោយអនុលោមតាមមាត្រា ១១០។

*មាត្រា ១១០*

*សិទ្ធិចុះត្រួតពិនិត្យ*

១.	លើកលែងតែមានវិធានផ្សេងទៀតកើតចេញពីអំណាចផ្តល់ជូនដោយ សន្ធិសញ្ញានេះ នាវាចម្បាំងដែល ប្រឈមនឹងនាវាបរទេសនៅដែនសមុទ្រអន្តរជាតិ ជានាវាដែលទទួលបាន អភ័យឯកសិទ្ធិពេញលេញតាមមាត្រា ៩៥ និង៩៦ មិនត្រូវបានអនុញ្ញាតឱ្យឡើងនាវានោះឡើយ លើកលែងតែមានមូលដ្ឋានច្បាស់លាស់សង្ស័យថា ៖

(ក) នាវានោះពាក់ព័ន្ធនឹងសកម្មភាពចោរកម្មតាមសមុទ្រ

(ខ) នាវានោះពាក់ព័ន្ធនឹងការធ្វើអាជីវកម្មទាសករ

(គ) នាវានោះពាក់ព័ន្ធនឹងការបញ្ជូនដំណឹងដោយគ្មានការអនុញ្ញាត ហើយរដ្ឋចុះបញ្ជីនាវាចមង្បាំនោះ មានយុត្តាធិការ តាមមាត្រា ១០៩

(ឃ) នាវាគ្មានសញ្ជាតិ ឬ

(ង) ទោះបីជាចងទង់ជាតិបរទេស ឬបដិសេធមិនព្រមបង្ហាញទង់ជាតិរបស់ខ្លួនក៏ដោយ តាមភាពពិតជាក់ស្តែង នាវានោះត្រូវបានចាត់ទុកជានាវាចម្បាំងដែលមានសញ្ជាតិដូចគ្នានោះដែរ។

២.	តាមករណីនានាក្នុងកថាខណ្ឌទី១ នាវាចម្បាំងអាចធ្វើការបញ្ជាក់អំពីសិទ្ធិរបស់នាវាដែលចងទង់ជាតិខ្លួន។ ក្នុងគោលបំណងនេះ នាវាចម្បាំងអាចនឹងបញ្ជូនទូកមួយគ្រឿងតាមបញ្ជាមន្ត្រីដែលសង្ស័យចំពោះនាវានោះ។ ក្នុងករណី នៅតែមានការសង្ស័យទោះបីជាក្រោយពេលត្រួតពិនិត្យឯកសារនោះ ខ្លួននឹងធ្វើការត្រួតពិនិត្យបន្ថែមនៅលើនាវាដែល ត្រូវអនុវត្តឡើងតាមការពិចារណាដែលមាន។

៣.	ប្រសិនបើការសង្ស័យមិនអាចត្រូវបានរកឃើញនោះ និងប្រសិនបើនាវាមិនបានធ្វើអ្វីដែលនាំទៅរកការវិនិច្ឆ័យ របស់ខ្លួននោះ នាវានឹងទទួលបានសំណងចំពោះការខាតបង់ ឬការខូចខាតជាក់ស្តែង។

៤.	បទបញ្ញត្តិទាំងនេះរួមទាំងវិសោធនកម្មរបស់វា ត្រូវអនុវត្តលើអាកាសយានយោធា។

៥.	បទបញ្ញត្តិទាំងនេះ ក៏ត្រូវអនុវត្តលើនាវា ឬអាកាសយានស្របច្បាប់ផ្សេងទៀតដែលបង្ហាញ និងកំណត់យ៉ាងច្បាស់ថា កំពុងបម្រើការជូនរដ្ឋផងដែរ។

*មាត្រា ១១១*

*សិទ្ធិតាមចាប់*

១. ការតាមចាប់ភ្លាមៗនូវនាវាបរទេស អាចអនុវត្តបាននៅពេលដែលអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋមានឆ្នេរសមុទ្រ មានហេតុផលត្រឹមត្រូវជឿជាក់បានថា នាវានោះបានបំពានច្បាប់ និងបទបញ្ជារដ្ឋនោះ។ ការតាមចាប់នេះ ត្រូវចាប់ផ្ដើមឡើងនៅពេលដែលនាវាបរទេស ឬទូកមួយរបស់ខ្លួននៅក្នុងដែនទឹកខាងក្នុង ដែនទឹកកំណាយបុរាណវិទ្យា ដែនទឹក ឬតំបន់ត្រួតស៊ីគ្នានៃរដ្ឋដែលកំពុងធ្វើការតាមចាប់ និងអាចគ្រាន់តែបន្តនៅក្រៅ ដែនទឹក ឬតំបន់ត្រួតស៊ីគ្នា ប្រសិនបើការតាមចាប់នោះមិនត្រូវបានបង្អាក់រំខាន។ វាមិនសំខាន់ទេ នៅពេលដែលនាវាបរទេសនៅក្នុងដែនទឹក ឬតំបន់ត្រួតស៊ីគ្នា ទទួលបានបញ្ជា ឬក៏ដូចគ្នាថា នាវា ដែលទទួលបានបញ្ជាគួរនៅក្នុងដែនទឹក ឬតំបន់ត្រួតស៊ីគ្នា។ ប្រសិនបើនាវាបរទេសនៅតំបន់ត្រួតស៊ីគ្នា ដូចកំណត់នៅក្នុងមាត្រា ៣៣ នោះការតាមចាប់អាចធ្វើឡើង បានតែក្នុង ករណីដែលមានការបំពានសិទ្ធិការពារនៅតំបន់នោះប៉ុណ្ណោះ។

២. សិទ្ធិតាមចាប់ភ្លាមៗនេះ ត្រូវអនុវត្ត *រួមជាមួយច្បាប់វិសោធនកម្ម* លើការបំពាននៅក្នុងតំបន់សេដ្ឋកិច្ច ពិសេសផ្ដាច់មុខ ឬបនភណ្ឌនៅតំបន់ខ្ពង់រាបបាតសមុទ្រ រួមទាំងច្បាប់ និងបទបញ្ញត្តិរដ្ឋជាប់ឆ្នេរជាធរមានតាម អនុសញ្ញាលើតំបន់សេដ្ឋកិច្ចផ្ដាច់មុខ ឬតំបន់ខ្ពង់រាបបាតសមុទ្រ រួមទាំងតំបន់សុវត្ថិភាពផងដែរ។

៣. សិទ្ធិតាមចាប់ភ្លាមៗនេះ ត្រូវបាត់បង់នៅពេលដែលនាវាដែលត្រូវបានដេញចាប់បានចូលទៅក្នុងដែនទឹករបស់រដ្ឋជាម្ចាស់ផ្ទះ ឬរដ្ឋទីបី។

៤. ការតាមចាប់ភ្លាមៗ មិនត្រូវបានចាប់ផ្ដើមឡើយ ប្រសិនបើនាវាដែលកំពុងតាមចាប់មិនបានបំពេញតាម តម្រូវការ ខ្លួនដោយមធ្យោបាយជាក់ស្ដែងដែលថា នាវាតាមចាប់ ឬទូករបស់ខ្លួន ឬយានណាមួយរបស់ខ្លួន កំពុងធ្វើការ ជាក្រុម និងប្រើប្រាស់នាវាតាមចាប់នាវាមេ នៅក្នុងព្រំដែនទឹក ឬក្នុងករណីដែលមានតំបន់ត្រួតគ្នា ឬតំបន់សេដ្ឋកិច្ច ផ្ដាច់មុខ ឬតំបន់ខ្ពង់រាបបាតសមុទ្រខាងលើ។ ការតាមចាប់អាចចាប់ផ្ដើមឡើង តែក្រោយពេលសញ្ញាឱ្យឈប់ដែលអាចមើល ឃើញ ឬស្ដាប់ឮត្រូវបានធ្វើឡើងក្នុងចំងាយមួយដែលអាចមើលឃើញ ឬស្ដាប់ឮដោយនាវាបរទេស។

៥.	សិទ្ធិតាមចាប់ភ្លាមៗ អាចត្រូវអនុវត្តបានដោយនាវាចម្បាំង ឬយានជំនិះកងទ័ព ឬនាវា ឬយានផ្សេងទៀត ដែល មានដាក់សញ្ញា និងអាចកំណត់បានយ៉ាងច្បាស់ថា កំពុងបំពេញការងារជូន រដ្ឋ និងត្រូវបានផ្តល់សិទ្ធិអំណាច លើការអនុវត្តនោះ។

៦.	នៅពេលដែលការតាមចាប់ភ្លាមៗ អនុវត្តដោយអាកាសយាន ៖

(ក)	បទបញ្ញត្តិនៃកថាខណ្ឌទី១ ដល់កថាខណ្ឌទី៤ ត្រូវអនុវត្តរួមទាំង *វិសោធនកម្ម របស់វាផងដែរ។*

(ខ)	អាកសាយានដែលចេញបញ្ជាឱ្យឈប់ ត្រូវតាមចាប់នាវាដោយខ្លួនឯង រហូតទាល់តែនាវា ឬអាកាសយានផ្សេងទៀតរបស់ រដ្ឋជាប់ឆ្នេរ ដែលបានកោះហៅដោយអាកាសយាន ទៅដល់ដើម្បីចាប់ផ្តើមធ្វើការតាមចាប់ ប្រសិនបើអាកាសយាន មិនអាចចាប់ឃាត់នាវា នោះដោយខ្លួនឯងបាន។ វាមិនគ្រប់គ្រាន់ឡើយក្នុងការវិនិច្ឆ័យធ្វើការចាប់ទុកនៅក្រៅ ដែនទឹកដែលនាវាគ្រាន់តែត្រូវបានអាកាសយានមើលឃើញថាបានប្រព្រឹត្តិល្មើស ឬត្រូវបានសង្ស័យថាបានប្រព្រឹត្តិល្មើស ប្រសិនបើ វាមិនត្រូវបានបញ្ជាឱ្យឈប់ និងតាមចាប់ដោយអាកាសយាននោះ ឬអាកាសយាន ឬនាវាផ្សេងទៀត ដែលបន្តការតាមចាប់ ដោយគ្មានការបង្អាក់។

៧.	ការដោះលែងនាវានៅក្នុងយុត្តាធិការរបស់រដ្ឋមួយ និងត្រូវបានអមដំណើរទៅកាន់កំពង់ផែរដ្ឋនោះ ដើម្បីស្ងួរចម្លើយ មុនពេលអាជ្ញាធរមានសមត្ថកិច្ច អាចនឹងមិនត្រូវបានទាមទារដោយឈរលើមូលដ្ឋានតែមួយថានាវា កំពុងនៅលើគន្លងផ្លូវធ្វើដំណើររបស់ខ្លួន ត្រូវបានអមដំណើរឆ្លងកាត់តំបន់សេដ្ឋកិច្ច ឬដែនសមុទ្រអន្តរជាតិ ប្រសិនបើ ពិតជាមានសារសំខាន់មែននោះ។

៨.	នៅពេលដែលនាវាត្រូវបានបញ្ឈប់ ឬឃាត់ទុកនៅក្រៅដែនទឹកក្នុងកាលៈទេសៈដែលមិនកំណត់វិនិច្ឆ័យ ថាត្រូវអនុវត្តសិទ្ធតាមចាប់ភ្លាមៗ ខ្លួននឹងទទួលបានសំណងសម្រាប់ការខាតបង់ ឬខូចខាតដែលខ្លួនជួបប្រទះ។

*មាត្រា ១១២*

*សិទ្ធិដាក់ពង្រាយបណ្ដាញកាប្លិ៍ និងបំពង់បញ្ជូនប្រេងនៅបាតសមុទ្រ*

១. រដ្ឋទាំងអស់មានសិទ្ធិដាក់ពង្រាយខ្សែកាប្លិ៍ និងបំពង់បញ្ជូនប្រេងនៅបាតសមុទ្រលើបាតសមុទ្រនៃដែនសមុទ្រ អន្តរជាតិក្រៅពីជាយទ្វីប។

២. កថាខណ្ឌទី ៥ នៃមាត្រា ៧៩ អនុវត្តលើបណ្ដាញកាប្លិ៍ និងបំពង់បញ្ជូនប្រេងនានា។

*មាត្រា ១១៣*

*ការបែកបាក់ ឬខូចខាតបណ្ដាញកាប្លិ៍ ឬបំពង់បញ្ជូនប្រេងនៅបាតសមុទ្រ*

រដ្ឋទាំងអស់ត្រូវអនុម័តច្បាប់ និងបទបញ្ញត្តិចាំបាច់ក្នុងករណីដែលការបែកបាក់ ឬខូចខាតដោយនាវាដែលចង ទង់ជាតិរបស់ខ្លួន ឬដោយបុគ្គលណាមួយស្ថិតក្នុងយុត្តាធិការខ្សែកាប្លិ៍នៅបាតសមុទ្រនៃដែនសមុទ្រអន្តរជាតិត្រូវបាន ធ្វើឡើងដោយចេតនា ឬការធ្វេសប្រហែសដោយកំហុសដែលនាំឱ្យមានការទទួលខុសត្រូវចំពោះការរំខាន ឬរអាក់រអួលដល់ប្រព័ន្ធទូរគមនាគមន៍តាមទូរលេខ ឬទូរស័ព្ទ និងករណីស្រដៀងនឹងការបែកបាក់ ឬការខូចខាតបំពង់ បញ្ជូនប្រេងនៅបាតសមុទ្រ ឬខ្សែកាប្លិ៍ថាមពលតុងស្យុងខ្ពស់ ត្រូវបានចាត់ទុកជាបទល្មើសត្រូវទទួលពិន័យ។បទបញ្ញត្តិនេះត្រូវអនុវត្តផងដែរលើសកម្មភាពដែលត្រូវបានចាត់ទុកថា ឬមានភាពស្រដៀងទៅនឹងលទ្ធផលដែលធ្វើឱ្យបាក់បែក ឬខូចខាត។ ប៉ុន្តែ វាមិនត្រូវបានអនុវត្តលើការបែកបាក់ ឬខូចខាតដែលបង្កឡើងដោយបុគ្គលដែលធ្វើឡើងគ្រាន់តែក្នុង គោលបំណងស្របច្បាប់ ជួយសង្គ្រោះជីវិតពួកគេ ឬនាវាពួកគេក្រោយពេលបានចាត់វិធានការប្រុងប្រយ័ត្នចាំបាច់នានា ដើម្បីបញ្ចៀសការបែកបាក់ ឬខូចខាតនោះហើយ។

*មាត្រា ១១៤*

*ការបង្កឱ្យបែកបាក់ ឬខូចខាតដោយម្ចាស់បណ្ដាញកាប្លិ៍*

*ឬបំពង់បញ្ជូនប្រេងនៅបាតសមុទ្រលើបណ្ដាញកាប្លិ៍*
*ឬបំពង់បញ្ជូនប្រេងនៅបាតសមុទ្រផ្សេងទៀត*

រដ្ឋទាំងអស់ត្រូវអនុម័តច្បាប់ និងបទបញ្ញត្តិចាំបាច់នានា ក្នុងករណីប្រសិនបើបុគ្គលនៅក្នុងយុត្តាធិការរបស់ ខ្លួនដែលជាម្ចាស់ខ្សែកាប្លិ៍ ឬបំពង់បញ្ជូនប្រេងនៅបាតដែនសមុទ្រអន្តរជាតិ នៅក្នុងការដាក់ពង្រាយ ឬជួសជុលបណ្ដាញ កាប្លិ៍ ឬបំពង់បញ្ជូននោះ បង្កការបែកបាក់ ឬខូចខាតលើខ្សែកាប្លិ៍ ឬបំពង់បញ្ជូនប្រេងផ្សេងទៀតនោះ ពួកគេត្រូវទទួល បន្ទុកលើការចំណាយ។

*មាត្រា ១១៥*
*សំណងលើការខូចខាតដែលកើតមានក្នុងពេលបញ្ចៀស*
*ការខូចខាតលើខ្សែកាប្លិ៍ ឬបំពង់បញ្ជូនប្រេងនៅបាតសមុទ្រ*

គ្រប់រដ្ឋទាំងអស់ត្រូវអនុម័តច្បាប់ និងបទបញ្ញត្តិដែលចាំបាច់ដើម្បីធានាឱ្យបានថា នាវាបតីដែលបញ្ជាក់បាន ថាពួកគេបានបោះយុថ្កា សំណាញ់ ឬមងនេសាទផ្សេងទៀតដើម្បីបញ្ចៀសការខូចខាតដល់បណ្ដាញកាប្លិ៍ ឬបំពង់បញ្ជូន នៅបាតសមុទ្រ ត្រូវរួចផុតពីការបង់សំណងទាមទារដោយម្ចាស់បណ្ដាញកាប្លិ៍ ឬបំពង់បញ្ជូននៅបាត សមុទ្រ ប្រសិនបើ នាវាបតីបានចាត់វិធានការប្រុងប្រយ័ត្នយ៉ាងសមស្របជាមុននោះ។

ជំពូកទី២៖ កិច្ចអភិរក្ស និងការគ្រប់គ្រងធនធានមានជីវិតនៅដែនសមុទ្រអន្តរជាតិ

*មាត្រា ១១៦*
*សិទ្ធិក្នុងការនេសាទនៅដែនសមុទ្រអន្តរជាតិ*

រដ្ឋទាំងអស់មានសិទ្ធិអនុញ្ញាតឱ្យពលរដ្ឋរបស់ខ្លួនធ្វើការនេសាទនៅដែនសមុទ្រអន្តរជាតិស្ថិតក្រោម ៖

(ក) កាតព្វកិច្ចក្រោមសន្ធិសញ្ញារបស់ខ្លួន

(ខ) សិទ្ធិ និងកាតព្វកិច្ច ព្រមទាំងអត្ថប្រយោជន៍រដ្ឋជាប់ឆ្នេរ ក្នុងករណីមានចែង *ក្នុង*
កថាខណ្ឌទី ២ នៃ *មាត្រា* ៦៣ និងមាត្រា ៦៤ ដល់ ៦៧ និង

(គ) បទបញ្ញត្តិក្នុងជំពូកនេះ។

*មាត្រា ១១៧*

*កាតព្វកិច្ចរបស់រដ្ឋក្នុងការអនុម័តវិធានការសម្រាប់ពលរដ្ឋរបស់*
*ខ្លួនទាក់ទងនឹងធនធានមានជីវិតនៅដែនសមុទ្រអន្តរជាតិ*

រដ្ឋទាំងអស់មានភារកិច្ចក្នុងការចាត់វិធានការ ឬសហការជាមួយរដ្ឋដទៃក្នុងការអនុវត្តវិធានការលើពលរដ្ឋរបស់ខ្លួនតាមដែលយល់ថាចាំបាច់ក្នុងការអភិរក្សធនធានមានជីវិតនៅដែនសមុទ្រអន្តរជាតិ។

*មាត្រា ១១៨*
*កិច្ចសហប្រតិបត្តិការបណ្តារដ្ឋនៅក្នុង*
*ការអភិរក្ស និងគ្រប់គ្រងធនធានមានជីវិត*

បណ្តារដ្ឋត្រូវចូលរួមសហការនៅក្នុងការអភិរក្ស និងគ្រប់គ្រងធនធានមានជីវិតនៅតំបន់ដែនសមុទ្រ អន្តរជាតិ។ រដ្ឋដែលប្រជាពលរដ្ឋខ្លួនធ្វើអាជីវកម្មលើធនធានមានជីវិតប្រភេទតែមួយ ឬធនធានមានជីវិតប្រភេទ ខុសគ្នានៅក្នុងតំបន់តែមួយ ត្រូវចុះកិច្ចចរចា ជាមួយនឹងទស្សនៈចាត់វិធានការចាំបាច់លើការអភិរក្សធនធាន មានជីវិតពាក់ព័ន្ធ។ រដ្ឋទាំងនោះ ត្រូវសហការគ្នាដើម្បីបង្កើតអង្គភាពនៃសាទតំបន់ ឬអនុតំបន់ក្នុងគោលបំណងនេះ តាមការចាំបាច់។

*មាត្រា ១១៩*

*កិច្ចអភិរក្សធនធានមានជីវិតនៅក្នុងដែនសមុទ្រអន្តរជាតិ*

១. នៅក្នុងការកំណត់ពីតំបន់នេសាទដែលអនុញ្ញាត និងការបង្កើតវិធានការអភិរក្សធនធានមានជីវិតនៅ ដែនសមុទ្រអន្តរជាតិនោះ រដ្ឋទាំងអស់នោះត្រូវ ៖

(ក) ចាត់វិធានការដែលបានកំណត់ឡើងផ្អែកតាមភស្តុតាងវិទ្យាសាស្ត្រដែលមានសម្រាប់រដ្ឋពាក់ព័ន្ធ ដើម្បីរក្សា និងស្តារប្រភេទពូជសម្រាប់នេសាទ ក្នុងកម្រិតមួយដែលអាចឱ្យកកើតឡើងវិញបានជា អតិបរមា ដែលសម្គាល់ដោយកត្តាបរិស្ថាន និងសេដ្ឋកិច្ចរាប់បញ្ចូលទាំងលក្ខខណ្ឌពិសេសៗនៃបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ និងពិចារណាទៅលើលំនាំនៃការនេសាទ អន្តរនិស្សរភាពនៃស្តុក និងបទដ្ឋាន អន្តរជាតិអប្បបរិមាដែលបានផ្តល់អនុសាសន៍ជាទូទៅ មិនថានៅថ្នាក់អនុតំបន់ តំបន់ ឬជាសកល នោះទេ។

(ខ) ពិចារណាអំពីផលប៉ះពាល់ទៅលើប្រភេទពូជដែលទាក់ទងនឹង ឬចំណុះនឹងប្រភេទពូជ សម្រាប់ នេសាទជាមួយនឹងទស្សនៈថែរក្សា ឬស្តារប្រភេទពូជពាក់ព័ន្ធ ឬដែលចំណុះនឹងប្រភេទពូជខាងលើ ដែលការកកើតឡើងវិញអាចនឹងរងការគំរាមកំហែង។

២. ចែករំលែក និងផ្លាស់ប្តូរទៅវិញទៅមកជាទៀងទាត់នូវព័ត៌មានវិទ្យាសាស្ត្រ ស្ថិតិការនេសាទ និងតំបន់នេសាទ ព្រមទាំងទិន្នន័យពាក់ព័ន្ធផ្សេងទៀត ស្តីពីការអភិរក្សស្តុកត្រី តាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ចនានា មិនថា នៅថ្នាក់អនុតំបន់ តំបន់ ឬពិភពលោក ដែលមានភាពសមស្រប និងមានការចូលរួមពីបណ្តារដ្ឋពាក់ព័ន្ធ។

៣. បណ្តារដ្ឋពាក់ព័ន្ធត្រូវធានាឱ្យបានថាវិធានការអភិរក្ស និងការអនុវត្តនូវវិធានការទាំងនេះមិនមានភាព រើសអើងទោះជាតាមរូបភាព ឬតថភាពជាមួយចំពោះប្រជានេសាទនៃរដ្ឋណាមួយឡើយ។

*មាត្រា ១២០*

*ថនិកសត្វសមុទ្រ*

មាត្រា ៦៥ ត្រូវបានអនុវត្តផងដែរលើកិច្ចអភិរក្ស និងការគ្រប់គ្រងថនិកសត្វសមុទ្រនៅដែនសមុទ្រ អន្តរជាតិ។

## ផ្នែកទី៨៖ របបកោះ

*មាត្រា ១២១*

*របបកោះ*

១. កោះមានសណ្ឋានជាដីដុះបែបធម្មជាតិ ហ៊ុំព័ទ្ធទៅដោយទឹក និងលើនីវ៉ូទឹករលក។

២. លើកលែងតែមានចែងក្នុងកថាខណ្ឌទី៣ ស្តីពីដែនទឹក តំបន់ត្រួត តំបន់សេដ្ឋកិច្ចផ្តាច់មុខ និង តំបន់ខ្ពង់រាបបាតសមុទ្រនៃកោះមួយ ត្រូវបានកំណត់ស្របតាមបទបញ្ញត្តិនៃអនុសញ្ញាដែលអនុវត្តលើដែនដីផ្សេងទៀត។

៣. ថ្មដែលមិនមានលក្ខណៈអាចឱ្យមនុស្សជាតិតាំងលំនៅឋានបាន ឬប្រកបជីវភាពសេដ្ឋកិច្ចបាន មិនត្រូវមាន តំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬតំបន់ខ្ពង់រាបបាតសមុទ្រឡើយ។

## ផ្នែកទី៩៖ សមុទ្រហ៊ុំព័ទ្ធ ឬពាក់កណ្ដាលហ៊ុំព័ទ្ធ

*មាត្រា ១២២*

*ការកំណត់និយមន័យ*

សម្រាប់គោលបំណងនៃអនុសញ្ញានេះ "សមុទ្របិទ ឬពាក់កណ្ដាលបិទ"មានន័យថា ឈូងសមុទ្រ អាងស្តុកទឹក ឬ សមុទ្រព័ទ្ធជុំវិញដោយរដ្ឋពីរ ឬច្រើន និងតភ្ជាប់នៅកាន់សមុទ្រផ្សេងទៀត ឬមហាសមុទ្រដោយ ច្រកចេញតូចចង្អៀត ឬមានដែនទឹកទាំងមូល ឬផ្នែកដែលសំខាន់ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរ ចំនួនពីរ ឬច្រើន។

*មាត្រា ១២៣*

*កិច្ចសហប្រតិបត្តិការរវាងរដ្ឋដែលមានព្រំដែនសមុទ្របិទ ឬពាក់កណ្ដាលបិទ*

បណ្ដារដ្ឋដែលមានព្រំដែនសមុទ្របិទ ឬពាក់កណ្ដាលបិទ នៅក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួនត្រូវសហការគ្នាក្នុងការបំពេញភារកិច្ចក្រោមអនុសញ្ញានេះ។ ក្នុងករណីនេះ រដ្ឋទាំងនេះត្រូវប្រឹងប្រែងដោយផ្ទាល់ ឬធ្វើតាមរយៈអង្គការក្នុងតំបន់ដែលសមស្របដើម្បី ៖

(ក) សម្របសម្រួលការងារគ្រប់គ្រង អភិរក្ស ការរុករក និងការធ្វើអាជីវកម្មធនធានសត្វមានជីវិតនៅក្នុងសមុទ្រ។

(ខ) សម្របសម្រួលការងារអនុវត្តសិទ្ធិ និងភារកិច្ចរបស់ពួកគេពាក់ព័ន្ធនឹងការការពារ និងអភិរក្សបរិស្ថាន សមុទ្រ។

(គ) សម្របសម្រួលគោលនយោបាយស្រាវជ្រាវវិទ្យាសាស្ត្ររបស់ខ្លួន និងសន្យាថានឹងចូលរួមកម្មវិធីស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រក្នុងករណីដែលអាចធ្វើទៅបាន។

(ឃ) អញ្ជើញបណ្ដារដ្ឋ ឬអង្គការអន្តរជាតិផ្សេងទៀតដែលចាប់អារម្មណ៍ធ្វើកិច្ចសហប្រតិបត្តិការជាមួយខ្លួនក្នុងការតាក់តែងបទបញ្ញត្តិបន្ថែមនៃមាត្រានេះ។

ផ្នែកទី១០៖ សិទ្ធិក្នុងការចេញចូលដែនសមុទ្រ និងសេរីភាពឆ្លងកាត់របស់រដ្ឋហ៊ុំព័ទ្ធដោយដីគោក

*មាត្រា ១២៤*

*ការប្រើប្រាស់វាក្យស័ព្ទ*

១. សម្រាប់គោលបំណងអនុសញ្ញានេះ ៖

(ក) "រដ្ឋហ៊ុំព័ទ្ធដោយដីគោក " មានន័យថារដ្ឋដែលគ្មានសមុទ្រ-ឆ្នេរសមុទ្រ។

(ខ) "រដ្ឋឆ្លងកាត់ " មានន័យថា រដ្ឋដែលមាន ឬគ្មានសមុទ្រ-ឆ្នេរសមុទ្រមានទីតាំងនៅចន្លោះរដ្ឋហ៊ុំព័ទ្ធ ដោយដីគោក និងសមុទ្រ ដែលការធ្វើដំណើរឆ្លងកាត់ដែនដីត្រូវធ្វើឡើង។

(គ) "ចរាចរណ៍ឆ្លងកាត់ " មានន័យថាការដឹកជញ្ជូនមនុស្ស ឥវ៉ាន់ ទំនិញ និងមានន័យថាការ ដឹកជញ្ជូនឆ្លងកាត់ ដែនដីនៃរដ្ឋឆ្លងកាត់មួយ ឬច្រើន ក្នុងករណីដែលការធ្វើដំណើរឆ្លងកាត់ដែនដីបែបនេះ មាន ឬគ្មាន ទំនិញដឹកជញ្ជូនតាមនាវាឆ្លងកាត់ប្រទេស ទំនិញឃ្លាំង ទំនិញក្នុងបរិមាណច្រើន ឬការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូន គ្រាន់តែជាចំណែកមួយនៃការធ្វើដំណើរពេញលេញដែលចាប់ផ្តើម ឬបញ្ចប់នៅក្នុងដែនទឹករដ្ឋហ៊ុំព័ទ្ធដោយដីគោក។

(ឃ) "អត្ថន័យមធ្យោបាយដឹកជញ្ជូន " មានន័យថា ៖

(i) យានរត់លើផ្លូវដែក (railway rolling stock) យានធ្វើដំណើរតាមសមុទ្រ បឹង និងទន្លេ និង យានរត់លើផ្លូវ។

(ii) ក្នុងករណីកំណត់ដោយលក្ខខណ្ឌក្នុងតំបន់ សំដៅដល់អ្នកទទួលផ្ទុកទំនិញ និងកម្លាំងអូសទាញ និងដឹកជញ្ជូន។

២. រដ្ឋហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋដែលឆ្លងកាត់អាចដាក់បញ្ចូលជាមធ្យោបាយដឹកជញ្ជូនដូចជា បំពង់បញ្ជូន ប្រេង និងឧស្ម័ន តាមរយៈការចុះកិច្ចព្រមព្រៀងរវាងរដ្ឋទាំងនោះ ព្រមទាំងមធ្យោបាយដឹកជញ្ជូនផ្សេងទៀតក្រៅពីអ្វីដែល មានចែងនៅក្នុង កថាខណ្ឌទី ១។

*មាត្រា ១២៥*

*សិទ្ធិក្នុងការចេញចូលដែនសមុទ្រ និងសេរីភាពក្នុងការឆ្លងកាត់*

១. រដ្ឋហ៊ុំព័ទ្ធដោយដីគោកមានសិទ្ធិចេញចូលដែនសមុទ្រ ក្នុងគោលបំណងអនុវត្តសិទ្ធិដែលផ្តល់ជូននៅក្នុង អនុសញ្ញានេះ រួមមានសិទ្ធិពាក់ព័ន្ធនឹងសេរីភាពនៅដែនសមុទ្រអន្តរជាតិ និងបេតិកភណ្ឌមនុស្សជាតិរួមគ្នា។ នៅក្នុងន័យនេះ រដ្ឋគ្មានដែនសមុទ្រអាចប្រើប្រាស់សេរីភាពឆ្លងកាត់ដែនដីរបស់រដ្ឋដែលឆ្លងកាត់តាមរយៈ មធ្យោបាយដឹកជញ្ជូន តាមរយៈការចុះកិច្ចព្រមព្រៀងរវាងគ្នា។

២. លក្ខខណ្ឌ និងបែបបទក្នុងការប្រើប្រាស់សេរីភាពឆ្លងកាត់ត្រូវមានការព្រមព្រៀងរវាងរដ្ឋហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋឆ្លងកាត់ដែលពាក់ព័ន្ធតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី អនុតំបន់ ឬតំបន់។

៣. នៅក្នុងការប្រើប្រាស់អធិបតេយ្យភាពដែនដីពេញលេញរបស់ខ្លួនលើដែនដីរបស់ ខ្លួននោះ រដ្ឋដែលឆ្លងកាត់ ត្រូវមានសិទ្ធិចាត់វិធានការចាំបាច់ដើម្បីធានាបានថា សិទ្ធិ និងលទ្ធភាពនានា(facilities) ដែលមានផ្តល់ជូននៅក្នុងផ្នែកនេះសម្រាប់រដ្ឋហ៊ុំព័ទ្ធដោយដីគោក មិនត្រូវប៉ះពាល់ដល់អត្ថប្រយោជន៍ស្របច្បាប់របស់ពួកគេទោះតាមមធ្យោបាយ ណាមួយនោះទេ។

*មាត្រា ១២៦*

*អញ្ញត្រកម្មនៃការអនុវត្តខចែងស្តីពីប្រជាជាតិទទួលការអនុគ្រោះ*

បទបញ្ញត្តិនៃអនុសញ្ញានេះ ព្រមទាំងកិច្ចព្រមព្រៀងពិសេសពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិ ចេញចូលសមុទ្រ ដែលបង្កើតបានជាសិទ្ធិ និងលទ្ធភាព ឈរលើទីតាំងភូមិសាស្ត្រពិសេសនៃរដ្ឋហ៊ុំព័ទ្ធដោយដីគោក ត្រូវមានអញ្ញត្រកម្មពីការ អនុវត្តខចែងស្តីពីប្រិជាជាតិទទួលការអនុគ្រោះ ។

*មាត្រា ១២៧*

*ពន្ធគយ អាករ និងបន្ទុកនានា*

១.  ការធ្វើចរាចរណ៍ឆ្លងកាត់ មិនត្រូវបានចាត់ទុកថាជាប់ពន្ធគយ អាករ ឬបន្ទុកផ្សេងៗ ឡើយ លើកលែងតែបន្ទុកលើសេវាកម្មជាក់លាក់ពាក់ព័ន្ធនឹងការធ្វើចរាចរណ៍នេះ។

២.  មធ្យោបាយដឹកជញ្ជូនឆ្លងកាត់ និងមធ្យោបាយផ្សេងទៀតដែលផ្តល់ជូន និងត្រូវបាន ប្រើប្រាស់ ដោយប្រទេសគ្មានឆ្នេរសមុទ្រ មិនត្រូវបានកំណត់ឱ្យយកពន្ធ ឬដាក់បន្ទុកខ្ពស់ជាងបន្ទុក លើមធ្យោបាយដឹកជញ្ជូនរបស់ រដ្ឋដែលឆ្លងកាត់ឡើយ។

*មាត្រា ១២៨*

*តំបន់សេរី និងមូលដ្ឋានគយដទៃទៀត*

ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការធ្វើចរាចរណ៍នៅតំបន់ឆ្លងកាត់ តំបន់សេរី ឬមូលដ្ឋានគយ ដទៃទៀតអាច ត្រូវបានបង្កើតឡើងនៅកំពង់ផែច្រកចេញចូលនៅរដ្ឋដែលឆ្លងកាត់ តាមការព្រមព្រៀង រវាងរដ្ឋទាំងនោះ ជាមួយ នឹងរដ្ឋហ៊ុំព័ទ្ធដោយដីគោក។

*មាត្រា ១២៩*

*កិច្ចសហប្រតិបត្តិការក្នុងការសាងសង់ និងការកែលម្អមធ្យោបាយដឹកជញ្ជូន*

ក្នុងករណីរដ្ឋដែលឆ្លងកាត់ គ្មានមធ្យោបាយដឹកជញ្ជូនដែលអាចឱ្យអនុវត្តនូវសេរីភាពក្នុងការ ឆ្លងកាត់បាន ឬក្នុងករណីដែលមធ្យោបាយដែលមានស្រាប់ដូចជា ឋបនភណ្ឌ និងបរិក្ខារកំពង់ផែ ពុំមានគ្រប់គ្រាន់តាមការកំណត់នោះ រដ្ឋដែលឆ្លងកាត់ និងរដ្ឋហ៊ុំព័ទ្ធដោយដីគោកពាក់ព័ន្ធ អាច សហការគ្នានៅក្នុងការសាងសង់ ឬកែលម្អមធ្យោបាយទាំងនោះ។

*មាត្រា ១៣០*

*វិធានការបញ្ចៀស ឬលុបបំបាត់ភាពយឺតយ៉ាវ*

*ឬការលំបាកខាងបច្ចេកទេសក្នុងសកម្មភាពចរាចរណ៍នៅតំបន់ដែលឆ្លងកាត់*

១.	រដ្ឋដែលឆ្លងកាត់ ត្រូវចាត់វិធានការឱ្យបានសមស្របដើម្បីបញ្ចៀសភាពយឺតយ៉ាវ ឬការលំបាកខាង បច្ចេកទេសក្នុងសកម្មភាពចរាចរណ៍នៅតំបន់ដែលឆ្លងកាត់។

២.	ក្នុងករណីដែលមានការយឺតយ៉ាវ ឬឧបសគ្គនានា អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដែលឆ្លងកាត់ និងរដ្ឋហ៊ុំព័ទ្ធដោយដីគោកពាក់ព័ន្ធទាំងអស់ត្រូវសហការគ្នាដើម្បីលុបបំបាត់វាឱ្យបានឆាប់រហ័ស។

*មាត្រា ១៣១*

*ប្រព្រឹត្តិកម្មដោយស្មើភាពនៅកំពង់ផែសមុទ្រ*

នាវាដែលចងទង់ជាតិរដ្ឋហ៊ុំព័ទ្ធដោយដីគោក ត្រូវទទួលបានប្រព្រឹត្តិកម្មក្នុងកម្រិតមួយដូចគ្នានឹងនាវាបរទេស នៅកំពង់ផែសមុទ្រ។

*មាត្រា ១៣២*

*ការផ្តល់មូលដ្ឋានសម្រួលដល់ការឆ្លងកាត់ក្នុងទ្រង់ទ្រាយធំ*

អនុសញ្ញានេះ មិនបានតម្រូវទោះជាក្នុងលក្ខណៈណាមួយឱ្យធ្វើការដកហូតមូលដ្ឋានសម្រួលដល់ការឆ្លងកាត់ ក្នុងទ្រង់ទ្រាយធំជាងការកំណត់ក្រោមអនុសញ្ញានេះ និងដែលបានព្រមព្រៀងរវាងរដ្ឋភាគីនៃអនុសញ្ញានេះ ឬដែលផ្តល់ ដោយរដ្ឋភាគីមួយឡើយ។ ដោយឡែក អនុសញ្ញានេះ មិនបានប្រានចោលការផ្តល់មូលដ្ឋានសម្រួលការ ឆ្លងកាត់ក្នុង ទ្រង់ទ្រាយធំនាពេលអនាគតនោះដែរ។

## ផ្នែកទី១១៖ តំបន់

## ជំពូកទី១៖ បទបញ្ញត្តិរួម

*មាត្រា ១៣៣*

*ការប្រើប្រាស់វាក្យស័ព្ទ*

ក្នុងគោលបំណងផ្នែកនេះ៖

(ក) "ធនធាន" មានន័យថា រាល់ធនធានរ៉ែជាអង្គធាតុរឹង រាវ ឬឧស្ម័នមាននៅក្នុងតំបន់មួយ ឬក្រោមបាត សមុទ្រ រួមមានកំណប់រ៉ែប៉ូលីមេតាលីក។

(ខ) នៅពេលទាញយកពីតំបន់នោះ ធនធានសំដៅដល់ "រ៉ែ"។

*មាត្រា ១៣៤*

*វិសាលភាពនៃផ្នែកនេះ*

១. ផ្នែកនេះអនុវត្តលើតំបន់។

២. សកម្មភាពនានានៅក្នុងតំបន់ គ្របដណ្តប់ដោយបទបញ្ញត្តិនៃផ្នែកនេះ។

៣. លក្ខខណ្ឌពាក់ព័ន្ធនឹងការតម្កល់ និងការផ្សព្វផ្សាយផែនទី ឬបញ្ជីចំណុចនិយាមកាភូមិសាស្ត្រដែលបង្ហាញ អំពីព្រំដែនសំដៅដល់មាត្រា ១ កឋាខណ្ឌទី១(១)ត្រូវបានកំណត់ក្នុងផ្នែកទី៦។

៤. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះនាំឱ្យប៉ះពាល់ដល់ការបង្កើតព្រំដែនខាងក្រៅតំបន់ខ្ពង់រាបបាតសមុទ្រ ដោយ អនុលោមតាមផ្នែកទី ៦ ឬសុពលភាពនៃកិច្ចព្រមព្រៀងនានា ស្ដីពីការកំណត់ព្រំដែនរវាងរដ្ឋ ជាមួយនឹងឆ្នេរសមុទ្រដែលនៅទល់មុខឬ នៅជាប់។

*មាត្រា ១៣៥*

*លក្ខណៈគតិយុត្តិនៃដែនទឹក និងដែនអាកាសព័ទ្ធជុំវិញ*

ផ្នែកនេះ ឬសិទ្ធិណាមួយមានផ្តល់ជូន ឬត្រូវបានអនុវត្តនោះ មិនមានឥទ្ធិពលលើលក្ខណៈគតិយុត្តិនៃដែនទឹកដែលព័ទ្ធជុំវិញតំបន់នោះ ឬលំហអាកាសនៅលើដែនទឹកនោះទេ។

ជំពូកទី២៖ គោលការណ៍គ្រប់ដណ្តប់តំបន់

*មាត្រា ១៣៦*

*បេតិកភណ្ឌមនុស្សជាតិរួម*

តំបន់ និងធនធាននានា ជាបេតិកភណ្ឌមនុស្សជាតិរួមគ្នា។

*មាត្រា ១៣៧*

*ស្ថានភាពគតិយុត្តិនៃតំបន់ និងធនធានរបស់ខ្លួន*

១. គ្មានរដ្ឋណាមួយអាចទាមទារ ឬអនុវត្តអធិបតេយ្យភាព ឬសិទ្ធិអធិបតេយ្យភាពលើផ្នែកណាមួយនៃតំបន់ ឬធនធានតំបន់នោះ ហើយក៏គ្មានរដ្ឋណាមួយ ឬ រូបវន្តបុគ្គល ឬនីតិបុគ្គលអាចអនុវត្តផ្នែកណាមួយឡើយ។ ការទាមទារ ឬការអនុវត្តអធិបតេយ្យ ឬសិទ្ធិអធិបតេយ្យភាព មិនត្រូវបានទទួលស្គាល់ថា មានលក្ខណៈសមស្របនោះដែរ។

២. សិទ្ធិទាំងអស់លើធនធានក្នុងតំបន់ ត្រូវបានផ្តល់ជូនដល់មនុស្សជាតិទាំងមូល ដែលមានអាជ្ញាធរជាតំណាង។ ធនធានទាំងនេះ មិនអាចធ្វើការផ្ទេរបានឡើយ។ ដោយឡែក ធនធានទាំងនេះអាចឱ្យផ្ទេរបាន អនុលោមតាមផ្នែក និងវិធាន បទបញ្ញត្តិ និងនីតិវិធីអាជ្ញាធរ។

៣. រដ្ឋ ឬរូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវធ្វើការទាមទារ កាន់កាប់ ឬអនុវត្តសិទ្ធិពាក់ព័ន្ធនឹងធនធានរ៉ែដែលទាញ យកបានពីតំបន់នោះលើកលែងតែអនុលោមតាមផ្នែកនេះ។ បើមិនដូច្នេះទេ គ្មានការទាមទារ ការកាន់កាប់ ឬការអនុវត្តសិទ្ធិប្រភេទនេះ នឹងត្រូវបានទទួលស្គាល់ឡើយ។

*មាត្រា ១៣៨*

*សកម្មភាពទូទៅនៃរដ្ឋពាក់ព័ន្ធនឹងតំបន់នេះ*

សកម្មភាពទូទៅរបស់បណ្ដារដ្ឋពាក់ព័ន្ធនឹងតំបន់នេះ ត្រូវអនុលោមតាមបទបញ្ញត្តិក្នុងផ្នែកនេះ គោលការណ៍ជាធរមានដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងវិធានច្បាប់អន្តរជាតិដទៃទៀត ដែលបម្រើដល់ប្រយោជន៍ក្នុងការរក្សាបាននូវសុខសន្តិភាព និងជំរុញឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការយោគយល់គ្នាទៅវិញទៅមក។

*មាត្រា ១៣៩*

*កាតព្វកិច្ចធានាឱ្យបាននូវការអនុវត្ត និងការទទួលខុសត្រូវលើភាពខូចខាត*

១. បណ្ដារដ្ឋភាគី ត្រូវមានកាតព្វកិច្ចធានាឱ្យបានថា សកម្មភាពនានានៅក្នុងតំបន់ មិនថាធ្វើឡើងដោយរដ្ឋ ភាគី ឬសហគ្រាសរដ្ឋ ឬរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិនៃរដ្ឋភាគីនោះ ឬត្រូវបានគ្រប់គ្រងដោយខ្លួន ឬប្រទេសរបស់ខ្លួនត្រូវធ្វើឡើងដោយអនុលោមតាមផ្នែកនេះ។ កាតព្វកិច្ចដូចគ្នានេះ អនុវត្តលើអង្គការអន្តរជាតិ ដែលធ្វើសកម្មភាពនៅក្នុងតំបន់នោះផងដែរ។

២. ដោយមិនគិតដល់អំពីវិធាន និងច្បាប់អន្តរជាតិ ព្រមទាំងឧបសម្ព័ន្ធ ៣មាត្រា ២២ ការខូចខាតដែលបង្ក ឡើងដោយភាពខកខានរបស់រដ្ឋភាគី ឬអង្គការអន្តរជាតិក្នុងការអនុវត្តកាតព្វកិច្ចក្រោមផ្នែកនេះ តម្រូវឱ្យទទួលខុសត្រូវ ហើយបណ្ដារដ្ឋភាគី ឬអង្គការអន្តរជាតិដែលធ្វើសកម្មភាព រួមគ្នា ត្រូវទទួលខុសត្រូវរួមគ្នា និងច្រើនករណី ផងដែរ។ ប៉ុន្តែរដ្ឋភាគីមួយមិនទទួលខុសត្រូវលើការខូចខាតបង្កឡើងដោយការមិនបានគោរពតាមផ្នែកនេះដោយ បុគ្គលណាមួយដែលធ្វើការឧបត្ថម្ភក្រោមមាត្រា ១៥៣ កថាខណ្ឌទី ២ (ខ) ប្រសិនបើរដ្ឋភាគីបានចាត់វិធានការចាំបាច់ និងសមស្របទាំងឡាយដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមមាត្រា ១៥៣ កថាខណ្ឌទី ៤ ព្រមទាំងឧបសម្ព័ន្ធ៣មាត្រា ៤ កថាខណ្ឌទី ៤ នោះហើយ។

៣. រដ្ឋភាគី ដែលជាសមាជិកអង្គការអន្តរជាតិ ត្រូវចាត់វិធានការសមស្របដើម្បីធានាបានការអនុវត្ត មាត្រានេះតាមប្រភេទនៃអង្គការនោះ។

*មាត្រា ១៤០*

*អត្ថប្រយោជន៍មនុស្សជាតិ*

១. ដូចមានចែងជាពិសេសក្នុងផ្នែកនេះ សកម្មភាពទាំងអស់នៅក្នុងតំបន់ ត្រូវបានអនុវត្តឡើង ដើម្បីអត្ថប្រយោជន៍មនុស្សជាតិទាំងស្រុង ដោយមិនគិតតាមទីតាំងភូមិសាស្ត្ររដ្ឋថាជារដ្ឋ ជាប់ឆ្នេរ ឬគ្មានឆ្នេរសមុទ្រ និងពិចារណាលើអត្ថប្រយោជន៍ និងតម្រូវការរដ្ឋកំពុងអភិវឌ្ឍន៍ និងប្រជាជាតិដែលមិនទាន់ទទួលបានឯករាជ្យ ឬតំបន់ស្វយ័តទទួលស្គាល់ដោយអង្គការសហប្រជាជាតិ អនុលោមតាមដំណោះស្រាយមហាសន្និបាត ១៥១៤ (១៥)និងដំណោះស្រាយមហាសន្និបាតពាក់ព័ន្ធផ្សេងទៀត។

២. អាជ្ញាធរត្រូវផ្តល់ចំណែក អត្ថប្រយោជន៍ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចផ្សេងទៀតស្មើគ្នាទទួលបានពីសកម្មភាព នៅក្នុងតំបន់នោះតាមរយៈយន្តការសមស្រប លើមូលដ្ឋានមិនរើសអើង អនុលោមតាមមាត្រា ១៦០ កថាខណ្ឌទី ២(ច)(ឈ)។

*មាត្រា ១៤១*

*ការប្រើប្រាស់តំបន់សម្រាប់តែបម្រើដល់គោលបំណងសន្តិភាព*

រដ្ឋទាំងអស់ ទាំងរដ្ឋជាប់ឆ្នេរ និងរដ្ឋហ៊ុំព័ទ្ធដោយដីគោក មានសិទ្ធិប្រើប្រាស់តំបន់ដោយសេរី សម្រាប់តែគោល បំណងសន្តិភាព ដោយគ្មានការរើសអើង និងពុំប៉ះពាល់ដល់បទបញ្ញត្តិផ្សេងទៀតនៃផ្នែកនេះ។

*មាត្រា ១៤២*

*សិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់របស់រដ្ឋជាប់ឆ្នេរ*

១. រាល់សកម្មភាពនៅក្នុងតំបន់ដែលពាក់ព័ន្ធនឹងធនធានក្នុងតំបន់ស្ថិតក្រោមយុត្តាធិការជាតិ ត្រូវអនុវត្ត ដោយពិចារណាឱ្យបានត្រឹមត្រូវដល់សិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់របស់រដ្ឋជាប់ឆ្នេរ ដែលជាប្រភពធនធាន។

២. ការពិគ្រោះយោបល់ រួមទាំងប្រព័ន្ធជូនដំណឹងជាមុន ត្រូវធ្វើឡើងជាប្រចាំជាមួយរដ្ឋ ដែលពាក់ព័ន្ធ ដើម្បីជៀសវាងការបំពានជាយថាហេតុលើសិទ្ធិ និងអត្ថប្រយោជន៍ទាំងនេះ។ ក្នុងករណីដែលសកម្មភាពនៅក្នុងតំបន់ អាចនាំ ទៅដល់ការធ្វើអាជីវកម្មទាញយកធនធានស្ថិតនៅក្នុងរង្វង់នៃយុត្តាធិការរបស់រដ្ឋមួយ នោះត្រូវមានការអនុញ្ញាត ពីរដ្ឋជាប់ឆ្នេរដែលពាក់ព័ន្ធនោះជាមុន។

៣. បទបញ្ញត្តិនៃផ្នែកនេះ និងសិទ្ធិដែលបានផ្តល់ឱ្យ ឬដែលអនុវត្តស្របតាមបទបញ្ញត្តិនៃផ្នែកនេះ នឹង មិនប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរ ក្នុងករាចាត់វិធានការស្របតាមបទបញ្ញត្តិពាក់ព័ន្ធនៅក្នុងផ្នែក ១២ ដើម្បី បង្ការ កាត់បន្ថយ ឬលុបបំបាត់គ្រោះអន្តរាយធ្ងន់ធ្ងរជាយថាហេតុមកលើមត់សមុទ្រ ឬអត្ថប្រយោជន៍ដែលពាក់ព័ន្ធពី ការបំពុល ឬការគំរាមកំហែង ឬព្រឹត្តិការណ៍ដែលបង្កគ្រោះថ្នាក់ផ្សេងទៀត បណ្តាលមកពី ឬបង្កឡើងដោយ សកម្មភាពនៅក្នុងតំបន់នោះឡើយ។

*មាត្រា ១៤៣*

*ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ*

១. ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់ អាចធ្វើបានក្នុងគោលបំណង សន្តិភាព និងបម្រើដល់ ផលប្រយោជន៍របស់មនុស្សជាតិទាំងមូល ស្របតាមបទបញ្ញត្តិក្នុងផ្នែកទី ១៣ តែប៉ុណ្ណោះ។

២. អាជ្ញាធរអាចអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រពាក់ព័ន្ធនឹងតំបន់ និងធនធាននៅក្នុងតំបន់ ហើយអាចចុះកិច្ចសន្យាសម្រាប់គោលបំណងនេះបាន។ អាជ្ញាធរត្រូវជំរុញលើកកម្ពស់ការងារស្រាវជ្រាវវិទ្យាសាស្ត្រ អំពីសមុទ្រនៅក្នុងតំបន់ និងផ្សព្វផ្សាយលទ្ធផលនៃការវិភាគស្រាវជ្រាវនៅពេលទទួលបានលទ្ធផលទាំងនោះ។

៣. រដ្ឋភាគីអាចអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រនៅក្នុងតំបន់។ រដ្ឋភាគីត្រូវលើកកម្ពស់ឱ្យមានកិច្ច សហប្រតិបត្តិការអន្តរជាតិនៅក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់ដោយ ៖

(ក) ចូលរួមកម្មវិធីអន្តរជាតិ និងជំរុញកិច្ចសហប្រតិបត្តិការនៅក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ដែលធ្វើឡើងដោយបុគ្គលិកមកពីប្រទេសផ្សេងៗ និងការស្រាវជ្រាវរបស់អាជ្ញាធរ។

(ខ) ធានាថាកម្មវិធីត្រូវបានបង្កើតឡើងតាមរយៈអាជ្ញាធរ ឬអង្គការអន្តរជាតិផ្សេងៗទៀតឱ្យបានសមស្របសម្រាប់បម្រើផលប្រយោជន៍របស់រដ្ឋកំពុងអភិវឌ្ឍន៍ និងរដ្ឋមានការអភិវឌ្ឍផ្នែកបច្ចេក វិទ្យាតិចតួចសំដៅ ៖

(i) ពង្រឹងសមត្ថភាពស្រាវជ្រាវរបស់រដ្ឋទាំងនោះ។

(ii) បណ្តុះបណ្តាលបុគ្គលិកនៃរដ្ឋទាំងនោះ និងបុគ្គលិកអាជ្ញាធរ ដើម្បីលើកកម្ពស់ការយល់ដឹង អំពីបច្ចេកទេស និងរបៀបអនុវត្តន៍នៅក្នុងការស្រាវជ្រាវ។

(iii) ជំរុញការផ្តល់ការងារដល់បុគ្គលិកមានគុណវុឌ្ឍិនៃរដ្ឋទាំងនោះ នៅក្នុងការងារស្រាវជ្រាវ នៅក្នុងតំបន់។

(គ) ផ្សព្វផ្សាយលទ្ធផលនៃការវិភាគស្រាវជ្រាវ នៅពេលទទួលបានលទ្ធផលទាំងនោះ ប្រកបដោយ ប្រសិទ្ធភាពតាមរយៈអាជ្ញាធរ ឬបណ្តាញអន្តរជាតិផ្សេងៗដែលសមស្រប។

*មាត្រា ១៤៤*

*ការផ្ទេរបច្ចេកវិទ្យា*

១. អាជ្ញាធរត្រូវចាត់វិធានការឱ្យបានសមស្របតាមអនុសញ្ញានេះ ដើម្បី ៖

(ក) ទទួលបានបច្ចេកវិទ្យា និងចំណេះដឹងខាងវិទ្យាសាស្ត្រទាក់ទងនឹងសកម្មភាពនៅក្នុងតំបន់។ និង

(ខ) ជំរុញលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងខាងវិទ្យាសាស្ត្រទាំងនេះទៅដល់បណ្តារដ្ឋកំពុង អភិវឌ្ឍន៍ ដើម្បីជាប្រយោជន៍ដល់រដ្ឋទាំងអស់។

២. ដើម្បីសម្រេចនូវគោលបំណងនេះ អាជ្ញាធរ និងរដ្ឋភាគីទាំងអស់ត្រូវសហការគ្នាក្នុងការជំរុញលើកកម្ពស់ ការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រទាក់ទងនឹងសកម្មភាពនៅក្នុង តំបន់ ដើម្បីជាប្រយោជន៍ដល់សហគ្រាស និងរដ្ឋភាគីទាំងអស់ ។ ជាពិសេស ត្រូវផ្តួចផ្តើម និងលើកកម្ពស់ ៖

(ក) កម្មវិធីផ្ទេរបច្ចេកវិទ្យាទៅដល់សហគ្រាស និងរដ្ឋកំពុងអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់ មានជាអាទិ៍ ការសម្របសម្រួលឱ្យសហគ្រាស និងរដ្ឋកំពុងអភិវឌ្ឍន៍ ទទួលបានបច្ចេកវិទ្យាពាក់ព័ន្ធ ក្រោមលក្ខខណ្ឌសមស្រប និងប្រកបដោយយុត្តិធម៌។

(ខ) វិធានការសំដៅលើកកម្ពស់បច្ចេកវិទ្យារបស់សហគ្រាស និងបច្ចេកវិទ្យាក្នុងស្រុករបស់រដ្ឋកំពុង អភិវឌ្ឍន៍ឱ្យរីកចម្រើន ជាពិសេសតាមរយៈការផ្តល់ឱកាសជូនបុគ្គលិកពីសហគ្រាស និងពីរដ្ឋកំពុងអភិវឌ្ឍន៍ឱ្យទទួលបានការ

បណ្តុះបណ្តាលអំពីបច្ចេកវិទ្យា និងវិទ្យាសាស្រ្តសមុទ្រ និងការចូលរួមក្នុងសកម្មភាពនៅក្នុងតំបន់បានយ៉ាងពេញលេញ។

*មាត្រា ១៤៥*

*ការការពារបរិស្ថានសមុទ្រ*

ដោយអនុលោមតាមអនុសញ្ញានេះ វិធានការចាំបាច់ដែលពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់នឹងត្រូវចាត់ឡើង ដើម្បីធានានូវការការពារបរិស្ថានសមុទ្រពីផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់ ដែលអាចនឹងកើតចេញពីសកម្ម ភាពទាំងនេះ ឱ្យបានមានប្រសិទ្ធភាព។ ដើម្បីសម្រេចនូវគោលបំណងនេះ អាជ្ញាធរត្រូវអនុវត្តវិធាន បទបញ្ញត្តិ និង នីតិវិធីសមស្រប រួមមានជាអាទិ៍ ៈ

(ក) ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងលើការបំពុល និងគ្រោះថ្នាក់ផ្សេងៗចំពោះបរិស្ថានសមុទ្រ រាប់ទាំងមាត់សមុទ្រ និងលើការប៉ះពាល់ដល់លំនឹងបរិស្ថាន ដោយយកចិត្តទុកដាក់ជាពិសេសទៅ លើតម្រូវការក្នុងការការពារពីផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់ ដែលកើតចេញពីសកម្មភាព ដូចជា ការខួង ការបូម ការជីកកកាយ ការចាក់ចោលកាកសំណល់ ការស្ថាបនា និងប្រតិបត្តិការ ឬការ ថែទាំបបនភណ្ឌ បំពង់ជយោ និងឧបករណ៍ផ្សេងៗទៀតដែលទាក់ទង នឹងសកម្មភាពទាំងនោះ។

(ខ) ការការពារ និងការអភិរក្សធនធានធម្មជាតិនៅក្នុងតំបន់ និងការបង្ការភាពអន្តរាយដល់រុក្ខជាតិ និងសត្វនៅក្នុងបរិស្ថានសមុទ្រ។

*មាត្រា ១៤៦*

*ការការពារជីវិតមនុស្ស*

វិធានការពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់ត្រូវចាត់ឡើងជាចាំបាច់ ដើម្បីធានាបានការការពារជីវិតមនុស្ស ប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្រេចនូវគោលដៅនេះ អាជ្ញាធរត្រូវអនុម័តវិធាន បទបញ្ញត្តិ និងនីតិវិធីសមស្រប បន្ថែមលើច្បាប់អន្តរជាតិដែលមានជាធរមាន ដូចដែលដាក់បញ្ចូលនៅក្នុងសន្ធិសញ្ញាដែលពាក់ព័ន្ធ។

*មាត្រា ១៤៧*

*ការសម្របសម្រួលសកម្មភាពនៅក្នុងតំបន់ និងបរិស្ថានសមុទ្រ*

១. សកម្មភាពនៅក្នុងសមុទ្រ ត្រូវបានអនុវត្តដោយពិចារណាឱ្យបានសមស្របទៅលើសកម្មភាពផ្សេងៗ នៅក្នុងបរិស្ថានសមុទ្រ។

២. បបនកណ្ឌដែលប្រើប្រាស់សម្រាប់អនុវត្តសកម្មភាពនៅក្នុងតំបន់ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម នេះ ៖

(ក) បបនកណ្ឌត្រូវសាងសង់ ដំឡើង និងរុះរើស្របតាមបទបញ្ញត្តិនៃផ្នែកនេះ និងវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរដែលមានជាធរមាន។ ត្រូវជូនដំណឹងឱ្យបានសមស្របអំពីការសាងសង់ ការដំឡើង និងរុះរើបបនកណ្ឌចេញ និងត្រូវរក្សាឱ្យមានជាប្រចាំនូវមធ្យោបាយអចិន្ត្រៃយ៍សម្រាប់ជាសញ្ញាសម្គាល់បបនកណ្ឌ ។

(ខ) មិនត្រូវសាងសង់បបនកណ្ឌនៅទីកន្លែងណាមួយ ដែលអាចនាំឱ្យប៉ះពាល់ដល់ការប្រើប្រាស់ផ្លូវសមុទ្រដែលមានការទទួលស្គាល់ និងមានសារៈសំខាន់ចំពោះនាវាចរណ៍អន្តរជាតិ ឬនៅក្នុងតំបន់ ដែលមានសកម្មភាពនេសាទមមាញឹក។

(គ) ត្រូវបង្កើតតំបន់សុវត្ថិភាពនៅជុំវិញបបនកណ្ឌ ជាមួយសញ្ញាសម្គាល់ដែលសមស្រប ដើម្បីធានា សុវត្ថិភាពទាំងសម្រាប់នាវាចរណ៍ និងបបនកណ្ឌ។ ការរៀបចំ និងទីតាំងតំបន់សុវត្ថិភាពមិនត្រូវ បង្កើតជាតំបន់ក្រវ៉ាត់មួយ ដែលរាំងស្ទះដល់នាវាធ្វើដំណើរចេញចូលដោយស្របច្បាប់ទៅកាន់ ដែនសមុទ្រណាមួយ ឬជាឧបស័គ្គដល់នាវាចរណ៍នៅតាមគន្លងផ្លូវសមុទ្រអន្តរជាតិឡើយ។

(ឃ) ត្រូវប្រើប្រាស់បបនកណ្ឌសម្រាប់គោលបំណងសន្តិភាពតែប៉ុណ្ណោះ។

(ង) បបនកណ្ឌមានស្ថានភាពខុសគ្នានឹងកោះនោះទេ។ បបនកណ្ឌមិនមានដែនសមុទ្រផ្ទាល់នោះទេ ហើយវត្តមានរបស់វា មិននាំឱ្យប៉ះពាល់ដល់ការបង្កើតព្រំនៃដែនសមុទ្រតំបន់សេដ្ឋកិច្ចផ្ដាច់មុខ ឬធ្នើទ្វីបនោះទេ។

៣. សកម្មភាពផ្សេងទៀតនៅក្នុងបរិស្ថានសមុទ្រ ត្រូវអនុវត្តដោយពិចារណាឱ្យបានសមស្របទៅលើសកម្មភាពនៅក្នុងតំបន់ដែលមានស្រាប់។

*មាត្រា ១៤៨*

*ការចូលរួមរបស់រដ្ឋកំពុងអភិវឌ្ឍន៍នៅក្នុងសកម្មភាពក្នុងតំបន់*

ត្រូវជំរុញឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីរដ្ឋកំពុងអភិវឌ្ឍន៍ នៅក្នុងសកម្មភាពក្នុងតំបន់ដូចមាន ចែងយ៉ាងច្បាស់លាស់នៅក្នុងផ្នែកនេះ ដោយបានពិចារណាសមស្របទៅលើអត្ថប្រយោជន៍ និងតម្រូវការពិសេស ជាពិសេស តម្រូវការជាក់លាក់របស់រដ្ឋហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋមានទីតាំងភូមិសាស្ត្រមិនអំណោយផល ដើម្បីជំនះរាល់ឧបសគ្គដែលកើតចេញពីទីតាំងមិនអំណោយផលរបស់ពួកគេ រួមទាំងការស្ថិតនៅឆ្ងាយពីតំបន់ និងការពិបាកក្នុងធ្វើ ដំណើរចេញចូលតំបន់។

*មាត្រា ១៤៩*

*បុរាណវត្ថុ និងវត្ថុប្រវត្តិសាស្ត្រ*

រាល់វត្ថុមានលក្ខណៈជាបុរាណវត្ថុ និងវត្ថុប្រវត្តិសាស្ត្រដែលប្រទះឃើញនៅក្នុងតំបន់ នឹងត្រូវអភិរក្ស ឬផ្ទេរ សម្រាប់ផលប្រយោជន៍មនុស្សជាតិទាំងមូល ដោយពិចារណាជាពិសេសទៅលើសិទ្ធិអាទិភាពរបស់រដ្ឋ ឬប្រទេស ជាប្រភពកំណើត ឬរដ្ឋជាប្រភពវប្បធម៌ ឬរដ្ឋជាប្រភពប្រវត្តិសាស្ត្រ ឬបុរាណសាស្ត្រនៃវត្ថុទាំងនោះ។

## ជំពូកទី៣៖ ការអភិវឌ្ឍធនធានក្នុងតំបន់

*មាត្រា ១៥០*

*គោលនយោបាយទាក់ទងនឹងសកម្មភាពក្នុងតំបន់*

សកម្មភាពនៅក្នុងតំបន់ដែលចែងយ៉ាងច្បាស់នៅក្នុងបញ្ញត្តិនៃផ្នែកនេះ នឹងត្រូវបានអនុវត្តក្នុងលក្ខណៈមួយដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកឱ្យមានសុខភាពល្អ និងការលូតលាស់ខាងពាណិជ្ជកម្មអន្តរជាតិប្រកបដោយតុល្យភាព និងដើម្បីជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការអភិវឌ្ឍជារួមរបស់ប្រទេសទាំងអស់ ជាពិសេស រដ្ឋកំពុងអភិវឌ្ឍន៍ ដើម្បីធានានូវ ៖

(ក) ការអភិវឌ្ឍធនធាននៅក្នុងតំបន់។

(ខ) សណ្ដាប់ធ្នាប់ សុវត្ថិភាព និងភាពសមស្របក្នុងការគ្រប់គ្រងធនធានក្នុងតំបន់ រាប់បញ្ចូលទាំងការអនុវត្តសកម្មភាពក្នុងតំបន់ប្រកបដោយប្រសិទ្ធភាព និងបញ្ចៀសនូវកាកសំណល់ដែលមិនចាំបាច់ ផ្សេងៗ ដោយគោរពគោលការណ៍អភិរក្សឱ្យបានល្អ។

(គ) ការពង្រីកនូវឱកាសចូលរួមក្នុងសកម្មភាពសមស្របតាមមាត្រា ១៤៤ និង ១៤៨ ។

(ឃ) ការចូលរួមក្នុងចំណូលដោយអាជ្ញាធរ និងការផ្ទេរបច្ចេកវិទ្យាទៅឱ្យសហគ្រាស និងរដ្ឋកំពុងអភិវឌ្ឍន៍ ដូចមានចែងនៅក្នុងអនុសញ្ញានេះ។

(ង) បង្កើនលទ្ធភាពធ្វើអាជីវកម្មរ៉ែដែលបានមកពីតំបន់ទៅតាមតម្រូវការ ជាមួយនឹងរ៉ែដែលបានមកពី ប្រភពផ្សេងៗ ដើម្បីធានានូវការផ្គត់ផ្គង់ជូនអ្នកប្រើប្រាស់រ៉ែ។

(ច) ការលើកកម្ពស់តម្លៃឱ្យមានស្ថិរភាព និងប្រកបដោយយុត្តិធម៌ ដែលនាំមកនូវផលចំណេញ សម្រាប់ផលិតករ និងមានភាពយុត្តិធម៌ចំពោះអ្នកប្រើប្រាស់រ៉ែដែលបានមកពីតំបន់ និងប្រភពផ្សេងៗ និងលើកកម្ពស់សមតុល្យរវាងការផ្គត់ផ្គង់ និងតម្រូវការរយៈពេលយូរអង្វែង។

(ឆ) ជំរុញឱ្យរដ្ឋភាគីទាំងអស់ ទទួលបានឱកាសចូលរួមនៅក្នុងការអភិវឌ្ឍធនធានក្នុងតំបន់ និងការ បង្ការការអនុវត្តសកម្មភាពផ្តាច់មុខតែម្នាក់ឯងនៅក្នុងតំបន់ ដោយមិនគិតពីប្រព័ន្ធសង្គម និង សេដ្ឋកិច្ច ឬទីតាំងភូមិសាស្ត្រនៃរដ្ឋទាំងនោះឡើយ។

(ជ) ការការពារប្រទេសកំពុងអភិវឌ្ឍន៍ពីឥទ្ធិពលអវិជ្ជមានទៅលើសេដ្ឋកិច្ច ឬផលពីការនាំចេញរបស់ ពួកគេដោយសារតែការធ្លាក់ចុះនៃតម្លៃរ៉ែដែលប៉ះពាល់ ឬនៃបរិមាណនាំ

ចេញរ៉ែ ក្នុងកម្រិតដែល ការធ្លាក់ចុះនេះបណ្តាលមកពីសកម្មភាពនៅក្នុងតំបន់ ដូចមានចែងនៅក្នុងមាត្រា ១៥១ ។

(ឈ) ការអភិវឌ្ឍបេតិកភណ្ឌសមូហភាព សម្រាប់ផលប្រយោជន៍មនុស្សជាតិទាំងមូល។ និង

(ញ) លក្ខខណ្ឌនៃការចូលទីផ្សារសម្រាប់ការនាំចេញរ៉ែដែលផលិតបានពីធនធានក្នុងតំបន់ និងសម្រាប់ការនាំចូលទំនិញដែលផលិតចេញពីរ៉ែទាំងនោះ នឹងមិនមានភាពអនុគ្រោះច្រើនជាងលក្ខខណ្ឌដែលមានភាពអនុគ្រោះបំផុតសម្រាប់ការនាំចូលពីប្រភពផ្សេងៗទៀតនោះទេ។

*មាត្រា ១៥១*

*គោលនយោបាយផលិតកម្ម*

១. (ក) ដោយមិនប៉ះពាល់ដល់កម្មវត្ថុដែលមានចែងនៅក្នុងមាត្រា ១៥០ និងសម្រាប់គោលបំណងនៃការអនុវត្តកថាខណ្ឌរង (ជ) នៃមាត្រានោះ អាជ្ញាធរត្រូវចាត់វិធានការចាំបាច់ ដើម្បីជំរុញកំណើន ប្រសិទ្ធភាព និងស្ថេរភាពនៃទីផ្សារទំនិញធ្វើពីរ៉ែក្នុងតំបន់ ក្នុងតម្លៃដែលផ្តល់ផលចំណេញដល់ ផលិតករ និងសមរម្យសម្រាប់អ្នកប្រើប្រាស់ តាមរយៈវេទិការដែលមានស្រាប់ ឬផែនការ និងកិច្ចព្រមព្រៀងថ្មីៗ ដែលអាចនឹងមានភាពសមស្របសម្រាប់ចូលរួម ដោយភាគីមានផលប្រយោជន៍ទាំងអស់ ទាំងអ្នកផលិត និងអ្នកប្រើប្រាស់។ រដ្ឋភាគីទាំងអស់ត្រូវសហការគ្នា ដើម្បីសម្រេចនូវគោលបំណងនេះ។

(ខ) អាជ្ញាធរមានសិទ្ធចូលរួមរាល់សន្និសីទស្តីពីទំនិញ ដែលរៀបចំឡើងដើម្បីគ្រប់គ្រងទំនិញទាំងនោះ និងចូលរួមដោយរាល់ភាគីដែលមានចំណាប់ អារម្មណ៍ រាប់បញ្ចូលទាំងផលិតករនិងអ្នកប្រើប្រាស់។ អាជ្ញាធរមានសិទ្ធិក្លាយជាសមាជិកមួយនៃផែនការ ឬកិច្ចព្រមព្រៀងដែលកើតចេញពីសន្និសីទទាំងនោះ។ ការចូលរួមរបស់អាជ្ញាធរនៅក្នុងស្ថាប័នណាមួយដែលត្រូវបាន

បង្កើតឡើងក្រោយផែនការ ឬកិច្ចព្រមព្រៀងទាំងនោះ ត្រូវពាក់ព័ន្ធនឹងផលិតកម្ម នៅក្នុងតំបន់ និងស្របតាមវិធានដែលពាក់ ព័ន្ធរបស់ស្ថាប័នទាំង នោះ។

(គ) អាជ្ញាធរត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមផែនការ ឬកិច្ចព្រមព្រៀងដែលមានចែងនៅក្នុង កថាខណ្ឌនេះ ដើម្បីធានានូវការអនុវត្តប្រកបដោយស្មើភាព និងដោយគ្មានការរើសអើង ពាក់ព័ន្ធនឹងរាល់ផលិតកម្មរ៉ែនៅក្នុងតំបន់។ នៅក្នុងការអនុវត្តនេះ អាជ្ញាធរត្រូវធ្វើសកម្មភាពឱ្យបានសម ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាដែលមានស្រាប់ និងផែនការការងាររបស់សហគ្រាសដែលបាន អនុម័ត។

២. (ក) នៅក្នុងអំឡុងរយៈពេលបណ្ដោះអាសន្នដែលមានចែងនៅក្នុងកថាខណ្ឌទី ៣ ផលិតកម្មសម្រាប់គោលបំណងពាណិជ្ជកម្ម នឹងមិនត្រូវអនុវត្តតាមផែនការការងារ ដែលត្រូវបានអនុម័តរួចនោះទេ លុះត្រាតែប្រតិបត្តិករបានដាក់ពាក្យស្នើសុំ និងទទួលបានការអនុញ្ញាតឱ្យផលិតពីអាជ្ញាធរជាមុនសិន។ មិនអាចស្នើសុំ ឬចេញការអនុញ្ញាតឱ្យផលិតសម្រាប់រយៈពេលលើសពីប្រាំឆ្នាំចំពោះផែនការចាប់ផ្ដើមការងារផលិតកម្មសម្រាប់គោលបំណងពាណិជ្ជកម្មនៅក្រោមផែនការការងារបានទេ លុះត្រាតែវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរបានកំណត់រយៈពេលផ្សេងពីនេះ ក្រោយពីបានពិចារណាលើលក្ខណៈ និងការកំណត់ពេលវេលានៃការអភិវឌ្ឍគម្រោង។

(ខ) នៅក្នុងការដាក់ពាក្យសុំការអនុញ្ញាតផលិត ប្រតិបត្តិករត្រូវបញ្ជាក់ពីបរិមាណនីកែលដែលរំពឹងថា នឹងផលិតបានក្នុងមួយឆ្នាំៗនៅក្រោមផែនការការងារដែលបានអនុម័ត។ ពាក្យសុំក៏ត្រូវបញ្ចូលនូវកាលវិភាគចំណាយរបស់ ប្រតិបត្តិករនៅក្រោយពេលទទួលបានការអនុញ្ញាត ដែលត្រូវបានគណនាយ៉ាងលម្អិតដើម្បីអាចចាប់ផ្ដើមការផលិតសម្រាប់គោលបំណងពាណិជ្ជកម្មនៅកាលបរិច្ឆេទតាមផែនការកំណត់។

(គ) សម្រាប់គោលបំណងនៃកថាខណ្ឌរង (ក) និង (ខ) អាជ្ញាធរត្រូវបង្កើតលក្ខខណ្ឌនៃប្រតិបត្តិការ ឱ្យបានសមស្របតាមឧបសម្ព័ន្ធ ៣មាត្រា ១៧។

(ឃ) អាជ្ញាធរត្រូវផ្តល់ការអនុញ្ញាតលើការផលិតក្នុងកម្រិតមួយតាមការស្នើសុំ លើកលែងតែកម្រិត ផលិតកម្ម ឬកម្រិតដែលបានអនុញ្ញាតមុនៗ កើនឡើងលើសពីបរិមាណអតិបរមានៃនីកែលដែល ផលិតបាននៅក្នុងឆ្នាំដែលផ្តល់ការអនុញ្ញាតផ្អែកតាមការគណនាស្របតាមកថាខណ្ឌទី៤ នៅក្នុងអំឡុងឆ្នាំផែនការផលិតសម្រាប់រយៈពេលបណ្តោះអាសន្ន។

(ង) នៅពេលផ្តល់ការអនុញ្ញាត ការអនុញ្ញាតផលិតកម្ម និងពាក្យសុំដែលត្រូវបានអនុម័តនឹងក្លាយជា ផ្នែកមួយនៃផែនការការងារដែលបានអនុម័ត។

(ច) ប្រសិនបើពាក្យសុំការអនុញ្ញាតផលិតកម្មរបស់ប្រតិបត្តិករត្រូវបាន បដិសេធក្រោមកថាខណ្ឌរង (ឃ) នោះ ប្រតិបត្តិករអាចដាក់ពាក្យសុំជាថ្មីម្តងទៀតទៅកាន់អាជ្ញាធរនៅគ្រប់ពេលទាំងអស់។

៣. រយៈពេលបណ្តោះអាសន្ន គឺជារយៈពេលប្រាំឆ្នាំមុនថ្ងៃទី ១ ខែមករានៃឆ្នាំដែលគម្រោងផលិតកម្មដំបូង សម្រាប់គោលបំណងពាណិជ្ជកម្មចាប់ផ្តើមដំណើរការ តាមផែនការការងារដែលបានអនុម័ត។ ប្រសិនបើផលិតកម្ម សម្រាប់គោលបំណងពាណិជ្ជកម្មដំបូងត្រូវអូសបន្លាយហួសពីឆ្នាំផែនការដំបូង រយៈពេលចាប់ផ្តើមនៃរយៈពេលបណ្តោះ អាសន្ន និងបរិមាណអតិបរមានៃផលិតកម្មដែលគណនារួច នឹងត្រូវកែសម្រួលទៅតាមនោះ។ រយៈពេលបណ្តោះ អាសន្នអាចនឹងមានរយៈពេល ២៥ ឆ្នាំ ឬបន្តរហូតដល់ចប់សន្និសីទបូកសរុបការងារ ដែលមានចែងនៅក្នុង មាត្រា ១៥៥ ឬរហូតដល់ថ្ងៃដែលផែនការ ឬកិច្ចព្រមព្រៀងថ្មីដែលបានចែងនៅក្នុងកថាខណ្ឌទី១ ចូលជាធរមាន ដោយជ្រើសរើសយករយៈពេលណាមួយដែលឆាប់ជាងគេ។ អាជ្ញាធរត្រូវបន្តមានអំណាចដូចមានចែងនៅក្នុងមាត្រា នេះសម្រាប់រយៈពេលបណ្តោះដែលនៅសល់ ប្រសិនបើផែនការ ឬកិច្ចព្រមព្រៀងទាំងនោះអស់សុពលភាព ឬក្លាយជា គ្មានប្រសិទ្ធភាព ទោះដោយសារហេតុផលណាក៏ដោយ។

៤. (ក) បរិមាណផលិតជាអតិបរមានៃឆ្នាំនីមួយៗនៅក្នុងរយៈពេលបណ្តោះអាសន្ន គឺជាបរិមាណនៃ ៖

(i) លំអៀងតម្លៃតាមខ្សែបន្ទាត់និន្នាការ (Trendlinevalues)នៃការប្រើប្រាស់លោហធាតុ នីកែល ផ្អែកតាមការគណនាក្រោមកថាខណ្ឌរង (ខ) នៅក្នុងឆ្នាំមុនឆ្នាំផលិតកម្មសម្រាប់ គោលបំណងពាណិជ្ជកម្មដំបូង និង នៅក្នុងឆ្នាំមុនការចាប់ផ្តើមរយៈពេលបណ្តោះអាសន្ន។ និង

(ii) ហុកសិបភាគរយនៃតម្លៃតាមខ្សែបន្ទាត់និន្នាការនៃការប្រើប្រាស់លោហធាតុនីកែល ផ្អែក តាមការគណនាក្រោមកថាខណ្ឌរង (ខ) នៅក្នុងឆ្នាំស្នើសុំការអនុញ្ញាតផលិតកម្ម និងនៅក្នុងឆ្នាំ ដែលមុនឆ្នាំផលិតកម្មសម្រាប់គោលបំណងពាណិជ្ជកម្មដំបូង។

(ខ) សម្រាប់គោលបំណងនៃកថាខណ្ឌរង (ក) ខាងលើ៖

(i) តម្លៃតាមខ្សែបន្ទាត់និន្នាការ សម្រាប់គណនាបរិមាណអតិបរមានៃលោហធាតុនីកែលដែលផលិតបាន គឺជាតម្លៃប្រើប្រាស់នីកែលប្រចាំឆ្នាំផ្អែកតាមខ្សែបន្ទាត់និន្នាការ ដែលបានគណនានៅក្នុងអំឡុងឆ្នាំដែលទទួលការអនុញ្ញាតឱ្យផលិត។ ខ្សែបន្ទាត់និន្នាការ គឺជាលទ្ធផលនៃលំដាប់ថយចុះរបស់លីនេអ៊ែរឡូការីតនៃការប្រើប្រាស់នីកែលជាក់ស្តែងនៅក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយដែលមានទិន្នន័យពេលវេលាជាអថេរឯករាជ្យ។ ខ្សែបន្ទាត់ និន្នាការនេះហៅថាខ្សែបន្ទាត់និន្នាការដើម។

(ii) ប្រសិនបើអត្រាកើនឡើងប្រចាំឆ្នាំនៃខ្សែបន្ទាត់និន្នាការដើម តិចជាង ៣ភាគរយនោះ ខ្សែបន្ទាត់និន្នាការដែលយកមកកំណត់បរិមាណដែលកំណត់នៅក្នុងកថាខណ្ឌរង (ក) គឺជាខ្សែកោងដែលប្រសព្វជាមួយខ្សែបន្ទាត់និន្នាការ ដើមត្រង់តម្លៃនៅឆ្នាំទីមួយនៃរយៈពេល១៥ឆ្នាំដែលពាក់ព័ន្ធ ក្នុងលក្ខខណ្ឌដែលបរិមាណផលិតកម្មអតិបរមា ដែលបង្កើតឡើង សម្រាប់ឆ្នាំណាមួយនៅក្នុងអំឡុងរយៈពេលបណ្តោះអាសន្ន មិនអាចកើនឡើងលើសតម្លៃខុសគ្នារវាងតម្លៃតាមខ្សែបន្ទាត់និន្នាការដើម

ក្នុងឆ្នាំនោះ និងតម្លៃតាមខ្សែបន្ទាត់ និន្នាការដើមសម្រាប់ឆ្នាំនៅមុនពេលចាប់ផ្តើមរយៈពេលបណ្តោះអាសន្ន។

៥. សម្រាប់ផលិតកម្មដំបូងរបស់ខ្លួន អាជ្ញាធរត្រូវបម្រុងទុកជូនសហគ្រាសនូវបរិមាណនីកែល ៣៨.០០០តោនពីបរិមាណផលិតកម្មអតិបរមាដែលមាន និងបានគណនាតាមកថាខណ្ឌទី៤ ។

៦. (ក) នៅក្នុងឆ្នាំនីមួយៗ ប្រតិបត្តិករអាចផលិតតិច ឬច្រើនជាងរហូតដល់ ៨ ភាគរយពីកម្រិតផលិតកម្ម រ៉ែប្រចាំឆ្នាំចេញពីដុំប៉ូលីមេតាលិក ដែលបានកំណត់នៅក្នុងលិខិតអនុញ្ញាតផលិតរបស់ខ្លួន ក្នុងលក្ខខណ្ឌដែលបរិមាណសរុបនៃផលិតកម្មនោះមិនលើសពីបរិមាណ ដែលបានកំណត់នៅក្នុងលិខិតអនុញ្ញាត។ ក្នុងករណីផលិតលើសពី ៨ភាគរយរហូតដល់ ២០ភាគរយនៅក្នុងឆ្នាំណាមួយ ឬផលិតលើសនៅក្នុងឆ្នាំទីមួយ និងឆ្នាំបន្តបន្ទាប់ក្រោយពីបានផលិតលើសរយៈពេលពីរឆ្នាំជាប់គ្នា ប្រតិបត្តិករត្រូវចរចាជាមួយអាជ្ញាធរ ដែលអាចនឹងទាមទារឱ្យប្រតិបត្តិករស្នើសុំការអនុញ្ញាតផលិតបន្ថែមសម្រាប់ការផលិតលើសនោះ។

(ខ) អាជ្ញាធរអាចពិចារណាលើពាក្យសុំការអនុញ្ញាតផលិតបន្ថែម បានតែនៅក្រោយពេលដែលពាក្យសុំមិនទាន់សម្រេចទាំងអស់របស់ប្រតិបត្តិករដែលពុំទាន់ទទួលបានការអនុញ្ញាតឱ្យផលិត ត្រូវបានពិនិត្យពិចារណារួចរាល់អស់ហើយបានពិចារណាលើពាក្យសុំរបស់ប្រតិបត្តិករសក្តានុពលផ្សេងៗទៀតប៉ុណ្ណោះ។ អាជ្ញាធរនឹងគោរពតាមគោលការណ៍មិនលើសផលិតកម្មសរុបដែលអនុញ្ញាតនៅក្រោមបរិមាណផលិតកម្មអតិបរមានៅក្នុងឆ្នាំនៃរយៈពេលបណ្តោះអាសន្ន។ អាជ្ញាធរនឹងមិនអនុញ្ញាតឱ្យផលិតកម្មនៅក្រោមផែនការការងារ ណាមួយដែលមានបរិមាណផលិតនីកែលលើសពី ៤៦.៥០០តោនក្នុងមួយ ឆ្នាំទេ។

៧. កម្រិតផលិតកម្មលោហៈផ្សេងៗ រួមមានដូចជា ទង់ដែង កូប៉ល និងម៉ង់កាណែសផលិតពីបណ្តុំ ប៉ូលីមេតាលិក ក្រោមលិខិតអនុញ្ញាតផលិតកម្ម មិនត្រូវលើសពីកម្រិតសមត្ថភាពផលិតរបស់ប្រតិបត្តិក ប្រសិនបើប្រតិបត្តិករផលិតនីកែលក្នុងកម្រិតខ្ពស់បំផុតជាអតិបរមាពីបណ្តុំ

ប៉ូលីមេតាលិកទាំងនោះ ស្របតាមមាត្រានេះ ។ អាជ្ញាធរត្រូវបង្កើតវិធាន បទបញ្ញត្តិ និងនីតិវិធី ស្របតាមឧបសម្ព័ន្ធ ៣មាត្រា ១៧ ក្នុងការអនុវត្តបញ្ញត្តិនៃកថាខណ្ឌនេះ។

៨. សិទ្ធិ និងកាតព្វកិច្ច ដែលទាក់ទងនឹងការអនុវត្តសេដ្ឋកិច្ចដោយគ្មានភាពយុត្តិធម៌ក្រោមកិច្ចព្រមព្រៀង ពាណិជ្ជកម្មពហុភាគី នឹងត្រូវអនុវត្តលើការរុករក និងការធ្វើអាជីវកម្មរ៉ែពីតំបន់។ នៅក្នុងការដោះស្រាយវិវាទ ដែលកើតចេញពីបទបញ្ញត្តិនេះ រដ្ឋភាគីដែលជាភាគីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី ត្រូវប្រើប្រាស់នីតិវិធីដោះ ស្រាយវិវាទដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងទាំងនោះ។

៩. អាជ្ញាធរមានអំណាចកំណត់កម្រិតនៃការផលិតរ៉ែពីតំបន់ (លើកលែងតែរ៉ែដែលផលិតចេញពីបណ្តុំប៉ូលី មេតាលិក) នៅក្រោមលក្ខខណ្ឌទាំងនេះ និងដោយអនុវត្តវិធីសាស្ត្រសមស្របតាមរយៈការអនុវត្តបទបញ្ញត្តិដែលមាន ចែងនៅក្នុងមាត្រា ១៦១ កថាខណ្ឌទី ៨ ។

១០. សន្និបាតត្រូវបង្កើតប្រព័ន្ធទូទាត់សំណង ឬចាត់វិធានផ្តល់ជំនួយសម្របសម្រួលផ្នែកសេដ្ឋកិច្ចផ្សេងៗ រាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារឯកទេស ឬអង្គការអន្តរជាតិផ្សេងៗ ដើម្បីជួយប្រទេសកំពុង អភិវឌ្ឍ ដែលរងគ្រោះពីឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរទៅលើផលពីការ នាំចេញ ឬសេដ្ឋកិច្ចរបស់ពួកគេ ដែលបណ្តាលមកពីការធ្លាក់ចុះនៃតម្លៃរ៉ែដែលរងផលប៉ះពាល់ ឬការធ្លាក់ចុះនៃបរិមាណនាំចេញរ៉ែ ក្នុងកម្រិតដែលការធ្លាក់ចុះ បណ្តាលមកពីសកម្មភាពនៅក្នុងតំបន់ ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សាដែលផ្អែកលើដំបូន្មានពីគណៈកម្មការ រៀបចំផែនការសេដ្ឋកិច្ច។ នៅពេលមានការស្នើសុំ អាជ្ញាធរត្រូវផ្តួចផ្តើមធ្វើការសិក្សាអំពីបញ្ហារបស់រដ្ឋទាំងនោះ ដែលទំនងជានឹងរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត ដើម្បីកាត់បន្ថយផលលំបាករបស់ពួកគេឱ្យនៅកម្រិតអប្បបរមា និងជួយសម្របសម្រួលដល់បញ្ហាសេដ្ឋកិច្ចនៃរដ្ឋនោះ។

*មាត្រា ១៥៣*

*ការអនុវត្តអំណាច និងតួនាទីរបស់អាជ្ញាធរ*

១.	អាជ្ញាធរត្រូវអនុវត្តអំណាច និងតួនាទីរបស់ខ្លួនដោយគ្មានការរើសអើស រាប់បញ្ចូលទាំងការផ្តល់ឱកាសអនុវត្តសកម្មភាពនៅក្នុងតំបន់។

២.	ទោះជាយ៉ាងណាក្តី ការពិចារណាជាលក្ខណៈពិសេសសម្រាប់រដ្ឋកំពុងអភិវឌ្ឍន៍ រាប់បញ្ចូលទាំងការពិចារ ណាជាលក្ខណៈពិសេសសម្រាប់រដ្ឋហ៊ុំព័ទ្ធដោយដីគោក ឬរដ្ឋមានទីតាំងភូមិសាស្ត្រមិនអំណោយផល ដែលមានចែងនៅក្នុងផ្នែក នេះ នឹងត្រូវបានអនុញ្ញាត។

*មាត្រា ១៥៣*

*ប្រព័ន្ធរុករក និងធ្វើអាជីវកម្ម*

១.	សកម្មភាពនៅក្នុងតំបន់ នឹងត្រូវបានរៀបចំ អនុវត្ត និងគ្រប់គ្រងដោយអាជ្ញាធរក្នុងនាមមនុស្សជាតិ ទាំងមូល ស្របតាមមាត្រានេះ ព្រមទាំងបទបញ្ញត្តិពាក់ព័ន្ធផ្សេងៗនៅក្នុងផ្នែកនេះ និងឧបសម្ព័ន្ធពាក់ព័ន្ធ និងវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

២.	សកម្មភាពនៅក្នុងតំបន់ នឹងត្រូវអនុវត្ត ដូចមានចែងនៅក្នុងកថាខណ្ឌទី ៣ ៖

(ក)	ដោយសហគ្រាស និង

(ខ)	ដោយរដ្ឋភាគី ឬសហគ្រាសរបស់រដ្ឋ ឬរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិរបស់រដ្ឋភាគី ឬដែលត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពដោយរដ្ឋភាគី ឬពលរដ្ឋរបស់រដ្ឋភាគី នៅពេលដែល ទទួលបានការឧបត្ថម្ភពីរដ្ឋ ឬក្រុមខាងលើដែលបំពេញបានតាមលក្ខខណ្ឌតម្រូវដែលមានចែងនៅ ក្នុងផ្នែកនេះ  និងឧបសម្ព័ន្ធ ៣ក្រោមកិច្ចសហការជាមួយអាជ្ញាធរ។

៣.

សកម្មភាពនៅក្នុងតំបន់នឹងត្រូវអនុវត្តស្របតាមផែនការការងារផ្លូវការជាលាយលក្ខណ៍អ ក្សរ ដែលត្រូវ បានរៀបចំឡើងស្របតាមឧបសម្ព័ន្ធ ៣និងអនុម័តដោយក្រុមប្រឹក្សា ក្រោយពីគណៈកម្មការនីតិកម្ម និងបច្ចេកទេស បានពិនិត្យរួច។

ក្នុងករណីដែលសកម្មភាពនៅក្នុងតំបន់ត្រូវបានអនុវត្តដោយអង្គភាពដែលមានចែងនៅក្នុងកថាខណ្ឌទី ២ (ខ) ក្រោមការអនុញ្ញាតដោយអាជ្ញាធរ នោះផែនការការងារត្រូវមានទម្រង់ជាកិច្ចសន្យាស្របតាមឧបសម្ព័ន្ធ ៣។ កិច្ចសន្យាទាំងនេះចែងអំពីការរៀបចំរួមគ្នា ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ៣មាត្រា ១១ ។

៤. អាជ្ញាធរត្រូវគ្រប់គ្រងលើសកម្មភាពនៅក្នុងតំបន់ ទៅតាមការចាំបាច់ ដើម្បីធានានូវការគោរពតាមបទ បញ្ញត្តិពាក់ព័ន្ធនៅក្នុងផ្នែកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធ និងវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ និងផែនការ ការងារដែលត្រូវបានអនុម័តស្របតាមកថាខណ្ឌទី ៣ ។ បណ្តារដ្ឋភាគីត្រូវជួយអាជ្ញាធរដោយចាត់នូវរាល់វិធានការ ដែលចាំបាច់ ដើម្បីធានានូវការគោរពតាមមាត្រា ១៣៩ ។

៥. អាជ្ញាធរមានសិទ្ធិចាត់វិធានការដែលមានចែងនៅក្នុងផ្នែកនេះបានគ្រប់ពេលវេលា ដើម្បីធានានូវការ គោរពតាមបទបញ្ញត្តិនៅក្នុងផ្នែកនេះ និងការអនុវត្តមុខងារគ្រប់គ្រង និងនិយតកម្មដែលខ្លួនផ្តល់ជូនក្រោមផ្នែកនេះ ឬ នៅក្រោមកិច្ចសន្យា។ អាជ្ញាធរមានសិទ្ធិត្រួតពិនិត្យលើរាល់បបនកណ្ឌនៅក្នុងតំបន់ ដែលត្រូវបានប្រើប្រាស់ពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់។

៦. កិច្ចសន្យាដែលមានចែងនៅក្នុងកថាខណ្ឌទី ៣ ត្រូវចែងអំពីសន្តិសុខនៃភាពជាម្ចាស់កម្មសិទ្ធិផងដែរ។ ហេតុដូច្នេះ កិច្ចសន្យានេះមិនអាចធ្វើការកែសម្រួល ពន្យារបន្ត ឬបញ្ចប់បានឡើយ លើកលែងតែធ្វើឡើងស្របតាម ឧបសម្ព័ន្ធ ៣មាត្រា ១៨ និង ១៩ ប៉ុណ្ណោះ។

*មាត្រា ១៥៤*

*ការត្រួតពិនិត្យជាប្រចាំ*

ជារៀងរាល់រយៈពេលប្រាំឆ្នាំម្តងគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ សន្និបាទត្រូវរៀបចំ ធ្វើការត្រួតពិនិត្យជាទូទៅ

និងជាលក្ខណៈប្រព័ន្ធមួយទៅលើដំណើរការបង្កើតរបបអន្តរជាតិលើតំបន់ក្រោមអនុសញ្ញា នេះបានប្រតិបត្តិការជាក់ស្តែង។ ដោយផ្អែកលើការត្រួតពិនិត្យនេះ សន្និបាតអាចចាត់វិធានការ ឬស្នើឱ្យស្ថាប័នដទៃ ចាត់វិធានការស្របតាមបទបញ្ញត្តិ និងនីតិវិធីនៃផ្នែកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធសំដៅជំរុញដំណើរការនៃ ប្រព័ន្ធរបបនេះឱ្យល្អប្រសើរ។

*មាត្រា ១៥៥*

*សន្និសីទរំលឹក*

១.

រយៈពេលប្រាំឆ្នាំគិតចាប់ពីថ្ងៃទី១ខែមករានៃឆ្នាំដែលផលិតកម្មក្នុងគោលបំណងពាណិជ្ជកម្មបានចាប់ ផ្តើមអនុវត្តនៅក្រោមផែនការការងារដែលត្រូវបានអនុម័តសន្និបាតត្រូវកោះប្រជុំសន្និសីទដើម្បីត្រួតពិនិត្យបទបញ្ញត្តិនៃផ្នែកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធរុករក និងធ្វើអាជីវកម្មធនធាននៅក្នុងតំបន់។ សន្និសីទត្រួតពិនិត្យនេះត្រូវពិចារណាជាលក្ខណៈលម្អិតដោយផ្អែកលើបទពិសោធន៍ដែលទទួលបាននៅក្នុងអំឡុងពេលនោះ ដើម្បី កំណត់ដូចខាងក្រោមៈ

(ក) តើបទបញ្ញត្តិនៃផ្នែកនេះដែលទាក់ទងនឹងប្រព័ន្ធរុករក និងធ្វើអាជីវកម្មធនធាននៅក្នុងតំបន់ សម្រេចបានតាមគោលបំណងនៅគ្រប់តថភាព រួមទាំងថាតើពួកវាមានបានផ្តល់ផលប្រយោជន៍ដល់មនុស្សជាតិទាំងមូលដែរឬយ៉ាងណា។

(ខ) តើនៅក្នុងអំឡុងរយៈពេល១៥ឆ្នាំនេះតំបន់បម្រុងទុកត្រូវបានធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងតុល្យភាពដែរឬយ៉ាងណា បើប្រៀបធៀបទៅនឹងតំបន់មិនបម្រុងទុក។

(គ) តើការអភិវឌ្ឍ និងការប្រើប្រាស់តំបន់ និងធនធានក្នុងតំបន់ត្រូវបានធ្វើឡើងតាមលក្ខណៈដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកប្រកបដោយសុខភាពល្អនិងកំណើននៃពាណិជ្ជកម្មអន្តរជាតិប្រកបដោយតុល្យភាពដែរឬយ៉ាងណា។

(ឃ)

តើការអនុវត្តសកម្មភាពផ្តាច់មុខនៅក្នុងតំបន់ត្រូវបានបង្ការកុំឱ្យកើតមានដែរឬយ៉ាងណា។

(ង) តើគោលនយោបាយដែលមានចែងនៅក្នុងមាត្រា ១៥០ និង ១៥១ ត្រូវបានបំពេញដែរឬយ៉ាងណា និង

(ច)

តើប្រព័ន្ធនោះផ្តល់ការបែងចែកផលប្រយោជន៍បានមកពីសកម្មភាពនៅក្នុងតំបន់ប្រកបដោយស្មើភាពដោយពិចារណាយ៉ាងពិសេសទៅលើអត្ថប្រយោជន៍ និងតម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍន៍ដែរ ឬយ៉ាងណា។

២.

សន្និសីទត្រួតពិនិត្យនេះត្រូវធានារក្សាឱ្យបាននូវគោលការណ៍កេរ្តិ៍តំណែលរួមរបស់មនុស្សលោក របបអន្តរជាតិដែលបង្កើតឡើងដើម្បីធានានូវការធ្វើអាជីវកម្មធនធានក្នុងតំបន់ប្រកប ដោយស្មើភាពសម្រាប់បម្រើផលប្រយោជន៍របស់ប្រទេសទាំងអស់ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ និងអាជ្ញាធរមួយដែលរៀបចំ អនុវត្ត និងគ្រប់គ្រង សកម្មភាពនៅក្នុងតំបន់។ សន្និសីទនេះក៏ធានារក្សាឱ្យបាននូវគោលការណ៍ដែលមានចែងនៅក្នុងផ្នែកនេះ និងទាក់ទងនឹងការមិនបញ្ចូលនូវការអះអាងកម្មសិទ្ធិ ឬការអនុវត្តអព្យាក្រឹត្យភាពលើផ្នែកណាមួយនៃតំបន់សិទ្ធិរបស់រដ្ឋ និងការអនុវត្តជាទូទៅដែលទាក់ទងនឹងតំបន់ និងការចូលរួមរបស់បណ្តារដ្ឋ នៅក្នុងសកម្មភាពក្នុងតំបន់ស្របតាមអនុសញ្ញា នេះ ការបង្ការការអនុវត្តសកម្មភាពផ្តាច់មុខនៅក្នុងតំបន់ ការប្រើប្រាស់តំបន់តែសម្រាប់គោលបំណងសន្តិភាព តថភាព

សេដ្ឋកិច្ចនៃសកម្មភាពនៅក្នុងតំបន់ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ការផ្ទេរបច្ចេកវិទ្យា ការការពារបរិស្ថានសមុទ្រ ការការពារជីវិតមនុស្ស សិទ្ធិរបស់រដ្ឋជាប់ឆ្នេរ លក្ខខណ្ឌគតិយុត្តិនៃដែនសមុទ្រក្នុងតំបន់ និងលក្ខខណ្ឌគតិយុត្តិនៃលំហអាកាសពីលើដែនសមុទ្រទាំងនោះ និងការសម្របសម្រួលរវាងសកម្មភាពនៅក្នុងតំបន់ និងសកម្មភាពផ្សេងៗ ទៀតនៅក្នុងបរិស្ថានសមុទ្រ។

៣. នីតិវិធីធ្វើសេចក្តីសម្រេចចិត្តដែលត្រូវអនុវត្តនៅក្នុងសន្និសីទត្រួតពិនិត្យនេះ គឺជានីតិវិធីតែមួយដែលធ្វើ ឡើងនៅសន្និសីទសហប្រជាជាតិលើកទីបីស្តីពីច្បាប់សមុទ្រ។ សន្និសីទត្រូវខិតខំប្រឹងប្រែងគ្រប់យ៉ាងដើម្បីសម្រេចនូវកិច្ចព្រមព្រៀងស្តីពីការធ្វើវិសោធនកម្មតាមសម្លេងជាឯកច្ឆន្ទ ហើយមិនគួរមានការបោះឆ្នោតលើបញ្ហាទាំងនោះទេ លុះត្រាតែបានខិតខំប្រឹងប្រែងគ្រប់យ៉ាងដើម្បីសម្រេចនូវសម្លេងអនុម័តជាឯកច្ឆន្ទរួចប៉ុណ្ណោះ។

៤.

ប្រសិនបើរយៈពេលប្រាំឆ្នាំក្រោយពេលចាប់ផ្តើមសន្និសីទត្រួតពិនិត្យពុំអាចឈានដល់កិច្ចព្រមព្រៀងស្តីពីប្រព័ន្ធរុករក និងធ្វើអាជីវកម្មធនធាននៅក្នុងតំបន់ សន្និសីទអាចនឹងសម្រេចចិត្តដោយសម្លេងបីភាគបួននៃ រដ្ឋភាគី នៅក្នុងរយៈពេល ១២ ខែ ក្រោយមក ធ្វើការអនុម័ត និងបញ្ជូនឱ្យរដ្ឋភាគីផ្តល់សច្ចាប័ន ឬបញ្ចូលការធ្វើ វិសោធនកម្មដើម្បីផ្លាស់ប្តូរ ឬកែប្រែប្រព័ន្ធនោះទៅតាមការចាំបាច់ និងសមស្រប។ វិសោធនកម្មទាំងនេះនឹងចូលជាធរមានសម្រាប់រដ្ឋភាគីទាំងអស់ ក្រោយពីបានដាក់លិខិតផ្តល់សច្ចាប័ន ឬទទួលចូលជាសមាជិកដោយសម្លេងឆ្នោត បីភាគបួននៃរដ្ឋភាគី ។

៥. រាល់វិសោធនកម្មដែលអនុម័តដោយសន្និសីទរំលឹកក្រោមមាត្រានេះ នឹងមិនជះឥទ្ធិពលទៅលើសិទ្ធិដែលមានក្នុងកិច្ចសន្យាដទៃទៀតដែលមានជាធរមាននោះឡើយ។

### ជំពូកទី៤៖ អាជ្ញាធរ

### ជំពូករងក៖ បទបញ្ញត្តិទូទៅ

*មាត្រា ១៥៦*

*ការបង្កើតអាជ្ញាធរ*

១.	អាជ្ញាធរបាតសមុទ្រអន្តរជាតិត្រូវបានបង្កើតឡើង និងត្រូវអនុវត្តមុខងារស្របតាមផ្នែកនេះ។

២.	រដ្ឋភាគីទាំងអស់ត្រូវក្លាយជាសមាជិកនៃអាជ្ញាធរនេះ។

៣.	អ្នកសង្កេតការណ៍នៅក្នុងសន្និសីទសហប្រជាជាតិលើកទីបីស្តីពីច្បាប់សមុទ្រ ដែលបានចុះហត្ថលេខាលើអត្ថបទច្បាប់ចុងក្រោយ (FINALACT)និងមិនមានចែងនៅក្នុងមាត្រា ៣០៥ កថាខណ្ឌទី ១(គ)(ឃ)(ង) ឬ (ច) មានសិទ្ធិចូលរួមក្នុងអាជ្ញាធរ ក្នុងនាមជាអ្នកសង្កេតការណ៍ ស្របតាមវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់ អាជ្ញាធរ។

៤.	អាជ្ញាធរមានទីស្នាក់ការកណ្តាលស្ថិតនៅក្នុងប្រទេសចាម៉ៃកា(Jamaica)។

៥.	អាជ្ញាធរអាចបង្កើតមជ្ឈមណ្ឌល ឬការិយាល័យប្រចាំតំបន់ ប្រសិនបើខ្លួនយល់ថាចាំបាច់ ដើម្បីអនុវត្តមុខងាររបស់ខ្លួន។

*មាត្រា ១៥៧*

*ចរិតលក្ខណៈ និងគោលការណ៍មូលដ្ឋានរបស់អាជ្ញាធរ*

១.	អាជ្ញាធរ គឺជាអង្គការដែលរដ្ឋភាគីប្រើប្រាស់ដើម្បីរៀបចំ និងគ្រប់គ្រងសកម្មភាពនៅក្នុងតំបន់ ជាពិសេស ដើម្បីគ្រប់គ្រងធនធាននៅក្នុងតំបន់ ដោយអនុលោមតាមផ្នែកនេះ។

២.	អំណាច និងមុខងាររបស់អាជ្ញាធរ ត្រូវបានផ្តល់ជូន និងមានចែងបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងអនុសញ្ញា នេះ។ អនុលោមតាមអនុសញ្ញានេះ អាជ្ញាធរមានអំណាចពាក់ព័ន្ធដែលមាន និងចាំបាច់នៅក្នុងការអនុវត្តអំណាច និង មុខងារ ដែលពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់។

៣.	អាជ្ញាធរត្រូវគោរពគោលការណ៍អធិបតេយ្យស្មើភាពរបស់សមាជិកទាំងអស់របស់ខ្លួន។

៤.

សមាជិកទាំងអស់របស់អាជ្ញាធរត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្រោមផ្នែកនេះដោយសុទ្ធចិត្ត ដើម្បី ធានាថា ពួកគេទាំងអស់ទទួលបានសិទ្ធិ និងផលប្រយោជន៍ពីសមាជិកភាព។

*មាត្រា ១៥៨*

*ស្ថាប័នរបស់អាជ្ញាធរ*

១. ស្ថាប័នសំខាន់ៗរបស់អាជ្ញាធរ ដែលត្រូវបង្កើតឡើងរួមមាន សន្និបាត ក្រុមប្រឹក្សា និងលេខាធិការដ្ឋាន។

២. សហគ្រាស ដែលជាស្ថាប័នមួយរបស់អាជ្ញាធរ នឹងត្រូវបានបង្កើតឡើង ដើម្បីអនុវត្តមុខងារដែលមាន ចែងនៅក្នុងមាត្រា ១៧០ កថាខណ្ឌទី ១ ។

៣. ស្ថាប័នផ្សេងៗ អាចនឹងត្រូវបង្កើតឡើងតាមការចាំបាច់ ដោយអនុលោមតាមផ្នែកនេះ។

៤. ស្ថាប័នសំខាន់ៗរបស់អាជ្ញាធរ និងសហគ្រាសត្រូវទទួលខុសត្រូវលើការអនុវត្តអំណាច និងមុខងារដែល ត្រូវបានប្រគល់ឱ្យខ្លួន។ នៅក្នុងការអនុវត្តអំណាច និងមុខងារទាំងនោះ ស្ថាប័ននីមួយៗមិនត្រូវធ្វើសកម្មភាពណាមួយ ដែលអាចធ្វើឱ្យប៉ះពាល់ ឬបន្ទុចបង្អាក់ដល់ការអនុវត្តអំណាច និងមុខងាររបស់ស្ថាប័នផ្សេងឡើយ។

ជំពូករងខ៖ សន្និបាត

*មាត្រា ១៥៩*

*សមាសភាព នីតិវិធី និងការបោះឆ្នោត*

១. សន្និបាតត្រូវមានសមាសភាពចូលរួមដោយសមាជិកទាំងអស់របស់អាជ្ញាធរ។ សមាជិកនីមួយៗត្រូវមាន តំណាងមួយរូបនៅក្នុងសន្និបាត ដែលអាចអមដោយភូឈ្នួយ និងទីប្រឹក្សា។

២.	សន្និបាតត្រូវបើកសម័យប្រជុំប្រចាំឆ្នាំជាទៀងទាត់ និងសម័យប្រជុំពិសេស ដែលអាចនឹងសម្រេចរៀបចំដោយសន្និបាត ឬកោះប្រជុំដោយអគ្គលេខាធិការតាមសំណើរបស់ក្រុមប្រឹក្សា ឬសមាជិកភាគច្រើនរបស់អាជ្ញាធរ។

៣.	សម័យប្រជុំត្រូវរៀបចំធ្វើនៅឯទីស្នាក់ការកណ្តាលរបស់អាជ្ញាធរ លើកលែងតែសន្និបាតសម្រេចផ្ទុយពីនេះ។

៤.	សន្និបាតត្រូវអនុវត្តវិធានស្តីពីនីតិវិធីរបស់ខ្លួន។ នៅពេលចាប់ផ្តើមសម័យប្រជុំជាទៀងទាត់នីមួយៗ សន្និបាតត្រូវបោះឆ្នោតជ្រើសរើសប្រធាន និងមន្ត្រីផ្សេងៗទៅតាមការចាំបាច់។ ប្រធាន និងមន្ត្រីទាំងនេះត្រូវកាន់មុខតំណែងរបស់ខ្លួនរហូតដល់ពេលប្រធាន និងមន្ត្រីថ្មីត្រូវបានបោះឆ្នោតឱ្យចូលកាន់តំណែងជំនួសនៅសម័យប្រជុំ បន្ទាប់។

៥.	សមាជិកភាគច្រើននៃសន្និបាតត្រូវបានកំណត់ជាកូរ៉ុមសម្រាប់សម័យប្រជុំ។

៦.	សមាជិកនីមួយៗនៃសន្និបាតមានសម្លេងឆ្នោតមួយ។

៧.	សេចក្តីសម្រេចចិត្តស្តីពីបញ្ហានីតិវិធី រាប់ទាំងសេចក្តីសម្រេចចិត្តស្តីពីការកោះប្រជុំពិសេសនៃសន្និបាត ត្រូវធ្វើឡើងដោយសម្លេងឆ្នោតសមាជិកភាគច្រើនដែលមានវត្តមាន និងបានបោះឆ្នោត។

៨.	សេចក្តីសម្រេចលើបញ្ហាមាតិកា ត្រូវធ្វើឡើងដោយសម្លេងឆ្នោតពីរភាគបីនៃសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត ដោយសម្លេងឆ្នោតភាគច្រើននេះជាសម្លេងឆ្នោតរបស់សមាជិកភាគច្រើនដែលបានចូលរួមនៅក្នុងកិច្ចប្រជុំ ។ នៅពេលដែលមានបញ្ហាកើតឡើងទាក់ទងនឹងថាតើបញ្ហាមួយជាបញ្ហាមាតិកាឬមិនមែននោះបញ្ហានេះនឹងត្រូវចាត់ទុកជាបញ្ហាខ្លឹមសារ លើកលែងតែសន្និបាតបានសម្រេចផ្ទុយពីនេះតាមសម្លេងមតិភាគច្រើនដែលចាំបាច់សម្រាប់ធ្វើសេចក្តីសម្រេចចិត្តស្តីពីបញ្ហាមាតិកាប៉ុណ្ណោះ។

៩.

នៅពេលដែលមានបញ្ហាមាតិកាកើតឡើងសម្រាប់បោះឆ្នោតជាលើកដំបូងនោះប្រធានសន្និបាតអាច និងត្រូវពន្យារពេលមិនបោះឆ្នោតលើបញ្ហានេះរយៈពេលយ៉ាងយូរប្រាំថ្ងៃនៃថ្ងៃប្រតិទិន ប្រសិនបើមានសំណើពីសមាជិក យ៉ាងតិចមួយភាគប្រាំនៃសមាជិកសន្និបាត។ វិធីនេះអាចឱ្យអនុវត្តតែមួយដងគត់ចំពោះបញ្ហានីមួយៗដែលកើតឡើង ហើយមិនត្រូវអនុវត្តវិធីនេះដើម្បីពន្យារពេលបញ្ហាឱ្យកន្លងផុតពីសម័យប្រជុំនោះទេ។

១០.

នៅពេលមានសំណើជាលាយលក្ខណ៍អក្សរដែលមានការគាំទ្រពីសមាជិកយ៉ាងតិចមួយភាគបួននៃសមាជិកសន្និបាតផ្ញើទៅកាន់ប្រធានសន្និបាតដើម្បីស្នើសុំយោបល់អំពីលក្ខណៈស្របតាមបញ្ញត្តិអនុសញ្ញានេះនៃសំណើណាមួយដែលត្រូវបានលើកឡើងនៅចំពោះមុខសន្និបាតស្តីពីបញ្ហាណាមួយនោះ សន្និបាតត្រូវស្នើឱ្យសភាវិវាទបាតសមុទ្រនៃសាលាក្តីអន្តរជាតិផ្នែកច្បាប់សមុទ្រផ្តល់នូវយោបល់អំពីលក្ខណៈស្របច្បាប់នៃសំណើនោះហើយត្រូវពន្យារពេលបោះឆ្នោតលើសំណើនោះដោយរង់ចាំទទួលយោបល់ពីសភាវិវាទជាមុនសិន។ ប្រសិនបើមិនទទួលបានយោបល់នៅមុនសប្តាហ៍ចុងក្រោយនៃសម័យប្រជុំ ដែលសំណើត្រូវបានលើកឡើងទេនោះ សន្និបាតត្រូវធ្វើសេចក្តីសម្រេចចិត្តនៅពេលប្រជុំបោះឆ្នោតលើសំណើដែលពន្យារពេលនោះ។

*មាត្រា ១៦០*

*អំណាច និងមុខងារ*

១.	ក្នុងនាមជាស្ថាប័នតែមួយគត់របស់អាជ្ញាធរ ដែលមានសមាសភាពចូលរួមដោយសមាជិកទាំងអស់ សន្និបាតត្រូវបានចាត់ទុកជាស្ថាប័នកំពូលរបស់អាជ្ញាធរ ដែលស្ថាប័នសំខាន់ៗផ្សេងទៀតត្រូវទទួលខុសត្រូវចំពោះមុខស្ថាប័ននេះ

ដូចមានចែងយ៉ាងច្បាស់លាស់នៅក្នុងអនុសញ្ញានេះ។ សន្និបាតមានអំណាចបង្កើតគោលនយោបាយរួម ដែលអនុលោមតាមបទបញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ សម្រាប់រាល់បញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរ។

២. ទន្ទឹមនឹងនេះ សន្និបាតមានអំណាច និងមុខងារដូចខាងក្រោមៈ

(ក) បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាស្របតាមមាត្រា ១៦១ ។

(ខ) បោះឆ្នោតជ្រើសរើសអគ្គលេខាធិការពីក្នុងចំណោមបេក្ខជនដែលស្នើឡើងដោយក្រុមប្រឹក្សា។

(គ) បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលសហគ្រាស និងអគ្គនាយកសហគ្រាស ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សា។

(ឃ) បង្កើតស្ថាប័នដែលខ្លួនយល់ថាចាំបាច់ ដើម្បីអនុវត្តមុខងាររបស់ខ្លួនស្របតាមផ្នែកនេះ។ នៅក្នុងសមាសភាពនៃស្ថាប័នផ្សេងៗទាំងនេះ ត្រូវគិតគូរឱ្យបានសមស្របទៅលើគោលការណ៍បែងចែកតាមភូមិសាស្ត្រ ដោយស្មើភាព និងគិតគូរដល់អត្ថប្រយោជន៍ពិសេសរបស់សមាជិក និងសេចក្តីត្រូវការសមាជិកដែលមានគុណវុឌ្ឍិ និងសមត្ថភាពលើបញ្ហាបច្ចេកទេសពាក់ព័ន្ធរបស់ស្ថាប័នទាំងនោះ។

(ង) កំណត់ចំនួនទឹកប្រាក់វិភាគទានដែលសមាជិកត្រូវបង់ចូលថវិការដ្ឋបាលរបស់អាជ្ញាធរ ស្របតាមកម្រិត នៃការកំណត់ដែលបានព្រមព្រៀងគ្នា ដោយផ្អែកលើកម្រិតដែលត្រូវបានប្រើប្រាស់សម្រាប់ថវិកាទូទៅរបស់អង្គការសហប្រជាជាតិរហូតដល់ពេលដែលអាជ្ញាធរមានចំណូលគ្រប់គ្រាន់ពីប្រភពផ្សេងៗ សម្រាប់បំពេញតាមការចំណាយលើផ្នែករដ្ឋបាលរបស់ខ្លួន។

(ច) (i) ពិចារណា និងអនុម័តលើវិធាន បទបញ្ញត្តិ និងនីតិវិធីស្តីពីការបែងចែកអត្ថប្រយោជន៍ហិរញ្ញវត្ថុ និងអត្ថប្រយោជន៍សេដ្ឋកិច្ចផ្សេងៗ ដែលបានមកពីសកម្មភាពនៅក្នុងតំបន់ និងទឹកប្រាក់វិភាគទានដែលទូទាត់តាមមាត្រា ៨២ ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សា ដោយពិចារណាយ៉ាងដិតដល់ទៅលើអត្ថប្រយោជន៍ និងតម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍន៍ និងប្រជាជនដែលមិន ទាន់ទទួលបានឯករាជ្យពេញលេញ ឬឋានៈស្វ័យគ្រប់គ្រងផ្សេងទៀត។ ប្រសិនបើសន្និបាតមិនអនុម័តលើអនុសាសន៍របស់ក្រុមប្រឹក្សា សន្និបាតត្រូវប្រគល់អនុសាសន៍ទាំងនោះទៅឱ្យក្រុមប្រឹក្សាពិចារណាជាថ្មីឡើងវិញ ដោយផ្អែកលើយោបល់របស់សន្និបាត។

(ii) ពិចារណា និងអនុម័តលើវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ និងរាល់វិសោធនកម្ម ទាំងឡាយ ដែលត្រូវបានអនុម័តជាបណ្តោះអាសន្នដោយក្រុមប្រឹក្សាស្របតាមមាត្រា ១៦២ កថាខណ្ឌទី ២ (ណ)(ii)។ វិធាន បទបញ្ញត្តិ និងនីតិវិធីទាំងនេះត្រូវទាក់ទងនឹងសកម្មភាព ធ្វើបុរេសនា រុករក និងធ្វើអាជីវកម្មរ៉ែនៅក្នុងតំបន់ ការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលផ្ទៃក្នុងរបស់អាជ្ញាធរ ហើយផ្ទេរមូលនិធិពីសហគ្រាសទៅកាន់អាជ្ញាធរតបតាមអនុសាសន៍របស់ក្រុមប្រឹក្សាភិបាលសហគ្រាស។

(ឆ) ធ្វើការសម្រេចលើការបែងចែកអត្ថប្រយោជន៍ហិរញ្ញវត្ថុ និងអត្ថប្រយោជន៍សេដ្ឋកិច្ចផ្សេងៗ ដែលបានមកពីសកម្មភាពនៅក្នុងតំបន់ដោយស្មើភាព ស្របតាមអនុសញ្ញា វិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

(ជ) ពិចារណា និងអនុម័តលើសំណើថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរដែលក្រុមប្រឹក្សាបានបញ្ជូនមកឱ្យ។

(ឈ) ពិនិត្យរបាយការណ៍ជាប្រចាំដែលផ្ញើពីក្រុមប្រឹក្សា និងពីសហគ្រាស និងរបាយការណ៍ពិសេសដែលស្នើពីក្រុមប្រឹក្សា ឬស្ថាប័នផ្សេងៗរបស់អាជ្ញាធរ។

(ញ) ផ្តួចផ្តើមអនុវត្តការសិក្សា និងផ្តល់អនុសាសន៍សម្រាប់គោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់ និងជំរុញឱ្យមានការបង្កើតច្បាប់អន្តរជាតិដែលពាក់ព័ន្ធ និងចងក្រងជាក្រុមតែមួយ ឱ្យបានកាន់តែល្អប្រសើរ។

(ដ) ពិចារណាលើបញ្ហាដែលមានលក្ខណៈទូទៅ និងពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់ ដោយបានកើតឡើងជាលក្ខណៈពិសេសចំពោះរដ្ឋកំពុងអភិវឌ្ឍន៍ ព្រមទាំងបណ្តាបញ្ហាចំពោះរដ្ឋដែលពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់ ដោយសារកត្តាទីតាំងភូមិសាស្ត្រ ជាពិសេសរដ្ឋហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋមានទីតាំងភូមិសាស្ត្រមិនអំណោយផល។

(ឋ) បង្កើតប្រព័ន្ធផ្តល់សំណង ឬវិធានការផ្តល់ជំនួយសម្របសម្រួលផ្នែកសេដ្ឋកិច្ចផ្សេងៗទៀតដែលមានចែងនៅក្នុងមាត្រា ១៥១ កថាខណ្ឌទី ១០ ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សាដែលផ្អែកលើយោបល់ពីគណៈកម្មការរៀបចំផែនការសេដ្ឋកិច្ច។

(ឌ) ព្យួរការអនុវត្តសិទ្ធិ និងបុព្វសិទ្ធិសមាជិកភាពស្របតាមមាត្រា ១៨៥ ។

(ឍ) ពិភាក្សាអំពីបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរ និងធ្វើការសម្រេចចិត្តថាតើស្ថាប័នណាមួយរបស់អាជ្ញាធរត្រូវដោះស្រាយបញ្ហា

ដែលពុំបានផ្តល់ទៅឱ្យស្ថាប័នណាមួយច្បាស់លាស់ ដោយអនុលោមតាមការបែង ចែកអំណាច និងមុខងារក្នុងចំណោមស្ថាប័នរបស់អាជ្ញាធរ។

ជំពូករងគ៖ ក្រុមប្រឹក្សា

មាត្រា ១៦១

*សមាសភាព នីតិវិធី និងការបោះឆ្នោត*

១. សមាសភាពក្រុមប្រឹក្សានេះមានសមាជិក ៣៦ របស់អាជ្ញាធរ ដែលត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយសន្និបាតតាមលំដាប់ដូចខាងក្រោមនេះ ៖

(ក) សមាជិកបួនរូបពីក្នុងចំណោមរដ្ឋភាគី ដែលនៅក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនៃស្ថិតិដែលមាន បានប្រើប្រាស់ច្រើនជាង ២ ភាគរយនៃការប្រើប្រាស់សរុបនៅលើពិភពលោក ឬបាននាំចូលច្រើនជាង ២ ភាគរយនៃការនាំចូលសុទ្ធសរុបនៅលើពិភពលោក នូវទំនិញដែលផលិតបានពីប្រភេទរ៉ែបានមកពីតំបន់ ហើយនៅគ្រប់ករណីទាំងអស់ រួមមានរដ្ឋមួយពីតំបន់អឺរ៉ុបខាងកើត (សង្គមនិយម) ព្រមទាំងរដ្ឋដែលបានប្រើប្រាស់ទំនិញច្រើន ជាងគេផងដែរ។

(ខ) សមាជិកបួនរូបពីក្នុងចំណោមរដ្ឋភាគីទាំងប្រាំបីដែលបានរួមចំណែកច្រើនជាងគេ នៅក្នុងការរៀបចំ និង ការអនុវត្តសកម្មភាពនៅក្នុងតំបន់ មិនថាដោយផ្ទាល់ ឬតាមរយៈពលរដ្ឋរបស់ពួកគេ ដោយក្នុងនោះយ៉ាងតិចក៏ត្រូវ មានរដ្ឋមួយពីតំបន់អឺរ៉ុបខាងកើត (សង្គមនិយម) ផងដែរ។

(គ) សមាជិកបួនរូបពីក្នុងចំណោមរដ្ឋភាគី ដែលផ្អែកលើផលិតកម្មនៅក្នុងតំបន់ស្ថិតក្រោមយុត្តាធិការរបស់ពួកគេ គឺជារដ្ឋនាំចេញសុទ្ធធំបំផុត នូវប្រភេទរ៉ែដែលនឹងយកចេញពីតំបន់

ដោយក្នុងនោះយ៉ាងតិចក៏ត្រូវមានរដ្ឋកំពុងអភិវឌ្ឍន៍ចំនួនពីរ ដែលការនាំចេញរ៉ែរបស់ពួកគេមានចំណែកធំធេងទៅលើសេដ្ឋកិច្ចរបស់ពួកគេ ។

(ឃ)

សមាជិកប្រាំមួយរូបពីក្នុងចំណោមរដ្ឋភាគីកំពុងអភិវឌ្ឍន៍ដែលតំណាងឱ្យអត្ថប្រយោជន៍ពិសេស។ អត្ថប្រយោជន៍ពិសេសដែលត្រូវមានតំណាងទាំងនោះ រួមមានអត្ថប្រយោជន៍របស់រដ្ឋដែលមានប្រជាជនច្រើន រដ្ឋគ្មានសមុទ្រ ឬរដ្ឋមានទីតាំងភូមិសាស្ត្រមិនអំណោយផល រដ្ឋនាំចូលធំៗនៃប្រភេទរ៉ែដែលនឹងត្រូវទាញចេញពីតំបន់រដ្ឋមានសក្តានុពលខ្ពស់ក្នុងការផលិតរ៉ែទាំងនោះ និងរដ្ឋដែលមានការអភិវឌ្ឍតិចតួចបំផុត។

(ង)

សមាជិកដប់ប្រាំបីរូបដែលត្រូវបានបោះឆ្នោតជ្រើសរើសតាមគោលការណ៍ធានាការបែងចែកអាសនៈនៅក្នុងក្រុមប្រឹក្សាទាំងមូលតាមភូមិសាស្ត្រដោយស្មើភាពដោយតំបន់ភូមិសាស្ត្រនីមួយៗត្រូវមានសមាជិកយ៉ាងតិចមួយរូបដែលត្រូវបានបោះឆ្នោតជ្រើសរើសនៅក្រោមកថាខណ្ឌរងនេះ។ សម្រាប់គោលបំណងនេះ តំបន់ភូមិសាស្ត្រទាំងនេះ រួមមានអាហ្វ្រិក អាស៊ី អឺរ៉ុបខាងកើត (សង្គមនិយម) អាមេរិកឡាទីន អឺរ៉ុបខាងលិច និងតំបន់ផ្សេងៗទៀត។

២.

នៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិករបស់ក្រុមប្រឹក្សាស្របតាមកថាខណ្ឌទី១សន្និបាតត្រូវធានាថា ៖

(ក) រដ្ឋហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល ទទួលបានភាពជាតំណាងក្នុងកម្រិតមួយ ដែលសមមាត្រទៅនឹងភាពជាតំណាងរបស់ពួកគេនៅក្នុងសន្និបាត។

(ខ) រដ្ឋជាប់ឆ្នេរ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ ដែលពុំមានលក្ខណៈសម្បត្តិក្រោមកថាខណ្ឌទី ១(ក)(ខ)(គ) ឬ (ឃ) ទទួលបានភាពជាតំណាងក្នុងកម្រិតមួយ ដែលសមមាត្រទៅនឹងភាពជាតំណាងរបស់ពួកគេនៅក្នុងសន្និបាត។

(គ) ក្រុមនីមួយៗនៃរដ្ឋភាគីដែលនឹងទទួលបានភាពជាតំណាងនៅក្នុងក្រុមប្រឹក្សា ត្រូវមានសមាជិកតំណាងឱ្យខ្លួន (ប្រសិនបើមាន) ដែលត្រូវជ្រើសតាំងដោយក្រុមខ្លួន។

៣. ការបោះឆ្នោតត្រូវរៀបចំធ្វើនៅក្នុងសម័យប្រជុំជាទៀងទាត់របស់សន្និបាត ។ សមាជិកនីមួយៗនៃក្រុមប្រឹក្សា នឹងត្រូវបោះឆ្នោតជ្រើសរើសសម្រាប់រយៈពេលបួនឆ្នាំ។ ទោះជាយ៉ាងណាក្តី នៅក្នុងការបោះឆ្នោតលើកទីមួយ អាណត្តិរបស់សមាជិកពាក់កណ្តាលនៃក្រុមនីមួយៗដែលមានចែងនៅក្នុងកថាខណ្ឌទី១ មានរយៈពេលតែពីរឆ្នាំប៉ុណ្ណោះ។

៤. សមាជិកក្រុមប្រឹក្សាមានសិទ្ធិឈរឈ្មោះបោះឆ្នោតជាថ្មី ប៉ុន្តែត្រូវយកចិត្តទុកដាក់ឱ្យបានសមស្របទៅលើបំណងចង់បានការផ្លាស់វេនសមាជិកភាព។

៥. ក្រុមប្រឹក្សាត្រូវអនុវត្តមុខងារនៅឯទីស្នាក់ការរបស់អាជ្ញាធរ ហើយត្រូវកោះប្រជុំឱ្យញឹកញាប់ទៅតាម តម្រូវការការងាររបស់អាជ្ញាធរ ប៉ុន្តែមិនត្រូវប្រជុំតិចជាងបីដងក្នុងមួយឆ្នាំទេ។

៦. សមាជិកភាគច្រើននៃក្រុមប្រឹក្សាបង្កើតបានជាកូរ៉ុម។

៧. សមាជិកនីមួយៗនៃក្រុមប្រឹក្សាមានសម្លេងឆ្នោតមួយ។

៨. (ក) សេចក្តីសម្រេចចិត្តស្តីពីបញ្ហានីតិវិធី ត្រូវធ្វើឡើងដោយសម្លេងឆ្នោតសមាជិកភាគច្រើនដែលមានវត្តមាន និងបានបោះឆ្នោត។

(ខ) សេចក្តីសម្រេចចិត្តស្តីពីបញ្ហាមាតិកា ដែលបានកើតឡើងនៅក្រោមបទបញ្ញត្តិខាងក្រោម

ត្រូវធ្វើឡើងដោយសម្លេងឆ្នោតពីរភាគបីនៃសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត ដោយសម្លេងឆ្នោតភាគច្រើននេះជាសម្លេងឆ្នោតរបស់សមាជិកភាគច្រើននៃក្រុមប្រឹក្សា៖ បទបញ្ញត្តិនៃមាត្រា ១៦២ កថាខណ្ឌទី ២ កថាខណ្ឌរង (ច)(ឆ)(ជ)(ឈ)(ឍ)(ត)(ផ) និងមាត្រា ១៩១ ផងដែរ។

(គ) សេចក្តីសម្រេចចិត្តស្តីពីបញ្ហាមាតិកា ដែលបានកើតឡើងនៅក្រោមបទបញ្ញត្តិខាងក្រោម ត្រូវធ្វើឡើងដោយសម្លេងឆ្នោតបីភាគបួននៃសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត ដោយសម្លេងឆ្នោតភាគច្រើននេះរួមមានទាំងសម្លេងឆ្នោតរបស់សមាជិកភាគច្រើននៃក្រុមប្រឹក្សា៖ បទបញ្ញត្តិ នៃមាត្រា ១៦២ កថាខណ្ឌទី ១ មាត្រា ១៦២ កថាខណ្ឌទី ២ កថាខណ្ឌរង (ក)(ខ)(គ)(ឃ)(ង)(ឋ)(ត)(ថ)(ទ)(ធ)(ន)(ប) ក្នុងករណីមិនគោរពអនុវត្តកិច្ចសន្យាដោយអ្នក ម៉ៅការ ឬម្ចាស់ឧបត្ថម្ភ កថាខណ្ឌរង (ព) ដោយបញ្ហាដែលចេញនៅក្រោមកថាខណ្ឌរងនេះ អាចនឹងចងភ្ជាប់កាតព្វកិច្ចរយៈពេលយ៉ាងយូរ៣០ថ្ងៃ លើកលែងតែមានការបញ្ជាក់ដោយសេចក្តីសម្រេចដែលធ្វើឡើងស្របតាមកថាខណ្ឌរង (ឃ) មាត្រា ១៦២ កថាខណ្ឌទី ២ កថាខណ្ឌរង (ភ)(ម)(យ) មាត្រា ១៦៣ កថាខណ្ឌទី ២ មាត្រា ១៧៤ កថាខណ្ឌទី ៣ ឧបសម្ព័ន្ធ ៤មាត្រា ១១ ។

(ឃ) សេចក្តីសម្រេចចិត្តស្តីពីបញ្ហាមាតិកា ដែលបានកើតឡើងនៅក្រោមបទបញ្ញត្តិខាងក្រោម ត្រូវធ្វើឡើងដោយសម្លេងឯកច្ឆន្ទ៖ បទបញ្ញត្តិនៃមាត្រា ១៦២ កថាខណ្ឌទី ២ (ឌ) និង (ណ) ការអនុម័តវិសោធនកម្មលើផ្នែកទី ៩។

(ង) សម្រាប់គោលបំណងនៃកថាខណ្ឌរង (ឃ)(ច) និង (ឆ) "សម្លេងឯកច្ឆន្ទ"មានន័យថា ពុំមាន សម្លេងជំទាស់ជាផ្លូវការ។ នៅក្នុងរវាង១៤ថ្ងៃក្រោយថ្ងៃដាក់សំណើទៅកាន់ក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវកំណត់ថាតើនឹងមាន ឬគ្មានការជំទាស់ជាផ្លូវការទៅលើការអនុម័តសំណើនោះដែរឬយ៉ាងណា។ ប្រសិនបើប្រធានក្រុមប្រឹក្សាកំណត់ថានឹងមានការជំទាស់ នោះប្រធានក្រុមប្រឹក្សាត្រូវបង្កើត និងកោះប្រជុំគណៈកម្មាធិការផ្សះផ្សាមួយនៅក្នុងរយៈពេលបីថ្ងៃក្រោយពេលកំណត់ ខាងលើ ដែលមានសមាសភាពយ៉ាងច្រើនបំផុតសមាជិកប្រាំបួនរូបនៃក្រុមប្រឹក្សាដោយប្រធានក្រុមប្រឹក្សាមានតួនាទីជាប្រធានគណៈកម្មាធិការនេះ ក្នុងគោលបំណងផ្សះផ្សាការខ្វែងគំនិត និងបង្កើតសំណើមួយដែលអាចឱ្យមានការអនុម័តជាឯកច្ឆន្ទ។ ប្រសិនបើគណៈកម្មាធិការមិនអាចលើកជាសំណើណាមួយដែលអាចឱ្យមានការអនុម័តជាឯកច្ឆន្ទទេនោះគណៈកម្មាធិការត្រូវបញ្ចូលមូលហេតុនៃការជំទាស់លើសំណើនេះទៅក្នុងរបាយការណ៍របស់ខ្លួន។

(ច) សេចក្តីសម្រេចចិត្តស្តីពីបញ្ហាពុំមានចែងខាងលើ ដែលក្រុមប្រឹក្សាមានសិទ្ធិធ្វើការសម្រេចតាមវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ ឬឯកសារផ្សេង នឹងត្រូវធ្វើឡើងស្របតាមកថាខណ្ឌរងនៃកថាខណ្ឌនេះ ដូចបានកំណត់នៅក្នុងវិធាន បទបញ្ញត្តិ និងនីតិវិធី ឬប្រសិនបើពុំមានកំណត់នៅក្នុងឯកសារទាំងនោះទេ នោះត្រូវធ្វើឡើងស្របតាមកថាខណ្ឌរងដែលកំណត់ដោយក្រុមប្រឹក្សាតាមសម្លេងឯកច្ឆន្ទជាមុន ប្រសិនអាចធ្វើទៅបាន។

(ឆ) នៅពេលដែលបញ្ហាមួយលេចឡើង ដោយគេមិនដឹងថាបញ្ហានេះស្ថិតក្នុងកថាខណ្ឌរង(ក)(ខ)(គ) ឬ (ឃ)

នោះបញ្ហានេះនឹងត្រូវចាត់ទុកជាបញ្ហាស្ថិតក្នុងកថាខណ្ឌរងមួយណាដែលទាមទារ សម្លេងអនុម័តភាគច្រើនខ្ពស់ជាងគេ ឬសម្លេងឯកច្ឆន្ទទៅតាមករណីជាក់ស្តែង លើកលែងតែក្រុមប្រឹក្សាបានសម្រេចផ្ទុយពីនេះដោយសម្លេងភាគច្រើន ឬដោយសម្លេងឯកច្ឆន្ទ។

៩. ក្រុមប្រឹក្សាត្រូវបង្កើតនីតិវិធីមួយ ដែលអនុញ្ញាតឱ្យសមាជិកអាជ្ញាធរ ដែលពុំមានតំណាងនៅក្នុងក្រុមប្រឹក្សា អាចបញ្ជូនតំណាងមួយរូបទៅចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សា នៅពេលដែលសមាជិករូបនោះដាក់សំណើ ឬនៅពេលមានកំពុងមានការពិចារណាទៅលើបញ្ហាដែលបង្កផលប៉ះពាល់ជាលក្ខណៈពិសេស។ អ្នកតំណាងរូបនេះមាន សិទ្ធិចូលរួមក្នុងកិច្ចពិភាក្សា តែពុំមានសិទ្ធិបោះឆ្នោតទេ។

*មាត្រា ១៦២*

*អំណាច និងមុខងារ*

១. ក្រុមប្រឹក្សាជាស្ថាប័នប្រតិបត្តិរបស់អាជ្ញាធរ។ ក្រុមប្រឹក្សាមានអំណាចបង្កើតគោលនយោបាយជាក់លាក់ សម្រាប់ឱ្យអាជ្ញាធរអនុវត្តទាក់ទិននឹងបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរ ស្របតាមបទបញ្ញត្តិនៃអនុសញ្ញានេះ និងគោលនយោបាយរួមរបស់សន្និបាត។

២. ទន្ទឹមនឹងនេះ សន្និបាតមានអំណាច និងមុខងារដូចខាងក្រោម ៖

(ក) ពិនិត្យ និងសម្របសម្រួលការអនុវត្តបញ្ញត្តិនៅក្នុងផ្នែកនេះ ទាក់ទិននឹងរាល់បញ្ហាដែលស្ថិតក្នុងយុត្តាធិការរបស់អាជ្ញាធរ និងត្រូវស្នើឱ្យសន្និបាតពិចារណាទៅលើករណីនៃការមិនបំពេញតាមលក្ខខណ្ឌ។

(ខ) ដាក់សំណើបញ្ជីឈ្មោះបេក្ខជនទៅកាន់សន្និបាតសម្រាប់ការបោះឆ្នោតជ្រើសរើសអគ្គលេខាធិការ។

(គ) ផ្តល់អនុសាសន៍ជូនសន្និបាតអំពីបេក្ខជន ដែលត្រូវបោះឆ្នោតជ្រើសរើសជាសមាជិកក្រុមប្រឹក្សាភិបាល សហគ្រាស និងអគ្គនាយកសហគ្រាស។

(ឃ) បង្កើតស្ថាប័នផ្សេងៗដែលខ្លួនយល់ថាចាំបាច់ឱ្យបានសមស្រប ដោយគិតគូរម៉ត់ចត់អំពីសេដ្ឋកិច្ច និងប្រសិទ្ធផល ដើម្បីអនុវត្តមុខងាររបស់ខ្លួនស្របតាមផ្នែកនេះ។ នៅក្នុងសមាសភាពនៃស្ថាប័នផ្សេងៗទាំងនេះ ត្រូវយកចិត្តទុកដាក់ខ្ពស់ទៅលើតម្រូវការសមាជិកដែលមានគុណវុឌ្ឍិ និងសមត្ថភាពលើការដោះស្រាយបញ្ហាបច្ចេកទេស ពាក់ព័ន្ធរបស់ស្ថាប័នទាំងនោះ ដោយបានគិតគូរដិតដល់ទៅលើគោលការណ៍បែងចែកតាមភូមិសាស្ត្រដោយស្មើភាពនិងអត្ថប្រយោជន៍ពិសេសរបស់សមាជិក ។

(ង) អនុវត្តវិធានស្តីពីនីតិវិធី រាប់បញ្ចូលទាំងវិធីសាស្ត្រជ្រើសរើសប្រធានក្រុមប្រឹក្សាផងដែរ។

(ច) ចុះកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ឬអង្គការអន្តរជាតិជួសមុខអាជ្ញាធរ និងក្នុងយុត្តាធិការរបស់ខ្លួនបន្ទាប់ពីទទួលបានការអនុម័តពីសន្និបាត។

(ឆ) ពិចារណាលើរបាយការណ៍របស់សហគ្រាស និងបញ្ជូនរបាយការណ៍ទៅសន្និបាតដោយអមជាមួយនឹងអនុសាសន៍។

(ជ) ដាក់របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ពិសេសទៅកាន់សន្និបាតនៅពេលមានសំណើពីសន្និបាត។

(ឈ) ចេញសេចក្តីណែនាំទៅកាន់សហគ្រាសស្របតាមមាត្រា ១៧០ ។

(ញ) អនុម័តផែនការការងារស្របតាមឧបសម្ព័ន្ធ ៣មាត្រា ៦ ។ ក្រុមប្រឹក្សាត្រូវធ្វើសកម្មភាពលើផែនការ ការងារនីមួយៗនៅក្នុងរយៈពេល ៦០ ថ្ងៃ

គិតចាប់ពីថ្ងៃគណៈកម្មការនីតិកម្ម និងបច្ចេកទេសបានដាក់ផែនការការងារនៅក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សា ស្របតាមនីតិវិធីខាងក្រោម៖

(i) ប្រសិនបើគណៈកម្មការផ្តល់អនុសាសន៍ឱ្យអនុម័តផែនការការងារណាមួយនោះត្រូវចាត់ទុកថា ក្រុមប្រឹក្សាបានអនុម័តលើផែនការនេះ ប្រសិនបើគ្មានសមាជិកណាមួយនៃក្រុមប្រឹក្សាបានដាក់លិខិតជំទាស់ទៅកាន់ប្រធានក្រុមប្រឹក្សា នៅក្នុងរយៈពេល ១៤ថ្ងៃ ដោយចោទប្រកាន់ពីករណី មិនគោរពតាមលក្ខខណ្ឌតម្រូវនៃឧបសម្ព័ន្ធ ៣មាត្រា ៦ ទេនោះ ។ ប្រសិនបើមានការជំទាស់នោះត្រូវអនុវត្តតាមនីតិវិធីផ្សះផ្សាដូចមានចែងនៅក្នុងមាត្រា ១៦១ កថាខណ្ឌទី ៨(ង)។ ប្រសិនបើនៅចុងបញ្ចប់នៃនីតិវិធីផ្សះផ្សានេះការជំទាស់នៅតែបន្តមាននោះ ផែនការការងារនឹងត្រូវចាត់ទុកថាបានអនុម័តដោយក្រុមប្រឹក្សា ប្រសិនបើក្រុមប្រឹក្សាពុំបានច្រានចោលផែនការនេះ ដោយសម្លេងឯកច្ឆន្ទក្នុងចំណោមសមាជិកក្រុមប្រឹក្សា ដោយពុំរាប់បញ្ចូលរដ្ឋដែលដាក់ពាក្យ ជំទាស់ ឬរដ្ឋគាំទ្រភាគីដាក់ពាក្យជំទាស់។

(ii) ប្រសិនបើគណៈកម្មការផ្តល់អនុសាសន៍ឱ្យច្រានចោលផែនការការងារ ឬមិនបានផ្តល់អនុសាសន៍ណាមួយទេ នោះក្រុមប្រឹក្សាអាចអនុម័តផែនការងារនេះដោយសម្លេងឆ្នោតបីភាគបួនរបស់សមាជិកដែលមានវត្តមាន និងបានបោះឆ្នោត ដោយសម្លេងឆ្នោតភាគច្រើននេះក៏ត្រូវមាន សម្លេងរបស់សមាជិកភាគច្រើនដែលបានចូលរួមនៅក្នុងកិច្ចប្រជុំផងដែរ ។

(ដ) អនុម័តផែនការការងារដែលដាក់ជូនដោយសហគ្រាសស្របតាមឧបសម្ព័ន្ធ ៤មាត្រា ១២ ដោយ អនុវត្ត រាប់ទាំងរាល់វិសោធនកម្មទាំងឡាយ នីតិវិធីចែងនៅក្នុងកថាខណ្ឌរង (ញ) ។

(ឋ) អនុវត្តការត្រួតពិនិត្យលើសកម្មភាពនៅក្នុងតំបន់ ស្របតាមមាត្រា ១៥៣ កថាខណ្ឌទី ៤ និងវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

(ឌ) ចាត់វិធានការចាំបាច់ និងសមស្របតាមមាត្រា ១៥០ កថាខណ្ឌរង (ជ) ទៅតាមអនុសាសន៍របស់គណៈកម្មការរៀបចំផែនការសេដ្ឋកិច្ច ដើម្បីផ្ដល់ការការពារពីផលប៉ះពាល់សេដ្ឋកិច្ចអវិជ្ជមាន ដែលមានចែងនៅក្នុងកថាខណ្ឌរងនោះ។

(ឍ) ផ្ដល់អនុសាសន៍ជូនសន្និបាត ដោយផ្អែកលើយោបល់របស់គណៈកម្មការរៀបចំផែនការសេដ្ឋកិច្ចអំពីការបង្កើតប្រព័ន្ធផ្ដល់សំណង ឬវិធានការផ្ដល់ជំនួយសម្របសម្រួលផ្នែកសេដ្ឋកិច្ចផ្សេងៗទៀត ដែលមានចែងនៅក្នុងមាត្រា ១៥១ កថាខណ្ឌទី ១០ ។

(ណ) (i) ផ្ដល់អនុសាសន៍ជូនសន្និបាតអំពីវិធាន បទបញ្ញត្តិ និងនីតិវិធីស្ដីពីការបែងចែកអត្ថប្រយោជន៍ ហិរញ្ញវត្ថុ និងអត្ថប្រយោជន៍សេដ្ឋកិច្ចផ្សេងៗ ដែលបានមកពីសកម្មភាពនៅក្នុងតំបន់ និងទឹកប្រាក់វិភាគទានដែលទូទាត់តាមមាត្រា ៨២ ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សា ដោយពិចារណាយ៉ាងពិសេសទៅលើអត្ថប្រយោជន៍ និងតម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍន៍ និងប្រជាជនដែលមិនទាន់ទទួលបានឯករាជ្យពេញលេញ ឬឋានៈស្វ័យគ្រប់គ្រងផ្សេងទៀត។

(ii) អនុម័ត និងអនុវត្តជាបណ្តោះអាសន្នដោយរង់ចាំការអនុម័តពីសន្និបាត នូវវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ និងរាល់វិសោធនកម្មទាំងឡាយ ដោយពិចារណាលើអនុសាសន៍របស់គណៈ កម្មការនីតិកម្ម និងបច្ចេកទេស ឬស្ថាប័នផ្សេងៗដែលពាក់ព័ន្ធផ្សេងទៀត។ វិធាន បទបញ្ញត្តិ និងនីតិវិធីទាំងនេះត្រូវទាក់ទងនឹងការធ្វើ បុរេសនា រុករក និងធ្វើអាជីវកម្មរ៉ែនៅក្នុងតំបន់ ការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលផ្ទៃក្នុងរបស់អាជ្ញាធរ។ អាទិភាពត្រូវផ្តល់ទៅលើការអនុម័ត វិធាន បទបញ្ញត្តិ និងនីតិវិធីស្តីពីការរុករក និងការធ្វើអាជីវកម្មដុំលោហៈប៉ូលីមេតាលិក។ វិធាន បទបញ្ញត្តិ និងនីតិវិធីស្តីពីការរុករក និងការធ្វើអាជីវកម្មធនធានក្រៅពីដុំលោហៈ ប៉ូលីមេតាលិកក្រៅពី នឹងត្រូវអនុម័តនៅក្នុងរយៈពេលបីឆ្នាំ គិតចាប់ពីថ្ងៃដែលសមាជិកណាមួយ របស់ខ្លួនដាក់សំណើទៅកាន់អាជ្ញាធរ ដែលស្នើឱ្យអនុម័តវិធាន បទបញ្ញត្តិ និងនីតិវិធីដែល ពាក់ព័ន្ធនឹងធនធានទាំងនោះ។ រាល់វិធាន បទបញ្ញត្តិ និងនីតិវិធីនៅបន្តមានប្រសិទ្ធភាពជាបណ្តោះអាសន្នរហូតដល់ពេលមាន ការអនុម័តពីសន្និបាត ឬការធ្វើវិសោធនកម្មរបស់ក្រុមប្រឹក្សាតាមទស្សនៈរបស់សន្និបាត។

(ត) ពិនិត្យលើការប្រមូលរាល់ទឹកប្រាក់ដែលទូទាត់ដោយអាជ្ញាធរ និងទឹកទឹកប្រាក់ដែលទូទាត់ជូនអាជ្ញាធរពាក់ព័ន្ធនឹងប្រតិបត្តិការស្របតាមផ្នែក នេះ។

(ថ) ធ្វើការជ្រើសរើសចេញពីក្នុងចំណោមបេក្ខជនដាក់ពាក្យសុំការអនុញ្ញាតផលិត ស្របតាមឧបសម្ព័ន្ធ ៣មាត្រា ៧ ប្រសិនបើបទបញ្ញត្តិនោះទាមទារឱ្យមានការជ្រើសរើសយ៉ាងដូច្នេះ។

(ទ) បញ្ជូនសំណើថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរទៅឱ្យសន្និបាតអនុម័ត។

(ធ) ផ្តល់អនុសាសន៍ជូនសន្និបាតពាក់ព័ន្ធនឹងគោលនយោបាយស្តីពីបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរ។

(ន) ផ្តល់អនុសាសន៍ជូនសន្និបាតពាក់ព័ន្ធនឹងការពន្យារពេលក្នុងអនុវត្តសិទ្ធិ និងបុព្វសិទ្ធិសមាជិកភាពតាម មាត្រា ១៨៥ ។

(ប) ផ្តួចផ្តើមនីតិវិធីបណ្តឹងក្នុងនាមអាជ្ញាធរទៅកាន់សភាវិវាទបាតសមុទ្រក្នុងករណីមានការរំលោភបំពានណាមួយ។

(ផ) ជូនដំណឹងដល់សន្និបាត នៅពេលដែលសភាវិវាទបាតសមុទ្រចេញសេចក្តីសម្រេចនៅក្នុងនីតិវិធីបណ្តឹងដែលធ្វើឡើងក្រោមកថាខណ្ឌរង (ប) និងផ្តល់អនុសាសន៍ដែលខ្លួនយល់ថាសមស្របពាក់ព័ន្ធនឹងវិធានការដែលត្រូវចាត់ឡើងនាពេលបន្ទាប់។

(ព) ចេញដីកាបន្ទាន់ ដែលអាចរួមមានទាំងដីកាពន្យារពេល ឬកែប្រែប្រតិបត្តិការផង ដើម្បីការពារផលប៉ះពាល់ធ្ងន់ធ្ងរទៅលើបរិស្ថានសមុទ្រ ដែលកើតឡើងដោយសារសកម្មភាពនៅក្នុងតំបន់។

(ភ) មិនផ្តល់ការអនុម័តលើតំបន់ធ្វើអាជីវកម្មដោយក្រុមហ៊ុនម៉ៅការ ឬសហគ្រាស ក្នុងករណីដែលមានភស្តុតាងច្បាស់លាស់បង្ហាញពីហានិភ័យនៃគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះបរិស្ថានសមុទ្រ។

(ម) បង្កើតស្ថាប័នផ្សេងៗមួយដើម្បីពន្យល់ពិស្តារអំពីពង្រាងវិធានហិរញ្ញវត្ថុ បទបញ្ញត្តិ និងនីតិវិធីដែលពាក់ព័ន្ធនឹង៖

(i) ការគ្រប់គ្រងហិរញ្ញវត្ថុស្របតាមមាត្រា ១៧១ ដល់មាត្រា ១៧៥ ។ និង

(ii) ការគ្រប់គ្រងហិរញ្ញវត្ថុស្របតាមឧបសម្ព័ន្ធ ៣មាត្រា ១៣ និងមាត្រា ១៧ កថាខណ្ឌទី ១(គ)។

(យ) បង្កើតយន្តការសមស្របសម្រាប់ដឹកនាំ និងត្រួតពិនិត្យបុគ្គលិកក្រុមអធិការកិច្ចដែលត្រួតពិនិត្យសកម្មភាពនៅក្នុងតំបន់ដើម្បីកំណត់ថាតើមានការគោរពអនុវត្តតាមផ្នែកនេះ វិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ និងលក្ខខណ្ឌក្នុងកិច្ចសន្យាជាមួយអាជ្ញាធរដែរឬយ៉ាងណា។

*មាត្រា ១៦៣*

*ស្ថាប័នក្រុមប្រឹក្សា*

១. ស្ថាប័នរបស់ក្រុមប្រឹក្សា ដែលត្រូវបង្កើតឡើងរួមមាន ៖

(ក) គណៈកម្មការរៀបចំផែនការសេដ្ឋកិច្ច

(ខ) គណៈកម្មការនីតិកម្ម និងបច្ចេកទេស

២. គណៈកម្មការនីមួយៗមានសមាជិក ១៥ រូប ដែលត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយក្រុមប្រឹក្សានៅក្នុងចំណោមបេក្ខជនដែលស្នើឡើងដោយរដ្ឋភាគី។ ទោះជាយ៉ាងណាក្តី ប្រសិនបើចាំបាច់ ក្រុមប្រឹក្សាអាចសម្រេចបង្កើនទំហំគណៈកម្មការនីមួយៗ ក្រោយពីបានពិចារណាយ៉ាងដិតដល់ទៅលើស្ថានភាពសេដ្ឋកិច្ច និងប្រសិទ្ធផល។

៣. សមាជិកគណៈកម្មការនីមួយៗត្រូវមានគុណវុឌ្ឍិសមស្របនៅក្នុងផ្នែកនៃសមត្ថកិច្ចរបស់គណៈកម្មការ។ រដ្ឋភាគីត្រូវស្នើបេក្ខជនដែលមានស្តង់ដារសមត្ថភាព

និងវិជ្ជាជីវៈខ្ពស់បំផុតរួមជាមួយនឹងគុណវុឌ្ឍិក្នុងផ្នែកដែលពាក់ព័ន្ធ ដើម្បីធានានូវការអនុវត្តមុខងាររបស់គណៈកម្មការបានដោយមានប្រសិទ្ធភាពខ្ពស់។

៤. នៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនីមួយៗ ត្រូវយកចិត្តទុកដាក់ឱ្យបានសមស្របទៅលើតម្រូវការបែងចែកតាមភូមិសាស្ត្រប្រកបដោយសមភាព និងភាពជាតំណាងឱ្យអត្ថប្រយោជន៍ពិសេស។

៥.

គ្មានរដ្ឋភាគីណាមួយអាចស្នើបេក្ខជនលើសពីមួយរូបសម្រាប់គណៈកម្មការតែមួយនោះទេ។ គ្មានបុគ្គលណាម្នាក់ត្រូវបានបោះឆ្នោតឱ្យបម្រើការនៅក្នុងគណៈកម្មការលើសពីមួយនោះដែរ។

៦. សមាជិកគណៈកម្មការមានអាណត្តិរយៈពេលប្រាំឆ្នាំ។ ពួកគេមានសិទ្ធិឈរឈ្មោះបោះឆ្នោតជាថ្មីសម្រាប់មួយអាណត្តិបន្តទៀត។

៧. ក្នុងករណីមរណភាព អសមត្ថភាព ឬលាលែងពីតំណែងរបស់សមាជិកណាម្នាក់ពីគណៈកម្មការនៅមុនពេលផុតអាណត្តិ ក្រុមប្រឹក្សាត្រូវបោះឆ្នោតជ្រើសរើសសមាជិកមួយរូបពីតំបន់ភូមិសាស្ត្រ ឬផ្នែកដដែលមកបន្តការងារសម្រាប់អាណត្តិដែលនៅសល់។

៨. សមាជិកគណៈកម្មការគ្មានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុនៅក្នុងសកម្មភាពណាមួយ ដែលទាក់ទងនឹងការរុករក និងការធ្វើអាជីវកម្មធនធាននៅក្នុងតំបន់នោះទេ។ ដោយផ្អែកលើការទទួលខុសត្រូវរបស់សមាជិកចំពោះ គណៈកម្មការដែលពួកគេបម្រើការ សមាជិកមិនត្រូវលាតត្រដាងនូវការសម្ងាត់ផ្នែកឧស្សាហកម្ម ទិន្នន័យស្ដីពីកម្មសិទ្ធិដែលត្រូវបានផ្ទេរទៅឱ្យអាជ្ញាធរតាមឧបសម្ព័ន្ធ ៣មាត្រា ១៤ ឬព័ត៌មានសម្ងាត់ផ្សេងៗទៀតដែលពួកគេ បានដឹងតាមរយៈការបំពេញភារកិច្ចជូនអាជ្ញាធរឡើយសូម្បីតែនៅក្រោយពេលដែលពួកគេឈប់ធ្វើការផង ដែរ។

៩. គណៈកម្មការនីមួយៗត្រូវអនុវត្តមុខងាររបស់ខ្លួនស្របតាមសេចក្ដីណែនាំ និងសរាចរណ៍ ដែលក្រុមប្រឹក្សាអាចនឹងអនុម័តឱ្យអនុវត្ត។

១០. គណៈកម្មការនីមួយៗត្រូវរៀបចំវិធាន និងបទបញ្ញត្តិដែលអាចនឹងចាំបាច់ដើម្បីអនុវត្តមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព រួចដាក់ជូនក្រុមប្រឹក្សាអនុម័ត។

១១. នីតិវិធីធ្វើសេចក្តីសម្រេចចិត្តរបស់គណៈកម្មការនឹងត្រូវបង្កើតឡើងដោយវិធានបទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។ ប្រសិនបើចាំបាច់ការផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាត្រូវអមមកជាមួយនឹងសេចក្តីសង្ខេបស្តីពីគំនិតផ្សេងៗគ្នារបស់សមាជិកនៅក្នុងគណៈកម្មការ។

១២. គណៈកម្មការនីមួយៗត្រូវបំពេញមុខងារជាធម្មតានៅឯទីស្នាក់ការរបស់អាជ្ញាធរ ហើយត្រូវជួបប្រជុំ ឱ្យបានញឹកញាប់ទៅតាមការចាំបាច់ ដើម្បីអនុវត្តមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

១៣. នៅក្នុងការអនុវត្តមុខងាររបស់ខ្លួន គណៈកម្មការនីមួយៗអាចពិគ្រោះយោបល់ជាមួយគ្នាទៅវិញទៅមក ឬជាមួយស្ថាប័នមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ ឬជាមួយទីភ្នាក់ងារបច្ចេកទេសរបស់ខ្លួន ឬជាមួយអង្គការអន្តរជាតិផ្សេងៗដែលមានសមត្ថកិច្ចលើកម្មវត្ថុនៃការពិគ្រោះយោបល់ទៅតាមករណីជាក់ស្តែង។

*មាត្រា ១៦៤*

*គណៈកម្មការរៀបចំផែនការសេដ្ឋកិច្ច*

១. សមាជិកគណៈកម្មការរៀបចំផែនការសេដ្ឋកិច្ចត្រូវមានគុណវុឌ្ឍិសមស្រប រួមមានដូចជាគុណវុឌ្ឍិដែល ទាក់ទងនឹងដំណើរការទាញយករ៉ែ ការគ្រប់គ្រងសកម្មភាពធនធានរ៉ែ ពាណិជ្ជកម្មអន្តរជាតិ ឬសេដ្ឋកិច្ចអន្តរជាតិ។ ក្រុមប្រឹក្សាត្រូវខិតខំធានាឱ្យបានថាសមាជិកភាពនៅក្នុងគណៈកម្មការនេះឆ្លុះបញ្ចាំងនូវរាល់គុណវុឌ្ឍិដែលសមស្របទាំងអស់។ សមាសភាពគណៈកម្មការត្រូវមានសមាជិកយ៉ាងតិចពីររូបមកពីរដ្ឋកំពុងអភិវឌ្ឍន៍

ដែលការនាំចេញប្រភេទរ៉ែយកចេញពីតំបន់របស់រដ្ឋពួកគេ
មានចំណែកធំធេងទៅលើសេដ្ឋកិច្ចរបស់រដ្ឋពួកគេ។

២. គណៈកម្មការនេះត្រូវ៖

(ក) លើកសំណើស្តីពីវិធានការដែលត្រូវអនុវត្តសេចក្តីសម្រេចចិត្តទាក់ទងនឹងសកម្មភាពនៅក្នុងតំបន់ ដែលត្រូវបានសម្រេចឡើងស្របតាមអនុសញ្ញានេះ តបតាមសំណើរបស់ក្រុមប្រឹក្សា។

(ខ) ត្រួតពិនិត្យនិន្នាការ និងកត្តាដែលប៉ះពាល់ដល់ការផ្គត់ផ្គង់ តម្រូវការ និងតម្លៃរ៉ែដែលអាចនឹងទាញចេញពីតំបន់ ដោយគិតគូរដល់អត្ថប្រយោជន៍របស់ប្រទេសនាំចូលនិងប្រទេសនាំចេញជាពិសេសអត្ថប្រយោជន៍របស់រដ្ឋកំពុងអភិវឌ្ឍន៍។

(គ) ត្រួតពិនិត្យស្ថានការណ៍ដែលអាចនាំឱ្យកើតមានឥទ្ធិពលអវិជ្ជមានដូចមានចែងនៅក្នុងមាត្រា ១៥០ កថាខណ្ឌ (ជ) ដែលរដ្ឋភាគីពាក់ព័ន្ធមួយ ឬច្រើនបានលើកមកឱ្យពិចារណា និងផ្តល់អនុសាសន៍សមស្របជូនក្រុមប្រឹក្សា។

(ឃ) ស្នើក្រុមប្រឹក្សាឱ្យបញ្ជូនទៅកាន់សន្និបាតដូចមានចែងនៅក្នុងមាត្រា ១៥១ កថាខណ្ឌទី ១០ នូវប្រព័ន្ធផ្តល់សំណង ឬវិធានការផ្តល់ជំនួយសម្របសម្រួលផ្នែកសេដ្ឋកិច្ចផ្សេងៗទៀតសម្រាប់រដ្ឋកំពុងអភិវឌ្ឍន៍ ដែលបានរងគ្រោះពីឥទ្ធិពលអវិជ្ជមានដែលបណ្តាលមកពីសកម្មភាពនៅក្នុងតំបន់។ គណៈកម្មការត្រូវផ្តល់ជូនក្រុមប្រឹក្សានូវអនុសាសន៍ដែលចាំបាច់សម្រាប់ការអនុវត្តប្រព័ន្ធ ឬ វិធានការផ្សេងៗ ដែលត្រូវបានអនុម័តដោយសន្និបាតនៅក្នុងករណីជាក់ស្តែងនីមួយៗ។

*មាត្រា ១៦៥*

*គណៈកម្មការនីតិកម្ម និងបច្ចេកទេស*

១. សមាជិកគណៈកម្មការនីតិកម្ម និងបច្ចេកទេសត្រូវមានគុណវុឌ្ឍិសមស្រប រួមមានដូចជាគុណវុឌ្ឍិដែល ទាក់ទងនឹងដំណើរការរុករក និងធ្វើអាជីវកម្មរ៉ែ ដំណើការកែច្នៃធនធានរ៉ែ សាគរសាស្ត្រ ការការពារបរិស្ថាន សមុទ្រ ឬបញ្ហាសេដ្ឋកិច្ច បញ្ហាច្បាប់ដែលទាក់ទងនឹងការទាញយករ៉ែនៅក្នុងមហាសមុទ្រ និងជំនាញឯកទេសពាក់ព័ន្ធផ្សេងៗ។ ក្រុមប្រឹក្សាត្រូវខិតខំធានាឱ្យបានថា សមាជិកភាពនៅក្នុងគណៈកម្មការនេះឆ្លុះបញ្ចាំងនូវរាល់គុណវុឌ្ឍិដែលសមស្របទាំងអស់។

២. គណៈកម្មការនេះត្រូវ៖

(ក) ផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់អាជ្ញាធរ តបតាមសំណើរបស់ក្រុមប្រឹក្សា។

(ខ) ពិនិត្យផែនការការងារផ្លូវការជាលាយលក្ខណ៍អក្សរសម្រាប់សកម្មភាពនៅក្នុងតំបន់ ស្របតាមមាត្រា ១៥៣ កថាខណ្ឌទី ៣ និងដាក់អនុសាសន៍សមស្របទៅកាន់ក្រុមប្រឹក្សា។ អនុសាសន៍របស់គណៈកម្មការត្រូវផ្អែកទៅលើមូលដ្ឋានដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ៣តែប៉ុណ្ណោះ ហើយគណៈកម្មការត្រូវ រាយការណ៍អំពីមូលដ្ឋានទាំងនេះជូនទៅក្រុមប្រឹក្សាឱ្យបានពេញលេញ។

(គ) ត្រួតពិនិត្យសកម្មភាពនៅក្នុងតំបន់ឱ្យបានសមស្រប ដោយពិគ្រោះយោបល់ និងសហការជាមួយ អង្គភាពដែលអនុវត្តសកម្មភាពទាំងនោះ ឬជាមួយរដ្ឋដែលពាក់ព័ន្ធ តបតាមសំណើរបស់ក្រុមប្រឹក្សា រួចរាយការណ៍អំពីលទ្ធផលត្រួតពិនិត្យជូនទៅក្រុមប្រឹក្សា។

(ឃ) រៀបចំការវាយតម្លៃលើបញ្ហាបរិស្ថានដែលកើតចេញពីសកម្មភាពនៅក្នុងតំបន់។

(ង) ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាស្តីពីការការពារបរិស្ថានសមុទ្រ ក្រោយពីបានពិចារណាទៅលើទស្សនៈរបស់អ្នកជំនាញការដែលមានការទទួលស្គាល់នៅក្នុងវិស័យនេះ។

(ច) បង្កើត និងដាក់ជូនក្រុមប្រឹក្សានូវវិធាន បទបញ្ញត្តិ និងនីតិវិធីដែលមានចែងនៅក្នុងមាត្រា ១៦២ កថាខណ្ឌទី ២(ណ) ក្រោយពីបានពិចារណាលើរាល់កត្តាពាក់ព័ន្ធទាំងអស់ រួមមានដូចជាការវាយតម្លៃ លើបញ្ហាបរិស្ថានដែលកើតចេញពីសកម្មភាពនៅក្នុងតំបន់។

(ឆ) ត្រួតពិនិត្យវិធាន បទបញ្ញត្តិ និងនីតិវិធីនៅជាប្រចាំ ហើយផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាអំពីការធ្វើ វិសោធនកម្មលើវិធាន បទបញ្ញត្តិ និងនីតិវិធីទាំងនោះ ទៅតាមការដែលខ្លួនយល់ថាចាំបាច់ ឬចង់បាន។

(ជ)

ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាពាក់ព័ន្ធនឹងការបង្កើតកម្មវិធីត្រួតពិនិត្យតាមដានមួយ ដើម្បីអង្កេតវាស់វែង វាយតម្លៃ និងវិភាគហានិភ័យ ឬឥទ្ធិពលនៃការបំពុលបរិស្ថានសមុទ្រដែលកើតចេញពីសកម្មភាពនៅក្នុងតំបន់ ដោយប្រើប្រាស់វិធីសាស្ត្រវិទ្យាសាស្ត្រដែលមានការទទួលស្គាល់ជាទៀងទាត់ដើម្បីធានាថា បទបញ្ញត្តិដែលមានស្រាប់ មានចំនួនគ្រប់គ្រាន់ ហើយត្រូវបានអនុវត្ត និងសម្របសម្រួលការអនុវត្តកម្មវិធីត្រួតពិនិត្យតាមដាន ក្រោយពីទទួលបានការអនុម័តពីក្រុមប្រឹក្សា។

(ឈ)

ផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាផ្តួចផ្តើមដាក់ពាក្យបណ្តឹងទៅកាន់សភាវិវាទបាតសមុទ្រក្នុងជួសមុខឱ្យអាជ្ញាធរ ដោយអនុលោមតាមផ្នែកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធក្រោយពីបានពិចារណា យ៉ាងល្អិតល្អន់ទៅលើមាត្រា ១៨៧ ។

(ញ) ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាពាក់ព័ន្ធនឹងវិធានការដែលត្រូវចាត់ឡើង ដោយផ្អែកលើសេចក្តីសម្រេចរបស់សភាវិវាទបាតសមុទ្រនៅក្នុងដំណើរការជំនុំជំរះលើពាក្យបណ្តឹងដែលដាក់ឡើងស្រប តាមកថាខណ្ឌរង (ឈ) ។

(ដ) ផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាចេញដីកាបន្ទាន់ ដែលអាចមានរួមទាំងដីកាផ្អាក ឬកែតម្រូវប្រតិបត្តិការ ដើម្បីបង្ការគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះបរិស្ថានសមុទ្រ ដែលកើតចេញពីសកម្មភាពនៅក្នុងតំបន់។ ក្រុមប្រឹក្សាត្រូវអនុម័តលើអនុសាសន៍ទាំងនេះ ដោយផ្អែកលើគោលការណ៍អាទិភាព។

(ឋ)

ផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាមិនផ្តល់ការអនុម័តលើតំបន់ធ្វើអាជីវកម្ម ដោយក្រុមហ៊ុនម៉ៅការ ឬសហគ្រាស ក្នុងករណីដែលមានភស្តុតាងច្បាស់លាស់បង្ហាញពីហានិភ័យនៃគ្រោះថ្នាក់ធ្ងន់ធ្ងរ ចំពោះ បរិស្ថានសមុទ្រ។

(ឌ) ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាពាក់ព័ន្ធនឹងការដឹកនាំ និងត្រួតពិនិត្យបុគ្គលិកក្រុមអធិការកិច្ចដែល ត្រួតពិនិត្យសកម្មភាពនៅក្នុងតំបន់ ដើម្បីកំណត់ថាតើមានការគោរពអនុវត្តតាមផ្នែកនេះ វិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ និងលក្ខខណ្ឌក្នុងកិច្ចសន្យាជាមួយអាជ្ញាធរដែរឬយ៉ាងណា។

(ឍ) គណនាកម្រិតផលិតកម្មអតិបរមា និងចេញលិខិតអនុញ្ញាតផលិតក្នុងនាមអាជ្ញាធរ ស្របតាមមាត្រា ១៥១ កថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៧ ក្រោយពីក្រុមប្រឹក្សាបានជ្រើសរើសពីក្នុងចំណោមបេក្ខជន ស្នើសុំលិខិតអនុញ្ញាតផលិត ស្របតាមឧបសម្ព័ន្ធ ៣មាត្រា ៧ ។

៣. នៅពេលមានសំណើពីរដ្ឋភាគី ឬភាគីផ្សេងទៀតដែលពាក់ព័ន្ធ សមាជិកគណៈកម្មការត្រូវមានតំណាង មួយរូបរបស់រដ្ឋ ឬភាគីពាក់ព័ន្ធនោះអមដំណើរជាមួយខ្លួន នៅពេលកំពុងអនុវត្តមុខងារត្រួតពិនិត្យ និងអង្កេតរបស់ខ្លួន។

ជំពូករងយះ លេខាធិការដ្ឋាន

*មាត្រា ១៦៦*

*លេខាធិការដ្ឋាន*

១. សមាសភាពលេខាធិការដ្ឋានរបស់អាជ្ញាធររួមមាន អគ្គលេខាធិការមួយរូប និងបុគ្គលិកផ្សេងៗដែល អាជ្ញាធរអាចនឹងត្រូវការ។

២. អគ្គលេខាធិការត្រូវបានជ្រើសរើសពីក្នុងចំណោមបេក្ខជនដែលស្នើឡើងដោយក្រុមប្រឹក្សា តាមរយៈការ បោះឆ្នោតដោយសន្និបាតសម្រាប់រយៈពេលបួនឆ្នាំ និងអាចឈរឈ្មោះបោះឆ្នោតជាថ្មី។

៣. អគ្គលេខាធិការគឺជាប្រធានមន្ត្រីរដ្ឋបាលនៃអាជ្ញាធរ និងត្រូវដើរតួនាទីក្នុងនាមជាប្រធាន មន្ត្រីរដ្ឋបាល នៅក្នុងរាល់កិច្ចប្រជុំរបស់សន្និបាតក្រុមប្រឹក្សា និងស្ថាប័នផ្សេងៗ ហើយត្រូវបំពេញមុខងាររដ្ឋបាលផ្សេងៗទៀតដែល ស្ថាប័នទាំងនេះបានផ្តល់ទៅឱ្យអគ្គលេខាធិការ។

៤. អគ្គលេខាធិការត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីការងាររបស់អាជ្ញាធរជូនសន្និបាត។

*មាត្រា ១៦៧*

*បុគ្គលិករបស់អាជ្ញាធរ*

១. បុគ្គលិកអាជ្ញាធររួមមានបុគ្គលិកផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស និងបុគ្គលិកមានគុណវុឌ្ឍិដទៃទៀត ដែល អាចនឹងត្រូវការដើម្បីអនុវត្តមុខងាររដ្ឋបាលរបស់អាជ្ញាធរ។

២. ការពិចារណាខ្ពស់បំផុតនៅក្នុងការជ្រើសរើស និងការផ្តល់កាងារដល់បុគ្គលិក និង ក្នុងការកំណត់លក្ខខណ្ឌការងារ គឺជាកត្តាចាំបាច់ក្នុងការធានានូវការទទួលបានស្តង់ដារប្រសិទ្ធភាព

សមត្ថភាព និងវិជ្ជាជីវៈខ្ពស់បំផុត។ នៅពេលធ្វើការពិចារណាលើបញ្ហានេះ ត្រូវយកចិត្តទុកដាក់សមស្របទៅលើសារៈសំខាន់នៃការជ្រើសរើសបុគ្គលិកដែលផ្អែកលើមូលដ្ឋានភូមិសាស្ត្រទូលំទូលាយបំផុត។

៣. បុគ្គលិកទទួលបានការតែងតាំងដោយអគ្គលេខាធិការ។ លក្ខខណ្ឌស្តីពីការតែងតាំង ការផ្តល់ភាគលាភ និងការបណ្តេញបុគ្គលិកចេញពីតំណែង ត្រូវស្របទៅនឹងវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរផងដែរ។

*មាត្រា ១៦៨*

*ចរិតលក្ខណៈជាអន្តរជាតិនៃលេខាធិការដ្ឋាន*

១. នៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន អគ្គលេខាធិការ និងបុគ្គលិកមិនត្រូវស្វែងរក ឬទទួលយកសេចក្តី ណែនាំពីរដ្ឋាភិបាលណាមួយ ឬពីប្រភពផ្សេងក្រៅពីអាជ្ញាធរឡើយ។ ពួកគេមិនត្រូវអនុវត្តសកម្មភាពណាមួយដែល អាចនាំឱ្យប៉ះពាល់ដល់ឋានៈរបស់ខ្លួនក្នុងនាមជាមន្ត្រីអន្តរជាតិទទួលបន្ទុកតែចំពោះមុខអាជ្ញាធរ។ រដ្ឋភាគីនីមួយៗ យល់ព្រមគោរពចរិតលក្ខណៈជាអន្តរជាតិទាំងស្រុងនៃការទទួលខុសត្រូវរបស់អគ្គលេខាធិការ និងបុគ្គលិក ហើយនឹង មិនព្យាយាមជះឥទ្ធិពលទៅលើពួកគេ នៅក្នុងការបំពេញភារកិច្ចទទួលខុសត្រូវរបស់ពួកគេឡើយ។ រាល់ករណីបំពាន លើការទទួលខុសត្រូវណាមួយដោយបុគ្គលិក នឹងត្រូវបញ្ជូនទៅសាលាក្តីរដ្ឋបាលសមស្រប ដូចមានចែងនៅក្នុងវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

២. អគ្គលេខាធិការ និងបុគ្គលិកគ្មានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុនៅក្នុងសកម្មភាពណាមួយ ដែលទាក់ទង នឹងការរុករក និងការធ្វើអាជីវកម្មធនធាននៅក្នុងតំបន់នោះទេ។ ដោយផ្អែកលើការទទួលខុសត្រូវរបស់បុគ្គលិក ចំពោះអាជ្ញាធរ បុគ្គលិកមិនត្រូវលាតត្រដាងនូវការសម្ងាត់ផ្នែកឧស្សាហកម្ម ទិន្នន័យស្តីពីកម្មសិទ្ធិដែលត្រូវបានផ្ទេរទៅ ឱ្យអាជ្ញាធរតាមឧបសម្ព័ន្ធ ៣មាត្រា ១៤ ឬព័ត៌មានសម្ងាត់ផ្សេងៗទៀតដែលពួកគេបានដឹងតាមរយៈការបំពេញ ភារកិច្ចជូនអាជ្ញាធរឡើយ សូម្បីតែនៅក្រោយពេលដែលពួកគេឈប់ធ្វើការផងដែរ។

៣. រាល់ករណីបំពានលើកាតព្វកិច្ចរបស់បុគ្គលិកអាជ្ញាធរដែលមានចែងនៅក្នុងកថាខណ្ឌទី ២ នឹងត្រូវអាជ្ញាធរ បញ្ជូនពាក្យបណ្តឹងប្រឆាំងបុគ្គលិកដែលពាក់ព័ន្ធរូបនោះទៅកាន់សាលាក្តីដែលកំណត់ដោយវិធាន បទបញ្ញត្តិ និងនីតិវិធី របស់អាជ្ញាធរ តបតាមសំណើរបស់រដ្ឋភាគីដែលរងផលប៉ះពាល់ពីការបំពាននោះ

ឬសំណើរបស់រូបវន្តបុគ្គល ឬនីតិ បុគ្គលដែលគាំទ្រដោយរដ្ឋភាគីមួយ ដូចមានចែងនៅក្នុងមាត្រា ១៥៣ កថាខណ្ឌទី ២(ខ) ដែលរងផលប៉ះពាល់ពីការបំពាននោះ។ ភាគីដែលរងផលប៉ះពាល់ មានសិទ្ធិចូលរួមក្នុងដំណើរការជំនុំជម្រះបាន។ ប្រសិនបើសាលាក្តីផ្តល់អនុសាសន៍ អគ្គលេខាធិការត្រូវបណ្តេញបុគ្គលិកដែលពាក់ព័ន្ធរូបនោះចេញពីតំណែង។

៤. វិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ ក៏ត្រូវរួមមានទាំងបទបញ្ញត្តិដែលចាំបាច់សម្រាប់អនុវត្តមាត្រានេះផងដែរ។

*មាត្រា ១៦៩*

*ការពិគ្រោះយោបល់ និង កិច្ចសហប្រជាជាតិជាមួយ*

*អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល*

១. ដោយមានការអនុម័តពីក្រុមប្រឹក្សា អគ្គលេខាធិការត្រូវរៀបចំឱ្យបានសមស្របនូវការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ ស្តីពីបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរ ។

២. អង្គការដែលអគ្គលេខាធិការបានចុះកិច្ចព្រមព្រៀងជាមួយខ្លួនក្រោមកថាខណ្ឌទី ១ ខាងលើ អាចចាត់តាំងតំណាងទៅចូលរួមកិច្ចប្រជុំរបស់ស្ថាប័ននៃអាជ្ញាធរក្នុងនាមជាអ្នកសង្កេតការណ៍ ស្របតាមវិធាននៃនីតិវិធីរបស់ស្ថាប័ន ទាំងនេះ។ នីតិវិធីនឹងត្រូវបង្កើតឡើង ដើម្បីស្នើសុំទស្សនៈរបស់អង្គការនៅក្នុងករណីសមស្រប។

៣. អគ្គលេខាធិការអាចចែកចាយជូនបណ្តារដ្ឋភាគី នូវរបាយការណ៍ជាលាយលក្ខណ៍អក្សរដែលអង្គការក្រៅ រដ្ឋាភិបាលដូចមានចែងនៅក្នុងកថាខណ្ឌទី ១ បានដាក់ជូនស្តីពីកម្មវត្ថុដែលពួកគេមានសមត្ថភាពពិសេស និងដែលទាក់ ទងនឹងការងាររបស់អាជ្ញាធរ។

## ជំពូករងង៖ សហគ្រាស

*មាត្រា ១៧០*

*សហគ្រាស*

១. សហគ្រាសគឺជាស្ថាប័នរបស់អាជ្ញាធរដែលត្រូវអនុវត្តសកម្មភាពនៅក្នុងតំបន់ដោយផ្ទាល់ ស្របតាម មាត្រា ១៥៣ កថាខណ្ឌទី ២(ក) ព្រមទាំងបញ្ជូន កែច្នៃ និងធ្វើទីផ្សារសម្រាប់រ៉ែដែលទាញចេញពីតំបន់។

២. នៅក្នុងក្របខ័ណ្ឌនៃលក្ខណៈស្របច្បាប់អន្តរជាតិរបស់អាជ្ញាធរ សហគ្រាសក៏ត្រូវមានភាពជាតំណាង ស្របច្បាប់ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុនយ៉ាងច្បាស់លាស់ ស្របតាមឧបសម្ព័ន្ធ ៤ផងដែរ។ សហគ្រាស ត្រូវធ្វើសកម្មភាពស្របតាមអនុសញ្ញានេះ និងវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ ព្រមទាំងគោលនយោបាយ ទូទៅ ដែលត្រូវបានសន្និបាតបង្កើតឡើង និងត្រូវគោរពតាមសរាចរណ៍ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សា។

៣. សហគ្រាសមានទីស្នាក់ការអាជីវកម្មធំស្ថិតនៅទីស្នាក់ការរបស់អាជ្ញាធរ។

៤.

សហគ្រាសនឹងត្រូវផ្តល់ជូននូវមូលនិធិដែលសហគ្រាសអាចនឹងត្រូវការដើម្បីអនុវត្តមុខងាររបស់ខ្លួន ស្រប តាមមាត្រា ១៧៣ កថាខណ្ឌទី ២ និងឧបសម្ព័ន្ធ ៤មាត្រា ១១ ហើយនឹងទទួលបានបច្ចេកវិទ្យាដូចមានចែងនៅក្នុង មាត្រា ១៤៤ និងបញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងអនុសញ្ញានេះ។

## ជំពូករងច៖ ផែនការហិរញ្ញវត្ថុរបស់អាជ្ញាធរ

*មាត្រា ១៧១*

*មូលនិធិរបស់អាជ្ញាធរ*

ប្រភពនៃមូលនិធិរបស់អាជ្ញាធររួមមាន៖

(ក) ទឹកប្រាក់វិភាគទានដែលកំណត់ឱ្យសមាជិកអាជ្ញាធរត្រូវចូលរួមបង់តាមមាត្រា ១៦០ កថាខណ្ឌទី ២ (ង)។

(ខ) មូលនិធិដែលអាជ្ញាធរទទួលបានតាមឧបសម្ព័ន្ធ ៣មាត្រា ១៣ ពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់។

(គ) មូលនិធិដែលផ្ទេរមកពីសហគ្រាសស្របតាមឧបសម្ព័ន្ធ ៤មាត្រា ១០ ។

(ឃ) មូលនិធិកម្ចីតាមមាត្រា ១៧៤ ។

(ង) ទឹកប្រាក់វិភាគទានស្ម័គ្រចិត្តដែលបង់ដោយសមាជិក ឬអង្គភាពផ្សេងៗ។ និង

(ច) ទឹកប្រាក់បង់ចូលមូលនិធិសំណង ស្របតាមមាត្រា ១៥១ កថាខណ្ឌទី ១០ ដែលគណៈកម្មការរៀបចំ ផែនការសេដ្ឋកិច្ចនឹងផ្តល់អនុសាសន៍អំពីប្រភពទឹកប្រាក់នេះ។

*មាត្រា ១៧២*

*ថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរ*

អគ្គលេខាធិការត្រូវរៀបចំពង្រាងសំណើថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរ រួចដាក់ជូនក្រុមប្រឹក្សា។ ក្រុមប្រឹក្សា ត្រូវពិនិត្យពិចារណាលើសំណើថវិកាប្រចាំឆ្នាំ រួចដាក់ជូនសន្និបាត ដោយអមជាមួយនឹងអនុសាសន៍អំពីសំណើនេះ។ សន្និបាតត្រូវពិចារណា និងអនុម័តលើសំណើថវិកាប្រចាំឆ្នាំដោយអនុលោមតាមមាត្រា ១៦០ កថាខណ្ឌទី ២(ជ) ។

*មាត្រា ១៧៣*

*ការចំណាយរបស់អាជ្ញាធរ*

១. ទឹកប្រាក់វិភាគទានដែលមានចែងនៅក្នុងមាត្រា ១៧១ កថាខណ្ឌរង (ក) នឹងត្រូវបង់ចូលក្នុងគណនី ពិសេស សម្រាប់បំពេញការចំណាយផ្នែកហិរញ្ញវត្ថុរបស់អាជ្ញាធរ

រហូតដល់ពេលដែលអាជ្ញាធរមានមូលនិធិគ្រប់គ្រាន់ ពីប្រភពផ្សេងៗទៀតដើម្បីបំពេញការចំណាយទាំងនោះ។

២. ការចំណាយផ្នែករដ្ឋបាលរបស់អាជ្ញាធរ គឺជាអាទិភាពចម្បងសម្រាប់ការប្រើប្រាស់មូលនិធិរបស់អាជ្ញាធរ។ លើកលែងតែទឹកប្រាក់វិភាគទានដែលបានកំណត់ និងមានចែងនៅក្នុងមាត្រា ១៧១ កថាខណ្ឌរង (ក) ចេញ មូលនិធិដែលនៅសល់ក្រោយពីកាទូតាត់ការចំណាយផ្នែករដ្ឋបាល អាចនឹងត្រូវ ៖

(ក) បែងចែកស្របតាមមាត្រា ១៤០ និងមាត្រា ១៦០ កថាខណ្ឌទី ២(ឆ)។

(ខ) ប្រើប្រាស់ដើម្បីផ្តល់ឱ្យសហគ្រាសនូវមូលនិធិស្របតាមមាត្រា ១៧០ កថាខណ្ឌទី ៤ ។

(គ) ប្រើប្រាស់ដើម្បីផ្តល់សំណងជូនរដ្ឋកំពុងអភិវឌ្ឍន៍ស្របតាមមាត្រា ១៥១ កថាខណ្ឌទី ១០ និងមាត្រា ១៦០ កថាខណ្ឌទី ២ (ឋ) ។

*មាត្រា ១៧៤*

*អំណាចខ្ចីប្រាក់របស់អាជ្ញាធរ*

១. អាជ្ញាធរមានអំណាចក្នុងការខ្ចីប្រាក់។

២.

សន្និបាតត្រូវកំណត់កម្រិតលើអំណាចខ្ចីប្រាក់របស់អាជ្ញាធរនៅក្នុងបទបញ្ញត្តិស្តីពីហិរញ្ញវត្ថុ ដែលអនុម័ត ស្របតាមមាត្រា ១៦០ មាត្រា ២(ច) ។

៣. ក្រុមប្រឹក្សាត្រូវអនុវត្តអំណាចខ្ចីប្រាក់របស់អាជ្ញាធរ។

៤. រដ្ឋភាគីមិនទទួលខុសត្រូវលើបំណុលរបស់អាជ្ញាធរទេ។

*មាត្រា ១៧៥*

*សវនកម្មប្រចាំឆ្នាំ*

បញ្ជី សៀវភៅ និងគណនីរបស់អាជ្ញាធរ រាប់បញ្ចូលទាំងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នឹងត្រូវធ្វើសវនកម្ម ជារៀងរាល់ឆ្នាំដោយសវនករឯករាជ្យដែលទទួលបានការតែងតាំងដោយសន្និបាត។

ជំពូករងឆះ ស្ថានភាពគតិយុត្តិបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ

*មាត្រា ១៧៦*

*ស្ថានភាពគតិយុត្តិ*

អាជ្ញាធរត្រូវមានលក្ខណៈស្របច្បាប់ជាអន្តរជាតិ និងសមត្ថភាពស្របច្បាប់ដែលចាំបាច់ដើម្បីអនុវត្តមុខងារ របស់ខ្លួន និងសម្រេចនូវគោលបំណងរបស់ខ្លួន។

*មាត្រា ១៧៧*

*បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ*

ដើម្បីអាចឱ្យអាជ្ញាធរអនុវត្តនូវមុខងាររបស់ខ្លួនបាន អាជ្ញាធរត្រូវមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៅក្នុង ដែនដីនៃរដ្ឋភាគីនីមួយៗ ដែលមានចែងនៅក្នុងជំពូករងនេះ។ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលទាក់ទងនឹងសហគ្រាស គឺជាបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ៤ មាត្រា ១៣ ។

*មាត្រា ១៧៨*

*អភ័យឯកសិទ្ធិរួចផុតពីដំណើរការក្តី*

អាជ្ញាធរ អចលនទ្រព្យ និងទ្រព្យសកម្មរបស់ខ្លួន ត្រូវទទួលបាននូវអភ័យឯកសិទ្ធិរួចផុតពីដំណើរការក្តី លើកលែងតែអាជ្ញាធរបានបញ្ជាក់យ៉ាងច្បាស់ថាបោះបង់អភ័យឯកសិទ្ធិនេះក្នុងករណីពិសេសណាមួយ។

*មាត្រា ១៧៩*

*អភ័យឯកសិទ្ធិពីការឆែកឆេរ និងពីការរឹបអូសគ្រប់រូបភាព*

អចលនទ្រព្យ និងទ្រព្យសកម្មរបស់អាជ្ញាធរ មិនថាមានទីតាំងនៅកន្លែងណា ឬនរណាកាន់កាប់នោះទេ ត្រូវ ទទួលបានអភ័យឯកសិទ្ធិរួចផុតពីការឆែកឆេរ ការទាមទារ ការរឹបអូស អស្សាមិករណ៍ ឬការរឹបអូសក្នុងទម្រង់ណា មួយដោយសកម្មភាពផ្នែកនីតិប្រតិបត្តិ ឬនីតិបញ្ញត្តិឡើយ។

*មាត្រា ១៨០*

*ការលើកលែងពីការដាក់កម្រិត បទបញ្ញត្តិ ការគ្រប់គ្រង និងការបង្អាក់*

អចលនទ្រព្យ និងទ្រព្យសកម្មរបស់អាជ្ញាធរត្រូវលើកលែងឱ្យរួចផុតពីការដាក់កម្រិត បទបញ្ញត្តិ ការគ្រប់គ្រង និងការបង្អាក់ក្នុងទម្រង់នានា។

*មាត្រា ១៨១*

*បណ្ណាសារ និងការផ្សព្វផ្សាយជាផ្លូវការរបស់អាជ្ញាធរ*

១. បណ្ណាសាររបស់អាជ្ញាធរ មិនថាមានទីតាំងនៅកន្លែងណានោះទេ ត្រូវរួចផុតពីការបំពានទាំងអស់។

២. ទិន្នន័យជាកម្មសិទ្ធិ អាថ៌កំបាំងផ្នែកឧស្សាហកម្ម ឬព័ត៌មានស្រដៀងគ្នានេះ និងបញ្ជីបុគ្គលិកមិនត្រូវរក្សាទុកនៅក្នុងបណ្ណាសារ ដែលបើកឱ្យមានការចូលពិនិត្យជាសាធារណៈនោះឡើយ។

៣. ទាក់ទិននឹងការផ្សព្វផ្សាយផ្លូវការរបស់ខ្លួន អាជ្ញាធរត្រូវទទួលបានការព្រមព្រៀងពីរដ្ឋភាគីនីមួយៗមិនតិចជាងអ្វីដែលបានព្រមព្រៀងដោយរដ្ឋនោះចំពោះអង្គការអន្តរជាតិដទៃទៀតឡើយ។

*មាត្រា ១៨២*

*ឯកសិទ្ធិ និងអភ័យឯកសិទ្ធិរបស់បុគ្គលមួយ*

*ចំនួនដែលទាក់ទិនជាមួយនឹងអាជ្ញាធរ*

តំណាងរបស់រដ្ឋភាគីដែលអញ្ជើញទៅចូលរួមកិច្ចប្រជុំមហាសន្និបាត កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ឬស្ថាប័នរបស់ មហាសន្និបាត ឬស្ថាប័នរបស់ក្រុមប្រឹក្សា អគ្គលេខាធិការ និងបុគ្គលិករបស់អាជ្ញាធរ ដែលប្រារព្ធធ្វើនៅក្នុងបូរណភាព ដែនដីរបស់រដ្ឋភាគីត្រូវទទួលបាន ៖

(ក) អភ័យឯកសិទ្ធិពីដំណើរការក្តី ទាក់ទិនទៅនឹងសកម្មភាពដែលពួកគេអនុវត្តដើម្បីបំពេញមុខងាររបស់ពួកគេ លើកលែងតែក្នុងកម្រិតមួយដែលរដ្ឋពួកគេតំណាង ឬអាជ្ញាធរបានបញ្ជាក់យ៉ាងច្បាស់លាស់អំពីការបោះបង់អភ័យឯកសិទ្ធិនេះ ក្នុងករណីពិសេសណាមួយទៅតាមការសមស្រប។

(ខ) ប្រសិនបើពួកគេមិនមែនជាពលរដ្ឋរបស់រដ្ឋភាគីនោះ ពួកគេក៏ទទួលបានការលើកលែងឱ្យរួចផុតដូចគ្នា នេះពីការដាក់កម្រិតផ្នែកអន្តោប្រវេសន៍ លក្ខខណ្ឌតម្រូវស្តីពីការចុះបញ្ជីជនបរទេស និងកាតព្វកិច្ចផ្នែកសេវាកម្មជាតិ មូលដ្ឋានសម្ភារដូចគ្នាទាក់ទងនឹងការដាក់កម្រិតលើការដោះដូរ និងការប្រព្រឹត្តិដូចគ្នាទាក់ទងនឹងមូលដ្ឋានសម្ភារធ្វើ ដំណើរ ដូចដែលរដ្ឋភាគីនោះបានផ្តល់ទៅឱ្យចំពោះតំណាង មន្ត្រី និងនិយោជិតរបស់រដ្ឋភាគីផ្សេងៗទៀតដែលមានឋានៈប្រហាក់ប្រហែលគ្នា។

*មាត្រា ១៨៣*

*ការលើកលែងឱ្យរួចផុតពីអាករ និងពន្ធគយ*

១. នៅក្នុងវិសាលភាពនៃសកម្មភាពផ្លូវការរបស់ខ្លួន អាជ្ញាធរ ទ្រព្យសកម្ម និងអចលនទ្រព្យ ចំណូល និងប្រតិបត្តិការ និងកិច្ចការជំនួយរបស់ខ្លួន ដែលអនុញ្ញាតក្រោមអនុសញ្ញានេះ

ត្រូវលើកលែងឱ្យរួច ផុតពីរាល់ពន្ធគយទាំងអស់។ អាជ្ញាធរមិនត្រូវទាមទារការរួចពន្ធដែលមិនច្រើនជាងជាងថ្លៃសម្រាប់ សេវាកម្មដែលផ្តល់ជូននោះឡើយ។

២. នៅពេលទិញទំនិញ ឬសេវាកម្មមានតម្លៃខ្ពស់ដែលចាំបាច់ដល់សកម្មភាពជាផ្លូវការរបស់អាជ្ញាធរត្រូវធ្វើ ឡើងដោយ ឬជួសមុខឱ្យអាជ្ញាធរ ហើយនៅពេលតម្លៃទំនិញ ឬសេវាកម្មនោះមានរាប់បញ្ចូលនូវពន្ធ អាករ ឬពន្ធគយហើយនេះ ភាគរដ្ឋត្រូវចាត់វិធានការដែលស័ក្តិសម ក្នុងកម្រិតណាមួយដែលអាចអនុវត្ត បាន ដើម្បីផ្តល់ការលើកលែងឱ្យរួចអាករ ឬពន្ធគយនោះ ឬផ្តល់នូវសំណងដល់ពួកគេ។ ទំនិញដែលនាំ ចូល ឬទិញក្រោមការលើកលែងឱ្យរួចពន្ធដែលបានផ្តល់ជូនក្នុងមាត្រានេះ មិនត្រូវលក់ ឬបើមិនដូច្នេះទេ បញ្ចោញនៅក្នុងបូរណភាពដែនដីរបស់រដ្ឋភាគីដែលបានផ្តល់ជូននូវការលើកលែងនោះទេ លើកលែងក្រោមលក្ខខណ្ឌដែលរដ្ឋភាគីនោះបានព្រមព្រៀង។

៣. រដ្ឋភាគីមិនត្រូវដាក់បន្ទុកពន្ធណាមួយទៅលើ ឬទាក់ទិននឹងប្រាក់បៀវត្ស និងប្រាក់ឈ្នួល ឬទម្រង់ប្រាក់ ផ្សេងទៀតដែលអាជ្ញាធរទូទាត់ជូនអគ្គលេខាធិការ និងបុគ្គលិករបស់អាជ្ញាធរ ក៏ដូចជាជូនអ្នកជំនាញដែល អនុវត្តបេសកកម្មសម្រាប់អាជ្ញាធរ ដែលមិនមែនជាប្រជាជាតិរបស់ពួកគេ។

### ជំពូករងជ៖ ការផ្អាកការអនុវត្តសិទ្ធិ និងឯកសិទ្ធិរបស់សមាជិក

*មាត្រា ១៨៤*

*ការផ្អាកការអនុវត្តសិទ្ធិបោះឆ្នោត*

រដ្ឋភាគីដែលនៅជំពាក់មិនទាន់បានបង់ប្រាក់វិភាគទានហិរញ្ញវត្ថុរបស់ខ្លួនជូនដល់អាជ្ញាធរមិនត្រូវ មានសិទ្ធិបោះ ឆ្នោតទេ ប្រសិនបើចំនួនទឹកប្រាក់ដែលនៅជំពាក់នោះស្មើនឹង ឬលើសពីចំនួនទឹកប្រាក់វិភាគទានដែលខ្លួនត្រូវបង់ សម្រាប់រយៈពេលពេញពីរឆ្នាំមុន។ ទោះបីជាយ៉ាងណាក៏ដោយ មហាសន្និបាតអាចអនុញ្ញាតឱ្យសមាជិកនោះបោះឆ្នោតបាន ប្រសិនបើខ្លួនគិតថា

ការខកខានក្នុងការបង់វិភាគទាននោះគឺដោយសារតែស្ថានភាពដែលហួសពីការគ្រប់គ្រងរបស់សមាជិកនោះ។

*មាត្រា ១៨៥*

*ការផ្អាកការអនុវត្តសិទ្ធិ និងឯកសិទ្ធិសមាជិកភាព*

១. រដ្ឋភាគីដែលបានបំពានទាំងស្រុង និងម្តងហើយម្តងទៀតលើបទបញ្ញត្តិនៃផ្នែកនេះអាចត្រូវបានផ្អាកការ អនុវត្តសិទ្ធិ និងឯកសិទ្ធិសមាជិកភាពដោយមហាសន្និបាត តាមការណែនាំពីក្រុមប្រឹក្សា។

២. គ្មានសកម្មភាពណាមួយត្រូវបានអនុវត្តក្រោមកថាខណ្ឌទី ១ ឡើយ រហូតដល់សភាវិវាទបាតសមុទ្ររកឃើញថារដ្ឋភាគីបានបំពានទាំងស្រុង និងម្តងហើយម្តងទៀតលើបទបញ្ញត្តិនៃផ្នែកនេះ។

ជំពូកទី៥៖ ការដោះស្រាយវិវាទ និង យោបល់ទីប្រឹក្សា

*មាត្រា ១៨៦*

*សភាវិវាទបាតសមុទ្រនៃសាលាក្តីអន្តរជាតិផ្នែកច្បាប់សមុទ្រ*

ការបង្កើតសភាវិវាទបាតសមុទ្រ និងលក្ខណៈដែលសភានេះអនុវត្តយុត្តាធិការរបស់ខ្លួនត្រូវគ្រប់គ្រងដោយបទបញ្ញត្តិនៃជំពូកនេះនៃផ្នែកទី១៥និងឧបសម្ព័ន្ធ ៦។

*មាត្រា ១៨៧*

*យុត្តាធិការរបស់សភាវិវាទបាតសមុទ្រ*

សភាវិវាទបាតសមុទ្រត្រូវមានយុត្តាធិការក្រោមផ្នែកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធ ក្នុងករណីមាន វិវាទទាក់ទិននឹងសកម្មភាពនៅក្នុងតំបន់ដែលស្ថិតក្នុងប្រភេទដូចខាងក្រោម ៖

(ក) វិវាទរវាងរដ្ឋភាគី ទាក់ទិននឹងការបកស្រាយ ឬការអនុវត្តផ្នែកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធ។

(ខ) វិវាទរវាងរដ្ឋភាគី និងអាជ្ញាធរ ទាក់ទិននឹងៈ

(i) ទង្វើ ឬការធ្វេសប្រហែសរបស់អាជ្ញាធរ ឬរបស់រដ្ឋភាគី ដែលត្រូវបានចោទប្រកាន់ថា ជាការបំពានលើផ្នែកនេះ ឬឧបសម្ព័ន្ធដែលពាក់ព័ន្ធ ឬលើវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរដែលបានរៀបចំឡើងអនុលោមទៅតាមផ្នែកនេះ ឬឧបសម្ព័ន្ធនោះ ឬ

(ii) ទង្វើរបស់អាជ្ញាធរដែលត្រូវបានចោទប្រកាន់ថាលើសពីយុត្តាធិការ ឬជាការប្រើប្រាស់អំណាចមិនបានត្រឹមត្រូវ។

(គ) វិវាទរវាងភាគីនៃកិច្ចសន្យា ក្នុងនាមជារដ្ឋភាគី អាជ្ញាធរ ឬសហគ្រាស សហគ្រាសរដ្ឋ និងរូបវន្ត ឬ នីតិបុគ្គលដែលមានចែងក្នុងមាត្រា ១៥៣ កថខ័ណ្ឌ ២(ខ) ទាក់ទិននឹងៈ

(១) ការបកស្រាយ ឬការអនុវត្តកិច្ចសន្យា ឬផែនការការងារដែលពាក់ព័ន្ធ ឬ

(២) ទង្វើ ឬការធ្វេសប្រហែសរបស់ភាគីនៃកិច្ចសន្យាទាក់ទិននឹងសកម្មភាពក្នុងតំបន់ និងចំពោះ ភាគីផ្សេងទៀត ឬដែលប៉ះពាល់ដោយផ្ទាល់ទៅលើផលប្រយោជនស្របច្បាប់របស់ខ្លួន។

(ឃ) វិវាទរវាងអាជ្ញាធរ និងភាគីដែលអាចចុះហត្ថលេខាដែលទទួលការធានាពីរដ្ឋមួយដូចមានចែងក្នុង មាត្រា ១៥៣ កថាខណ្ឌទី ២(ខ) និងបានបំពេញយ៉ាងត្រឹមត្រូវនូវលក្ខខណ្ឌដែលមានចែងក្នុង ឧបសម្ព័ន្ធ ៣ មាត្រា ៤ កថាខណ្ឌទី ៦ និងមាត្រា ១៣ កថាខណ្ឌទី ២ ទាក់ទិនទៅនឹងការបដិសេធកិច្ច សន្យា ឬបញ្ហាផ្លូវច្បាប់ដែលកើតមានក្នុងពេលចរចាអំពីកិច្ចសន្យា។

(ង) វិវាទរវាងអាជ្ញាធរ និងរដ្ឋភាគី សហគ្រាសរដ្ឋ រូបវន្ត ឬនីតិបុគ្គលដែលធានាដោយរដ្ឋភាគីដូចមាន ចែងក្នុងមាត្រា ១៥៣ កថាខណ្ឌទី ២(ខ) ដែលទទួលការចោទប្រកាន់ថា អាជ្ញាធរបានបង្កើតនូវបន្ទុក ដូចមានចែងក្នុងឧបសម្ព័ន្ធ ៣ មាត្រា ២២ ។

(ច)

វិវាទផ្សេងទៀតក្រោមយុត្តាធិការរបស់សភាដូចមានចែងយ៉ាងច្បាស់លាស់ក្នុងអនុសញ្ញានេះ។

*មាត្រា ១៨៨*

*ការបញ្ជូនវិវាទទៅសភាពិសេសនៃសាលាក្តីអន្តរជាតិ*
*ផ្នែកច្បាប់សមុទ្រ ឬសភាពិសេសនៃសភាវិវាទបាតសមុទ្រ*
*ឬទៅផ្នែកមជ្ឈត្តកម្មពាណិជ្ជកម្មដែលមានសមត្ថកិច្ច*

១. វិវាទរវាងរដ្ឋភាគីដែលមានចែងក្នុងមាត្រា ១៨៧ កថាខណ្ឌរង (ក) អាចត្រូវបញ្ជូនៈ

(ក) ទៅសភាពិសេសនៃសាលាក្តីអន្តរជាតិផ្នែកច្បាប់សមុទ្រ ដែលត្រូវបង្កើតឡើងក្រោមឧបសម្ព័ន្ធ ៦ មាត្រា ១៥ និង ១៧ តាមសំណើរបស់ភាគីវិវាទ ឬ

(ខ) ទៅសភាពិសេសនៃសភាវិវាទបាតសមុទ្រដែលត្រូវបង្កើតឡើងក្រោមឧបសម្ព័ន្ធ ៦ មាត្រា ៣៦ តាមសំណើរបស់ភាគីវិវាទ។

២. (ក) វិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តកិច្ចសន្យាដែលមានចែងក្នុងមាត្រា ១៨៧ កថាខណ្ឌរង(គ)(១) ត្រូវបញ្ជូន ទៅតាមសំណើរបស់ភាគីវិវាទណាមួយ ទៅផ្នែកមជ្ឈត្តកម្មពាណិជ្ជកម្ម មានសមត្ថកិច្ច លើកលែងតែភាគីមានការព្រមព្រៀងគ្នាផ្សេងពីនេះ។ អង្គមជ្ឈត្តកម្មពាណិជ្ជកម្ម ដែលបានទទួលវិវាទមិនមានយុត្តាធិការ ក្នុងការសម្រេចអំពីរាល់បញ្ហានានាស្តីពីការបកស្រាយ អនុសញ្ញានេះទេ។ នៅពេលវិវាទមានទាក់ទងទៅនឹងបញ្ហាបកស្រាយ ផ្នែកទី ១១និង ឧបសម្ព័ន្ធដែលពាក់ព័ន្ធ ទាក់ទិននឹងសកម្មភាពនៅក្នុងតំបន់ បញ្ហានោះត្រូវបញ្ជូនទៅអង្គជំនុំ ជំរះវិវាទបាតសមុទ្រដើម្បីសម្រេច។

(ខ) នៅពេលចាប់ផ្តើម ឬក្នុងពេលដំណើរការមជ្ឈត្តកម្ម ប្រសិនបើអង្គមជ្ឈត្តកម្មកំណត់ទៅតាម សំណើរបស់ភាគីវិវាទណាមួយ ឬកំណត់ដោយខ្លួនឯងថា សេចក្តីសម្រេចរបស់ខ្លួនគឺអាស្រ័យទៅតាមសេចក្តីសម្រេចរបស់សភាវិវាទបាតសមុទ្រ នោះអង្គមជ្ឈត្តកម្មត្រូវបញ្ជូនបញ្ហា

នោះទៅសភាវិវាទបាតសមុទ្រដើម្បីសម្រេច។ បន្ទាប់មក អង្គមជ្ឈត្តកម្មត្រូវដំណើរការដើម្បីផ្តល់សេចក្តីសម្រេចស្របទៅតាមសេចក្តីសម្រេចរបស់សភាវិវាទបាតសមុទ្រ។

(គ) ក្នុងករណីកិច្ចសន្យាពុំមានបទបញ្ញត្តិណាមួយចែងអំពីនីតិវិធីមជ្ឈត្តកម្ម ដែលត្រូវអនុវត្តក្នុងការដោះស្រាយវិវាទនោះ ដំណើរការមជ្ឈត្តកម្មត្រូវអនុវត្តដោយអនុលោមទៅតាមវិធានមជ្ឈត្តកម្ម UNCITRALឬវិធានមជ្ឈត្តកម្មផ្សេងទៀតដែលអាចមានចែងក្នុងវិធាន បទបញ្ញត្តិ និងនីតិ វិធីរបស់អាជ្ញាធរ លើកលែងតែភាគីវិវាទព្រមព្រៀងផ្សេងពីនេះ។

*មាត្រា ១៨៩*

*ការកំណត់យុត្តាធិការទាក់ទងនឹងសេចក្តីសម្រេចរបស់អាជ្ញាធរ*

សភាវិវាទបាតសមុទ្រមិនមានយុត្តាធិការលើការអនុវត្តរបស់អាជ្ញាធរនូវអំណាចសម្រេចរបស់ខ្លួន អនុលោម ទៅតាមផ្នែកនេះ។ ទោះក្នុងករណីណាក៏ដោយ សភាវិវាទបាតសមុទ្រមិនត្រូវប្រើសេចក្តីសម្រេចរបស់ខ្លួនជំនួស ឱ្យសេចក្តីសម្រេចរបស់អាជ្ញាធរឡើយ។ ដោយមិនប៉ះពាល់ដល់មាត្រា ១៩១ ក្នុងការអនុវត្តរដ្ឋជាប់ឆ្នេររបស់ខ្លួន អនុលោមទៅតាមមាត្រា ១៨៧ សភាវិវាទបាតសមុទ្រមិនត្រូវប្រកាសខ្លួនឯងអំពីបញ្ហានោះ ថាតើវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរមានលក្ខណៈស្របទៅតាមអនុសញ្ញានេះឬមិនស្របនោះទេ ហើយក៏មិនត្រូវប្រកាសថាវិធាន បទបញ្ញត្តិ និងនីតិវិធីទាំងនេះមានទុព្វលភាពឬអត់ឡើយ។ រដ្ឋជាប់ឆ្នេររបស់សភាវិវាទបាតសមុទ្រក្នុងបញ្ហានេះ គឺមានត្រឹមតែអាចសម្រេចប្រកាសថាតើការអនុវត្តវិធាន បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរក្នុងករណីមួយៗផ្ទុយទៅនឹងកាតព្វកិច្ចជាប់កិច្ចសន្យារបស់ភាគីវិវាទ ឬកាតពព្វកិច្ចរបស់ពួកគេក្រោម អនុសញ្ញានេះ

ការប្រកាសទាក់ទិននឹងការប្រើប្រាស់អំណាចលើសពីរដ្ឋជាប់ឆ្នោរ ឬការប្រើប្រាស់អំណាចមិនត្រឹមត្រូវ និងប្រកាសអំពីសំណងដែលត្រូវទូទាត់

ឬដំណោះស្រាយផ្សេងទៀតដែលត្រូវផ្តល់ជូនភាគីពាក់ព័ន្ធសម្រាប់ការខកខាន

របស់ភាគីម្ខាងទៀតក្នុងការគោរពអនុវត្តតាមកាតព្វកិច្ចក្នុងកិច្ចសន្យា

ឬកាតព្វកិច្ចរបស់ខ្លួនក្រោមអនុញ្ញានេះ ប៉ុណ្ណោះ។

*មាត្រា ១៩០*

*ការចូលរួម និងការចូលខ្លួន*

*របស់បណ្តារដ្ឋភាគីផ្តល់ការធានានៅក្នុងដំណើរការក្តី*

១. ប្រសិនបើរូបវន្ត ឬនីតិបុគ្គលគឺជាភាគីវិវាទដែលមានចែងក្នុងមាត្រា ១៨៧ រដ្ឋដែលធានាត្រូវទទួលបាន ការជូនដំណឹងអំពីបញ្ហានេះ និងត្រូវមានសិទ្ធិចូលរួមក្នុងដំណើរការក្តី តាមរយៈការដាក់ជូននូវសេចក្តីអះអាងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។

២. ប្រសិនបើបណ្តឹងត្រូវបានធ្វើឡើងចំពោះរដ្ឋភាគីដោយរូបវន្ត ឬនីតិបុគ្គលដែលធានាដោយរដ្ឋភាគីផ្សេង មួយទៀត នៅក្នុងវិវាទដែលមានចែងក្នុងមាត្រា ១៨៧ កថាខណ្ឌ (គ) នោះរដ្ឋចុងបណ្តឹងអាចស្នើឱ្យរដ្ឋដែលធានាបុគ្គលនោះចូលខ្លួនដោះស្រាយនៅក្នុងដំណើរការក្តីជួសមុខឱ្យបុគ្គលនោះ។ ក្នុងករណីមានការខកខានក្នុងការចូលខ្លួន នោះរដ្ឋចុងបណ្តឹងអាចរៀបចំឱ្យមាននីតិបុគ្គលណាមួយដែលមានសញ្ជាតិខ្លួនធ្វើជាតំណាងរបស់ខ្លួនក្នុងដំណើរការក្តីបាន។

*មាត្រា ១៩១*

*មតិណែនាំ*

សភាវិវាទបាតសមុទ្រត្រូវផ្តល់មតិណែនាំទៅតាមការស្នើរបស់មហាសន្និបាត ឬក្រុមប្រឹក្សាស្តីពីបញ្ហាច្បាប់ដែលកើតឡើងនៅក្នុងដែនសកម្មភាពរបស់ពួកគេ។ មតិណែនាំនេះត្រូវផ្តល់ជូនជាលក្ខណៈបន្ទាន់។

## ផ្នែកទី១២៖ការការពារ និង ការថែរក្សាបរិស្ថានសមុទ្រ

## ជំពូកទី១៖ បទបញ្ញត្តិរួម

*មាត្រា ១៩២*

*កាតព្វកិច្ចទូទៅ*

រដ្ឋមានកាតព្វកិច្ចការពារ និងថែរក្សាបរិស្ថានសមុទ្រ។

*មាត្រា ១៩៣*

*សិទ្ធិអធិបតេយ្យភាពរបស់បណ្តារដ្ឋក្នុងការប្រើប្រាស់ធនធានធម្មជាតិរបស់ខ្លួន*

រដ្ឋមានសិទ្ធិអធិបតេយ្យភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិរបស់ខ្លួន ដោយអនុលោមទៅតាមគោល នយោបាយស្តីពីបរិស្ថានរបស់ខ្លួន និងអនុលោមទៅតាមកាតព្វកិច្ចរបស់ពួកគេក្នុងការការពារ និងអភិរក្សបរិស្ថានសមុទ្រ។

*មាត្រា ១៩៤*

*វិធានការបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ*

១. បណ្តារដ្ឋមួយៗ ឬរួមគ្នាតាមដែលសមស្រប ត្រូវចាត់វិធានការគ្រប់យ៉ាងដែលចាំបាច់ស្របតាមអនុសញ្ញា នេះ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីប្រភពនានា ដោយប្រើប្រាស់នូវរាល់មធ្យោបាយ ដែលល្អបំផុតសម្រាប់គោលបំណងនេះ តាមការសម្រេច និងសមត្ថភាពរបស់ខ្លួន ហើយពួកគេត្រូវប្រឹងប្រែង កែសម្រួលគោលនយោបាយរបស់ពួកគេឱ្យមានលក្ខណៈស្របគ្នាទាក់ទិននឹងបញ្ហានេះ។

២. បណ្តារដ្ឋត្រូវចាត់គ្រប់វិធានការទាំងអស់ដែលចាំបាច់ ដើម្បីធានាថារាល់សកម្មភាពក្រោមរដ្ឋជាប់ឆ្នេរ ឬ ការគ្រប់គ្រងរបស់ពួកគេអាចអនុវត្តទៅដោយមិនមានបណ្តាលឱ្យមានការខូចខាត ដោយសារការបំពុលរដ្ឋដទៃ និងបរិស្ថានរបស់ពួកគេ ព្រមទាំងថា ការបំពុលដែលកើតមានដោយសារឧប្បត្តិហេតុ ឬសកម្មភាពនានាក្រោមរដ្ឋជាប់ឆ្នេរ ឬការគ្រប់គ្រងរបស់ពួកគេមិនរាលដាលសាយភាយហួសពីតំបន់ ដែលពួកគេអនុវត្តសិទ្ធិអធិបតេយ្យនៅក្រោមអនុសញ្ញានេះទេ។

៣.

វិធានការដែលអនុវត្តក្រោមផ្នែកនេះត្រូវអនុវត្តលើរាល់ប្រភពទាំងអស់នៃការបំពុលបរិស្ថានសមុទ្រ។ វិធានការទាំងនេះរួមមានជាអាទិ៍ រាល់វិធានការទាំងឡាយដែលរៀបចំឡើងដើម្បីកាត់បន្ថយនូវទំហំដែលអាចកើតមាននៃៈ

(ក) ការសាយភាយសារធាតុមានជាតិពុល ជាតិពិស ឬគ្រោះថ្នាក់ ជាពិសេសសារធាតុទាំងឡាយណា ដែលមានប្រភពនៅនឹងដី ពី ឬ តាមរយៈបរិស្ថាន ឬតាមរយៈការចាក់ចោល ហើយស្ថិតនៅជាប់មិនបាត់។

(ខ) ការបំពុលពីនាវា ជាពិសេសវិធានការបង្ការគ្រោះថ្នាក់ និងដោះស្រាយចំពោះស្ថានភាពបន្ទាន់ ដែលធានាបាននូវសុវត្ថិភាពប្រតិបត្តិការក្នុងសមុទ្រ បង្ការការបញ្ចេញចោលនូវកាកសំណល់ ដោយចេតនា និងដោយអចេតនា ព្រមទាំងធ្វើនិយ័តកម្មលើរាល់ការទ្រង់ទ្រាយ ការសាងសង់ បរិក្ខារ ប្រតិបត្តិការ និងការគ្រប់គ្រងនាវា។

(គ) ការបំពុលពីបបនកណ្ឌ និងឧបករណ៍ដែលប្រើប្រាស់នៅក្នុងការរុករក និងធ្វើអាជីវកម្មធនធាន ធម្មជាតិនៅក្នុងបរិស្ថានសមុទ្រ ជាពិសេសវិធានការបង្ការគ្រោះថ្នាក់ និងដោះស្រាយចំពោះ ស្ថានភាពបន្ទាន់ ដែលធានាបាននូវសុវត្ថិភាពប្រតិបត្តិការក្នុងសមុទ្រ ព្រមទាំងធ្វើនិយ័តកម្មលើ

រាល់ការទូទាត់ការសាងសង់ បរិក្ខារ ប្រតិបត្តិការ និងការគ្រប់គ្រងបបនភណ្ឌ ឬ ឧបករណ៍ទាំងនោះ។

(ឃ) ការបំពុលពីបបនភណ្ឌ និងឧបករណ៍ផ្សេងទៀតដែលប្រតិបត្តិការក្នុងបរិស្ថានសមុទ្រ ជាពិសេស វិធានការបង្ការគ្រោះថ្នាក់ និងដោះស្រាយចំពោះស្ថានភាពបន្ទាន់ ដែលធានាបាននូវសុវត្ថិភាព ប្រតិបត្តិការក្នុងសមុទ្រ ដែលធានាបាននូវសុវត្ថិភាពប្រតិបត្តិការក្នុងសមុទ្រ ព្រមទាំងធ្វើនិយ័តកម្មលើរាល់ការទូទាត់ ការសាងសង់ បរិក្ខារ ប្រតិបត្តិការ និងការគ្រប់គ្រងបបនភណ្ឌ ឬ ឧបករណ៍ទាំងនោះ។

៤. ក្នុងការអនុវត្តវិធានការបង្ការ កាត់បន្ថយ ឬគ្រប់គ្រងការបំពុលបរិស្ថានសមុទ្របណ្តារដ្ឋត្រូវជៀសវាងពីការជ្រៀតជ្រែកដោយមិនសមហេតុផលក្នុងសកម្មភាពដែលបណ្តារដ្ឋផ្សេងទៀតអនុវត្តស្របទៅតាមសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ អនុលោមទៅតាមអនុសញ្ញានេះ។

៥.

វិធានការដែលអនុវត្តក្រោមផ្នែកនេះត្រូវរាប់បញ្ចូលទាំងវិធានការដែលចាំបាច់ក្នុងការការពារ និងថែរក្សាប្រព័ន្ធអេកូសាស្ត្រកម្រៗ ឬងាយខូចខាត ក៏ដូចជាជម្រកពូជសត្វជិតផុតពូជ រងការគំរាមកំហែង ឬស្ថិតក្នុងគ្រោះថ្នាក់ និងទម្រង់ផ្សេងទៀតនៃជីវិតក្នុងសមុទ្រ។

*មាត្រា ១៩៥*

*កាតព្វកិច្ចមិនផ្ទេរការខូចខាត ឬគ្រោះថ្នាក់*
*ឬបំលែងការបំពុលពីប្រភេទមួយទៅជាប្រភេទផ្សេងមួយទៀត*

ក្នុងការអនុវត្តវិធានការបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ បណ្តារដ្ឋត្រូវអនុវត្តយ៉ាងណា កុំឱ្យមានការផ្ទេរដោយផ្ទាល់ ឬដោយប្រយោល នូវការខូចខាត

ឬគ្រោះថ្នាក់ពីតំបន់មួយទៅតំបន់មួយផ្សេងទៀត ឬ បំលែងការបំពុលពីប្រភេទមួយទៅជាប្រភេទមួយផ្សេងទៀត។

*មាត្រា ១៩៦*

*ការប្រើប្រាស់បច្ចេកវិទ្យា ឬការដាក់បញ្ចូលនូវពូជប្លែក ឬថ្មី*

១. បណ្តារដ្ឋត្រូវអនុវត្តរាល់វិធានការដែលចាំបាច់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថាន សមុទ្រ ដោយសារការប្រើប្រាស់បច្ចេកវិទ្យា ក្រោមរដ្ឋជាប់ឆ្មេរ ឬការគ្រប់គ្រងរបស់ខ្លួន ឬដោយសារការ ដាក់បញ្ចូលដោយចេតនា ឬដោយចៃដន្យនូវពូជប្លែក ឬថ្មី ទៅក្នុងផ្នែកជាក់លាក់មួយនៃបរិស្ថានសមុទ្រ ដែលអាចបង្កឱ្យមានការផ្លាស់ប្តូរសំខាន់ៗ និងមានគ្រោះថ្នាក់។

២. មាត្រានេះមិនមានអនុភាពលើការអនុវត្តអនុសញ្ញានេះ ទាក់ទិននឹងការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ។

## ជំពូកទី២៖ កិច្ចសហប្រតិបត្តិជាសកល និងក្នុងតំបន់

*មាត្រា ១៩៧*

*កិច្ចសហប្រតិបត្តិការជាសកល ឬក្នុងតំបន់*

បណ្តារដ្ឋត្រូវសហប្រតិបត្តិការជាសកល និងប្រសិនបើសមស្រប ក្នុងតំបន់ ដោយផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ដើម្បីរៀបចំ និងពិចារណាអំពីវិធានអន្តរជាតិ បទដ្ឋាន ព្រមទាំងនិយាម និងនីតិវិធីដែលបាន ណែនាំ ស្របតាមអនុសញ្ញានេះ សម្រាប់ការពារ និងថែរក្សាបរិស្ថានសមុទ្រ ដោយពិចារណាទៅលើលក្ខណៈពិសេស របស់តំបន់មួយៗ។

*មាត្រា ១៩៨*

*ការជូនដំណឹងអំពីការខូចខាតជាក់ស្តែង និងការខូចខាតដែលនឹងកើតមាន*

នៅពេលរដ្ឋមួយបានជ្រាបអំពីករណីបរិស្ថានសមុទ្រកំពុងស្ថិតគ្រោះថ្នាក់អាចមានការខូចខាតនាពេលខាងមុខ ឬ បានខូចខាតរួចមកហើយ ដោយសារការបំពុល នោះខ្លួនត្រូវជូនដំណឹងភ្លាមៗដល់រដ្ឋផ្សេងទៀតដែលខ្លួនគិតថាអាចនឹង ទទួលរងនូវការខូចខាតនោះ ក៏ដូចជាដល់អង្គការអន្តរជាតិមានសមត្ថកិច្ចផងដែរ។

*មាត្រា ១៩៩*

*ផែនការយថាភាពទប់ស្កាត់ការបំពុល*

ក្នុងករណីដូចមានក្នុងមាត្រា ១៩៨ អនុលោមទៅតាមសមត្ថភាពរបស់ខ្លួន បណ្តារដ្ឋក្នុងតំបន់រងគ្រោះ និងអង្គការអន្តរជាតិមានសមត្ថកិច្ចត្រូវសហការគ្នាក្នុងកម្រិតមួយដែលអាចធ្វើទៅបាន ដើម្បីលុបបំបាត់នូវផលប៉ះពាល់ពីការបំពុល និងបង្ការ ឬកាត់បន្ថយការខូចខាតឱ្យនៅតិចតួចបំផុត។ ទាក់ទិននឹងចំណុចនេះ បណ្តារដ្ឋត្រូវរួមគ្នារៀបចំ និងផ្សព្វផ្សាយនូវផែនការយថាភាពសម្រាប់ឆ្លើយតបទៅនឹងឧប្បត្តិហេតុបំពុលក្នុងបរិស្ថានសមុទ្រ។

*មាត្រា ២០០*

*ការសិក្សា កម្មវិធីស្រាវជ្រាវ និងការចែករំលែកព័ត៌មាន និងទិន្នន័យ*

បណ្តារដ្ឋត្រូវសហការគ្នា ដោយផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ដើម្បីផ្សព្វផ្សាយ អនុវត្ត កម្មវិធីស្រាវជ្រាវវិទ្យាសាស្ត្រ និងលើកទឹកចិត្តដល់ការចែករំលែកព័ត៌មាន និងទិន្នន័យដែលទទួលបានស្តីពីការបំពុល បរិស្ថានសមុទ្រ។ បណ្តារដ្ឋទាំងនោះត្រូវប្រឹងប្រែងចូលរួមយ៉ាងសកម្មក្នុងកម្មវិធីតំបន់ និងជាសកល ដើម្បីទទួលបានចំណេះដឹងសម្រាប់ការវាយតម្លៃអំពីធម្មជាតិ និងទំហំនៃការបំពុល ការប្រឈមចំពោះវា និងច្រកផ្លូវគ្រោះថ្នាក់ និងការដោះស្រាយរបស់វា។

*មាត្រា ២០១*

*លក្ខណៈវិនិច្ឆ័យផ្អែកវិទ្យាសាស្ត្រសម្រាប់និយ័តកម្ម*

ទាក់ទិននឹងព័ត៌មាន និងទិន្នន័យដែលទទួលបានក្រោមមាត្រា ២០០ បណ្តារដ្ឋត្រូវសហការដោយផ្ទាល់ ឬ តាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច

ដើម្បីរៀបចំបង្កើតនូវលក្ខណៈវិនិច្ឆ័យផ្នែកវិទ្យាសាស្ត្រសម្រាប់ការតាក់តែង និងពិនិត្យអំពីវិធាន បទដ្ឋាន និងនិយាម និងនីតិវិធីដែលបានណែនាំសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ។

ជំពូកទី៣៖ ជំនួយបច្ចេកទេស

*មាត្រា ២០២*

*ការផ្តល់ជំនួយវិទ្យាសាស្ត្រ និងបច្ចេកទេសដល់បណ្តារដ្ឋកំពុងអភិវឌ្ឍន៍*

ដោយផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច បណ្តារដ្ឋត្រូវៈ

(ក) លើកកំពស់កម្មវិធីផ្តល់ជំនួយវិទ្យាសាស្ត្រ អប់រំ បច្ចេកទេស និងជំនួយផ្សេងទៀតដល់រដ្ឋកំពុងអភិវឌ្ឍន៍ សម្រាប់ការពារ និងថែរក្សាបរិស្ថានសមុទ្រ និងបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលសមុទ្រ។ ជំនួយទាំងនេះរួមមានជាអាទិ៍៖

(១) ការបណ្តុះបណ្តាលបុគ្គលិកផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស។

(២) ការសម្រួលដល់ការចូលរួមរបស់ពួកគេក្នុងកម្មវិធីអន្តរជាតិពាក់ព័ន្ធ។

(៣) ការផ្តល់ជូនពួកគេនូវបរិក្ខារ និងសម្ភារចាំបាច់នានា។

(៤) ការបង្កើតសមត្ថភាពរបស់ពួកគេក្នុងការផលិតបរិក្ខារទាំងនោះ។

(៥) ដំបូន្មានស្តីពី និងការបង្កើតសម្ភារសម្រាប់កម្មវិធីស្រាវជ្រាវ តាមដាន អប់រំ និងកម្មវិធីផ្សេងទៀត។

(ខ) ផ្តល់នូវជំនួយសមស្រប ជាពិសេសដល់រដ្ឋកំពុងអភិវឌ្ឍន៍ ដើម្បីកាត់បន្ថយឱ្យនៅសល់តិចតួចបំផុតនូវ ផលប៉ះពាល់ពីឧប្បត្តិហេតុធំៗដែលអាចបង្កនូវការបំពុលធ្ងន់ធ្ងរដល់បរិស្ថានសមុទ្រ។

*មាត្រា ២០៣*

*ការផ្តល់លក្ខខណ្ឌអនុគ្រោះសម្រាប់បណ្តារដ្ឋកំពុងអភិវឌ្ឍន៍*

ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ឬកាត់បន្ថយផលប៉ះពាល់របស់វាឱ្យនៅតិចតួចបំផុត អង្គការអន្តរជាតិត្រូវផ្តល់ជូនបណ្តារដ្ឋកំពុងអភិវឌ្ឍន៍នូវលក្ខខណ្ឌអនុគ្រោះក្នុង ៖

(ក) ការបែងចែកមូលនិធិ និងជំនួយបច្ចេកទេសឱ្យបានសមស្រប និង

(ខ) ការប្រើប្រាស់សេវាកម្មឯកទេសរបស់ពួកគេ។

ជំពូកទី៤៖ ការតាមដាន និងការវាយតម្លៃបរិស្ថាន

*មាត្រា ២០៤*

*ការតាមដានហានិភ័យ ឬផលប៉ះពាល់ពីការបំពុល*

១. ដោយមិនប៉ះពាល់ដល់សិទ្ធិរបស់បណ្តារដ្ឋផ្សេងទៀត បណ្តារដ្ឋត្រូវខិតខំឱ្យអស់ពីសមត្ថភាពដោយផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ចក្នុងការសង្កេត វាស់វែង វាយតម្លៃ និងវិភាគ តាមវិធីសាស្ត្រវិទ្យាសាស្ត្រដែលមានការទទួលស្គាល់អំពីហានិភ័យ ឬផលប៉ះពាល់ពីការបំពុលបរិស្ថានសមុទ្រ។

២. ជាពិសេស បណ្តារដ្ឋរក្សាឃ្លាំមើលផលប៉ះពាល់ពីរាល់សកម្មភាពដែលពួកគេបានអនុញ្ញាត ឬដែលពួកគេ ចូលរួម ដើម្បីកំណត់ថាតើសកម្មភាពទាំងនេះអាចបំពុលបរិស្ថានសមុទ្រដែរឬទេ។

*មាត្រា ២០៥*

*ការបោះពុម្ពផ្សាយរបាយការណ៍*

បណ្តារដ្ឋត្រូវបោះពុម្ពផ្សាយរបាយការណ៍ស្តីពីលទ្ធផលដែលទទួលបានក្រោមមាត្រា ២០៤ ឬផ្តល់របាយការណ៍

នោះដល់អង្គការអន្តរជាតិមានសមត្ថកិច្ចដែលអាចផ្សព្វផ្សាយរបាយការណ៍ទាំងនោះដល់បណ្តារដ្ឋទាំងអស់ យ៉ាងទៀង ទាត់តាមចិរវេលាសមស្របមួយ។

*មាត្រា ២០៦*

*ការវាយតម្លៃអំពីផលប៉ះពាល់ប្រកបដោយសក្តានុពលរបស់សកម្មភាព*

នៅពេលបណ្តារដ្ឋមានហេតុផលសមស្របក្នុងការជឿថា សកម្មភាពដែលគ្រោងទុកក្រោមយុត្តាធិការ ឬការគ្រប់គ្រងរបស់ខ្លួនអាចបង្កឱ្យមានការបំពុលធ្ងន់ធ្ងរ ឬការផ្លាស់ប្តូរសំខាន់ៗ និងមានគ្រោះថ្នាក់ដល់បរិស្ថានសមុទ្រ នោះតាមដែលអាចធ្វើទៅបាន ពួកគេត្រូវធ្វើការវាយតម្លៃអំពីផលប៉ះពាល់ប្រកបដោយសក្តានុពលភាពរបស់សកម្មភាពទៅលើបរិស្ថានសមុទ្រ ព្រមទាំងត្រូវផ្សព្វផ្សាយរបាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃនោះតាមលក្ខណៈដូចមានចែងក្នុងមាត្រា ២០៥។

ជំពូកទី៥៖ វិធានអន្តរជាតិ និង នីតិកម្មជាតិដើម្បីបង្ការ

*មាត្រា ២០៧*

*ការបំពុលពីប្រភពនៅលើដី*

១. បណ្តារដ្ឋត្រូវរៀបចំច្បាប់ និងបទបញ្ញត្តិដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ពីប្រភពនៅលើដី ដោយរាប់បញ្ចូលទាំងទន្លេ ដៃសមុទ្រ បំពង់ និងសំណង់បង្ហូរទឹកសំអុយ ដោយផ្អែកទៅតាមវិធាន បទដ្ឋាន ព្រមទាំងនិយាម និងនីតិវិធីដែលបានព្រមព្រៀងជាអន្តរជាតិ។

២. បណ្តារដ្ឋត្រូវចាត់វិធានការផ្សេងទៀតតាមដែលចាំបាច់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលទាំងនោះ។

៣. 

បណ្តារដ្ឋត្រូវប្រឹងប្រែងសម្រួលគោលនយោបាយរបស់ខ្លួនឱ្យមានលក្ខណៈស្របគ្នាទាក់ទិននឹងបញ្ហានេះ នៅថ្នាក់តំបន់។

៤. ជាពិសេសតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូត បណ្តារដ្ឋត្រូវប្រឹងប្រែងរៀបចំ នូវវិធាន បទដ្ឋាន ព្រមទាំងនិយាម និងនីតិវិធីក្រោមការណែនាំជាសកល និងក្នុងតំបន់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីប្រភពនៅលើដីដោយផ្អែកទៅតាមលក្ខណៈពិសេសរបស់តំបន់ សមត្ថភាព សេដ្ឋកិច្ចរបស់រដ្ឋកំពុងអភិវឌ្ឍន៍ និងតំរូវការរបស់ពួកគេនូវការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច។ វិធាន បទដ្ឋាន ព្រមទាំង និយាម និងនីតិវិធីទាំងនេះនឹងត្រូវបានពិនិត្យឡើងវិញជាបន្តបន្ទាប់ទៅតាមការចាំបាច់។

៥. ច្បាប់ បទបញ្ញត្តិ វិធានការ វិធាន បទដ្ឋាន ព្រមទាំងនិយាម និងនីតិវិធីក្រោមការណែនាំដូចមានចែង ក្នុងកថាខណ្ឌទី ១,២ និង ៤ ត្រូវមានបញ្ចូលនូវផ្នែកដែលរៀបចំឡើងដើម្បីកាត់បន្ថយឱ្យនៅសល់តិចតួចបំផុតតាមដែលអាចធ្វើបាននូវរាល់ការសាយភាយនូវសារធាតុដែលមានជាតិពុល គ្រោះថ្នាក់ ឬជាតិពិសជាពិសេសប្រភេទដែល មានឥទ្ធិពលយូរអង្វែង ទៅក្នុងបរិស្ថានសមុទ្រ។

*មាត្រា ២០៨*

*ការបំពុលពីសកម្មភាពនៅបាតសមុទ្រក្រោមយុត្តាធិការជាតិ*

១. បណ្តារដ្ឋជាប់ឆ្នេរត្រូវរៀបចំច្បាប់ និងបទបញ្ញត្តិ ដើម្បីការពារ កាត់បន្ថយ និងគ្រប់គ្រងការបំពុល បរិស្ថានសមុទ្រ ដោយសារ ឬទាក់ទិននឹងសកម្មភាពនៅបាតសមុទ្រក្រោមរដ្ឋជាប់ឆ្នេររបស់ខ្លួន និងពីកោះសប្បនិម្មិត ឋបនភណ្ឌ និងសំណង់ក្រោមរដ្ឋជាប់ឆ្នេររបស់ខ្លួន អនុលោមតាមមាត្រា ៦០ និង ៨០។

២. បណ្តារដ្ឋត្រូវចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុល ទាំងនោះ។

៣.	ច្បាប់ បទបញ្ញត្តិ និងវិធានការត្រូវមានអនុភាពស្មើនឹងវិធាន បទដ្ឋានអន្តរជាតិ ព្រមទាំងនិយាម និង នីតិវិធីក្រោមការណែនាំ។

៤.	បណ្តារដ្ឋត្រូវប្រឹងប្រែងកែសម្រួលគោលនយោបាយរបស់ខ្លួនឱ្យមានលក្ខណៈស្របគ្នា ទាក់ទិននឹងបញ្ហា នេះ នៅថ្នាក់តំបន់។

៥.	ជាពិសេសតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូត បណ្តារដ្ឋត្រូវរៀបចំនូវវិធាន បទដ្ឋានអន្តរជាតិ ព្រមទាំងនិយាម និងនីតិវិធីតាមការណែនាំជាសកល និងក្នុងតំបន់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ដែលមានចែងក្នុងកថាខណ្ឌទី ១។ វិធាន បទដ្ឋាន ព្រមទាំងគោលនយោបាយ និងនីតិវិធីតាមការណែនាំទាំងនេះ នឹងត្រូវបានពិនិត្យឡើងវិញជាបន្តបន្ទាប់ទៅតាមការចាំបាច់។

*មាត្រា ២០៩*

*ការបំពុលពីសកម្មភាពក្នុងតំបន់*

១.	វិធាន បទបញ្ញត្តិ និងនីតិវិធីអន្តរជាតិត្រូវបានរៀបចំបង្កើតឡើងអនុលោមតាមផ្នែកទី ១១ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីសកម្មភាពក្នុងតំបន់។ វិធាន បទបញ្ញត្តិ និងនីតិវិធីទាំងនេះ នឹងត្រូវពិនិត្យឡើងវិញជាបន្តបន្ទាប់ទៅតាមការចាំបាច់។

២.	ក្រោមបញ្ញត្តិពាក់ព័ន្ធនៃជំពូកនេះ បណ្តារដ្ឋត្រូវរៀបចំច្បាប់ និងបទបញ្ញត្តិ ដើម្បីបង្ការ កាត់បន្ថយ និង គ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីសកម្មភាពនៅក្នុងតំបន់ ដែលបង្កឡើងដោយនាវា ឋបនភណ្ឌ សំណង់ និងឧបករណ៍ផ្សេងទៀតដែលចងទង់ជាតិរបស់ខ្លួន ឬបានចុះបញ្ជីជាមួយនឹងខ្លួន ឬមានប្រតិបត្តិការស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ទៅតាមករណីដែលអាចកើតឡើងជាយថាហេតុ។ លក្ខខណ្ឌនៃច្បាប់ និងបទបញ្ញត្តិទាំងនោះ ត្រូវមានអនុភាពស្មើនឹងវិធាន បទបញ្ញត្តិ និងនីតិវិធីអន្តរជាតិដែលមានចែងក្នុងកថាខណ្ឌទី ១ ។

*មាត្រា ២១០*

*ការបំពុលពីការចាក់កាកសំណល់*

១. បណ្តារដ្ឋត្រូវរៀបចំច្បាប់ និងបទបញ្ញត្តិ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ពីការចាក់កាកសំណល់។

២. បណ្តារដ្ឋត្រូវចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលទាំងនោះ។

៣. ច្បាប់ បទបញ្ញត្តិ និងវិធានការទាំងនោះត្រូវធានាបានថា គ្មានការចាក់កាកសំណល់ណាមួយត្រូវបានធ្វើឡើងដោយគ្មានការអនុញ្ញាតអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋឡើយ។

៤. ជាពិសេសតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូត បណ្តារដ្ឋត្រូវប្រឹងប្រែងរៀបចំ បង្កើតនូវវិធាន បទដ្ឋាន ព្រមទាំងនិយាម និងនីតិវិធីតាមការណែនាំជាសកល និងក្នុងតំបន់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលទាំងនោះ។ វិធាន បទដ្ឋាន ព្រមទាំងនិយាម និងនីតិវិធីតាមការណែនាំទាំងនេះត្រូវទទួលការពិនិត្យឡើងវិញជាបន្តបន្ទាប់ទៅតាមការចាំបាច់។

៥. ការចាក់កាកសំណល់ក្នុងដែនសមុទ្រ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬនៅលើតំបន់ខ្ពង់រាបបាតសមុទ្រ មិនត្រូវធ្វើឡើងដោយគ្មានការយល់ព្រមជាមុនយ៉ាងច្បាស់លាស់ពីរដ្ឋជាប់ឆ្នេរ ដែលមានសិទ្ធិអនុញ្ញាត ធ្វើនិយ័តកម្ម និងគ្រប់គ្រងលើការចាក់កាកសំណល់ទាំងនោះ បន្ទាប់ពីមានការពិភាក្សាយ៉ាងត្រឹមត្រូវអំពីបញ្ហានេះជាមួយនឹងរដ្ឋផ្សេងទៀត ដែលអាចទទួលរកការប៉ះពាល់មិនល្អ ដោយសារស្ថានភាពភូមិសាស្ត្ររបស់ពួកគេឡើយ។

៦. ច្បាប់ បទញ្ញត្តិ និងវិធានការជាតិមិនត្រូវមានអនុភាពក្នុងការបង្ការ កាត់បន្ថយ និងគ្រប់គ្រងលើការ បំពុលទាំងនោះតិចជាងវិធាន និងបទដ្ឋានជាសកលឡើយ។

*មាត្រា ២១១*

*ការបំពុលពីនាវា*

១.	តាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតទូទៅ បណ្តារដ្ឋត្រូវរៀបចំបង្កើតច្បាប់ និងបទដ្ឋានអន្តរជាតិ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីនាវា និងជំរុញការបង្កើតក្នុង លក្ខណៈដូចគ្នានេះ ប្រសិនបើអាច នូវប្រព័ន្ធចរាចរណ៍មួយ ដើម្បីកាត់បន្ថយឱ្យនៅសល់តិចតួចបំផុត នូវការគំរាមកំហែងពីគ្រោះថ្នាក់ដែលអាចបង្កឱ្យមានការបំពុលបរិស្ថានសមុទ្រ ដោយរាប់បញ្ចូលទាំងតំបន់មាត់សមុទ្រ និងបង្ការខូចខាតពីការបំពុលទៅលើផលប្រយោជន៍ពាក់ព័ន្ធរបស់រដ្ឋជាប់ឆ្នេរ។ វិធាន និងបទដ្ឋានទាំងនេះ នឹងត្រូវបានពិនិត្យឡើងវិញក្នុងលក្ខណៈដូចគ្នានេះជាបន្តបន្ទាប់ទៅតាមការចាំបាច់។

២.	បណ្តារដ្ឋរៀបចំបង្កើតច្បាប់ និងបទបញ្ញត្តិសម្រាប់ការបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថាន សមុទ្រពីនាវាដែលចងទង់ជាតិរបស់ខ្លួន ឬដែលបានចុះបញ្ជីជាមួយខ្លួន។ ច្បាប់ និងបទបញ្ញត្តិទាំងនោះយ៉ាងហោច ណាស់ត្រូវមានអនុភាពស្មើគ្នាទៅនឹងវិធាន និងបទដ្ឋានអន្តរជាតិដែលមានការទទួលស្គាល់ជាទូទៅ ដែលបង្កើតឡើង តាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតទូទៅ។

៣.	បណ្តារដ្ឋដែលបង្កើតលក្ខខណ្ឌជាក់លាក់សម្រាប់ការបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថាន សមុទ្រសម្រាប់ជាលក្ខខណ្ឌក្នុងការអនុញ្ញាតឱ្យនាវាបរទេសចូលចតក្នុងកំពង់ផែ ឬដែនសមុទ្រក្នុងរបស់ខ្លួន ឬសម្រាប់តម្រូវការចតឆ្ងាយពីច្រាំងរបស់ពួកគេ ត្រូវធ្វើការផ្សព្វផ្សាយលក្ខខណ្ឌទាំងនេះឱ្យបានត្រឹមត្រូវ ព្រមទាំងត្រូវជូនដំណឹងអំពីលក្ខខណ្ឌទាំងនេះដល់អង្គការអន្តរជាតិមានសមត្ថកិច្ចផងដែរ។ ក្នុងករណីដែលលក្ខខណ្ឌទាំងនេះត្រូវបាន បង្កើតឡើងក្នុងទម្រង់ដូចគ្នាដោយបណ្តារដ្ឋជាប់ឆ្នេរចាប់ពីពីរឡើង ដើម្បីសម្រួលគោលនយោបាយរបស់ពួកគេឱ្យ មានលក្ខណៈស្របគ្នា នោះការផ្សព្វផ្សាយត្រូវបង្ហាញថា តើរដ្ឋណាខ្លះកំពុងចូលរួមក្នុងកិច្ចសហប្រតិបត្តិការនេះ។

រដ្ឋនីមួយៗត្រូវតម្រូវឱ្យប្រធាននាវាដែលចងទង់ជាតិរបស់ខ្លួន ឬចុះបញ្ជីជាមួយខ្លួន និងដែលកំពុងបើកបរក្នុង ដែនសមុទ្ររបស់រដ្ឋមួយដែលចូលរួមក្នុងកិច្ចសហប្រតិបត្តិការ ផ្តល់ជូនតាមការស្នើសុំរបស់រដ្ឋនោះ នូវព័ត៌មានថាតើនាវាកំពុងធ្វើដំណើរទៅកាន់រដ្ឋក្នុងតំបន់តែមួយដែលបានចូលរួមក្នុងកិច្ចសហប្រតិបត្តិការនោះឬយ៉ាងណា ហើយប្រសិនបើដូច្នេះមែន ត្រូវបង្ហាញថាតើនាវាបានបំពេញតាមលក្ខខណ្ឌក្នុងការចូលចតក្នុងកំពង់ផែរបស់រដ្ឋនោះហើយ ឬយ៉ាងណា។ មាត្រានេះមិនប៉ះពាល់ដល់ការអនុវត្តសិទ្ធិរបស់នាវាក្នុងការឆ្លងកាត់ដោយគ្មានការបំពានរបស់ខ្លួន ឬដល់ការអនុវត្តមាត្រា ២៥ កថាខណ្ឌទី ២ ឡើយ។

៤. ក្នុងការអនុវត្តអធិបតេយ្យភាពក្នុងដែនសមុទ្ររបស់ខ្លួន បណ្តារដ្ឋជាប់ឆ្នេរអាចរៀបចំច្បាប់ និងបទបញ្ញត្តិ សម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលសមុទ្រពីនាវាបរទេស ដោយរាប់បញ្ចូលទាំង នាវាដែលអនុវត្តសិទ្ធិឆ្លងកាត់គ្មានការបំពានផងដែរ។ ច្បាប់ និងបទបញ្ញត្តិទាំងនោះមិនត្រូវរំខានដល់ការឆ្លងកាត់ ដោយគ្មានការបំពានរបស់នាវាបរទេសឡើយ អនុលោមតាមផ្នែកទី ២ ជំពូកទី ៣ ។

៥. សម្រាប់ការអនុវត្តដូចមានចែងក្នុងជំពូកទី ៦ ទាក់ទិននឹងតំបន់សេដ្ឋកិច្ចផ្តាច់មុខ បណ្តារដ្ឋជាប់ឆ្នេរ អាចរៀបចំច្បាប់ និងបទបញ្ញត្តិសម្រាប់ការបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា ដែលសមស្រប និងផ្តល់សុពលភាពដល់វិធាន និងបទដ្ឋានអន្តរជាតិដែលមានការទទួលស្គាល់ជាទូទៅ និងត្រូវបានបង្កើតឡើងតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតទូទៅ។

៦. (ក) ក្នុងករណីដែលវិធាន និងបទដ្ឋានអន្តរជាតិដែលមានចែងក្នុងកថាខណ្ឌទី ១ មិនមានលក្ខណៈគ្រប់ គ្រាន់ស្របទៅតាមស្ថានភាពពិសេស ហើយរដ្ឋមានឆ្នេរមានមូលហេតុសមស្របក្នុងការសម្រេចថា តំបន់ដែលបានកំណត់ច្បាស់លាស់ យ៉ាងជាក់លាក់នៃតំបន់សេដ្ឋកិច្ចផ្តាច់មុខមួយៗរបស់ពួកគេ គឺជាតំបន់ដែលចាំបាច់ត្រូវមានការរៀបចំនូវវិធានការចាំបាច់ជាពិសេសសម្រាប់ប

ង្ការការបំពុលពីនាវា ក្នុងមូលហេតុបច្ចេកទេសដែលមានការទទួលស្គាល់ទាក់ទិននឹងលក្ខខណ្ឌអេកូសាស្ត្រ និងសាគរសាស្ត្ររបស់ខ្លួន ក៏ដូចជាការប្រើប្រាស់ ឬការការពារធនធានរបស់ខ្លួន និងលក្ខណៈជាក់លាក់នៃចរាចរបស់ខ្លួន នោះបន្ទាប់ពីពិភាក្សាយ៉ាងត្រឹមត្រូវតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ចជាមួយនឹងបណ្តារដ្ឋពាក់ព័ន្ធផ្សេងទៀត បណ្តារដ្ឋដែលជាប់ឆ្នេរអាចធ្វើការជូនដំណឹងដល់អង្គការនោះ ដោយដាក់ជូននូវភស្តុតាងបច្ចេកទេស និងវិទ្យាសាស្ត្រដើម្បីសំអាង និងព័ត៌មានស្តីពីមូលដ្ឋានទទួលយកដែលចាំបាច់។ ក្នុងរវាង ១២ ខែ បន្ទាប់ពីទទួលការផ្សព្វផ្សាយនេះ អង្គការត្រូវកំណត់ថាតើលក្ខខណ្ឌក្នុងតំបន់នោះឆ្លើយតបទៅនឹងលក្ខខណ្ឌដែលបានកំណត់ខាងលើដែរឬយ៉ាងណា។ ប្រសិនបើអង្គការកំណត់ថាឆ្លើយតបសម្រាប់តំបន់នោះ រដ្ឋជាប់ឆ្នេរអាចរៀបចំច្បាប់ និងបទបញ្ញត្តិដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវាដែលអនុវត្តនូវវិធាន និងបទដ្ឋាន ឬការអនុវត្តផ្នែកនាវាចរណ៍អន្តរជាតិជាធរមានទាំងនោះ តាមរយៈអង្គការសម្រាប់តំបន់ពិសេសៗ។ ច្បាប់ និងបទបញ្ញត្តិទាំងនេះនឹងមិនត្រូវអនុវត្តលើនាវាបរទេសនោះទេ រហូតដល់ ១៥ ខែ បន្ទាប់ពីបានដាក់ជូននូវការផ្សព្វផ្សាយនោះជូនដល់អង្គការ។

(ខ) រដ្ឋជាប់ឆ្នេរត្រូវបោះពុម្ពផ្សាយអំពីព្រំដែននៃតំបន់ជាក់លាក់ដែលបានកំណត់យ៉ាងច្បាស់នោះ។

(គ) ប្រសិនបើរដ្ឋជាប់ឆ្នេរមានបំណងរៀបចំនូវច្បាប់ និងបទបញ្ញត្តិបន្ថែមសម្រាប់តំបន់ដដែលនោះ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា នោះនៅពេលដាក់ជូននូវការផ្សព្វផ្សាយខាងលើ

រដ្ឋនោះត្រូវជូនដំណឹងអំពីបញ្ហានេះដល់អង្គការក្នុងពេលតែមួយតែម្តង។ ច្បាប់ និងបទបញ្ញត្តិបន្ថែមទាំងនេះអាចទាក់ទងទៅនឹងការអនុវត្តផ្នែកបញ្ចោញកាកសំណល់ ឬនាវាចរណ៍ ប៉ុន្តែមិនត្រូវតម្រូវឱ្យនាវាបរទេសគោរពតាមបទដ្ឋានម៉ូតរចនា ការសាងសង់ ការផ្ទុកមនុស្ស ឬសម្ភារបរិក្ខារក្រៅពីវិធាន និងបទដ្ឋានអន្តរជាតិដែលបានទទួលយកជាទូទៅ។ ច្បាប់ និងបទបញ្ញត្តិទាំងនេះត្រូវចាប់អនុវត្តលើនាវាបរទេស នៅ ១៥ ខែ ក្រោយពីបានដាក់ជូននូវការផ្សព្វផ្សាយដល់អង្គការ ក្នុងលក្ខខណ្ឌថាអង្គការត្រូវផ្តល់ការយល់ព្រមក្នុងរវាង ១២ ខែ ក្រោយពីការដាក់ជូននូវការផ្សព្វផ្សាយនេះ។

៧. វិធាន និងបទដ្ឋានអន្តរជាតិដែលមានចែងក្នុងមាត្រានេះត្រូវរាប់បញ្ចូលជាអាទិ៍នូវរាល់ចំណុចទាំងឡាយដែលទាក់ទិននឹង ការជូនដំណឹងជាបន្ទាន់ដល់បណ្តារដ្ឋជាប់ឆ្នេរ ដែលមានខ្សែបន្ទាត់ឆ្នេរ ឬផលប្រយោជន៍ទាក់ទិនអាចរងការប៉ះពាល់ពីឧប្បត្តិហេតុ រាប់បញ្ចូលទាំងការស្លាប់ និងរបួសក្នុងដែនសមុទ្រ ដែលពាក់ព័ន្ធនឹងការបញ្ចោញកាកសំណល់ ឬលទ្ធភាពអាចកើតមានការបញ្ចោញកាកសំណល់នោះ។

*មាត្រា ២១២*

*ការបំពុលពី ឬតាមរយៈបរិយាកាស*

បណ្តារដ្ឋត្រូវរៀបចំច្បាប់ និងបទបញ្ញត្តិដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពី ឬតាមរយៈបរិយាកាស ដើម្បីអនុវត្តលើលំហអាកាសក្រោមអធិបតេយ្យភាពរបស់ខ្លួន និងលើនាវាដែលចងទង់ជាតិរបស់ខ្លួន ឬនាវា ឬអាកាសយាន ដែលបានចុះបញ្ជីជាមួយខ្លួន ដោយផ្អែកតាមវិធាន បទដ្ឋាន និងនិយាម និងនីតិវិធីក្រោមការណែនាំដែលបានព្រមព្រៀងជាអន្តរជាតិ និងសុវត្ថិភាពនៃការហោះហើរ។

បណ្តារដ្ឋត្រូវចាត់វិធានការផ្សេងទៀតតាមដែលអាចចាំបាច់ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលទាំងនេះ។

បណ្តារដ្ឋ ជាពិសេសតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតត្រូវខិតខំរៀបចំវិធាន បទដ្ឋាន និងនិយាម និងនីតិវិធីក្រោមការណែនាំជាសកល និងថ្នាក់តំបន់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលទាំងនេះ។

## ជំពូកទី៦៖ ការពង្រឹងច្បាប់

*មាត្រា ២១៣*

*ការពង្រឹងច្បាប់ទាក់ទិនទៅនឹងការបំពុលពីប្រភពនៅលើដីគោក*

បណ្តារដ្ឋត្រូវពង្រឹងច្បាប់ និងបទបញ្ញត្តិរបស់ខ្លួនដែលរៀបចំឡើងអនុលោមតាមមាត្រា ២០៧ និង ត្រូវរៀបចំច្បាប់ និងបទបញ្ញត្តិ និងចាត់វិធានការផ្សេងទៀតដែលចាំបាច់ដើម្បីអនុវត្តវិធាន និងបទដ្ឋានអន្តរជាតិ ជាធរមាន ដែលបានបង្កើតឡើងតាមរយៈ អង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូត ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីប្រភពនៅលើដីគោក។

*មាត្រា ២១៤*

*ការពង្រឹងច្បាប់ទាក់ទិនទៅនឹងការបំពុលពីសកម្មភាពនៅបាតសមុទ្រ*

បណ្តារដ្ឋត្រូវពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញត្តិរបស់ខ្លួនដែលបានរៀបចំឡើងអនុលោមតាមមាត្រា ២០៨ និងត្រូវរៀបចំច្បាប់ និងបទបញ្ញត្តិ និងចាត់វិធានការផ្សេងទៀតដែលចាំបាច់ដើម្បីអនុវត្តវិធាន និងបទដ្ឋានអន្តរជាតិជាធរមានដែលបានបង្កើតឡើងតាមរយៈ អង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រដែលកើតចេញពី

ឬទាក់ទិនទៅនឹងសកម្មភាពនៅបាតសមុទ្រ អនុលោមទៅតាមរបស់ខ្លួន យុត្តាធិការ និងពីកោះសប្បនិម្មិត បបនកណ្ឌ និងសំណង់ ក្រោម យុត្តាធិការរបស់ខ្លួន អនុលោមទៅតាមមាត្រា ៦០ និង ៨០។

*មាត្រា ២១៥*

*ការពង្រឹងច្បាប់ទាក់ទិនទៅនឹងការបំពុលពីសកម្មភាពនៅក្នុងតំបន់*

ការពង្រឹងវិធាន បទបញ្ញត្តិ និង នីតិវិធីអន្តរជាតិ ដែលបង្កើតឡើងអនុលោមទៅតាមផ្នែកទី១១ ដើម្បីបង្ការកាត់បន្ថយ និងគ្រប់គ្រង ការបំពុលបរិស្ថានសមុទ្រពីសកម្មភាពនៅក្នុងតំបន់ត្រូវគ្រប់គ្រងដោយផ្នែកនោះ។

*មាត្រា ២១៦*

*ការពង្រឹងច្បាប់ទាក់ទិនទៅនឹងការបំពុលពីការចាក់កាកសំណល់*

១. ច្បាប់ និងបទបញ្ញត្តិដែលបានរៀបចំអនុលោមតាមអនុសញ្ញានេះ និងវិធាន និងបទដ្ឋានអន្តរជាតិ ជាធរមាន ដែលត្រូវបានបង្កើតឡើងតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីការចាក់កាកសំណល់ត្រូវត្រូវពង្រឹងការអនុវត្តៈ

(ក) ដោយរដ្ឋជាប់ឆ្នេរ ទាក់ទិនទៅនឹងការចាក់កាកសំណល់នៅក្នុងដែនសមុទ្រ ឬតំបន់សេដ្ឋកិច្ច ផ្តាច់មុខរបស់ខ្លួន ឬនៅលើទ្រនាប់ទ្វីបរបស់ខ្លួន។

(ខ) ដោយរដ្ឋចុះបញ្ជីនាវា ទាក់ទិនទៅនឹងនាវាដែលចងទង់ជាតិរបស់ខ្លួន ឬ នាវា ឬអាកាសយានដែល ចុះបញ្ជីជាមួយខ្លួន។

(គ) ដោយរដ្ឋណាមួយទាក់ទិនទៅនឹងទង្វើផ្ទុកកាកសំណល់ ឬរូបធាតុផ្សេងទៀតដែលធ្វើឡើងនៅក្នុង បូរណភាពដែនដីរបស់ខ្លួន ឬនៅមូលដ្ឋានឆ្ងាយពីច្រាំងរបស់ខ្លួន។

២. ក្រោមមាត្រានេះ គ្មានរដ្ឋមានកាតព្វកិច្ចចាប់ផ្តើមដំណើរការក្តីនៅពេលរដ្ឋមួយផ្សេងទៀតបាន ចាប់ផ្តើមដំណើរការក្តីអនុលោមតាមមាត្រានេះរួចមកហើយនោះទេ។

*មាត្រា ២១៧*

*ការអនុវត្តដោយរដ្ឋចុះបញ្ជីនាវា*

១. បណ្តារដ្ឋត្រូវធានាឱ្យបាននូវការគោរពរបស់នាវាដែលចងទង់ជាតិរបស់ខ្លួន ឬដែលបានចុះបញ្ជីជាមួយខ្លួននូវវិធាន និងបទដ្ឋានអន្តរជាតិជាធរមាន ដែលបានបង្កើតឡើងដោយអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតទូទៅ ព្រមទាំងនូវច្បាប់ និងបទបញ្ញត្តិរបស់ខ្លួនដែលរៀបចំឡើងអនុលោមតាមអនុសញ្ញានេះ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីនាវា ហើយត្រូវរៀបចំច្បាប់ និងបទបញ្ញត្តិទៅតាមនោះ ព្រមទាងចាត់វិធានការផ្សេងទៀតដែលចាំបាច់សម្រាប់ការអនុវត្តរបស់ខ្លួន។ បណ្តារដ្ឋចុះបញ្ជីនាវាត្រូវសម្រួលដល់ការពង្រឹងយ៉ាងមានប្រសិទ្ធភាពនូវវិធាន បទដ្ឋាន ច្បាប់ និងបទបញ្ញត្តិទាំងនេះ មិនថាការបំពានកើតមាននៅទីណានោះទេ។

២. ជាពិសេស បណ្តារដ្ឋត្រូវចាត់វិធានការសមស្របដើម្បីធានាថា នាវាដែលចងទង់ជាតិរបស់ខ្លួន ឬដែលបានចុះបញ្ជីជាមួយខ្លួនត្រូវបានហាមឃាត់មិនឱ្យបើកបរនោះទេ រហូតដល់ពួកគេអាចដំណើរការនៅក្នុងសមុទ្រ អនុលោមទៅតាមលក្ខខណ្ឌនៃវិធាន និងបទដ្ឋានអន្តរជាតិ ដែលលើកឡើងក្នុងកថាខណ្ឌទី ១ រួមទាំងលក្ខខណ្ឌទាក់ទិនទៅនឹងប្លង់រចនា ការសាងសង់ សម្ភារបរិក្ខារ និងការផ្ទុកមនុស្សរបស់នាវា។

៣. បណ្តារដ្ឋត្រូវធានាបានថានាវាដែលចងទង់ជាតិរបស់ខ្លួន ឬ ដែលបានចុះបញ្ជីជាមួយខ្លួនមានជាប់ខ្លួននូវលិខិតបញ្ជាក់ដែលកំណត់ដោយ

និងបានចេញជូនអនុលោមទៅតាមវិធាន និងបទដ្ឋានអន្តរជាតិ ដែលលើកឡើងក្នុងកថាខណ្ឌទី ១។ បណ្តារដ្ឋត្រូវធានាបានថា នាវាដែលចងទង់ជាតិរបស់ខ្លួនត្រូវបានត្រួតពិនិត្យយ៉ាងទៀងទាត់ ដើម្បីផ្ទៀងផ្ទាត់ថាលិខិតបញ្ជាក់នេះ មានលក្ខណៈស្របទៅតាមស្ថានភាពជាក់ស្តែងរបស់នាវា។ លិខិតបញ្ជាក់ទាំងនេះត្រូវទទួលយកដោយបណ្តារដ្ឋផ្សេងទៀត ទុកជាភស្តុតាងស្តីពីស្ថានភាពរបស់នាវា និងត្រូវបានចាត់ទុកថាមានអានុភាពដូចគ្នាទៅនឹងលិខិតបញ្ជាក់ដែលចេញដោយពួកគេ លើកលែងតែមាន មានអំណះអំណាងច្បាស់លាស់ក្នុងការជឿថាស្ថានភាពរបស់នាវាមិនមានលក្ខណៈស្របគ្នាខ្លាំងទៅនឹងលក្ខណៈដែលបញ្ជាក់ក្នុងលិខិតបញ្ជាក់។

៤. ប្រសិនបើនាវាប្រព្រឹត្តបំពានទៅនឹងវិធាន និងបទដ្ឋានដែលបានបង្កើតឡើងដោយអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតទូទៅ នោះដោយមិនប៉ះពាល់មាត្រា ២១៨ ២២០ និង ២២៨ រដ្ឋចុះបញ្ជីនាវាត្រូវសម្រួលឱ្យមានការស៊ើបអង្កេតភ្លាមៗ ហើយប្រសិនបើអាចចាប់ផ្តើមដំណើរការក្តីទាក់ទិនទៅនឹងការបំពានដែលបានចោទប្រកាន់ មិនថាការបំពានបានកើតឡើងនៅទីកន្លែងណា ឬការបំពុលដែលកើតចេញពីការបំពាននេះបានកើតឡើង ឬ បានរកឃើញនៅទីកន្លែងណានោះទេ។

៥. បណ្តារដ្ឋចុះបញ្ជីនាវាដែលធ្វើការស៊ើបអង្កេតការបំពានអាច ស្នើសុំជំនួយពីរដ្ឋផ្សេងទៀតដែលកិច្ចសហប្រតិបត្តិការនេះអាចមានប្រយោជន៍ក្នុងការបំភ្លឺអំពីស្ថានភាពនៃករណីនោះ។ បណ្តារដ្ឋត្រូវប្រឹងប្រែងបំពេញតាមសំណើសុំសមស្របរបស់បណ្តារដ្ឋចុះបញ្ជីនាវា។

៦. តាមការស្នើសុំជាលាយលក្ខណ៍អក្សររបស់រដ្ឋនានា បណ្តារដ្ឋត្រូវតាមដានលើការបំពានដែលបានចោទប្រកាន់ថា បានប្រព្រឹត្តដោយនាវាដែលចងទង់ជាតិរបស់ខ្លួន។ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ដែលអាចចាប់ផ្តើមដំណើរការក្តីទាក់ទិនទៅនឹងការបំពានដែលបានចោទប្រកាន់នោះ បណ្តារដ្ឋចុះបញ្ជីនាវាត្រូវចាប់ផ្តើមដំណើរការក្តីនេះភ្លាមៗ ដោយអនុលោមតាមច្បាប់របស់ខ្លួន។

៧. បណ្តារដ្ឋចុះបញ្ជីនាវាត្រូវជូនដំណឹងភ្លាមៗដល់រដ្ឋដែលបានស្នើសុំ និងអង្គការអន្តរជាតិមាន សមត្ថកិច្ចអំពីសកម្មភាពដែលបានធ្វើឡើង និងអំពីលទ្ធផលរបស់វា។ ព័ត៌មាននេះត្រូវជូនដំណឹងទៅដល់បណ្តា រដ្ឋទាំងអស់។

៨. ទណ្ឌកម្មដែលធ្វើឡើងក្រោមច្បាប់ និងបទបញ្ញត្តិរបស់បណ្តារដ្ឋចំពោះនាវាដែលចងទង់ជាតិរបស់ខ្លួន ត្រូវមានទម្ងន់គ្រប់គ្រាន់ ដើម្បីបង្ការកុំឱ្យមានការប្រព្រឹត្តការបំពាននោះទៀត ទោះបីជាវាកើតមាននៅ ទីណាក៏ដោយ។

*មាត្រា ២១៨*

*ការអនុវត្តដោយរដ្ឋជាម្ចាស់កំពង់ផែ*

១. ក្នុងករណីមាននាវាចូលទៅក្នុងកំពង់ផែ ឬនៅឯមូលដ្ឋានឆ្ងាយពីច្រាំងរបស់រដ្ឋដោយខ្លួនឯង រដ្ឋនោះអាចធ្វើការស៊ើបអង្កេត ហើយនៅពេលដែលមានភស្តុតាងគ្រប់គ្រាន់ នោះអាចចាប់ផ្តើមដំណើរការក្តី ទាក់ទិនទៅនឹងការបញ្ចេញចោលកាកសំណល់នានាពីនាវានោះ នៅខាងក្រៅទឹកខាងក្នុង ដែនសមុទ្រ ឬ តំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋនោះ ដោយបំពានទៅនឹងវិធាន និងបទដ្ឋានអន្តរជាតិជាធរមានដែលបានបង្កើត ឡើងដោយអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតទូទៅ។

២. គ្មានដំណើរការក្តីអនុលោមទៅតាមកថាខណ្ឌទី ១ ត្រូវបានចាប់ផ្តើមទាក់ទិនទៅនឹងការបំពានដោយបញ្ចេញចោលកាកសំណល់នៅក្នុងទឹកខាងក្នុង ដែនសមុទ្រ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋមួយផ្សេងទៀតនោះទេ លើកលែងតែមានការស្នើសុំពីរដ្ឋនោះ រដ្ឋចុះបញ្ជីនាវា ឬរដ្ឋដែលរងការខូចខាត ឬការគំរាមកំហែងពីការបញ្ចេញចោលកាកសំណល់នោះ ឬលើកលែងតែការបំពាននោះបានបណ្តាល ឬអាចនឹងបង្កឱ្យមានការបំពុលនៅក្នុងទឹកខាងក្នុង ដែនសមុទ្រ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋដែលចាប់ផ្តើមដំណើរការក្តីនោះ។

៣. ក្នុងករណីមាននាវាចូលទៅក្នុងកំពង់ផែ ឬនៅឯមូលដ្ឋានឆ្ងាយពីច្រាំងរបស់រដ្ឋដោយខ្លួនឯង រដ្ឋនោះតាមដែលអាចអនុវត្តទៅបានត្រូវគោរពអនុវត្តតាមសំណើពីរដ្ឋនានា ដែលសុំឱ្យមានការស៊ើបអង្កេតលើការបំពានដោយបញ្ចេញចោលកាកសំណល់ដែលលើកឡើងក្នុងកថាខណ្ឌទី ១ ដែលជឿថាបានកើតឡើងនៅក្នុង បានបង្កឱ្យមាន ឬ បានគំរាមកំហែងបង្កការខូចខាតដល់ទឹកខាងក្នុង ដែនសមុទ្រ

ឬតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់រដ្ឋដែលស្នើឡើង។ ដូចគ្នានេះដែរ តាមដែលអាចអនុវត្តទៅបាន រដ្ឋនោះត្រូវគោរពទៅតាមសំណើពីរដ្ឋចុះបញ្ជីនាវាដែលសុំឱ្យមានការស៊ើបអង្កេតលើការបំពានទាំងនេះ មិនថាការបំពានបានកើតឡើងនៅទីកន្លែងណានោះទេ។

៤. កំណត់ត្រាស្ដីពីការស៊ើបអង្កេតដែលបានធ្វើឡើងដោយរដ្ឋម្ចាស់កំពង់ផែ អនុលោមទៅតាមមាត្រានេះ ត្រូវបញ្ជូនតាមសំណើទៅរដ្ឋចុះបញ្ជីនាវា ឬទៅរដ្ឋជាប់ឆ្នេរ។ ដំណើរការក្ដីនានាដែលបានចាប់ផ្ដើមដោយរដ្ឋម្ចាស់កំពង់ផែ ផ្អែកតាមការស៊ើបអង្កេតនេះ អនុលោមទៅតាមជំពូកទី ៧ អាចត្រូវបានផ្អាក ទៅតាមសំណើរបស់រដ្ឋជាប់ឆ្នេរ ក្នុងករណីដែលការបំពាននោះបានកើតឡើងនៅក្នុងទឹកខាងក្នុង ដែនសមុទ្រ ឬតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ខ្លួន។ ភស្តុតាង និងកំណត់ត្រាស្ដីពីករណី រួមជាមួយនឹងប្រាក់កក់ ឬប្រាក់ធានានានាផ្សេងទៀតដែលបង់ជូនអាជ្ញាធរនៃរដ្ឋម្ចាស់កំពង់ផែ ក្នុងករណីនោះ ត្រូវបានផ្ទេរបញ្ជូនទៅឱ្យរដ្ឋជាប់ឆ្នេរ។ ការផ្ទេរបញ្ជូនទាំងនេះត្រូវមានអនុភាពលុបចោលនូវការបន្តដំណើរការក្ដីក្នុងរដ្ឋម្ចាស់កំពង់ផែ។

*មាត្រា ២១៩*

*វិធានការទាក់ទិននឹងភាពស័ក្ដិសមរបស់នាវាដើម្បីជៀសវាងការបំពុល*

អនុលោមទៅតាមជំពូកទី ៧ តាមសំណើ ឬ តាមការផ្ដួចផ្ដើមផ្ទាល់ខ្លួន បណ្ដារដ្ឋដែលច្បាស់ថា នាវានៅក្នុងកំពង់ផែរបស់ខ្លួន ឬនៅឯមូលដ្ឋានឆ្ងាយពីច្រាំងមួយរបស់ខ្លួនបានបំពានទៅនឹងវិធាន និងបទដ្ឋានអន្តរជាតិជាធរមានទាក់ទិននឹងភាពស័ក្ដិសមរបស់នាវា ដូច្នេះហើយវាគំរាមកំហែងបង្ករការខូចខាតដល់បរិស្ថានសមុទ្រ ត្រូវចាត់វិធានការរដ្ឋបាលដើម្បីបង្ការកុំឱ្យនាវានោះធ្វើការបើកបរ តាមដែលអាចអនុវត្តទៅបាន។ បណ្ដារដ្ឋទាំងនេះអាចអនុញ្ញាតឱ្យនាវាធ្វើដំណើរតែទៅកាន់កន្លែងជួសជុលដែលស័កដិសមនៅជិតបំផុត

ប៉ុណ្ណោះ ហើយនៅពេលបំបាត់នូវមូលហេតុដែលបណ្ដាលឱ្យមានការបំពានរួចហើយ ត្រូវអនុញ្ញាតនាវាឱ្យបន្តដំណើរភ្លាមៗ។

*មាត្រា ២២០*

*ការអនុវត្តដោយរដ្ឋជាប់ឆ្នេរ*

១. ក្នុងករណីមាននាវាចូលទៅក្នុងកំពង់ផែ ឬនៅឯមូលដ្ឋានឆ្ងាយពីច្រាំងរបស់រដ្ឋដោយខ្លួនឯង អនុលោមទៅតាមជំពូកទី ៧ រដ្ឋនោះអាចចាប់ផ្ដើមដំណើរការក្ដីទាក់ទិនទៅនឹងការបំពាននានាលើច្បាប់ និងបទបញ្ញត្តិរបស់ខ្លួនដែលរៀបចំឡើងអនុលោមតាមអនុសញ្ញានេះ ឬ វិធាន និងបទដ្ឋានអន្តរជាតិជាធរមាន ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា នៅពេលដែលការបំពាននោះបានកើតឡើងនៅក្នុងដែនសមុទ្រ ឬ តំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់រដ្ឋនោះ។

២. ក្នុងករណីមានអំណះអំណាងច្បាស់លាស់ដែលអាចជឿថា នាវាដែលបើកបរក្នុងដែនសមុទ្ររបស់រដ្ឋ ក្នុងអំឡុងពេលឆ្លងកាត់របស់ខ្លួន ក្នុងរដ្ឋនោះ បានបំពានច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋនោះដូចដែលបានរៀបចំឡើងអនុលោមតាមអនុសញ្ញានេះ ឬ វិធាន និងបទដ្ឋានអន្តរជាតិជាធរមានដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា នោះរដ្ឋនោះ ដោយមិនប៉ះពាល់ដល់ការអនុវត្តបញ្ញត្តិពាក់ព័ន្ធនៃផ្នែកទី ២ជំពូកទី ៣ អាចធ្វើការពិនិត្យជារូបសាស្ត្រលើនាវានោះ ទាក់ទិននឹងការបំពាន ហើយក្នុងករណីមានភស្តុតាងបញ្ជាក់ថាមានការបំពានដូច្នេះមែន អាចចាប់ផ្ដើមដំណើរការក្ដី រួមទាំងការបង្ខាំងទុកនាវានោះ ក្រោមច្បាប់របស់ខ្លួន អនុលោមទៅតាមបញ្ញត្តិនៃជំពូកទី ៧ ផងដែរ។

៣. ក្នុងករណីមានអំណះអំណាងច្បាស់លាស់ដែលអាចជឿថា នាវាដែលបើកបរក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ ឬ ដែនសមុទ្ររបស់រដ្ឋ នៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខនោះ បានប្រព្រឹត្តបំពានទៅលើវិធាន និងបទដ្ឋានអន្តរជាតិជាធរមានដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា ឬ ច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋនោះដែលមានលក្ខណៈស្រប

និងផ្តល់នូវប្រសិទ្ធិភាពដល់វិធាន និងបទដ្ឋានទាំងនោះ រដ្ឋនោះអាចតម្រូវឱ្យនាវានោះផ្តល់នូវព័ត៌មានទាក់ទិននឹងអត្តសញ្ញាណរបស់ខ្លួន និងកំពង់ផែដែលខ្លួនបានចុះបញ្ជី កំពង់ផែបន្ទាប់ និងចុងក្រោយរបស់ខ្លួន និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលចាំបាច់ដើម្បីកំណត់ថាតើមានការបំពានមែនឬទេ។

៤. បណ្តារដ្ឋត្រូវរៀបចំច្បាប់ និងបទបញ្ញត្តិ ព្រមទាំងចាត់វិធានការផ្សេងទៀត ដើម្បីធ្វើយ៉ាងណាឱ្យនាវាដែលចងទង់ជាតិរបស់ខ្លួនគោរពទៅតាមសំណើសុំនូវព័ត៌មានអនុលោមទៅតាមកថាខណ្ឌទី ៣។

៥. ក្នុងករណីមានអំណះអំណាងច្បាស់លាស់ដែលអាចជឿថា នាវាដែលបើកបរក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬ ដែនសមុទ្ររបស់រដ្ឋ ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនោះ បានប្រព្រឹត្តបំពានដូចដែលមានលើកឡើងក្នុងកថាខណ្ឌទី ៣ ដែលនាំមកនូវការបញ្ចេញចោលកាកសំណល់យ៉ាងធ្ងន់ធ្ងរបណ្តាលឱ្យមាន ឬអាចគំរាមកំហែងឱ្យមានការបំពុលបរិស្ថានសមុទ្រធ្ងន់ធ្ងរ នោះរដ្ឋនោះអាចធ្វើការពិនិត្យជារូបសាស្ត្រលើនាវានោះ ដើម្បីស្វែងរកបញ្ហាដែលទាក់ទិននឹងការបំពាន ប្រសិនបើនាវាបានបដិសេធមិនផ្តល់ព័ត៌មាន ឬ ប្រសិនបើព័ត៌មានដែលនាវានោះបានផ្តល់ឱ្យមានលក្ខណៈខុសគ្នាយ៉ាងច្បាស់ពីស្ថានភាពជាក់ស្តែង និងប្រសិនបើស្ថានភាពជាក់ស្តែងនៃករណីតម្រូវឱ្យមានការពិនិត្យនេះ។

៦. ក្នុងករណីមានភស្តុតាងច្បាស់លាស់ថា នាវាដែលបើកបរក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬ ដែនសមុទ្ររបស់រដ្ឋ ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនោះ បានប្រព្រឹត្តបំពានដូចដែលលើកឡើងក្នុងកថាខណ្ឌទី ៣ ដែលនាំមកនូវការបញ្ចេញចោលកាកសំណល់បណ្តាលឱ្យមានការខូចខាតធំៗ ឬគំរាមកំហែងបង្កនូវការខូចខាតធំៗទៅលើខ្សែបន្ទាត់ឆ្នេរ ឬផលប្រយោជន៍ដែលទាក់ទិនរបស់រដ្ឋជាប់ឆ្នេរ ឬទៅលើធនធាននានាក្នុងដែនសមុទ្រ ឬ តំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន នោះរដ្ឋនោះ អនុលោមទៅតាមជំពូកទី ៧ ក្នុងលក្ខខណ្ឌថាភស្តុតាងនោះគឺពិតជាដូច្នេះមែន អាចចាប់ផ្តើមដំណើរការក្តី រួមទាំង ការបង្ខាំងទុកនាវានោះ អនុលោមតាមច្បាប់របស់ខ្លួន។

៧. ទោះបីជាមានចែងដូចបទបញ្ញត្តិនៃកថាខណ្ឌទី ៦ ក៏ដោយ ក្នុងករណីមានការបង្កើតឡើងនូវនីតិវិធីសមស្របតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬផ្សេងពីនេះ តាមការព្រមព្រៀងគ្នានោះ ដែលប្រាក់ធានា ឬប្រាក់កក់សមស្របផ្សេងទៀតត្រូវបានធ្វើឡើងតាមលក្ខខណ្ឌកំណត់ហើយនោះ រដ្ឋជាប់ឆ្នេរ ប្រសិនបើមានកាតព្វកិច្ចត្រូវគោរពតាមនីតិវិធីទាំងនេះ ត្រូវអនុញ្ញាតឱ្យនាវានោះបន្តដំណើរតទៅទៀត។

៨. បទបញ្ញត្តិនៃកថាខណ្ឌទី ៣ ៤ ៥ ៦ និង ៧ ក៏ត្រូវអនុវត្តផងដែរ ទាក់ទិនទៅនឹងច្បាប់ និងបទបញ្ញត្តិថ្នាក់ជាតិ ដែលបានរៀបចំឡើងអនុលោមទៅតាមមាត្រា ២១១ កថាខណ្ឌទី ៦។

*មាត្រា ២២១*

*វិធានការបញ្ចៀសការបំពុលកើតចេញពីគ្រោះថ្នាក់ក្នុងសមុទ្រ*

១. គ្មានចំណុចណាមួយក្នុងផ្នែកនេះប៉ះពាល់ដល់សិទ្ធិរបស់បណ្តារដ្ឋ អនុលោមទៅតាមច្បាប់អន្តរជាតិ ទាំងថ្មី និងចាស់ ក្នុងការចាត់ និងពង្រឹងវិធានការហួសពីដែនសមុទ្រ សមាមាត្រទៅនឹងការខូចខាត ជាក់ស្តែង ឬបានគំរាមកំហែង ក្នុងការការពារខ្សែបន្ទាត់ឆ្នេរ ឬផលប្រយោជន៍ទាក់ទិនរបស់ខ្លួនឡើយ រាប់បញ្ចូលទាំងការនេសាទ ពីការបំពុល ឬការគំរាមកំហែងបំពុល បន្ទាប់ពីមានគ្រោះថ្នាក់ក្នុងសមុទ្រ ឬទង្វើទាក់ទិននឹងគ្រោះថ្នាក់ទាំងនេះ ដែលអាចត្រូវបានរំពឹងយ៉ាងសមហេតុផលថានឹងនាំមកនូវគ្រោះថ្នាក់ធ្ងន់ធ្ងរជាផលវិបាក។

២. សម្រាប់គោលបំណងនៃមាត្រានេះ "ការប៉ះទង្គិចគ្នាក្នុងសមុទ្រ " មានន័យថា ការបុកគ្នារបស់នាវា ការជាប់គៀង ឬឧប្បត្តិហេតុផ្សេងទៀតក្នុងពេលបើកបរ ឬហេតុការណ៍ផ្សេងទៀតដែលកើតមាននៅលើនាវា ឬខាងក្រៅនាវា ដែលនាំមកនូវការខូចខាតធ្ងន់ធ្ងរ ឬអាចនាំឱ្យការគំរាមកំហែងបង្កការខូចខាតធ្ងន់ធ្ងរទៅលើនាវា ឬឥវ៉ាន់។

*មាត្រា ២២២*

*ការពង្រឹងច្បាប់ទាក់ទិនទៅនឹងការបំពុលពី ឬតាមរយៈបរិយាកាស*

បណ្តារដ្ឋត្រូវពង្រឹង នៅក្នុងលំហអាកាសដែលស្ថិតក្រោមអធិបតេយ្យភាពរបស់ខ្លួន ឬទាក់ទិនទៅនឹងនាវាដែលចងទង់ជាតិរបស់ខ្លួន ឬ នាវា ឬអាកាសយានដែលបានចុះបញ្ជីជាមួយខ្លួន នូវច្បាប់ និងបទបញ្ញត្តិរបស់ខ្លួនដែលបានរៀបចំឡើងអនុលោមតាមមាត្រា ២១២ កថាខណ្ឌទី ១ រួមជាមួយនឹងបទបញ្ញត្តិផ្សេងៗទៀតនៃអនុសញ្ញានេះ ព្រមទាំងត្រូវរៀបចំច្បាប់ និងបទបញ្ញត្តិ និងចាត់វិធានការចាំបាច់ផ្សេងទៀត ដើម្បីអនុវត្តវិធាន និងបទដ្ឋានអន្តរជាតិជាធរមានដែលបានបង្កើតឡើងដោយអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូត ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពី ឬតាមរយៈ បរិយាកាស ស្របទៅតាមវិធាន និងបទដ្ឋានអន្តរជាតិពាក់ព័ន្ធទាំងអស់ទាក់ទិននឹងសុវត្ថិភាពក្នុងការការហោះហើរ។

## ជំពូកទី៧៖ ការការពារ

*មាត្រា ២២៣*

*វិធានការដើម្បីសម្រួលដល់ដំណើរការក្តី*

ក្នុងដំណើរការក្តីដែលបានចាប់ផ្តើមអនុលោមទៅតាមផ្នែកនេះ បណ្តារដ្ឋត្រូវចាត់វិធានការដើម្បីសម្រួលដល់ ការបើកសវនាការស្តាប់ចម្លើយសាក្សី និងការផ្តល់ភស្តុតាងពីអាជ្ញាធររបស់រដ្ឋមួយផ្សេងទៀត ឬពីអង្គការអន្តរជាតិមានសមត្ថកិច្ច ព្រមទាំងត្រូវសម្រួលការចូលរួមក្នុងដំណើរការក្តីនេះពីតំណាងផ្លូវការរបស់អង្គការអន្តរជាតិមានសមត្ថកិច្ច រដ្ឋចុះបញ្ជីនាវា និងរដ្ឋនានាដែលបានរងការប៉ះពាល់ពីការបំពុលដែលកើតចេញពីការបំពានណាមួយ។ តំណាងផ្លូវការដែលចូលរួមដំណើរការក្តីនេះត្រូវមានសិទ្ធិ និងភារកិច្ចតាមដែលអាចត្រូវបានកំណត់ក្រោមច្បាប់ និងបទបញ្ញត្តិជាតិ ឬ ច្បាប់អន្តរជាតិ។

*មាត្រា ២២៤*

*ការប្រើប្រាស់អំណាចអនុវត្តន៍*

សិទ្ធិអំណាចក្នុងការពង្រឹងច្បាប់ចំពោះនាវាបរទេសក្រោមផ្នែកនេះ អាចត្រូវបានអនុវត្តដោយ មន្ត្រី ឬដោយនាវាចំបាំង អាកាសយានចំបាំង ឬ នាវា ឬ អាកាសយានផ្សេងទៀតដែលមានសញ្ញា និងអាចកំណត់អំពីអត្តសញ្ញាណយ៉ាងច្បាស់ថាកំពុងបំពេញបេសកកម្មឱ្យរដ្ឋាភិបាល និងទទួលបានសិទ្ធិក្នុងការអនុវត្តនេះតែប៉ុណ្ណោះ។

*មាត្រា ២២៥*

*ភារកិច្ចក្នុងជៀសវាងពីផលវិបាកមិនល្អក្នុងការអនុវត្តសិទ្ធិអំណាចពង្រឹងច្បាប់*

ក្នុងការអនុវត្តនូវសិទ្ធិអំណាចរបស់ខ្លួន ក្នុងការពង្រឹងច្បាប់ចំពោះនាវាបរទេសក្រោមអនុសញ្ញានេះ បណ្តារដ្ឋមិនត្រូវបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់នាវាចរណ៍ ឬបង្កើតនូវគ្រោះថ្នាក់ណាមួយដល់នាវា ឬនាំឱ្យនាវានោះទៅកាន់កំពង់ផែគ្មានសុវត្ថិភាព ឬបោះយុថ្កាចតក្នុងទីគ្មានសុវត្ថិភាព ឬបង្កឱ្យបរិស្ថានសមុទ្រប្រឈមទៅនឹងហានិភ័យមិនសមហេតុផល។

*មាត្រា ២២៦*

*ការស៊ើបអង្កេតលើនាវាបរទេស*

១. (ក)

បណ្តារដ្ឋមិនត្រូវបង្កភាពយឺតយ៉ាវដល់នាវាបរទេសលើសពីរយៈពេលចាំបាច់សម្រាប់គោលបំណងស៊ើបអង្កេតដូចមានចែងក្នុងមាត្រា ២១៦ ២១៨ និង ២២០ នោះទេ។ រាល់ការពិនិត្យជារូបវន្តលើនាវាបរទេសត្រូវមានកម្រិតត្រឹមការពិនិត្យលើលិខិតបញ្ជាក់ កំណត់ត្រា ឬ ឯកសារផ្សេងទៀត ដែលនាវាចាំបាច់ត្រូវមាន អនុលោមតាមវិធាន និងបទដ្ឋានអន្តរជាតិដែលបានទទួលយកជាទូទៅ ឬឯកសារស្រដៀងគ្នានេះផ្សេងទៀតដែលនាវាមានប៉ុណ្ណោះ។ ការពិនិត្យជារូបវន្តបន្ថែមលើនាវាអាចត្រូវបានធ្វើឡើងតែបន្ទាប់ពីមានការពិនិត្យអង្កេតរួចរាល់ និងតែក្នុងករណីដែល ៖

១. មានអំណះអំណាងច្បាស់លាស់ដែលអាចជឿថា ស្ថានភាពរបស់នាវា ឬសម្ភារបរិក្ខាររបស់នាវាមានលក្ខណៈមិនស្របគ្នាខ្លាំងទៅនឹងលក្ខណៈដែលបានបញ្ជាក់ក្នុងឯកសារទាំងនោះ។

២. ខ្លឹមសារក្នុងឯកសារទាំងនោះមិនមានលក្ខណៈគ្រប់គ្រាន់អាចបញ្ជាក់ ឬផ្ទៀងផ្ទាត់អំពីការបំពានដែលបានសង្ស័យ ឬ

៣. នាវាមិនមានលិខិតបញ្ជាក់ និងកំណត់ត្រាដែលមានសុពលភាពត្រឹមត្រូវ។

(ខ) ប្រសិនបើការស៊ើបអង្កេតបង្ហាញថាមានការបំពានទៅលើច្បាប់ និងបទបញ្ញត្តិជាធរមាន ឬ វិធាន និងបទដ្ឋានអន្តរជាតិ ស្តីពីការការពារ និងការថែរក្សាបរិស្ថានសមុទ្រ

នោះត្រូវធ្វើការដោះលែងនាវានោះភ្លាមៗបន្ទាប់ពីបានអនុវត្តនីតិវិធីយ៉ាងសមហេតុផល ដូចជាមានការបង់ប្រាក់ធានា ឬការធានាហិរញ្ញវត្ថុសមស្របផ្សេងទៀត។

(គ) ដោយមិនប៉ះពាល់វិធាន និងបទដ្ឋានអន្តរជាតិជាធរមានទាក់ទិននឹងភាពស័ក្តិសមក្នុងសមុទ្ររបស់នាវា ការដោះលែងនាវាអាច ក្នុងករណីមានការគំរាមកំហែងបង្កការខូចខាតមិនសមហេតុផលណាមួយដល់បរិស្ថានសមុទ្រ ត្រូវបានបដិសេធ ឬមានលក្ខខណ្ឌតម្រូវឱ្យធ្វើដំណើរទៅកាន់កន្លែងជួសជុលដែលស័ក្តិសមនៅជិតបំផុត។ ក្នុងករណីដែលការដោះលែងត្រូវបានបដិសេធ ឬមានលក្ខខណ្ឌ រដ្ឋចុះបញ្ជីនាវាដែលនាវាបង្ហូតត្រូវបានជូនដំណឹងភ្លាមៗ ហើយអាចស្វែងរកការដោះលែងនាវានោះ អនុលោមតាមផ្នែកទី ១៥។

២. បណ្តារដ្ឋត្រូវសហការគ្នាបង្កើតនីតិវិធីសម្រាប់ជៀសវាងការពិនិត្យជារូបសាស្ត្រដែលមិនចាំបាច់លើនាវានៅក្នុងសមុទ្រ។

*មាត្រា ២២៧*

*ការមិនរើសអើងទាក់ទិនទៅនឹងនាវាបរទេស*

ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន និងបំពេញភារកិច្ចរបស់ខ្លួនក្រោមផ្នែកនេះ បណ្តារដ្ឋមិនត្រូវរើសអើងក្នុងរូបភាពណាមួយចំពោះនាវារបស់រដ្ឋផ្សេងទៀតនោះឡើយ។

*មាត្រា ២២៨*

*ការផ្អាក និងការដាក់បម្រាមលើការចាប់ផ្តើមដំណើរការក្តី*

១.  ដំណើរការក្តីដើម្បីដាក់ទណ្ឌកម្មទាក់ទិនទៅនឹងការបំពាននានាលើច្បាប់ និងបទបញ្ញត្តិជាធរមាន ឬវិធាន និងបទដ្ឋានអន្តរជាតិទាក់ទិននឹងការបង្ការ ការកាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា ដែលបានប្រព្រឹត្តឡើងដោយនាវាបរទេសនៅហួសពីដែនសមុទ្ររបស់រដ្ឋដែលចាប់ផ្តើមដំណើរការក្តី ត្រូវបានផ្អាកនៅពេលមានការចាប់ផ្តើមដំណើរការក្តីដើម្បីដាក់ទណ្ឌកម្ម ទាក់ទិនទៅនឹងបន្ទុកដូចគ្នានោះដោយរដ្ឋចុះបញ្ជីនាវាក្នុងរវាងរយៈពេលប្រាំមួយខែបន្ទាប់ពីកាលបរិច្ឆេទដែលដំណើរការក្តីនោះបានចាប់ផ្តើមដំបូង លើកលែងតែដំណើរការក្តីទាំងនោះទាក់ទងទៅនឹងករណីការខូចខាតធ្ងន់ធ្ងរទៅលើរដ្ឋជាប់ឆ្នេរ ឬរដ្ឋចុះបញ្ជីនាវាដែលពាក់ព័ន្ធ មិនគោរពកាតព្វកិច្ចរបស់ខ្លួនម្តងហើយម្តងទៀតក្នុងការពង្រឹងប្រកបដោយប្រសិទ្ធភាពនូវវិធាន និងបទដ្ឋានអន្តរជាតិជាធរមាន ទាក់ទិនទៅនឹងការបំពានដែលបានប្រព្រឹត្តដោយនាវារបស់ខ្លួន។ រដ្ឋចុះបញ្ជីនាវាត្រូវផ្តល់យ៉ាងទាន់ពេលវេលាដល់រដ្ឋដែលបានចាប់ផ្តើមដំណើរការក្តីពីមុន នូវសំណុំរឿងពេញលេញនៃករណី និងកំណត់ត្រាស្តីពីដំណើរការក្តី នៅពេលណាដែលរដ្ឋចុះបញ្ជីនាវាបានស្នើសុំ ឱ្យមានការផ្អាកដំណើរការក្តី អនុលោមតាមមាត្រានេះ។ ក្នុងករណីដំណើរការក្តីដែលបានចាប់ផ្តើមឡើងដោយរដ្ឋចុះបញ្ជីនាវាត្រូវឈានដល់ការធ្វើសេចក្តីសន្និដ្ឋាន នោះដំណើរការក្តីដែលបានបានផ្អាកនឹងត្រូវបានបញ្ចប់។ នៅពេលដែលការចំណាយដែលបានកើតមានទាក់ទិនទៅនឹងដំណើរការក្តីនេះត្រូវបានទូទាត់រួចរាល់នោះ រដ្ឋជាប់ឆ្នេរត្រូវបង្វិលជូនវិញនូវប្រាក់ធានា ឬការធានាផ្នែកហិរញ្ញវត្ថុផ្សេងទៀតដែលបានផ្តល់ជូនទាក់ទិនទៅនឹងដំណើរការក្តីដែលបានផ្អាក។

២.  ដំណើរការក្តីដើម្បីដាក់ទណ្ឌកម្មលើនាវាបរទេសនឹងមិនត្រូវចាប់ផ្តើមទេ បន្ទាប់ពីផុតកំណត់បីឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការប្រព្រឹត្តការបំពាននោះ ហើយមិនត្រូវបានអនុវត្តដោយរដ្ឋណាមួយឡើយក្នុងករណីដំណើរការក្តីត្រូវបានចាប់ផ្តើមដោយរដ្ឋមួយផ្សេងទៀត អនុលោមទៅតាមបញ្ញត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១។

៣.	បទបញ្ញត្តិនៃមាត្រានេះ ដោយមិនប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋចុះបញ្ជីនាវាក្នុងការចាត់វិធានការនានា ត្រូវរួមបញ្ចូលទាំងដំណើរការក្តីដើម្បីដាក់ទណ្ឌកម្ម អនុលោមទៅតាមច្បាប់របស់ខ្លួន ដោយមិនគិតអំពីដំណើរការ ក្តីមុនៗដោយរដ្ឋមួយផ្សេងទៀតនោះទេ។

*មាត្រា ២២៩*

*ការចាប់ផ្តើមដំណើរការក្តីរដ្ឋប្បវេណី*

គ្មានចំណុចណាមួយក្នុងអនុសញ្ញានេះប៉ះពាល់ដល់ការចាប់ផ្តើមដំណើរការក្តីរដ្ឋប្បវេណី ទាក់ទិនទៅនឹង តវ៉ាទាមទារ នានានូវសំណងលើការបាត់បង់ ឬការខូចខាតដែលកើតចេញពីការបំពុលបរិស្ថានសមុទ្រឡើយ។

*មាត្រា ២៣០*

*ការផាកពិន័យជាប្រាក់ និងការគោរពសិទ្ធិ*

*បានទទួលស្គាល់របស់ចុងចម្លើយ*

១. ការផាកពិន័យជាប្រាក់អាចធ្វើឡើងតែទាក់ទិនទៅនឹងការបំពានលើច្បាប់ និងបទបញ្ញត្តិជាតិ ឬវិធាន និងបទដ្ឋានអន្តរជាតិជាធរមានដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ដែលបានប្រព្រឹត្តដោយនាវាបរទេសហួសពីដែនសមុទ្រប៉ុណ្ណោះ។

២. ការផាកពិន័យជាប្រាក់អាចធ្វើឡើងតែទាក់ទិនទៅនឹងការបំពានលើច្បាប់ និងបទបញ្ញត្តិជាតិ ឬវិធាន និងបទដ្ឋានអន្តរជាតិជាធរមានដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ដែលបានប្រព្រឹត្តដោយនាវាបរទេសហួសពីដែនសមុទ្រប៉ុណ្ណោះ បើមិនដូច្នេះទេលើកលែងតែក្នុងករណីដែលសកម្មភាពបំពុលក្នុងដែនសមុទ្រធ្វើឡើងដោយចេតនា និងមានសភាពធ្ងន់ធ្ងរ។

៣.

ក្នុងដំណើរការក្តីទាក់ទិនទៅនឹងការបំពានដែលបានប្រព្រឹត្តឡើងដោយនាវាបរទេសដែលអាចនាំទៅដល់ការដាក់ទណ្ឌកម្មទាំងនេះ សិទ្ធិដែលបានទទួលស្គាល់របស់ចុងបណ្តឹងត្រូវទទួលបានការគោរព។

*មាត្រា ២៣១*

*ការជូនដំណឹងទៅដល់រដ្ឋចុះបញ្ជីនាវា*

*និងបណ្តារដ្ឋផ្សេងទៀតដែលពាក់ព័ន្ធ*

បណ្តារដ្ឋត្រូវជូនដំណឹងភ្លាមៗដល់រដ្ឋចុះបញ្ជីនាវា និងរដ្ឋផ្សេងទៀតដែលពាក់ព័ន្ធអំពីវិធានការនានាដែលបានអនុវត្ត អនុលោមទៅតាមជំពូកទី ៦ លើនាវាបរទេស ហើយត្រូវដាក់ជូនទៅរដ្ឋចុះបញ្ជីនាវានូវរបាយការណ៍ទាំងអស់ដែលពាក់ព័ន្ធនឹងវិធានការទាំងនេះ។

ទោះបីជាយ៉ាងណា ទាក់ទិនទៅនឹងការបំពានដែលបានប្រព្រឹត្តក្នុងដែនសមុទ្រកាតព្វកិច្ចដែលបានចែងរបស់រដ្ឋជាប់ឆ្នេរត្រូវអនុវត្តតែទៅលើវិធានការទាំងនេះដែលបានអនុវត្តក្នុងដំណើរការក្តីប៉ុណ្ណោះ។ មន្ត្រីការទូត ឬ មន្ត្រីកុងស៊ុល និង តាមករណីដែលអាចអាជ្ញាធរសមុទ្ររបស់រដ្ឋចុះបញ្ជីនាវា ត្រូវជូនដំណឹងភ្លាមៗអំពីវិធានការនានាដែលបានអនុវត្តអនុលោមទៅតាមជំពូកទី ៦ ទៅលើនាវាបរទេស។

*មាត្រា ២៣២*

*បន្ទុករបស់បណ្តារដ្ឋកើតចេញពីវិធានការពង្រឹងច្បាប់*

បណ្តារដ្ឋត្រូវទទួលខុសត្រូវលើការខូចខាត ឬការបាត់បង់ដែលកើតមានចំពោះពួកគេចេញពីវិធានការដែលបានអនុវត្ត អនុលោមទៅតាមជំពូកទី ៦ ក្នុងករណីដែលវិធានការទាំងនេះមានលក្ខណៈមិនស្របច្បាប់ ឬលើសពីអ្វីដែលចាំបាច់យ៉ាងសមហេតុផល ផ្អែកតាមព័ត៌មានដែលទទួលបាន។ បណ្តារដ្ឋត្រូវសម្រួលឱ្យមានដំណើរការក្តីក្នុងតុលាការរបស់ខ្លួនសម្រាប់ករណីទាក់ទិនទៅនឹងការខូចខាត ឬ ការបាត់បង់ទាំងនេះ។

*មាត្រា ២៣៣*

*ការការពារទាក់ទិនទៅនឹងច្រកសមុទ្រ*

*ដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ*

គ្មានចំណុចណាមួយក្នុងជំពូកទី ៥ ៦ និង ៧ ប៉ះពាល់ដល់វិធានច្បាប់នៃច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ។ ទោះបីជាយ៉ាងណា ប្រសិនបើនាវាបរទេសក្រៅពីនាវាដែលលើកឡើងក្នុងជំពូកទី ១០ បានប្រព្រឹត្តបំពានច្បាប់

និងបទបញ្ញត្តិដែលលើកឡើងក្នុងមាត្រា ៤២ កថាខណ្ឌទី ១(ក) និង (ខ) ដែលបណ្ដាលឱ្យមាន ឬគំរាមកំហែងបង្ករឱ្យមានការខូចខាតធ្ងន់ធ្ងរដល់បរិស្ថានសមុទ្រនៃច្រកសមុទ្រ នោះបណ្ដារដ្ឋដែលមានព្រំប្រទល់ជាប់នឹងច្រកសមុទ្រអាចចាត់វិធានការសមស្របដើម្បីពង្រឹងច្បាប់ ហើយប្រសិនបើដូច្នេះ *ប្រសិនបើចាំបាច់* ត្រូវគោរពតាមបទបញ្ញត្តិនៃជំពូកនេះ។

## ជំពូកទី៨៖ តំបន់គ្របដណ្ដប់ដោយទឹកកក

*មាត្រា ២៣៤*

*តំបន់គ្របដណ្ដប់ដោយទឹកកក*

រដ្ឋជាប់ឆ្នេរមានសិទ្ធិរៀបចំ និងពង្រឹងដោយគ្មានការរើសអើងនូវច្បាប់ និងបទបញ្ញត្តិដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីនាវាក្នុងតំបន់គ្របដណ្ដប់ដោយទឹកកក នៅក្នុងព្រំដែននៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខ ដែលលក្ខខណ្ឌអាកាសធាតុមានសភាពធ្ងន់ធ្ងរជាពិសេស ហើយវត្តមាននៃទឹកកកដែលគ្របដណ្ដប់លើតំបន់នោះ ភាគច្រើនក្នុងមួយឆ្នាំៗ បង្កើតឱ្យមានឧបសគ្គ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ការធ្វើនាវាចរ ហើយការបំពុលបរិស្ថានសមុទ្រអាចបង្កឱ្យមាន គ្រោះថ្នាក់ធ្ងន់ៗ ឬការរំខានដែលមិនអាចកែតម្រូវបានចំពោះតុល្យភាពអេកូសាស្ត្រ។ ច្បាប់ និងបទបញ្ញត្តិទាំងនេះត្រូវធ្វើឡើងដោយពិចារណាយ៉ាងត្រឹមត្រូវទៅលើការនាវាចរ ព្រមទាំងការការពារ និងការថែរក្សាបរិស្ថានសមុទ្រ ផ្អែកទៅតាមភស្តុតាងជាលក្ខណៈវិទ្យាសាស្ត្រច្បាស់លាស់បំផុតដែលទទួលបាន។

## ជំពូកទី៩៖ ការទទួលខុសត្រូវ និងបន្ទុក

*មាត្រា ២៣៥*

*ការទទួលខុសត្រូវ និងបន្ទុក*

១.

បណ្តារដ្ឋត្រូវទទួលខុសត្រូវលើការបំពេញកាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួនពាក់ព័ន្ធនឹងការការពារ និងការថែរក្សាបរិស្ថានសមុទ្រ។ ពួកគេត្រូវត្រូវទទួលបន្ទុក អនុលោមតាមច្បាប់អន្តរជាតិ។

២. បណ្តារដ្ឋត្រូវធានាបានថា មានការសម្រួលអនុលោមតាមប្រព័ន្ធច្បាប់របស់ខ្លួនដល់ការព្យាយាម និងការផ្តល់សំណងពេញលេញ ឬដំណោះស្រាយផ្សេងទៀត ទាក់ទិនទៅនឹងការខូចខាតដោយសារការបំពុលបរិស្ថានសមុទ្រ ដោយរូបវ័ន្តបុគ្គល ឬនីតិបុគ្គល ក្រោមយុត្តាធិការរបស់ខ្លួន។

៣. ជាមួយនឹងគោលបំណងធានានូវការព្យាយាម និងការផ្តល់សំណងពេញលេញ ទាក់ទិនទៅនឹងការខូចខាតទាំងអស់ ដែលបណ្តាលមកពីការបំពុលបរិស្ថានសមុទ្រ បណ្តារដ្ឋត្រូវសហការគ្នាអនុវត្តច្បាប់អន្តរជាតិដែលមានស្រាប់ និងរៀបចំបន្ថែមទៀតនូវច្បាប់អន្តរជាតិទាក់ទិននឹងការទទួលខុសត្រូវ និងបន្ទុកលើការវាយតម្លៃអំពី និងអំពីការផ្តល់សំណងសម្រាប់ការខូចខាត និងការដោះស្រាយវិវាទដែលទាក់ទិន ក៏ដូចជាប្រសិនបើអាច ការរៀបចំលក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ការទូទាត់ការផ្តល់សំណងពេញលេញ ដូចជាការធានារ៉ាប់រងចាំបាច់ ឬ មូលនិធិប្រាក់សំណង។

## ជំពូកទី១០៖ អភ័យឯកសិទ្ធិរបស់រដ្ឋមានអធិបតេយ្យភាព

*មាត្រា ២៣៦*

*អភ័យឯកសិទ្ធិរបស់រដ្ឋមានអធិបតេយ្យភាព*

បទបញ្ញត្តិនៃអនុសញ្ញានេះ ទាក់ទិននឹងការការពារ និងការថែរក្សាបរិស្ថានសមុទ្រមិនអនុវត្តទៅលើនាវាចំបាំង បរិក្ខារលើនាវាចំបាំង នាវា ឬអាកាសយានផ្សេងទៀតដែលកាន់កាប់ ឬប្រតិបត្តិការដោយរដ្ឋ និងបានប្រើប្រាស់ ក្នុងពេលនោះ ក្នុងបុព្វហេតុបម្រើឱ្យរដ្ឋាភិបាលមិនមែនជាលក្ខណៈពាណិជ្ជកម្ម។ ទោះបីជាយ៉ាងណា រដ្ឋនីមួយៗត្រូវធានាបាននូវ តាមរយៈការរៀបចំនូវវិធានការសមស្របដោយមិនរំខានដល់ប្រតិបត្តិការ

ឬសមត្ថភាពប្រតិបត្តិការរបស់នាវា ឬ អាកាសយានដែលខ្លួនកាន់កាប់ ឬប្រតិបត្តិការទាំងនោះ ថានាវា ឬ អាកាសយានទាំងនេះប្រព្រឹត្តិទៅក្នុងលក្ខណៈមួយស្របតាមអនុសញ្ញានេះ ក្នុងវិសាលភាពមួយសមហេតុផល និងអាចអនុវត្តបាន។

ជំពូកទី១១៖ កាតព្វកិច្ចក្រោមអនុសញ្ញាផ្សេងទៀតស្តីពីការការពារនិងការថែរក្សាបរិស្ថានសមុទ្រ

*មាត្រា ២៣៧*

*កាតព្វកិច្ចក្រោមអនុសញ្ញាផ្សេងទៀតស្តីពី*
*ការការពារ និងការថែរក្សាបរិស្ថានសមុទ្រ*

១. បទបញ្ញត្តិនៃផ្នែកនេះ ដោយមិនប៉ះពាល់ដល់កាតព្វកិច្ចជាក់លាក់របស់បណ្តារដ្ឋនានាក្រោមអនុសញ្ញា និងកិច្ចព្រមព្រៀងពិសេសៗដែលធ្វើឡើងពីមុនមកទាក់ទងទៅនឹងការការពារ និងការថែរក្សាបរិស្ថានសមុទ្រ និងកិច្ចព្រមព្រៀងដែលអាចធ្វើឡើង ជាជំនួយដល់គោលការណ៍ទូទៅដែលបានកំណត់ក្នុងអនុសញ្ញានេះ។

២. កាតព្វកិច្ចជាក់លាក់របស់បណ្តារដ្ឋនានាក្រោមអនុសញ្ញាពិសេសៗ ទាក់ទិនទៅនឹងការការពារ និងការថែរក្សាបរិស្ថានសមុទ្រ ត្រូវអនុវត្តក្នុងលក្ខណៈមួយស្របតាមគោលការណ៍ទូទៅ និងគោលបំណងនៃអនុសញ្ញានេះ។

## ផ្នែកទី១៣៖ ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ

## ជំពូកទី១៖ បទបញ្ញត្តិទូទៅ

*មាត្រា ២៣៨*

*សិទ្ធិធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ*

បណ្តារដ្ឋទាំងអស់ ដោយមិនគិតអំពីទីតាំងភូមិសាស្ត្ររបស់ខ្លួន និងអង្គការអន្តរជាតិមានសមត្ថកិច្ចមានសិទ្ធិធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ អនុលោមទៅតាមសិទ្ធិ និងភារកិច្ចរបស់បណ្តារដ្ឋផ្សេងទៀតដូច មានចែងក្នុងអនុសញ្ញានេះ។

*មាត្រា ២៣៩*

*ការផ្សព្វផ្សាយអំពីការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ*

បណ្តារដ្ឋ និងអង្គការអន្តរជាតិមានសមត្ថកិច្ចត្រូវផ្សព្វផ្សាយ និងសម្រួលដល់ការរៀបចំ និងការធ្វើការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក្នុងសមុទ្រ អនុលោមតាមអនុសញ្ញានេះ។

*មាត្រា ២៤០*

*គោលការណ៍ទូទៅសម្រាប់ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក្នុងសមុទ្រ*

ក្នុងអនុវត្តការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក្នុងសមុទ្រ គោលការណ៍ខាងក្រោមត្រូវអនុវត្ត ៖

(ក) ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក្នុងសមុទ្រត្រូវធ្វើឡើងតែក្នុងគោលបំណងប្រកប ដោយសន្តិភាព ប៉ុណ្ណោះ។

(ខ)

ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក្នុងសមុទ្រត្រូវធ្វើឡើងតាមវិធីសាស្ត្រជាលក្ខណៈវិទ្យាសាស្ត្រ និងមធ្យោបានសមស្របស្របតាមអនុសញ្ញានេះ។

(គ)

ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក្នុងសមុទ្រមិនត្រូវមានការរំខានដោយមិនសមហេតុផលដល់ការប្រើ ប្រាស់សមុទ្រជាលក្ខណៈស្របច្បាប់ផ្សេងទៀត ស្របតាមអនុសញ្ញានេះ និងត្រូវបានគោរពយ៉ាង ត្រឹមត្រូវក្នុងរយៈពេលនៃការប្រើប្រាស់នេះ។

(ឃ)

ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក្នុងសមុទ្រត្រូវធ្វើឡើងអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធទាំងអស់ ដែលរៀបចំឡើងស្របតាមអនុសញ្ញានេះ ដែលរួមមានបទបញ្ញត្តិស្តីពីការការពារ និងការថែរក្សា បរិស្ថានសមុទ្រផងដែរ។

*មាត្រា ២៤១*

*ការមិនទទួលស្គាល់ការប្រើប្រាស់សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ*
*ជាមូលដ្ឋានច្បាប់សម្រាប់បណ្តឹងទាមទារ*

សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ មិនត្រូវបង្កើតជាមូលដ្ឋានច្បាប់សម្រាប់បណ្តឹងទាមទារផ្នែកណាមួយនៃបរិស្ថានសមុទ្រ ឬធនធានរបស់វានោះឡើយ។

## ជំពូកទី២៖ កិច្ចសហប្រតិបត្តិការអន្តរជាតិ

*មាត្រា ២៤២*

*ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ*

១. រដ្ឋ និងអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ត្រូវជំរុញលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុង ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រក្នុងគោលបំណងសន្តិភាព ស្របតាមគោលការណ៍គោរពអធិបតេយ្យភាព និងយុត្តាធិការ និងដោយផ្អែកលើផលប្រយោជន៍រួម។

២. នៅក្នុងបរិបទនេះ បណ្តារដ្ឋត្រូវផ្តល់ឱ្យគ្នាទៅវិញទៅមកឱ្យបានសមស្រប នូវឱកាសសមរម្យក្នុងការទទួល បានកិច្ចសហប្រតិបត្តិការពីគ្នា និងព័ត៌មានដែលចាំបាច់ ដើម្បីបង្ការទប់ស្កាត់ផលប៉ះពាល់ចំពោះសុខភាព និងសុវត្ថិភាព របស់មនុស្ស និងបរិស្ថានសមុទ្រ។

*មាត្រា ២៤៣*

*ការបង្កើតលក្ខខណ្ឌអនុគ្រោះ*

រដ្ឋ និងអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ត្រូវចូលរួមក្នុងកិច្ចសហការប្រតិបត្តិការតាមរយៈការចុះកិច្ច ព្រមព្រៀងទ្វេភាគី និងពហុភាគី ដើម្បីបង្កើតនូវលក្ខខណ្ឌអនុគ្រោះសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ នៅក្នុងបរិស្ថានសមុទ្រ និងដើម្បីធ្វើសមាហរណកម្មកិច្ចខិតខំប្រឹងប្រែងរបស់អ្នកវិទ្យាសាស្ត្រនៅក្នុងការសិក្សាអំពី លក្ខណៈនៃបាតុភូត និងដំណើរការដែលកំពុងកើតឡើងនៅក្នុងបរិស្ថានសមុទ្រ និងអំពីភាពទំនាក់ទំនងគ្នាទៅវិញទៅ មករវាងពួកវា។

*មាត្រា ២៤៤*

*ការបោះពុម្ព និងផ្សព្វផ្សាយព័ត៌មាន និងចំណេះដឹង*

១. រដ្ឋ និងអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ត្រូវជំរុញឱ្យមានការបោះពុម្ព និងការផ្សព្វផ្សាយព័ត៌មានអំពី សំណើអនុវត្តកម្មវិធីសំខាន់ៗ និងកម្មវត្ថុនៃសំណើទាំងនោះ

ព្រមទាំងចំណេះដឹងដែលបានមកពីការស្រាវជ្រាវវិទ្យា-សាស្ត្រអំពីសមុទ្រ តាមរយៈមធ្យោបាយដែលសមស្រប។

២. សម្រាប់គោលបំណងនេះ រដ្ឋត្រូវធ្វើការជំរុញឱ្យមានភាពសកម្មដោយខ្លួនឯងផ្ទាល់ និងដោយសហការ ជាមួយរដ្ឋផ្សេងៗ និងជាមួយអង្គការអន្តរជាតិដែលមានសមត្ថកិច្ច នូវលំហូទិន្នន័យ និងព័ត៌មានវិទ្យាសាស្ត្រ និង ការផ្ទេរចំណេះដឹង ដែលបានមកពីការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ជាពិសេសទៅដល់បណ្តារដ្ឋកំពុងអភិវឌ្ឍន៍ ព្រមទាំងពង្រឹងសមត្ថភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដោយស្វយតភាពរបស់រដ្ឋកំពុងអភិវឌ្ឍន៍ ដូចជាតាមរយៈ កម្មវិធីផ្តល់ការអប់រំ និងបណ្តុះបណ្តាលដល់បុគ្គលិកផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសរបស់រដ្ឋទាំងនោះឱ្យបានគ្រប់គ្រាន់។

## ជំពូកទី៣៖ ការអនុវត្ត និងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ

*មាត្រា ២៤៥*

*ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងដែនសមុទ្រ*

នៅក្នុងការអនុវត្តសិទ្ធិអធិបតេយ្យភាពរបស់ខ្លួន រដ្ឋជាប់ឆ្នេរមានសិទ្ធិផ្តាច់មុខក្នុងការគ្រប់គ្រង អនុញ្ញាត និងអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងដែនសមុទ្ររបស់ខ្លួន។ រាល់ការស្រាវជ្រាវវិទ្យាសាស្ត្រអំពី សមុទ្រនៅក្នុងដែនសមុទ្ររបស់រដ្ឋជាប់ឆ្នេរ ត្រូវមានការអនុញ្ញាតច្បាស់លាស់ និងស្ថិតក្រោមលក្ខខណ្ឌកំណត់ របស់រដ្ឋជាប់ឆ្នេរនោះ។

*មាត្រា ២៤៦*

*ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុង តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ*

១. នៅក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួន រដ្ឋជាប់ឆ្នេរមានសិទ្ធិក្នុងការគ្រប់គ្រង ផ្ដល់ការអនុញ្ញាត និងអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ នៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ខ្លួន និងនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ដោយអនុលោមតាមបទបញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ។

២. ការអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ និងនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ ត្រូវមានការអនុញ្ញាតពីរដ្ឋជាប់ឆ្នេរ។

៣. នៅក្នុងកាលៈទេសៈធម្មតា រដ្ឋជាប់ឆ្នេរត្រូវផ្ដល់ការអនុញ្ញាតរបស់ខ្លួនសម្រាប់គម្រោងស្រាវជ្រាវ វិទ្យាសាស្ត្រអំពីសមុទ្ររបស់រដ្ឋដទៃ ឬរបស់អង្គការអន្តរជាតិមានសមត្ថកិច្ចនៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ខ្លួន និងនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ដែលនឹងត្រូវអនុវត្តស្របតាមអនុសញ្ញានេះតែសម្រាប់គោលបំណងសន្តិភាព និង ដើម្បីបង្កើនចំណេះដឹងវិទ្យាសាស្ត្រអំពីបរិស្ថានសមុទ្រសម្រាប់បម្រើផលប្រយោជន៍មនុស្សជាតិទាំងអស់។ សម្រាប់ គោលបំណងនេះ រដ្ឋជាប់ឆ្នេរត្រូវបង្កើតវិធាន និងនីតិវិធីដើម្បីធានាថានឹងពុំមានការពន្យារពេល ឬការបដិសេធ មិនផ្ដល់ការអនុញ្ញាតដោយគ្មានហេតុផលសមស្របនោះទេ។

៤. សម្រាប់គោលបំណងនៃការអនុវត្តកថាខណ្ឌទី ៣ ខាងលើ កាលៈទេសៈធម្មតាក៏អាចនឹងមានផងដែរ ទោះ បីជារដ្ឋជាប់ឆ្នេរ និងរដ្ឋស្រាវជ្រាវ គ្មានទំនាក់ទំនងការទូតជាមួយគ្នាក៏ដោយ។

៥. ទោះជាយ៉ាងណាក្ដី រដ្ឋជាប់ឆ្នេរមានសិទ្ធិសម្រេចមិនផ្ដល់ការអនុញ្ញាតរបស់ខ្លួនសម្រាប់គម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្ររបស់រដ្ឋដទៃ ឬរបស់អង្គការអន្តរជាតិមានសមត្ថកិច្ច នៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ និងនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ប្រសិនបើគម្រោងនោះ ៖

- (ក) គឺសម្រាប់តែគោលបំណងរុករក និងធ្វើអាជីវកម្មធនធានធម្មជាតិ មិនថាធនធានមានជីវិត ឬធនធានគ្មានជីវិតដោយផ្ទាល់។
- (ខ) មានការខួងចូលតំបន់ខ្ពង់រាបបាតសមុទ្រ ការប្រើប្រាស់គ្រឿងផ្ទុះ ឬការបញ្ចូលសារធាតុគ្រោះថ្នាក់ទៅ ក្នុងបរិស្ថានសមុទ្រ។

(គ) មានការសាងសង់ ការប្រតិបត្តិការ ឬការប្រើប្រាស់កោះសិប្បនិម្មិត បបនភណ្ឌ និងរចនាសម្ព័ន្ធ ដែលមានចែងនៅក្នុងមាត្រា ៦០ និងមាត្រា ៨០ ។

(ឃ) មានព័ត៌មានដែលត្រូវបានជូនដំណឹងស្របតាមមាត្រា ២៤៨ ពាក់ព័ន្ធនឹងលក្ខណៈ និងកម្មវត្ថុនៃគម្រោងដែលពុំមានភាពច្បាស់លាស់ ឬប្រសិនបើរដ្ឋស្រាវជ្រាវ ឬអង្គការអន្តរជាតិមានសមត្ថកិច្ច នោះមានកាតព្វកិច្ចត្រូវអនុវត្តចំពោះរដ្ឋជាប់ឆ្នេរដែលបន្សល់ទុកពីគម្រោងស្រាវជ្រាវមុនៗ។

៦. ទោះបីជាមានបទបញ្ញត្តិចែងដូចក្នុងកថាខណ្ឌទី ៥ រដ្ឋជាប់ឆ្នេរមិនអាចអនុវត្តសិទ្ធិសម្រេចរបស់ខ្លួន ក្នុងការមិនផ្តល់ការអនុញ្ញាតតាមកថាខណ្ឌរង (ក) នៃកថាខណ្ឌនោះ ពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រ អំពីសមុទ្រ ដែលនឹងត្រូវអនុវត្តស្របតាមបទបញ្ញត្តិនៃផ្នែកនេះ នៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្រដែលមានចម្ងាយលើសពី ២០០ ម៉ៃល៍សមុទ្រ គិតចាប់ពីខ្សែបន្ទាត់មូលដ្ឋាននៃរង្វាស់ផ្ទៃទទឹងសមុទ្រ នៅខាងក្រៅតំបន់ជាក់លាក់ដែល រដ្ឋជាប់ឆ្នេរអាចកំណត់ជាសាធារណៈថាជាតំបន់ដែលមានការធ្វើអាជីវកម្មធនធាន ឬមានប្រតិបត្តិការរុករកលម្អិតកំពុងកើតឡើង ឬនឹងកើតឡើងនៅក្នុងរយៈពេលសមស្រប។ រដ្ឋជាប់ឆ្នេរត្រូវជូនដំណឹងឱ្យបានសមស្រប អំពីការកំណត់តំបន់ទាំងនោះ ព្រមទាំងអំពីការកែប្រែណាមួយ ប៉ុន្តែមិនមានកាតព្វកិច្ចផ្តល់ព័ត៌មានលម្អិតអំពី ប្រតិបត្តិការដែលមាននៅក្នុងតំបន់ទាំងនោះទេ។

៧. បទបញ្ញត្តិនៃកថាខណ្ឌទី៦ មិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរលើតំបន់ខ្ពង់រាបបាតសមុទ្រ ដែលបង្កើតឡើងក្រោមមាត្រា ៧៧ ឡើយ។

៨. សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដែលមានចែងក្នុងមាត្រានេះ ទោះជាដោយប្រការណាក៏ដោយ មិនត្រូវបង្កការរំខានទៅលើសកម្មភាពរបស់រដ្ឋជាប់ឆ្នេរនៅក្នុងការអនុវត្តសិទ្ធិអធិបតេយ្យភាព និង យុត្តាធិការរបស់ខ្លួនដែលមានចែងនៅក្នុងអនុសញ្ញានេះឡើយ។

*មាត្រា ២៤៧*

*គម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដែលអនុវត្ត*

*ដោយ ឬស្ថិតក្រោមការឧបត្ថម្ភពីអង្គការអន្តរជាតិ*

រដ្ឋជាប់ឆ្នេរដែលជាសមាជិកអង្គការអន្តរជាតិ ឬបានចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយអង្គការអន្តរជាតិ ហើយអង្គការនោះចង់អនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដោយខ្លួនឯងផ្ទាល់ ឬតាមរយៈការជួយឧបត្ថម្ភនៅ ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្ររបស់រដ្ឋនោះ នឹងត្រូវចាត់ទុកថាបានផ្តល់ការអនុញ្ញាតឱ្យអនុវត្ត គម្រោងនោះស្របតាមលក្ខខណ្ឌជាក់លាក់ដែលបានព្រមព្រៀង ប្រសិនបើរដ្ឋនោះបានអនុម័តគម្រោងលម្អិតនៅពេល ដែលអង្គការបានសម្រេចចិត្តអនុវត្តគម្រោង ឬមានឆន្ទៈចូលរួមក្នុងគម្រោង និងមិនបានជំទាស់នៅក្នុងរយៈពេល បួនខែ គិតចាប់ពីពេលដែលអង្គការបានជូនដំណឹងឱ្យរដ្ឋជាប់ឆ្នេរនោះបានជ្រាបអំពីគម្រោងទេនោះ។

*មាត្រា ២៤៨*

*ភារកិច្ចផ្តល់ព័ត៌មានដល់រដ្ឋជាប់ឆ្នេរ*

រដ្ឋ និងអង្គការអន្តរជាតិមានសមត្ថកិច្ច ដែលមានបំណងអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុង តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្ររបស់រដ្ឋជាប់ឆ្នេរ ត្រូវរៀបចំដោយលម្អិតអំពីចំណុចខាង ក្រោម នៅក្នុងរយៈពេលមិនលើសពីប្រាំមួយខែ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមអនុវត្តគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រ អំពីសមុទ្រ៖

(ក) លក្ខណៈ និងកម្មវត្ថុនៃគម្រោង ។

(ខ) វិធីសាស្ត្រ និងមធ្យោបាយដែលប្រើប្រាស់ រាប់បញ្ចូលទាំងឈ្មោះ ទម្ងន់ ប្រភេទ និងចំណាត់ថ្នាក់នៃនាវា និងសេចក្តីបរិយាយអំពីបរិក្ខារវិទ្យាសាស្ត្រ។

(គ) តំបន់ភូមិសាស្ត្រជាក់លាក់ដែលគម្រោងនឹងត្រូវអនុវត្ត។

(ឃ) កាលបរិច្ឆេទរំពឹងទុកអំពីការមកដល់ដំបូង និងការចាកចេញចុងក្រោយរបស់នាវា ឬការដាក់ ពង្រាយ និងការរុះរើបរិក្ខារតាមករណីដែលសមស្រប ។

(ង) ឈ្មោះស្ថាប័នដែលគាំទ្រ ប្រធានស្ថាប័ន និងបុគ្គលទទួលខុសត្រូវលើគម្រោង។

(ច) វិសាលភាពដែលកំណត់ថា រដ្ឋជាប់ឆ្នេរមួយឃួអាចនឹងចូលរួម ឬឱ្យគេតំណាងខ្លួននៅក្នុងគម្រោង ។

*មាត្រា ២៤៩*

*ភារកិច្ចគោរពតាមលក្ខខណ្ឌជាក់លាក់*

នៅពេលអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្ររបស់រដ្ឋជាប់ឆ្នេរ រដ្ឋ និងអង្គការអន្តរជាតិមានសមត្ថកិច្ច ត្រូវគោរពតាមលក្ខខណ្ឌខាងក្រោម៖

(ក) ធានានូវការគោរពសិទ្ធិរបស់រដ្ឋជាប់ឆ្នេរ តាមដែលរដ្ឋមានបំណងដូច្នោះ ក្នុងការចូលរួម ឬឱ្យគេ តំណាងខ្លួន នៅក្នុងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ជាពិសេសការឡើងលើនាវា ស្រាវជ្រាវ និងអាកាសយាន ឬបនភណ្ឌស្រាវជ្រាវផ្សេងៗ ផ្អែកតាមស្ថានភាពជាក់ស្តែងដោយពុំចាំបាច់បង់លាភការដល់អ្នកវិទ្យាសាស្ត្រនៃរដ្ឋជាប់ឆ្នេរ និងដោយពុំចាំបាច់មានកាតព្វកិច្ច ជួយចេញការចំណាយនៃគម្រោង។

(ខ) ផ្តល់របាយការណ៍បឋមឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន និងលទ្ធផល ព្រមទាំងសេចក្តីសន្និដ្ឋានចុងក្រោយ ក្រោយពេលបញ្ចប់ការងារស្រាវជ្រាវ ជូនដល់រដ្ឋជាប់ឆ្នេរតាមសំណើ។

(គ) យល់ព្រមផ្តល់លទ្ធភាពដល់រដ្ឋជាប់ឆ្នេរទទួលបានរាល់ទិន្នន័យ និងវត្ថុវិភាគដែលបានមកពី គម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រតាមសំណើ និងផ្តល់ឱ្យរដ្ឋជាប់ឆ្នេរនូវទិន្នន័យដែល អាចនឹងថតចម្លង និងសំណាកដែលអាចនឹងបែងចែក ដោយពុំនាំឱ្យប៉ះពាល់ដល់តម្លៃវិទ្យាសាស្ត្រនៃទិន្នន័យ និងសំណាកទាំងនោះ។

(ឃ) ប្រសិនបើមានសំណើ ត្រូវផ្តល់ឱ្យរដ្ឋជាប់ឆ្នេរនូវការវាយតម្លៃលើទិន្នន័យ សំណាក និងលទ្ធផល ស្រាវជ្រាវ ឬផ្តល់ជំនួយនៅក្នុងការវាយតម្លៃ និងការបកស្រាយ។

(ង) ធានាដោយអនុលោមតាមកថាខណ្ឌទី ២ ថា លទ្ធផលស្រាវជ្រាវត្រូវបានផ្សព្វផ្សាយជាអន្តរជាតិ តាមរយៈបណ្តាញជាតិ ឬអន្តរជាតិ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន។

(ច) ជូនដំណឹងដល់រដ្ឋជាប់ឆ្នេរជាបន្ទាន់អំពីរាល់ការផ្លាស់ប្តូរនៅក្នុងកម្មវិធីស្រាវជ្រាវ ។

(ឆ) រុះរើបបនភណ្ឌ ឬបរិក្ខារស្រាវជ្រាវវិទ្យាសាស្ត្រ នៅពេលដែលការស្រាវជ្រាវបានបញ្ចប់ លើកលែងតែមានការព្រមព្រៀងផ្ទុយពីនេះ។

២. មាត្រានេះពុំប៉ះពាល់ដល់លក្ខខណ្ឌដែលបង្កើតឡើងដោយច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋជាប់ឆ្នេរសម្រាប់ ការអនុវត្តនូវសិទ្ធិសម្រេចរបស់ខ្លួននៅក្នុងការផ្តល់ ឬមិនផ្តល់ការអនុញ្ញាតតាមមាត្រា ២៤៦ កថាខណ្ឌទី ៥ រួមបញ្ចូលទាំងការតម្រូវឱ្យមានកិច្ចព្រមព្រៀងជាមុន សម្រាប់ការផ្សព្វផ្សាយជាអន្តរជាតិនូវលទ្ធផលស្រាវជ្រាវគម្រោង ដែលមានគោលបំណងតែសម្រាប់ការរុករក និងធ្វើអាជីវកម្មធនធានធម្មជាតិដោយផ្ទាល់ឡើយ។

*មាត្រា ២៥០*

*ការទំនាក់ទំនងដែលពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ*

រាល់ការទំនាក់ទំនងពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ត្រូវធ្វើឡើងតាមរយៈមធ្យោបាយ ជាផ្លូវការដែលសមស្រប លើកលែងតែមានការព្រមព្រៀងគ្នាផ្ទុយពីនេះ។

*មាត្រា ២៥១*

*លក្ខខណ្ឌវិនិច្ឆ័យ និងសេចក្តីណែនាំទូទៅ*

រដ្ឋត្រូវខិតខំជំរុញការបង្កើតនូវលក្ខខណ្ឌ និងសេចក្តីណែនាំទូទៅ ដើម្បីជួយដល់រដ្ឋនៅក្នុងការស្វែងយល់អំពី លក្ខណៈ និងភាពស្មុគស្មាញនៃការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ តាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ច។

*មាត្រា ២៥២*

*ការចាត់ទុកថាមានការអនុញ្ញាត*

រដ្ឋ ឬអង្គការអន្តរជាតិមានសមត្ថកិច្ច អាចដំណើរការគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្របានក្នុង រយៈពេលប្រាំមួយខែគិតចាប់ពីថ្ងៃដែលផ្តល់ព័ត៌មានតាមការតម្រូវក្រោមមាត្រា ២៤៨ ទៅដល់រដ្ឋជាប់ឆ្នេរ លើកលែងតែរដ្ឋជាប់ឆ្នេរបានជូនដំណឹងដល់រដ្ឋ ឬអង្គការដែលធ្វើការស្រាវជ្រាវនោះឱ្យបានជ្រាបវិញនៅក្នុងរយៈពេលបួនខែក្រោយពីខ្លួនបានទទួលព័ត៌មានទាំងនោះថា៖

(ក) ខ្លួនមិនផ្តល់ការអនុញ្ញាតជូនតាមមាត្រា ២៤៦ ទេ ។ ឬ

(ខ) ព័ត៌មានដែលផ្តល់ដោយរដ្ឋ ឬអង្គការអន្តរជាតិពាក់ព័ន្ធនឹងលក្ខណៈ ឬកម្មវត្ថុនៃគម្រោង មិនសមស្របនឹងសក្ខីកម្មជាក់ស្តែង។ ឬ

(គ) ខ្លួនត្រូវការព័ត៌មានបន្ថែមពាក់ព័ន្ធនឹងលក្ខខណ្ឌ និងព័ត៌មានដែលមានចែងនៅក្នុងមាត្រា ២៤៨ និងមាត្រា ២៤៩ ។ ឬ

(ឃ) នៅមានកាតព្វកិច្ចត្រូវអនុវត្តនៅឡើយ ពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រលើកមុនដែលរដ្ឋ ឬអង្គការនោះបានអនុវត្តកន្លងមក ពាក់ព័ន្ធនឹងលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ២៤៩ ។

*មាត្រា ២៥៣*

*ការផ្អាក ឬការបញ្ឈប់សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ*

១. រដ្ឋជាប់ឆ្នេរមានសិទ្ធិទាមទារឱ្យមានការផ្អាកសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដែលកំពុង ដំណើរការនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន និងនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ប្រសិនបើៈ

(ក) សកម្មភាពស្រាវជ្រាវទាំងនោះ មិនកំពុងត្រូវបានអនុវត្ត ស្របតាមព័ត៌មានដែលបានផ្តល់ជូន ដូចមានចែងនៅក្នុងមាត្រា ២៤៨ ដែលតម្រូវឱ្យមានការអនុញ្ញាតពីរដ្ឋជាប់ឆ្នេរ។

(ខ) រដ្ឋ ឬអង្គការអន្តរជាតិមានសមត្ថកិច្ចដែលអនុវត្តសកម្មភាពស្រាវជ្រាវទាំងនោះ ពុំបានគោរពតាម បទបញ្ញត្តិនៃមាត្រា ២៤៩ ស្តីពីសិទ្ធិរបស់រដ្ឋជាប់ឆ្នេរទៅលើគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ។

២. រដ្ឋជាប់ឆ្នេរមានសិទ្ធិទាមទារឱ្យមានការបញ្ឈប់សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ក្នុងករណីមានការបំពានលើបទបញ្ញត្តិនៃមាត្រា ២៤៨ ដែលនាំឱ្យមានការប្រែប្រួលគួរកត់សម្គាល់នៃគម្រោងស្រាវជ្រាវ ឬសកម្មភាពស្រាវជ្រាវ។

៣.

រដ្ឋជាប់ឆ្នេរក៏អាចទាមទារឱ្យមានការបញ្ឈប់សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្របានផងដែរ ប្រសិនបើពុំមានការកែតម្រូវស្ថានភាពដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ នៅក្នុងរយៈពេលសមស្របទនោះ។

៤. ក្រោយពីរដ្ឋជាប់ឆ្នេរបានជូនដំណឹងអំពីការសម្រេចចិត្តឱ្យផ្អាក ឬបញ្ឈប់សកម្មភាពស្រាវជ្រាវរដ្ឋ ឬអង្គការអន្តរជាតិមានសមត្ថកិច្ចដែលត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ត្រូវបញ្ចប់សកម្មភាពស្រាវជ្រាវដែលជាកម្មវត្ថុនៃការជូនដំណឹង។

៥. រដ្ឋជាប់ឆ្នេរត្រូវដកបញ្ហាឱ្យផ្អាកក្រោមកថាខណ្ឌទី ១ ខាងលើវិញ ហើយសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ នឹងត្រូវអនុញ្ញាតឱ្យបន្តដំណើរការវិញ នៅពេលដែលរដ្ឋ ឬអង្គការអន្តរជាតិមានសមត្ថកិច្ច ដែលអនុវត្តការស្រាវជ្រាវនោះ បានគោរពតាមលក្ខខណ្ឌដែលតម្រូវក្រោមមាត្រា ២៤៨ និងមាត្រា ២៤៩ ។

*មាត្រា ២៥៤*

*សិទ្ធិរបស់រដ្ឋក្បែរខាងដែលហ៊ុំព័ទ្ធដោយដីគោក*

*និងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល*

១. រដ្ឋ ឬអង្គការអន្តរជាតិមានសមត្ថកិច្ច ដែលបានដាក់សំណើសុំអនុវត្តគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រ អំពីសមុទ្រទៅកាន់រដ្ឋជាប់ឆ្នេរ ដូចមានចែងនៅក្នុងមាត្រា ២៤៦ កថាខណ្ឌទី ៣ ត្រូវជូនដំណឹងដល់រដ្ឋក្បែរខាង ដែលហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋមានភូមិសាស្ត្រមិនអំណោយផលស្តីពីសំណើអនុវត្តគម្រោងស្រាវជ្រាវនោះ ហើយត្រូវជូនដំណឹងដល់រដ្ឋជាប់ឆ្នេរអំពីការជូនដំណឹងនេះផងដែរ។

២.

ក្រោយពីរដ្ឋជាប់ឆ្នេរដែលពាក់ព័ន្ធបានផ្តល់ការអនុញ្ញាតទៅលើសំណើសុំអនុវត្តគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដូចមានចែងនៅក្នុងមាត្រា ២៤៥ និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងៗនៃអនុសញ្ញានេះ រដ្ឋ និង អង្គការអន្តរជាតិដែលអនុវត្តគម្រោង ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធដែលមានចែងនៅក្នុងមាត្រា ២៤៨ និងមាត្រា ២៤៩ កថាខណ្ឌទី ១ (ច) ទៅដល់បណ្តារដ្ឋក្បែរដែលខាងហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល តបតាមសំណើ របស់ពួកគេ នៅពេលដែលសមស្រប។

៣. បណ្តារដ្ឋក្បែរដែលខាងហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល នឹងត្រូវបានផ្តល់ឱកាសឱ្យ ចូលរួមតបតាមសំណើរបស់ខ្លួន (នៅពេលដែលអាចធ្វើទៅបាន) នៅក្នុងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដែលបានស្នើឡើងតាមរយៈអ្នកជំនាញការមានគុណវុឌ្ឍិដែលរដ្ឋទាំងនោះបានចាត់តាំងឡើង និងដោយគ្មានការជំទាស់ពីរដ្ឋជាប់ឆ្នេរ ស្របតាមលក្ខខណ្ឌដែលរដ្ឋជាប់ឆ្នេរពាក់ព័ន្ធ និងរដ្ឋ ឬអង្គការអន្តរជាតិមានសមត្ថកិច្ច ដែលអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ បានព្រមព្រៀងគ្នាឡើងសម្រាប់គម្រោងនោះ ដោយអនុលោម តាមបទបញ្ញត្តិនៃគម្រោងនេះ។

៤. រដ្ឋ ឬអង្គការអន្តរជាតិមានសមត្ថកិច្ច ដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តល់ព័ត៌មាន និងជំនួយដែលមានចែងនៅក្នុងមាត្រា ២៤៩ កថាខណ្ឌទី ១(ឃ) ជូនដល់រដ្ឋក្បែរខាងហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋមានភូមិសាស្ត្រ មិនអំណោយផល តបតាមសំណើរបស់ពួកគេ ដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រា ២៤៩ កថាខណ្ឌទី ២ ។

*មាត្រា ២៥៥*

*វិធានការដើម្បីសម្របសម្រួលការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ*

*និងដើម្បីជួយនាវាស្រាវជ្រាវ*

បណ្តារដ្ឋត្រូវខិតខំប្រឹងប្រែងអនុវត្តវិធាន បទបញ្ញត្តិ និងនីតិវិធីដែលសមស្របដើម្បីជំរុញ និងសម្របសម្រួល

ការងារស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដែលត្រូវបានអនុវត្តស្របតាមអនុសញ្ញានេះនៅក្រៅដែនសមុទ្ររបស់ខ្លួន និងផ្តល់ការសម្របសម្រួលឱ្យបានសមស្របតាមបញ្ញត្តិនៃច្បាប់ និងបទបញ្ញត្តិរបស់ខ្លួន នូវលទ្ធភាពចូលចតនៅកំពង់ផែរបស់ខ្លួន និងជំរុញការងារផ្តល់ជំនួយសម្រាប់នាវាស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដែលបានគោរពតាមបទបញ្ញត្តិពាក់ព័ន្ធនៃផ្នែកនេះ។

*មាត្រា ២៥៦*

*ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់*

ដោយពុំគិតអំពីទីតាំងភូមិសាស្ត្រ រដ្ឋទាំងអស់ និងអង្គការអន្តរជាតិមានសមត្ថកិច្ចមានសិទ្ធិអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់ដោយអនុលោមតាមបទបញ្ញត្តិនៃផ្នែកទី ១១។

*មាត្រា ២៥៧*

*ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងដែនទឹក*

*ខាងក្រៅតំបន់សេដ្ឋកិច្ចផ្តាច់មុខ*

ដោយពុំគិតអំពីទីតាំងភូមិសាស្ត្រ រដ្ឋទាំងអស់ និងអង្គការអន្តរជាតិមានសមត្ថកិច្ច មានសិទ្ធិអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងដែនទឹកខាងក្រៅដែនកំណត់នៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដោយអនុលោមតាមបទបញ្ញត្តិនៃអនុសញ្ញានេះ។

ជំពូកទី៤៖ បបនកណ្ឌា ឬបរិក្ខារស្រាវជ្រាវវិទ្យាសាស្ត្រនៅក្នុងបរិស្ថានសមុទ្រ

*មាត្រា ២៥៨*

*ការពង្រាយ និង ការប្រើប្រាស់*

ការពង្រាយ និងការប្រើប្រាស់ប្រភេទបបនកណ្ឌា ឬបរិក្ខារស្រាវជ្រាវវិទ្យាសាស្ត្រនៅក្នុងតំបន់ណាមួយនៃ បរិស្ថានសមុទ្រនឹងត្រូវគោរពតាមលក្ខខណ្ឌតែមួយដូចដែលបានកំណត់នៅក្នុងអនុសញ្ញានេះ សម្រាប់ការអនុវត្តការ ស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់ទាំងនោះផងដែរ។

*មាត្រា ២៥៩*

*ស្ថានភាពគតិយុត្តិ*

បំបនភណ្ឌ ឬបរិក្ខារដែលចែងនៅក្នុងជំពូកនេះ មានភាពខុសគ្នានឹងកោះ។ បំបនភណ្ឌ ឬបរិក្ខារទាំងនោះ មិនមានដែនសមុទ្រផ្ទាល់នោះទេ ហើយវត្តមានរបស់ពួកវា ក៏មិននាំឱ្យប៉ះពាល់ដល់ការបង្កើតព្រំនៃដែនសមុទ្រ តំបន់សេដ្ឋកិច្ចផ្ដាច់មុខ ឬតំបន់ខ្ពង់រាបបាតសមុទ្រនោះដែរ។

*មាត្រា ២៦០*

*តំបន់សុវត្ថិភាព*

តំបន់សុវត្ថិភាពដែលមានទំហំសមស្របមិនលើសពីចម្ងាយ ៥០០ ម៉ែត្រ អាចនឹងត្រូវបង្កើតឡើងនៅជុំវិញបំបនភណ្ឌស្រាវជ្រាវវិទ្យាសាស្ត្រ ស្របតាមបទបញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ។ រដ្ឋទាំងអស់ត្រូវធានាថា តំបន់សុវត្ថិភាពទាំងនេះ ត្រូវបានគោរពដោយនាវាទាំងឡាយ។

*មាត្រា ២៦១*

*ការមិនរំខានដល់ផ្លូវនាវាចរណ៍*

ការពង្រាយ និងការប្រើប្រាស់ប្រភេទបំបនភណ្ឌ ឬបរិក្ខារស្រាវជ្រាវវិទ្យាសាស្ត្រ មិនត្រូវបង្កើតជាឧបសគ្គណាមួយចំពោះផ្លូវនាវាចរណ៍អន្តរជាតិដែលត្រូវបានបង្កើតឡើងនោះទេ។

*មាត្រា ២៦២*

*សញ្ញាសម្គាល់ និងសញ្ញាព្រមាន*

បរិក្ខារ ឬបរិក្ខារដែលចែងនៅក្នុងជំពូកនេះ ត្រូវមានសញ្ញាសម្គាល់ដែលបង្ហាញពីរដ្ឋចុះបញ្ជី ឬអង្គការ អន្តរជាតិជាម្ចាស់កម្មសិទ្ធិ និងត្រូវមានសញ្ញាព្រមានដែលបានព្រមព្រៀងគ្នាជាអន្តរជាតិឱ្យបានគ្រប់គ្រាន់ ដើម្បីធានាសុវត្ថិភាពនៅក្នុងសមុទ្រ និងសុវត្ថិភាពនៃចរាចរណ៍ផ្លូវអាកាស ដោយពិចារណាទៅលើវិធាន និងបទដ្ឋានកំណត់របស់ អង្គការអន្តរជាតិមានសមត្ថកិច្ច។

## ជំពូកទី៥៖ ការទទួលខុសត្រូវ និង បន្ទុក

*មាត្រា ២៦៣*

*ការទទួលខុសត្រូវ និងបន្ទុក*

១. រដ្ឋ និងអង្គការអន្តរជាតិមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវធានាថា ការស្រាវជ្រាវវិទ្យាសាស្ត្រ អំពីសមុទ្រត្រូវបានអនុវត្តស្របតាមអនុសញ្ញានេះ មិនថាត្រូវបានអនុវត្តដោយខ្លួនឯកផ្ទាល់ ឬដោយតំណាងរបស់ខ្លួន នោះទេ។

២. រដ្ឋ និងអង្គការអន្តរជាតិមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវ និងទទួលបន្ទុកលើវិធានការដែលខ្លួនចាត់ឡើង ដោយបំពានលើអនុសញ្ញានេះ ទាក់ទងនឹងការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដែលត្រូវបានអនុវត្តដោយរដ្ឋដទៃ រូបវន្តបុគ្គល ឬនីតិបុគ្គលរបស់រដ្ឋទាំងនោះ ឬដោយអង្គការអន្តរជាតិមានសមត្ថកិច្ច ហើយត្រូវផ្តល់សំណងជម្ងឺចិត្ត សម្រាប់ការខូចខាតដែលបណ្តាលមកពីវិធានការទាំងនោះ។

៣. រដ្ឋ និងអង្គការអន្តរជាតិមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវ និងទទួលបន្ទុកស្របតាមមាត្រា ២៣៥ ចំពោះការខូចខាតបណ្តាលមកពីការបំពុលបរិស្ថានសមុទ្រ ដែលបានកើតឡើងដោយសារការស្រាវជ្រាវវិទ្យាសាស្ត្រ អំពីសមុទ្រដែលអនុវត្តឡើងដោយខ្លួន ឬតំណាងរបស់ខ្លួន។

ជំពូកទី៦៖ ការដោះស្រាយវិវាទ និងវិធានការបណ្ដោះអាសន្ន

*មាត្រា ២៦៤*

*ការដោះស្រាយវិវាទ*

រាល់វិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ ដែលពាក់ព័ន្ធនឹងការស្រាវជ្រាវ វិទ្យាសាស្ត្រអំពីសមុទ្រ ត្រូវដោះស្រាយតាមផ្នែកទី ១៥ជំពូកទី ២ និងជំពូកទី ៣ ។

*មាត្រា ២៦៥*

*វិធានការបណ្ដោះអាសន្ន*

នៅពេលរង់ចាំការដោះស្រាយវិវាទតាមផ្នែកទី ១៥ជំពូកទី ២ និងជំពូកទី ៣ រដ្ឋ ឬអង្គការអន្តរជាតិមាន សមត្ថកិច្ចដែលត្រូវបានអនុញ្ញាតឱ្យអនុវត្តគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ មិនត្រូវអនុញ្ញាតឱ្យចាប់ផ្ដើម ឬបន្តសកម្មភាពស្រាវជ្រាវដោយគ្មានការអនុញ្ញាតច្បាស់លាស់ពីរដ្ឋជាប់ឆ្នេរដែលពាក់ព័ន្ធនោះឡើយ។

## ផ្នែកទី១៤៖ ការអភិវឌ្ឍ និង ការផ្ទេរបច្ចេកវិទ្យាសមុទ្រ

## ជំពូកទី១៖ បទបញ្ញត្តិទូទៅ

*មាត្រា ២៦៦*

*ការជំរុញការអភិវឌ្ឍ និង ការផ្ទេរបច្ចេកវិទ្យាសមុទ្រ*

១. តាមរយៈខ្លួនឯងផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ច បណ្តារដ្ឋត្រូវសហការគ្នាជំរុញការ អភិវឌ្ឍ និងការផ្ទេរវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសមុទ្រឱ្យបានសកម្ម ទៅតាមសមត្ថភាពរបស់រដ្ឋនីមួយៗ ដោយផ្អែក លើលក្ខខណ្ឌសមស្រប និងយុត្តិធម៌។

២. បណ្តារដ្ឋត្រូវជំរុញការអភិវឌ្ឍសមត្ថភាពផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រអំពីសមុទ្ររបស់រដ្ឋដែលត្រូវការ ឬបានស្នើសុំជំនួយបច្ចេកទេសនៅក្នុងផ្នែកនេះ ជាពិសេសបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ រាប់បញ្ចូលទាំងរដ្ឋហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល ពាក់ព័ន្ធនឹងការរុករក ការធ្វើអាជីវកម្ម ការអភិរក្ស និងការគ្រប់គ្រងធនធាន សមុទ្រ ការការពារ និងការអភិរក្សបរិស្ថានសមុទ្រ ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ និងសកម្មភាពនៅក្នុង បរិស្ថានសមុទ្រផ្សេងៗទៀត ដែលស្របតាមអនុសញ្ញានេះ ដើម្បីពន្លឿនដំណើរការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចរបស់រដ្ឋកំពុងអភិវឌ្ឍន៍ទាំងនោះ។

៣. បណ្តារដ្ឋត្រូវខិតខំកែលម្អលក្ខខណ្ឌសេដ្ឋកិច្ច និងលក្ខខណ្ឌគតិយុត្តិឱ្យមានភាពអនុគ្រោះសម្រាប់ការផ្ទេរ បច្ចេកវិទ្យាសមុទ្រ ដើម្បីបម្រើផលប្រយោជន៍របស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នា។

*មាត្រា ២៦៧*

*ការការពារអត្ថប្រយោជន៍ស្របច្បាប់*

នៅក្នុងការជំរុញកិច្ចសហប្រតិបត្តិការដែលមានចែងនៅក្នុងមាត្រា ២៦៨ បណ្តារដ្ឋត្រូវគិតគូរឱ្យបានម៉ត់ចត់ ទៅលើអត្ថប្រយោជន៍ស្របច្បាប់ទាំងអស់ រួមមានជាអាទិ៍ សិទ្ធិ និងភារកិច្ចរបស់ម្ចាស់កម្មសិទ្ធិ អ្នកផ្តល់ និងអ្នកទទួល បច្ចេកវិទ្យាសមុទ្រ។

*មាត្រា ២៦៨*

*កម្មវត្ថុជាមូលដ្ឋាន*

តាមរយៈខ្លួនឯងផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ច បណ្តារដ្ឋត្រូវសហការគ្នាជំរុញ៖

(ក) ការទទួលបាន ការវាយតម្លៃ និងការផ្សព្វផ្សាយចំណេះដឹងអំពីបច្ចេកវិទ្យាសមុទ្រ និងសម្រប សម្រួលលទ្ធភាពក្នុងការទទួលបាននូវព័ត៌មាន និងទិន្នន័យទាំងនោះ។

(ខ) ការអភិវឌ្ឍបច្ចេកវិទ្យាសមុទ្រសមស្រប។

(គ) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាដែលចាំបាច់ដើម្បីសម្របសម្រួលការផ្ទេរបច្ចេកវិទ្យា។

(ឃ) ការអភិវឌ្ឍធនធានមនុស្សតាមរយៈការបណ្តុះបណ្តាល និងការអប់រំពលរដ្ឋនៃរដ្ឋ និងប្រទេស កំពុងអភិវឌ្ឍន៍ ជាពិសេសពលរដ្ឋនៃរដ្ឋ និងប្រទេសដែលមានការអភិវឌ្ឍតិចតួចជាងគេ។

(ង) កិច្ចសហប្រតិបត្តិការអន្តរជាតិនៅគ្រប់កម្រិត ជាពិសេសនៅកម្រិតតំបន់ អនុតំបន់ និងទ្វេភាគី។

*មាត្រា ២៦៩*

*វិធានការដើម្បីសម្រេចតាមកម្មវត្ថុជាមូលដ្ឋាន*

ដើម្បីសម្រេចបានតាមកម្មវត្ថុដែលមានចែងនៅក្នុងមាត្រា ២៦៨ បណ្តារដ្ឋត្រូវខិតខំប្រឹងប្រែង តាមរយៈ ខ្លួនឯងផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ចដើម្បីះ

(ក) បង្កើតកម្មវិធីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដើម្បីទទួលបានប្រសិទ្ធភាពក្នុងការផ្ទេរបច្ចេកវិទ្យាសមុទ្រគ្រប់ប្រភេទទៅឱ្យបណ្តារដ្ឋដែលត្រូវការ ឬបានស្នើសុំជំនួយបច្ចេកទេសនៅក្នុងផ្នែកនេះ ជាពិសេសបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ដែលហ៊ុំព័ទ្ធដោយដីគោក និងមានភូមិសាស្ត្រមិនអំណោយផលព្រមទាំង បណ្តារដ្ឋកំពុងអភិវឌ្ឍន៍ផ្សេងៗទៀត ដែលពុំមានសមត្ថភាពបង្កើតកម្មវិធី ឬអភិវឌ្ឍសមត្ថភាពផ្នែកបច្ចេកទេសអំពីវិទ្យាសាស្ត្រសមុទ្រ ការរុករក និងការធ្វើអាជីវកម្មធនធានសមុទ្រផ្ទាល់ខ្លួន ឬពុំមានសមត្ថភាពអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែកបច្ចេកទេសនេះបាន។

(ខ) ជំរុញឱ្យមានលក្ខខណ្ឌអនុគ្រោះសម្រាប់ការចុះកិច្ចព្រមព្រៀងកិច្ចសន្យា និងផែនការប្រហាក់ប្រហែលផ្សេងៗទៀត នៅក្រោមលក្ខខណ្ឌដែលសមស្រប និងស្មើភាព។

(គ) រៀបចំសន្និសីទ សិក្ខាសាលា និងកិច្ចប្រជុំស្តីពីប្រធានបទវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាពិសេស ស្តីពីគោលនយោបាយ និងវិធីសាស្ត្រសម្រាប់ការផ្ទេរបច្ចេកវិទ្យាសមុទ្រ ។

(ឃ) ជំរុញការផ្លាស់ប្តូរអ្នកវិទ្យាសាស្ត្រ អ្នកជំនាញបច្ចេកទេស និងអ្នកឯកទេសផ្សេងៗទៀត ។

(ង) អនុវត្តគម្រោង និងជំរុញគម្រោងរួមគ្នា ព្រមទាំងទម្រង់ផ្សេងៗទៀតនៃកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ។

*មាត្រា ២៧០*

*វិធី និង មធ្យោបាយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ*

កិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យាសមុទ្រ ត្រូវអនុវត្តឡើងទៅតាម ការដែលអាចធ្វើទៅបាន និងសមស្របតាមរយៈកម្មវិធីទ្វេភាគី កម្មវិធីថ្នាក់តំបន់ ឬពហុភាគីដែលមានស្រាប់ និងកម្មវិធីថ្មីៗ និងពង្រីកបន្ថែម ដើម្បីសម្របសម្រួលការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ការផ្ទេរបច្ចេកវិទ្យាសមុទ្រ ជាពិសេសនៅក្នុងផ្នែកថ្មីៗ និងមូលនិធិអន្តរជាតិសមស្របសម្រាប់ការអភិវឌ្ឍ និងការស្រាវជ្រាវអំពីមហាសមុទ្រ។

*មាត្រា ២៧១*

*សេចក្តីណែនាំ លក្ខខណ្ឌវិនិច្ឆ័យ និងបទដ្ឋាន*

តាមរយៈខ្លួនឯងផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ច បណ្តារដ្ឋត្រូវជំរុញការបង្កើតនូវ សេចក្តីណែនាំ លក្ខខណ្ឌវិនិច្ឆ័យ និងបទដ្ឋានសម្រាប់ការផ្ទេរបច្ចេកវិទ្យាសមុទ្រ ដោយផ្អែកលើមូលដ្ឋានទ្វេភាគី ឬនៅក្នុងក្របខណ្ឌអង្គការអន្តរជាតិ និងវេទិកាផ្សេងៗទៀត ដោយគិតគូរជាពិសេសទៅលើអត្ថប្រយោជន៍ និងតម្រូវការ របស់រដ្ឋកំពុងអភិវឌ្ឍន៍។

*មាត្រា ២៧២*

*ការសម្របសម្រួលកម្មវិធីអន្តរជាតិ*

នៅក្នុងវិស័យផ្ទេរបច្ចេកវិទ្យាសមុទ្រ រដ្ឋត្រូវខិតខំធានាថា អង្គការអន្តរជាតិមានសមត្ថកិច្ចសម្របសម្រួលសកម្មភាពរបស់ខ្លួន រាប់បញ្ចូលទាំងកម្មវិធីថ្នាក់តំបន់

ឬថ្នាក់សកល ដោយគិតគូរទៅលើអត្ថប្រយោជន៍ និងតម្រូវការ របស់រដ្ឋកំពុងអភិវឌ្ឍន៍ ជាពិសេសរដ្ឋហ៊ុំព័ទ្ធដោយដីគោក និងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល។

*មាត្រា ២៧៣*

*កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងអាជ្ញាធរ*

រដ្ឋត្រូវសហការយ៉ាងសកម្មជាមួយអង្គការអន្តរជាតិមានសមត្ថកិច្ច និងអាជ្ញាធរ ដើម្បីជំរុញ និងសម្រប សម្រួលការផ្ទេរជំនាញ និងបច្ចេកវិទ្យាសមុទ្រ ដែលពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់ទៅឱ្យរដ្ឋកំពុងអភិវឌ្ឍន៍ពលរដ្ឋរបស់រដ្ឋកំពុងអភិវឌ្ឍន៍ និងសហគ្រាស។

*មាត្រា ២៧៤*

*គោលដៅរបស់អាជ្ញាធរ*

ទាក់ទងនឹងអត្ថប្រយោជន៍ស្របច្បាប់ទាំងអស់ មានជាអាទិ៍ សិទ្ធិ និងភារកិច្ចរបស់គាហក អ្នកផ្គត់ផ្គង់ និង អ្នកទទួលបច្ចេកវិទ្យាដែលពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់ អាជ្ញាធរត្រូវធានាថា៖

(ក) ពលរដ្ឋរបស់រដ្ឋកំពុងអភិវឌ្ឍន៍ មិនថារដ្ឋជាប់ឆ្នេរ រដ្ឋហ៊ុំព័ទ្ធដោយដីគោក ឬរដ្ឋមានភូមិសាស្ត្រមិន អំណោយផល ត្រូវបានទទួលយកសម្រាប់គោលបំណងបណ្ដុះបណ្ដាលជាសមាជិកនៃក្រុមបុគ្គលិក ផ្នែកគ្រប់គ្រង ស្រាវជ្រាវ និងបច្ចេកទេសសម្រាប់អនុវត្តការងាររបស់ខ្លួន ដោយផ្អែកលើគោល- ការណ៍បែងចែកភូមិសាស្ត្រដោយស្មើភាព។

(ខ) ឯកសារបច្ចេកទេសស្ដីពីបរិក្ខារ គ្រឿងចក្រ ឧបករណ៍ និងដំណើរការដែលពាក់ព័ន្ធ ត្រូវបាន ផ្សព្វផ្សាយដល់រដ្ឋទាំងអស់ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ ដែលអាចនឹងត្រូវការ និងស្នើសុំជំនួយ បច្ចេកទេសនៅក្នុងផ្នែកនេះ។

(គ) ជំនួយគ្រប់គ្រាន់ត្រូវបានផ្តល់ជូនដោយអាជ្ញាធរ ដើម្បីសម្របសម្រួលឱ្យមានការទទួលបាននូវ ជំនួយផ្នែកបច្ចេកទេសនៅក្នុងវិស័យបច្ចេកវិទ្យាសមុទ្រដោយរដ្ឋដែលអាចនឹងត្រូវការ និងស្នើសុំ ជំនួយនេះ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ និងការទទួលបានដោយពលរដ្ឋរបស់រដ្ឋទាំងនោះនូវ ជំនាញ និងចំណេះធ្វើដែលចាំបាច់ រាប់បញ្ចូលទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ ។

(ឃ) រដ្ឋដែលអាចនឹងត្រូវការ និងស្នើសុំជំនួយបច្ចេកទេសនៅក្នុងផ្នែកនេះ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ ត្រូវបានជួយជ្រោមជ្រែងឱ្យទទួលបាននូវបរិក្ខារ ដំណើរការ រោងចក្រ និងចំណេះធ្វើផ្នែកបច្ចេកទេសផ្សេងៗទៀត តាមរយៈផែនការហិរញ្ញវត្ថុដែលមានចែងនៅក្នុងអនុសញ្ញានេះ។

## ជំពូកទី៣៖ មជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសមុទ្រថ្នាក់ជាតិ និងថ្នាក់តំបន់

*មាត្រា ២៧៥*

*ការបង្កើតមជ្ឈមណ្ឌលថ្នាក់ជាតិ*

១. តាមរយៈខ្លួនឯងផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ច និងអាជ្ញាធរ បណ្តារដ្ឋត្រូវជំរុញឱ្យមានការបង្កើតនូវមជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសមុទ្រថ្នាក់ជាតិ ជាពិសេសនៅតាមបណ្តារដ្ឋកំពុង អភិវឌ្ឍន៍ដែលមានឆ្នេរសមុទ្រ និងជំរុញការពង្រឹងមជ្ឈមណ្ឌលជាតិដែលមានស្រាប់ ដើម្បីជំរុញ និងបង្កើនការអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដែលធ្វើឡើងដោយរដ្ឋកំពុងអភិវឌ្ឍន៍មានឆ្នេរសមុទ្រឱ្យបានប្រសើរ និងលើកកម្ពស់សមត្ថភាពថ្នាក់ជាតិរបស់រដ្ឋទាំងនោះ ដើម្បីប្រើប្រាស់ និងអភិរក្សធនធានសមុទ្ររបស់ពួកគេ សម្រាប់បម្រើ ផលប្រយោជន៍សេដ្ឋកិច្ចរបស់ពួកគេ។

២. តាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ច និងអាជ្ញាធរ បណ្តារដ្ឋត្រូវផ្តល់ការគាំទ្រឱ្យបានគ្រប់គ្រាន់ ដើម្បីសម្របសម្រួលការបង្កើត និងការពង្រឹងមជ្ឈមណ្ឌលជាតិទាំងនោះ ដើម្បីផ្តល់នូវមូលដ្ឋានសម្ភារបណ្តុះបណ្តាល ដែលទំនើប

និងបរិក្ខារ ជំនាញ និងចំណេះធ្វើដែលចាំបាច់ ព្រមទាំងជំនាញបច្ចេកទេស ទៅឱ្យរដ្ឋដែលអាចនឹងត្រូវការ និងស្នើសុំជំនួយទាំងនេះ។

*មាត្រា ២៧៦*

*ការបង្កើតមជ្ឈមណ្ឌលថ្នាក់តំបន់*

១. តាមរយៈការសម្របសម្រួលជាមួយអង្គការអន្តរជាតិដែលមានសមត្ថកិច្ច អាជ្ញាធរ ស្ថាប័នស្រាវជ្រាវ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសមុទ្រថ្នាក់ជាតិ បណ្តារដ្ឋត្រូវជំរុញឱ្យមានការបង្កើតនូវមជ្ឈមណ្ឌលវិទ្យាសាស្ត្រ និង បច្ចេកវិទ្យាសមុទ្រថ្នាក់តំបន់ ជាពិសេសនៅក្នុងបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ ដើម្បីជំរុញ និងបង្កើនការអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដែលធ្វើឡើងដោយរដ្ឋកំពុងអភិវឌ្ឍន៍មានឆ្នេរសមុទ្រឱ្យបានប្រសើរ និងលើកកម្ពស់ ការផ្ទេរបច្ចេកវិទ្យាសមុទ្រ។

២. រដ្ឋទាំងអស់នៅក្នុងតំបន់ ត្រូវសហការជាមួយមជ្ឈមណ្ឌលថ្នាក់តំបន់ដែលមានចែងនៅក្នុងអនុសញ្ញានេះ ដើម្បីធានានូវការសម្រេចបានតាមគោលបំណងរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់។

*មាត្រា ២៧៧*

*មុខងាររបស់មជ្ឈមណ្ឌលថ្នាក់តំបន់*

មជ្ឈមណ្ឌលថ្នាក់តំបន់មានមុខងារជាច្រើនរួមមានដូចជា ៖

(ក)

កម្មវិធីបណ្តុះបណ្តាលអប់រំនៅគ្រប់កម្រិតទាំងអស់ស្តីពីកត្តាផ្សេងៗនៃការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសមុទ្រ ជាពិសេសជីវវិជ្ជាសមុទ្រ រាប់បញ្ចូលទាំងការអភិរក្ស និងការគ្រប់គ្រងធនធានមានជីវិត សាគរសាស្ត្រ

ជលធារសាស្ត្រ វិស្វកម្ម ការរុករកភូមិសាស្ត្រនៅបាតសមុទ្រ បច្ចេកវិទ្យាទាញយករ៉ែ និងបច្ចេកវិទ្យាបន្សាបជាតិអំបិល។

(ខ) ការសិក្សាគ្រប់គ្រង។

(គ) ការសិក្សាកម្មវិធីដែលទាក់ទងនឹងការការពារ និងការអភិរក្សបរិស្ថានសមុទ្រ ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុល។

(ឃ) រៀបចំសន្និសីទ សិក្ខាសាលា និងកិច្ចប្រជុំថ្នាក់តំបន់។

(ង) ការទទួលបាន និងការដំណើរការព័ត៌មាន និងទិន្នន័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសមុទ្រ។

(ច) ផ្សព្វផ្សាយឱ្យបានជាបន្ទាន់នូវការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសមុទ្រ នៅក្នុងច្បាប់បោះពុម្ពផ្សាយដែលមាន។

(ឆ) ផ្សព្វផ្សាយគោលនយោបាយជាតិដែលពាក់ព័ន្ធនឹងការផ្ទេរបច្ចេកវិទ្យាសមុទ្រ និងការសិក្សាប្រៀបធៀបគោលនយោបាយទាំងនោះជាលក្ខណៈប្រព័ន្ធ។

(ជ) ចងក្រង និងរៀបចំជាប្រព័ន្ធនូវព័ត៌មានស្តីពីទីផ្សារបច្ចេកវិទ្យា និងកិច្ចសន្យា និងផែនការផ្សេងៗ ដែលទាក់ទងនឹងប៉ាតង់។

(ឈ) កិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយបណ្តារដ្ឋផ្សេងៗទៀតក្នុងតំបន់។

## ជំពូកទី៤៖ កិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការអន្តរជាតិ

*មាត្រា ២៧៨*

*កិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការអន្តរជាតិ*

អង្គការអន្តរជាតិមានសមត្ថកិច្ចដែលមានចែងនៅក្នុងផ្នែកនេះ និងផ្នែកទី ១៣ត្រូវចាត់វិធានការសមស្រប ទាំងឡាយដើម្បីធានាថា មុខងារ និងការទទួលខុសត្រូវរបស់ខ្លួននៅក្រោមផ្នែកនេះត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធ ភាព មិនថាដោយខ្លួនឯងផ្ទាល់ ឬដោយកិច្ចសហប្រតិបត្តិការជិតស្និទ្ធក្នុងចំណោមអង្គការទេ ។

## ផ្នែកទី១៥៖ ការដោះស្រាយវិវាទ

### ជំពូកទី១៖ បទបញ្ញត្តិទូទៅ

*មាត្រា ២៧៩*

*កាតព្វកិច្ចដោះស្រាយវិវាទដោយសន្តិវិធី*

រដ្ឋភាគីត្រូវដោះស្រាយរាល់វិវាទដែលកើតឡើងរវាងរដ្ឋភាគីដូចគ្នា ទាក់ទងនឹងការបកស្រាយ ឬការអនុវត្ត បទបញ្ញត្តិនៃអនុសញ្ញានេះ តាមរយៈមធ្យោបាយសន្តិវិធីស្របតាមមាត្រា ២ កថាខណ្ឌទី ៣ នៃធម្មនុញ្ញសហប្រជាជាតិ ហើយដើម្បីសម្រេចបានតាមគោលបំណងនេះ រដ្ឋភាគីត្រូវស្វែងរកដំណោះស្រាយតាមរយៈមធ្យោបាយដែលមានចែង នៅក្នុងមាត្រា ៣៣ កថាខណ្ឌទី ១ នៃធម្មនុញ្ញសហប្រជាជាតិ។

*មាត្រា ២៨០*

*ការដោះស្រាយវិវាទតាមរយៈមធ្យោបាយសន្តិវិធីដែលជ្រើសរើសដោយគូភាគីនៃវិវាទ*

គ្មានបញ្ញត្តិណាមួយនៅក្នុងផ្នែកនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋភាគី នៅក្នុងការព្រមព្រៀងគ្នាដោះស្រាយ វិវាទរវាងពួកគេដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ តាមរយៈមធ្យោបាយសន្តិវិធី ដែលពួកគេបានជ្រើសរើសដោយខ្លួនឯងផ្ទាល់នៅពេលណាមួយនោះទេ។

*មាត្រា ២៨១*

*នីតិវិធីក្នុងករណីគូភាគីមិនអាចដោះស្រាយវិវាទ*

១. ប្រសិនបើរដ្ឋភាគីជាភាគីនៃវិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ បាន

ព្រមព្រៀងគ្នាស្វែងរកដំណោះស្រាយវិវាទតាមរយៈមធ្យោបាយសន្តិវិធីដែលពួកគេបានជ្រើសរើសផ្ទាល់ នោះនីតិវិធីដែលមានចែងនៅក្នុងផ្នែកនេះនឹងត្រូវមានប្រសិទ្ធភាពអនុវត្តតែក្នុងករណីដែលពុំមានដំណោះស្រាយ តាមរយៈការប្រើ ប្រាស់មធ្យោបាយដោយសន្តិវិធីនោះប៉ុណ្ណោះ ហើយការព្រមព្រៀងរវាងគូភាគីមិនបានច្រានចោលនូវនីតិវិធីផ្សេងៗ ទៀតនោះទេ។

២. ប្រសិនបើភាគីនៃវិវាទក៏បានព្រមព្រៀងគ្នាអំពីរយៈពេលកំណត់ផងដែរ នោះកថាខណ្ឌទី ១ មានប្រសិទ្ធភាពអនុវត្តតែនៅក្រោយពេលផុតកំណត់រយៈពេលកំណត់នោះប៉ុណ្ណោះ។

*មាត្រា ២៨២*

*នីតិវិធីក្នុងករណីគូភាគីមិនអាចដោះស្រាយវិវាទ*

ប្រសិនបើរដ្ឋភាគីជាភាគីនៃវិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ បាន ព្រមព្រៀងគ្នាតាមរយៈកិច្ចព្រមព្រៀងរួម កិច្ចព្រមព្រៀងថ្នាក់តំបន់ ឬកិច្ចព្រមព្រៀងទ្វេភាគី ឬកិច្ចព្រមព្រៀងផ្សេងៗ ទៀតថា នៅពេលមានសំណើពីភាគីណាមួយនៃវិវាទស្នើសុំឱ្យបញ្ជូនវិវាទនោះទៅដោះស្រាយតាមនីតិវិធីមួយដើម្បីសម្រេចបាននូវសេចក្តីសម្រេចមួយដែលចងភ្ជាប់កាតព្វកិច្ច នោះនីតិវិធីនោះនឹងត្រូវមានប្រសិទ្ធភាពអនុវត្តជំនួសឱ្យ នីតិវិធីដែលមានចែងនៅក្នុងផ្នែកនេះ លើកលែងតែភាគីនៃវិវាទព្រមព្រៀងគ្នាផ្សេងពីនេះ។

*មាត្រា ២៨៣*

*កាតព្វកិច្ចផ្លាស់ប្តូរទស្សនៈ*

១. នៅពេលកើតមានវិវាទរវាងរដ្ឋភាគីទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ នោះភាគីនៃវិវាទត្រូវប្រញាប់ប្រញាល់ផ្លាស់ប្តូរទស្សនៈគ្នាអំពីការដោះស្រាយវិវាទតាមរយៈការចរចា ឬតាមរយៈ មធ្យោបាយសន្តិវិធីផ្សេងៗទៀត។

២. ភាគីនៃវិវាទត្រូវប្រញាប់ប្រញាល់ផ្លាស់ប្តូរទស្សនៈគ្នា ក្នុងករណីដែលនីតិវិធីមួយសម្រាប់ដោះស្រាយវិវាទ ត្រូវបានបញ្ចប់ដោយពុំមានដំណោះស្រាយ ឬក្នុងករណីដែលអាចសម្រេចបាននូវដំណោះស្រាយមួយ តែកាលៈទេសៈ តម្រូវឱ្យមានការពិគ្រោះយោបល់គ្នាអំពីរបៀបដែលត្រូវអនុវត្តដំណោះស្រាយនោះ។

*មាត្រា ២៨៤*

*ការផ្សះផ្សា*

១. រដ្ឋភាគីដែលជាភាគីមួយនៃវិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះអាច អញ្ជើញភាគីម្ខាងទៀតឱ្យបញ្ជូនវិវាទទៅផ្សះផ្សាគ្នាស្របតាមនីតិវិធីដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ៥ជំពូកទី ១ ឬ នីតិវិធីផ្សះផ្សាផ្សេងទៀត។

២. ប្រសិនបើការអញ្ជើញត្រូវបានទទួលយក និងប្រសិនបើភាគីនៃវិវាទបានឯកភាពគ្នាលើនីតិវិធីផ្សះផ្សា ដែលនឹងត្រូវអនុវត្ត នោះភាគីនីមួយៗអាចបញ្ជូនវិវាទទៅដោះស្រាយតាមនីតិវិធីនោះបាន។

៣. ប្រសិនបើការអញ្ជើញមិនត្រូវបានទទួលយក ឬភាគីនៃវិវាទមិនបានឯកភាពគ្នាលើនីតិវិធីផ្សះផ្សាទេ នោះដំណើរការផ្សះផ្សានឹងត្រូវចាត់ទុកជាអាសាបង់។

៤. នៅពេលដែលវិវាទត្រូវបានបញ្ជូនទៅផ្សះផ្សា នោះដំណើរការផ្សះផ្សាអាចបញ្ចប់បានតែតាមនីតិវិធីផ្សះ ផ្សាដែលបានឯកភាពគ្នានោះប៉ុណ្ណោះ លើកលែងតែភាគីនៃវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ។

*មាត្រា ២៨៥*

*ការអនុវត្តជំពូកនេះសម្រាប់វិវាទដែលត្រូវបានបញ្ជូនស្របតាមផ្នែកទី ១១*

ជំពូកនេះមានប្រសិទ្ធភាពអនុវត្តចំពោះវិវាទទាំងឡាយដែលស្របតាមផ្នែកទី ១១ជំពូកទី ៥ ត្រូវបានដោះស្រាយ តាមនីតិវិធីដែលមានចែងនៅក្នុងផ្នែកនេះ។ ប្រសិនបើអង្គភាពណាមួយក្រៅពីរដ្ឋភាគី គឺជាភាគីមួយនៃវិវាទ នោះ ជំពូកនេះមានប្រសិទ្ធភាពអនុវត្ត *ដោយរាប់បញ្ចូលទាំងរាល់វិសោធនកម្មទាំងឡាយដែលបានធ្វើឡើងផងដែរ។*

*មាត្រា ២៨៦*

*ការអនុវត្តនីតិវិធីក្រោមជំពូកនេះ*

អនុលោមតាមជំពូកទី ៣ ក្នុងករណីកើតមានវិវាទណាមួយទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញា នេះ ហើយដែលពុំមានដំណោះស្រាយយោងតាមឧបាស្រ័យដូចមានចែងក្នុងជំពូកទី ១ នោះករណីវិវាទនេះត្រូវបញ្ជូន ឡើងទៅតុលាការ ឬសាលាក្តីដែលមានសមត្ថកិច្ចក្រោមជំពូកនេះ តាមការស្នើឡើងពីភាគីនីមួយៗ។

*មាត្រា ២៨៧*

*ជម្រើសនៃនីតិវិធី*

១. នៅពេលចុះហត្ថលេខាលើអនុសញ្ញានេះ ឬផ្តល់សច្ចាប័ន ឬការព្រមព្រៀងលើអនុសញ្ញានេះ ឬនៅពេលបន្ទាប់ ពីនេះ នោះរដ្ឋនីមួយៗត្រូវមានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយមួយ ឬលើសពីមួយដូចខាងក្រោមតាមរយៈការប្រកាសជាលាយលក្ខណ៍អក្សរ ដើម្បីដោះស្រាយវិវាទដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ៖

(ក) ដំណោះស្រាយតាមរយៈសាលាក្តីអន្តរជាតិផ្នែកច្បាប់សមុទ្រ ដែលបានបង្កើតឡើងស្របតាម ឧបសម្ព័ន្ធទី៦។

(ខ) តាមរយៈតុលាការយុត្តិធម៌អន្តរជាតិ ។

(គ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលបង្កើតឡើងស្របតាមឧបសម្ព័ន្ធទី៧។

(ឃ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិសេសមួួយដែលបង្កើតឡើងស្របតាមឧបសម្ព័ន្ធទី៨ ទទួលបន្ទុកដោះស្រាយ វិវាទច្រើនរបភេទដូចមានចែងនៅក្នុងឧបសម្ព័ន្ធនេះ។

២.	សេចក្តីប្រកាសដែលធ្វើឡើងក្រោមកថាខណ្ឌទី១ មិនត្រូវនាំឱ្យប៉ះពាល់ ឬរងការប៉ះពាល់ដោយសារកាតព្វកិច្ចរបស់រដ្ឋភាគីមួយនៅក្នុងការទទួលយកយុត្តាធិការរបស់សភាវិវាទ បាតសមុទ្រនៃសាលា ជំនុំជំរះអន្តរជាតិផ្នែកច្បាប់សមុទ្រនៅក្នុងវិសាលភាព និងលក្ខណៈណាមួយដូចមានចែងក្នុងផ្នែក១១ នៃ ជំពូកទី៥ឡើយ។

៣.	រដ្ឋភាគីដែលជាភាគីមួយនៃវិវាទដែលមិនមានចែងនៅក្នុងសេចក្តីប្រកាសជាធរមាន ត្រូវបានចាត់ទុកថាបាន ទទួលយកការជំនុំជំរះបែបមជ្ឈត្តកម្មស្របតាមឧបសម្ព័ន្ធទី៧។

៤.	ប្រសិនបើភាគីនៃរឿងវិវាទបានទទួលយកនីតិវិធីតែមួយសម្រាប់ការដោះស្រាយវិវាទ នោះករណីវិវាទនេះ អាចត្រូវបានបញ្ជូនឡើងទៅដោះស្រាយតាមនីតិវិធីនោះតែប៉ុណ្ណោះ វៀរលែងតែមានការព្រមព្រៀងផ្សេងពី នេះរវាងភាគីដែលពាក់ព័ន្ធ។

៥.	ដោយឡែក ប្រសិនបើភាគីនៃរឿងវិវាទពុំយល់ព្រមទទួលយកនីតិវិធីតែមួយសម្រាប់ធ្វើការដោះស្រាយវិវាទ នោះករណីនេះអាចត្រូវបានបញ្ជូនឡើងទៅដោះស្រាយបែបមជ្ឈត្តកម្មស្របតាមឧបសម្ព័ន្ធទី៧ តែប៉ុណ្ណោះ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះរវាងភាគីដែលពាក់ព័ន្ធ។

៦.	សេចក្តីប្រកាសដែលធ្វើឡើងក្រោមកថាខណ្ឌទី១ ត្រូវរក្សាមានសុពលភាពរហូតរយៈពេលបីខែបន្ទាប់ពីមានការជូនដំណឹងលុបចោលសុពលភាពនៃលិខិត ដែលតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៧.	សេចក្តីប្រកាសថ្មីក្រោមលិខិតជូនដំណឹងលុបចោលសុពលភាពនៃលិខិតចាស់ ឬការអស់អានុភាពនៃសេចក្តី ប្រកាស មិនត្រូវនាំឱ្យប៉ះពាល់ដោយប្រការណាមួយទៅដល់នីតិវិធីត្រៀមការជំនុំជំរះនៅតុលាការ ឬ សាលាជំនុំជំរះដែលមានយុត្តាធិការក្រោមមាត្រានេះឡើយ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះរវាង ភាគីដែលពាក់ព័ន្ធ។

៨.	សេចក្តីប្រកាស និងលិខិតជូនដំណឹងដូចមានចែងក្នុងមាត្រានេះ ត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការ សហប្រជាជាតិ ដែលទទួលបន្ទុកចែកចាយសេចក្តីចម្លងនៃលិខិតទាំងនេះទៅកាន់បណ្តារដ្ឋភាគី។

*មាត្រា ២៨៨*

*យុត្តាធិការ*

១. តុលាការ ឬសាជំនុំជំរះដូចមានចែងនៅក្នុងមាត្រា ២៨៧ ត្រូវមានយុត្តាធិការលើរាល់វិវាទទាំងអស់ដែលទាក់ទងនឹងការបកស្រាយខ្លឹមសារ ឬការអនុវត្តអនុសញ្ញានេះ ដោយការបញ្ជូនរឿងក្តីស្របតាមនីតិវិធីដែលបាន កំណត់ក្នុងផ្នែកនេះ។

២. តុលាការ ឬសាលាក្តីដូចមានចែងនៅក្នុងមាត្រា ២៨៧ ក៏ត្រូវមានយុត្តាធិការផងដែរលើរាល់វិវាទដែល ទាក់ទងនឹងការបកស្រាយខ្លឹមសារ ឬការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិដែលមានកម្មវត្ថុទាក់ទងនឹងអនុសញ្ញានេះ ដោយការបញ្ជូនរឿងក្តីស្របតាមនីតិវិធីដែលបានកំណត់ស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ។

៣. សភាវិវាទបាតសមុទ្រនៃសាលាក្តីអន្តរជាតិផ្នែកច្បាប់សមុទ្រដែលបង្កើតឡើងស្របតាម ឧបសម្ព័ន្ធទី៦ និងសភា ឬក្រុមប្រឹក្សាជំនុំជំរះផ្សេងទៀតដូចមានចែងក្នុងផ្នែកទី ៥ ជំពូកទី៥ ត្រូវមាន យុត្តាធិការលើគ្រប់រឿងក្តីដែលបានបញ្ជូនមកដោះស្រាយស្របតាមនីតិវិធីដែលបានកំណត់។

៤. ក្នុងករណីមានវិវាទក្នុងការកំណត់ថាតើរឿងក្តីស្ថិតក្នុងយុត្តាធិការរបស់តុលាការ ឬសាលាក្តី រឿងក្តីនោះ ត្រូវដោះស្រាយតាមការសម្រេចរបស់តុលាការ ឬសាលាក្តីដែលមានសមត្ថកិច្ច។

*មាត្រា ២៨៩*

*ក្រុមអ្នកជំនាញ*

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងវិស័យវិទ្យាសាស្ត្រ ឬបច្ចេកទេស នោះតុលាការ ឬសាលាក្តីដែលមាន យុត្តាធិការក្រោមជំពូកនេះ តាមការស្នើសុំពីភាគីណាមួយ ឬដោយមានការព្រមព្រៀងពីភាគីនោះ អាចធ្វើការជ្រើសរើសក្រុមអ្នកវិទ្យាសាស្ត្រ ឬអ្នកបច្ចេកទេសយ៉ាងតិចពីររូបដោយការពិគ្រោះយោបល់ជាមួយបណ្តាភាគី ដែលពាក់ព័ន្ធ ជាពិសេសជ្រើសរើសចេញពីបញ្ជីឈ្មោះដែលពាក់ព័ន្ធ និងរៀបចំឡើងស្របតាមមាត្រា ២ នៃ

ឧបសម្ព័ន្ធទី៨ ដើម្បីស្ដាប់ការវិនិច្ឆ័យនៅក្នុងតុលាការ ឬសាលាក្ដី ប៉ុន្តែពួកគេពុំមានសិទ្ធិក្នុងការបោះឆ្នោតនោះទេ។

*មាត្រា ២៩០*
*វិធានការបណ្ដោះអាសន្ន*

១. ប្រសិនបើវិវាទមួយត្រូវបានបញ្ជូនត្រឹមត្រូវតាមនីតិវិធីទៅតុលាការ ឬសាលាក្ដីដែលមានយុត្តាធិការ ជារូបវន្តលើរឿងនោះក្រោមផ្នែកនេះ ឬផ្នែកទី ១១ ជំពូកទី៥ នោះតុលាការ ឬសាលាក្ដីដែលមានយុត្តាធិការនេះអាចចាត់ឱ្យមានវិធានការបណ្ដោះអាសន្នមួយតាមដែលខ្លួនយល់ថាសមស្របក្នុងកាលៈទេសៈ បែបនោះ ដើម្បីរក្សាការពារនូវសិទ្ធិរបស់ភាគីនៃរឿងវិវាទ ឬដើម្បីបង្ការការខូចខាតធ្ងន់ធ្ងរជាយថាហេតុដល់ បរិស្ថានសមុទ្រ រង់ចាំការសម្រេចដល់អង្គសេចក្ដី។

២. វិធានការបណ្ដោះអាសន្នទាំងនេះអាចនឹងមានការកែប្រែ ឬលុបចោលវិញភ្លាមៗ កាលបើមានកាលៈទេសៈ ប្រែប្រួល ឬផុតរលត់ទៅវិញ។

៣. វិធានការបណ្ដោះអាសន្នអាចនឹងត្រូវចាត់ឡើង មានការកែប្រែ ឬលុបចោលវិញស្របតាមមាត្រានេះតែក្នុង ករណីដែលស្នើឡើងដោយភាគីម្ខាងនៃវិវាទ និងបន្ទាប់ពីបណ្ដាភាគីត្រូវបានផ្ដល់ឱកាសដើម្បីស្ដាប់នូវវិធានការ នោះប៉ុណ្ណោះ។

៤. តុលាការ ឬសាលាក្ដីត្រូវផ្ដល់ការជូនដំណឹងភ្លាមៗទៅកាន់បណ្ដាភាគីនៃរឿងវិវាទ និងទៅកាន់រដ្ឋភាគី ដទៃទៀតតាមដែលខ្លួនយល់ថាសមស្រប ស្ដីពីការបង្គាប់ឱ្យចាត់វិធានការ ការកែប្រែ ឬការលុបចោល វិធានការបណ្ដោះអាសន្ននោះ។

៥. ខណៈដែលរង់ចាំការបង្កើតក្រុមប្រឹក្សាជំនុំជំរះដែលទទួលរឿងវិវាទក្រោមជំពូកនេះ តុលាការ ឬសាលា ជំនុំជំរះដែលព្រមព្រៀងដោយភាគីនៃវិវាទ ឬករណីមិនមានការព្រមព្រៀងគ្នានៅក្នុងរយៈពេលពីរសប្ដាហ៍គិតចាប់ពីកាលបរិច្ឆេទដាក់បណ្ដឹងសុំឱ្យចាត់វិធានការបណ្ដោះអាសន្ន សាលាក្ដីអន្តរជាតិផ្នែកច្បាប់សមុទ្រ ឬសភាវិវាទបាតសមុទ្រ

ករណីដែលទាក់ទងនឹងសកម្មភាពនៅក្នុងតំបន់ អាចបង្គាប់ឱ្យមានការចាត់វិធានការ កែប្រែ ឬលុបចោលវិធានការបណ្ដោះអាសន្នស្របទៅតាមមាត្រានេះ ប្រសិនបើខ្លួនយល់យ៉ាងជាក់ច្បាស់ថាសាលាក្ដីដែលត្រូវបង្កើតឡើងនោះ ជាស្ថាប័នដែលមានយុត្តាធិការ និងបានពិចារណាដល់ស្ថានភាពបន្ទាន់នៃរឿងនោះ។ នៅពេលដែលបង្កើតឡើង សាលាក្ដីដែលទទួលរឿងវិវាទនោះអាចធ្វើការកែប្រែ លុបចោល ឬយល់ព្រមលើវិធានការបណ្ដោះអាសន្នស្របទៅតាមកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤។

៦. បណ្ដាភាគីនៃរឿងវិវាទត្រូវអនុវត្តជាបន្ទាន់តាមវិធានការបណ្ដោះអាសន្នដែលចាត់ឡើងស្របតាមមាត្រានេះ។

*មាត្រា ២៩១*

*សិទ្ធិក្នុងការជ្រើសរើស*

១. រាល់នីតិវិធីដោះស្រាយវិវាទទាំងអស់ដូចមានចែងនៅក្នុងផ្នែកនេះ អាចឱ្យបណ្ដារដ្ឋភាគីអនុវត្តបានដោយបើកទូលាយ។

២. រាល់នីតិវិធីដោះស្រាយវិវាទទាំងអស់ដូចមានចែងនៅក្នុងផ្នែកនេះ អាចឱ្យបណ្ដាអង្គការក្រៅពីរដ្ឋភាគីដែល បានកំណត់យ៉ាងច្បាស់នៅក្នុងអនុសញ្ញានេះ អនុវត្តបានដោយបើកទូលាយ។

*មាត្រា ២៩២*

*ការដោះលែងឱ្យមានសេរីភាពភ្លាមៗនូវនាវា និងក្រុមនាវិក*

១. ក្នុងករណីដែលអាជ្ញាធរនៃរដ្ឋភាគីមួយបានឃាត់ទុកនាវាដែលប្រើទង់របស់រដ្ឋភាគីមួយផ្សេងទៀត

ហើយករណីដែលមានការបង្ហាញអង្គហេតុថា រដ្ឋដែលធ្វើការឃាត់ទុកនាវាមិនបានអនុវត្តទៅតាមបទបញ្ញត្តិនៃ អនុសញ្ញានេះដែលចែងពីការឱ្យដោះលែងមានសេរីភាពភ្លាមៗនូវនាវា ឬក្រុមនាវិកនៅលើនាវា ក្រោយពីមានការតម្កល់ប្រាក់ធានា ឬការធានាផ្នែកហិរញ្ញវត្ថុយ៉ាងត្រឹមត្រូវហើយនោះ នោះសំណុំរឿងនៃការ ដោះលែងពីការជាប់ឃុំអាចត្រូវរៀបចំបញ្ជូនឡើងទៅតុលាការ ឬសាលាក្តីណាមួយដោយមានការ ឯកភាពពីបណ្តាភាគីដែលពាក់ព័ន្ធ ឬក្នុងករណីដែលពុំអាចឈានដល់ការឯកភាពគ្នាបាននៅក្នុងរយៈពេល ១០ ថ្ងៃគិតចាប់ពីពេលនៃការឃាត់ទុកនោះត្រូវបញ្ជូនទៅកាន់តុលាការ ឬសាលាក្តីណាមួយដែលទទួលស្គាល់ដោយរដ្ឋ ដែលធ្វើការឃាត់ទុកស្របតាមមាត្រា ២៨៧ ឬអាចបញ្ជូនទៅកានសាលាក្តីអន្តរជាតិផ្នែកច្បាប់សមុទ្រលើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះដោយភាគីដែលពាក់ព័ន្ធ។

២. ការដាក់ពាក្យសុំឱ្យដោះលែងនាវាអាចធ្វើឡើងបានដោយ ឬក្នុងនាមរដ្ឋចុះបញ្ជីនាវាតែប៉ុណ្ណោះ។

៣. តុលាការ ឬសាលាក្តីត្រូវដំណើរការពិនិត្យលើពាក្យសុំឱ្យដោះលែងនាវាដោយគ្មានការពន្យារពេល និងត្រូវដោះស្រាយតែទៅលើបញ្ហាទាក់ទងនឹងការដោះលែងនាវាប៉ុណ្ណោះ ដោយមិននាំឱ្យប៉ះពាល់ទៅដល់បញ្ហា អង្គសេចក្តីនៃករណីជាកម្មវត្ថុនៅមុនពេលបើកសវនការក្នុងស្រុកដែលសមស្របប្រឆាំងនឹងនាវា នាវាបតី ឬនាវិកដែលធ្វើការនៅលើនាវាឡើយ។ ដោយឡែក អាជ្ញាធរនៃរដ្ឋដែលធ្វើការឃាត់ទុកនាវានៅតែមានសមត្ថកិច្ចក្នុងការដោះលែងនាវា ឬនាវិកនៅលើនាវាបានគ្រប់ពេលទាំងអស់។

៤. នៅពេលដែលមានការតម្កល់ប្រាក់ធានា ឬការធានាផ្នែកហិរញ្ញវត្ថុដែលតុលាការ ឬសាលាក្តីបានកំណត់ នោះអាជ្ញាធរនៃរដ្ឋដែលធ្វើការឃាត់នាវាត្រូវអនុវត្តភ្លាមៗតាមដីកាសម្រេចរបស់តុលាការ ឬសាលាក្តីលើបញ្ហាឱ្យដោះលែងនាវា ឬនាវិកដែលធ្វើការនៅលើនាវា។

*មាត្រា ២៩៣*

*ច្បាប់អនុវត្តន៍*

១. តុលាការ ឬសាលាក្តីដែលមានយុត្តាធិការក្រោមជំពូកនេះត្រូវទទួលអនុវត្តអនុសញ្ញានេះ ព្រមទាំងវិធាន ច្បាប់អន្តរជាតិផ្សេងទៀត ដែលមិនមានវិសមិតភាពជាមួយនឹងអនុសញ្ញានេះ។

២. កថាខណ្ឌទី ១ ខាងលើមិនត្រូវប៉ះពាល់ទៅដល់អំណាចរបស់តុលាការ ឬសាលាក្តីដែលមានយុត្តាធិការក្រោមជំពូកនេះ នៅក្នុងការសម្រេចលើរឿងក្តីផ្អែកតាមគោលការណ៍យុត្តិធម៌ត្រឹមត្រូវនោះឡើយ ប្រសិនបើភាគីដែលពាក់ព័ន្ធ យល់ព្រមទទួលយកការសម្រេចបែបនោះ។

*មាត្រា ២៩៤*
*នីតិវិធីត្រៀម*

១. តុលាការ ឬសាលាក្ដីដែលមានចែងនៅក្នុងមាត្រា ២៨៧ ដែលទទួលពាក្យបណ្ដឹងទាក់ទងនឹងរឿងវិវាទ ដូចមានចែងក្នុងមាត្រា ២៩៧ ត្រូវធ្វើការសម្រេចតាមការស្នើសុំរបស់ភាគីម្ខាង ឬអាចធ្វើការសម្រេចដោយផ្ទាល់បាន បើទោះជាការជូនសំអាងហេតុនាំឱ្យបំពានដល់ដំណើរការផ្លូវច្បាប់ ឬអង្គហេតុបឋមមានមូលដ្ឋានច្បាស់លាស់ក៏ដោយ។ ប្រសិនបើតុលាការ ឬសាលាក្ដីកំណត់ថាការជូនសំអាងហេតុនោះនាំទៅដល់ការបំពានលើដំណើរការផ្លូវច្បាប់ ឬអង្គហេតុបឋមពុំមានមូលដ្ឋានច្បាប់លាស់ នោះរឿងក្ដីជាកម្មវត្ថុមិនត្រូវចាត់ការជាបន្តឡើយ។

២. នៅពេលដែលទទួលបានពាក្យបណ្ដឹង តុលាការ ឬសាលាក្ដីត្រូវជូនដំណឹងភ្លាមៗទៅដល់ភាគីម្ខាង ឬ ភាគីនៃបណ្ដឹងវិវាទ និងត្រូវកំណត់រយៈពេលឱ្យបានច្បាស់លាស់ ដែលភាគីនៃរឿងវិវាទអាចដាក់ស្នើទៅតុលាការដើម្បីឱ្យធ្វើការសម្រេចស្របតាមកថាខណ្ឌទី១។

៣. គ្មានបញ្ញត្តិណាមួយនៅក្នុងមាត្រានេះ នាំឱ្យប៉ះពាល់ទៅដល់សិទ្ធិរបស់ភាគីណាមួយនៃរឿងវិវាទ ក្នុងការជំទាស់ជាបឋមស្របតាមវិធាននីតិវិធីជាធរមាននោះឡើយ។

*មាត្រា ២៩៥*
*ការប្រើប្រាស់ដំណោះស្រាយក្នុងស្រុកឱ្យអស់ពីលទ្ធភាព*

ក្នុងករណីដែលមានវិវាទណាមួយរវាងបណ្ដារដ្ឋភាគីទាក់ទងនឹងការបកស្រាយខ្លឹមសារ ឬការអនុវត្តអនុសញ្ញា នេះ

នោះរឿងវិវាទនេះអាចដាក់ឱ្យដោះស្រាយតាមនីតិវិធីដែលមានចែងក្នុងជំពូកនេះបានតែក្នុងករណីដែលពុំអាច ដោះស្រាយបានតាមរយៈដំណោះស្រាយនៅក្នុងស្រុក និងដែលតម្រូវដោយច្បាប់អន្តរជាតិប៉ុណ្ណោះ។

*មាត្រា ២៩៦*

*អាជ្ញាអស់ជំនុំ*

១. រាល់ដីកាសម្រេចរបស់តុលាការ ឬសាលាក្ដីដែលមានយុត្តាធិការក្រោមជំពូកនេះ ត្រូវមានអានុភាពស្ថាពរ និងអនុវត្តចំពោះគ្រប់បណ្ដាភាគីនៃវិវាទ។

២. រាល់ការសម្រេចខាងលើនឹងពុំមានអាជ្ញាអស់ជំនុំឡើយ លើកលែងតែរវាងភាគីដែលពាក់ព័ន្ធ និងក្នុងករណីពាក់ព័ន្ធនឹងវិវាទជាក់លាក់នោះ។

ជំពូកទី៣៖ ដែនអនុវត្តន៍ និងអញ្ញត្រកម្មនៃការអនុវត្តជំពូកទី ២

*មាត្រា ២៩៧*

*ដែនកំណត់នៃការអនុវត្តជំពូកទី ២*

១. ករណីវិវាទដែលទាក់ទងនឹងការបកស្រាយខ្លឹមសារ ឬការអនុវត្តអនុសញ្ញានេះ នៅក្នុងការប្រើប្រាស់នូវសិទ្ធិ អធិបតេយ្យភាពរបស់រដ្ឋជាប់ឆ្នេរ ឬដែលមានយុត្តាធិការក្រោមអនុញ្ញានេះ ត្រូវដោះស្រាយស្របតាម នីតិវិធីដូចមានចែងក្នុងជំពូកទី ២ លើករណីដូចខាងក្រោម៖

(ក) នៅពេលដែលមានការចោទប្រកាន់ថា រដ្ឋជាប់ឆ្នេរមួយបានប្រព្រឹត្តិទង្វើណាមួយដែលផ្ទុយទៅនឹង បទបញ្ញត្តិនៃអនុសញ្ញានេះដែលពាក់ព័ន្ធទៅដល់សិទ្ធិសេរីភាពនៃការធ្វើនាវាចរណ៍ ការហោះហើររំលងសមុទ្រ ឬការដាក់ពង្រាយបណ្ដាញខ្សែកាប្ល៍ និងបំពង់បញ្ជូនប្រេងនៅបាតសមុទ្រ ឬដែលទាក់ទងនឹងការប្រើប្រាស់ដោយចេតនាដទៃទៀតនូវដែនសមុទ្រដែលមានចែងនៅក្នុងមាត្រា ៥៨។

(ខ) នៅពេលដែលមានការចោទប្រកាន់ថារដ្ឋមួយនៅក្នុងការអនុវត្តនូវសិទ្ធិ សេរីភាព ឬការប្រើប្រាស់ដូច រៀបរាប់ខាងលើ បានប្រព្រឹត្តនូវទង្វើដែលផ្ទុយនឹងខ្លឹមសារអនុសញ្ញានេះ ឬច្បាប់ ឬបទបញ្ញត្តិដែលអនុម័ត ដោយរដ្ឋជាប់ឆ្នេរ

ស្របតាមខ្លឹមសារនៃអនុសញ្ញានេះ
និងវិធានច្បាប់អន្តរជាតិដទៃទៀតដែលមិនមាន វិសមិតភាពជាមួយអនុសញ្ញានេះ ឬ

(គ)

នៅពេលដែលមានការចោទប្រកាន់ថារដ្ឋជាប់ឆ្នេរបានប្រព្រឹត្តនូវទង្វើផ្ទុយនឹងវិធានច្បាប់ និងលិខិត បទដ្ឋានអន្តរជាតិជាក់លាក់ស្តីពីការការពារ និងអភិរក្សបរិស្ថានសមុទ្រដែលអនុវត្តចំពោះរដ្ឋជាប់ឆ្នេរ ហើយដែលបង្កើតឡើងដោយអនុសញ្ញានេះ ឬតាមរយៈអង្គការអន្តរជាតិ ឬសន្និសីទការទូតនានាស្របតាមខ្លឹមសារ នៃអនុសញ្ញានេះ។

២. (ក) ក្នុងករណីមានវិវាទទាក់ទងនឹងការបកស្រាយខ្លឹមសារ ឬអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះដែលទាក់ទងនឹងការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ រឿងវិវាទនោះត្រូវធ្វើការដោះស្រាយស្របតាមជំពូកទី២ លើកលែងតែក្នុងករណីដែលរដ្ឋជាប់ឆ្នេរមិនមានកាតព្វកិច្ចក្នុងការទទួលយកសំណុំរឿងដែលបានដាក់ជូនឱ្យធ្វើការដោះស្រាយវិវាទនានាដែលបណ្តាលមកពី ៖

(i) ការអនុវត្តសិទ្ធិសេរីភាព ឬឆន្ទានុសិទ្ធិណាមួយដែលធ្វើឡើងដោយរដ្ឋជាប់ឆ្នេរស្របតាមមាត្រា ២៤៦ ឬ

(ii) ការសម្រេចរបស់រដ្ឋជាប់ឆ្នេរបង្គាប់ឱ្យផ្អាកជាបណ្តោះអាសន្ន ឬបញ្ឈប់ការអនុវត្តគម្រោង ស្រាវជ្រាវស្របតាមមាត្រា ២៥៣។

(ខ)

ក្នុងករណីដែលមានវិវាទជាលទ្ធផលពីការចោទប្រកាន់របស់រដ្ឋដែលធ្វើការស្រាវជ្រាវទាក់ទងនឹង
គម្រោងជាក់លាក់ណាមួយដែលរដ្ឋជាប់ឆ្នេរមិនអនុវត្តនូវសិទ្ធិរបស់ខ្លួនដូចមានចែ

ងនៅក្នុងមាត្រា ២៤៦ និងមាត្រា ២៥៣ ស្របទៅតាមខ្លឹមសារនៃអនុសញ្ញានេះ រឿងវិវាទនោះត្រូវបញ្ជូនតាមការ ស្នើរបស់ភាគីណាមួយ ឱ្យធ្វើការផ្សះផ្សាសម្រុះសម្រួលស្របតាមឧបសម្ព័ន្ធទី៥ ជំពូកទី២ ក្នុងលក្ខខណ្ឌដែលគណៈកម្មការផ្សះផ្សាសម្រុះសម្រួលមិនបានកោះហៅធ្វើការសាកសួរពីការអនុវត្តនូវ ឆន្ទានុសិទ្ធិរបស់រដ្ឋជាប់ឆ្នេរ ដើម្បីឱ្យកំណត់ពីតំបន់ជាក់លាក់ដូចដែលមានចែងនៅក្នុងមាត្រា ២៤៦ កថាខណ្ឌទី៦
ឬការអនុវត្តនូវឆន្ទានុសិទ្ធិរបស់រដ្ឋនោះដោយបដិសេធន៍ផ្តល់ការយល់ព្រមស្របតាម កថាខណ្ឌទី៥ មាត្រា ២៤៦។

៣. (ក) ក្នុងករណីដែលមានវិវាទទាក់ទងនឹងការបកស្រាយខ្លឹមសារ ឬការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ លើបញ្ហាទាក់ទងនឹងវិស័យជលផល រឿងវិវាទនោះត្រូវធ្វើការដោះស្រាយស្របតាមជំពូកទី២ លើកលែងតែរដ្ឋជាប់ឆ្នេរពុំមានកាតព្វកិច្ចទទួលយករឿងវិវាទដែលដាក់ជូនឱ្យដោះស្រាយទាក់ទងនឹងសិទ្ធិអធិបតេយ្យភាពរបស់ខ្លួនទាក់ទងនឹងធនធានមានជីវិតដែលមាននៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬទាក់ទងនឹងការអនុវត្តនូវសិទ្ធិរបស់ខ្លួន រាប់បញ្ចូលទាំងសិទ្ធិឆន្ទានុសិទ្ធិនៅក្នុងការកំណត់ពីទិន្នផលនេសាទដែលអនុញ្ញាត សមត្ថភាពប្រមូលទិន្នផលរបស់ខ្លួន ការបែងចែកផលដែលលើសទៅដល់រដ្ឋដទៃទៀត និងការអនុវត្តនូវលក្ខខណ្ឌដែល មានចែងនៅក្នុងច្បាប់ និងបទបញ្ញត្តិស្តីពីកិច្ចអភិរក្ស និងគ្រប់គ្រងធនធានរបស់រដ្ឋនោះ។

(ខ)

នៅក្នុងករណីដែលពុំមានដំណោះស្រាយតាមរយៈឧបាស្រ័យដូចមានចែងក្នុងជំពូកទី១នៃផ្នែកនេះ រឿងវិវាទនោះត្រូវបញ្ជូនឱ្យធ្វើការដោះស្រាយតាមរយៈការផ្សះផ្សាសម្រុះសម្រួលស្រប

តាមឧបសម្ព័ន្ធទី៥ ជំពូកទី២ តាមការស្នើរបស់ភាគីណាមួយនៃរឿងវិវាទ នៅពេលដែលមានការចោទប្រកាន់ថា៖

(i) រដ្ឋជាប់ឆ្នេរមួយមានការខកខានយ៉ាងច្បាស់ក្នុងការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការថែរក្សាធនធានមានជីវិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មិនឱ្យរងការអន្តរាយធ្ងន់ធ្ងរ តាមរយៈការដាក់ចេញនូវ វិធានការអភិរក្ស និងការពារដែលសមស្រប។

(ii) រដ្ឋជាប់ឆ្នេរមួយបានធ្វើការបដិសេធន៍ដោយទំនើងចិត្តបើទោះបីមានការស្នើសុំពីរដ្ឋមួយផ្សេងទៀត នៅក្នុងការកំណត់ពីទិន្នផលនេសាទដែលអនុញ្ញាត និងសមត្ថភាពក្នុងការប្រមូលផលធនធានមានជីវិតរបស់ខ្លួន នូវស្តុកផលនេសាទដែលដែលរដ្ឋដទៃមានចំណាប់អារម្មណ៍ក្នុងការនេសាទ ឬ

(iii) រដ្ឋជាប់ឆ្នេរមួយបានធ្វើការបដិសេធន៍ដោយទំនើងចិត្តក្នុងការបែងចែកទៅឱ្យរដ្ឋដទៃទៀតស្របតាមមាត្រា ៦២ មាត្រា ៦៩ និងមាត្រា៧០ និងក្រោមលក្ខខណ្ឌដែលបង្កើតឡើងដោយរដ្ឋជាប់ឆ្នេរនោះ ស្របតាមខ្លឹមសារនៃអនុសញ្ញានេះ នូវផលដែលលើសទាំងស្រុង ឬមួយផ្នែកដែលបានប្រកាសថាមានដោយរដ្ឋនោះ។

(គ) ទោះជានៅក្នុងករណីណាក៏ដោយ គណៈកម្មការផ្សះផ្សាសម្រុះសម្រួលមិនត្រូវប្រើឆន្ទានុសិទ្ធិរបស់ខ្លួនជំនួសមខរដ្ឋជាប់ឆ្នេរបានឡើយ។

(ឃ) របាយការណ៍ផ្សះផ្សាសម្រុះសម្រួលរបស់គណៈកម្មការផ្សះផ្សាសម្រុះសម្រួលត្រូវបញ្ជូនទៅបណ្តា អង្គការអន្តរជាតិដែលពាក់ព័ន្ធ។

(ង) នៅក្នុងការចរចាលើកិច្ចព្រមព្រៀងស្របតាមមាត្រា ៦៩ និងមាត្រា ៧០ រដ្ឋភាគីត្រូវដាក់បញ្ចូលប្រការ ស្តីពីវិធានការដែលត្រូវចាត់ឡើងលើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ដើម្បីកាត់បន្ថយឱ្យបាន ច្រើនបំផុតតាមលទ្ធភាពដែលអាចធ្វើទៅបាននូវការខ្វែងគំនិតគ្នាដែលទាក់ទងនឹងការបកស្រាយខ្លឹមសារ ឬ ការអនុវត្តកិច្ចព្រមព្រៀងនេះ និងអំពីការដាក់ឱ្យដំណើរការនូវវិធានការទាំងនោះ ក្នុងករណីដែលមានការខ្វែងគំនិតគ្នា ។

*មាត្រា ២៩៨*

*ជម្រើសអញ្ញត្រកម្មនៃការអនុវត្តជំពូកទី ២*

១. នៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ឬនៅពេលជាបន្តបន្ទាប់នោះរដ្ឋមួយអាចធ្វើការប្រកាសជាលាយលក្ខណ៍អក្សរដោយមិនប៉ះពាល់ទៅដល់កាតព្វកិច្ចដែលមានចែងក្នុងជំពូកទី១ថា ខ្លួនពុំទទួលយកបាននូវនីតិវិធីណាមួយ ឬលើសពីមួយដូចដែលមានចែងនៅក្នុងជំពូកទី២ ស្តីពីប្រភេទវិវាទមួយ ឬលើសពីមួយដូចខាងក្រោម ៖

(ក) (i) វិវាទដែលទាក់ទងនឹងការបកស្រាយខ្លឹមសារ ឬការអនុវត្តមាត្រា ១៥ មាត្រា ៧៤ និងមាត្រា ៨៣ ស្តីពីឆកសមុទ្រ ឬកម្មសិទ្ធិជាប្រវត្តិសាស្ត្រ ក្នុងលក្ខខណ្ឌដែលរដ្ឋធ្វើការប្រកាសនោះ យល់ព្រមទទួលយករឿង វិវាទដែលបញ្ជូនមកដោះស្រាយផ្សះផ្សាសម្រុះសម្រួលស្របតាមឧបសម្ព័ន្ធទី ៥ នៅពេលវិវាទជាកម្មវត្ថុអាចនាំទៅដល់ការចូលជាធរមាននៃអនុសញ្ញានេះ និងក្នុងករណីដែលវាពុំអាចឈានដល់ការព្រមព្រៀងគ្នាបាន តាមរយៈការចរចាគ្នារវាងភាគីនៃវិវាទនៅក្នុងអំឡុងពេលដែលសមស្រប

និងក្នុងលក្ខខណ្ឌដែលវិវាទនោះ
មានការជាប់ពាក់ព័ន្ធជាចាំបាច់ជាមួយនឹងរឿងវិវាទទាក់ទងនឹងអធិបតេយ្យភាព
ឬសិទ្ធដទៃទៀតលើបូរណភាពដែនដីទ្វីបឬកោះដែលនៅមិនទាន់បានដោះស្រាយ និងកំពុងស្ថិតក្រោមការពិចារណាក្នុងពេល ដំណាលគ្នា ហើយដែលមានលក្ខណៈដាច់ដោយឡែកពីរឿងវិវាទដែលបានដាក់ជូន។

(ii)

ក្រោយពេលដែលគណៈកម្មការផ្សះផ្សាសម្រុះសម្រួលបានបង្ហាញពីរបាយការណ៍របស់ខ្លួនដែលមានបញ្ជាក់ពីសំអាងហេតុផងដែរ នោះភាគីនៃរឿងវិវាទត្រូវធ្វើការចរចាគ្នាលើកិច្ចព្រមព្រៀងដោយយករបាយការណ៍នេះជាគោល
ហើយប្រសិនបើការចរចាគ្នានេះមិននាំទៅដល់ការព្រមព្រៀងគ្នាបាន នោះភាគីនៃរឿងវិវាទតាមការព្រមព្រៀងគ្នាអាចបញ្ជូនរឿងវិវាទនេះទៅដោះស្រាយស្របតាមនិតិវិធីណាមួយដែលមាន ចែងនៅក្នុងជំពូកទី២ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះរវាងភាគីនៃរឿងវិវាទ។

(iii) កថាខណ្ឌរងនេះមិនអនុវត្តចំពោះវិវាទអំពីព្រំប្រទល់សមុទ្រ ដែលត្រូវធ្វើការដោះស្រាយជាចុងក្រោយតាមរយៈការព្រមព្រៀងគ្នារវាងភាគីនៃរឿងវិវាទនោះទេ ឬចំពោះវិវាទទាំងឡាយដែលត្រូវធ្វើការដោះស្រាយស្របតាមកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ដែលមានអានុភាពចំពោះភាគីនៃរឿងវិវាទនោះដែរ។

(ខ) វិវាទទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពយោធា រាប់បញ្ចូលទាំងសកម្មភាពយោធារបស់នាវា និង អាកាសយានរបស់រដ្ឋាភិបាលដែលធ្វើប្រតិបត្តិការបេសកកម្មមិនមែនក្នុងគោលបំណងពាណិជ្ជកម្ម

និងវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពអនុវត្តច្បាប់លើការប្រើប្រាស់នូវសិទ្ធិអធិបតេយ្យភាព ឬយុត្តាធិការដាច់ដោយឡែកពីយុត្តាធិការរបស់តុលាការ ឬសាលាក្តីដូចដែលមានចែងក្នុងកថាខណ្ឌទី២ ឬទី៣ នៃមាត្រា ២៩៧។

(គ)

វិវាទទាក់ទងនឹងការបំពេញតួនាទីរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិដែលបានប្រគល់ដល់ខ្លួនក្រោមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ លើកលែងតែក្រុមប្រឹក្សាសន្តិសុខធ្វើការសម្រេចដកចេញបញ្ហានេះពីរបៀបវារៈរបស់ខ្លួន ឬកោះហៅឱ្យភាគីនៃរឿងវិវាទធ្វើការដោះស្រាយវិវាទនោះតាមរយៈមធ្យោបាយដែលមានចែងនៅក្នុងអនុសញ្ញានេះ។

២. រដ្ឋភាគីដែលធ្វើការប្រកាសក្រោមកថាខណ្ឌទី១ខាងលើ អាចដកសេចក្តីប្រកាសនេះវិញបានគ្រប់ពេល ឬព្រមព្រៀងបញ្ជូនរឿងវិវាទដែលដាច់ដោយឡែកពីសេចក្តីប្រកាសខាងលើ ដើម្បីដោះស្រាយតាមនីតិវិធីណាមួយដូចមានចែងនៅក្នុងអនុសញ្ញានេះបាន។

៣. រដ្ឋភាគីដែលធ្វើការប្រកាសក្រោមកថាខណ្ឌទី១ ខាងលើ មិនមានសិទ្ធិបញ្ជូនរឿងវិវាទដែលស្ថិតក្នុងប្រភេទ វិវាទអញ្ញត្រកម្ម ដើម្បីធ្វើការដោះស្រាយតាមនីតិវិធីណាមួយដូចមានចែងក្នុងអនុសញ្ញានេះប្រឆាំងទៅនឹងរដ្ឋភាគីមួយផ្សេងទៀតដោយគ្មានការព្រមព្រៀងពីភាគីនោះបានឡើយ។

៤. ប្រសិនបើរដ្ឋភាគីមួយបានធ្វើការប្រកាសរេកាមកថាខណ្ឌទី១(ក) នោះរដ្ឋភាគីដទៃអាចមានសិទ្ធិបញ្ជូនរឿង វិវាទដែលស្ថិតក្នុងប្រភេទវិវាទអញ្ញត្រកម្ម ដើម្បីធ្វើការដោះស្រាយស្របតាម នីតិវិធីដែលមានចែងក្នុងសេចក្តីប្រកាសប្រឆាំងនឹងភាគីដែលធ្វើការប្រកាសនេះបាន។

៥. ការធ្វើសេចក្តីប្រកាសជាថ្មី ឬការដកសេចក្តីប្រកាសវិញមិននាំឱ្យប៉ះពាល់ដោយប្រការណាមួយទៅដល់នីតិវិធី

ត្រៀមមុនពេលតុលាការ ឬសាលាក្តីសម្រេចដល់អង្គសេចក្តីស្របតាមមាត្រានេះឡើយ លើកលែងតែមានការព្រមព្រៀងគ្នាដោយឡែករវាងភាគីនៃរឿងវិវាទ។

៦. សេចក្តីប្រកាស និងលិខិតជូនដំណឹងអំពីការដកសេចក្តីប្រកាសដែលធ្វើឡើងក្រោមមាត្រានេះ ត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលមានតួនាទីចម្លងចែកចាយលិខិតខាងលើទៅដល់បណ្តារដ្ឋភាគី។

*មាត្រា ២៩៩*

*សិទ្ធិរបស់ភាគីក្នុងការព្រមព្រៀងលើនីតិវិធី*

១. វិវាទដែលត្រូវបានដកចេញក្រោមមាត្រា ២៩៧ ឬវិវាទអញ្ញត្រកម្មដោយសេចក្តីប្រកាសដែលធ្វើឡើងក្រោមមាត្រា ២៩៨ ដាច់ដោយឡែកពីនីតិវិធីដោះស្រាយវិវាទដែលមានចែងក្នុងជំពូកទី២ អាចត្រូវបានបញ្ជូនឱ្យដោះស្រាយស្របតាមនីតិវិធីដែលមានការព្រមព្រៀងគ្នារវាងភាគីនៃរឿងវិវាទតែប៉ុណ្ណោះ។

២. គ្មានបញ្ញត្តិណាមួយនៃជំពូកនេះនាំឱ្យប៉ះពាល់ទោដល់សិទ្ធិរបស់ភាគីនៃរឿងវិវាទក្នុងការព្រមព្រៀងគ្នាលើនីតិវិធីដទៃទៀតក្នុងការដោះស្រាយវិវាទ ឬដើម្បីឈានដល់ដំណោះស្រាយក្នុងលក្ខណៈមិត្តភាពនោះឡើយ។

## ផ្នែកទី១៦៖ បទបញ្ញត្តិទូទៅ

*មាត្រា ៣០០*

*សុចរិតភាព និងការរំលោភសិទ្ធិ*

បណ្តារដ្ឋភាគីត្រូវបំពេញកាតព្វកិច្ចដែលមានចែងក្រោមអនុសញ្ញានេះដោយអំពើសុចរិតទៀងត្រង់ និងត្រូវ ប្រើប្រាស់នូវសិទ្ធិ យុត្តាធិការ និងសេរីភាពដែលទទួលស្គាល់ក្រោមអនុសញ្ញានេះឱ្យបានត្រឹមត្រូវដោយមិនរំលោភព បំពានទៅដល់សិទ្ធិណាមួយឡើយ។

*មាត្រា ៣០១*

*ការប្រើប្រាស់ដែនសមុទ្រដោយសន្តិភាព*

នៅក្នុងការប្រើប្រាស់សិទ្ធិ និងអនុវត្តនូវតួនាទីរបស់ខ្លួនដែលមានក្រោមអនុសញ្ញានេះ បណ្តារដ្ឋភាគីត្រូវវៀរ ចាកពីអំពើគំរាមកំហែង ឬការប្រើកម្លាំងបាយប្រឆាំងមកលើបូរណភាពដែនដី ឬឯករាជ្យភាពខាងនយោបាយរបស់ រដ្ឋណាមួយ ឬក្នុងលក្ខណៈណាមួយដែលមិនស្របទៅនឹងគោលការណ៍ច្បាប់អន្តរជាតិដែលមានចែងនៅក្នុងធម្មនុញ្ញ របស់អង្គការសហប្រជាជាតិ។

*មាត្រា ៣០២*

*ការលាតត្រដាងព័ត៌មាន*

ដោយមិនគិតដល់សិទ្ធិរបស់រដ្ឋភាគីក្នុងការទាមទារឱ្យមាននីតិវិធីនៃការដោះស្រាយវិវាទដូចដែល បានចែងក្នុង អនុសញ្ញានេះ គ្មានបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះត្រូវចាត់ទុកថាជាការតម្រូវឱ្យរដ្ឋភាគីនោះបំពេញកាតព្វកិច្ច របស់ខ្លួនក្រោមអនុសញ្ញានេះ ក្នុងការផ្តល់ព័ត៌មានដែលប្រសិនបើត្រូវបានប្រកាស នាំឱ្យប្រឆាំងនឹងផលប្រយោជន៍ ជាចម្បងខាងផ្នែកសន្តិសុខរបស់ខ្លួននោះឡើយ។

*មាត្រា ៣០៣*

*បុរាណវត្ថុ និងវត្ថុបន្សល់ពីប្រវត្តិសាស្ត្រដែលប្រទះឃើញនៅសមុទ្រ*

១. បណ្តារដ្ឋទាំងឡាយមានតួនាទីរក្សាការពារបុរាណវត្ថុ និងវត្ថុបន្សល់ទុកពីប្រវត្តិសាស្ត្រ ដែលប្រទះឃើញនៅ ឯសមុទ្រ និងត្រូវផ្តល់កិច្ចសហប្រតិបត្តិការលើវិស័យនេះ ។

២. ដើម្បីទប់ស្កាត់ការធ្វើចរាចរណ៍វត្ថុទាំងនេះ រដ្ឋជាប់ឆ្នេរដោយអនុវត្តតាមមាត្រា ៣៣ អាចសន្មតថាការដឹកយកវត្ថុទាំងនេះពីបាតសមុទ្រនៅក្នុងតំបន់ដែលមានចែងក្នុងមាត្រាខាងលើដោយគ្មានការអនុញ្ញាតពីខ្លួន នឹងនាំទៅដល់ការបំពានលើបូរណភាពដែនដីរបស់ខ្លួន ឬច្បាប់ និងបទបញ្ញត្តិស្តីពីដែនសមុទ្រដែលមានចែងក្នុងមាត្រាខាងលើ។

៣.

គ្មានបញ្ញត្តិណាមួយនៃមាត្រានេះនាំឱ្យប៉ះពាល់ទៅដល់សិទ្ធិរបស់ម្ចាស់កម្មសិទ្ធិដែលគេអាចកំណត់ដឹង អត្តសញ្ញាណ ច្បាប់ស្តីពីការងារសង្គ្រោះ ឬវិធានច្បាប់សមុទ្រដទៃទៀត ឬច្បាប់ និងបែបបទអនុវត្តន៍ដែល ទាក់ទងនឹងការផ្លាស់ប្តូរខាងផ្នែកវប្បធម៌។

៤. មាត្រានេះមិននាំឱ្យប៉ះពាល់ទៅដល់កិច្ចព្រមព្រៀងអន្តរជាតិ និងវិធានច្បាប់អន្តរជាតិដទៃទៀតដែលទាក់ទង នឹងកិច្ចការពារបុរាណវត្ថុ និងវត្ថុបន្សល់ពីប្រវត្តិសាស្រ្តនោះឡើយ។

*មាត្រា ៣០៤*

*ការទទួលខុសត្រូវ និងបន្ទុកលើការខូចខាត*

បទបញ្ញត្តិនៃអនុញ្ញានេះស្តីពីការទទួលខុសត្រូវ និងបន្ទុកលើការខូចខាត មិនត្រូវនាំឱ្យប៉ះពាល់ទៅដល់ការអនុវត្តនូវវិធានជាធរមាន និងការបង្កើតវិធានច្បាប់បន្ថែមទៀតទាក់ទងនឹងការទទួលខុសត្រូវ និងបន្ទុកនានានៅក្រោមច្បាប់អន្តរជាតិនោះឡើយ។

## ផ្នែកទី១៧៖ អវសានប្បញ្ញត្តិ

*មាត្រា ៣០៥*

*ហត្ថលេខា*

១. អនុសញ្ញានេះត្រូវមានលក្ខណៈបើកទូលាយដែលអាចចុះហត្ថលេខាបានដោយ ៖

(ក) បណ្ដារដ្ឋទាំងអស់ ។

(ខ) សាធារណរដ្ឋណាំមីប៊ីយ៉ា ដែលតំណាងដោយក្រុមប្រឹក្សាណាំមីប៊ីយ៉ារបស់អង្គការសហប្រជាជាតិ។

(គ) រាល់បណ្ដារដ្ឋសម្ព័ន្ធមិត្តដែលមានស្វ័យអភិបាលកិច្ច ដែលបានជ្រើសរើសយកឋានៈនេះក្នុងការធ្វើការសម្រេចដោយផ្ទាល់ក្រោមការត្រួតពិនិត្យ និងអនុម័តដោយអង្គការសហប្រជាជាតិស្របតាមសេចក្ដីសម្រេចរបស់អង្គមហាសន្និបាតលេខ១៥១៤(ចំណុចទី១៥)ហើយដែលមានសមត្ថភាពលើរាល់បញ្ហាដែលគ្របដណ្ដប់ក្រោមអនុសញ្ញានេះរាប់បញ្ចូលទាំងសមត្ថភាពក្នុងការចុះសន្ធិសញ្ញាដែលមានកម្មវត្ថុទាក់ទងនឹងបញ្ហាទាំងនេះ។

(ឃ) រាល់បណ្ដារដ្ឋសម្ព័ន្ធមិត្តដែលមានស្វ័យអភិបាលកិច្ច ដែលទទួលបានសមត្ថភាពក្រោមឯកសារលក្ខន្តិកៈនៃរដ្ឋនោះលើរាល់បញ្ហាដែលគ្របដណ្ដប់ក្រោមអនុសញ្ញានេះរាប់បញ្ចូលទាំងសមត្ថភាពក្នុងការចុះសន្ធិសញ្ញាដែលមានកម្មវត្ថុទាក់ទងនឹងបញ្ហាទាំងនេះ។

(ង) រាល់បូរណភាពដែនដីដែលមានស្វ័យអភិបាលកិច្ចផ្ទៃក្នុងពេញលេញដែលទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ប៉ុន្តែមិនទាន់ទទួលបានឯករាជ្យភាពពេញលេញស្របតាមសេចក្ដីសម្រេចលេខ ១៥១៤ (ចំណុចទី១៥)

ហើយដែលមានសមត្ថភាពលើរាល់បញ្ហាដែលគ្របដណ្តប់ក្រោមអនុសញ្ញានេះរាប់បញ្ចូលទាំងសមត្ថភាពក្នុងការចុះសន្ធិសញ្ញាដែលមានកម្មវត្ថុទាក់ទងនឹងបញ្ហាទាំងនេះ។

(ច) បណ្តាអង្គការអន្តរជាតិដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី៩ ។

២. អនុសញ្ញានេះត្រូវបើកឱ្យចុះហត្ថលេខារហូតដល់ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨៤ នៅក្រសួងការបរទេសនៃប្រទេសចាម៉ៃកា និងចន្លោះចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៨៣ រហូតដល់ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨៤ នៅទីស្នាក់ការអង្គការសហប្រជាជាតិ ក្រុងញូវយ៉ក។

*មាត្រា ៣០៦*

*ការផ្តល់សច្ចាប័ន និងសេចក្តីបញ្ជាក់ជាផ្លូវការ*

អនុសញ្ញានេះស្ថិតក្រោមការផ្តល់សច្ចាប័នដោយបណ្តារដ្ឋ និងអង្គភាពដទៃទៀតដែលមានចែងក្នុងកថាខណ្ឌទី១(ខ)(គ)(ឃ) និង(ង)នៃមាត្រា៣០៥ ព្រមទាំងការផ្តល់សេចក្តីបញ្ជាក់ជាផ្លូវការស្របតាមឧបសម្ព័ន្ធទី៩ដោយបណ្តាអង្គភាពនានាដែលមានចែងក្នុងកថាខណ្ឌទី១(ច)នៃមាត្រា៣០៥។ លិខិតបទដ្ឋានក្នុងការផ្តល់សច្ចាប័ន និងការបញ្ជាក់ជាផ្លូវការត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

*មាត្រា ៣០៧*

*ការចូលជាសមាជិក*

អនុសញ្ញានេះត្រូវរក្សាបើកឱ្យចូលជាសមាជិកចំពោះបណ្តារដ្ឋនានា និងអង្គភាពផ្សេងៗដូចមានចែងក្នុង មាត្រា ៣០៥ ។ ការចូលជាសមាជិករបស់អង្គភាពនានាដូចមានចែងក្នុងកថាខណ្ឌទី១(ច)នៃមាត្រា ៣០៥ ត្រូវធ្វើឡើងស្របតាមឧបសម្ព័ន្ធទី៩។
លិខិតបទដ្ឋាននៃការចូលជាសមាជិកត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការ សហប្រជាជាតិ។

*មាត្រា ៣០៨*

*ការចូលជាធរមាន*

១. អនុសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល ១២ខែ បន្ទាប់ពីថ្ងៃតម្កល់ទុកលិខិតបទដ្ឋានលើកទីដប់ប្រាំមួយនៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកនៃអនុសញ្ញានេះ។

២. ចំពោះរដ្ឋនីមួយៗដែលផ្តល់សច្ចាប័ន ឬចូលជាសមាជិកភាពនៃអនុសញ្ញានេះក្រោយពេលដែលតម្កល់លិខិត បទដ្ឋានលើកទីដប់ប្រាំមួយនៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកនៃអនុសញ្ញានេះ នោះអនុសញ្ញានេះនឹង ត្រូវចូលជាធរមាននៅថ្ងៃទីសាមសិបបន្ទាប់ពីតម្កល់លិខិតបទដ្ឋានរបស់ខ្លួនលើការផ្តល់សច្ចាប័ន ឬការចូលជា សមាជិកនៃអនុសញ្ញានេះក្រោមកថាខណ្ឌទី១។

៣. សន្និបាតរបស់អាជ្ញាធរត្រូវជួបប្រជុំនៅថ្ងៃចូលជាធរមាននៃអនុសញ្ញានេះ និងត្រូវបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាជ្ញាធរ។ ក្រុមប្រឹក្សាដំបូងត្រូវបង្កើតឡើងក្នុងលក្ខណៈមួយស្របទៅកម្មវត្ថុនៃមាត្រា១៦១ ប្រសិនបើបទបញ្ញត្តិនៃមាត្រានោះមិនអាចឱ្យអនុវត្តបានយ៉ាងតឹងរឹង។

៤. សេចក្តីព្រាងនៃវិធាន បទបញ្ញត្តិ និងនីតិវិធីដែលរៀបចំបង្កើតដោយគណៈកម្មការរៀបចំកិច្ចការ ត្រូវយកមកអនុវត្តជាបណ្តោះអាសន្នរង់ចាំការអនុម័តជាផ្លូវការរបស់អាជ្ញាធរស្របតាមផ្នែកទី១១។

៥. អាជ្ញាធរ និងស្ថាប័នរបស់ខ្លួនត្រូវដើរតួនាទីស្របតាមសេចក្តីសម្រេចទី ២របស់អង្គសន្និបាតលើកទីបីរបស់អង្គការប្រជាជាតិស្តីពីច្បាប់សមុទ្រ ដែលទាក់ទងនឹងការត្រៀមលក្ខណៈវិនិយោគ

និងផ្អែកតាមសេចក្តីសម្រេចរបស់គណៈកម្មការរៀបចំកិច្ចការដែលធ្វើឡើងស្របតាមសេចក្តីសម្រេចខាងលើ។

*មាត្រា ៣០៩*

*ឧបម្រុង និងអញ្ញត្រកម្ម*

ពុំមានឧបម្រុង ឬអញ្ញត្រកម្មណាមួយលើអនុសញ្ញានេះឡើយ លុះត្រាតែលមានការអនុញ្ញាតយ៉ាងច្បាស់លាស់ក្រោមមាត្រាផ្សេងទៀតនៃអនុសញ្ញានេះ។

*មាត្រា ៣១០*

*សេចក្តីប្រកាស និងសេចក្តីថ្លែងការណ៍*

មាត្រា ៣០៩ មិនត្រូវដាក់កម្រិតលើរដ្ឋណាមួយដែលបានចុះហត្ថលេខា ឬផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ នៅក្នុងការធ្វើសេចក្តីប្រកាស ឬសេចក្តីថ្លែងការណ៍ដែលមានសំណង់ឃ្លា ឬមានចំណងជើងក្នុងទិសដៅធ្វើឱ្យមានសុខដុមនីយកម្មនៃច្បាប់ និងបទបញ្ញត្តិនៃរដ្ឋរបស់ខ្លួនជាមួយនឹងខ្លឹមសារនៃអនុសញ្ញានេះឡើយ ប្រសិនបើ សេចក្តីប្រកាស ឬសេចក្តីថ្លែងការណ៍នោះមិនមានគោលដៅច្រានចោល ឬកែប្រែអានុភាពគតិយុត្តនៃបទបញ្ញត្តិរបស់អនុសញ្ញានេះនៅក្នុងការអនុវត្តបទបញ្ញត្តិទាំងនេះចំពោះរដ្ឋសាមី។

*មាត្រា ៣១១*

*ភាពទាក់ទងគ្នាជាមួយនឹងអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត*

១. សម្រាប់បណ្តារដ្ឋភាគី អនុសញ្ញានេះត្រូវមានឧត្តមានុភាពលើអនុសញ្ញាក្រុងហ្សឺណែវស្តីពីច្បាប់សមុទ្រចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៥៨។

២. ដោយឡែក អនុសញ្ញានេះមិននាំទៅដល់ការកែប្រែនូវសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋភាគីដែលបង្កើតឡើងក្រោមកិច្ចព្រមព្រៀងដទៃទៀតដែលមានខ្លឹមសារស្របតាមអនុសញ្ញានេះ ហើយដែលមិននាំឱ្យប៉ះពាដល់ទៅដល់ការប្រើប្រាស់នូវសិទ្ធិរបស់រដ្ឋដទៃ ឬការអនុវត្តនូវកាតព្វកិច្ចរបស់រដ្ឋទាំងនោះក្រោមអនុសញ្ញានេះឡើយ។

៣. រដ្ឋភាគីពីរ ឬច្រើនជាងនេះអាចចុះកិច្ចព្រមព្រៀងស្តីពីការកែប្រែ ឬផ្អាកការអនុវត្តនូវបទបញ្ញត្តិនៃអនុសញ្ញានេះបានដែលអនុវត្តទាំងស្រុងទៅលើទំនាក់ទំនងរវាងរដ្ឋទាំងនោះក្នុងលក្ខខណ្ឌដែលកិច្ចព្រមព្រៀងនេះមិនមានទំនាក់ទំនងជាមួយនឹងបដិបញ្ញត្តិដែលមានវិសមិតភាពនឹងអានុភាពក្នុងការអនុវត្តតាមកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះ និងក្នុងលក្ខខណ្ឌដែលកិច្ចព្រមព្រៀងនេះមិនមានអានុភាពលើការអនុវត្តគោលការណ៍មូលដ្ឋានដែលមានចែងក្នុងអនុសញ្ញានេះ និងប្រសិនបើខ្លឹមសារនៃកិច្ចព្រមព្រៀងនេះមិននាំឱ្យប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិរបស់រដ្ឋភាគីដទៃ ឬការអនុវត្តនូវកាតព្វកិច្ចរបស់រដ្ឋទាំងនេះនៅក្រោមអនុសញ្ញានេះ។

៤.

បណ្តារដ្ឋភាគីដែលមានបំណងចុះកិច្ចព្រមព្រៀងដូចមានចែងក្នុងកថាខណ្ឌទី៣ខាងលើត្រូវជូនដំណឹងដល់រដ្ឋភាគីដទៃទៀតតាមរយៈអង្គភាពរក្សាតម្កល់អនុសញ្ញានេះស្តីពីចេតនារបស់ពួកគេក្នុងការចុះកិច្ចព្រមព្រៀងនេះ និងអំពីការកែប្រែ ឬការផ្អាកអនុវត្តនូវបទបញ្ញត្តិនោះ។

៥. មាត្រានេះមិននាំឱ្យប៉ះពាល់ទៅដល់កិច្ចព្រមព្រៀងអន្តរជាតិដែលអនុញ្ញាតឱ្យបង្កើតឡើង ឬរក្សាទុកក្រោមមាត្រាដទៃទៀតនៃអនុសញ្ញានេះឡើយ។

៦.

បណ្ដារដ្ឋភាគីព្រមព្រៀងគ្នាថាមិនធ្វើវិសោធនកម្មទៅលើគោលការណ៍មូលដ្ឋានទាក់ទងនឹងបេតិកភណ្ឌដែលជាសម្បត្តិសមូហភាពរបស់មនុស្សជាតិដូចមានចែងក្នុងមាត្រា១៣៦ និងថាខ្លួននឹងមិនក្លាយជាភាគីនៃកិច្ចព្រមព្រៀងណាមួយដែលមានបដិបញ្ញត្តិជាមួយអនុសញ្ញានេះឡើយ ។

*មាត្រា ៣១២*

*វិសោធនកម្ម*

១. បន្ទាប់ពីផុតកំណត់រយៈពេល១០ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមាន រដ្ឋភាគីមួយអាចដាក់ស្នើសុំឱ្យធ្វើវិសោធនកម្មជាក់លាក់ទៅលើអនុសញ្ញានេះ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ លើកលែងតែទៅលើបទបញ្ញត្តិដែលទាក់ទងនឹងសកម្មភាពនៅក្នុងតំបន់និងអាចស្នើឱ្យកោះប្រជុំសន្និសីទ ដើម្បីពិនិត្យពិចារណាទៅលើសំណើឱ្យធ្វើវិសោធនកម្មខាងលើបាន។ អគ្គលេខាធិការត្រូវថតចម្លងចែកចាយលិខិតជូនដំណឹងនេះទៅកាន់បណ្ដារដ្ឋភាគីទាំងអស់។ ដោយឡែកក្នុងករណីដែលពុំមានការឆ្លើយតបគាំទ្រចំពោះសំណើនេះដោយរដ្ឋភាគីយ៉ាងតិចពាក់កណ្ដាលនៅក្នុងរយៈពេល១២ខែ គិតចាប់ពីថ្ងៃចែកចាយលិខិតជូនដំណឹងខាងលើ នោះអគ្គលេខាធិការត្រូវកោះប្រជុំសន្និសីទ។

២. នីតិវិធីនៃការសម្រេចដែលអនុវត្តនៅក្នុងសន្និសីទស្ដីពីការធ្វើវិសោធនកម្មនេះ ត្រូវអនុវត្តទៅតាមបែបបទដូចគ្នានឹងនីតិវិធីនៅក្នុងសន្និសីទលើកទីបីរបស់អង្គការសហប្រជាជាតិស្ដីពីច្បាប់សមុទ្រដែរលើកលែងតែអង្គសន្និសីទធ្វើការសម្រេចផ្សេងពីនេះ។ អង្គសន្និសីទត្រូវខិតខំព្យាយាមដើម្បីឈានទៅដល់ការព្រមព្រៀងគ្នា ជាឯកច្ឆន្ទទៅលើការធ្វើវិសោធនកម្ម

និងការសម្រេចដោយការបោះឆ្នោតមិនត្រូវធ្វើឡើងឡើយលុះត្រាតែពុំអាចឈានដល់ការព្រមព្រៀងគ្នាជាឯកច្ឆន្ទ។

*មាត្រា ៣១៣*

*ការធ្វើវិសោធនកម្មតាមនីតិវិធីសាមញ្ញ*

១. រដ្ឋភាគីមួយអាចដាក់សំណើឱ្យធ្វើវិសោធនកម្មលើអនុសញ្ញានេះបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិលើកលែងតែការធ្វើវិសោធនកម្មដែលទាក់ទងទៅនឹងសកម្មភាពនៅក្នុងតំបន់ដោយអនុវត្តទៅតាមនីតិវិធីសាមញ្ញដូចមានចែងនៅក្នុងមាត្រានេះ ដោយពុំចាំបាច់ធ្វើការកោះប្រជុំសន្និសីទឡើយ។ អគ្គលេខាធិការត្រូវថតចម្លងចែកចាយលិខិតជូនដំណឹងនេះទៅដល់បណ្តារដ្ឋភាគីទាំងអស់។ ដោយឡែកប្រសិនបើនៅក្នុងរយៈពេល១២ខែគិតចាប់ពីថ្ងៃចែកចាយលិខិតជូនដំណឹងខាងលើរដ្ឋភាគីណាមួយជំទាស់ទៅលើសំណើសុំការធ្វើវិសោធនកម្មនេះ ឬទៅលើសំណើសុំការអនុម័តច្បាប់វិសោធនកម្មនេះស្របតាមនីតិវិធីសាមញ្ញ នោះច្បាប់វិសោធនកម្មត្រូវចាត់ទុកថាត្រូវបានបដិសេធ។ ក្នុងករណីនេះ អគ្គលេខាធិការត្រូវធ្វើការជូនដំណឹងភ្លាមៗទៅដល់រាល់បណ្តារដ្ឋភាគីទាំងអស់ទៅតាមនោះ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើនៅក្នុងអំឡុងពេល១២ខែ គិតចាប់ពីកាលបរិច្ឆេទចែកចាយលិខិតជូនដំណឹងនេះពុំមានរដ្ឋភាគីណាមួយជំទាស់ទៅនឹងសំណើសុំការធ្វើវិសោធនកម្ម ឬទៅលើសំណើសុំការអនុម័តលើច្បាប់វិសោធនកម្មស្របតាមនីតិវិធីសាមញ្ញទេនោះ សំណើសុំធ្វើវិសោធនកម្មនេះត្រូវចាត់ទុកថាត្រូវបានអនុម័តរួចរាល់។ ក្នុងករណីនេះ អគ្គលេខាធិការត្រូវធ្វើការជូនដំណឹងទៅដល់បណ្តារដ្ឋភាគីទាំងអស់ថា សំណើសុំការធ្វើវិសោធនកម្មនេះត្រូវបានអនុម័តយករួចរាល់។

*មាត្រា ៣១៤*

*ការធ្វើវិសោធនកម្មលើបទបញ្ញត្តិនៃអនុសញ្ញានេះដែលមានការទាក់ទងទាំងស្រុង ជាមួយនឹងសកម្មភាពនៅក្នុងតំបន់*

១.

រដ្ឋភាគីមួយអាចដាក់សំណើឱ្យធ្វើវិសោធនកម្មលើបទបញ្ញត្តិនៃអនុសញ្ញានេះបានដោយធ្វើការជូនដំណឹង ជាលាយលក្ខណ៍អក្សរទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ កាលបើវាមានការទាក់ទងទាំងស្រុងជាមួយនឹងសកម្មភាពនៅក្នុងតំបន់ ដោយរាប់បញ្ចូលទាំងឧបសម្ព័ន្ធទី៦ នៃជំពូកទី ៤ផងដែរ។ ក្នុងករណីនេះ អគ្គលេខាធិការត្រូវថតចម្លងចែកចាយលិខិតជូនដំណឹងនេះទៅកាន់បណ្ដារដ្ឋភាគីទាំងអស់។ សំណើសុំការធ្វើវិសោធនកម្មនេះត្រូវស្ថិតក្រោមការអនុម័តឯកភាពរបស់អង្គសន្និបាត បន្ទាប់ពីមានការយល់ព្រមតាមសំណើពីក្រុមប្រឹក្សា។ តំណាងរបស់រដ្ឋភាគីដែលមានសមាសភាពនៅក្នុងស្ថាប័នទាំងនេះត្រូវមានសិទ្ធិអំណាចពេញលេញក្នុងការពិនិត្យ និងសម្រេចលើសំណើសុំការធ្វើវិសោធនកម្មនេះ។ សំណើសុំការធ្វើវិសោធនកម្មដែលបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សា និងអង្គសន្និបាតត្រូវចាត់ទុកថាត្រូវបានអនុម័តយក។

២. នៅមុនពេលផ្ដល់ការអនុម័លើច្បាប់វិសោធនកម្មណាមួយក្រោមកថាខណ្ឌទី១ ខាងលើក្រុមប្រឹក្សា និងអង្គសន្និបាតត្រូវធានាថាប្រព័ន្ធនៃការស្រាវជ្រាវ និងធ្វើអាជីវកម្មលើធនធានក្នុងតំបន់នឹងមិនមានការប៉ះពាល់ ដោយរង់ចាំរហូតដល់អង្គសន្និសីទរំលឹកដែលកោះឡើងស្របតាមមាត្រា ១៥៥ ។

*មាត្រា ៣១៥*

*ការចុះហត្ថលេខា ការផ្ដល់សច្ចាប័ន ការចូលជាសមាជិក និងអត្ថបទយថាភូតនៃច្បាប់វិសោធនកម្ម*

១.

នៅពេលដែលបានអនុម័តយកច្បាប់វិសោធនកម្មលើអនុសញ្ញានេះត្រូវបើកឱ្យបណ្តារដ្ឋភាគីចុះហត្ថលេខា នៅទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ នៅក្នុងអំឡុងពេល ១២ខែ គិតចាប់ពីកាលបរិច្ឆេទដែលបានអនុម័ត
លើកលែងតែមានប្រការចែងដោយឡែកពីនេះនៅក្នុងច្បាប់វិសោធនកម្មនេះ។

២. មាត្រា៣០៦ មាត្រា៣០៧ និងមាត្រា៣២០ ត្រូវយកមកអនុវត្តលើរាល់ច្បាប់វិសោធនកម្មទាំងអស់ដែលធ្វើឡើងលើអនុសញ្ញានេះ។

*មាត្រា ៣១៦*

*ការចូលជាធរមាននៃច្បាប់វិសោធនកម្ម*

១. ច្បាប់វិសោធនកម្មលើអនុសញ្ញានេះក្រៅពីអ្វីដូចមានចែងនៅក្នុងកថាខណ្ឌទី៥ ត្រូវចូលជាធរមាន និងមានអានុភាពលើបណ្តារដ្ឋភាគីដែលផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃច្បាប់នេះនៅថ្ងៃទីដប់បី បន្ទាប់ពីការតម្កល់នូវលិខិតបទដ្ឋានស្តីពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកដោយ ២/៣នៃរដ្ឋភាគី ឬដោយរដ្ឋភាគីចំនួន ៦០ ដោយជ្រើសរើសយកជម្រើសណាមួយដែលច្រើនជាង។ ដោយឡែក ច្បាប់វិសោធនកម្មទាំងនេះមិនត្រូវនាំឱ្យប៉ះពាល់ទៅដល់ការប្រើប្រាស់នូវសិទ្ធិរបស់រដ្ឋភាគីដទៃទៀត ឬដល់ការអនុវត្តនូវកាតព្វកិច្ចរបស់ពួកគេ ដែលមានចែងនៅក្នុងអនុសញ្ញានេះឡើយ។

២. នៅក្នុងច្បាប់វិសោធនកម្មនេះ អាចចែងថាចំនួនភាគច្រើននៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកគឺជាលក្ខខណ្ឌមួយនៃការចូលជាធរមាននៃច្បាប់នេះជាជាងការកំណត់ក្រោមមាត្រានេះ។

៣. សម្រាប់រដ្ឋភាគីនីមួយៗដែលផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃច្បាប់វិសោធនកម្មដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើបន្ទាប់ពីការតម្កល់ទុកនូវលិខិតបទដ្ឋានគ្រប់ចំនួនដែលទាមទារស្តីពីការផ្តល់សច្ចាប័ន

ឬការចូលជាសមាជិកនោះច្បាប់វិសោធនកម្មត្រូវចូលជាធរមាននៅថ្ងៃទីដប់បីក្រោយពីការតម្កល់ទុកនូវលិខិតបទដ្ឋានស្តីពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកនៃច្បាប់វិសោធនកម្មនេះ។

៤.

រដ្ឋណាមួយដែលក្លាយជាភាគីមួយនៃអនុសញ្ញានេះក្រោយពេលដែលច្បាប់វិសោធនកម្មនៃអនុសញ្ញានេះចូលជាធរមានស្របតាមកថាខណ្ឌទី១ខាងលើ ហើយដែលពុំបានបញ្ជាក់ពីចេតនាផ្ទុយពីនេះ ក្នុងករណីនេះ រដ្ឋខាងលើត្រូវ ៖

(ក) ត្រូវចាត់ទុកថាជាភាគីមួយនៃច្បាប់វិសោធនកម្មលើអនុសញ្ញានេះផងដែរ និង

(ខ) ត្រូវចាត់ទុកថាជាភាគីមួយនៃអនុសញ្ញាដែលពុំបានធ្វើវិសោធនកម្ម ក្នុងទំនាក់ទំនងជាមួយនឹងបណ្តារដ្ឋភាគីណាមួយដែលពុំជាប់កាតព្វកិច្ចក្រោមច្បាប់វិសោធនកម្ម។

៥. រាល់ការធ្វើវិសោធនកម្មដែលទាក់ទងទាំងស្រុងទៅនឹងសកម្មភាពនៅក្នុងតំបន់ និងរាល់វិសោធនកម្មលើឧបសម្ព័ន្ធទី៦ត្រូវចូលជាធរមានចំពោះរាល់បណ្តារដ្ឋភាគីទាំងអស់នៅក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីការតម្កល់ ទុកលិខិតបទដ្ឋានស្តីពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកភាពដោយ ៣/៤នៃរដ្ឋភាគី។

៦.

រដ្ឋណាមួយដែលក្លាយជាភាគីមួយនៃអនុសញ្ញានេះក្រោយពីការចូលជាធរមាននៃច្បាប់វិសោធនកម្មដែលធ្វើឡើងស្របតាមកថាខណ្ឌទី៥
ត្រូវបានចាត់ទុកថាជាភាគីមួយនៃច្បាប់វិសោធនកម្មលើអនុសញ្ញានេះផងដែរ។

*មាត្រា ៣១៧*

*ការប្រកាសមិនយល់ស្រប*

១. រដ្ឋភាគីមួយអាចបង្ហាញពីការមិនយល់ស្របនឹងអនុសញ្ញានេះបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍ អក្សរជូនទៅអគ្គលេខាធិការអង្គការសហប្រជាតិ

និងអាចបង្ហាញពីហេតុផលនៃការមិនយល់ព្រមនោះ។
ការប្រកាសមិនយល់ស្របនេះត្រូវមានអានុភាពរយៈពេលមួយឆ្នាំ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងនេះ វៀរលែងតែមាន ការកំណត់កាលបរិច្ឆេទយូរជាងនេះនៅក្នុងលិខិតជូនដំណឹង។

២. ទោះជាមានហេតុផលបញ្ជាក់ពីការមិនយល់ស្របនេះក៏ដោយ រដ្ឋមួយពុំអាចរួចចាកផុតពីកាតព្វកិច្ចខាងហិរញ្ញវត្ថុ និងក្រោមកិច្ចសន្យាដែលបង្កើតឡើងខណៈដែលរដ្ឋនោះនៅជាភាគីមួយនៃអនុសញ្ញានេះឡើយ ហើយការប្រកាសមិនយល់ស្របនេះក៏មិនត្រូវនាំឱ្យប៉ះពាល់ទៅដល់សិទ្ធិ កាតព្វកិច្ច ឬស្ថានភាពគតិយុត្តិណាមួយរបស់រដ្ឋសាមី ដែលបង្កើតឡើងតាមរយៈការចុះអនុសញ្ញានេះនៅមុនពេលផុតដែលផុតសុពលភាពសម្រាប់រដ្ឋសាមីនោះដែរ។

៣.

ការប្រកាសមិនយល់ស្របនេះមិនត្រូវនាំឱ្យប៉ះពាល់ដោយប្រការណាមួយទៅលើតួនាទីរបស់បណ្តារដ្ឋភាគីនៅក្នុងការបំពេញនូវកាតព្វកិច្ចដែលបង្កើតឡើងក្រោមអនុសញ្ញានេះដែលវាជាកម្មវត្ថុមួយនៅក្នុងច្បាប់អន្តរជាតិដាច់ដោយឡែកពីអនុសញ្ញានេះឡើយ។

*មាត្រា ៣១៨*

*ស្ថានភាពនៃឧបសម្ព័ន្ធ*

ឯកសារឧបសម្ព័ន្ធត្រូវចាត់ទុកថាជាផ្នែកដ៏សំខាន់មួយនៃអនុសញ្ញានេះ ហើយវៀរលែងតែមានបដិបញ្ញត្តិ សេចក្តីយោងដល់អនុសញ្ញានេះ ឬភាគីណាមួយនៃអនុសញ្ញានេះ ត្រូវរាប់បញ្ចូលទាំងឧបសម្ព័ន្ធដែលពាក់ព័ន្ធផងដែរ។

*មាត្រា ៣១៩*

*កន្លែងតម្កល់ឯកសារ*

១.	អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវរក្សា និងតម្កល់ទុកអនុសញ្ញានេះ រួមទាំងច្បាប់វិសោធនកម្មផ្សេងៗលើអនុសញ្ញានេះផងដែរ។

២.	បន្ថែមលើតួនាទីក្នុងការរក្សាតម្កល់ទុកឯកសារនេះ អគ្គលេខាធិការត្រូវ ៖

(ក)	រាយការណ៍ជូនដល់បណ្តារដ្ឋភាគីទាំងអស់ អាជ្ញាធរ និងបណ្តាអង្គការអន្តរជាតិដែលមានសមត្ថកិច្ចស្តីពីបញ្ហាទូទៅដែលជាប់ទាក់ទងនឹងអនុសញ្ញានេះ។

(ខ)	ជូនដំណឹងដល់អាជ្ញាធរ ស្តីពីការផ្តល់សច្ចាប័ន និងការបញ្ជាក់ជាផ្លូវការ និងការចូលជាសមាជិកនៃអនុសញ្ញានេះ និងច្បាប់វិសោធនកម្មលើអនុសញ្ញានេះ ព្រមទាំងការប្រកាសមិនយល់ស្របចំពោះអនុសញ្ញានេះផងដែរ។

(គ)

ជូនដំណឹងដល់បណ្តារដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលធ្វើឡើងស្របតាមកថាខណ្ឌទី៤ នៃមាត្រា៣១១។

(ឃ)

ចតចម្លងចែកចាយច្បាប់វិសោធនកម្មដែលបានអនុម័តយកស្របតាមអនុសញ្ញានេះ ទៅដល់បណ្តារដ្ឋភាគីដើម្បីផ្តល់សច្ចាប័ន ឬចូលជាសមាជិក។

(ង)	កោះប្រជុំបណ្តារដ្ឋភាគីតាមការដែលចាំបាច់ ស្របតាមខ្លឹមសារនៃអនុសញ្ញានេះ។

៣.	(ក)

អគ្គលេខាធិការក៏ត្រូវបញ្ជូនផងដែរទៅដល់អ្នកសង្កេតការណ៍ដូចមានចែងក្នុងមាត្រា១៥៦ នូវ ៖

(i)	របាយការណ៍ដូចមានចែងក្នុងកថាខណ្ឌទី ២(ក)

(ii)	សេចក្តីជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌទី២(ខ) និង(គ) និង

(iii) សំណៅច្បាប់វិសោធនកម្មដូចមានចែងក្នុងកថាខណ្ឌទី២(ឃ)ដើម្បីជ្រាប ជាព័ត៌មាន។

(ខ) លើសពីនេះទៀត អគ្គលេខាធិការត្រូវកោះអញ្ជើញក្រុមអ្នកសង្កេតការណ៍ទាំងនេះឱ្យចូលរួមក្នុងនាម ជាអ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំរដ្ឋភាគីដែលធ្វើឡើងស្របតាមកថាខណ្ឌទី២ (ង)។

*មាត្រា ៣២០*

*អត្ថបទយថាភូត*

ឯកសារច្បាប់ដើមនៃអនុសញ្ញានេះដែលធ្វើឡើងជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង និងអេស្បាញ ត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្របតាមមាត្រា៣០៥។

ដើម្បីជាសក្ខីភាព តំណាងពេញសមត្ថភាព និងស្របច្បាប់ខាងក្រោម បានព្រមព្រៀងគ្នាចុះហត្ថលេខាលើអនុសញ្ញានេះ។

ធ្វើនៅ MONTEGOBAYថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ។

# ឧបសម្ព័ន្ធ១៖ ពូជត្រីដែលផ្លាស់ជម្រកតាមរដូវកាលខ្លាំង

១. ត្រីទូណាអាល់បាខ័រ : *Thunnus alalunga*.

២. ត្រីទូណាព្រុយខៀវ : *Thunnus thynnus*.

៣. ត្រីទូណាភ្នែកធំ : *Thunnus obesus*.

៤. ត្រីទូណាស្គីបជេក : *Katsuwonus pelamis*.

៥. ត្រីទូណាព្រុយលឿង : *Thunnus albacares.*

៦. ត្រីទូណាព្រុយខ្មៅ : *Thunnus atlanticus*.

៧. ត្រីទូណាតូច : *Euthynnus alletteratus*; *Euthynnus affinis*.

៨. ត្រីទូណាព្រុយខៀវភាគខាងត្បូង : *Thunnus maccoyii.*

៩. ត្រីស្បែកាប្រេហ្គាត : *Auxis thazard*; *Auxis rochei*.

១០. ត្រីកន្ទួនដៃ : អំបូរ *Bramidae*.

១១. ត្រីម៉ាលីន : *Tetrapturus angustirostris*; *Tetrapturus belone*; *Tetrapturus pfluegeri*; *Tetrapturus albidus*; *Tetrapturus audax*; *Tetrapturus georgei*; *Makaira mazara*; *Makaira indica*; *Makaira nigricans*.

១២. ត្រីសេល : *Istiophorus platypterus*; *Istiophorus albicans*.

១៣. ត្រីឆ្លាម : *Xiphias gladius*.

១៤. ត្រីប្លាធូ: *Scomberesox saurus*; *Cololabis saira*; *Cololabis adocetus*; *Scomberesox saurus scombroides*.

១៥. ត្រីផ្សោត: *Coryphaena hippurus*; *Coryphaena equiselis*.

១៦. ត្រីឆ្លាមសមុទ្រ : *Hexanchus griseus*; *Cetorhinus maximus*; អំបូរ *Alopiidae*; *Rhincodon typus*; អំបូរ *Carcharhinidae*; អំបូរ *Sphyrnidae*; អំបូរ *Isurida*.

១៧. ត្រីសេតាស៊ីន : អំបូរ *Physeteridae*; អំបូរ *Balaenopteridae*; អំបូរ *Balaenidae*; អំបូរ *Eschrichtiidae*; អំបូរ *Monodontidae*; អំបូរ *Ziphiidae*; អំបូរ *Delphinidae*.

ឧបសម្ព័ន្ធ២៖ គណៈកម្មការកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្រ

*មាត្រា ១*

អនុលោមតាមបទបញ្ញត្តិនៃមាត្រា ៧៦ គណៈកម្មការកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្រដែលលាតសន្ធឹងលើសពី ២០០ ម៉ែល៍សមុទ្រ ត្រូវបានបង្កើតឡើងស្របតាមមាត្រាខាងក្រោម។

*មាត្រា ២*

១. គណៈកម្មការនេះត្រូវមានសមាជិកចំនួន ២១រូប ដែលជាអ្នកជំនាញលើផ្នែកភូគព្ភសាស្ត្រ ភូគព្ភរូបវន្ត ឬផ្នែកជលធារសាស្ត្រ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយរដ្ឋភាគីនៃអនុសញ្ញានេះ ចេញពីក្នុង ចំណោមពលរដ្ឋរបស់ខ្លួន ក្នុងទិសដៅដើម្បីឆ្លើយតបនឹងតម្រូវការក្នុងការធានាឱ្យមានតំណាងប្រកប ដោយសមធម៌មកពីតំបន់នានា ដែលត្រូវបម្រើការងារទៅតាមសមត្ថភាពផ្ទាល់របស់ពួកគេ។

២. ដំណើរការបោះឆ្នោតដំបូងនឹងត្រូវប្រារព្ធឡើងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប៉ុន្តែមិនត្រូវលើសពី រយៈពេល ១៨ខែ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាននោះទេ។ យ៉ាងហោចណាស់រយៈពេលបីខែ នៅមុនកាលបរិច្ឆេទបោះឆ្នោតជ្រើសរើសនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូន លិខិតអញ្ជើញមួយទៅកាន់រដ្ឋភាគីទាំងអស់ ស្នើសុំឱ្យធ្វើការចាត់តាំងតំណាងនៅក្នុងរយៈពេលបីខែ បន្ទាប់ពីមានការពិគ្រោះយោបល់យ៉ាងសមស្របនៅថ្នាក់តំបន់។ អគ្គលេខាធិការត្រូវរៀបចំបញ្ជីឈ្មោះ រាល់បេក្ខជនដែលចាត់តាំងឡើងតាមលំដាប់អក្ខរក្រម និងត្រូវបញ្ជូនបញ្ជីឈ្មោះនេះដល់រាល់រដ្ឋភាគីទាំង អស់។

៣.	ការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការ ត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំរដ្ឋភាគី នៅទីស្នាក់ការ អង្គការសហប្រជាជាតិ តាមការកោះអញ្ជើញពីអគ្គលេខាធិការ។ នៅក្នុងកិច្ចប្រជុំនេះ ២/៣ នៃរដ្ឋភាគី ទាំងអស់នឹងបង្កើតបានជាកូរ៉ុម ហើយបេក្ខជនដែលត្រូវបានបោះឆ្នោតជ្រើសតាំងក្នុងគណៈកម្មការនេះ ត្រូវទទួលសិទ្ធិជាតំណាងដែលមានសម្លេងឆ្នោតភាគច្រើន ២/៣ នៃតំណាងរបស់រដ្ឋភាគីដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ និងនៅក្នុងការបោះឆ្នោត។

៤.	សមាជិកគណៈកម្មការដែលជាប់ឆ្នោត ត្រូវកាន់មុខតំណែងសម្រាប់អាណត្តិប្រាំឆ្នាំ។ ដោយឡែក សមាជិកគ្រប់រូបអាចមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសម្រាប់អាណត្តិបន្ទាប់បាន។

៥.	រដ្ឋភាគីដែលបានបញ្ជូនឈ្មោះបេក្ខជនឱ្យឈរឈ្មោះជាសមាជិករបស់គណៈកម្មការ ត្រូវទទួលបន្ទុកការ ចំណាយរបស់សមាជិករូបនោះ ខណៈដែលបំពេញភារកិច្ចការងារនៅក្នុងគណៈកម្មការ។ រដ្ឋជាប់ឆ្នេរ ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកការចំណាយទាក់ទងនឹងការណែនាំដូចមានចែងក្នុងកថាខណ្ឌទី ១(ខ) ក្រោម មាត្រា ៣ នៃឧបសម្ព័ន្ធនេះ។ លេខាធិការដ្ឋានរបស់គណៈកម្មការនឹងត្រូវផ្តល់ដោយអគ្គលេខាធិការ របស់អង្គការសហប្រជាជាតិ ។

*មាត្រា ៣*

១.	គណៈកម្មការមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

(ក) ពិនិត្យទិន្នន័យ និងសម្ភារឯកសារផ្សេងទៀតដែលរដ្ឋជាប់ឆ្នេរបានផ្តល់ឱ្យទាក់ទងនឹងដែនខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រនៅក្នុងតំបន់ដែលព្រំដែនទាំងនោះលាតសន្ធឹងលើសពី ២០០ ម៉ៃល៍សមុទ្រ និងផ្តល់អនុសាសន៍ស្របតាមមាត្រា ៧៦

និងសេចក្តីថ្លែងការណ៍នៃការយោគយល់ដែលបានអនុម័តនៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ ១៩៨០ នៅក្នុងអង្គសន្និសីទអង្គការសហប្រជាជាតិស្តីពីច្បាប់ដែនសមុទ្រ។

(ខ) ផ្តល់ការណែនាំផ្នែកបច្ចេកទេស និងវិទ្យាសាស្រ្ត កាលបើមានការស្នើសុំពីរដ្ឋជាប់ឆ្នេរដែលពាក់ព័ន្ធនៅក្នុងការរៀបចំទិន្នន័យដូចមានចែងក្នុងកថាខណ្ឌរង (ក)។

២. គណៈកម្មការអាចធ្វើការសហការក្នុងកម្រិតមួយដែលយល់ថាចាំបាច់ និងមានសារប្រយោជន៍ ជាមួយនឹងគណៈកម្មការសាគរសាស្រ្តអន្តររដ្ឋាភិបាល (Intergovernmental Oceanography Commission)របស់អង្គការ UNESCOអង្គការជលធារសាស្រ្តអន្តរជាតិ (International Hydrographic Organization) និងបណ្តាអង្គការអន្តរជាតិមានសមត្ថកិច្ចដទៃទៀត ក្នុងទិសដៅធ្វើការផ្លាស់ប្តូរទៅវិញទៅមកនូវព័ត៌មានវិទ្យាសាស្រ្ត និងបច្ចេកទេស ដែលអាចជាប្រយោជន៍ដល់ការ បំពេញភារកិច្ចរបស់គណៈកម្មការ។

*មាត្រា ៤*

ក្នុងករណីដែលរដ្ឋជាប់ឆ្នេរមួយមានបំណងបង្កើតនូវព្រំដែនខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួនដែលលាតសន្ធឹង លើសពី ២០០ ម៉ៃល៍សមុទ្រ ស្របតាមមាត្រា ៧៦ សាមីរដ្ឋត្រូវផ្តល់សេចក្តីលម្អិតឱ្យបានច្បាស់លាស់អំពីព្រំដែន ទាំងនោះមកគណៈកម្មការ រួមជាមួយនឹងទិន្នន័យបច្ចេកទេស និងវិទ្យាសាស្រ្តសម្រាប់ជាសំអាងផង ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ប៉ុន្តែទោះជាក្នុងករណីណាក៏ដោយ មិនត្រូវលើសពីរយៈពេល ១០ឆ្នាំ គិតចាប់ពីអនុសញ្ញានេះ ចូលជាធរមានសម្រាប់រដ្ឋភាគីនោះឡើយ។ ទន្ទឹមនឹងនោះដែររដ្ឋជាប់ឆ្នេរត្រូវផ្តល់ឈ្មោះសមាជិករបស់គណៈកម្មការ ណាមួយដែលបានផ្តល់ឱ្យរដ្ឋនោះនូវការណែនាំផ្នែកបច្ចេកទេស និងវិទ្យាសាស្រ្ត។

*មាត្រា ៥*

លើកលែងតែមានការសម្រេចផ្ទុយពីនេះដោយគណៈកម្មការ គណៈកម្មការត្រូវបំពេញមុខងារតាមរយៈ អនុគណៈកម្មការដែលមានសមាសភាពសមាជិកចំនួនប្រាំពីររូប ដែលត្រូវបានជ្រើសតាំងឡើងរដ្ឋភាគី ដោយមានតុល្យភាពជាមួយនឹងសមាសធាតុជាក់លាក់របស់អនុគណៈកម្មការនីមួយៗ។ ពលរដ្ឋនៃរដ្ឋភាគីដាក់បញ្ជូនសំណើដែល ជាសមាជិករបស់គណៈកម្មការ និងសមាជិកគណៈកម្មការណាមួយដែលបានជួយដល់រដ្ឋភាគីដោយផ្តល់ការណែនាំផ្នែក បច្ចេកទេស និងវិទ្យាសាស្ត្រទាក់ទងនឹងការកំណត់ខ្សែបន្ទាត់ព្រំប្រទល់ មិនត្រូវជាសមាជិករបស់អនុគណៈកម្មការទទួលបន្ទុកដោះស្រាយសំណើដែលបានដាក់ជូនឡើយ គឺមានសិទ្ធិត្រឹមតែចូលរួមក្នុងនាមជាសមាជិកមួយរូបនៅក្នុង កិច្ចដំណើរការរបស់គណៈកម្មការទាក់ទងនឹងសំណើដែលបានដាក់ជូនប៉ុណ្ណោះ។ រដ្ឋជាប់ឆ្នេរដែលបានដាក់បញ្ជូនសំណើ មកគណៈកម្មការ អាចចាត់បញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមនៅក្នុងកិច្ចដំណើរការពាក់ព័ន្ធបាន ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតនោះទេ។

*មាត្រា ៦*

១. អនុគណៈកម្មការត្រូវដាក់បញ្ជូនអនុសាសន៍របស់ខ្លួនមកគណៈកម្មការ។

២. ការអនុម័តរបស់គណៈកម្មការលើអនុសាសន៍ដែលផ្តល់ដោយអនុគណៈកម្មការ ត្រូវមានសម្លេងគាំទ្រ ភាគច្រើន ២/៣ នៃសមាជិកគណៈកម្មការទាំងអស់ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ និងមានសិទ្ធិបោះ ឆ្នោត។

៣.

អនុសាសន៍របស់គណៈកម្មការត្រូវដាក់បញ្ជូនជាលាយលក្ខណ៍អក្សរទៅកាន់រដ្ឋជាប់ឆ្នេរដែលបាន ដាក់សំណើ និងអគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ។

*មាត្រា ៧*

រដ្ឋជាប់ឆ្នេរត្រូវបង្កើតនូវព្រំដែនខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រ អនុលោមតាមបទបញ្ញត្តិនៃមាត្រា ៧៦ កថាខណ្ឌទី ៨ និងស្របតាមនីតិវិធីសមស្របរបស់ប្រទេសនីមួយៗ ។

*មាត្រា ៨*

ក្នុងករណីដែលមានការយល់ទាស់របស់រដ្ឋជាប់ឆ្នេរទៅលើអនុសាសន៍របស់គណៈកម្មការ នោះរដ្ឋជាប់ឆ្នេរ ត្រូវធ្វើការពិនិត្យឡើងវិញ ឬដាក់សំណើថ្មីទៅកាន់គណៈកម្មការនៅក្នុងរយៈពេលដែលសមស្រប។

*មាត្រា ៩*

ចំណាត់ការរបស់គណៈកម្មការ នឹងមិនប៉ះពាល់ដល់បញ្ហាទាក់ទងនឹងការកំណត់ព្រំប្រទល់រវាងរដ្ឋដែលមាន តំបន់ឆ្នេរទល់គ្នា ឬជាប់គ្នានោះទេ។

ឧបសម្ព័ន្ធ៣៖ លក្ខខណ្ឌមូលដ្ឋាននៃការធ្វើបុរេសនា ការរុករក និងការធ្វើអាជីវកម្មធនធានរ៉ែ

*មាត្រា ១*

*កម្មសិទ្ធិលើធនធានរ៉ែ*

កម្មសិទ្ធិលើធនធានរ៉ែដែលប្រទះឃើញ នឹងត្រូវផ្តល់ជូនអនុលោមតាមអនុសញ្ញានេះ។

*មាត្រា ២*

*ការធ្វើបុរេសនារ៉ែ*

១. (ក) អាជ្ញាធរត្រូវជំរុញឱ្យមានការធ្វើបុរេនារ៉ែនៅក្នុងតំបន់។

(ខ) ការធ្វើបុរេសនារ៉ែអាចអនុវត្តបាន តែក្នុងករណីដែលអាជ្ញាធរទទួលបានការសន្យាជាលាយលក្ខណ៍អក្សរគួរជាទីពេញចិត្តថា បុរេសនករដែលដាក់សំណើសុំធ្វើបុរេសនារ៉ែយល់ព្រមគោរពតាមខ្លឹមសារ អនុសញ្ញានេះ រួមទាំងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីដែលពាក់ព័ន្ធរបស់អាជ្ញាធរទាក់ទងនឹងកិច្ចសហប្រតិបត្តិការលើកម្មវិធីបណ្តុះបណ្តាលដូចមានចែងក្នុងមាត្រា ១៤៣ និង ១៤៤ និងការការពារ បរិស្ថានសមុទ្រ និងយល់ព្រមឱ្យមានការត្រួតពិនិត្យលើការប្រតិបត្តិពីសំណាក់អាជ្ញាធរ។ ទន្ទឹមនឹងនេះដែរ បុរេសនជនដែលស្នើសុំត្រូវជូនដំណឹងដល់អាជ្ញាធរអំពីផ្ទៃក្រឡាប្រហាក់ប្រហែល ឬអំពីតំបន់ដែលត្រូវធ្វើបុរេសនា។

(គ)

ការធ្វើបុរេសនារ៉ែអាចអនុវត្តដោយបុរេសនករលើសពីមួយបានក្នុងពេលដំណាលគ្នានៅក្នុងតំបន់តែមួយ។

២.	ការធ្វើបុរេសនាវ៉ែមិនមែនជាការផ្តល់សិទ្ធិឱ្យបុរេសនករ នូវសិទ្ធិណាមួយលើធនធាននោះទេ។ ដោយឡែក បុរេសនករអាចប្រមូលយកធនធានរ៉ែក្នុងចំនួនដែលសមស្របសម្រាប់បម្រើឱ្យគោលបំណងនៃការពិសោធន៍។

*មាត្រា ៣*

*ការរុករក និងការធ្វើអាជីវកម្ម*

១.	សហគ្រាស រដ្ឋភាគី និងអង្គភាពដទៃទៀតដូចមានចែងក្នុងកថាខណ្ឌទី ២(ខ) នៃមាត្រា ១៥៣ អាចដាក់ ពាក្យមកអាជ្ញាធរ ស្នើសុំការអនុម័តលើផែនការងារធ្វើសកម្មាពនៅក្នុងតំបន់បាន។

២.	សហគ្រាសអាចដាក់ពាក្យសុំលើផ្នែកណាមួយនៃតំបន់បាន ដោយឡែក ការដាក់ពាក្យសុំដោយអង្គភាព ដទៃទៀតទាក់ទងនឹងតំបន់រក្សាទុក ត្រូវស្ថិតក្រោមលក្ខខណ្ឌបន្ថែមដូចមានចែងក្នុងមាត្រា ៩ នៃ ឧបសម្ព័ន្ធនេះ។

៣.	សកម្មភាពស្វែងរុករក និងការធ្វើអាជីវកម្មធនធានរ៉ែ អាចអនុវត្តបានតែនៅក្នុងតំបន់ដែលបានកំណត់ ច្បាស់លាស់ នៅក្នុងផែនការការងារដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៥៣ តែប៉ុណ្ណោះ និងត្រូវអនុម័តដោយ អាជ្ញាធរស្របតាមខ្លឹមសារនៃអនុសញ្ញានេះ រួមទាំងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីជាធរមានរបស់ អាជ្ញាធរ។

៤.	រាល់ផែនការការងារដែលបានអនុម័ត ត្រូវៈ

(ក) គោរពតាមខ្លឹមសារនៃអនុសញ្ញានេះ រួមទាំងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវធិជីធារមានរបស់អាជ្ញាធរ។

(ខ) ផ្តល់សិទ្ធិឱ្យអាជ្ញាធរធ្វើការត្រួតពិនិត្យទៅលើសកម្មភាពនៅក្នុងតំបន់ ស្របតាមកថាខណ្ឌទី ៤ នៃមាត្រា ១៥៣។

(គ) ផ្តល់ឱ្យប្រតិបត្តិករនូវសិទ្ធិផ្តាច់មុខនៅក្នុងការរុករក និងធ្វើអាជីវកម្មប្រភេទធនធានជាក់លាក់ នៅក្នុងតំបន់ដែលបានកំណត់ក្នុងផែនការងារ ស្របតាមវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។ ទោះជាយ៉ាងនេះក្តី ក្នុងករណី ដែលអ្នកដាក់ពាក្យសុំដាក់សំណើសុំការអនុម័តផែនការ

ការងារដែលគ្របដណ្តប់តែលើដំណាក់កាលនៃការរុករក ឬធ្វើអាជីវកម្មធនធានរ៉ែ នោះផែនការ ការងារដែលបានអនុម័ត នឹងត្រូវទទួលបានសិទ្ធិផ្តាច់មុខសម្រាប់តែសកម្មភាពការងាដែល គ្របដណ្តប់នៅក្នុងដំណាក់កាលនោះប៉ុណ្ណោះ។

៥. នៅពេលដែលទទួលបានការអនុម័តពីអាជ្ញាធរ គ្រប់ផែនការការងារទាំងអស់ លើកលែងតែផែនការងារទាំងឡាយដែលដាក់ដោយសហគ្រាស ត្រូវមានទម្រង់ជាកិច្ចសន្យាធ្វើឡើងរវាងអាជ្ញាធរ និងអ្នកដាក់ពាក្យសុំមួយ ឬច្រើន។

*មាត្រា ៤*

*លក្ខណៈសម្បត្តិរបស់អ្នកដាក់ពាក្យសុំ*

១. អ្នកដាក់ពាក្យសុំដែលមិនមែនជាសហគ្រាស ត្រូវបានចាត់ទុកថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប្រសិន បើគេមានសញ្ជាតិ ឬស្ថិតក្រោមការត្រួតពិនិត្យ និងការធានាតាមការតម្រូវក្រោមកថាខណ្ឌទី ២(ខ)នៃ មាត្រា ១៥៣ និង ប្រសិនបើគេអនុវត្តបានត្រឹមត្រូវតាមនីតិវិធី និងបំពេញតាមបទដ្ឋានកំណត់ពី លក្ខណៈសម្បត្តិដូច មានចែងនៅក្នុងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីជាធរមានរបស់អាជ្ញាធរ។

២. លើកលែងតែមានបញ្ញត្តិចែងក្នុងកថាខណ្ឌទី ៦ បទដ្ឋានកំណត់ពីលក្ខណៈសម្បត្តិនេះ ត្រូវមានទំនាក់ទំនង ជាមួយនឹងសមត្ថភាពផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសរបស់អ្នកដាក់ពាក្យសុំ និងការអនុវត្តរបស់សាមីខ្លួន នៅក្នុងកិច្ចសន្យាមុនៗដែលធ្វើឡើងជាមួយអាជ្ញាធរ។

៣.	អ្នកដាក់ពាក្យសុំត្រូវទទួលការធានាពីរដ្ឋភាគីរបស់ខ្លួន លើកលែងតែអ្នកដាក់ពាក្យសុំមានសញ្ជាតិលើសពីមួយ ដូចជានៅក្នុងករណីក្រុមហ៊ុនសហកម្មសិទ្ធិ ឬសម្ព័ន្ធអាជីវកម្មពីបណ្តារដ្ឋជាច្រើនដែលក្នុងករណីនេះគ្រប់រដ្ឋភាគីដែលពាក់ព័ន្ធត្រូវផ្តល់ការធានាលើពាក្យសុំ ឬលុះត្រាតែអ្នកដាក់ពាក្យសុំស្ថិត ក្រោមអានុភាពគ្រប់គ្រងរបស់រដ្ឋភាគីមួយផ្សេងទៀត ឬពលរដ្ឋរបស់រដ្ឋនោះ ហើយក្នុងករណីនេះ រដ្ឋភាគីទាំងពីរត្រូវផ្តល់ការធានារួមគ្នាលើពាក្យសុំ។ លក្ខណៈវិនិច្ឆ័យ និងនីតិវិធីអនុវត្តន៍លក្ខខណ្ឌនៃការធានា ត្រូវបានកំណត់នៅក្នុងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

៤.	រដ្ឋមួយ ឬច្រើនដែលផ្តល់ការធានា ស្របតាមមាត្រា ១៣៩ ត្រូវទទួលខុសត្រូវក្នុងការធានាក្រោមក្របខ័ណ្ឌប្រព័ន្ធច្បាប់របស់ខ្លួនថា អ្នកចុះកិច្ចសន្យាដែលមានការធានាត្រូវអនុវត្តសកម្មភាពនៅក្នុងតំបន់ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា និងកាតព្វកិច្ចរបស់ខ្លួនដែលបានកំណត់ក្នុងអនុសញ្ញានេះ។ ទោះជាយ៉ាង នេះក្តី រដ្ឋដែលផ្តល់ការធានានឹងមិនទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយដែលបណ្តាលមកពីអ្នកចុះកិច្ចសន្យាដែលមានការធានា មិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួននោះទេ ប្រសិនបើរដ្ឋភាគីនោះបាន អនុម័តច្បាប់ និងបទបញ្ញត្តិ ព្រមទាំងបានចាត់វិធានការផ្នែករដ្ឋបាលក្រោមក្របខ័ណ្ឌនៃប្រព័ន្ធច្បាប់របស់ខ្លួន ផ្តល់មូលហេតុសមស្របក្នុងការជំរុញការធានាលើការប្រតិបត្តិរបស់បុគ្គលដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន។

៥.	នីតិវិធីក្នុងការកំណត់ និងវាយតម្លៃលើលក្ខណៈសម្បត្តិរបស់រដ្ឋភាគីដែលជាអ្នកដាក់ពាក្យសុំ ត្រូវពិចារណាទៅលើចរិតលក្ខណៈជារដ្ឋរបស់រដ្ឋនោះ។

៦. បទដ្ឋានកំណត់ពីលក្ខណៈសម្បត្តិ កំណត់ថា សម្រាប់ជាផ្នែកមួយនៃការដាក់ពាក្យសុំ អ្នកដាក់ពាក្យសុំទាំងអស់ដោយមិនលើកលែង ត្រូវសន្យាដូចខាងក្រោម ៖

(ក) យល់ព្រមអនុវត្ត និងបំពេញតាមកាតព្វកិច្ចជាធរមានដូចមានចែងនៅក្នុងផ្នែកទី ១១ វិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ សេចក្តីសម្រេចរបស់អង្គភាពនៃអាជ្ញាធរ ព្រមទាំងលក្ខខណ្ឌនៃកិច្ចសន្យា ដែលបានធ្វើជាមួយអាជ្ញាធរ។

(ខ) យល់ព្រមឱ្យអាជ្ញាធរត្រួតពិនិត្យលើសកម្មភាពនៅក្នុងតំបន់ដែលបានអនុញ្ញាតក្រោមអនុញ្ញានេះ ។

(គ) ផ្តល់លិខិតធានាចំពោះអាជ្ញាធរថា ខ្លួននឹងបំពេញតាមកាតព្វកិច្ចក្រោមកិច្ចសន្យាដោយស្មោះត្រង់។

(ឃ) គោរពតាមបទបញ្ញត្តិស្តីពីការផ្ទេរបច្ចេកវិទ្យាដូចមានចែងក្នុងមាត្រា ៥ នៃឧបសម្ព័ន្ធនេះ ។

*មាត្រា ៥*

*ការផ្ទេរបច្ចេកវិទ្យា*

១. នៅពេលដាក់បញ្ជូនផែនការការងារ អ្នកដាក់ពាក្យសុំនីមួយៗត្រូវផ្តល់ដល់អាជ្ញាធរនូវសេចក្តីលម្អិតទូទៅ អំពីសម្ភារបរិក្ខារ និងវិធីសាស្ត្រប្រើប្រាស់ក្នុងការអនុវត្តសកម្មភាពនៅក្នុងតំបន់ ព្រមទាំងព័ត៌មាន ពាក់ព័ន្ធផ្សេងទៀតមិនស្ថិតក្រោមកម្មសិទ្ធិបញ្ញា ស្តីពីចរិតលក្ខណៈនៃបច្ចេកវិទ្យា និងព័ត៌មានអំពីប្រភពនៃបច្ចេកវិទ្យាទាំងនេះ។

២.  ប្រតិបត្តិករទាំងអស់ត្រូវជូនដំណឹងដល់អាជ្ញាធរអំពីការកែប្រែណាមួយទៅលើសេចក្តីលម្អិត និងព័ត៌មាន ខាងលើដែលត្រូវផ្តល់ស្របតាមកថាខណ្ឌទី ១ ក្នុងករណីដែលមានការកែប្រែគួរឱ្យកត់សម្គាល់ទៅលើ បច្ចេកវិទ្យា ឬការបង្កើតបច្ចេកវិទ្យាថ្មីៗ ។

៣.  គ្រប់កិច្ចសន្យាស្តីពីការអនុវត្តសកម្មភាពនៅក្នុងតំបន់ ត្រូវមានការសន្យាដូចខាងក្រោមពីអ្នកចុះកិច្ចសន្យា ៖

(ក)  ត្រូវផ្តល់ដល់សហគ្រាសនូវលក្ខខណ្ឌផ្នែកពាណិជ្ជកម្មឱ្យបានត្រឹមត្រូវ និងសមស្រប តាមការស្នើឡើង របស់អាជ្ញាធរ បច្ចេកវិទ្យាដែលប្រើប្រាស់ក្នុងការអនុវត្តសកម្មភាពនៅក្នុងតំបន់ក្រោមកិច្ចសន្យា ដែលអ្នកចុះកិច្ចសន្យាមានសិទ្ធិស្របច្បាប់ក្នុងការផ្ទេរបន្ត។ ទាំងនេះត្រូវធ្វើឡើង តាមមធ្យោបាយផ្តល់អាជ្ញាប័ណ្ណ ឬមធ្យោបាយដទៃទៀតដែលសមស្រប ដែលអ្នកចុះកិច្ចសន្យាត្រូវមានការចរចាជាមួយសហគ្រាស ហើយ ដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀងបន្ថែមលើកិច្ចសន្យាជាធរមាន។ ការសន្យានេះ អាចនឹងត្រូវធ្វើឡើងតែក្នុងករណីដែលសហគ្រាសយល់ថា មិនអាចស្វែងរកបច្ចេកវិទ្យាដូចគ្នានេះ ឬ បច្ចេក វិទ្យាដែលមានប្រសិទ្ធភាព និងតម្លៃប្រើប្រាស់សមមូលនឹងបច្ចេកវិទ្យាទាំងនេះបាននៅលើទីផ្សារសេរីក្រោម លក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវ និងសមស្របប៉ុណ្ណោះ។

(ខ)

ត្រូវទទួលបានការធានាជាលាយលក្ខណ៍អក្សរពីម្ចាស់កម្មសិទ្ធិនៃបច្ចេកវិទ្យាដែលបានប្រើប្រាស់សម្រាប់ អនុវត្តសកម្មភាពនៅក្នុងតំបន់ក្រោមកិច្ចសន្យា ដែលជាទូទៅមិនអាចស្វែងរកបាននៅលើទីផ្សារសេរី ហើយ ដែលមិនមានចែងនៅក្នុងកថាខណ្ឌរង(ក) ដែលម្ចាស់កម្មសិទ្ធិនឹងត្រូវផ្តល់បច្ចេកវិទ្យាទាំងនេះដល់សហគ្រាស ដែលទទួលបានអាជ្ញាប័ណ្ណ ឬតាមរយៈមធ្យោបាយដទៃទៀតដែលសមស្របទៅតាម

ការស្នើសុំរបស់អាជ្ញាធរ និងស្ថិតក្រោមលក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវ និងសមស្រប នៅក្នុងលក្ខណៈដូចគ្នានឹងការផ្តល់ជូនដល់អ្នកចុះកិច្ចសន្យាដែរ។ ដោយឡែក កាលបើពុំទទួលបានការធានានេះទេ នោះអ្នកចុះកិច្ចសន្យាពុំមាន សិទ្ធិប្រើប្រាស់បច្ចេកវិទ្យាទាំងនេះសម្រាប់អនុវត្តសកម្មភាពនៅក្នុងតំបន់បានឡើយ។

(គ) ត្រូវទទួលពីម្ចាស់កម្មសិទ្ធិតាមរយៈការអនុវត្តកិច្ចសន្យាជាធរមាន និងតាមការស្នើសុំពីសហគ្រាស និង បើសិនការធ្វើបែបនេះនាំទៅដល់ការបង្កើតបន្ទុកចំណាយដ៏ច្រើនសន្ធឹកសន្ធាប់ចំពោះអ្នកចុះ កិច្ចសន្យា នូវសិទ្ធិ ស្របច្បាប់ក្នុងការផ្ទេរទៅដល់សហគ្រាសនូវបច្ចេកវិទ្យាដែលអ្នកចុះកិច្ចសន្យាប្រើប្រាស់ស ម្រាប់អនុវត្ត សកម្មភាពនៅក្នុងតំបន់ក្រោមកិច្ចសន្យា ដែលអ្នកចុះកិច្ចសន្យាពុំមានសិទ្ធិស្របច្បាប់ក្នុងការផ្ទេរបន្ត ហើយ ដែលជាទូទៅពុំអាចស្វែងរកបាននៅលើទីផ្សារសេរី ។ ដោយឡែក ក្នុងករណីដែលអ្នកចុះកិច្ចសន្យា និងម្ចាស់ កម្មសិទ្ធិលើបច្ចេកវិទ្យាមានទំនាក់ទំនងផ្នែកពាណិជ្ជកម្មយ៉ាងមុតមាំ នោះកម្រិតនៃទំនាក់ទំនង និងការ ត្រួតត្រា ឬឥទ្ធិពលរវាងគ្នា ត្រូវមានទំនាក់ទំនងជាមួយនឹងការកំណត់ថាតើរាល់វិធានការត្រូវបានធ្វើឡើង អស់ពីលទ្ធភាពដើម្បីទទួលបានសិទ្ធិខាងលើដែរឬយ៉ាងណា។ ក្នុងករណីដែលអ្នកចុះកិច្ចសន្យាមានអានុភាព ត្រួតត្រាលើម្ចាស់កម្មសិទ្ធិ នោះករណីដែលអ្នកចុះកិច្ចសន្យាមិនទទួលបានសិទ្ធិស្របច្បាប់ នឹងត្រូវធ្វើការ ពិចារណាដោយផ្អែកលើលក្ខណៈសម្បត្តិរបស់អ្នកចុះកិច្ចសន្យាផ្ទាល់ នៅក្នុងការបំពេញពាក្យសុំជាបន្តបន្ទាប់ ដើម្បីសុំការអនុម័តលើផែនការងារ។

(ឃ) ត្រូវជួយសម្រួលតាមការស្នើសុំពីសហគ្រាស ដើម្បីឱ្យសហគ្រាសអាចមានលទ្ធភាពទទួលបានបច្ចេក វិទ្យាក្រោមអាជ្ញាប័ណ្ណ ដូចបានកំណត់ក្នុងកថាខណ្ឌរង (ខ) ឬតាមមធ្យោបាយដទៃទៀតដែលសមស្រប និង

ផ្អែកតាមលក្ខខណ្ឌផ្អែកពាណិជ្ជកម្មដែលត្រឹមត្រូវ និងសមស្រប កាលបើសហគ្រាសធ្វើការសម្រេចក្នុងការចរចាដោយផ្ទាល់ជាមួយនឹងម្ចាស់កម្មសិទ្ធិលើបច្ចេកវិទ្យា ។

(ង) ត្រូវចាត់វិធានការដូចដែលបានកំណត់ក្នុងកថាខណ្ឌរង (ក) (ខ) (គ) និង(ឃ) ដើម្បីជាប្រយោជន៍ សម្រាប់រដ្ឋកំពុងអភិវឌ្ឍន៍ ឬបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ ដែលបានដាក់ស្នើសុំកិច្ចសន្យាក្រោមមាត្រា ៩ នៃ ឧបសម្ព័ន្ធនេះ ក្នុងលក្ខខណ្ឌដែលវិធានការទាំងនេះមានវិសាលភាពគ្របដណ្តប់លើការធ្វើអាជីវកម្មលើផ្នែកណាមួយនៃតំបន់រក្សាទុក ដែលស្នើឡើងដោយអ្នកចុះកិច្ចសន្យា ស្របតាមមាត្រា ៨ នៃឧបសម្ព័ន្ធនេះ និងប្រសិនបើសកម្មភាពក្រោមកិច្ចសន្យាដែលស្នើឡើដោយរដ្ឋកំពុងអភិវឌ្ឍន៍ណាមួយ ឬដោយបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ មិនមានការពាក់ព័ន្ធនឹងការផ្ទេរបច្ចេកវិទ្យាទៅដល់រដ្ឋទីបី ឬពលរដ្ឋនៃរដ្ឋទីបីនោះ។ កាតព្វកិច្ចក្រោមបញ្ញត្តិនេះត្រូវអនុវត្តចំពោះអ្នកចុះកិច្ចសន្យា តែក្នុងករណីដែលបច្ចេកវិទ្យាពុំត្រូវបានស្នើសុំពីសហគ្រាស ឬបច្ចេកវិទ្យាមិនត្រូវបានផ្ទេរពីអ្នកចុះកិច្ចសន្យានោះទៅដល់សហគ្រាសប៉ុណ្ណោះ។

៤. ដូចគ្នានឹងបទបញ្ញត្តិដទៃទៀតដែរ

ក្នុងករណីដែលកើតមានវិវាទណាមួយទាក់ទងនឹងការសន្យាដែល តម្រូវឡើងក្នុងកថាខណ្ឌទី៣ នោះត្រូវធ្វើការដោះស្រាយស្របតាមខ្លឹមសារនៃផ្នែកទី ១១ ហើយក្នុងករណីមានការបំពានលើការសន្យាទាំងនេះ នោះវាអាចនឹងនាំទៅដល់ការព្យួរ ឬលុបចោលកិច្ចសន្យា ឬការផាកពិន័យជាប្រាក់ ស្របតាមមាត្រា ១៨ នៃឧបសម្ព័ន្ធនេះ។ ក្នុងករណីដែលមានវិវាទទៅលើការកំណត់ថាតើការផ្តល់ជូនរបស់អ្នកចុះកិច្ចសន្យាធ្វើឡើងផ្អែកតាមលក្ខខណ្ឌផ្អែកពាណិជ្ជកម្មដែលត្រឹមត្រូវ និងសមស្របយ៉ាងណានោះ ភាគីនីមួយៗអាចដាក់បញ្ជូនករណីវិវាទនោះដើម្បីធ្វើការដោះស្រាយជាស្ថាពរដោយមជ្ឈត្តិករផ្នែកពាណិជ្ជកម្ម ស្របតាមវិធានមជ្ឈត្តិកម្មរបស់គណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកច្បាប់ពាណិជ្ជកម្ម UNCITRAL ឬវិធានមជ្ឈត្តកមដ្ធទៃទៀតដែលអាចនឹង

កំណត់នៅក្នុងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។ ប្រសិនបើការស្រាវជ្រាវរកឃើញថា ការផ្តល់ជូនដែលស្នើឡើងដោយអ្នកចុះកិច្ចសន្យាមិនបានធ្វើឡើងត្រឹមត្រូវតាមលក្ខខណ្ឌផ្នែកពាណិជ្ជកម្ម ដែលត្រឹមត្រូវ និងសមស្របទេនោះ អ្នកចុះកិច្ចសន្យាត្រូវបានផ្តល់រយៈពេល ៤៥ថ្ងៃ ដើម្បីកែតម្រូវលើ ការផ្តល់ជូនដែលស្នើឡើងឱ្យល្អប្រសើរឡើងវិញនៅមុនពេលដែលអាជ្ញាធរចាត់វិធានការណាមួយ ស្រប តាមមាត្រា ១៨ នៃឧបសម្ព័ន្ធនេះ។

៥.

ប្រសិនបើសហគ្រាសពុំមានលទ្ធភាពទទួលបានផ្នែកតាមលក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវ និងសមស្រប នូវបច្ចេកវិទ្យាដែលសមស្រប ដើម្បីអាចដំណើរការឱ្យទាន់ពេលវេលានូវការរុករក និងការកែច្នៃធនធានរ៉ែពីក្នុងតំបន់ទេនោះ ក្រុមប្រឹក្សា ឬសភាអាចកោះប្រជុំបណ្តារដ្ឋភាគីដែលមានសមាសភាពអ្នកដែលបានចូលរួមសកម្មភាពនៅក្នុងតំបន់ អ្នកដែលបានផ្តល់ការធានាចំពោះអង្គភាពដែល ចូលរួមសកម្មភាពនៅក្នុងតំបន់ និងរដ្ឋភាគីដទៃទៀតដែលមានលទ្ធភាពអាចទទួលបានបច្ចេកវិទ្យាទាំងនេះ។ បណ្តារដ្ឋទាំងនេះត្រូវពិគ្រោះពិភាក្សាគ្នា និងត្រូវចាត់វិធានការដែលមានប្រសិទ្ធភាព ដើម្បីធានាថា បច្ចេកវិទ្យាទាំងនេះត្រូវបានផ្តល់ជូនដល់សហគ្រាសផ្អែកតាមលក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវ និងសមស្រប។ បណ្តារដ្ឋនីមួយៗទាំងនេះត្រូវមានវិធានការគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាទាំងនេះ នៅក្នុងក្របខ័ណ្ឌច្បាប់របស់ខ្លួន។

៦. ដោយឡែក ក្នុងករណីដែលមានកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មជាមួយសហគ្រាស ការផ្ទេរបច្ចេកវិទ្យានឹងត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មដែលបានបង្កើតឡើង។

៧. ការសន្យាដែលតម្រូវឡើងក្រោមកថាខណ្ឌទី ៣ ត្រូវដាក់បញ្ចូលជាផ្នែកមួយនៅក្នុងកិច្ចសន្យានីមួយៗ សម្រាប់អនុវត្តសកម្មភាពនៅក្នុងតំបន់ រហូតរយៈពេល១០ឆ្នាំ បន្ទាប់ពីការចាប់ផ្ដើមដំណើរការ ផលិតកម្មអាជីវកម្មរបស់សហគ្រាស និងអាចស្នើឡើងនៅក្នុងរយៈពេលនោះ។

៨. សម្រាប់គោលបំណងនៃមាត្រានេះ ពាក្យ "បច្ចេកវិទ្យា" សំដៅដល់ឧបករណ៍ផ្នែកឯកទេស និងចំណេះធ្វើ ផ្នែកបច្ចេកទេស រាប់បញ្ចូលទាំងសៀវភៅណែនាំបច្ចេកទេស ប្លង់រចនា សេចក្ដីណែនាំអំពីរបៀបប្រើ ប្រាស់ ការបណ្ដុះបណ្ដាល ព្រមទាំងការណែនាំ និងជំនួយផ្នែកបច្ចេកទេសដែលចាំបាច់សម្រាប់ការងារ ដំឡើង ថែទាំជួសជុល និងដំណើរការប្រព័ន្ធដោយចីរភាព និងសិទ្ធិស្របច្បាប់ក្នុងកាប្រើប្រាស់គ្រឿង បរិក្ខារទាំងនេះ សម្រាប់គោលបំណងប្រើប្រាស់មិនផ្ដាច់មុខ។

*មាត្រា ៦*

*ការអនុម័តលើផែនការការងារ*

១. ប្រាំមួយខែបន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន ហើយបន្ទាប់ពីនោះ នៅរៀងរាល់ខែទីបួន អាជ្ញាធរត្រូវចាប់ផ្ដើមពិចារណាលើផែនការការងារដែលបានស្នើឡើង។

២. នៅពេលពិចារណាលើពាក្យសុំការអនុម័តលើផែនការការងារក្នុងទម្រង់ជាកិច្ចសន្យា ជាដំបូងបំផុត អាជ្ញាធរត្រូវពិនិត្យឱ្យច្បាស់ថាតើៈ

(ក) អ្នកដាក់ពាក្យសុំបានគោរពតាមនីតិវិធីដែលបានកំណត់ឡើងសម្រាប់ការដាក់ពាក្យសុំ អនុលោមតាមមាត្រា ៤ នៃឧបសម្ព័ន្ធនេះ និងបានធ្វើការធានាអះអាង ដែលកំណត់ដោយមាត្រា នោះជូនដល់អាជ្ញាធរដែរឬទេ។ ក្នុងករណី

មិនមានការគោរពអនុវត្តតាមនីតិវិធីទាំងនេះ ឬ មិនមានរាល់ការធានាអះអាងទាំងនេះ នោះត្រូវទុកពេលឱ្យអ្នកដាក់ពាក្យសុំចំនួន ៤៥ ថ្ងៃ ដើម្បីដំណោះស្រាយកង្វះខាតទាំងនេះ។

(ខ) អ្នកដាក់ពាក្យសុំមានលក្ខណៈសម្បត្តិចាំបាច់គ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា ៤ នៃឧបសម្ព័ន្ធនេះដែរឬទេ។

៣. ផែនការការងារដែលបានស្នើឡើងទាំងអស់ត្រូវបានពិចារណា ទៅតាមលំដាប់លំដោយនៃការទទួលបាន។ ផែនការការងារដែលបានស្នើឡើងត្រូវមានលក្ខណៈស្របទៅតាម និងត្រូវគ្រប់គ្រងដោយបទបញ្ញត្តិពាក់ព័ន្ធនៃ អនុសញ្ញានេះ ព្រមទាំងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ រាប់បញ្ចូលទាំងផ្នែកដែលចែងអំពី លក្ខខណ្ឌប្រតិបត្តិ ការចូលរួមចំណែកហិរញ្ញប្បទាន និងការធានាអះអាងដែលពាក់ព័ន្ធនឹងការផ្ទេរបច្ចេកវិទ្យា។ ប្រសិនបើផែនការការងារដែលបានស្នើឡើងមានលក្ខណៈស្របទៅតាម លក្ខខណ្ឌទាំងនេះ អាជ្ញាធរត្រូវផ្តល់អនុម័តលើ ផែនការទាំងនោះ ក្នុងលក្ខខណ្ឌថា វាអនុលោមតាមលក្ខខណ្ឌដែលមានឯកភាព និងគ្មានការរើសអើងដែលបាន កំណត់ក្នុងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ លើកលែងតែ៖

(ក) ផ្នែកណាមួយ ឬផ្នែកទាំងមូលនៃតំបន់ស្ថិតនៅក្រោមផែនការការងារដែលបានស្នើឡើងត្រូវបានបញ្ចូលក្នុងផែនការការងារដែលបានអនុម័ត ឬ ផែនការការងារដែលបានដាក់ជូនពីមុន ប៉ុន្តែនៅមិនទាន់បានពិចារណាជាស្ថាពរដោយអាជ្ញាធរ។

(ខ) ផ្នែកណាមួយ ឬផ្នែកទាំងមូលនៃតំបន់ស្ថិតនៅក្រោមផែនការការងារដែលបានស្នើឡើងត្រូវបានបដិសេធដោយអាជ្ញាធរ អនុលោមទៅតាមមាត្រា ១៦២ នៃកថាខណ្ឌទី ២(ផ) ឬ

(គ) ផែនការការងារដែលបានស្នើឡើងមានត្រូវបានដាក់ជូន ឬធានាដោយ រដ្ឋភាគីដែលមានក្នុងដៃរួចមកហើយនូវ៖

(i) ផែនការរុករក និងធ្វើអាជីវកម្មធនធានរ៉ែដុំលោហធាតុធាតុក្នុងតំបន់មិនរក្សាទុក ដែលក្នុងនោះ
រួមជាមួយនឹងផ្នែកណាមួយនៃតំបន់ស្ថិតនៅក្រោមពាក្យសុំអនុម័តលើផែនការការងារ មានផ្ទៃក្រឡាលើសពី ៣០ ភាគរយ នៃផ្ទៃក្រឡារង្វង់ ៤០០ ០០០ គីឡូម៉ែត្រការ៉េនៅជុំវិញផ្ចិតនៃផ្នែកណាមួយរបស់តំបន់ដែលស្ថិតនៅក្រោមផែនការការងារដែលបានស្នើឡើង។

(ii) ផែនការរុករក និងធ្វើអាជីវកម្មធនធានរ៉ែដុំលោហធាតុធាតុក្នុង តំបន់មិនរក្សាទុក ដែលបូករួមបញ្ចូលគ្នា ស្មើនឹង ២ ភាគរយនៃផ្ទៃក្រឡាបាតសមុទ្រសរុបដែលមិនត្រូវបានរក្សាទុក ឬបដិសេធសម្រាប់ការធ្វើអាជីវកម្ម អនុលោមទៅតាមមាត្រា ១៦២ នៃកថាខណ្ឌទី(២)(ម)។

៤. ដើម្បីស្របតាមបទដ្ឋានដែលបានកំណត់ក្នុងកថាខណ្ឌទី ៣(គ) ផែនការការងារដែលបានដាក់ជូនដោយក្រុមហ៊ុនសហកម្មសិទ្ធិ ឬសហគមត្រូវបានរាប់ផ្អែកតាម *មូលដ្ឋានសមាមាត្រ* ក្នុងចំណោមរដ្ឋភាគីធានាដែលពាក់ព័ន្ធ អនុលោមតាមមាត្រា ៤ ក្នុងកថាខណ្ឌទី ៣ នៃឧបសម្ព័ន្ធនេះ។ អាជ្ញាធរអាចអនុម័តលើផែនការការងារដែលស្ថិតនៅក្រោមកថាខណ្ឌទី ៣ (គ) ប្រសិនបើខ្លួនកំណត់ឃើញថា ការអនុម័តបែបនេះនឹងមិនអនុញ្ញាតឱ្យរដ្ឋភាគី ឬអង្គភាពដែលខ្លួនធានាមានសិទ្ធិផ្តាច់មុខក្នុងការធ្វើសកម្មភាពនៅក្នុងតំបន់ ឬក្នុងការហាមឃាត់មិនឱ្យរដ្ឋភាគីផ្សេងទៀតធ្វើសកម្មភាពនៅក្នុងតំបន់នោះទេ។

៥. ទោះបីជាមានចែងដូចក្នុងកថាខណ្ឌទី ៣(ក) ក៏ដោយ បន្ទាប់ពីបញ្ចប់រយៈពេលបណ្តោះអាសន្នដែលបានចែងក្នុងមាត្រា ១៥១ កថាខណ្ឌទី ៣ ផ្អែកតាមវិធានច្បាប់ បទបញ្ញត្តិ និង នីតិវិធី អាជ្ញាធរអាចរៀបចំនីតិវិធី និងលក្ខណៈវិនិច្ឆ័យផ្សេងទៀតស្របតាមអនុសញ្ញានេះ

សម្រាប់ធ្វើសេចក្តីសម្រេចថាតើអ្នកដាក់ពាក្យសុំមួយណាត្រូវទទួលបានការអនុម័តលើផែនការការងារ ក្នុងករណីមានការជ្រើសរើសក្នុងចំណោមអ្នកដាក់ពាក្យសុំតំបន់ដែលបានស្នើឡើង។ នីតិវិធី និងលក្ខណៈវិនិច្ឆ័យទាំងនេះនឹងធានាបាននូវការទទួលបានការអនុម័តលើផែនការការងារ ផ្អែកលើមូលដ្ឋានសមធម៌ និងមិនរើសអើង។

*មាត្រា ៧*

*ការជ្រើសរើសក្នុងចំណោមអ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យផលិតកម្ម*

១. រយៈពេលប្រាំមួយខែបន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន និងបន្ទាប់ពីនោះ នៅរៀងរាល់ខែទីបួន អាជ្ញាធរត្រូវចាប់ផ្តើមពិចារណាលើពាក្យសុំការអនុញ្ញាតឱ្យផលិតដែលបានដាក់ជូន ក្នុងរយៈពេលចុងក្រោយ។ អាជ្ញាធរត្រូវចេញជូននូវសេចក្តីអនុញ្ញាតតាមការដាក់ពាក្យសុំ ប្រសិនបើអាចអនុម័តលើពាក្យសុំទាំងនោះបាន ដោយមិនលើសពីដែនកំណត់ក្នុងការផលិត ឬ បំពានលើកាតព្វកិច្ចរបស់អាជ្ញាធរ ក្រោមកិច្ចព្រមព្រៀង ឬការរៀបចំរួមគ្នាស្តីពីទំនិញ ដែលមានខ្លួនជាភាគី ដូចមានចែងក្នុងមាត្រា ១៥១។

២. នៅពេលដែលការជ្រើសរើសត្រូវធ្វើឡើងក្នុងចំណោមអ្នកដាក់ពាក្យសុំ ការអនុញ្ញាតឱ្យផលិតកម្ម ដោយសារដែនកំណត់ក្នុងការផលិតដែលបានកំណត់ក្នុងមាត្រា ១៥១ កថាខណ្ឌទី ២ ដល់ ៧ ឬ ដោយសារកាតព្វកិច្ចរបស់អាជ្ញាធរក្រោមកិច្ចព្រមព្រៀង ឬកិច្ចសម្រុះសម្រួលស្តីពីទំនិញ ដែលមានខ្លួនជាភាគី ដូចមានចែងក្នុងមាត្រា ១៥១ កថាខណ្ឌទី ១ នោះអាជ្ញាធរត្រូវធ្វើការជ្រើសរើសផ្អែកលើកម្មវត្ថុ និងបទដ្ឋានមិនរើសអើងដែលបានកំណត់ក្នុងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់ខ្លួន។

៣. ក្នុងការអនុវត្តន៍កថាខណ្ឌទី ២ អាជ្ញាធរត្រូវផ្តល់អាទិភាពដល់អ្នកដាក់ពាក្យសុំទាំងឡាយណាដែល៖

(ក) ផ្តល់ការធានាលើសមត្ថភាពអនុវត្តការងារល្អជាង ដោយពិចារណាទៅលើលិខិតបញ្ជាក់អំពីហិរញ្ញវត្ថុ និងបច្ចេកទេសរបស់ពួកគេ ព្រមទាំងសមត្ថភាពការងាររបស់ពួកគេ ប្រសិនបើមាន ក្រោមផែនការការងារដែលទទួលបានការអនុម័តមុនៗ។

(ខ) ផ្តល់នូវអត្ថប្រយោជន៍ហិរញ្ញវត្ថុនាពេលអនាគតរហ័សជាងគេដល់អាជ្ញាធរ ដោយពិចារណាថាតើផលិតកម្មអាជីវកម្មត្រូវបានកំណត់ចាប់ផ្តើមនៅពេលណា។

(គ) បានធ្វើការវិនិយោគរួចមកហើយនូវធនធាន និងកិច្ចប្រឹងប្រែងច្រើនបំផុតទៅលើការពិនិត្យដី ឬការរុករក រ៉ែ។

៤.

អ្នកដាក់ពាក្យសុំដែលមិនត្រូវបានជ្រើសរើសក្នុងរយៈពេលណាមួយនោះត្រូវមានអាទិភាពនៅក្នុងរយៈពេលបន្តបន្ទាប់ទៀតរហូតដល់ពួកគេទទួលបានការអនុញ្ញាតឱ្យផលិតកម្ម។

៥. ការជ្រើសរើសត្រូវធ្វើឡើង ដោយពិចារណាទៅលើតម្រូវការក្នុងការពង្រឹងឱកាសសម្រាប់រដ្ឋភាគីទាំងអស់ ក្នុងការចូលរួមសកម្មភាពក្នុងតំបន់ និងក្នុងការបង្ការឯកាធិកម្មលើសកម្មភាពទាំងនោះ ដោយមិនគិតអំពីប្រព័ន្ធសង្គមកិច្ច និងសេដ្ឋកិច្ច ឬទីតាំងភូមិសាស្ត្ររបស់ពួកគេនោះទេ ដើម្បីជៀសវាងការរើសអើងរដ្ឋ ឬប្រព័ន្ធណាមួយ។

៦. នៅពេលណាដែលមានតំបន់រក្សាទុកតិចជាងតំបន់មិនរក្សាទុកស្ថិតនៅក្រោមការធ្វើអាជីវកម្ម នោះពាក្យសុំការអនុញ្ញាតឱ្យផលិតកម្មទាក់ទិននឹងតំបន់រក្សាទុកត្រូវមានអាទិភាព។

៧. សេចក្តីសម្រេចដែលមានលើកឡើងក្នុងមាត្រានេះត្រូវធ្វើឡើងភ្លាមៗតាមដែលអាចធ្វើបាន បន្ទាប់ពីបិទរយៈពេលនីមួយៗ។

*មាត្រា ៨*

*ការរក្សាទុកតំបន់*

ពាក្យសុំតំបន់រក្សាទុកនីមួយៗក្រៅពីពាក្យសុំដែលបានដាក់ជូនដោយសហគ្រាស ឬ ដោយអង្គភាពផ្សេងទៀត ត្រូវបង្ហាញអំពីផ្ទៃក្រឡាសរុបមិនបាច់ថាត្រូវតែជាតំបន់ជាប់គ្នាមិនដាច់ ដែលមានទំហំធំគ្រប់គ្រាន់ និងតម្លៃពាណិជ្ជកម្មតាមការប៉ាន់ប្រមាណគ្រប់គ្រាន់អាចមានប្រតិបត្តិការជីករ៉ែចំនួនពីរ។ អ្នកដាក់ពាក្យសុំត្រូវបង្ហាញអំពីកូអរ៍ឌីនេ ដែលចែកតំបន់ជាចំនួនពីរផ្នែកមានតម្លៃពាណិជ្ជកម្មតាមការប៉ាន់ប្រមាណស្មើគ្នា និងដាក់ជូននូវទិន្នន័យទាំងអស់ដែលខ្លួនទទួលបានទាក់ទិននឹងផ្នែកទាំងពីរ។ ដោយមិនប៉ះពាល់ទៅដល់សិទ្ធិអំណាចរបស់អាជ្ញាធរ អនុលោមទៅតាមមាត្រា ១៧ នៃឧបសម្ព័ន្ធនេះ ទិន្នន័យដែលត្រូវដាក់ជូនស្តីពីដុំលោហធាតុធាតុត្រូវទាក់ទិនទៅនឹងផែនទី សំណាក ភាពសម្បូរ និងចំណុះលោហធាតុរបស់វា។ ក្នុងរវាង ៤៥ ថ្ងៃ បន្ទាប់ពីទទួលបានទិន្នន័យបែបនេះ អាជ្ញាធរត្រូវកំណត់ថាតើផ្នែកមួយណាត្រូវរក្សាទុកទាំងស្រុង សម្រាប់ការអនុវត្តសកម្មភាពរបស់អាជ្ញាធរ តាមរយៈសហគ្រាស ឬ ក្រោមកិច្ចសហការជាមួយរដ្ឋកំពុងអភិវឌ្ឍន៍។ ការកំណត់នេះអាចពន្យារពេល ៤៥ ថ្ងៃ បន្ថែមទៀត ប្រសិនបើអាជ្ញាធរស្នើសុំឱ្យអ្នកជំនាញឯករាជ្យវាយតម្លៃថាតើទិន្នន័យទាំងអស់ ដែលតម្រូវឱ្យមានក្រោមមាត្រានេះត្រូវបានដាក់ជូនសព្វគ្រប់ហើយឬនៅ។ តំបន់ដែលបានកំណត់ត្រូវក្លាយជាតំបន់រក្សាទុកភ្លាមៗ នៅពេលដែលផែនការការងារសម្រាប់តំបន់មិនរក្សាទុកត្រូវបានអនុម័ត ហើយកិច្ចសន្យាត្រូវបានចុះហត្ថលេខា។

*មាត្រា ៩*

*សកម្មភាពក្នុងតំបន់រក្សាទុក*

១. សហគ្រាសត្រូវទទួលបានឱកាសធ្វើការសម្រេចថាតើខ្លួនមានបំណងអនុវត្តសកម្មភាពក្នុងតំបន់រក្សាទុកនីមួយៗឬទេ។ សេចក្តីសម្រេចនេះអាចធ្វើឡើងនៅពេលណាមួយក៏បាន លើកលែងតែអាជ្ញាធរទទួលបានការជូនដំណឹង អនុលោមទៅតាមកថាខណ្ឌទី ៤

ដែលជាករណីសហគ្រាសត្រូវធ្វើការសម្រេចរបស់ខ្លួនក្នុងរវាងថិរវេលាសមហេតុផលមួយ។ សហគ្រាសអាចសម្រេចធ្វើអាជីវកម្មលើតំបន់បែបនេះ ក្នុងលក្ខណៈជាបុត្រសម្ព័ន្ធជាមួយនឹងរដ្ឋ ឬ អង្គភាពដែលមានចំណាប់អារម្មណ៍។

២. សហគ្រាសអាចធ្វើកិច្ចសន្យាសម្រាប់ការអនុវត្តន៍ផ្នែកនៃសកម្មភាពរបស់ខ្លួន អនុលោមតាមឧបសម្ព័ន្ធ ៤ មាត្រា ១២។ សហគ្រាសក៏អាចចូលរួមជាបុត្រសម្ព័ន្ធ សម្រាប់ការអនុវត្តន៍សកម្មភាពបែបនោះជាមួយនឹងអង្គភាពណាមួយដែលមានសិទ្ធិធ្វើសកម្មភាពនៅក្នុង តំបន់ អនុលោមទៅតាមមាត្រា ១៥៣ កថាខណ្ឌទី ២(ខ) ផងដែរ។ នៅពេលពិចារណាលើបុត្រសម្ព័ន្ធបែបនេះ សហគ្រាសត្រូវផ្តល់ជូនរដ្ឋភាគីដែលជារដ្ឋកំពុង អភិវឌ្ឍន៍ និងប្រជាជាតិរបស់ពួកគេនូវឱកាសចូលរួមយ៉ាងមានប្រសិទ្ធភាព។

៣. អាជ្ញាធរអាចចែងក្នុងវិធានច្បាប់ បទបញ្ញត្តិ និង នីតិវិធីរបស់ខ្លួនអំពីលក្ខខណ្ឌសារធាតុ និងនីតិវិធី ទាក់ទិននឹងកិច្ចសន្យា និងបុត្រសម្ព័ន្ធទាំងនោះ។

៤. រដ្ឋភាគីណាមួយដែលជារដ្ឋកំពុងអភិវឌ្ឍន៍ ឬ រូបវន្ត ឬ នីតិបុគ្គលណាមួយដែលធានាដោយខ្លួន និងត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដោយខ្លួន ឬ ដោយរដ្ឋកំពុងអភិវឌ្ឍន៍ផ្សេងទៀតដែលជាអ្នកដាក់ពាក្យសុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬ ក្រុមណាមួយខាងលើ អាចជូនដំណឹងដល់អាជ្ញាធរថាខ្លួនមានបំណងដាក់ជូននូវផែនការការងារ អនុលោមទៅតាមមាត្រា ៦ នៃឧបសម្ព័ន្ធនេះ ទាក់ទិននឹងតំបន់រក្សាទុក។ ផែនការការងារត្រូវបានពិចារណា ប្រសិនបើសហគ្រាសសម្រេច អនុលោមទៅតាម កថាខណ្ឌទី ១ ថាខ្លួនមិនមានបំណងអនុវត្តសកម្មភាពក្នុងតំបន់នោះ។

*មាត្រា ១០*

*បុរមា និងអាទិភាពក្នុងចំណោមអ្នកដាក់ពាក្យសុំ*

ប្រតិបត្តិករដែលទទួលបានការអនុម័តលើផែនការការងាររុករកតែម្យ៉ាង ដូចមានចែងក្នុងមាត្រា ៣ កថាខណ្ឌទី ៤(គ) នៃឧបសម្ព័ន្ធនេះ ត្រូវមានបុរមា និងអាទិភាពក្នុងចំណោមអ្នកដាក់ពាក្យសុំសម្រាប់ផែនការការងារដែលគ្របដណ្តប់លើការធ្វើអាជីវកម្មលើតំបន់ និងធនធានដដែល។ ទោះបីជាយ៉ាងណា បុរមា និងអាទិភាពបែបនេះអាចត្រូវបានដកហូតវិញ ប្រសិនបើសមត្ថភាពការងារប្រតិបត្តិករមិនជាទីពេញចិត្ត។

*មាត្រា ១១ ការរៀបចំរួមគ្នា*

១. កិច្ចសន្យាអាចផ្តល់នូវការរៀបចំរួមគ្នារវាងអ្នកចុះកិច្ចសន្យា និងអាជ្ញាធរតាមរយៈសហគ្រាស ក្នុងទម្រង់ជាបុត្រសម្ព័ន្ធ ឬការចែករំលែកផលិតកម្ម ក៏ដូចជាទម្រង់ផ្សេងទៀតនៃការរៀបចំរួមគ្នា ដែលត្រូវមានការការពារដូចគ្នាទល់នឹងការកែសម្រួល ការផ្អាក ឬ ការបញ្ចប់កិច្ចសន្យាជាមួយនឹងអាជ្ញាធរ។

២. អ្នកចុះកិច្ចសន្យាដែលធ្វើការរៀបចំរួមគ្នាបែបនេះជាមួយនឹងសហគ្រាសអាចទទួលបាននូវរង្វាន់លើកទឹកចិត្តហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រា ១៣ នៃឧបសម្ព័ន្ធនេះ។

៣. ដៃគូក្នុងបុត្រសម្ព័ន្ធជាមួយនឹងសហគ្រាសត្រូវទទួលខុសត្រូវលើប្រាក់ទូទាត់ដែលតម្រូវឱ្យមានក្រោមមាត្រា ១៣ នៃឧបសម្ព័ន្ធនេះ ក្នុងទំហំមួយទៅតាមភាគហ៊ុនរបស់ខ្លួនក្នុងបុត្រសម្ព័ន្ធនោះ អនុលោមទៅតាមរង្វាន់លើកទឹកចិត្តហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រានោះ។

*មាត្រា ១២*

*សកម្មភាពដែលអនុវត្តដោយសហគ្រាស*

១. សកម្មភាពនៅក្នុងតំបន់ដែលអនុវត្តដោយសហគ្រាស អនុលោមទៅតាមមាត្រា ១៥៣ កថាខណ្ឌទី ២(ក) ត្រូវគ្រប់គ្រងដោយផ្នែកទី ១១ វិធានច្បាប់ បទបញ្ញត្តិ និង នីតិវិធី របស់អាជ្ញាធរ និងសេចក្តីសម្រេចពាក់ព័ន្ធរបស់អាជ្ញាធរ។

២. រាល់ផែនការការងារដែលបានដាក់ជូនដោយសហគ្រាសត្រូវអមដោយភស្តុតាងដែលបញ្ជាក់អំពីសមត្ថភាពហិរញ្ញវត្ថុ និងបច្ចេកទេសរបស់ខ្លួន។

*មាត្រា ១៣*

*លក្ខខណ្ឌហិរញ្ញវត្ថុនៃកិច្ចសន្យា*

១. ក្នុងការរៀបចំវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីដែលពាក់ព័ន្ធនឹងលក្ខខណ្ឌហិរញ្ញវត្ថុនៃកិច្ចសន្យារវាងអាជ្ញាធរ និងអង្គភាពដែលមានលើកឡើងក្នុងមាត្រា ១៥៣ កថាខណ្ឌទី ២(ខ) និងក្នុងការចរចាអំពីលក្ខខណ្ឌហិរញ្ញវត្ថុទាំងនោះ អនុលោមតាមផ្នែកទី ១១និងវិធានច្បាប់ បទបញ្ញត្តិ និង នីតិវិធីទាំងនោះ អាជ្ញាធរត្រូវគោរពតាមកម្មវត្ថុខាងក្រោមៈ

(ក) ធានាបាននូវប្រាក់ចំណូលខ្ពស់បំផុតសម្រាប់អាជ្ញាធរចេញពីប្រាក់ចំណូលបានពីផលិតកម្មអាជីវកម្ម។

(ខ) ទាក់ទាញការវិនិយោគ និងបច្ចេកវិទ្យារុករក និងធ្វើអាជីវកម្មលើតំបន់។

(គ) ធានាបាននូវសមភាពនៃការកំណត់ហិរញ្ញវត្ថុ និងកាតព្វកិច្ចហិរញ្ញវត្ថុសមស្របសម្រាប់ អ្នកចុះកិច្ចសន្យា។

(ឃ) ផ្តល់នូវរង្វាន់លើកទឹកចិត្តផ្អែកលើមូលដ្ឋានដែលមានការឯកភាព និងមិនរើសអើង សម្រាប់អ្នកចុះកិច្ចសន្យាអនុវត្តការសម្រុះសម្រួលរួមគ្នាជាមួយនឹងសហគ្រាស និងរដ្ឋកំពុងអភិវឌ្ឍន៍ ឬប្រជាជាតិរបស់ពួកគេ ដើម្បីជម្រុញដល់ការផ្ទេរបច្ចេកវិទ្យា និងការបណ្តុះបណ្តាលបុគ្គលិករបស់អាជ្ញាធរ និងរបស់រដ្ឋកំពុងអភិវឌ្ឍន៍។

(ង) ជួយឱ្យសហគ្រាសអាចចូលរួមក្នុងការជីករ៉ែបាតសមុទ្រប្រកបដោយប្រសិទ្ធភាព ក្នុងពេលតែមួយជាមួយនឹងអង្គភាព ដែលមានលើកឡើងក្នុងមាត្រា ១៥៣ កថាខណ្ឌទី ២(ខ) និង

(ច) ធានាថា ដោយសាររង្វាន់លើកទឹកចិត្តហិរញ្ញប្បទានដែលបានផ្តល់ជូនដល់អ្នកចុះកិច្ចសន្យា ក្រោមកថាខណ្ឌទី ១៤ ក្រោមលក្ខខណ្ឌកិច្ចសន្យាដែលបានពិនិត្យអនុលោមតាមមាត្រា ១៩ នៃឧបសម្ព័ន្ធនេះ ឬ ក្រោមបញ្ញត្តិនៃមាត្រា ១១ នៃឧបសម្ព័ន្ធនេះ ទាក់ទិននឹងបុត្រសម្ព័ន្ធ អ្នកចុះកិច្ចសន្យាមិនត្រូវបានទទួលការឧបត្ថម្ភ ដើម្បីទទួលបានអត្ថប្រយោជន៍ដែលអាចប្រកួតប្រជែងជាមួយនឹងអ្នកស្វែងរុករករ៉ែដីគោកទេ។

២.

ថ្លៃសេវាកម្មនឹងត្រូវបានគិតសម្រាប់សោហ៊ុយរដ្ឋបាលសម្រាប់ការដំណើរការដាក់ពាក្យសុំការអនុម័តលើផែនការការងារ ក្នុងទម្រង់ជាកិច្ចសន្យា ហើយត្រូវបានកំណត់យកក្នុងចំនួន ៥០០ ០០០ ដុល្លារអាមេរិក ក្នុងពាក្យសុំមួយ។ តម្លៃនេះនឹងត្រូវពិនិត្យឡើងវិញពីពេលមួយទៅពេលមួយដោយក្រុមប្រឹក្សា ដើម្បីធានាបានថា វាគ្របដណ្តប់លើសោហ៊ុយរដ្ឋបាលដែលបានកើតមាន។ ប្រសិនបើសោហ៊ុយរដ្ឋបាលបែបនេះដែលកើតមានឡើងដោយសារអាជ្ញាធរនៅក្នុងការដំណើរការដាក់ពា

ក្យសុំមានចំនួនតិចជាងចំនួនទឹកប្រាក់ដែលបានកំណត់ នោះអាជ្ញាធរត្រូវផ្ទេរទឹកប្រាក់ដែលនៅសល់ជូនអ្នកដាក់ពាក្យសុំវិញ។

៣. អ្នកចុះកិច្ចសន្យាត្រូវបង់ប្រចាំឆ្នាំថ្លៃសេវាកម្មប្រចាំឆ្នាំដែលបានកំណត់ចំនួន ១ លាន ដុល្លារអាមេរិក បន្ទាប់ពីកាលបរិច្ឆេទដែលកិច្ចសន្យាចូលជាធរមាន។ ប្រសិនបើកាលបរិច្ឆេទចាប់ផ្ដើមផលិតកម្មអាជីវកម្មដែលបានអនុម័តត្រូវបានអូសបន្លាយដោយសារការយឺតយ៉ាវក្នុងការចេញនូវការអនុញ្ញាតឱ្យផលិតកម្ម អនុលោមតាមមាត្រា ១៥១ថ្លៃសេវាកម្មប្រចាំឆ្នាំដែលបានកំណត់ត្រូវបោះបង់ចោលសម្រាប់រយៈពេលដែលបានអូសបន្លាយ។ បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្ដើមផលិតកម្មអាជីវកម្ម អ្នកចុះកិច្ចសន្យាត្រូវបង់បន្ទុកផលិតកម្ម ឬថ្លៃសេវាកម្មប្រចាំឆ្នាំដែលបានកំណត់ តាមចំនួនមួយណាដែលច្រើនជាង។

៤. ក្នុងរវាងមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទចាប់ផ្ដើមផលិតកម្មអាជីវកម្ម អនុលោមទៅតាមកថាខណ្ឌទី៣ អ្នកចុះកិច្ចសន្យាត្រូវជ្រើសរើសធ្វើការចូលរួមចំណែកហិរញ្ញប្បទានរបស់ខ្លួនជូនដល់អាជ្ញាធរតាមរយៈ៖

(ក) បង់តែបន្ទុកផលិតកម្មប៉ុណ្ណោះ ឬ

(ខ) បង់បន្ទុករួមបញ្ចូលគ្នារវាងបន្ទុកផលិតកម្ម និងចំណែកក្នុងចំណូល សុទ្ធ។

៥. (ក)

ប្រសិនបើអ្នកចុះកិច្ចសន្យាជ្រើសរើសធ្វើការចូលរួមចំណែកហិរញ្ញប្បទានរបស់ខ្លួនជូនអាជ្ញាធរតាមរយៈការបង់តែបន្ទុកផលិតកម្មប៉ុណ្ណោះនោះ វាត្រូវកំណត់តាមភាគរយនៃតម្លៃទីផ្សាររបស់លោហធាតុកែច្នៃដែលបានផលិតពីដុំលោហធាតុធាតុដែលចម្រាញ់ចេញពីតំបន់ដែលស្ថិតនៅក្រោមកិច្ចសន្យា។ ភាគរយនេះត្រូវកំណត់ដូចតទៅ:

(i) ឆ្នាំទី ១-១០ នៃផលិតកម្មអាជីវកម្ម ៥ ភាគរយ

(ii) ឆ្នាំទី ១១ រហូតដល់ចុងរយៈពេលផលិតកម្មអាជីវកម្ម ១២ ភាគរយ (ខ) តម្លៃទីផ្សារខាងលើគឺជាផលិតផលនៃបរិមាណ លោហធាតុកែច្នៃដែលបានផលិតចេញពីដុំលោហធាតុធាតុយកពីតំបន់ស្ថិតនៅក្រោមកិច្ចសន្យា និងតម្លៃមធ្យមសម្រាប់លោហធាតុទាំងនោះក្នុងឆ្នាំសារពើពន្ធពាក់ព័ន្ធ ដូចបានកំណត់ក្នុងកថាខណ្ឌទី ៧ និង ៨។

៦.

ប្រសិនបើអ្នកចុះកិច្ចសន្យាជ្រើសរើសធ្វើការចូលរួមចំណែកហិរញ្ញប្បទានរបស់ខ្លួនជូនដល់អាជ្ញាធរ តាមរយៈការបង់បន្ទុករួមបញ្ចូលគ្នារវាងបន្ទុកផលិតកម្ម និងចំណែកក្នុងចំណូលសុទ្ធ នោះការទូទាត់ត្រូវកំណត់ដូចតទៅៈ

(ក) បន្ទុកផលិតកម្ម ត្រូវកំណត់ជាភាគរយនៃតម្លៃទីផ្សារដែលបានកំណត់អនុលោមតាមកថាខណ្ឌរង (ខ) របស់លោហធាតុកែច្នៃដែលបានផលិតចេញពីដុំលោហធាតុធាតុយកពីតំបន់ស្ថិតនៅក្រោមកិច្ចសន្យា។ ភាគរយនេះត្រូវកំណត់ដូចតទៅៈ

(i) រយៈពេលទីមួយនៃផលិតកម្មអាជីវកម្ម ២ ភាគរយ

(ii) រយៈពេលទីពីរនៃផលិតកម្មអាជីវកម្ម ៤ ភាគរយ ប្រសិនបើក្នុងរយៈពេលទីពីរនៃផលិតកម្មអាជីវកម្ម ដូចបានកំណត់ក្នុងកថាខណ្ឌរង (ឃ) ផលពីការវិនិយោគក្នុងឆ្នាំសារពើពន្ធណាមួយ ដូចបានកំណត់ក្នុងកថាខណ្ឌរង (ឋ) ធ្លាក់ក្រោម ១៥ ភាគរយ ដោយសារ ការទូទាត់បន្ទុកផលិតកម្ម ៤ ភាគរយ នោះបន្ទុកផលិតកម្មត្រូវគិត ២ ភាគរយ ជំនួសឱ្យ ៤ ភាគរយ ក្នុងឆ្នាំសារពើពន្ធនោះ។

(ខ)

តម្លៃទីផ្សារខាងលើគឺជាផលិតផលនៃបរិមាណលោហធាតុកែច្នៃដែលបានផលិតចេញ ពីដុំលោហធាតុធាតុយកពីតំបន់ស្ថិតនៅក្រោមកិច្ចសន្យា និងតម្លៃមធ្យមសម្រាប់លោហធាតុទាំងនោះក្នុងឆ្នាំសារពើពន្ធពាក់ព័ន្ធ ដូចបានកំណត់ក្នុងកថាខណ្ឌទី ៧ និង ៨។

(គ) (១) ចំណែកនៃចំណូលសុទ្ធរបស់អាជ្ញាធរត្រូវបានកាត់ចេញពី
ចំណែកនៃចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យា
ដែលទទួលបានពីការជីកយកធនធាននៃតំបន់ស្ថិតនៅក្រោមកិច្ចសន្យា
តទៅហៅថាចំណូលសុទ្ធដែលសម្រេចបាន។ (២)
ចំណែកនៃចំណូលសុទ្ធដែលសម្រេចបានរបស់អាជ្ញាធរត្រូវបានកំណត់
អនុលោមតាមកាលវិភាគបន្ថែមខាងក្រោមៈ
ចំណែកនៃចំណូលសុទ្ធដែលសម្រេចបាន
ភាគហ៊ុនរបស់អាជ្ញាធររយៈពេលទីមួយនៃផលិតកម្មអាជីវកម្ម
រយៈពេលទី២នៃផលិតកម្មអាជីវកម្ម
ចំណែកដែលតំណាងឱ្យផលពីការវិនិយោគដែលមានភាគរយច្រើនជាង 0 ភាគរយ ប៉ុន្តែតិចជាង ១០ ភាគរយ ។ ចំណែកដែលតំណាងឱ្យផលពីការវិនិយោគ ១0 ភាគរយ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ២0 ភាគរយ ។ ចំណែកដែលតំណាងឱ្យផលពីការវិនិយោគ ដែលស្មើនឹង ២0 ភាគរយ ឬ ច្រើនជាង។៣៥ ភាគរយ៤0 ភាគរយ៤២,៥ ភាគរយ៥0 ភាគរយ៥0 ភាគរយ៧0 ភាគរយ

(ឃ) (១) រយៈពេលទីមួយនៃផលិតកម្មអាជីវកម្ម ដែលមានលើកឡើងក្នុងកថាខណ្ឌរង (ក) និង (គ) ត្រូវចាប់ផ្តើមក្នុងឆ្នាំសារពើពន្ធទីមួយនៃផលិតកម្មអាជីវកម្ម និងបញ្ចប់ក្នុងឆ្នាំសារពើពន្ធដែលក្នុងនោះ
សោហ៊ុយអភិវឌ្ឍន៍ជាមួយនឹងការប្រាក់របស់អ្នកចុះកិច្ចសន្យាលើចំណែកដែលមិនអាចស្តារមកវិញត្រូវបានស៊ីសងយ៉ាងពេញលេញដោយប្រើអតិរេកសាច់ប្រាក់ផ្ទាល់របស់ខ្លួន ដូចតទៅៈ
ក្នុងឆ្នាំសារពើពន្ធទីមួយដែលបានកើតមាននូវចំណាយលើការអភិវឌ្ឍន៍
ចំណាយលើការអភិវឌ្ឍន៍ដែលមិនអាចស្តារទទួលមកវិញត្រូវស្មើគ្នានឹងចំណាយលើការអភិវឌ្ឍន៍ដកអតិរេកសាច់ប្រាក់ក្នុងឆ្នាំនោះ។ ក្នុងឆ្នាំសារពើពន្ធបន្តបន្ទាប់ទៀតនីមួយៗ ចំណាយលើការអភិវឌ្ឍន៍ដែលមិនអាចស្តារមកវិញត្រូវស្មើគ្នានឹងចំណាយ

លើការអភិវឌ្ឍន៍ដែលមិនបានទទួលមកវិញនៅចុងឆ្នាំសារពើពន្ធចុងក្រោយបូករួមជាមួយ ការប្រាក់របស់វាក្នុងអត្រា ១០ ភាគរយក្នុងមួយឆ្នាំ បូករួមជាមួយចំណាយលើការអភិវឌ្ឍន៍ដែលបានកើតមានក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន រួចដកអតិរេកសាច់ប្រាក់របស់អ្នកចុះកិច្ចសន្យាក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន។ ឆ្នាំសារពើពន្ធដែលក្នុងនោះ ចំណាយលើការអភិវឌ្ឍន៍ដែលមិនអាចស្តារមកវិញមានលទ្ធផលស្មើសូន្យជាលើកដំបូងត្រូវជាឆ្នាំសារពើពន្ធដែលក្នុងនោះ ចំណាយលើការអភិវឌ្ឍន៍របស់អ្នកចុះកិច្ចសន្យាជាមួយនឹងការប្រាក់របស់វាលើចំណែកដែលមិនអាចស្តារមកវិញបាននោះត្រូវស៊ីសងគ្នាអស់ទាំងស្រុងជាមួយនឹងអតិរេកសាច់ប្រាក់របស់ខ្លួន។ តិរេកសាច់ប្រាក់របស់អ្នកចុះកិច្ចសន្យាក្នុងឆ្នាំសារពើពន្ធណាមួយត្រូវជាបរាក់ចំណូលដុលរបស់ខ្លួនដកសោហ៊ុយចំណាយប្រតិបត្តិរបស់ខ្លួន និងដកប្រាក់ដែលខ្លួនបង់ជូនអាជ្ញាធរក្រោមកថាខណ្ឌរង (គ) ចេញ។ (២) រយៈពេលទីពីរនៃផលិតកម្មអាជីវកម្ម ត្រូវចាប់ផ្តើមក្នុងឆ្នាំសារពើពន្ធបន្ទាប់ពីបញ្ចប់រយៈពេលទីមួយនៃផលិតកម្មអាជីវកម្ម និងត្រូវបន្តរហូតដល់បញ្ចប់កិច្ចសន្យា។

(ង) "ចំណូលសុទ្ធដែលសម្រេចបាន " មានន័យថាជាលទ្ធផលនៃចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យា និងអនុបាតនៃចំណាយលើការអភិវឌ្ឍន៍ក្នុងវិស័យរ៉ែទៅនឹងចំណាយលើការអភិវឌ្ឍន៍របស់អ្នកចុះកិច្ចសន្យា។ ប្រសិនបើអ្នកចុះកិច្ចសន្យាចូលរួមក្នុងការជីក ដឹកជញ្ជូនដុំលោហធាតុ និងផលិតកម្មជាចំបងនូវលោហធាតុកែច្នៃចំនួនបី គឺ កូប៉ល ទង់ដែង និងនីកែល នោះចំនួនចំណូលសុទ្ធដែលសម្រេចបានមិនត្រូវតិចជាង ២៥ ភាគរយនៃចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យាឡើយ។ អនុលោមទៅតាមកថាខណ្ឌរង (ឈ) ក្នុងករណីផ្សេងទៀតទាំងអស់ រាប់បញ្ចូលទាំងករណីដែលអ្នកចុះកិច្ចសន្យាចូលរួមក្នុងការជីក

ដឹកជញ្ជូនដុំលោហធាតុធាតុ និងផលិតកម្មជាចំបងនូវលោហធាតុកែច្នៃចំនួនបួន គឺកូប័ល ទង់ដែង ម៉ង់កាណែស និងនីកែល នោះនៅក្នុងវិធានច្បាប់ បទបញ្ញត្តិ និង នីតិវិធីរបស់ខ្លួន អាជ្ញាធរអាចចែងអំពីកម្រិតទាបបំផុតសមស្របដែលត្រូវមានទំនាក់ទំនងដូចគ្នាជាមួយទៅនឹងករណីនីមួយៗដែលមានកម្រិតទាបបំផុត ២៥ ភាគរយ មានចំពោះករណីលោហធាតុចំនួនបីដូច្នេះដែរ។

(ច) "ចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យា" មានន័យថាជា ប្រាក់ចំណូលដុលរបស់អ្នកចុះកិច្ចសន្យាដកសោហ៊ុយចំណាយប្រតិបត្តិរបស់ខ្លួន រួចដកប្រាក់ទូទាត់របស់ខ្លួនលើចំណាយលើការអភិវឌ្ឍន៍ដូចបានកំណត់ក្នុង កថាខណ្ឌរង (ញ)។

(ឆ) (១) ប្រសិនបើអ្នកចុះកិច្ចសន្យាចូលរួមក្នុងការជីក ដឹកជញ្ជូនដុំលោហធាតុធាតុ និងផលិតកម្មលោហធាតុកែច្នៃ នោះ"ប្រាក់ចំណូលដុលរបស់អ្នកចុះកិច្ចសន្យា" មានន័យថាជា ចំណូលដុលទទួលបានពីការលក់លោហធាតុកែច្នៃ និងប្រាក់ផ្សេងទៀតដែលចាត់ទុកយ៉ាងសមហេតុផលទទួលបានពីប្រតិបត្តិការក្រោមកិច្ចសន្យា អនុលោមតាមវិធានច្បាប់ បទបញ្ញត្តិ និង នីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ។ (២) ក្នុងគ្រប់ករណីទាំងអស់ក្រៅពីករណីដែលបានចែងក្នុងកថាខណ្ឌរង (ឆ)(១) និង (ឈ)(៣) "ប្រាក់ចំណូលដុលរបស់អ្នកចុះកិច្ចសន្យា" មានន័យថាជា ចំណូលដុលបានមកពីការលក់លោហធាតុពាក់កណ្តាលកែច្នៃពីដុំលោហធាតុធាតុដែលស្តារមកវិញបានពីតំបន់ស្ថិតនៅក្រោមកិច្ចសន្យា និងប្រាក់ផ្សេងទៀតដែលចាត់ទុកយ៉ាងសមហេតុផលទទួលបានពីប្រតិបត្តិការក្រោមកិច្ចសន្យា អនុលោមតាមវិធានច្បាប់ បទបញ្ញត្តិ និង នីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ។

(ញ) "ចំណាយលើការអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យា" ដែលកើតឡើងមុនពេលចាប់ផ្តើមផលិតកម្ម អាជីវកម្មដូចមានចែងក្នុងកថាខណ្ឌ (ជ) (ឈ) និង (ធ)(៤) នឹងត្រូវប្រមូលវិញជា ១០ ដំណាក់កាលប្រចាំឆ្នាំដែលមានចំនួនប្រាក់ស្មើៗគ្នា

គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមផលិតកម្ម អាជីវកម្ម។ ចំណាយលើការអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យា ដែលកើតឡើងក្រោយពេលចាប់ផ្តើមផលិតកម្មអាជីវកម្ម ដូចចែងក្នុងកថាខណ្ឌ (ជ)(២) និង (ធ)(៤) ត្រូវប្រមូលវិញជា ១០ ដំណាក់កាលប្រចាំឆ្នាំ ឬតិចជាង ១០ ដំណាក់កាលដែលមានចំនួនប្រាក់ស្មើគ្នា ដើម្បីធានាការ ទទួលបានមកវិញគ្រប់ចំនួន នៅមុនពេលបញ្ចប់នៃកិច្ចសន្យា។

(ដ) ″ចំណាយប្រតិបត្តិការរបស់អ្នកចុះកិច្ចសន្យា″ មានន័យថា រាល់ការចំណាយទាំងអស់ដែលកើតឡើង ក្រោយការចាប់ផ្តើមផលិតកម្មអាជីវកម្ម ក្នុងប្រតិបត្តិការផលិតកម្មនៅតំបន់ក្រោមកិច្ចសន្យា និង សកម្មភាពពាក់ព័ន្ធប្រតិបត្តិការក្នុងកិច្ចសន្យា អនុលោមតាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅដែល រួមមានដូចជាកម្រៃកំណត់ប្រចាំឆ្នាំ ឬថ្លៃដើមផលិតកម្ម ដោយជ្រើសរើសយកជម្រើសណាមួយ ដែលច្រើនជាង ការចំណាយលើប្រាក់ឈ្នួល ប្រាក់បៀវត្ស អត្ថប្រយោជន៍ និយោជិត សម្ភារ សេវាកម្ម ថ្លៃដឹកជញ្ជូន កែច្នៃ និងផ្សព្វផ្សាយទីផ្សារ ការប្រាក់ អត្ថប្រយោជន៍ ការរក្សាបរិស្ថាន សមុទ្រ កម្រៃរដ្ឋបាល និងដំណើរការដែលទាក់ទងជាក់លាក់នឹងប្រតិបត្តិការ ក្រោមកិច្ចសន្យា ព្រមទាំងការខាតបង់សុទ្ធណាមួយខាងប្រតិបត្តិការដែលទូទាត់ក្នុងបញ្ជីគណនីឆ្នាំបន្ទាប់ ឬឆ្នាំមុន ដូចចែងក្នុងកិច្ចសន្យានេះ។ ការខាតបង់សុទ្ធលើប្រតិបត្តិការអាចយកមកទូទាត់ក្នុងបញ្ជីគណនី សម្រាប់ ២ ឆ្នាំបន្ទាប់ជាប់ៗគ្នា លើកលែងតែ ២ ឆ្នាំចុងក្រោយ ដែលការខាតបង់នេះអាចយកមក ទូទាត់បញ្ជីគណនីសម្រាប់ ២ ឆ្នាំមុនបាន។

(ថ) ប្រសិនបើអ្នកចុះកិច្ចសន្យាជីកយករ៉ែ ដឹកជញ្ជូនដុំលោហៈប៉ូលីមេតាលិក និងផលិតលោហៈកែច្នៃ និងលោហៈពាក់កណ្តាលកែច្នៃ ″ចំណាយលើការអភិវឌ្ឍក្នុងវិស័យរ៉ែ″ មានន័យថា ចំណែកនៃចំណាយលើការអភិវឌ្ឍរបស់ អ្នកចុះកិច្ចសន្យាទាក់ទងដោយផ្ទាល់នឹងការជីកយកធនធាននៅតំបន់ក្រោមកិច្ចសន្យា

អនុលោមតាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅ ហើយវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ មានជាអាទិ៍ កម្រៃដាក់ពាក្យសុំ កម្រៃកំណត់ប្រចាំឆ្នាំ និងចំណាយពិនិត្យបែបបទស្នើសុំ និងស្វែងរុករកធនធានរ៉ែនៅក្នុងតំបន់ក្រោមកិច្ចសន្យា ព្រមទាំងចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍។

(ឱ) ″ផលពីការវិនិយោគ″ ក្នុងឆ្នាំសារពើពន្ធណាមួយ មានន័យថា អនុបាតនៃចំណូលសុទ្ធនៅក្នុងឆ្នាំនោះ លើការចំណាយអភិវឌ្ឍក្នុងវិស័យរ៉ែ។ ក្នុងគោលបំណងគណនាអនុបាតនេះ ចំណាយលើការអភិវឌ្ឍក្នុងវិស័យរ៉ែត្រូវរាប់បញ្ចូលថ្លៃដើមគ្រឿងបរិក្ខារថ្មី ឬការផ្លាស់ប្តូរគ្រឿងបរិក្ខារក្នុងវិស័យរ៉ែដកនឹងថ្លៃដើមគ្រឿងបរិក្ខារដែលដាក់ជំនួសនោះ។

(ផ) ប្រសិនបើអ្នកចុះកិច្ចសន្យាប្រតិបត្តិការជីកយករ៉ែតែមួយគត់ ៖

(i) ″ចំណូលសុទ្ធ″ មានន័យថាប្រាក់ចំណូលសុទ្ធទាំងអស់របស់អ្នកចុះកិច្ចសន្យា។

(ii) ″ចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យា″ ត្រូវកំណត់និយមន័យក្នុងកថាខណ្ឌ (ច)។

(iii) ″ចំណូលសរុបរបស់អ្នកចុះកិច្ចសន្យា″ មានន័យថា ប្រាក់សរុបដែលបានមកពីការលក់ដុំរ៉ែលោហៈ

និងប្រាក់ដទៃទៀតដែលទទួលបានសមស្របពីប្រតិបត្តិការតាមកិច្ចសន្យា អនុលោមតាម វិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ។

(iv) ″ការចំណាយអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យា″ រាល់ការចំណាយទាំងអស់ដែលកើតឡើងមុនពេល ចាប់ផ្តើមផលិតកម្មអាជីវកម្ម ដូចចែងក្នុងកថាខណ្ឌ (ជ)(i) និងរាល់ការចំណាយអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យាទាំងអស់ ដែលកើតឡើងក្រោយពេលចាប់ផ្តើមផលិតកម្មអាជីវកម្ម ដូចចែងក្នុងកថាខណ្ឌ (ជ)(ii)ដែលទាក់ទងដោយផ្ទាល់នឹងការជីក

យកធនធាននៅតំបន់ដែលចែងក្នុងកិច្ចសន្យា

អនុលោមតាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅ។

(v) ″ការចំណាយប្រតិបត្តិការរបស់អ្នកចុះកិច្ចសន្យា″ មានន័យថា រាល់ការចំណាយប្រតិបត្តិការ ទាំងអស់ ដូចចែងក្នុងកថាខណ្ឌ (ដ) ដែលទាក់ទងដោយផ្ទាល់នឹងការជីកយកធនធាន

នៅតំបន់ដែលចែងក្នុងកិច្ចសន្យា

អនុលោមតាមគោលការណ៍គណនេយ្យដែលត្រូវបាន ទទួលស្គាល់ជាទូទៅ។

(vi) ″ផលវិនិយោគ″ ក្នុងឆ្នាំគណនេយ្យណាមួយមានន័យ អនុបាតនៃចំណូលសុទ្ធរបស់អ្នកម៉ៅ ការ នៅក្នុងឆ្នាំនោះ លើការចំណាយអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យា។ ក្នុងគោលបំណងគណនា

អនុបាតនេះ

ការចំណាយអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យាត្រូវរាប់បញ្ចូលការចំណាយលើគ្រឿង

ដកនឹងថ្លៃដើមគ្រឿង បរិក្ខារជំនួសនោះ។

(ណ) ការចំណាយដូចមានចែងក្នុងកថាខណ្ឌ (ជ) (ដ) (ថ) និង (ធ) ទាក់ទងនឹងការប្រាក់ដែលត្រូវបង់ ដោយអ្នកចុះកិច្ចសន្យា ត្រូវអនុញ្ញាតរហូតដល់កម្រិតដែលអាជ្ញាធរបានឯកភាពលើអនុបាតរវាងបំណុល និងទុន ព្រមទាំងអាត្រាការប្រាក់សមស្របទាក់ទងនឹងទម្លាប់ពាណិជ្ជកម្មដែលមានស្រាប់ នៅគ្រប់កាលៈទេសៈទាំងអស់អនុលោមតាមមាត្រា ៤ កថាខណ្ឌទី ១ នៃឧបសម្ព័ន្ធនេះ។

(ប) ការចំណាយដូចមានចែងក្នុងកថាខណ្ឌនេះមិនត្រូវយកមកបកស្រាយ ដើម្បីរាប់បញ្ចូលទាំងការបង់ពន្ធចំណូលក្រុមហ៊ុន ឬកម្រៃប្រហាក់ប្រហែលដែលកំណត់ដោយរដ្ឋ ទាក់ទងនឹងប្រតិបត្តិការរបស់អ្នកចុះកិច្ចសន្យាឡើយ។

៧. (ក) ″លោហៈកែច្នៃ″ ដូចមានចែងក្នុងកថាខណ្ឌទី ៥ និង ៦ មានន័យថា លោហៈក្នុងទ្រង់ទ្រាយមូលដ្ឋានបំផុតដែលជាធម្មតា ត្រូវបានធ្វើពាណិជ្ជកម្ម នៅលើទីផ្សារអន្តរជាតិ។ ក្នុងគោលបំណងនេះ អាជ្ញាធរត្រូវកំណត់

ឱ្យច្បាស់ពីទីផ្សារអន្តរជាតិពាក់ព័ន្ធ នៅក្នុងវិធានច្បាប់ បទបញ្ញាត្តិ និងនីតិវិធីហិរញ្ញវត្ថុរបស់ខ្លួន។ ចំពោះលោហធាតុមិនមែនសម្រាប់គោលបំណង ពាណិជ្ជកម្មនៅលើទីផ្សារ "លោហៈកែច្នៃ" មានន័យថា លោហធាតុក្នុងទ្រង់ទ្រាយមូលដ្ឋានបំផុត ដែលជាធម្មតាត្រូវបានធ្វើពាណិជ្ជកម្មរវាងភាគីឯករាជ្យពីគ្នា។

(ខ) ប្រសិនបើអាជ្ញាធរមិនអាចធ្វើការកំណត់បរិមាណលោហៈកែច្នៃបាន ដែលផលិតបានពីបណ្តុំរ៉ែលោហៈពី តំបន់ក្រោមកិច្ចសន្យាដូចមានចែងក្នុងកថាខណ្ឌទី ៥(ខ) និង ៦(ខ) បរិមាណត្រូវកំណត់ផ្អែកលើសារធាតុរ៉ែលោះនៃបណ្តុំរ៉ែនោះ ប្រសិទ្ធភាពនៃការកែច្នៃ និងកត្តាពាក់ព័ន្ធដទៃទៀត អនុលោមតាមវិធានច្បាប់ បទបញ្ញត្តិ នីតិវិធីរបស់អាជ្ញាធរ និងស្របតាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅ។

៨. ប្រសិនបើទីផ្សារអន្តរជាតិផ្តល់ជាយន្តការកំណត់តម្លៃចំពោះលោហៈកែច្នៃ ដុំរ៉ែលោហៈ និងលោហៈពាក់កណ្តាលកែ ឆ្អែពីដុំលោហៈ តម្លៃជាមធ្យមនៅលើទីផ្សារនោះត្រូវយកមកប្រើប្រាស់។ ក្នុងករណីដទៃទៀត អាជ្ញាធរត្រូវកំណត់តម្លៃ សមរម្យចំពោះទំនិញ អនុលោមតាមកថាខណ្ឌទី ៩ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយនឹងអ្នកចុះកិច្ចសន្យារួច។

៩. (ក) សោហ៊ុយ ការចំណាយ ចំណូល និងផលទុន និងការកំណត់តម្លៃទាំងអស់ ដែលលើកឡើងក្នុង មាត្រានេះ ត្រូវជាលទ្ធផលទីផ្សារសេរី ឬប្រតិបត្តិការរវាងភាគីឯករាជ្យពីគ្នា។ បើគ្មានទេនោះ វាត្រូវកំណត់ដោយអាជ្ញាធរ បន្ទាប់ពីពីគ្រោះយោបល់ជាមួយនឹងអ្នកចុះកិច្ចសន្យា ហាក់បីដូចជាវាជា លទ្ធផលទីផ្សារ ឬប្រតិបត្តិការរវាងភាគីឯករាជ្យពីគ្នាអញ្ចឹង ដោយពិចារណាលើប្រតិបត្តិការ ពាក់ព័ន្ធនៅលើទីផ្សារដទៃទៀត។

(ខ) ក្នុងគោលបំណងធានាលើការគោរពតាម និងការអនុវត្តបញ្ញត្តិនៃកថាខណ្ឌនេះ អាជ្ញាធរត្រូវ អនុវត្តតាមគោលការណ៍ និងការបកស្រាយចំពោះ ប្រតិបត្តិការរវាងភាគីឯករាជ្យពីគ្នា ដែល បានអនុម័ត និងបកស្រាយដោយគណៈកម្មការអង្គការសហប្រជាជាតិស្តីពីសាជីវកម្មពហុជាតិ ក្រុមអ្នកជំនាញទទួលបន្ទុកសនស្ធិញ្ញាសារពើពន្ធ និងអង្គការអន្តរជាតិដទៃទៀត

ហើយត្រូវកំណត់វិធានច្បាប់ និង នីតិវិធីគណនេយ្យរួម

និងដែលត្រូវបានទទួលស្គាល់ជាទូទៅ និងវិធីជ្រើសរើសគណនេយ្យករ

ឯករាជ្យដោយអ្នកចុះកិច្ចសន្យា ដែលអាជ្ញាធរអាចទទួលយកបាន នៅក្នុងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់ខ្លួន ក្នុងគោលបំណងដើម្បីធ្វើសវនកម្មអនុលោមតាមវិធានច្បាប់ បទបញ្ញត្ត និងបែបបទទាំងនោះ។

១០. អនុលោមតាមវិធានច្បាប់ បទបញ្ញត្តិ និងបែបទហិរញ្ញវត្ថុ របស់អាជ្ញាធរ អ្នកចុះកិច្ចសន្យាត្រូវផ្តល់ទិន្នន័យ ហិរញ្ញវត្ថុដល់គណនេយ្យករ ដែលត្រូវការដើម្បីកំណត់ការគោរពតាមមាត្រានេះ។

១១. សោហ៊ុយ ការចំណាយ ចំណូល និងផលទុនទាំងអស់ ព្រមទាំងតម្លៃទាំងអស់ ដែលលើកឡើងក្នុងមាត្រា នេះ ត្រូវកំណត់តាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅ និងតាមវិធានច្បាប់ បទបញ្ញត្តិ និង នីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ។

១២. ការបង់ប្រាក់ឱ្យអាជ្ញាធរ តាមកថាខណ្ឌទី ៥ និង ៦ ត្រូវធ្វើឡើងដោយសេរី ជារូបិយវត្ថុដែលមានដោយ សេរី និងអាចប្រើការបានប្រកបដោយប្រសិទ្ធភាព នៅលើទីផ្សារប្តូរប្រាក់អន្តរជាតិសំខាន់ៗ ឬតាមជម្រើសរបស់ អ្នកចុះកិច្ចសន្យា ជាវត្ថុសមមូលនឹងលោហៈកែច្នៃក្នុងតម្លៃទីផ្សារ។ តម្លៃទីផ្សារត្រូវកំណត់អនុលោមតាមកថាខណ្ឌទី ៥(ខ)។ រូបិយវត្ថុដែលមានដោយសេរី និងអាចប្រើការបានប្រកបដោយប្រសិទភ្ជាពនៅលើទីផ្សារប្តូរប្រាក់អន្តរជាតិសំខាន់ៗត្រូវបានកំណត់ ក្នុងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ អនុលោមតាមទម្លាប់អនុវត្តនៃរូបិយវត្ថុអន្តរជាតិនាពេលបច្ចុប្បន្ន។

១៣. រាល់កាតព្វកិច្ចហិរញ្ញវត្ថុទាំងអស់របស់អ្នកចុះកិច្ចសន្យាចំពោះអាជ្ញាធរ ក៏ដូចជា កម្រៃ សោហ៊ុយ ការចំណាយ ចំណូល និងផលទុនទាំងអស់របស់អ្នកចុះកិច្ចសន្យា ដែលលើកឡើងក្នុងមាត្រានេះ ត្រូវកែប្រែ ដោយកំណត់វាក្នុងតម្លៃថេរទាក់ទងនឹងឆ្នាំមូលដ្ឋាន។

១៤. ដោយពិចារណាលើអនុសាសន៍របស់គណៈកម្មការរៀបចំផែនការសេដ្ឋកិច្ច និងគណៈកម្មការជំនាញ និងច្បាប់ អាជ្ញាធរអាចអនុម័តវិធានច្បាប់ បទបញ្ញត្តិ នីតិវិធី

ដែលផ្តល់ការលើកទឹកចិត្តដល់អ្នកចុះកិច្ចសន្យា ជាទូទៅ និងគ្មានការរើសអើង ដើម្បីសម្រេចគោលបំណងដែលមានចែងក្នុងកថាខណ្ឌទី ១។

១៥. ក្នុងករណីមានវិវាទរវាងអាជ្ញាធរ និងអ្នកចុះកិច្ចសន្យាលើការបកស្រាយ ឬការអនុវត្តលក្ខខណ្ឌហិរញ្ញវត្ថុនៃ កិច្ចសន្យា ភាគីណាមួយអាចបញ្ជូនវិវាទនោះទៅធ្វើមជ្ឈត្តកម្មពាណិជ្ជកម្មដែលចងកាតព្វកិច្ច ប្រសិនបើភាគីទាំងពីរមិនបានព្រមព្រៀងគ្នាដោះស្រាយវិវាទតាមវិធីផ្សេងទៀតទេនោះ អនុលោមតាម កថាខណ្ឌទី ២នៃមាត្រា ១៨៨។

*មាត្រា ១៤*

*ការផ្ទេរទិន្នន័យ*

១. អនុលោមតាមវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ និងតាមប្រការ និងលក្ខខណ្ឌនៃផែនការ ការងារ ប្រតិបត្តិករត្រូវផ្ទេររាល់ទិន្នន័យទាំងអស់ទៅឱ្យអាជ្ញាធរ ដែលចាំបាច់ និងពាក់ព័ន្ធនឹងការអនុវត្តអំណាច និងមុខងាររបស់ស្ថាប័នចម្បងនៃអាជ្ញាធរទាក់ទងនឹងតំបន់ក្រោមផែនការការងារ ក្នុងរយៈពេលដែលកំណត់ដោយអាជ្ញាធរ។

២. ទិន្នន័យដែលផ្ទេរទាក់ទងនឹងតំបន់ដែលចែងក្នុងផែនការការងារ ដែលត្រូវចាត់ទុកជាសិទ្ធិកម្មសិទ្ធិ អាចប្រើប្រាស់បានតែសម្រាប់គោលបំណងដែលមានចែងក្នុងមាត្រានេះប៉ុណ្ណោះ។ ទិន្នន័យដែលចាំបាច់សម្រាប់ អាជ្ញាធររៀបចំវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីទាក់ទងនឹងការការពារបរិស្ថាន និងសុវត្ថិភាពដែនសមុទ្រ មិនត្រូវចាត់ទុកជាសិទ្ធិកម្មសិទ្ធិ លើកលែងតែទិន្នន័យគំនូសប្លង់គ្រឿងបរិក្ខារ។

៣. ទិន្នន័យដែលផ្ទេរទៅឱ្យអាជ្ញាធរដោយអ្នកសិក្សាតំបន់ បេក្ខជនដាក់ពាក្យក្រោមកិច្ចសន្យា ឬអ្នកចុះកិច្ចសន្យា ដែលចាត់ទុកជាសិទ្ធិកម្មសិទ្ធិ មិនត្រូវបញ្ចេញដោយអាជ្ញាធរទៅឱ្យសហគ្រាស ឬជនណាម្នាក់ដែលនៅក្រៅអាជ្ញាធរទេ ប៉ុន្តែទិន្នន័យស្តីពីតំបន់ដែលមនាធនធានបម្រុង

អាចផ្តល់ទៅឱ្យសហគ្រាសបាន។ ទិន្នន័យដែលផ្ទេរ ដោយបុគ្គលនោះទៅឱ្យសហគ្រាសមិនត្រូវបញ្ចោញទៅឱ្យអាជ្ញាធរដោយសហគ្រាស ឬទៅឱ្យជនណាម្នាក់ដែល នៅក្រៅអាជ្ញាធរឡើយ។

*មាត្រា ១៥*

*កម្មវិធីបណ្តុះបណ្តាល*

អ្នកចុះកិច្ចសន្យាត្រូវរៀបចំកម្មវិធីអនុវត្តសម្រាប់បណ្តុះបណ្តាលបុគ្គលិករបស់អាជ្ញាធរ និងរដ្ឋអភិវឌ្ឍន៍ ដែល រាប់បញ្ចូលការចូលរួមរបស់បុគ្គលិកធ្វើសកម្មភាពនៅតំបន់ដែលចែងក្នុងកិច្ចសន្យា អនុលោមតាមមាត្រា ១៤៤ កថាខណ្ឌទី ២។

*មាត្រា ១៦*

*សិទ្ធិស្វែងរុករក និងធ្វើអាជីវកម្មផ្តាច់មុខ*

អនុលោមតាមភាគទី ៤ និងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់ខ្លួន អាជ្ញាធរត្រូវផ្តល់សិទ្ធិផ្តាច់មុខដល់ ប្រតិបត្តិករដើម្បីស្វែងរុករក និងធ្វើអាជីវកម្មនៅតំបន់ក្រោមផែនការការងារលើប្រភេទធនធានជាក់លាក់ ហើយ ត្រូវធានាថា គ្មានអង្គភាពដទៃទៀតប្រតិបត្តិការនៅតំបន់ដដែលសម្រាប់ធនធានប្រភេទផ្សេងទៀត ក្នុងរបៀប ដែលអាចជ្រៀតជ្រែកដល់ប្រតិបត្តិការរបស់ប្រតិបត្តិករឡើយ។ ប្រតិបត្តិការត្រូវមានសុវត្ថិភាពសិទ្ធិ អនុលោម តាមកថាខណ្ឌទី ៦នៃមាត្រា ១៥៣។

*មាត្រា ១៧*

*វិធានច្បាប់ បទបញ្ញាត្តិ និងនីតិវិធីរបស់អាជ្ញាធរ*

១. អាជ្ញាធរត្រូវអនុម័ត និងអនុវត្តជាទូទៅនូវវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធី អនុលោមតាមកថាខណ្ឌ ២(ច)(ii) មាត្រា ១៦០ និង កថាខណ្ឌ (ណ)(ii) នៃមាត្រា ១៦២ សម្រាប់ការអនុវត្តមុខងាររបស់ខ្លួន ដែលមានចែង ក្នុងផ្នែកទី ១១ ស្តីពីបញ្ហាដូចខាងក្រោម:

(ក) នីតិវិធីរដ្ឋបាលទាក់ទងនឹងការសិក្សា ការរុករក និងការធ្វើអាជីវកម្មនៅ តំបន់។

(ខ) ប្រតិបត្តិការ ៖

(i) ផ្ទៃក្រឡាតំបន់

(ii) រយៈពេលប្រតិបត្តិការ

(iii) លក្ខខណ្ឌលទ្ធផលការងារ រួមមានការធានា អនុលោមតាម កថាខណ្ឌទី ៦(គ) មាត្រា ៤ នៃឧបសម្ព័ន្ធនេះ។

(iv) ប្រភេទធនធាន

(v) ការបោះបង់តំបន់

(vi) របាយការណ៍វឌ្ឍនភាព

(vii) ការផ្តល់ទិន្នន័យ

(viii) ការត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការ

(ix) ការបង្ការការជ្រៀតជ្រែកលើសកម្មភាពដទៃទៀតនៅបរិស្ថានសមុទ្រ។

(x) ការផ្ទេរសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកចុះកិច្ចសន្យា។

(xi) នីតិវិធីសម្រាប់ផ្ទេរបច្ចេកវិទ្យាដល់រដ្ឋអភិវឌ្ឍ អនុលោមតាមមាត្រា ១៥ ៤៤ និងនីតិវិធីសម្រាប់ការចូលរួមដោយផ្ទាល់ ។

(xii) និយាម និងទម្លាប់អនុវត្តនៃការជីករុករកែរ៉ែ ដែលរួមមានបទដ្ឋាន និងទម្លាប់អនុវត្តដែលទាក់ទងនឹងសុវត្ថិភាពប្រតិបត្តិការ ការអភិរក្សធនធាន និងការការពារបរិស្ថានសមុទ្រ

(xiii) និយមន័យនៃផលិតកម្មអាជីវកម្ម។

( xiv) បទដ្ឋានកំណត់ពីលក្ខណៈសម្បត្តិរបស់បេក្ខជន។

(គ) បញ្ហាហិរញ្ញវត្ថុ ៖

(i) ការបង្កើតវិធានច្បាប់គណនេយ្យ និងចំណាយដែលមានលក្ខណៈទូទៅ និងមិនរើសអើង ព្រមទាំងវិធីជ្រើសរើសសវនករ ។

(ii) ការបែងចែកចំណូលប្រតិបត្តិការ ។

(iii) ការលើកទឹកចិត្ត ដែលលើកឡើងក្នុងមាត្រា ១៣ នៃឧបសម្ព័ន្ធនេះ

(ឃ) ការអនុវត្តសេចក្តីសម្រេចដែលបានធ្វើឡើងអនុលោមតាម កថាខណ្ឌទី ១០ នៃមាត្រា ១៥១ និងកថាខណ្ឌទី ២(ឃ)នៃមាត្រា ១៦៤។

២. វិធានច្បាប់ បតបញ្ញត្តិ និងនីតិវិធីលើបញ្ហាខាងក្រោម ត្រូវឆ្លុះបញ្ចាំងឱ្យបានពេញលេញនូវលក្ខណៈវិនិច្ឆ័យពិតច្បាស់ ដែលចែងដូចតទៅ ៖

(ក) ផ្ទៃក្រឡាតំបន់ ៖

អាជ្ញាធរត្រូវកំណត់ផ្ទៃក្រឡាតំបន់សមស្របសម្រាប់ការរុករក ដែលអាចមានទំហំធំពីរដងស្មើនឹង តំបន់សម្រាប់ធ្វើអាជីវកម្ម ក្នុងគោលបំណងដើម្បីឯនុញ្ញាតប្រតិបត្តិការរុករក ឱ្យបានល្អិតល្អន់។ ផ្ទៃក្រឡាតំបន់នឹងត្រូវគណនាផ្អែកតាមលក្ខខណ្ឌនៃមាត្រា ៨ ក្នុងឧបសម្ព័ន្ធនេះ ស្តីពីការអភិរក្សតំបន់ ក៏ដូចជាលក្ខខណ្ឌផលិតកម្មស្របតាមមាត្រា ១៥១ អនុុលោមតាមលក្ខខណ្ឌកិច្ចសន្យា ដោយពិចារណាលើបច្ចេក វិទ្យាទំនើបដែលមានសម្រាប់ការជីករ៉ែនៅបាតសមុទ្រ និងលក្ខណៈរូបវន្តពាក់ព័ន្ធនៃតំបន់។ តំបន់មិន ត្រូវមានទំហំតូចពេក ឬធំពេកទេ ដែលចាំបាច់ដើម្បីសម្រេចនូវគោលបំណងនេះ ។

(ខ) រយៈពេលប្រតិបត្តិការ ៖

(i) ការសិក្សាត្រូវមានរយៈពេលមិនកំណត់។

(ii) ការរុករក គួរមានរយៈពេលគ្រប់គ្រាន់ដើម្បីធ្វើការវាស់វែងតំបន់ឱ្យបានល្អិតល្អន់ ធ្វើគំនូសប្លង់ និងបំពាក់គ្រឿងបរិក្ខារជីករ៉ែក្នុងតំបន់ ក៏ដូចជាធ្វើគំនូសប្លង់ និង

សាងរោងចក្រកែច្នៃខ្នាតតូច និងមធ្យមក្នុងគោលបំណងដំណើរការគម្រោងសាកល្បងក្នុងការជីករុករករ៉ែ និងប្រព័ន្ធកែឆ្នៃ។

(iii) រយៈពេលធ្វើអាជីវកម្មគួរទាក់ទងនឹងអាយុកាលសេដ្ឋកិច្ចនៃគម្រោងជីករុករករ៉ែ ដោយ ពិចារណាលើកត្តាផ្សេងៗ ដូចជា ការតំហយចុះធនធានរ៉ែ អាយុកាលប្រើប្រាស់នៃគ្រឿងបរិក្ខារជីករុករករ៉ែ និងរោងចក្រកែច្នៃ និងលទភ្ធាពផ្អែកសេដ្ឋកិច្ច។ ការធ្វើអាជីវកម្ម គួរមានរយៈពេលគ្រប់គ្រាន់ដើម្បីទាញយកសារធាតុរ៉ែជាលក្ខណៈពាណិជ្ជកម្មពីតំ

បន់ ហើយគួររាប់បញ្ចូលរយៈពេលសមស្របសម្រាប់ការសាងសង់ប្រព័ន្ធជីករ៉ែ និងកែច្នៃ ខ្នាតពាណិជ្ជកម្ម ដែលក្នុងអំឡុងរយៈពេលនេះ មិនគួរតម្រូវឱ្យមានផលិតកម្មអាជីវកម្ម ឡើយ។ ប៉ុន្តែ រយៈពេលសរុបនៃការធ្វើអាជីវកម្មគួរខ្លីល្មម ដើម្បី ផ្តល់ឱកាសដល់អាជ្ញាធរកែប្រែប្រការ និងលក្ខខណ្ឌនៃផែនការការងារ នៅពេលដែល អាជ្ញាធរពិចារណាលើការបន្តរយៈពេល ដោយអនុលោមតាមវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធី ដែលអាជ្ញាធរបានអនុម័ត ក្រោយការអនុម័តលើផែនការការងារ។

(គ) លក្ខខណ្ឌលទ្ធផលការងារៈ

ក្នុងអំឡុងដំណាក់កាលស្វែងរុករក អាជ្ញាធរត្រូវតម្រូវឱ្យប្រតិបត្តិករធ្វើការចំណាយតាមកំណតពេល ដែលទាក់ទងសមស្របនឹងផ្ទៃក្រឡាតំបន់ក្រោមផែនការការងារ និងការចំណាយជាយថាហេតុផ្សេងៗពីប្រតិបត្តិករពិតប្រាកដែដលមានបំណងដាក់ឱ្យដំណើរការផលិតកម្មអាជីវកម្មនៅតំបន់ ក្នុងរយៈពេលដែលកំណត់ដោយអាជ្ញាធរ។ ការចំណាយដែលតម្រូវនោះមិនគួរកំណត់ឡើងនៅកម្រិតដែលនឹងបំបាក់ទឹកចិត្តប្រតិបត្តិករដែលមានបច្ចេកវិទ្យាចំណាយតិចជាងបច្ចេកវិទ្យាដែលប្រើប្រាស់ទូទៅនោះទេ។ អាជ្ញាធរត្រូវកំណត់រយៈពេលអតិបរមាដើម្បីសម្រេចបាននូវផលិតកម្មអាជីវកម្ម បន្ទាប់ពីដំណាក់កាលស្វែងរុករកបានបញ្ចប់ ហើយដំណាក់កាលធ្វើអាជីវកម្មបានចាប់ផ្តើម។ ដើម្បីកំណត់រយៈពេលនេះ អាជ្ញាធរគួរពិចារណាថា ការសាងសង់ប្រព័ន្ធជីករុករ៉ែ និងកែច្នៃទ្រង់ទ្រាយធំមិនអាចចាប់ផ្តើមបានទេ រហូតទាល់ តែបញ្ចប់ដំណាក់កាលស្វែងរុករក និងចាប់ផ្តើមដំណាក់កាលធ្វើអាជីវកម្ម។ ដូច្នោះ រយៈពេលសម្រាប់ដាក់ដំណើរការផលិកម្មអាជីវកម្មនៅតំបន់ គួរពិចារណាលើពេលវេលាចាំបាច់ចំពោះការសាងសង់ នេះបន្ទាប់ពីបញ្ចប់ដំណាក់កាលស្វែងរុករក

ហើយគួរទុករយៈពេលសមស្របចំពោះការពន្យារពេលកម្មវិធី សាងសង់ ដែលមិនអាចជៀសវាងបាន។ នៅពេលសម្រេចបាននូវផលិតកម្មអាជីវកម្ម ក្នុងដែនកំណត់សមស្រប និងដោយពិចារណាកត្តាពាក់ព័ន្ធទាំងអស់ អាជ្ញាធរត្រូវតម្រូវឱ្យប្រតិបត្តិករ រក្សាផលិតកម្មអាជីវកម្ម សម្រាប់រយៈពេលនៃផែនការការងារទាំងមូល។

(ឃ) ប្រភេទធនធាន ៖

ក្នុងការកំណត់ប្រភេទធនធានដែលត្រូវបានអនុមតក្នុងផែនការការងារ អាជ្ញាធរត្រូវសង្កត់ធ្ងន់ លើលក្ខណៈដូចតទៅៈ

(i) ធនធានខ្លះតម្រូវឱ្យប្រើប្រាស់វិធីសាស្ត្រជីករុករ៉ែស្រដៀងគ្នា។ និង

(ii) ធនធានមួយចំនួនអាចអភិវឌ្ឍ ក្នុងពេលដំណាលគ្នា ដោយគ្មានការជ្រៀតជ្រែកកម្រិត រវាងប្រតិបត្តិករដែលអភិវឌ្ឍធនធានផ្សេងៗគ្នា នៅតំបន់តែមួយនោះឡើយ។

គ្មានប្រការណាមួយក្នុងកថាខណ្ឌនេះ ត្រូវរារាំងអាជ្ញាធរមិនឱ្យផ្តល់ការអនុម័តលើផែនការការងារ ទាក់ទងនឹងប្រភេទធនធានច្រើនជាមួយ នៅតំបន់តែមួយ ទៅឱ្យបេក្ខជនតែមួយនោះឡើយ។

(ង) ការលះបង់តំបន់ ៖

ប្រតិបត្តិករអាចបោះបង់សិទ្ធិទាំងស្រុង ឬមួយផ្នែកនៅតំបន់ក្រោមផែនការការងារ នៅពេលណាក៏បាន ដោយគ្មានការពិន័យអ្វីឡើយ។

(ច) ការការពារបរិស្ថានសមុទ្រ ៖

វិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីត្រូវរៀបចំឡើង ដើម្បីធានាឱ្យមានការការពារបរិស្ថានសមុទ្រប្រកបដោយប្រសិទ្ធភាពពីផលប៉ះពាល់មិនល្អ ដែលកើតចេញដោយផ្ទាល់ពីសកម្មភាពនៅតំបន់ ឬពីការកែច្នៃរ៉ែលើនាវា នៅផ្ទាល់ពីលើការដ្ឋានជីករ៉ែនោះ ដោយពិចារណាកម្រិតដែលផលប៉ះពាល់មិនល្អ នោះអាចកើតចេញដោយផ្ទាល់ពីការខួង ការបូម និងការជីក និងពីការបោះចោល ការចាក់ចោល និងការបញ្ចេញ សារធាតុ សំណល់ ឬសារធាតុរាវដទៃទៀត។

(ឆ) ផលិតកម្មអាជីវកម្ម ផលិតកម្មជាលក្ខណៈពាណិជ្ជកម្មត្រូវបានចាត់ទុកថាបានចាប់ ផ្តើម ប្រសិនបើប្រតិបត្តិករដំណើរ ការទាញយកជាទ្រង់ទ្រាយធំ ដែលផលិតបានបរិមាណរ៉ែគ្រប់គ្រាន់ ដែល ចង្អុលបង្ហាញយ៉ាងច្បាស់ថា គោលបំណងចម្បងគឺការផលិតទ្រង់ទ្រាយធំ មិនមែនជាការផលិតដើម្បីប្រមូល វិភាគព័ត៌មាន ឬសាកល្បងគ្រឿងបរិក្ខារ ឬរោងចក្រឡើយ។

*មាត្រា ១៨*

*ទោសទណ្ឌ*

១. សិទ្ធិរបស់អ្នកចុះកិច្ចសន្យាជាប់កិច្ចសន្យាអាចត្រូវបានព្យួរទុក ឬដកហូត តែក្នុងករណីខាងក្រោមប៉ុណ្ណោះៈ

(ក) ករណីដែលអ្នកចុះកិច្ចសន្យាធ្វើសកម្មភាពដែលរំលោភបំពានធ្ងន់ធ្ងរ មិនរាងចាល និងដោយ ចេតនានូវលក្ខខណ្ឌមូលដ្ឋាននៃកិច្ចសន្យា ផ្នែកទី ១១ និងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធី របស់អាជ្ញាធរ បើទោះបីជាមានការព្រមានពីអាជ្ញាធរក៏ដោយ។ ឬ

(ខ) ករណីដែលអ្នកចុះកិច្ចសន្យាខកខានមិនគោរពតាមសេចក្តីសម្រេចស្ថាពរ និងចងកាតព្វកិច្ចចេញដោយស្ថាប័នដោះស្រាយវិវាទ ដែលអ្នកចុះកិច្ចសន្យាត្រូវអនុវត្ត និងគោរពតាម។

២. ក្នុងករណីមានការរំលោភកិច្ចសន្យាដែលមិនបានចែងក្នុងកថាខណ្ឌទី ១(ក) ឬជាការជំនួសការព្យួរ ឬការ ដកហូតសិទ្ធិដូចមានចែងក្នុងកថាខណ្ឌទី ១(ក) អាជ្ញាធរអាចដាក់ពិន័យជាប្រាក់លើអ្នកចុះកិច្ចសន្យា ដែលមានចំនួនស្មើនឹង កម្រិតធ្ងន់ធ្ងរនៃការរំលោភបំពាននោះ។

៣. លើកលែងតែមានដីកាបន្ទាន់តាម កថាខណ្ឌទី ២ (ទ)នៃមាត្រា ១៦២ អាជ្ញាធរមិនអាចអនុវត្តសេចក្តី សម្រេចទាក់ទងនឹងប្រាក់ពិន័យ ការព្យួរ ឬការដកហូតសិទ្ធិបានទេ រហូតទាល់តែអ្នកចុះកិច្ចសន្យាទទួលបានឱកាសសមស្រប ក្នុងការប្រើគ្រប់មធ្យោបាយតាមផ្លូវតុលាការដែលខ្លួនមាន អនុលោមតាមផ្នែកទី ១១ និងផ្នែកទី ៥។

*មាត្រា ១៩*

*ការធ្វើវិសោធនកម្មលើកិច្ចសន្យា*

១. នៅក្នុងករណី ឬកាលៈទេសៈណាមួយដែលភាគីនីមួយៗយល់ឃើញថា នឹងធ្វើឱ្យកិច្ចសន្យាមានវិសមភាព ឬមិនអាចសម្រេចគោលបំណងដូចមានចែងក្នុងកិច្ចសន្យា ឬក្នុងផ្នែកទី ១១ បណ្តាភាគីត្រូវ ធ្វើការចរចាដើម្បីកែប្រែកិច្ចសន្យា ផ្អែកតាមករណីជាក់ស្តែងនីមួយៗ។

២. កិច្ចសន្យាដែលធ្វើឡើងស្របតាម កថាខណ្ឌ ៣នៃមាត្រា ១៥៣ មិនអាចធ្វើការកែប្រែបានឡើយ លុំ្តកណាមានការឯកភាពពីបណ្តាភាគី។

*មាត្រា ២០*

*ការផ្ទេរសិទ្ធិ និងកាតព្វកិច្ច*

សិទ្ធិ និងកាតព្វកិច្ចក្នុងកិច្ចសន្យាអាចផ្ទេរបាន តែក្នុងករណីមានការឯកភាពពីអាជ្ញាធរប៉ុណ្ណោះ និង អនុលោមតាមវិធានច្បាប់ បទបញ្ញត្តិ និងបែបបទរបស់អាជ្ញាធរ។ អាជ្ញាធរមិនត្រូវបដិសេធផ្តល់ការឯកភាពលើការផ្ទេរដោយគ្មានមូលហេតុច្បាស់លាស់នោះឡើយ ប្រសិនបើអ្នកទទួលការផ្ទេរមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយទទួលយករាល់កាតព្វកិច្ចទាំងអស់របស់ម្ចាស់ផ្ទេរ ហើយប្រសិនបើការផ្ទេរនោះមិនផ្តល់ផែនការការងារឡើយ ដែលការត្រូវបានហាមឃាត់មិនឱ្យអនុម័តទេ តាម កថាខណ្ឌ ៣(គ) មាត្រា ៦ នៃឧបសម្ព័ននេះ។

*មាត្រា ២១*

*ច្បាប់អនុវត្តន៍*

១.	កិច្ចសន្យានេះស្ថិតក្រោមការគ្រប់គ្រងដោយលក្ខខណ្ឌនៃកិច្ចសន្យា វិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ ផ្នែកទី ១១ និងវិធានច្បាប់ដទៃទៀតនៃច្បាប់អន្តរជាតិ ដែលមានខ្លឹមសារមិនផ្ទុយនឹងខ្លឹមសារនៃអនុសញ្ញានេះ។

២.	សេចក្តីសម្រេចស្ថាពររបស់តុលាការ ឬសាលាជំនុំជំរះដែលមានយុត្តាធិការក្រោមអនុសញ្ញា នេះ ទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ចរបស់អាជ្ញាធរ និងអ្នកចុះកិច្ចសន្យា ត្រូវអាចយកទៅអនុវត្តបាននៅក្នុងទឹកដីរបស់ រដ្ឋភាគីនីមួយៗ។

៣.	គ្មានរដ្ឋភាគីណាមួយអាចដាក់លក្ខខណ្ឌអនុវត្តលើអ្នកចុះកិច្ចសន្យា ដែលផ្ទុយនឹងផ្នែកទី ១១ឡើយ។ ទោះជាយ៉ាងនេះក្តី ការអនុវតច្បាប់ និងបទបញ្ញត្តិស្តីពីបរិស្ថាន ឬច្បាប់ និងបទបញ្ញត្តិដទៃទៀតដោយរដ្ឋភាគីចំពោះអ្នកចុះកិច្ចសន្យាដែល ខ្លួនឧបត្ថម្ភ ឬចំពោះនាវាដែលដោតទង់ជាតិរបស់ខ្លួនយ៉ាងតឹងរ៉ឹងជាងអ្វីដែលចែងក្នុងវិធានច្បាប់ បទបញ្ញត្តិ និងបែបបទរបស់អាជ្ញាធរដែលអនុម័តអនុលោមតាមមាត្រា ១៧ កថាខណ្ឌទី ២ (ច) នៃឧបសម្ព័ន្ធនេះមិនត្រូវចាត់ទុកថា ផ្ទុយនឹងផ្នែក ១១ ឡើយ។

*មាត្រា ២២*

*ការទទួលខុសត្រូវ*

អ្នកចុះកិច្ចសន្យាត្រូវទទួលខុសត្រូវ ឬមានភារៈទទួលខុសត្រូវចំពោះការខូចខាតណាមួយដែលកើតចេញពី អំពើខុសឆ្គងក្នុងប្រតិបត្តិការរបស់ខ្លួន ដោយពិចារណាលើសកម្មភាពរួមចំណែកឬការធ្វេសប្រហេសដោយអាជ្ញា ធរផងដែរ។ ដូចគ្នាផងដែរ អាជ្ញាធរត្រូវទទួលខុសត្រូវ ឬមានភារៈទទួលខុសត្រូវចំពោះការខូចខាតណាមួយ ដែលកើតចេញពីការអនុវត្តអំណាច និងមុខងាររបស់ខ្លួន ដែលរួមមានការរំលោភ កថាខណ្ឌទី២ នៃមាត្រា ១៦៨ អំពើខុសឆ្គងក្នុងប្រតិបត្តិករបស់ខ្លួន ដោយពិចារណាលើសកម្មភាពរួមចំណែកឬការធ្វេសប្រហេសដោយអ្នកម៉ៅ ការផងដែរ។ ភារៈទទួលខុសត្រូវក្នុងរាល់ករណីទាំងអស់ត្រូវជាការទទួលខុសត្រូវចំពោះចំនួនខូចខាតជាក់ស្តែង។

ឧបសម្ព័ន្ធ៤៖លក្ខន្តិកៈរបស់សហគ្រាស

*មាត្រា ១*

*គោលបំណង*

១.

សហគ្រាសគឺជាស្ថាប័នរបស់អាជ្ញាធរដែលត្រូវអនុវត្តសកម្មភាពដោយផ្ទាល់នៅតំបន់អនុលោមតាមកថាខណ្ឌទី ២(ក) នៃមាត្រា ១៥៣ ព្រមទាំងដឹកជញ្ជូន កែច្នៃ និងដាក់លក់រ៉ែនៅទីផ្សារដែលទាញយកបានពីតំបន់។

២. ក្នុងការអនុវត្តគោលបំណង និងក្នុងការអនុវត្តមុខងាររបស់ខ្លួន សហគ្រាសត្រូវធ្វើសកម្មភាពអនុលោម តាមអនុសញ្ញានេះ និងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

៣. ក្នុងការអភិវឌ្ឍធនធានពីតំបន់ អនុលោមតាមមាត្រា ១ សហគ្រាសត្រូវប្រតិបត្តិការអនុលោមតាមគោលការណ៍ពាណិជ្ជកម្មត្រឹមត្រូវ ដោយស្ថិតក្រោមលក្ខខណ្ឌនៃអនុសញ្ញានេះ។

*មាត្រា ២*

*ទំនាក់ទំនងជាមួយអាជ្ញាធរ*

១. អនុលោមតាមមាត្រា ១៧០ សហគ្រាសត្រូវធ្វើសកម្មភាពអនុលោមតាមគោលនយោបាយទូទៅរបស់ សភា និងសេចក្តីណែនាំរបស់ក្រុមប្រឹក្សា។

២. អនុលោមតាមកថាខណ្ឌទី ១ សហគ្រាសត្រូវមានស្វ័យភាពក្នុងប្រតិបត្តិការរបស់ខ្លួន។

៣. គ្មានប្រការណាមួយក្នុងអនុសញ្ញានេះត្រូវកំណត់ឱ្យសហគ្រាសទទួលខុសត្រូវចំពោះសកម្មភាព ឬកាតព្វកិច្ចរបស់អាជ្ញាធរ ឬកំណត់ឱ្យអាជ្ញាធរទទួលខុសត្រូវចំពោះសកម្មភាព ឬកាតព្វកិច្ចរបស់សហគ្រាសឡើយ។

*មាត្រា ៣*

*ការកម្រិតលើការទទួលខុសត្រូវ*

ដោយមិនគិតដល់ កថាខណ្ឌទី ៣ មាត្រា ១១ នៃឧបសម្ព័ន្ធនេះ គ្មានសមាជិកអាជ្ញាធរណាមួយត្រូវទទួល ខុសត្រូវចំពោះសកម្មភាព ឬកាតព្វកិច្ចរបស់សហគ្រាស ដោយសារមូលហេតុខ្លួនជាសមាជិកនោះឡើយ។

*មាត្រា ៤*

*រចនាសម្ព័ន្ធ*

សហគ្រាសត្រូវមានក្រុមប្រឹក្សាភិបាលមួយរូប អគ្គនាយកមួយរូប និងបុគ្គលិកមួយចំនួនដែលចាំបាច់ ដើម្បីអនុវត្ត មុខងាររបស់ខ្លួន។

*មាត្រា ៥*

*ក្រុមប្រឹក្សាភិបាល*

១. ក្រុមប្រឹក្សាអភិបាលត្រូវមានសមាជិក ១៥ នាក់ ដែលត្រូវបានបោះឆ្នោតជ្រើររើសដោយសភា អនុលោមតាម កថាខណ្ឌទី ២(គ)នៃមាត្រា ១៦០។ ក្នុងការបោះឆ្នោតសមាជិកក្រុមប្រឹក្សាភិបាល ត្រូវយកចិត្តទុកដាក់លើគោលការណ៍បែងចែកតាមភូមិសាស្ត្រឱ្យបានត្រឹមត្រូវ។
ក្នុងការដាក់ឈ្មោះបេក្ខជនឈរឈ្មោះជាសមាជិកក្រុមប្រឹក្សា អភិបាល សមាជិកនៃអាជ្ញាធរត្រូវចងចាំពីសេចក្តីត្រូវការត្រូវជ្រើសតាំងបេក្ខជនដែលមានកម្រិតសមត្ថភាពខ្ពស់បំផុត ដោយមានលក្ខណៈសម្បត្តិក្នុងវិស័យពាក់ព័ន្ធ ដើម្បីធានានូវលទ្ធភាព និងជោគជ័យរបស់សហគ្រាស។

២.	សមាជិកក្រុមប្រឹក្សាភិបាលត្រូវបោះឆ្នោតសម្រាប់អាណត្តិ ៤ ឆ្នាំ ហើយអាចត្រូវបោះឆ្នោតជាថ្មីបាន។ ហើយត្រូវយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវលើគោលការណ៍ប្តូរវេនសមាជិកភាព។

៣.	សមាជិកក្រុមប្រឹក្សាភិបាលត្រូវបន្តកាន់តំណែងរហូតទាល់តែអ្នកស្នងបន្តត្រូវបានបោះឆ្នោត។ ប្រសិនបើតំណែងសមាជិកក្រុមប្រឹក្សាណាម្នាក់នៅទំនេរ សភាត្រូវជ្រើសរើសសមាជិកថ្មីឱ្យកាន់តំណែងសម្រាប់ អាណត្តិដែលនៅសល់ អនុលោមតាមមាត្រា ១៦០ កថាខណ្ឌទី ២(គ)។

៤.	សមាជិកក្រុមប្រឹក្សាភិបាលត្រូវធ្វើសកម្មភាព ក្នុងឋានៈផ្ទាល់របស់ខ្លួន។ ក្នុងការបំពេញករណីកិច្ច សមាជិកមិនត្រូវស្វែងរក ឬទទួលសេចក្តីណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយឡើយ។ សមាជិកនីមួយៗនៃអាជ្ញា ធរត្រូវគោរពឯករាជភាពរបស់សមាជិកក្រុមប្រឹក្សាភិបាល ហើយមិនត្រូវខិតខំជះឥទ្ធិពលលើសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ក្នុងការបំពេញករណីកិច្ចរបស់ស មាជិកក្រុមប្រឹក្សាភិបាលឡើយ។

៥.	សមាជិកក្រុមប្រឹក្សាភិបាលនីមួយៗត្រូវទទួលប្រាក់បៀវត្ស ដែលត្រូវបង់ចេញពីមូលនិធិរបស់សហ គ្រាស។ ចំនួនប្រាក់បៀវត្សត្រូវកំណត់ដោយសភា តាមអនុសាសន៍របស់ក្រុមប្រឹក្សា។

៦.	ក្រុមប្រឹក្សាភិបាលត្រូវដំណើរការជាធម្មតា នៅទីស្នាក់ការរបស់សហគ្រាស និងត្រូវជួបប្រជុំឱ្យបានញឹក ញាប់ដូចដែលកិច្ចការរបស់សហគ្រាសអាចតម្រូវឱ្យជួបប្រជុំ។

៧.	សមាជិក ២ ភាគ ៣ នៃក្រុមប្រឹក្សាភិបាលត្រូវបង្កើតជាកូរ៉ុម។

៨.	សមាជិកក្រុមប្រឹក្សាភិបាលនីមួយៗត្រូវមានសម្លេងឆ្នោត ១។ រាល់កិច្ចការទាំងអស់ដែលដាក់នៅចំពោះមុខក្រុមប្រឹក្សាភិបាលត្រូវសម្រេចដោយសម្លេងភាគច្រើនរបស់ សមាជិក។ ប្រសិនបើសមាជិកណាម្នាក់ មានទំនាស់ផលប្រយោជន៍លើបញ្ហាណាមួយដែលដាក់នៅចំពោះមុខក្រុមប្រឹក្សា ភិបាលមិនត្រូវបោះឆ្នោតលើបញ្ហានោះឡើយ។

៩.	សមាជិកណាម្នាក់នៃអាជ្ញាធរអាចស្នើសុំព័ត៌មានពីក្រុមប្រឹក្សាភិបាល ទាក់ទងនឹងប្រតិបត្តិការរបស់ ក្រុមប្រឹក្សាភិបាល ដែលប៉ះពាល់ដល់សមាជិកនោះ។ ក្រុមប្រឹក្សាភិបាលត្រូវខិតខំផ្តល់ព័ត៌មាននោះ។

*មាត្រា ៦*

*អំណាច និងមុខងាររបស់ក្រុមប្រឹក្សាភិបាល*

ក្រុមប្រឹក្សាភិបាលត្រូវដឹកនាំប្រតិបត្តិការរបស់សហគ្រាស។ ស្ថិតក្រោមអនុសញ្ញានេះ ក្រុមប្រឹក្សាអភិបាលត្រូវអនុវត្តអំណាចដែលចាំបាច់ដើម្បីបំពេញគោលបំណងរបស់សហគ្រាស ដែលរួមមានអំណាច ៖

(ក)	បោះឆ្នោតប្រធានពីចំណោមសមាជិក ។

(ខ)	អនុម័តវិធានច្បាប់នីតិវិធី ។

(គ)	ព្រាង និងដាក់ផែនការការងារជាលាយលក្ខណ៍អក្សរផ្លូវការជូនក្រុមប្រឹក្សា អនុលោមតាមកថាខណ្ឌទី ៣ នៃមាត្រា ១៥៣ និង កថាខណ្ឌទី ២(ញ)នៃមាត្រា ១៦២។

(ឃ)	រៀបចំផែនការការងារ និងកម្មវិធីដើម្បីអនុវត្តសកម្មភាពដែលចែងក្នុងមាត្រា ១៧០

(ង)	រៀបចំ និងដាក់ពាក្យសុំការអនុញ្ញាតផលិតជូនក្រុមប្រឹក្សា អនុលោមតាមកថាខណ្ឌទី ២ ទៅ ៧ នៃមាត្រា ១៥១។

(ច)

អនុញ្ញាតការចរចារទាក់ទងនឹងការទទួលបច្ចេកវិទ្យាដែលរាប់មានបច្ចេកវិទ្យាដូចចែងក្នុងកថាខណ្ឌទី ៣(ក) (គ) និង (ឃ) មាត្រា ៥ នៃឧបសម្ព័ន្ធ ៣និងអនុម័តលើលទ្ធផល នៃការចរចាទាំងនោះ។

(ឆ)	បង្កើតប្រការ និងលក្ខខណ្ឌ និងអនុញ្ញាតការចរចា ទាក់ទងនឹងការវិនិយោគរួមទុន និងកិច្ចសហប្រតិបត្តិអាជីវកម្មក្រោមរូបភាពដទៃទៀតដែលលើកឡើងក្នុងឧបសម្ព័ន្ធ ៣ មាត្រា ៩ និង ១១ និងអនុម័តលើលទ្ធផលនៃកិច្ចចរចាទាំងនោះ។

(ជ)

ផ្តល់អនុសាសន៍ដល់សភាថាតើចំណែកចំណូលសុទ្ធរបស់សហគ្រាសគួររក្សាទុកជាមូលនិធិបម្រុង អនុលោមតាម កថាខណ្ឌទី ២ (ច)នៃមាត្រា ១៦០ និងមាត្រា ២០ នៃឧបសម្ព័ន្ធនេះ។

(ឈ) ឯកភាពលើថវិកាប្រចាំឆ្នាំរបស់សហគ្រាស។

(ញ) អនុញ្ញាតលើការងារលទ្ធកម្មទំនិញ និងសេវាកម្ម អនុលោមតាមកថាខណ្ឌមាត្រា ១២ នៃឧបសម្ព័ន្ធនេះ។

(ដ) ដាក់របាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សា អនុលោមតាមមាត្រា ៩ នៃឧបសម្ព័ន្ធនេះ។

(ឋ) ដាក់សេចក្តីព្រាងវិធានច្បាប់ទាក់ទងនឹងការរៀបចំ ការគ្រប់គ្រង ការតែងតាំង និងការបញ្ឈប់បុគ្គ-លិករបស់សហគ្រាសជូនក្រុមប្រឹក្សា ដើម្បីទទួលបានការអនុម័តពីសភា ហើយអនុម័តបទ បញ្ញត្តិ ដើម្បីផ្តល់សុពលភាពលើវិធានច្បាប់នោះ។

(ឌ) ខ្ចីប្រាក់ និងដាក់វត្ថុបញ្ចាំ ឬប្រាតិភោគដទៃទៀត ដូចដែលខ្លួនអាចកំណត់អនុលោមតាមមាត្រា ១១ កថាខណ្ឌទី ២ នៃឧបសម្ព័ន្ធនេះ។

(ឍ) ចូលរួមក្នុងនីតិវិធីច្បាប់ ចុះកិច្ចព្រមព្រៀង និងប្រតិបត្តិការ និងចាត់វិធានច្បាប់ការដទៃទៀត អនុលោមតាមមាត្រា ១៣ នៃឧបសម្ព័ន្ធនេះ។

(ណ) ប្រគល់អំណាចមិនដាច់ខាតទៅឱ្យអគ្គនាយក និងគណៈកម្មាធិការរបស់ខ្លួន ដោយស្ថិតក្រោម លក្ខខណ្ឌទទួលបានការឯកភាពពីក្រុមប្រឹក្សា។

*មាត្រា ៧*

*អគ្គនាយក និងបុគ្គលិករបស់សហគ្រាស*

១. តាមអនុសាសន៍របស់ក្រុមប្រឹក្សា និងការជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល សភាត្រូវបោះឆ្នោតជ្រើសរើសអគ្គនាយកសហគ្រាស ដែលមិនមែនជាសមាជិកនៃក្រុមប្រឹក្សាភិបាល។

អគ្គនាយកត្រូវកាន់តំណែង សម្រាប់អាណត្តិជាកំណត់ ដែលមិនត្រូវលើសពី ៥ ឆ្នាំឡើយ ហើយអាចត្រូវបានបោះឆ្នោតជ្រើសរើសជាថ្មី សម្រាប់អាណត្តិបន្ថែមទៀត។

២. អគ្គនាយកត្រូវជាតំណាងផ្លូវច្បាប់ និងជាប្រធានប្រតិបត្តិរបស់សហគ្រាស ហើយត្រូវទទួលខុសត្រូវ ដោយផ្ទាល់ចំពោះមុខក្រុមប្រឹក្សាភិបាលលើប្រតិបត្តិការរបស់សហគ្រាស។ អគ្គនាយកត្រូវទទួលខុសត្រូវលើ ការរៀបចំ ការគ្រប់គ្រង ការតែងតាំង និងការបញ្ឈប់បុគ្គលិកសហគ្រាស អនុលោមតាមវិធានច្បាប់ និងបទបញ្ញត្តិ ដែលលើកឡើងក្នុងកថាខណ្ឌ (ថ) មាត្រា ៦ នៃឧបសម្ព័ន្ធនេះ។ អគ្គនាយកត្រូវចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាអភិបាល ដោយគ្មានសិទ្ធិបោះឆ្នោត ហើយអាចចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សា និងសភា ដោយគ្មានសិទ្ធិបោះឆ្នោត នៅពេលស្ថាប័នទាំងនេះពិភាក្សាលើបញ្ហាទាក់ទងនឹងសហគ្រាស។

៣. ក្នុងការជ្រើសរើស និងជួលបុគ្គលិក និងក្នុងការកំណត់លក្ខខណ្ឌសេវាកម្ម ត្រូវពិចារណាជាចម្បងលើភាព ចាំបាច់ត្រូវធានាកម្រិតប្រសិទ្ធភាពខ្ពស់ និងសមត្ថភាពបច្ចេកទេស។ ស្ថិតក្រោមលក្ខខណ្ឌនៃការពិចារណា នេះ ត្រូវយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវលើការជ្រើសរើសបុគ្គលិកឱ្យបានស្មើភាពគ្នាផ្អែកតាមភូមិសាស្ត្រ។

៤. ក្នុងការបំពេញករណីកិច្ចរបស់ខ្លួន អគ្គនាយកមិនត្រូវស្វែងរក ឬទទួលសេចក្តីណែនាំពីរដ្ឋាភិបាល ឬប្រភពដទៃទៀតពីខាងក្រៅសហគ្រាសឡើយ។ អគ្គនាយកមិនត្រូវធ្វើសកម្មភាពណាមួយដែលអាចឆ្លុះបញ្ចាំងពីជំហាររបស់ខ្លួន ក្នុងឋានៈជាមន្ត្រីអន្តរជាតិនៃសហគ្រាសឡើយ ដោយអគ្គនាយកទទួលខុសត្រូវចំពោះសហគ្រាសតែមួយគត់។ រដ្ឋភាគីនីមួយៗសន្យាគោរពលក្ខណៈអន្តរជាតិនៃការទទួលខុសត្រូវរបស់អគ្គនាយក និងបុគ្គលិក ហើយមិនត្រូវខិតខំជះឥទ្ធិពលលើអគ្គនាយកក្នុងការបំពេញករណីកិច្ចរបស់អគ្គនាយកឡើយ។

៥. ការទទួលខុសត្រូវដែលចែងក្នុង កថាខណ្ឌទី ២នៃមាត្រា ១៦៨ អនុវត្តស្មើភាពគ្នាចំពោះបុគ្គលិកសហគ្រាស។

*មាត្រា ៨*

*ទីតាំង*

សហគ្រាសត្រូវមានការិយាល័យចម្បងនៅអាសនៈរបស់អាជ្ញាធរ។ សហគ្រាសអាចបង្កើតការិយាល័យ ដទៃទៀតក្នុងរដ្ឋភាគីណាមួយ ដោយមានការយល់ព្រមពីរដ្ឋភាគីនោះ។

*មាត្រា ៩*

*របាយការណ៍ និងរបាយការណ៍ហិរញ្ញវត្ថុ*

១. ក្នុងរយៈពេលមិនលើសពី ៣ ខែបន្ទាប់ពីចប់ឆ្នាំហិរញ្ញវត្ថុនីមួយៗ សហគ្រាសត្រូវដាក់របាយការណ៍ប្រចាំ ឆ្នាំ ក្នុងនោះមានរបាយការណ៍សវនកម្មគណនេយ្យជូនក្រុមប្រឹក្សាពិនិត្យ និងត្រូវបញ្ជូនរបាយការណ៍ខ្លីពីស្ថានភាព ហិរញ្ញវត្ថុ និងរបាយការណ៍ចំណេញ និងខាតបង់ដែលបង្ហាញលទ្ធផលនៃប្រតិបត្តិការរបស់ខ្លួនជូនក្រុមប្រឹក្សា ក្នុង រយៈពេលសមស្រប។

២. សហគ្រាសត្រូវចុះផ្សាយរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ដទៃទៀត ដែលខ្លួនយល់ថាសមស្រប។

៣. គ្រប់របាយការណ៍ និងរបាយការណ៍ហិរញ្ញវត្ថុទាំងអស់ ដែលលើកឡើងក្នុងមាត្រានេះ ត្រូវចែកជូនសមាជិកនៃអាជ្ញាធរ។

*មាត្រា ១០*

*ការបែងចែកផលចំណូលសុទ្ធ*

១. អនុលោមតាមកថាខណ្ឌទី ៣ សហគ្រាសត្រូវបង់កម្រៃសួយសារជូនអាជ្ញាធរ តាមឧបសម្ព័ន្ធ ៣ មាត្រា ១៣ ឬអ្វីផ្សេងទៀតដែលមានតម្លៃសមមូល។

២. តាមអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល សភាត្រូវកំណត់ចំណែកខ្លះនៃចំណូលសុទ្ធរបស់សហគ្រាសត្រូវរក្សាទុកមូលនិធិបម្រុងរបស់សហគ្រាស។ ចំណូលដែលនៅសល់ត្រូវផ្ទេរទៅឱ្យអាជ្ញាធរ។

៣. ក្នុងអំឡុងរយៈពេលដំបូងដែលមិនត្រូវលើសពី ១០ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមផលិតកម្មអាជីវកម្មដោយសហគ្រាស ដែលតម្រូវឱ្យសហគ្រាសត្រូវមានលទ្ធភាពអាចឧបត្ថម្ភខ្លួនឯងបានសភាត្រូវលើកលែងសហគ្រាសមិនឱ្យបង់ប្រាក់ដែលលើកឡើងក្នុងកថាខណ្ឌទី ១ ហើយត្រូវទុករាល់ចំណូលសុទ្ធទាំងអស់របស់សហគ្រាសជាប្រាក់បម្រុងរបស់សហគ្រាស។

*មាត្រា ១១*

*ហិរញ្ញវត្ថុ*

១. មូលនិធិរបស់សហគ្រាសត្រូវរួមមាន ៖

(ក) ចំនួនប្រាក់ដែលទទួលបានពីអាជ្ញាធរ អនុលោមតាមកថាខណ្ឌទី ២ (ខ) នៃមាត្រា ១៧៣។

(ខ) វិភាគទានដោយស្ម័គ្រចិត្តដែលបង់ដោយរដ្ឋភាគី ក្នុងគោលបំណងដើម្បីគាំទ្រសកម្មភាពរបស់សហគ្រាស។

(គ) ចំនួនប្រាក់ដែលសហគ្រាសខ្ចី អនុលោមតាមកថាខណ្ឌទី ២ និង ៣ ។

(ឃ) ចំណូលរបស់សហគ្រាសពីប្រតិបត្តិការ ។

(ង) មូលនិធិដទៃទៀត ដែលសហគ្រាសមាន ដើម្បីផ្តល់លទ្ធភាពដល់សហគ្រាសដើម្បីចាប់ផ្តើម ប្រតិបត្តិការ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងដើម្បីអនុវត្តមុខងាររបស់ខ្លួន។

២. (ក) សហគ្រាសត្រូវមានសិទ្ធិអំណាចខ្ចីប្រាក់ និងដាក់វត្ថុធានា ឬប្រាតិភោគដទៃទៀតដែលខ្លួនអាច កំណត់។ មុនពេលដាក់លក់ជាសាធារណៈនូវកាតព្វកិច្ចរបស់ខ្លួននៅលើផ្សារហិរញ្ញវត្ថុ ឬរូបិយវត្ថុរបស់រដ្ឋភាគី សហគ្រាសត្រូវទទួលបានការឯកភាពពីរដ្ឋភាគីនោះ។ ចំនួនប្រាក់ខ្ចីសរុបត្រូវមាន ការឯកភាពពីក្រុមប្រឹក្សា តាមអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល។

(ខ) រដ្ឋភាគីត្រូវខិតខំប្រឹងប្រែងគ្រប់មធ្យោបាយសមស្របទាំងអស់ ដើម្បីជួយដល់ការដាក់ពាក្យខ្ចី ប្រាក់ដោយសហគ្រាសពីផ្សារមូលធន និងពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ។

៣. (ក) សហគ្រាសត្រូវទទួលបានមូលនិធិដែលចាំបាច់ដើម្បីស្វែងរុករក និងធ្វើអាជីវកម្មរ៉ែនៅការដ្ឋានរ៉ែមួយ ហើយដឹកជញ្ជូន កែច្នៃ លក់រ៉ែដែលទាញយកបានពីការដ្ឋាននោះ និងនីកែល ស្ពាន់ កូបាល និងម៉ង់កាណែសដែលជីកបាន ព្រមទាំងបង់ការចំណាយរដ្ឋបាលដំបូងរបស់ខ្លួន។ ចំនួនមូលនិធិ នោះ និងលក្ខណៈវិនិច្ឆ័យ និងកត្តាកែតម្រូវ ត្រូវដាក់បញ្ចូលដោយគណៈកម្មការត្រៀមរៀបចំទៅក្នុងសេចក្តីព្រាងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

(ខ)

រដ្ឋភាគីទាំងអស់ត្រូវបង់សហគ្រាសចំនួនប្រាក់ស្មើនឹងពាក់កណ្តាលនៃមូលនិធិដែលចែងក្នុងកថា ខណ្ឌ (ខ) តាមរយៈកម្ចីគ្មានការប្រាក់រយៈពេលវែង អនុលោមតាមទំហំនៃការវាយតម្លៃ សម្រាប់ថវិកាជាប្រចាំរបស់អង្គការសហប្រជាជាតិដែលនៅជាធរមាន ពេលធ្វើការវាយតម្លៃ នោះ

ដែលកែតម្រូវពិចារណាលើរដ្ឋដែលមិនមែនជាសមាជិកអង្គការសហប្រជាជាតិ។ បំណុល ដែលបង្កើតឡើងដោយសហគ្រាសក្នុងការរកមូលនិធិពាក់កណ្តាលទៀត ត្រូវធានាដោយរដ្ឋភាគី ទាំងអស់ អនុលោមតាមទំហំដដែលនៃការវាយតម្លៃនោះ។

(គ) ប្រសិនបើចំនួនប្រាក់វិភាគទានរបស់រដ្ឋភាគី មានចំនួនតិចជាងមូលនិធិ ដែលផ្តល់ឱ្យសហគ្រាស តាមកថាខណ្ឌ (ក) សភាត្រូវពិចារណាកម្រិតខ្វះខាត ក្នុងសម័យប្រជុំដំបូងរបស់ខ្លួន ហើយអនុម័តដោយមតិរួមលើវិធានច្បាប់ការដោះស្រាយបញ្ហាខ្វះខាតនេះ ដោយពិចារណាកាតព្វកិច្ចរបស់ រដ្ឋភាគី តាមកថាខណ្ឌ (ក) និង (ខ) និងអនុសាសន៍របស់គណៈកម្មការត្រៀមរៀបចំ។

(ឃ) (i) ក្នុងរយៈពេល ៦០ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន ឬក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ ពីដាក់លិខិតុបករណ៍សច្ចាប័ន ឬលិខិតុបករណ៍ចូលជាភាគីមួយណាក៏ដោយដែលកើតក្រោយគេ រដ្ឋភាគីនីមួយៗត្រូវដាក់កម្កល់លិខិតសន្យាគ្មានការប្រាក់ មិនអាចផ្ទេរបាន និងមិនអាចលុបចោលបាន នៅនឹងសហគ្រាស ដែលមានចំនួនជាកម្ចីគ្មានការប្រាក់នៃ ចំណែករបស់រដ្ឋភាគី អនុលោមតាមកថាខណ្ឌ (ខ)។

(ii) ក្រុមប្រឹក្សាភិបាលត្រូវរៀបចំតារាងបង្ហាញពីទំហំ និងពេលវេលាសម្រាប់ហិរញ្ញប្បទានបង់លើចំណាយរដ្ឋបាលរបស់ខ្លួន និងសកម្មភាពដែលអនុវត្តដោយសហគ្រាស អនុលោមតាមមាត្រាង ១៧០ និង ១២ នៃឧបសម្ព័ន្ធនេះ ក្នុងពេលឆាប់ៗបន្ទាប់ពីអនុសញ្ញាចូល ជាធរមាន និងនៅពេលក្រោយៗមកជាប្រចាំឆ្នាំ ឬក្នុងអំឡុងរយៈពេលសមស្របដទៃទៀត។

(iii) រដ្ឋភាគីត្រូវទទួលបានការជូនដំណឹងពីសហគ្រាស តាមរយៈអាជ្ញាធរ អំពីចំណែកមូល និធិរៀងៗខ្លួន អនុលោមតាមកថាខណ្ឌ (ខ)

ដែលត្រូវការសម្រាប់កាចំណាយ។ សហគ្រាសត្រូវប្តូរលិខិតសន្យាជាសាច់ប្រាក់ដែលអាចត្រូវការដើម្បីបង់ការចំណាយលើកឡើងក្នុងតារាងទាក់ទងនឹងកម្ចីគ្មានការប្រាក់។

(iv) នៅពេលទទួលបានសេចក្តីជូនដំណឹងរួច រដ្ឋភាគីត្រូវផ្តល់លិខិតធានាបំណុលក្នុងចំនួនជាចំណែករបស់ខ្លួនឱ្យសហគ្រាសអនុលោមតាមលិខិតធានាបំណុលក្នុងកថាខណ្ឌ (ខ)។

(ង) (i) ប្រសិនបើសហគ្រាសស្នើសុំ រដ្ឋភាគីអាចផ្តល់លិខិតធានាបំណុលបន្ថែមពីលើមូលនិធិ ដែលផ្តល់តាមទំហំនៃការវាយតម្លៃ ក្នុងកថាខណ្ឌ (ខ)។

(ii) ជំនួសលិខិតធានាបំណុល រដ្ឋភាគីអាចបង់វិភាគទានស្ម័គ្រចិត្តដល់សហគ្រាសក្នុងចំនួន ដែលស្មើនឹងចំណែកបំណុលនោះ ដែលខ្លួនទទួលខុសត្រូវធានា។

(ច) ការបង់សងបំណុលគ្មានការប្រាក់ត្រូវមានអាទិភាពលើការបង់សងបំណុលដទៃទៀត។ ការបង់សងបំណុលគ្មានការប្រាក់ត្រូវធ្វើឡើងអនុលោមតាមតារាងដែលអនុម័តដោយសភាតាមអនុសាសន៍របស់ក្រុមប្រឹក្សា និងយោបល់របស់ក្រុមប្រឹក្សាភិបាល។ ក្នុងការអនុវត្តមុខងារនេះ ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តតាមបញ្ញត្តិ វិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីពាក់ព័ន្ធរបស់ អាជ្ញាធរ ដែលត្រូវពិចារណាពីសារសំខាន់ត្រូវធានាឱ្យមានដំណើរការប្រកបដោយប្រសិទ្ធភាពរបស់សហគ្រាស និងជាពិសេស ត្រូវធានាឯករាជភាពហិរញ្ញវត្ថុរបស់សហគ្រាស។

(ឆ) មូលនិធិដែលមានសម្រាប់សហគ្រាសត្រូវជារូបិយវត្ថុដែលមានដោយសេរី និងអាចប្រើប្រាស់ បានប្រកបដោយប្រសិទ្ធភាព នៅលើទីផ្សារប្តូរប្រាក់អន្តរជាតិចម្បង។ រូបិយវត្ថុទាំងនេះត្រូវកំណត់នៅក្នុងវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ អនុលោមតាមទម្លាប់អនុវត្តផ្នែករូបិយវត្ថុអន្តរជាតិនាពេលបច្ចុប្បន្ន។

(ជ) ″លិខិតធានាបំណុល″ គឺជាលិខិតសន្យារបស់រដ្ឋភាគីចំពោះម្ចាស់ឥណទានរបស់សហគ្រាស

ដោយសន្យាបង់កាតព្វកិច្ចហិរញ្ញវត្ថុរបស់សហគ្រាសដែលធានាដោយលិខិតធានានេះ តាមសមាមាត្រអនុលោមតាមទំហំសមស្រប បន្ទាប់ពីម្ចាស់ឥណទានជូនដំណឹងរដ្ឋភាគីអំពីការខកខាន ដោយឥសហគ្រាស។ នីតិវិធីបង់ប្រាក់លើកាតព្វកិច្ចទាំងនោះត្រូវអនុលោមតាមវិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

៤. មូលនិធិ ទ្រព្យសកម្ម និងការចំណាយរបស់សហគ្រាសត្រូវរក្សាទុកដោយឡែកពីមូលនិធិ ទ្រព្យសកម្ម និងការចំណាយរបស់អាជ្ញាធរ។ មាត្រា ១ មិនរារាំងសហគ្រាសមិនឱ្យធ្វើការព្រមព្រៀងជាមួយនឹងអាជ្ញាធរ ទាក់ទងនឹងប្រព័ន្ធ បុគ្គលិក និងសេវាកម្ម និងការព្រមព្រៀងបង់សងលើការចំណាយរដ្ឋបាលដែលបង់ដោយសហគ្រាស ឬអាជ្ញាធរ តាងនាមឱ្យអាជ្ញាធរ ឬសហគ្រាសនោះទេ។

៥. កំណត់ត្រា សៀវភៅ និងបញ្ជីរបស់សហគ្រាស រាប់បញ្ចូលទាំងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវ ធ្វើសវនកម្មជាប្រចាំឆ្នាំ ដោយសវនករឯករាជ្យ ដែលតែងតាំងដោយក្រុមប្រឹក្សា។

*មាត្រា ១២*

*ប្រតិបត្តិការ*

១. សហគ្រាសត្រូវស្នើគម្រោងអនុវត្តសកម្មភាពអនុលោមតាមមាត្រា ១៧០ ជូនក្រុមប្រឹក្សា។ សំណើនោះ ត្រូវរាប់បញ្ចូលផែនការការងារជាលាយលក្ខណ៍អក្សរជាផ្លូវការសម្រាប់សកម្មភាពនៅតំបន់ អនុលោមតាមមាត្រា ១៥៣ កថាខណ្ឌទី៣ ព្រមទាំងរាល់ព័ត៌មាន និងទិន្នន័យដទៃទៀត ដែលអាចតម្រូវតាមភាពជាក់ស្តែងសម្រាប់ការ វាយតម្លៃដោយគណៈកម្មការបច្ចេកទេស និងច្បាប់ សម្រាប់ការឯកភាពពីក្រុមប្រឹក្សា។

២. នៅពេលក្រុមប្រឹក្សាឯកភាព សហគ្រាសត្រូវអនុវត្តគម្រោងផ្អែកតាមផែនការការងារជាលាយលក្ខណ៍ អក្សរ ដែលចែងក្នុងកថាខណ្ឌទី ១។

៣. (ក) ប្រសិនបើសហគ្រាសមិនមែនទំនិញ និងសេវាកម្ម ដែលត្រូវការសម្រាប់ប្រតិបត្តិការរបស់ខ្លួន ទេនោះ សហគ្រាសអាចធ្វើលទ្ធកម្មបាន។ ក្នុងគោលបំណងលទ្ធកម្មនោះ សហគ្រាសត្រូវ អញ្ជើញឱ្យមានការដេញថ្លៃ និងប្រគល់កិច្ចសន្យាដល់អ្នកដេញថ្លៃដែលផ្តល់គុណភាព តម្លៃ និង ពេលប្រគល់បានល្អប្រសើរបំផុត។

(ខ) ប្រសិនបើមានការដេញថ្លៃច្រើនជាងមួយដែលផ្តល់គុណភាព តម្លៃ និងពេលប្រគល់បានល្អ ប្រសើរបំផុត សហគ្រាសត្រូវប្រគល់កិច្ចសន្យា អនុលោមតាមៈ

(i) គោលការណ៍មិនរើសអើងខាងនយោបាយ ឬការពិចារណាដទៃទៀត ដែលមិនពាក់ព័ន្ធ នឹងការអនុវត្តការងារប្រកបដោយការយកចិត្តទុកដាក់ និងប្រសិទ្ធភាព និង

(ii) សេចក្តីណែនាំដែលបានអនុម័តដោយក្រុមប្រឹក្សាទាក់ទងនឹងបុរិមា ដែលត្រូវផ្តល់ដល់ ទំនិញ និងសេវាកម្មដែលមានប្រភពពីរដ្ឋកំពុងអភិវឌ្ឍ ដែលរួមមានរដ្ឋដីគោក និងរដ្ឋ ដែលភូមិសាស្ត្រមិនអំណោចផល។

(គ) ក្រុមប្រឹក្សាភិបាលអាចអនុម័តវិធានច្បាប់ដែលកំណត់ស្ថានការណ៍ពិសេស ដែលអាចលះបង់លក្ខខណ្ឌអញ្ជើញចូលរួមដេញថ្លៃ ដែលជាប្រយោជន៍ល្អប្រសើរបំផុតរបស់សហគ្រាស។

៤. សហគ្រាសត្រូវមានសិទ្ធិកម្មសិទ្ធិលើធនធានរ៉ែ និងសារធាតុកែច្នៃទាំងអស់ ដែលខ្លួនផលិតបាន។

៥. សហគ្រាសត្រូវលក់ទំនិញរបស់ខ្លួន ដោយគ្មានការរើសអើង។ សហគ្រាសមិនត្រូវផ្តល់ការបញ្ចុះតម្លៃដែលមិនមែនអាជីវកម្ម។

៦. ដោយមិនប៉ះពាល់ដល់សិទ្ធិអំណាចពិសេស ឬទូទៅដែលប្រគល់ឱ្យសហគ្រាស ក្រោមបញ្ញត្តិដទៃណាមួយក្នុងអនុសញ្ញានេះ សហគ្រាសត្រូវអនុវត្តសិទ្ធិអំណាចដែលកើតចេញពីអាជីវកម្មរបស់ខ្លួន តាមភាពចាំបាច់។

៧. សហគ្រាសមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការនយោបាយរបស់រដ្ឋភាគី ហើយក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន សហគ្រាសក៏មិនត្រូវទទួលឥទ្ធិពលនយោបាយពីរដ្ឋភាគីពាក់ព័ន្ធផងដែរ។ មានតែការពិចារណាខាងពាណិជ្ជកម្មប៉ុណ្ណោះដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន ហើយការពិចារណាទាំងនេះត្រូវថ្លឹងថ្លែងដោយគ្មានលំអៀង ដើម្បីអនុវត្តគោលបំណងដែលចែងក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ។

*មាត្រា ១៣*

*ស្ថានភាពគតិយុត្តិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ*

១. ដើម្បីផ្តល់លទ្ធភាពដល់សហគ្រាសក្នុងការអនុវត្តមុខងាររបស់ខ្លួន ឋានៈ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែល ចែងក្នុងមាត្រានេះត្រូវប្រគល់ឱ្យសហគ្រាស ក្នុងទឹកដីរបស់រដ្ឋភាគី។ ដើម្បីបង្កើតប្រសិទ្ធភាពដល់គោលការណ៍នេះ សហគ្រាស និងរដ្ឋភាគីអាចចុះកិច្ចព្រមព្រៀងពិសេស ប្រសិនបើចាំបាច់។

២. សហគ្រាសមានសមត្ថភាពផ្លូវច្បាប់ ដែលចាំបាច់ដើម្បីអនុវត្តមុខងាររបស់ខ្លួន និងសម្រេចគោលបំណងរបស់ខ្លួន ហើយជាពិសេស មានសមត្ថភាព ៖

(ក) ចុះកិច្ចសន្យា កិច្ចការរួម ឬកិច្ចការដទៃទៀត ក្នុងនោះមានកិច្ចព្រមព្រៀងជាមួយរដ្ឋ និងអង្គការ អន្តរជាតិ។

(ខ) ទិញយក ជួល កាន់កាប់ និងលក់ចលនទ្រព្យ និងអចលនទ្រព្យ។

(គ) ធ្វើជាភាគីនៅក្នុងនីតិវិធីបណ្តឹង។

៣. (ក) បណ្តឹងអាចធ្វើឡើងប្រឆាំងនឹងសហគ្រាស តែក្នុងតុលាការមានសមត្ថកិច្ច ក្នុងទឹកដីរដ្ឋភាគី ដែលសហគ្រាសៈ

(i) មានការិយាល័យ ឬអគារ។

(ii) បានតែងតាំងភ្នាក់ងារ ក្នុងគោលបំណងទទួលការជូនដំណឹងពីនីតិវិធី។

(iii) បានចុះកិច្ចសន្យាចំពោះទំនិញ ឬសេវាកម្ម។

(iv) បានចេញមូលបត្រ ឬ

(v) បានធ្វើសកម្មភាពពាណិជ្ជកម្ម។

(ខ) ទ្រព្យសម្បត្តិ និងទ្រព្យសកម្មរបស់សហគ្រាស ទោះនៅទីកន្លែងណាក៏ដោយ និងកាន់កាប់ដោយអ្នកណាក៏ដោយ ត្រូវមានអភ័យសិទ្ធិពីរាល់ការរឹបអូស ឃាត់ទុក ឬការអនុវត្តដីកាគ្រប់រូបភាពទាំងអស់ មុនពេលប្រគល់សេចក្តីសម្រេចស្ថាពរប្រឆាំងសហគ្រាស។

៤. (ក) ទ្រព្យសម្បត្តិ និងទ្រព្យសកម្មរបស់សហគ្រាស ទោះនៅទីកន្លែងណាក៏ដោយ និងកាន់កាប់ដោយអ្នកណាក៏ដោយ ត្រូវមានអភ័យសិទ្ធិពីរាល់ការស្នើយក ការរឹបអូសអស្សាមិករណ៍ ឬការរឹបអូស ក្នុងរូបភាពផ្សេងទៀត ដោយចំណាត់ការអង្គនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ។

(ខ) ទ្រព្យសម្បត្តិ និងទ្រព្យសកម្មរបស់សហគ្រាស ទោះនៅទីកន្លែងណាក៏ដោយ និងកាន់កាប់ដោយ អ្នកណាក៏ដោយ ត្រូវមានអភ័យសិទ្ធិពីការកំហិត បទបញ្ញត្តិ ការគ្រប់គ្រង ការបង្អាក់ប្រភេទណាក៏ដោយដែលមានលក្ខណៈរើសអើង។

(គ) សហគ្រាស និងបុគ្គលិករបស់ខ្លួនត្រូវគោរពច្បាប់ និងបទបញ្ញត្តិក្នុងស្រុក នៅក្នុងរដ្ឋ ឬទឹកដី ដែលសហគ្រាស ឬបុគ្គលិកសហគ្រាសអាចធ្វើអាជីវកម្ម ឬក៏ធ្វើសកម្មភាព។

(ឃ) រដ្ឋភាគីត្រូវធានាថា សហគ្រាសមានសិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងអស់ ដែលរដ្ឋបានផ្តល់ឱ្យអង្គភាពនានាដែលធ្វើសកម្មភាពពាណិជ្ជកម្ម ក្នុងទឹកដីរបស់រដ្ឋ។ សិទ្ធិ បុព្វសិទ្ធិ និងអភ័យឯក សិទ្ធិទាំងនេះត្រូវផ្តល់ឱ្យសហគ្រាស ក្នុងលក្ខណៈដូចគ្នានឹងសិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែល រដ្ឋភាគីបានផ្តល់ឱ្យអង្គភាពនានាដែលធ្វើពាណិជ្ជកម្មស្រដៀងគ្នា។ ប្រសិនបើរដ្ឋភាគីផ្តល់បុព្វសិទ្ធិ ពិសេសដល់រដ្ឋកំពុងអភិវឌ្ឍន៍

ឬអង្គភាពពាណិជ្ជកម្មរបស់រដ្ឋកំពុងអភិវឌ្ឍន៍នោះ សហគ្រាសត្រូវទទួលបានបុព្វសិទ្ធិទាំងនោះ ក្នុងលក្ខខណ្ឌពិសេសដូចគ្នា។

(ង) រដ្ឋភាគីអាចផ្តល់ការលើកទឹកចិត្ត សិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិពិសេសដល់សហគ្រាស ដោយមិនមានកាតព្វកិច្ចផ្តល់ការលើកទឹកចិត្ត សិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិពិសេសដល់អង្គភាព ពាណិជ្ជកម្មដទៃទៀតឡើយ។

៥. សហគ្រាសត្រូវធ្វើការចរចាជាមួយនឹងប្រទេសម្ចាស់ផ្ទះ ដែលខ្លួនតាំងការិយាល័យ និងអគារនៅប្រទេស នោះ ដើម្បីទទួលបានការលើកលែងពន្ធផ្ទាល់ និងប្រយោល។

៦. រដ្ឋភាគីនីមួយៗត្រូវចាត់វិធានច្បាប់ការចាំបាច់ ដែលចាំបាច់ដើម្បីផ្តល់ប្រសិទ្ធភាពដល់គោលការណ៍ដែលចែង ក្នុងឧបសម្ព័ន្ធនេះ តាមលក្ខខណ្ឌច្បាប់ក្នុងស្រុករបស់ខ្លួន ហើយត្រូវជូនដំណឹងដល់សហគ្រាសអំពីវិធានច្បាប់ការជាក់លាក់ដែលបានធ្វើនោះ។

៧. សហគ្រាសអាចលះបង់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិណាមួយ ដែលចែងក្នុងមាត្រានេះ ឬកិច្ចព្រមព្រៀង ពិសេស ដែលលើកឡើងក្នុងកថាខណ្ឌទី ១ ដល់កម្រិត និងក្នុងលក្ខខណ្ឌដែលខ្លួនអាចកំណត់។

ឧបសម្ព័ន្ធ៥៖ ការផ្សះផ្សា

ជំពូកទី១៖ នីតិវិធីផ្សះផ្សាអនុលោមតាមជំពូកទី ១ នៃផ្នែកទី១៥

*មាត្រា ១*

*ការផ្ដួចផ្ដើមនីតិវិធី*

អនុលោមតាមមាត្រា ២៨៤ ប្រសិនបើភាគីវិវាទបានព្រមព្រៀងបញ្ជូនវិវាទទៅធ្វើការផ្សះផ្សាក្រោមផ្នែកនេះ ភាគីនោះអាចចាប់ផ្ដើមនីតិវិធីផ្សះផ្សាបានតាមរយៈសេចក្ដីជូនដំណឹងជាលាយលក្ខណ៍ទៅកាន់ភាគីម្ខាង ទៀត ឬភាគីវិវាទនានា។

*មាត្រា ២*

*បញ្ជីឈ្មោះអ្នកផ្សះផ្សា*

បញ្ជីឈ្មោះអ្នកផ្សះផ្សាត្រូវរៀបចំឡើង និងរក្សាទុកដោយអគ្គលេខាធិការអង្គការសហប្រជា ជាតិ។ រាល់រដ្ឋភាគីមានសិទ្ធិជ្រើសតាំងអ្នកផ្សះផ្សា ៤ រូប ដែលម្នាក់ៗត្រូវជាបុគ្គលដែលមានកេរ្តិ៍ឈ្មោះខាងយុត្តិធម៌ មាន សមត្ថភាព និងភាពសុចរិត។ ឈ្មោះបុគ្គលដែលជ្រើសតាំងនោះត្រូវបង្កើតជាបញ្ជីឈ្មោះ។ ប្រសិនបើអ្នកផ្សះផ្សាដែលរដ្ឋភាគីបានជ្រើសតាំងក្នុងបញ្ជីឈ្មោះមានចំនួនតិចជាង ៤ នាក់ រដ្ឋភាគីនោះមានសិទ្ធិជ្រើសតាំងបន្ថែមជាការចាំបាច់។

ឈ្មោះអ្នកផ្សះផ្សាម្នាក់ត្រូវមាននៅក្នុងបញ្ជីឈ្មោះរហូតទាល់តែរដ្ឋភាគីដែលធ្វើការជ្រើសតាំង នោះបានដកឈ្មោះ នោះចេញ ឱ្យតែអ្នកផ្សះផ្សានោះត្រូវបន្តធ្វើការក្នុងគណៈកម្មការផ្សះផ្សាដែលខ្លួនត្រូវបានតែងតាំងឱ្យធ្វើជាសមាជិករហូតទាល់តែបញ្ចប់នីតិវិធីផ្សះផ្សានៅចំពោះមុខគណៈកម្មការនោះ។

*មាត្រា ៣*

*ការបង្កើតគណៈកម្មការផ្សះផ្សា*

ប្រសិនបើគ្មានការព្រមព្រៀងផ្សេងដោយភាគីទេនោះ គណៈកម្មការផ្សះផ្សាត្រូវបង្កើតឡើងដូចខាងក្រោមៈ

(ក) ដោយស្ថិតក្រោមលក្ខខណ្ឌនៃកថាខណ្ឌ (ឆ) គណៈកម្មការផ្សះផ្សាត្រូវមានសមាជិក ៥ នាក់។

(ខ) ភាគីដែលចាប់ផ្តើមនីតិវិធីផ្សះផ្សាត្រូវតែងតាំងអ្នកផ្សះផ្សា ២នាក់ដែលត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះដែលចែងក្នុងមាត្រា ២ នៃឧបសម្ព័ន្ធនេះដោយម្នាក់ក្នុងចំណោម នោះ ជាប្រជាជនរបស់ខ្លួន

ប្រសិនបើភាគីមិនបានព្រមព្រៀងផ្សេងទេនោះ។

ការតែងតាំងនោះត្រូវសរសេរក្នុងសេចក្ដីជូនដំណឹងដែលចែងក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ។

(គ) ភាគីម្ខាងទៀតត្រូវតែងតាំងអ្នកផ្សះផ្សា ២ នាក់ទៀត តាមរបៀបដូចចែងក្នុងកថាខណ្ឌ (ខ) ក្នុងរយៈពេល ២១ ថ្ងៃ បន្ទាប់ពីទទួលបានសេចក្ដីជូនដំណឹងដែលចែងក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ។ ប្រសិនបើគ្មានការតែងតាំងក្នុងរយៈពេលនោះទេ ក្នុងរយៈពេល ១ សប្ដាហ៍ បន្ទាប់ពីផុតកំណត់រយៈពេលនោះ ភាគីដែលចាប់ផ្ដើមនីតិវិធីផ្សះផ្សាអាចបញ្ចប់នីតិវិធីផ្សះផ្សា ដោយជូនដំណឹងទៅភាគីម្ខាងទៀត ឬស្នើសុំអគ្គលេខាធិការអង្គការសហប្រជាជាតិធ្វើការតែងតាំងអនុលោមតាមកថាខណ្ឌ (ង)។

(ឃ) ក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីអ្នកផ្សះផ្សា ៤នាក់ត្រូវបានតែងតាំងរួច អ្នកផ្សះផ្សា ទាំងបួនត្រូវតែងតាំងអ្នកផ្សះផ្សាទី ៥ ដែលត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះចែងក្នុងមាត្រា ២ នៃឧបសម្ព័ន្ធនេះ ដែលត្រូវធ្វើជាប្រធានគណៈកម្មការ។ ប្រសិនបើគ្មានការតែងតាំងក្នុងរយៈពេលនេះទេ ក្នុងរយៈពេល ១សប្ដាហ៍ បន្ទាប់ពីផុតកំណត់រយៈពេលនោះ ភាគីណាមួយអាចស្នើសុំអគ្គលេខាធិការអង្គការសហប្រជាជាតិធ្វើការតែងតាំងអនុលោមតាមកថាខណ្ឌ (ង)។

(ង) ក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីទទួលបានសំណើ ដូចចែងក្នុងកថាខណ្ឌ (គ) ឬ (ឃ) អគ្គលេខា ធិការអង្គការសហប្រជាជាតិត្រូវធ្វើការតែងតាំងដែលចាំបាច់ចេញពីបញ្ជីឈ្មោះចែងក្នុងមាត្រា ២ នៃឧបសម្ព័ន្ធនេះ ដោយពិគ្រោះយោបល់ជាមួយនឹងភាគីវិវាទ។

(ច) ក្នុងករណីតំណែងអ្នកផ្សះផ្សាទំនេរ ត្រូវធ្វើការតែងតាំងតាមរបៀបដែលបានកំណត់សម្រាប់ការតែងតាំងដំបូង។

(ឆ) ភាគីពីរ ឬច្រើនដែលកំណត់តាមការព្រមព្រៀងថា ពួកគេមានផលប្រយោជន៍ដូចគ្នា ត្រូវធ្វើការតែងតាំងអ្នកផ្សះផ្សាពីរនាក់រួមគ្នា។ នៅពេលភាគីពីរ

ឬច្រើនមានផលប្រយោជន៍ដោយឡែកពីគ្នា ឬគ្មានការព្រមព្រៀងថាពួកគេមានផលប្រយោជន៍តែមួយ ពួកគេត្រូវតែងតាំងអ្នកផ្សះផ្សារដោយឡែកពីគ្នា។

(ជ) ក្នុងវិវាទដែលមានភាគីច្រើនជាង ២ ដែលមានផលប្រយោជន៍ដាច់ដោយឡែកពីគ្នា ឬប្រសិនបើ គ្មានការព្រមព្រៀងថាពួកគេមានផលប្រយោជន៍តែមួយនោះ ភាគីត្រូវអនុវត្តតាមកថាខណ្ឌ (ក) ដល់ (ច) ប្រសិនបើអាចធ្វើទៅបាន។

*មាត្រា ៤*
*នីតិវិធី*

ប្រសិនបើភាគីគ្មានការព្រមព្រៀងផ្សេងទេនោះ គណៈកម្មការផ្សះផ្សាត្រូវកំណត់នីតិវិធីផ្ទាល់របស់ខ្លួន។ ដោយមានការយល់ព្រមពីភាគីវិវាទ គណៈកម្មការអាចអញ្ជើញរដ្ឋភាគីស្នើទស្សនៈរបស់ខ្លួន ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ សេចក្តីសម្រេចរបស់គណៈកម្មការទាក់ទងនឹងបញ្ហានីតិវិធីរបាយការណ៍ និងអនុសាសន៍ ត្រូវធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើនរបស់សមាជិក។

*មាត្រា ៥*
*ដំណោះស្រាយជាលក្ខណៈមិត្តភាព*

គណៈកម្មការអាចទាញការយកចិត្តទុកដាក់របស់ភាគីចំពោះវិធានច្បាប់ការណាមួយ ដែលអាចសម្រួលឱ្យមាន ដំណោះស្រាយ ជាលក្ខណៈមិត្តភាពលើវិវាទ។

*មាត្រា ៦*
*មុខងាររបស់គណៈកម្មការ*

គណៈកម្មការត្រូវស្តាប់ភាគី ពិនិត្យការអះអាង និងការបដិសេធ និងលើកសំណើដល់ភាគី ក្នុងគោល បំណងឈានដល់ដំណោះស្រាយជាលក្ខណៈមិត្តភាព។

*មាត្រា ៧*
*របាយការណ៍*

១.	គណៈកម្មការត្រូវរាយការណ៍ ក្នុងរយៈពេល ១២ ខែបន្ទាប់ពីការបង្កើតគណៈកម្មការ។ របាយការណ៍ របស់គណៈកម្មការត្រូវកត់ត្រាការព្រមព្រៀងដែលភាគីឈានដល់ និងការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងអង្គហេតុ និងអង្គច្បាប់ ប្រសិនបើគ្មានការព្រមព្រៀងទេនោះ ដែលគណៈកម្មការអាចចាត់ទុកថាសមស្របសម្រាប់ដំណោះ ស្រាយជាលក្ខណៈមិត្តភាព។ របាយការណ៍ត្រូវទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ អង្គការសហប្រជាជាតិត្រូវបញ្ជូនទៅឱ្យភាគីវិវាទភ្លាម។

២.	របាយការណ៍របស់គណៈកម្មការ ដែលមានសេចក្តីសន្និដ្ឋាន ឬអនុសាសន៍ មិនត្រូវចងកាតព្វកិច្ចលើភាគី ទេ។

*មាត្រា ៨*

*ការបញ្ចប់*

នីតិវិធីផ្សះផ្សាត្រូវបញ្ចប់ នៅពេលឈានដល់ដំណោះស្រាយមួយ នៅពេលភាគីទទួលយក ឬភាគីមួយ បានបដិសេធអនុសាសន៍នៃរបាយការណ៍ តាមរយៈសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលផ្ញើទៅអគ្គលេខាធិ ការអង្គការសហប្រជាជាតិ ឬនៅពេលរយៈពេល ៣ ខែ បានកន្លងផុត ចាប់ពីកាលបរិច្ឆេទបញ្ជូនរបាយការណ៍ទៅ ភាគី។

*មាត្រា ៩*

*កម្រៃ និងការចំណាយ*

កម្រៃ និងការចំណាយរបស់គណៈកម្មការត្រូវទទួលបន្ទុកដោយភាគីវិវាទ។

*មាត្រា ១០*

*សិទ្ធិរបស់ភាគីកែប្រែនីតិវិធី*

ភាគីវិវាទអាចកែប្រែបញ្ញត្តិណាមួយនៃឧបសម្ព័ន្ធនេះ តាមការព្រមព្រៀងដែលអនុវត្តចំពោះតែវិវាទនោះប៉ុណ្ណោះ។

ជំពូកទី២៖ លក្ខខណ្ឌត្រូវចូលរួមនីតិវិធីផ្សះផ្សា អនុលោមតាមជំពូកទី ៣ នៃផ្នែកទី ១៥

*មាត្រា ១១*

*ការផ្តួចផ្តើមនីតិវិធីផ្សះផ្សា*

១. អនុលោមតាមផ្នែកទី១៥ជំពូកទី ៣ ភាគីណាមួយនៃវិវាទអាចត្រូវធ្វើការផ្សះផ្សា ក្រោមផ្នែកនេះ អាចចាប់ផ្តើមនីតិវិធីផ្សះផ្សា តាមរយៈសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីម្ខាងទៀត ឬភាគីនៃវិវាទ។

២. បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹង តាមកថាខណ្ឌទី ១ ភាគីណាមួយនៃវិវាទត្រូវតែចូលរួមក្នុងនីតិវិធីផ្សះផ្សា។

*មាត្រា ១២*

*ការខកខានឆ្លើយតប ឬចូលរួមនីតិវិធីផ្សះផ្សា*

ការខកខានរបស់ភាគីមួយ ឬច្រើននៃវិវាទ ក្នុងការឆ្លើយតបនឹងសេចក្តីជូនដំណឹងពីការចាប់ផ្តើមនីតិវិធី ផ្សះផ្សា ឬចូលរួមក្នុងនីតិវិធីផ្សះផ្សា មិនត្រូវបង្កើតជាឧបសគ្គចំពោះនីតិវិធីផ្សះផ្សាឡើយ។

*មាត្រា ១៣*

*សមត្ថកិច្ច*

ការមិនព្រមព្រៀងទាក់ទងនឹងថាតើគណៈកម្មការផ្សះផ្សា ដែលធ្វើសកម្មភាពក្រោមផ្នែកនេះ មានសមត្ថកិច្ច ឬយ៉ាងណា ត្រូវសម្រេចដោយគណៈកម្មការ។

*មាត្រា ១៤*

*ការអនុវត្តជំពូកទី ១*

មាត្រា ២ ដល់ ១០ ក្រោមជំពូកទី ១ នៃឧបសម្ព័ន្ធនេះ ត្រូវយកមកអនុវត្ត ស្ថិតក្រោមលក្ខខណ្ឌនៃជំពូកនេះ។

## ឧបសម្ព័ន្ធ៦៖ លក្ខន្តិកៈក្រុមប្រឹក្សាជំនុំជម្រះអន្តរជាតិសម្រាប់ច្បាប់សមុទ្រ

*មាត្រា ១*

*បទបញ្ញត្តិទូទៅ*

១. ក្រុមប្រឹក្សាជំនុំជម្រះអន្តរជាតិសម្រាប់ច្បាប់សមុទ្រត្រូវបានបង្កើតឡើង និងត្រូវមានមុខងារ អនុលោមតាមបញ្ញត្តិ នៃអនុសញ្ញានេះ និងលក្ខន្តិកៈនេះ។

២. ទីកន្លែងរបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវស្ថិតនៅ Free and Hanseatic City of Hamburg សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់។

៣. ក្រុមប្រឹក្សាជំនុំជម្រះអាចតាំងទីកន្លែង និងអនុវត្តមុខងាររបស់ខ្លួន នៅទីកន្លែងផ្សេង នៅពេលណាក៏ដោយដែលយល់ថាគួរអាចធ្វើបាន។

៤. ការបញ្ជូនវិវាទទៅក្រុមប្រឹក្សាជំនុំជម្រះត្រូវគ្រប់គ្រងដោយបញ្ញាត្តនៃផ្នែកទី ១១និង១៥។

### ជំពូកទី១៖ ការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ

*មាត្រា ២*

*សមាសភាព*

១. ក្រុមប្រឹក្សាជំនុំជម្រះជាស្ថាប័នដែលមានមាជិកឯករាជ្យ ២១នាក់ ដែលបោះឆ្នោតចេញពីក្នុងចំណោមបុគ្គលិកដែលមាន កេរ្តិ៍ឈ្មោះខ្ពស់ខាងយុត្តិធម៌ និងសេចក្តីសុចរិត និងមានសមត្ថិភាពដែលត្រូវបានទទួលស្គាល់នៅក្នុងវិស័យច្បាប់សមុទ្រ។

២. នៅក្នុងក្រុមប្រឹក្សាជំនុំជម្រះទាំងមូល ភាពជាតំណាងនៃប្រព័ន្ធច្បាប់ចម្បងរបស់ពិភពលោក និងរបាយស្មើគ្នាតាមភូមិសាស្ត្រត្រូវបានធានា។

*មាត្រា ៣*

*សមាជិកភាព*

១.	គ្មានសមាជិកពីរនាក់ក្នុងក្រុមប្រឹក្សាជំនុំជម្រះអាចជាប្រជាជននៃរដ្ឋតែមួយបានឡើយ។ បុគ្គលដែលអាចចាត់ទុកថា ជាប្រជាជនរបស់រដ្ឋច្រើនជាងមួយ ក្នុងគោលបំណងនៃសមាជិកភាព ត្រូវចាត់ទុកថាជាប្រជាជនរបស់រដ្ឋមួយ ដែលខ្លួនជាធម្មតាអនុវត្តសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

២.	មិនត្រូវមានសមាជិកតិចជាង ៣ នាក់ ឡើងពីក្រុមភូមិសាស្ត្រនីមួយៗ ដែលបង្កើតឡើងដោយមហាសន្និ បាតនៃអង្គការសហប្រជាជាតិ។

*មាត្រា ៤*

*ការជ្រើសតាំង និងការបោះឆ្នោត*

១.	រដ្ឋភាគីនីមួយៗអាចជ្រើសតាំងបុគ្គលមិនលើសពី ២នាក់ឡើយ ដែលមានលក្ខណៈសម្បត្តិដូចកំណត់ក្នុង មាត្រា ២ នៃឧបសម្ព័ន្ធនេះ។ សមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះត្រូវបោះឆ្នោតចេញពីបញ្ជីឈ្មោះបេក្ខជនដែលបានជ្រើសតាំងនោះ។

២.	ក្នុងរយៈពេលយ៉ាងហោចណាស់ ៣ ខែមុនថ្ងៃបោះឆ្នោត អគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងករណីជាការបោះឆ្នោតលើកទី ១ និងបញ្ជីកានៃក្រុមប្រឹក្សាជំនុំជម្រះ ក្នុងករណីបោះឆ្នោតក្រោយៗ ត្រូវផ្ញើលិខិតអញ្ជើញ ទៅរដ្ឋភាគីឱ្យដាក់ឈ្មោះបុគ្គលជ្រើសតាំងរបស់ខ្លួនសម្រាប់ឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះ ក្នុងរយៈពេល ២ ខែ។ មន្ត្រីកាន់បញ្ជីត្រូវរៀបចំបញ្ជីតាមលំដាប់តួអក្សរនៃបេក្ខជនទាំងអស់ដែលត្រូវបានជ្រើសតាំងនោះ ហើយដាក់បញ្ជី ឈ្មោះនោះជូនរដ្ឋភាគី មុនថ្ងៃទី ៧ ក្នុងខែចុងក្រោយ មុនកាលបរិច្ឆេទបោះឆ្នោតនីមួយៗ។

៣.	ការបោះឆ្នោតលើកទី ១ ត្រូវរៀបចំឡើងក្នុងរយៈពេល ៦ ខែ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន។

៤. សមាជិកក្រុមប្រឹក្សាជំនុំជម្រះត្រូវបោះឆ្នោតជាសម្ងាត់។ ការបោះឆ្នោតត្រូវរៀបចំនៅក្នុងកិច្ចប្រជុំរបស់រដ្ឋភាគី ដែលកោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងករណីជាការបោះឆ្នោតលើកទី ១ និងដោយនីតិវិធី ដែលរដ្ឋភាគីព្រមព្រៀង ក្នុងករណីជាការបោះឆ្នោតក្រោយៗមក។ រដ្ឋភាគី ២ភាគ៣ ត្រូវបង្កើតជាកូរ៉ុម ក្នុងកិច្ចប្រជុំ។ ជនដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះត្រូវជាបុគ្គលជ្រើសតាំងទាំងឡាយដែលទទួលបានសម្លេងសន្លឹក ឆ្នោតច្រើនបំផុត ដោយមានរដ្ឋភាគីភាគច្រើន ២ ភាគ ៣ មានវត្តមាន និងបោះឆ្នោត ឱ្យតែភាគច្រើននោះរាប់ បញ្ចូលរដ្ឋភាគីភាគច្រើន។

*មាត្រា ៥*

*អាណត្តិតំណែង*

១. សមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះត្រូវបោះឆ្នោតសម្រាប់រយៈពេល ៩ឆ្នាំ ហើយអាចត្រូវបានបោះឆ្នោតជាថ្មី ឱ្យតែ ក្នុងចំណោមសមាជិកដែលជាប់ឆ្នោត ក្នុងការបោះឆ្នោតលើកទី ១ អាណត្តិរបស់សមាជិក ៧ នាក់ត្រូវផុតកំណត់ នៅចុងឆ្នាំទី ៣ និងអាណត្តិរបស់សមាជិក ៧ នាក់ទៀតត្រូវផុតកំណត់នៅចុងឆ្នាំទី ៦។

២. សមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះដែលមានអាណត្តិនឹងត្រូវផុតកំណត់នៅចុងឆ្នាំទី ៣ និងចុងឆ្នាំទី ៦ ក្នុងរយៈពេលដំបូង ដូចរៀបរាប់ខាងលើ នឹងត្រូវជ្រើសរើសដោយការចាប់ឆ្នោតដោយ អគ្គលេខាធិការអង្គការសហប្រជាជាតិ ភ្លាមៗបន្ទាប់ពីការបោះឆ្នោតលើកទី ១។

៣. សមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះត្រូវបន្តបំពេញករណីកិច្ចរបស់ខ្លួន រហូតទាល់តែមានអ្នកមកកាន់តំណែងរបស់ខ្លួន។ ទោះបីមានអ្នកថ្មីមកជំនួសក៏ដោយ ប៉ុន្តែពួកគេត្រូវបញ្ចប់នីតិវិធីបណ្តឹងណាមួយដែលខ្លួនអាចចាប់ផ្តើម មុនកាល បរិច្ឆេទជំនួសនោះ។

៤.	ក្នុងករណីមានការលាលែងពីសមាជិកម្នាក់នៃក្រុមប្រឹក្សាជំនុំជម្រះ លិខិតសុំលាលែងត្រូវផ្ញើទៅប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ តំណែងនោះនឹងនៅទំនេរ ពេលទទួលបានលិខិតលាលែងនោះ។

*មាត្រា ៦*

*តំណែងទំនេរ*

១.	តំណែងទំនេរត្រូវយកមនុស្សមកដាក់ តាមវិធីតែមួយ ដែលចែងសម្រាប់ការបោះឆ្នោតលើកទី ១ ដោយស្ថិតក្រោមលក្ខខណ្ឌនៃបញ្ញត្តិ ដូចតទៅៈ ក្នុងរយៈពេលមួយខែបន្ទាប់ពីមានតំណែងទំនេរ មន្ត្រីកាន់បញ្ជីត្រូវចេញលិខិតអញ្ជើញ ដូចមានចែងក្នុងមាត្រា ៤ នៃឧបសម្ព័ន្ធនេះ ហើយកាលបរិច្ឆេទបោះឆ្នោតត្រូវកំណត់ដោយប្រធានសា-លាក្តី បន្ទាប់ពីពិគ្រោះយោបល់ជាមួយនឹងរដ្ឋភាគី។

២.	សមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះមួយរូប ដែលត្រូវបានបោះឆ្នោតជំនួសសមាជិកម្នាក់ទៀតដែលមានអាណត្តិមិនទាន់ផុតកំណត់ ត្រូវកាន់តំណែងសម្រាប់រយៈពេលនៅសល់របស់សមាជិកមុននោះ។

*មាត្រា ៧*

*សកម្មភាពវិសមិតភាព*

១.	គ្មានសមាជិកណាម្នាក់នៅក្នុងក្រុមប្រឹក្សាជំនុំជម្រះអាចអនុវត្តមុខងារនយោបាយ ឬរដ្ឋបាល ឬចូលរួមយ៉ាងសកម្ម ឬ មានផលប្រយោជន៍ហិរញ្ញវត្ថុក្នុងប្រតិបត្តិការណាមួយរបស់សហគ្រាស ពាក់ព័ន្ធនឹងការរុករក ឬធ្វើអាជីវកម្មធនធាននៅសមុទ្រ ឬបាតសមុទ្រ ឬការប្រើប្រាស់សមុទ្រ ឬបាត់សមុទ្រជាលក្ខណៈពាណិជ្ជកម្មផ្សេងទៀត។

២.	គ្មានសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើជាភ្នាក់ងារ ទីប្រឹក្សា ឬអ្នកតស៊ូមតិក្នុងករណីណាមួយឡើយ។

៣.	ការមន្ទិលសង្ស័យលើចំណុចទាំងនេះត្រូវសម្រេច ដោយសេចក្តីសម្រេចសម្លេងភាគច្រើននៃសមាជិក ដទៃទៀតដែលមានវត្តមាននៅក្នុងក្រុមប្រឹក្សាជំនុំជម្រះ។

*មាត្រា ៨*

*លក្ខខណ្ឌទាក់ទងនឹងការចូលរួមរបស់សមាជិកក្នុងរឿងក្តីណាមួយ*

១.	គ្មានសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះអាចចូលរួមក្នុងការសម្រេចរឿងក្តីណាមួយឡើយ ដែលខ្លួនធ្លាប់ធ្វើជាភ្នាក់ងារ ទីប្រឹក្សា ឬអ្នកតស៊ូមតិសម្រាប់ភាគីមួយ ឬជាសមាជិកតុលាការជាតិ ឬអន្តរជាតិ ឬក្រុមប្រឹក្សាជំនុំជម្រះ ឬក្នុងសមត្ថភាព ដទៃផ្សេងទៀត។

២.	ប្រសិនបើ សម្រាប់មូលហេតុពិសេស សមាជិកម្នាក់នៃក្រុមប្រឹក្សាជំនុំជម្រះពិចារណាថា ខ្លួនមិនគួរចូលរួមក្នុងការធ្វើ សេចក្តីសម្រេចលើរឿងក្តីណាមួយនោះ សមាជិកគួរជូនដំណឹងប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

៣.	ប្រសិនបើប្រធានពិចារណាថា ដោយសារមូលហេតុពិសេស សមាជិកម្នាក់ក្នុងចំណោមសមាជិកក្រុមប្រឹក្សាជំនុំជម្រះ មិនគួរចូលរួមក្នុងរឿងក្តីណាមួយនោះ ប្រធានត្រូវជូនដំណឹងសមាជិកនោះ តាមភាពសមស្រប។

៤.	ការមន្ទិលសង្ស័យលើចំណុចទាំងនេះត្រូវសម្រេច ដោយសេចក្តីសម្រេចសម្លេងភាគច្រើននៃសមាជិក ដទៃទៀតដែលមានវត្តមាននៅក្នុងក្រុមប្រឹក្សាជំនុំជម្រះ។

*មាត្រា ៩*

*ផលវិបាកនៃការឈប់បំពេញលក្ខខណ្ឌតម្រូវ*

ប្រសិនបើសមាជិកដទៃទៀតនៃក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញជាឯកច្ឆន្ទថា សមាជិកម្នាក់ឈប់បំពេញលក្ខខណ្ឌ ដែលតម្រូវហើយនោះ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចប្រកាសឱ្យតំណែងនោះនៅទំនេរ។

*មាត្រា ១០*

*បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ*

សមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិការទូត នៅពេលបំពេញការងាររបស់ ក្រុមប្រឹក្សាជំនុំជម្រះ។

*មាត្រា ១១*

*ការប្រកាសជាឱឡារឹករបស់សមាជិក*

មុនពេលទទួលភារកិច្ច រាល់សមាជិកទាំងអស់នៃក្រុមប្រឹក្សាជំនុំជម្រះត្រូវប្រកាសជាឱឡារឹក ក្នុងសម័យប្រជុំ បើកចំហរថា ខ្លួននឹងអនុវត្ត សិទ្ធិអំណាចដោយគ្មានលំអៀង និងមានសម្បជញ្ញៈ។

*មាត្រា ១២*

*ប្រធាន អនុប្រធាន និងការចុះបញ្ជិកា*

១. ក្រុមប្រឹក្សាជំនុំជម្រះត្រូវបោះឆ្នោតរើសប្រធាន និងអនុប្រធានសម្រាប់រយៈពេល ៣ ឆ្នាំ។ ពួកគេអាចត្រូវបាន បោះឆ្នោតជាថ្មីបាន។

២. ក្រុមប្រឹក្សាជំនុំជម្រះត្រូវតែងតាំងមន្ត្រីកាន់បញ្ជីរបស់ខ្លួន ហើយអាចធ្វើការតែងតាំងមន្ត្រីដទៃទៀត ដែលអាចជាការ ចាំបាច់។

៣. ប្រធាន និងមន្ត្រីកាន់បញ្ជីត្រូវស្នាក់នៅនៅទីតាំងរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

*មាត្រា ១៣*

*កូរ៉ុម*

១. រាល់សមាជិកទាំងអស់នៃក្រុមប្រឹក្សាជំនុំជម្រះត្រូវជួបប្រជុំ។ ចំនួនកូរ៉ុមសមាជិកជាប់ឆ្នោត ១១ នាក់ជាចំនួនដែល ត្រូវការ ដើម្បីបង្កើតក្រុមប្រឹក្សាជំនុំជម្រះ។

២. ដោយស្ថិតក្រោមលក្ខខណ្ឌមាត្រា ១៧ នៃឧបសម្ព័ន្ធនេះ ក្រុមប្រឹក្សាជំនុំជម្រះត្រូវកំណត់ថាតើសមាជិកណាអាច បង្កើតជាក្រុមប្រឹក្សាជំនុំជម្រះ សម្រាប់ពិចារណាលើរឿងក្តីមួយ ដោយពិចារណាលើការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព នៃសភាវិវាទ ដូចចែងក្នុងមាត្រា ១៤ និង ១៥ នៃឧបសម្ព័ន្ធនេះ។

៣. រាល់វិវាទ និងពាក្យសុំទាំងអស់ ដែលបានដាក់មកក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបើកសវនាការ និងសម្រេចដោយ ក្រុមប្រឹក្សាជំនុំជម្រះ ប្រសិនបើមាត្រា ១៤ នៃឧបសម្ព័ន្ធនេះមិនអនុវត្តនោះទេ ឬភាគីអាចស្នើសុំឱ្យចាត់ការលើវិវាទ និងពាក្យសុំ អនុលោមតាមមាត្រា ១៥ នៃឧបសម្ព័ន្ធនេះ។

*មាត្រា ១៤*

*សភាវិវាទបាតសមុទ្រ*

សភាវិវាទបាតសមុទ្រត្រូវបង្កើតឡើងអនុលោមតាមជំពូកទី ៤ នៃឧបសម្ព័ន្ធនេះ។ យុត្តាធិការ សិទ្ធិអំណាច និងមុខងារ មានចែងក្នុងផ្នែកទី ១១ផ្នែកទី ៥។

*មាត្រា ១៥*

*សភាវិវាទពិសេស*

១. ក្រុមប្រឹក្សាជំនុំជម្រះអាចបង្កើតសភាវិវាទពិសេសនេះ ដែលមានសមាជិកជាប់ឆ្នោត ៣ នាក់ ឬច្រើនជាង ៣ នាក់ ដែលខ្លួនចាត់ទុកថាជាការចាំបាច់ ដើម្បីចាត់ការលើប្រភេទវិវាទជាក់លាក់។

២. ក្រុមប្រឹក្សាជំនុំជម្រះត្រូវបង្កើតសភាវិវាទ ដើម្បីចាត់ការលើវិវាទដែលបញ្ជូនមកក្រុមប្រឹក្សាជំនុំជម្រះ ប្រសិនបើភាគីស្នើសុំ។ សមាសភាពនៃសភាវិវាទត្រូវកំណត់ដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយមានការឯកភាពពីភាគី។

៣.	ដោយមានគោលបំណងបំពេញការងារឱ្យបានលឿន ក្រុមប្រឹក្សាជំនុំជម្រះត្រូវបង្កើតសភាវិវាទជាប្រចាំឆ្នាំ ដែលមានសមាសភាពសមជិកជាបឆ្នាត ៥ នាក់ ដែលអាចបើកសវនាការ និងសម្រេចវិវាទ តាមនីតិវិធីសង្ខេប។ សមាជិកផ្សេងពីរនាក់ទៀត ត្រូវបានជ្រើសរើស ក្នុងគោលបំណងដាក់ជំនួសសមាជិកណា ដែលមិនអាចចូលរួមក្នុងនីតិវិធីបាន។

៤.	វិវាទត្រូវបើកសវនាការ និងសម្រេច ដោយសភាវិវាទ ដែលមានចែងក្នុងមាត្រានេះ ប្រសិនបើភាគីស្នើសុំ។

៥.	សេចក្តីសម្រេចដែលធ្វើឡើងដោយសភាវិវាទណាមួយ ដែលចែងក្នុងមាត្រានេះ និងមាត្រា ១៤ នៃ ឧបសម្ព័ន្ធនេះត្រូវចាត់ទុកថា ជាសេចក្តីសម្រេចដែលបានធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជម្រះ។

*មាត្រា ១៦*

*វិធានច្បាប់របស់ក្រុមប្រឹក្សាជំនុំជម្រះ*

ក្រុមប្រឹក្សាជំនុំជម្រះត្រូវបង្កើតវិធានច្បាប់សម្រាប់អនុវត្តមុខងាររបស់ខ្លួន។ ជាពិសេស ក្រុមប្រឹក្សាជំនុំជម្រះត្រូវកំណត់វិធានច្បាប់នីតិវិធី។

*មាត្រា ១៧*

*សញ្ជាតិរបស់សមាជិក*

១.	សមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះ ដែលមានសញ្ជាតិរបស់ភាគីណាមួយនៃវិវាទ ត្រូវរក្សាសិទិច្ចិលូរួមជាសមាជិកនៃ ក្រុមប្រឹក្សាជំនុំជម្រះ។

២.	នៅពេលបើកសវនាការលើវិវាទ ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះដាក់បញ្ចូលសមាជិកម្នាក់ដែលមានសញ្ជាតិនៃភាគី ម្ខាង ភាគីម្ខាងទៀតអាចជ្រើសរើសបុគ្គលឱ្យចូលរួមជាសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះបាន។

៣.	នៅពេលបើកសវនាការលើវិវាទ

ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះមិនដាក់បញ្ចូលសមាជិកម្នាក់ដែលមានសញ្ជាតិរបស់ ភាគី ភាគីនីមួយៗអាចជ្រើសរើសបុគ្គលឱ្យចូលរួមជាសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះបាន។

៤.	មាត្រានេះអនុវត្តចំពោះសភាវិវាទ ដែលចែងក្នុងមាត្រា ១៤ និង ១៥ នៃឧបសម្ព័ន្ធនេះ។ ក្នុងករណីនេះ ដោយពិគ្រោះយោបល់ជាមួយនឹងភាគី ប្រធានអាចស្នើសុំឱ្យមានចំនួនសមាជិកច្រើនក្នុងការបង្កើតសភាវិវាទដែលជាការចាំបាច់ ដើម្បីផ្តល់កន្លែងដល់សមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះដែលមានសញ្ជាតិរបស់ភាគី ហើយប្រសិនបើគ្មាន ឬប្រសិនបើគេមិនអាចមានវត្តមាន ដល់សមាជិកដែលភាគីជ្រើសរើសជាពិសេស។

៥.	ប្រសិនបើមានភាគីច្រើនមានផលប្រយោជន៍តែមួយ ពួកគេត្រូវចាត់ទុកថាជាភាគីមួយប៉ុណ្ណោះក្នុង គោលបំណងនៃបញ្ញត្តិមុនៗ។ ការមន្ទិលសង្ស័យលើចំណុចនេះត្រូវដោះស្រាយដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

៦.	សមាជិកដែលជ្រើសរើសអនុលោមតាមកថាខណ្ឌទី ២ ៣ និង ៤ ត្រូវបំពេញលក្ខខណ្ឌ ដែលចែងក្នុងមាត្រា ២ ៨ និង ១១ នៃឧបសម្ព័ន្ធនេះ។ ពួកគេត្រូវចូលរួមក្នុងការធ្វើសេចក្តីសម្រេច ដោយស្មើភាពជាមួយនឹងសមាជិកដទៃទៀត។

*មាត្រា ១៨*

*ប្រាក់បៀវត្សរបស់សមាជិក*

១.	សមាជិកជាប់ឆ្នោតម្នាក់ៗនៃក្រុមប្រឹក្សាជំនុំជម្រះត្រូវទទួលបានប្រាក់វិភាជន៍ប្រចាំឆ្នាំ និងប្រាក់វិភាជន៍ពិសេស សម្រាប់ចំនួនថ្ងៃដែលខ្លួនបំពេញមុខងារ ឱ្យតែប្រាក់វិភាជនន៍ពិសេសសរុប ដែលបង់ឱ្យសមាជិក មិនត្រូវលើស ប្រាក់វិភាជន៍ប្រចាំឆ្នាំឡើយ។

២.	ប្រធានទទួលបានប្រាក់វិភាជន៍ពិសេសប្រចាំឆ្នាំ។

៣.	អនុប្រធានត្រូវទទួលបានប្រាក់វិភាជន៍ពិសេស សម្រាប់ចំនួនថ្ងៃដែលខ្លួនធ្វើជាប្រធាន។

៤. សមាជិកដែលជ្រើសរើសតាមមាត្រា ១៧ នៃឧបសម្ព័ន្ធនេះ ក្រៅពីសមាជិកជាប់ឆ្នោតរបស់ក្រុមប្រឹក្សាជំនុំជម្រះ ត្រូវទទួលបានប្រាក់តបស្នង សម្រាប់ចំនួនថ្ងៃដែលខ្លួនបានបំពេញមុខងារ។

៥. ប្រាក់បៀវត្ស ភាគលាភ លាភការ ត្រូវកំណត់តាមពេលវេលាជាក់ស្តែង ក្នុងកិច្ចប្រជុំរបស់រដ្ឋភាគី ដោយពិចារណាលើទំហំការងាររបស់ក្រុមប្រឹក្សាជំនុំជម្រះ។ ប្រាក់ទាំងនេះមិនអាចបន្ថយទេ ក្នុងអំឡុងអាណត្តិកាន់តំណែង។

៦. ប្រាក់បៀវត្សរបស់មន្ត្រីកាន់បញ្ជីត្រូវកំណត់ក្នុងកិច្ចប្រជុំរបស់រដ្ឋភាគី តាមសំណើរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

៧. បទបញ្ញត្តិដែលអនុម័តក្នុងកិច្ចប្រជុំរដ្ឋភាគី ត្រូវកំណត់លក្ខខណ្ឌដែលអាចបង់ប្រាក់សោធនិវត្តន៍ដល់ សមាជិកក្រុមប្រឹក្សាជំនុំជម្រះ និងដល់បញ្ជីកា និងលក្ខខណ្ឌដែលត្រូវបង់សងថ្លៃធ្វើដំណើរឱ្យសមាជិកក្រុមប្រឹក្សាជំនុំជម្រះ និងបញ្ជីកា វិញ។

៨. ប្រាក់បៀវត្ស ការបែងចែកភាគលាភ និងលាភការ មិនត្រូវជាប់ពន្ធទាំងអស់។

*មាត្រា ១៩*

*ការចំណាយរបស់ក្រុមប្រឹក្សាជំនុំជម្រះ*

១. ការចំណាយរបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវទទួលបន្ទុកដោយរដ្ឋភាគី និងដោយអាជ្ញាធរ តាមលក្ខខណ្ឌ និងវិធី ដែលត្រូវសម្រេចក្នុងកិច្ចប្រជុំរដ្ឋភាគី។

២. នៅពេលអង្គភាពមួយ ក្រៅពីរដ្ឋភាគី ឬអាជ្ញាធរ ក្លាយជាភាគីនៃរឿងក្តីដែលបញ្ជូនមកក្រុមប្រឹក្សាជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះនឹងកំណត់ចំនួនប្រាក់ដែលភាគីនោះត្រូវចូលរួមចំណែកបង់លើការចំណាយរបស់ក្រុម ប្រឹក្សាជំនុំជម្រះ។

ជំពូកទី២៖ យុត្តាធិការ

*មាត្រា ២០*

*លទ្ធភាពប្រើប្រាស់ក្រុមប្រឹក្សាជំនុំជម្រះ*

១. ក្រុមប្រឹក្សាជំនុំជម្រះត្រូវបើកចំហរចំពោះរដ្ឋភាគី។

២. ក្រុមប្រឹក្សាជំនុំជម្រះត្រូវបើកចំហរចំពោះអង្គភាពនានា ក្រៅពីរដ្ឋភាគី ក្នុងរឿងក្តីណាមួយដែលចែងច្បាស់ក្នុងផ្នែកទី១១ ឬក្នុងរឿងក្តីណាមួយ ដែលបញ្ជូនមកក្រុមប្រឹក្សាជំនុំជម្រះអនុលោមតាមការព្រមព្រៀងដទៃទៀតដែលផ្តល់ដែនយុត្តាធិការដល់ក្រុមប្រឹក្សាជំនុំជម្រះ ដែលទទួលយកដោយភាគីនៃវិវាទទាំងអស់។

*មាត្រា ២១*

*យុត្តាធិការ*

១. យុត្តាធិការរបស់ក្រុមប្រឹក្សាជំនុំជម្រះមានលើវិវាទ និងពាក្យទាំងអស់ដែលបញ្ជូនមកក្រុមប្រឹក្សាជំនុំជម្រះ អនុលោមតាមអនុសញ្ញានេះ និងរាល់បញ្ហាទាំងអស់ ដែលចែងជាក់លាក់ក្នុងកិច្ចព្រមព្រៀងណាមួយ ដែលផ្តល់ដែនយុត្តាធិការដល់ក្រុមប្រឹក្សាជំនុំជម្រះ។

*មាត្រា ២២*

*ការលើកឡើងពីវិវាទដែលស្ថិតក្រោមលក្ខខណ្ឌកិច្ចព្រមព្រៀងដទៃទៀត*

ប្រសិនបើភាគីទាំងអស់នៃសន្ធិសញ្ញា ឬអនុសញ្ញា ដែលចូលជាធរមានរួចហើយ និងដែលពាក់ព័ន្ធនឹង កម្មវត្ថុដែលចែងក្នុងអនុសញ្ញានេះ មានការព្រមព្រៀង នោះវិវាទណាមួយដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តសន្ធិសញ្ញា ឬអនុសញ្ញានោះ អាចបញ្ជូនមកក្រុមប្រឹក្សាជំនុំជម្រះបាន អនុលោមតាមការព្រមព្រៀងនោះ។

*មាត្រា ២៣*

*ច្បាប់អនុវត្តន៍*

ក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើវិវាទ និងពាក្យសុំទាំងអស់ អនុលោមតាមមាត្រា ២៩៣។

ជំពូកទី៣៖ នីតិវិធី

*មាត្រា ២៤*

*ការផ្តួចផ្តើមនីតិវិធី*

១. វិវាទត្រូវបញ្ជូនមកក្រុមប្រឹក្សាជំនុំជម្រះ តាមករណីជាក់ស្តែង តាមសេចក្តីជូនដំណឹងពីកិច្ចព្រមព្រៀងពិសេស ឬ តាមពាក្យសុំជាលាយលក្ខណ៍អក្សរ ដោយផ្ញើទៅមន្ត្រីកាន់បញ្ជី។ ក្នុងករណីមួយណាក៏ដោយ កម្មវត្ថុ និងភាគីត្រូវ ចង្អុលបង្ហាញឱ្យដឹង។

២. មន្ត្រីកាន់បញ្ជីត្រូវជូនដំណឹងភ្លាមៗពីកិច្ចព្រមព្រៀងពិសេស ឬពាក្យសុំដល់អ្នកពាក់ព័ន្ធទាំងអស់។

៣. បញ្ជីកាក៏ត្រូវជូនដំណឹងរដ្ឋភាគីទាំងអស់។

*មាត្រា ២៥*

*វិធានច្បាប់ការបណ្តោះអាសន្ន*

១. អនុលោមតាមមាត្រា ២៩០ ក្រុមប្រឹក្សាជំនុំជម្រះ និងសភាវិវាទបាតសមុទ្រ ត្រូវមានសិទ្ធិអំណាចកំណត់ វិធានច្បាប់ការបណ្តោះអាសន្ន។

២. ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះមិនជួបប្រជុំ ឬមិនមានចំនួនសមាជិកគ្រប់គ្រាន់ដើម្បីបង្កើតកូរ៉ុមទេនោះ វិធានច្បាប់ការ

បណ្តោះអាសន្នត្រូវកំណត់ដោយសភាវិវាទនៃនីតិវិធីសង្ខេប ដែលបង្កើតឡើងតាម កថាខណ្ឌទី ៣ មាត្រា ១៥ នៃឧបសម្ព័ន្ធនេះ។ បើទោះបីមានចែងក្នុងមាត្រា ១៥ កថាខណ្ឌទី ៤ នៃឧបសម្ព័ន្ធនេះ វិធានច្បាប់ការបណ្តោះអាសន្ន អាចអនុម័តបាន តាមសំណើរបស់ភាគីណាមួយនៃវិវាទ។ វិធានច្បាប់ការបណ្តោះអាសន្ននោះត្រូវស្ថិតក្រោមការត្រួត ពិនិត្យ និងកែតម្រូវដោយក្រុមប្រឹក្សាជំនុំជម្រះ។

*មាត្រា ២៦*

*សវនាការ*

១. សវនាការត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធាន ឬអនុប្រធាន ប្រសិនបើប្រធានមិនអាចធ្វើជាអធិបតីបានទេ។ ប្រសិនបើប្រធាន និងអនុប្រធានមិនអាចធ្វើជាអធិបតីបាន ចៅក្រមជាន់ខ្ពស់នៃក្រុមប្រឹក្សាជំនុំជម្រះត្រូវធ្វើ ជាអធបតី។

២. សវនាការត្រូវធ្វើជាសាធារណៈ ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះមិនសម្រេចផ្សេងទេនោះ ឬប្រសិនបើភាគីមិនទាម ទារកុំឱ្យសាធារណៈចូលរួមទេនោះ។

*មាត្រា ២៧*

*ដំណើរការក្តី*

ក្រុមប្រឹក្សាជំនុំជម្រះត្រូវចេញដីកាសម្រាប់ដំណើរការក្តី ត្រូវសម្រេចទម្រង់ និងពេលវេលា ដែលភាគីនីមួយៗត្រូវ សន្និដ្ឋានការអះអាងរបស់ខ្លួន និងធ្វើការរៀបចំពាក់ព័ន្ធនឹងការទទួលភស្តុតាង។

*មាត្រា ២៨*

*ការខកខាន*

នៅពេលភាគីម្ខាងមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ ឬខកខានមិនបានការពារក្តីរបស់ខ្លួន ភាគី ម្ខាងទៀតអាចស្នើសុំក្រុមប្រឹក្សាជំនុំជម្រះបន្តនីតិវិធី និងចេញសេចក្តី សម្រេច។ អវត្តមានរបស់ភាគី ឬការខកខានរបស់ភាគី ក្នុងការការពារក្តី មិនត្រូវបង្កើតជាឧបសគ្គដល់នីតិវិធីទេ។ មុនពេលចេញសេចក្តីសម្រេច ក្រុមប្រឹក្សាជំនុំជម្រះត្រូវបំពេញ លក្ខខណ្ឌផ្ទាល់ខ្លួន គឺក្រុមប្រឹក្សាជំនុំជម្រះមានយុត្តាធិការលើវិវាទ និងការទាមទារមានមូលដ្ឋានច្បាស់លាស់លើអង្គហេតុ និងអង្គច្បាប់។

*មាត្រា ២៩*

*សម្លេងភាគច្រើនសម្រាប់សេចក្ដីសម្រេច*

១.

រាល់បញ្ហាទាំងអស់ត្រូវសម្រេចដោយសមាជិកភាគច្រើននៃក្រុមប្រឹក្សាជំនុំជម្រះដែលមានវត្តមាន
។

២. ក្នុងករណីមានសម្លេងស្មើគ្នា ប្រធាន ឬសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះដែលជំនួសប្រធានត្រូវបោះឆ្នោតសម្រេច។

*មាត្រា ៣០*

*សេចក្ដីសម្រេច*

១. សេចក្ដីសម្រេចត្រូវចែងពីមូលហេតុដែលជាមូលដ្ឋាននៃសេចក្ដីសម្រេច។

២.

សេចក្ដីសម្រេចត្រូវមានសរសេរឈ្មោះសមាជិកក្រុមប្រឹក្សាជំនុំជម្រះដែលចូលរួមធ្វើសេចក្ដីសម្រេច
។

៣.

ប្រសិនបើសេចក្ដីសម្រេចមិនមែនជាមតិយោបល់ឯកច្ឆន្ទរបស់សមាជិកក្រុមប្រឹក្សាជំនុំជម្រះទេនោះ ទោះទាំងមូល ឬផ្នែកទីណាមួយក្ដី សមាជិកត្រូវមានសិទ្ធិលើកឡើងពីមតិយោបល់ដោយឡែក។

៤. សេចក្ដីសម្រេចត្រូវចុះហត្ថលេខាដោយប្រធាន និងបញ្ជីកា។ សេចក្ដីសម្រេចត្រូវអានដោយបើកចំហរ ដោយបានជូនដំណឹងត្រឹមត្រូវដល់ភាគីវិវាទ។

*មាត្រា ៣១*

*សំណើសុំអន្តរាគមន៍*

១.	ប្រសិនបើរដ្ឋភាគីមួយយល់ថា ខ្លួនមានផលប្រយោជន៍ច្បាប់ដែលអាចប៉ះពាល់ដោយសារសេចក្តីសម្រេច លើវិវាទ ខ្លួនអាចដាក់សំណើសុំការអនុញ្ញាតពីក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីធ្វើអន្តរាគមន៍។

២.	ក្រុមប្រឹក្សាជំនុំជម្រះជាអ្នកសម្រេចលើសំណើនោះ។

៣.	ប្រសិនបើសំណើសុំអន្តរាគមន៍ត្រូវបានអនុញ្ញាត សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះទាក់ទងនឹងវិវាទ ត្រូវចងកាតព្វកិច្ចលើរដ្ឋភាគីដែលធ្វើអន្តរាគមន៍នោះ ដរាបណាវាពាក់ព័ន្ធនឹងបញ្ហាដែលរដ្ឋភាគីបានស្នើសុំធ្វើអន្តរាគមន៍។

*មាត្រា ៣២*

*សិទ្ធិធ្វើអន្តរាគមន៍ក្នុងករណីបកស្រាយ ឬអនុវត្ត*

១.	នៅពេលណាមានការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ មន្ត្រីកាន់បញ្ជីត្រូវជូនដំណឹងរដ្ឋភាគីទាំងអស់ ភ្លាមៗ។

២.	អនុលោមតាមមាត្រា ២១ និង ២២ នៃឧបសម្ព័ន្ធនេះ នៅពេលណាមានការបកស្រាយ ឬការអនុវត្ត កិច្ចព្រមព្រៀងអន្តរជាតិណាមួយ មន្ត្រីកាន់បញ្ជីត្រូវជូនដំណឹងភាគីទាំងអស់នៃកិច្ចព្រមព្រៀង។

៣.	ភាគីនីមួយៗ ដែលចែងក្នុងកថាខណ្ឌទី ១ និង ២ មានសិទ្ធិធ្វើអន្តរាគមន៍ក្នុងនីតិវិធី។ ប្រសិនបើខ្លួនមាន សិទ្ធិនេះ ការបកស្រាយក្នុងសេចក្តីសម្រេចនឹងត្រូវចងកាតព្វកិច្ចស្មើគ្នាលើភាគីនោះ។

*មាត្រា ៣៣*

*សេចក្តីសម្រេចស្ថាពរ និងអានុភាពចងភ្ជាប់កាតព្វកិច្ច*

១. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះជាសេចក្តីសម្រេចចុងក្រោយ
ហើយភាគីទាំងអស់នៃវិវាទត្រូវគោរពតាម។

២. សេចក្តីសម្រេចមិនមានអនុភាពចងកាតព្វកិច្ចទេ លើកលែងតែរវាងភាគីនៃវិវាទនោះ។

៣. ក្នុងករណីមានវិវាទទាក់ទងនឹងអត្ថន័យ ឬវិសាលភាពនៃសេចក្តីសម្រេច
ក្រុមប្រឹក្សាជំនុំជម្រះត្រូវបកស្រាយសេចក្តី សម្រេច តាមសំណើរបស់ភាគី។

*មាត្រា ៣៤*

*សោហ៊ុយ*

ប្រសិនបើគ្មានសម្រេចផ្សេងដោយក្រុមប្រឹក្សាជំនុំជម្រះទេនោះ ភាគីនីមួយៗត្រូវទទួលបន្ទុកសោហ៊ុយផ្ទាល់ខ្លួន។

ជំពូកទី៤៖ សភាវិវាទបាតសមុទ្រ

*មាត្រា ៣៥*

*សមាសភាព*

១. សភាវិវាទបាតសមុទ្រ ដែលចែងក្នុងមាត្រា ១៤ នៃឧបសម្ព័ន្ធនេះ ត្រូវមានសមាសភាព ១១ នាក់ ដែលជ្រើសរើសដោយសម្លេងភាគច្រើននៃសមាជិកជាប់ឆ្នោតរបស់ក្រុមប្រឹក្សាជំនុំជម្រះចេញពីចំណោមសមាជិកជាប់ ឆ្នោតទាំងនោះ។

២. ក្នុងការជ្រើសរើសសមាជិកអង្គសភា ភាពជាតំណាងនៃប្រព័ន្ធច្បាប់ចម្បងរបស់ពិភពលោក និងរបាយស្មើគ្នាតាមភូមិសាស្ត្រត្រូវបានធានា។ សភា និងអាជ្ញាធរអាចអនុម័តអនុសាសន៍ដែលមានលក្ខណៈទូទៅ ទាក់ទងនឹងភាពជាតំណាង និងរបាយភូមិសាស្ត្រនោះ។

៣. សមាជិកនៃសភាវិវាទត្រូវជ្រើសរើសរាល់ ៣ ឆ្នាំម្តង ហើយអាចជ្រើសរើសសម្រាប់អាណត្តិទី ២ បាន។

៤. សភាវិវាទត្រូវជ្រើសរើសប្រធានពីចំណោមសមាជិក ដែលនឹងកាន់តំណែងសម្រាប់អាណត្តិជ្រើសរើស សភាវិវាទ។

៥. ប្រសិនបើនីតិវិធីបណ្តឹងនៅបន្ត នៅចុងអាណត្តិ ៣ ឆ្នាំរបស់សភាវិវាទសភាវិវាទនោះត្រូវបញ្ចប់នីតិវិធី ក្នុងសមាសភាពដើមរបស់ខ្លួន។

៦. ប្រសិនបើសភាវិវាទមានតំណែងទំនេរ សភាវិវាទត្រូវជ្រើសរើសអ្នកស្នងបន្ទាប់ពីចំណោមសមាជិកជាប់ឆ្នោតរបស់ខ្លួន ដែលត្រូវកាន់តំណែងសម្រាប់រយៈពេលដែលនៅសល់របស់អ្នកកាន់តំណែងមុន។

៧. កូរ៉ុមសមាជិក ៧ នាក់ ដែលក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសរើសជាចំនួនត្រូវការដើម្បីបង្កើតសភាវិវាទ។

*មាត្រា ៣៦*

*សភាវិវាទពិសេស*

១. សភាវិវាទបាតសមុទ្រត្រូវបង្កើតសភាវិវាទពិសេស ដែលមានសមាជិក ៣ នាក់ ដើម្បីចាត់ការលើវិវាទដែលបញ្ជូនមក អនុលោមតាមមាត្រា ១៨៨ កថាខណ្ឌទី ១(ខ)។ សមាសភាពរបស់សភាវិវាទពិសេស នោះត្រូវកំណត់ដោយសភាវិវាទបាតសមុទ្រ ដោយមានការឯកភាពពីភាគី។

២. ប្រសិនបើភាគីមិនឯកភាពលើសមាសភាពរបស់សភាវិវាទពិសេសទេនោះ ភាគីនីមួយៗនៃវិវាទត្រូវ តែងតាំងសមាជិកម្នាក់ ហើយសមាជិកទី ៣ ត្រូវតែងតាំងដោយមានការព្រមព្រៀងរបស់ ភាគី។ ប្រសិនបើភាគី មិនឯកភាព ឬប្រសិនបើភាគីខកខានមិនបានតែងតាំង ប្រធានសភាវិវាទបាតសមុទ្រត្រូវធ្វើការតែងតាំងភ្លាមៗចេញពីចំណោសមាជិករបស់ខ្លួន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយនឹងភាគី។

៣. សមាជិកនៃសភាវិវាទពិសេសមិនត្រូវបម្រើ ឬជាប្រជាជននៃភាគីណាមួយក្នុងវិវាទឡើយ។

*មាត្រា ៣៧*

*លទ្ធភាពចូលរួម*

សភាវិវាទត្រូវបើកចំហរចំពោះរដ្ឋភាគី អាជ្ញាធរ និងអង្គភាពដទៃទៀត ដែលចែងក្នុងជំពូកទី ១១ ផ្នែកទី ៥។

*មាត្រា ៣៨*

*ច្បាប់អនុវត្តន៍*

បន្ថែមពីលើបញ្ញត្តិនៃមាត្រា ២៩៣ សភាវិវាទត្រូវអនុវត្ត ៖

(ក) វិធានច្បាប់ បទបញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរដែលអនុម័តអនុលោមតាមអនុសញ្ញានេះ។ និង

(ខ) លក្ខខណ្ឌនៃកិច្ចសន្យាទាក់ទងនឹងសកម្មភាពនៅតំបន់ដែលទាក់ទងនឹងកិច្ចសន្យានោះ។

*មាត្រា ៣៩*

*ការអនុវត្តសេចក្តីសម្រេចរបស់សភាវិវាទ*

សេចក្តីសម្រេចរបស់សភាវិវាទអាចយកអនុវត្ត ក្នុងទឹកដីរបស់រដ្ឋភាគី តាមរបៀបតែមួយដូចដែលសាលក្រម ឬដីការបស់តុលាការកំពូលបំផុតនៃរដ្ឋភាគីក្នុងទឹកដីដែលស្នើសុំការអនុវត្តសេចក្តីសម្រេចនេះ។

*មាត្រា ៤០*

*ការអនុវត្តផ្នែកដទៃទៀតនៃឧបសម្ព័ន្ធនេះ*

១. ផ្នែកដទៃទៀតនៃឧបសម្ព័ន្ធនេះ ដែលមិនស្របនឹងផ្នែកនេះ ត្រូវអនុវត្តចំពោះសភាវិវាទ។

២. ក្នុងការអនុវត្តមុខងារទាក់ទងនឹងយោបល់ប្រឹក្សា សភាវិវាទត្រូវដឹកនាំដោយបញ្ញត្តិនៃឧបសម្ព័ន្ធនេះ ទាក់ទងនឹងនីតិវិធីនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះដល់កម្រិតដែលសភាវិវាទទទួលស្គាល់អាចអនុវត្តបាន។

## ជំពូកទី៥៖ វិសោធនកម្ម

*មាត្រា ៤១*

*វិសោធនកម្ម*

១. រាល់វិសោធនកម្មទៅលើឧបសម្ព័ន្ធនេះ ក្រៅពីវិសោធនកម្មនៅជំពូកទី ៤ អាចនឹងធ្វើទៅបានតែតាម មាត្រា ៣១៣ ឬតាមសម្លេងគាំទ្រជាឯកឆន្ទៈនៅក្នុងសន្និសីទដែលកោះប្រជុំឡើងស្របតាមអនុសញ្ញានេះប៉ុណ្ណោះ។

២. វិសោធនកម្មលើជំពូកទី ៤ អាចនឹងធ្វើទៅបានតែស្របតាមមាត្រា ៣១៤ ប៉ុណ្ណោះ។

៣. ក្រុមប្រឹក្សាមជ្ឈត្តកម្មអាចដាក់ស្នើសុំធ្វើវិសោធនកម្មលើលក្ខន្តិកៈនេះ ក្នុងករណីចាំបាច់ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់រដ្ឋភាគីដើម្បីពិចារណាស្របតាមកថាខណ្ឌទី ១ និង ២។

## ឧបសម្ព័ន្ធ៧៖ មជ្ឈត្តកម្ម

*មាត្រា ១ ការផ្តួចផ្តើមបណ្តឹង*

ដោយអនុលោមតាមបញ្ញត្តិនៃផ្នែកទី ១៥ភាគីនៃវិវាទអាចអាចដាក់ពាក្យបណ្តឹងឱ្យមានដំណើរការជំនុំជម្រះតាមនីតិវិធីមជ្ឈត្តកម្មដូចមានចែងនៅក្នុងឧបសម្ព័ន្ធនេះដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅដល់ភាគីម្ខាងទៀត ឬ បណ្តាភាគីនៃវិវាទ។ លិខិតជូនដំណឹងនេះត្រូវអមជាមួយសេចក្តីអះអាង និងសំអាងហេតុនៃសេចក្តីអះអាងផងដែរ។

*មាត្រា ២*

*បញ្ជីឈ្មោះមជ្ឈត្តករ*

១. អគ្គលេខាធិការអង្គការសហប្រជាជាតិមានភារកិច្ចរៀបចំ និងគ្រប់គ្រងបញ្ជីឈ្មោះមជ្ឈត្តករ។ រដ្ឋភាគីនីមួយៗមានសិទ្ធិជ្រើសតាំងមជ្ឈត្តករចំនួនបួនរូប ដែលសុទ្ធតែមានបទពិសោធន៍ផ្នែកកិច្ចការសមុទ្រ និងមានកេរ្តិ៍ឈ្មោះល្អក្នុងផ្នែកយុត្តិធម៌ សមត្ថភាព និងបំពេញការងារបានល្អឥតខ្ចោះ។ ឈ្មោះបុគ្គលដែលត្រូវបានជ្រើសតាំង ត្រូវបញ្ចូលទៅក្នុងបញ្ជីឈ្មោះមជ្ឈត្តករ។

២. ប្រសិនបើនៅពេលណាមួយមជ្ឈត្តករដែលរដ្ឋភាគីមួយបានជ្រើសតាំងទៅក្នុងបញ្ជីឈ្មោះមជ្ឈត្តករមានចំនួនតិចជាងបួនរូប រដ្ឋភាគីនោះមានសិទ្ធិជ្រើសតាំងមជ្ឈត្តករបន្ថែមទៅតាមការ ចាំបាច់។

៣. ឈ្មោះរបស់មជ្ឈត្តករនឹងស្ថិតនៅលើបញ្ជីឈ្មោះជានិច្ចរហូតដល់ពេលដែលមានការដកចេញវិញដោយរដ្ឋភាគីដែលបានធ្វើការជ្រើសតាំងនោះ

ប្រសិនបើមជ្ឈត្តករូបនោះនៅតែបន្តបម្រើក្រុមប្រឹក្សាមជ្ឈត្តកម្មដែលខ្លួនត្រូវបានតែងតាំងឱ្យបម្រើការរហូតដល់ចប់នីតិវិធីនៅក្រុមប្រឹក្សាមជ្ឈត្តកម្ម។

*មាត្រា ៣*

*ការបង្កើតក្រុមប្រឹក្សាមជ្ឈត្តកម្ម*

សម្រាប់គោលបំណងនៃដំណើរការជំនុំជម្រះនៅក្រោមឧបសម្ព័ន្ធនេះ ប្រសិនបើភាគីនៃវិវាទបានពុំបានព្រមព្រៀងគ្នាផ្ទុយពីនេះទេនោះក្រុមប្រឹក្សាមជ្ឈត្តកម្មនឹងត្រូវបង្កើតឡើងស្របតាមលក្ខខណ្ឌខាងក្រោម ៖

(ក) ក្រុមប្រឹក្សាមជ្ឈត្តកម្មត្រូវមានសមាជិក ៥ រូប លើកលែងតែក្នុងករណីដូចមានចែងនៅក្នុងកថាខណ្ឌរង (ឆ) ។

(ខ) ភាគីដើមបណ្ដឹងត្រូវតែងតាំងសមាជិកមួយរូប ដែលជាការប្រសើរត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះ ដែលមានចែងនៅក្នុងមាត្រា ២ នៃឧបសម្ព័ន្ធនេះ ដែលមជ្ឈត្តករូបនេះក៏អាចជាពលរដ្ឋរបស់ខ្លួន បានផងដែរ។ ការតែងតាំងនេះត្រូវបញ្ចូលទៅក្នុងលិខិតជូនដំណឹងដែលមានចែងនៅក្នុង មាត្រា ១ នៃឧបសម្ព័ន្ធនេះ។

(គ) នៅក្នុងរយៈពេល ៣០ ថ្ងៃក្រោយពីបានទទួលលិខិតជូនដំណឹងដែលមានចែងនៅក្នុងមាត្រា ១ នៃ ឧបសម្ព័ន្ធនេះ ភាគីម្ខាងទៀតនៃវិវាទត្រូវតែងតាំងសមាជិកមួយរូប ដែលជាការប្រសើរត្រូវជ្រើស រើសចេញពីបញ្ជីឈ្មោះមជ្ឈត្តករ ដែលអាចក៏ជាពលរដ្ឋរបស់ខ្លួនបានផងដែរ។ ប្រសិនបើពុំមានការ តែងតាំងសមាជិកនៅក្នុងរយៈពេលនេះទេ ភាគីដើមបណ្ដឹងអាចស្នើសុំឱ្យមានការតែងតាំងនេះតាម កថាខណ្ឌរង (ង) នៅក្នុងរយៈពេលពីរសប្ដាហ៍ក្រោយពេលផុតកំណត់រយៈពេលខាងលើ។

(ឃ) ចំណែកសមាជិកបីរូបផ្សេងទៀត នឹងត្រូវតែងតាំងឡើងដោយផ្អែកលើការព្រមព្រៀងគ្នារវាងគូ ភាគី។ ជាការប្រសើរពួក គេនឹងត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះមជ្ឈត្តករ

ប៉ុន្តែពួកគេត្រូវតែជា ពលរដ្ឋរបស់រដ្ឋទីបី លើកលែងតែគូភាគីបានព្រមព្រៀងគ្នាផ្ទុយពីនេះ។ គូភាគីនៃវិវាទត្រូវតែងតាំងប្រធានក្រុមប្រឹក្សាមជ្ឈត្តកម្មចេញពីក្នុងចំណោមសមាជិកទាំងបីរូបនេះ។ ប្រសិនបើនៅក្នុងរយៈ ពេល ៦០ ថ្ងៃក្រោយពីទទួលបានលិខិតជូនដំណឹងដែលមានចែងនៅក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ គូភាគីមិនអាចឈានដល់ការព្រមព្រៀងគ្នាលើការតែងតាំងសមាជិកមួយរូប ឬច្រើនរូបនៃក្រុមប្រឹក្សា ដែលត្រូវតែងតាំងតាមរយៈការព្រមព្រៀង ឬទៅលើការតែងតាំងប្រធានក្រុមប្រឹក្សា នោះរាល់ការតែងតាំងនៅសេសសល់នឹងត្រូវធ្វើឡើងស្របតាមកថាខណ្ឌរង (ង) នៅពេលមាន សំណើពីភាគីណាមួយនៃវិវាទ។ សំណើនេះត្រូវធ្វើឡើងនៅក្នុងរយៈពេលពីរសប្តាហ៍ក្រោយពេលផុត កំណត់រយៈពេល ៦០ ថ្ងៃខាងលើ។

(ង) ប្រសិនបើគូភាគីមិនបានព្រមព្រៀងគ្នាថា រាល់ការតែងតាំងនៅក្រោមកថាខណ្ឌរង (គ) និង (ឃ) ត្រូវធ្វើឡើងដោយបុគ្គលមួយរូប ឬរដ្ឋទីបីដែលជ្រើសរើសដោយគូភាគីទេ នោះប្រធានក្រុមប្រឹក្សា អន្តរជាតិទទួលបន្ទុកច្បាប់ស្តីពីសមុទ្រ ត្រូវធ្វើការតែងតាំងចាំបាច់ទាំងនេះ។ ប្រសិនបើប្រធានក្រុមប្រឹក្សាពុំអាចធ្វើការតែងតាំងនៅក្រោម កថាខណ្ឌរងនេះ ឬជាពលរដ្ឋនៃភាគីមួយនៃវិវាទ នោះការតែងតាំងនឹងត្រូវធ្វើឡើងដោយសមាជិកជាន់ខ្ពស់បន្ទាប់នៃក្រុមប្រឹក្សាអន្តរជាតិទទួលបន្ទុកច្បាប់ ស្តីពីសមុទ្រដែលអាចធ្វើការតែងតាំងបាន និងមិនមែនជាពលរដ្ឋនៃភាគីនៃវិវាទ។ រាល់ការតែងតាំង នៅក្រោមកថាខណ្ឌរងនេះ ត្រូវជ្រើសចេញពីបញ្ជីឈ្មោះមជ្ឈត្តករដែលមានចែងនៅក្នុងមាត្រា ២ នៃឧបសម្ព័ន្ធនេះ នៅក្នុងរយៈពេល ៣០ ថ្ងៃក្រោយពីទទួលបានសំណើពីភាគីណាមួយនៃវិវាទ និង ដោយមានការពិគ្រោះយោបល់ជាមួយគូភាគីនៃវិវាទ។

សមាជិកដែលត្រូវបានតែងតាំងឡើង ត្រូវ មានសញ្ជាតិផ្សេងៗគ្នា និងមិនត្រូវធ្វើការឱ្យ ឬរស់នៅជាអចិន្ត្រៃយ៍នៅក្នុងដែនដីរបស់ភាគីនៃវិវាទ ឬមិនមែនជាពលរដ្ឋរបស់ភាគីនៃវិវាទឡើយ។

(ច)

រាល់មុខតំណែងទំនេរនឹងត្រូវបំពេញតាមនីតិវិធីដែលបានកំណត់សម្រាប់ការតែងតាំងនាលើកដំបូង។

(ឆ) បណ្ដាភាគីដែលមានផលប្រយោជន៍រួមគ្នា ត្រូវព្រមព្រៀងគ្នាតែងតាំងសមាជិកមួយរូបសម្រាប់ក្រុមប្រឹក្សា។ ក្នុងករណីដែលមានភាគីច្រើនមានផលប្រយោជន៍ដាច់ដោយឡែកពីគ្នា ឬក្នុងករណីដែលមិនមានការឯកភាពគ្នាទាក់ទងនឹងថាតើជាផលប្រយោជន៍រួមគ្នា ឬយ៉ាងណានោះ ភាគីនីមួយៗ ត្រូវតែងតាំងសមាជិកមួយរូបម្នាក់សម្រាប់ក្រុមប្រឹក្សា។ ចំនួនសមាជិកក្រុមប្រឹក្សាមជ្ឈត្តកម្មដែល ត្រូវបានតែងតាំងដាច់ដោយឡែកដោយភាគីនីមួយៗ ត្រូវតែមានចំនួនតិចជាងសមាជិកក្រុមប្រឹក្សា ដែលត្រូវបានតែងតាំងរួមគ្នាចំនួនមួយរូប។

(ជ) នៅក្នុងវិវាទដែលពាក់ព័ន្ធភាគីចាប់ពីពីរឡើង ត្រូវអនុវត្តបញ្ញត្តិនៃកថាខណ្ឌរង (ក) ដល់ (ច) ក្នុង កម្រិតខ្ពស់បំផុតជាអតិបរមា។

*មាត្រា ៤*

*មុខងាររបស់ក្រុមប្រឹក្សាមជ្ឈត្តកម្ម*

ក្រុមប្រឹក្សាមជ្ឈត្តកម្មដែលត្រូវបានបង្កើតឡើងនៅក្រោមមាត្រា ៣ នៃឧបសម្ព័ន្ធនេះ ត្រូវមានមុខងារដែល អនុលោមតាមឧបសម្ព័ន្ធនេះ និងរាល់បញ្ញត្តិផ្សេងៗនៃអនុសញ្ញានេះ។

*មាត្រា ៥*

*នីតិវិធី*

ក្រុមប្រឹក្សាមជ្ឈត្តកម្មត្រូវកំណត់នូវនីតិវិធីរបស់ខ្លួន ដោយធានាថា ភាគីនីមួយៗមានឱកាសពេញលេញ ក្នុងការបញ្ចេញយោបល់ និងថ្លែងការណ៍អំពីករណីរបស់ពួកគេ លើកលែងតែគូភាគីនៃវិវាទបានព្រមព្រៀងគ្នាផ្ទុយពីនេះ។

*មាត្រា ៦*

*ភារកិច្ចរបស់ភាគីវិវាទ*

ភាគីនៃវិវាទត្រូវសម្របសម្រួលការងាររបស់ក្រុមប្រឹក្សាមជ្ឈត្តកម្មឱ្យដំណើរការបានល្អ ហើយជាពិសេសត្រូវ អនុវត្តនូវចំណុចខាងក្រោម ដោយគោរពតាមច្បាប់របស់ខ្លួន និងប្រើប្រាស់រាល់មធ្យោបាយដែលខ្លួនមាន ៖

(ក)ផ្តល់ឱ្យក្រុមប្រឹក្សានូវរាល់ឯកសារ សម្ភារ និងព័ត៌មានពាក់ព័ន្ធទាំងអស់។ និង

(ខ) អនុញ្ញាតឱ្យក្រុមប្រឹក្សាកោះហៅសាក្សី ឬអ្នកជំនាញការ ប្រមូលភស្តុតាង និងអាចចុះត្រួតពិនិត្យនៅតំបន់ដែលពាក់ព័ន្ធនឹងករណីវិវាទបាន។

*មាត្រា ៧*

*ការចំណាយផ្សេងៗ*

បណ្តាភាគីនៃវិវាទត្រូវរ៉ាប់រងស្មើៗគ្នាលើការចំណាយផ្សេងៗរបស់ក្រុមប្រឹក្សា រាប់បញ្ចូលទាំងលាភការ សម្រាប់សមាជិករបស់ភាគីនីមួយៗផងដែរ លើកលែងតែក្រុមប្រឹក្សាមជ្ឈត្តកម្មបានសម្រេចផ្ទុយពីនេះទៅតាមករណី ជាក់ស្តែងនីមួយៗ។

*មាត្រា ៨*

*សម្លេងភាគច្រើនសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត*

សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាមជ្ឈត្តកម្ម ត្រូវធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើនរបស់សមាជិក ក្រុមប្រឹក្សាមជ្ឈត្តកម្ម។ អវត្តមាន ឬការបោះសម្លេងឆ្នោតអនុប្បវាទដោយសមាជិកក្រុមប្រឹក្សាមិនដល់ចំនួនពាក់ កណ្តាល នឹងមិនបង្កជាឧបសគ្គរារាំងក្រុមប្រឹក្សាមិនឱ្យធ្វើសេចក្តីសម្រេចចិត្តនោះទេ។ ក្នុងករណីសម្លេងឆ្នោតស្មើគ្នានោះប្រធានក្រុមប្រឹក្សានេះនឹងមានសម្លេងឆ្នោតឧត្តមានុភាព។

*មាត្រា ៩*

*កំហុសនៃការមិនចូលបង្ហាញខ្លួន*

ប្រសិនបើភាគីណាមួយនៃវិវាទមិនបានចូលបង្ហាញខ្លួនចំពោះមុខក្រុមប្រឹក្សាមជ្ឈត្តកម្ម ឬមិនបានមកការពារ ករណីរបស់ខ្លួន នោះភាគីម្ខាងទៀតអាចស្នើសុំឱ្យក្រុមប្រឹក្សានេះបន្តដំណើរការជំនុំជម្រះ និងចេញសេចក្តីសម្រេច។ ក្នុងករណីភាគីណាមួយអវត្តមាន ឬមិនបានមកការពារករណីរបស់ខ្លួន នឹងមិនបង្កជាឧបសគ្គរារាំងក្រុមប្រឹក្សាក្នុងការ បន្តដំណើរការជំនុំជម្រះឡើយ។ នៅមុនពេលធ្វើសេចក្តីសម្រេច ក្រុមប្រឹក្សាមជ្ឈត្តកម្មត្រូវធានាចំពោះខ្លួនឯងថា ខ្លួនមិនត្រឹមតែមានយុត្តាធិការលើវិវាទប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវធានាផងដែរថា សេចក្តីអះអាងមាននៅក្នុងអង្គហេតុ និងអង្គច្បាប់។

*មាត្រា ១០*

*សេចក្តីសម្រេច*

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាមជ្ឈត្តកម្ម ត្រូវផ្តោតតែទៅលើកម្មវត្ថុនៃវិវាទប៉ុណ្ណោះ និងត្រូវបញ្ជាក់ពី មូលហេតុនៃសេចក្តីសម្រេចនេះ។ សេចក្តីសម្រេចត្រូវដាក់ឈ្មោះរបស់សមាជិកដែលបានចូលរួម និងកាលបរិច្ឆេទធ្វើ សេចក្តីសម្រេច។ សមាជិកនៃក្រុមប្រឹក្សាមជ្ឈត្តកម្មអាចភ្ជាប់នូវមតិដោយឡែក ឬមតិជំទាស់របស់ខ្លួននៅក្នុងសេចក្តីសម្រេចនេះបានផងដែរ។

*មាត្រា ១១*

*សេចក្តីសម្រេចស្ថាពរ*

សេចក្តីសម្រេចមានលក្ខណៈស្ថាពរដោយពុំមានការប្តឹងឧទ្ធរណ៍ណាមួយឡើយ លើកលែងតែភាគីនៃវិវាទបាន ព្រមព្រៀងគ្នាទទួលយកនីតិវិធីប្តឹងឧទ្ធរណ៍ជាមុន។ គូភាគីនៃវិវាទត្រូវគោរពអនុវត្តសេចក្តីសម្រេចនេះ។

*មាត្រា ១២*

*ការបកស្រាយ ឬការអនុវត្តសេចក្តីសម្រេច*

១. ភាគីនីមួយៗអាចបញ្ជូនករណីនៃការខ្វែងគំនិតគ្នាដែលអាចនឹងកើតឡើងរវាងគូភាគីនៃវិវាទដែលទាក់ទងនឹងការបកស្រាយ ឬលក្ខណៈនៃការអនុវត្តសេចក្តីសម្រេចទៅកាន់ក្រុមប្រឹក្សាមជ្ឈត្តកម្មដើម្បីជំនះជុំរះសេចក្តី។ សម្រាប់គោលបំណងនេះ រាល់មុខតំណែងទំនេរនៅក្នុងក្រុមប្រឹក្សានេះ នឹងត្រូវបំពេញវិញតាមរបៀបដែលមានចែង ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សានាលើកដំបូង។

២. ការខ្វែងគំនិតគ្នានេះអាចនឹងត្រូវបញ្ជូនទៅកាន់តុលាការ ឬក្រុមប្រឹក្សាមជ្ឈត្តកម្មផ្សេងៗទៀត ស្រប តាមមាត្រា ២៨៧ តាមរយៈការព្រមព្រៀងគ្នានៃបណ្តាភាគីវិវាទ។

*មាត្រា ១៣*

*ការអនុវត្តចំពោះនីតិបុគ្គលក្រៅពីរដ្ឋភាគី*

បញ្ញត្តិនៃឧបសម្ព័ន្ធនេះ រួមទាំងរាល់វិសោធនកម្មទាំងឡាយ នឹងត្រូវអនុវត្តចំពោះរាល់ករណីវិវាទដែលពាក់ព័ន្ធនឹងនីតិបុគ្គលក្រៅពីរដ្ឋភាគីផងដែរ។

## ឧបសម្ព័ន្ធ៨៖ មជ្ឈត្តកម្មពិសេស

*មាត្រា ១*

*ការផ្តួចផ្តើមបណ្តឹង*

ដោយអនុលោមតាមបញ្ញត្តិនៃផ្នែកទី ១៥ភាគីនៃវិវាទដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តមាត្រា នៃអនុសញ្ញានេះ ដែលទាក់ទងនឹងផ្នែក (១) ជលផល (២) ការការពារ និងការអភិរក្សបរិស្ថានសមុទ្រ (៣) ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ឬ (៤) ការធ្វើនាវាចរណ៍ រាប់បញ្ចូលទាំងការបំពុលពីនាវា និងការបំពុលដោយ ការចាក់ចោលកាកសំណល់ អាចដាក់ពាក្យបណ្តឹងឱ្យមានដំណេរការជំនុំជម្រះតាមនីតិវិធីមជ្ឈត្តកម្មពិសេស ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅដល់ភាគីម្ខាងទៀត ឬបណ្តាភាគីនៃវិវាទ។ លិខិតជូនដំណឹងនេះត្រូវអមជាមួយសេចក្តីអះអាង និងសំអាងហេតុនៃសេចក្តីអះអាងផងដែរ។

*មាត្រា ២*

*បញ្ជីឈ្មោះអ្នកជំនាញការ*

១. បញ្ជីឈ្មោះអ្នកជំនាញការ នឹងត្រូវបង្កើតឡើង និងគ្រប់គ្រងទៅតាមផ្នែកនីមួយៗ រួមមាន (១) ជលផល (២) ការការពារ និងការអភិរក្សបរិស្ថានសមុទ្រ (៣) ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ឬ (៤) ការធ្វើនាវាចរណ៍ រាប់បញ្ចូលទាំងការបំពុលពីនាវា និងការបំពុលដោយការចាក់ចោលកាកសំណល់។

២. បញ្ជីឈ្មោះអ្នកជំនាញការ នឹងត្រូវរៀបចំ និងគ្រប់គ្រងដោយអង្គការស្បៀងអាហារ និងកសិកម្មនៃ អង្គការសហប្រជាជាតិទទួលបន្ទុកវិស័យជលផល អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិទទួលបន្ទុក វិស័យការពារ និងអភិរក្សបរិស្ថានសមុទ្រ គណៈកម្មាការអន្តររដ្ឋាភិបាលទទួលបន្ទុកភូមិសាស្ត្រមហាសមុទ្រ

សម្រាប់ផ្នែកការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ និងអង្គការសមុទ្រអន្តរជាតិ សម្រាប់ផ្នែកការធ្វើនាវាចរណ៍ រាប់បញ្ចូលទាំងការបំពុល ពីនាវា និងការបំពុលដោយការចាក់ចោលកាក សំណល់ ឬនៅក្នុងករណីជាក់ស្តែងនីមួយៗ បញ្ជីឈ្មោះនេះនឹង ត្រូវរៀបចំ និងគ្រប់គ្រងដោយស្ថាប័នក្រោមបង្គាប់ពាក់ព័ន្ធ ដែលទទួលបានសិទ្ធិប្រតិភូកម្ម ពីអង្គការកម្មវិធី ឬ គណៈកម្មាការខាងលើឱ្យទទួលអនុវត្តមុខងារនេះ។

៣. រដ្ឋភាគីនីមួយៗមានសិទ្ធិជ្រើសតាំងអ្នកជំនាញការចំនួនពីររូបសម្រាប់ផ្នែកនីមួយៗ ដែលមានសមត្ថភាព ខាងផ្លូវច្បាប់ វិទ្យាសាស្ត្រ ឬបច្ចេកទេសលើផ្នែកខាងលើត្រូវបានទទួលស្គាល់ជាទូទៅ និងដែលមានកេរ្តិ៍ឈ្មោះល្អ ក្នុងផ្នែកយុត្តិធម៌ និងបំពេញការងារបានល្អឥតខ្ចោះ។ ឈ្មោះបុគ្គលដែលត្រូវបានជ្រើសតាំងសម្រាប់ផ្នែកនីមួយៗ ត្រូវបញ្ចូលទៅក្នុងបញ្ជីឈ្មោះដែលសមស្រប។

៤. ប្រសិនបើនៅពេលណាមួយអ្នកជំនាញការដែលរដ្ឋភាគីមួយបានជ្រើសតាំងទៅក្នុងបញ្ជីឈ្មោះមានចំនួន តិច ជាងពីររូប រដ្ឋភាគីនោះមានសិទ្ធិជ្រើសតាំងបន្ថែមទៅតាមការចាំបាច់។

៥. ឈ្មោះរបស់អ្នកជំនាញការនឹងស្ថិតនៅលើបញ្ជីឈ្មោះជានិច្ច រហូតដល់ពេលដែលមានការដកចេញវិញ ដោយរដ្ឋភាគីដែលបានធ្វើការជ្រើសតាំងនោះ ប្រសិនបើអ្នកជំនាញការរូបនោះនៅតែបន្តបម្រើក្រុមប្រឹក្សាមជ្ឈត្តកម្ម ពិសេសដែលខ្លួនត្រូវបានតែងតាំងឱ្យបម្រើការរហូតដល់ចប់នីតិវិធីនៅក្រុមប្រឹក្សាមជ្ឈត្តកម្មពិសេស។

*មាត្រា ៣*

*ការបង្កើតក្រុមប្រឹក្សាមជ្ឈត្តកម្មពិសេស*

សម្រាប់គោលបំណងនៃដំណើរការជំនុំជម្រះសេចក្តីនៅក្រោមឧបសម្ព័ន្ធនេះ ប្រសិនបើភាគីនៃវិវាទបានពុំ បានព្រមព្រៀងគ្នាផ្ទុយពីនេះទេ នោះក្រុមប្រឹក្សាមជ្ឈត្តកម្មពិសេសនឹងត្រូវបង្កើតឡើងស្របតាមលក្ខខណ្ឌខាងក្រោម ៖

(ក) ក្រុមប្រឹក្សាមជ្ឈត្តកម្មពិសេសត្រូវមានសមាជិក ៥ រូប លើកលែងតែក្នុងករណីដូចមានចែងនៅក្នុង កថាខណ្ឌរង (ឆ) ។

(ខ) ភាគីដើមបណ្តឹងត្រូវតែងតាំងសមាជិកពីររូប ដែលជាការប្រសើរត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះ សមស្រប ឬពីបណ្តាបញ្ជីឈ្មោះមានចែងនៅក្នុងមាត្រា ២ នៃឧបសម្ព័ន្ធនេះ ដែលទាក់ទងនឹង បញ្ហាវិវាទ ក្នុងនោះសមាជិកមួយរូបអាចជាពលរដ្ឋរបស់ខ្លួនបានផងដែរ។ ការតែងតាំងនេះ ត្រូវ បញ្ចូលទៅក្នុងលិខិតជូនដំណឹងដែលមានចែងនៅក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ។

(គ) នៅក្នុងរយៈពេល ៣០ ថ្ងៃក្រោយពីបានទទួលលិខិតជូនដំណឹងដែលមានចែងនៅក្នុងមាត្រា ១ នៃ ឧបសម្ព័ន្ធនេះ ភាគីម្ខាងទៀតនៃវិវាទត្រូវតែងតាំងសមាជិកពីររូប ដែលជាការប្រសើរត្រូវជ្រើស រើសចេញពីបញ្ជីឈ្មោះសមស្រប ឬបញ្ជីឈ្មោះដែលទាក់ទងនឹងបញ្ហាវិវាទ ក្នុងនោះសមាជិកមួយ រូបក៏អាចជាពលរដ្ឋរបស់ខ្លួនបានផងដែរ។ ប្រសិនបើពុំមានការតែងតាំងសមាជិកនៅក្នុងរយៈពេល នេះទេ ភាគីដើមបណ្តឹងអាចស្នើសុំឱ្យមានការតែងតាំងនេះតាមកថាខណ្ឌរង (ង) នៅក្នុងរយៈពេល ពីរសប្តាហ៍ក្រោយពេលផុតកំណត់រយៈពេលខាងលើ។

(ឃ) ភាគីនៃវិវាទត្រូវចុះកិច្ចព្រមព្រៀងលើការតែងតាំងប្រធានក្រុមប្រឹក្សាមជ្ឈត្តកម្មពិសេស ដែលជា ការប្រសើរត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះសមស្រប ប៉ុន្តែត្រូវតែជាពលរដ្ឋរបស់រដ្ឋទីបី លើកលែង តែគូភាគីបានព្រមព្រៀងគ្នាផ្ទុយពីនេះ។ ប្រសិនបើនៅក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយពីទទួលបាន លិខិតជូនដំណឹងដែលមានចែងនៅក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ គូភាគីមិនអាចឈានដល់ការ ព្រមព្រៀងគ្នាលើការតែងតាំងប្រធានក្រុមប្រឹក្សាទេ នោះការតែងតាំងនេះ នឹងត្រូវធ្វើឡើងស្រប តាមកថាខណ្ឌរង (ង)

នៅពេលមានសំណើពីភាគីណាមួយនៃវិវាទ។ សំណើនេះត្រូវធ្វើឡើងនៅក្នុងរយៈពេលពីរសប្តាហ៍ក្រោយពេលផុតកំណត់រយៈពេល ៣០ ថ្ងៃខាងលើ។

(ង) ប្រសិនបើគូភាគីមិនបានព្រមព្រៀងគ្នាថា ការតែងតាំងខាងលើត្រូវធ្វើឡើងដោយបុគ្គលមួយរូប ឬរដ្ឋទីបីដែលជ្រើសរើសដោយគូភាគីទេ នោះអគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវធ្វើការតែងតាំងចាំបាច់ទាំងនេះនៅក្នុងរយៈពេល ៣០ ថ្ងៃក្រោយពីទទួលបានសំណើដែលមានចែងនៅ ក្នុងកថាខណ្ឌរង (គ) និង (ឃ) ។ រាល់ការតែងតាំងនៅក្រោមកថាខណ្ឌរងនេះ ត្រូវជ្រើសចេញ ពីបញ្ជីឈ្មោះសមស្រប ឬបញ្ជីឈ្មោះអ្នកជំនាញការដែលមានចែងនៅក្នុងមាត្រា ២ នៃឧបសម្ព័ន្ធ នេះ ដោយមានការពិគ្រោះយោបល់គ្នាជាមួយភាគីនៃវិវាទ និងអង្គការអន្តរជាតិដែលសមស្រប។ សមាជិកដែលត្រូវបានតែងតាំងឡើងត្រូវមានសញ្ជាតិផ្សេងៗគ្នា និងមិនត្រូវធ្វើការឱ្យ ឬរស់នៅជាអចិន្ត្រៃយ៍នៅក្នុងដែនដីរបស់ភាគីនៃវិវាទ ឬមិនមែនជាពលរដ្ឋរបស់ភាគីនៃវិវាទឡើយ។

(ច)

រាល់មុខតំណែងទំនេរនឹងត្រូវបំពេញតាមនីតិវិធីដែលបានកំណត់សម្រាប់ការតែងតាំងនាលើកដំបូង។

(ឆ) បណ្តាភាគីដែលមានផលប្រយោជន៍រួមគ្នា ត្រូវព្រមព្រៀងគ្នាតែងតាំងសមាជិកមួយរូបសម្រាប់ ក្រុមប្រឹក្សា។ ក្នុងករណីដែលមានភាគីច្រើនមានផលប្រយោជន៍ដាច់ដោយឡែកពីគ្នា ឬក្នុងករណីដែលមិនមានការឯកភាពគ្នាទាក់ទងនឹងថាតើជាផលប្រយោជន៍រួមគ្នាឬយ៉ាងណានោះ ភាគីនីមួយៗ ត្រូវតែងតាំងសមាជិកមួយរូបសម្រាប់ក្រុមប្រឹក្សា។

(ជ) នៅក្នុងវិវាទដែលពាក់ព័ន្ធភាគីចាប់ពីពីរឡើង ត្រូវអនុវត្តបញ្ញត្តិនៃកថាខណ្ឌរង (ក) ដល់ (ច) ក្នុង កម្រិតខ្ពស់បំផុតជាអតិបរមា។

*មាត្រា ៤*

*បទបញ្ញត្តិទូទៅ*

មាត្រា ៤ ដល់ ៣ នៃឧបសម្ព័ន្ធ ៧រួមទាំងរាល់វិសោធនកម្មទាំងឡាយ នឹងត្រូវអនុវត្តចំពោះរាល់ដំណើរការជំនំជម្រះនៅក្រុមប្រឹក្សាមជ្ឈត្តកម្មពិសេស ដោយអនុលោមតាមឧបសម្ព័ន្ធនេះ។

*មាត្រា ៥*

*ការស្រាវជ្រាវអង្គហេតុ*

១. ភាគីនៃវិវាទដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តបញ្ញត្តិនៃអនុសញ្ញានេះ ដែលទាក់ទងនឹងវិស័យ (១) ជលផល (២) ការការពារ និងការអភិរក្សបរិស្ថានសមុទ្រ (៣) ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ឬ (៤) ការធ្វើនាវាចរណ៍ រាប់បញ្ចូលទាំងការបំពុលពីនាវា និងការបំពុលដោយការចាក់ចោលកាកសំណល់ អាចព្រមព្រៀងគ្នាលើកសំណើសុំបង្កើតក្រុមប្រឹក្សាមជ្ឈត្តកម្មពិសេសស្របតាមមាត្រា ៣ នៃឧបសម្ព័ន្ធនេះ ដើម្បីធ្វើការសាកសួរ និងស្រាវជ្រាវអង្គហេតុដែលជាមូលហេតុនាំឱ្យកើតមានវិវាទ។

២. ការស្រាវជ្រាវអង្គហេតុរបស់ក្រុមប្រឹក្សាមជ្ឈត្តកម្មពិសេសដែលធ្វើសកម្មភាពតាមកថាខណ្ឌខាងលើ នឹងត្រូវចាត់ទុកជាលទ្ធផលស្ថាពររវាងគូភាគី លើកលែងតែគូភាគីបានព្រមព្រៀងគ្នាផ្ទុយពីនេះ។

៣. ប្រសិនបើភាគីវិវាទទាំងអស់លើកជាសំណើដូច្នេះមែន នោះក្រុមប្រឹក្សាមជ្ឈត្តកម្មពិសេសត្រូវចេញ អនុសាសន៍ ដោយអនុសាសន៍នេះពុំមានអនុភាពជាសេចក្តីសម្រេចណាមួយឡើយ គ្រាន់តែជាមូលដ្ឋានសម្រាប់ភាគីវិវាទពិនិត្យពិចារណាលើបញ្ហាដែលនាំឱ្យកើតមានវិវាទជាថ្មីឡើងវិញប៉ុណ្ណោះ។

៤. ដោយអនុលោមតាមកថាខណ្ឌទី ២ ក្រុមប្រឹក្សាមជ្ឈត្តកម្មពិសេសត្រូវធ្វើសកម្មភាពស្របតាមបញ្ញត្តិនៃឧបសម្ព័ន្ធនេះ លើកលែងតែគូភាគីបានព្រមព្រៀងគ្នាផ្ទុយពីនេះ ។

ឧបសម្ព័ន្ធ៩៖ ការចូលរួមរបស់អង្គការអន្តរជាតិ

*មាត្រា ១*

*ការប្រើប្រាស់វាក្យស័ព្ទ*

សម្រាប់គោលបំណងនៃមាត្រា ៣០៥ និងឧបសម្ព័ន្ធនេះ ឃ្លា "អង្គការអន្តរជាតិ" សំដៅដល់អង្គការអន្តររដ្ឋាភិបាលដែលបង្កើតឡើងដោយរដ្ឋជាច្រើន ហើយដែលរដ្ឋជាសមាជិកបានផ្ទេរសមត្ថកិច្ចលើការចាត់ចែងបញ្ហាដែល ស្ថិតក្រោមអនុសញ្ញានេះ រាប់ទាំងសមត្ថកិច្ចចុះសន្ធិសញ្ញាពាក់ព័ន្ធនឹងបញ្ហាទាំងនោះផងដែរ។

*មាត្រា ២*

*ហត្ថលេខា*

អង្គការអន្តរជាតិអាចចុះហត្ថលេខាលើអនុសញ្ញានេះបាន ប្រសិនបើរដ្ឋជាសមាជិកភាគច្រើនរបស់ខ្លួនគឺជា ហត្ថលេខីនៃអនុសញ្ញានេះ។ នៅពេលចុះហត្ថលេខា អង្គការអន្តរជាតិត្រូវធ្វើសេចក្តីប្រកាសបញ្ជាក់ពីរាល់បញ្ហាដែល ស្ថិតក្រោមអនុសញ្ញានេះ និងដែលសមត្ថកិច្ចពាក់ព័ន្ធនឹងបញ្ហាទាំងនេះ ត្រូវបានរដ្ឋជាសមាជិកដែលក៏ជាហត្ថលេខីនៃអនុសញ្ញាបានផ្ទេរមកឱ្យខ្លួន ព្រមទាំងបញ្ជាក់ពីលក្ខណៈ និងទំហំនៃសមត្ថកិច្ចនោះផងដែរ។

*មាត្រា ៣*

*ការបញ្ជាក់ និងការចូលរួមជាផ្លូវការ*

១. អង្គការអន្តរជាតិអាចដាក់លិខិតបញ្ជាក់ ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការ ប្រសិនបើរដ្ឋជាសមាជិក ភាគច្រើនរបស់ខ្លួនបានដាក់លិខិតស្តីពីការផ្តល់សច្ចានុម័ត ឬការចូលរួមជាហត្ថលេខីរួចហើយនោះ។

២. លិខិតដែលដាក់ដោយអង្គការអន្តរជាតិ ត្រូវរួមមានការសន្យា និងសេចក្តីប្រកាសដែលមានចែងនៅ ក្នុងមាត្រា ៤ និងមាត្រា ៥ នៃឧបសម្ព័ន្ធនេះផងដែរ។

*មាត្រា ៤*

*ទំហំនៃការចូលរួម សិទ្ធិ និងកាតព្វកិច្ច*

១. លិខិតស្តីពីការបញ្ជាក់ ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរបស់អង្គការអន្តរជាតិ ត្រូវរួមមានការ សន្យាយល់ព្រមទទួលយកសិទ្ធិ និងកាតព្វកិច្ចរបស់បណ្តារដ្ឋនៅក្រោមអនុសញ្ញានេះ ដែលទាក់ទងនឹងបញ្ហាដែលរដ្ឋ ជាសមាជិករបស់ខ្លួន និងក៏ជាភាគីនៃអនុសញ្ញានេះ បានផ្ទេរសមត្ថកិច្ចលើការចាត់ចែងមកឱ្យខ្លួន។

២. អង្គការអន្តរជាតិគឺជាភាគីមួយនៃអនុសញ្ញានេះក្នុងទំហំដែលខ្លួនមានសមត្ថកិច្ចស្របតាមសេចក្តីប្រកាស លិខិតទំនាក់ទំនងព័ត៌មាន ឬលិខិតជូនដំណឹងដែលមានចែងនៅក្នុងមាត្រា ៥ នៃឧបសម្ព័ន្ធនេះ។

៣. អង្គការអន្តរជាតិត្រូវអនុវត្តសិទ្ធិ និងបំពេញកាតព្វកិច្ចដែលបណ្តារដ្ឋជាសមាជិករបស់ខ្លួន និងក៏ជាភាគី នៃអនុសញ្ញាមាននៅក្រោមអនុសញ្ញានេះ ទាក់ទងនឹងបញ្ហាដែលរដ្ឋជាសមាជិកទាំងនោះបានផ្ទេរសមត្ថកិច្ចលើការចាត់ ចែងមកឱ្យខ្លួន។ រដ្ឋជាសមាជិកនៃអង្គការអន្តរជាតិមិនត្រូវអនុវត្តនូវសមត្ថកិច្ចដែលខ្លួនបានផ្ទេរទៅឱ្យអង្គការរួចហើយ នោះឡើយ។

៤. នៅគ្រប់ករណីទាំងអស់ ការចូលរួមរបស់អង្គការអន្តរជាតិនៅក្នុងអនុសញ្ញានេះ នឹងមិននាំឱ្យកើនឡើងនូវ ភាពជាតំណាងរបស់រដ្ឋជាសមាជិករបស់ខ្លួនដែលក៏ជារដ្ឋភាគីផងដែរនោះឡើយ រាប់បញ្ចូលទាំងសិទ្ធិក្នុងការធ្វើសេចក្តី សម្រេចចិត្តផងដែរ។

៥. នៅគ្រប់ករណីទាំងអស់ ការចូលរួមរបស់អង្គការអន្តរជាតិនៅក្នុងអនុសញ្ញានេះ នឹងមិនផ្តល់នូវសិទ្ធិ ណាមួយនៅក្រោមអនុសញ្ញានេះទៅឱ្យរដ្ឋជាសមាជិករបស់អង្គការ ដែលមិនមែនជារដ្ឋភាគីនៃអនុសញ្ញានេះឡើយ។

៦. ក្នុងករណីមានភាពផ្ទុយគ្នារវាងកាតព្វកិច្ចរបស់អង្គការអន្តរជាតិនៅក្រោមអនុសញ្ញានេះ ជាមួយនឹង កាតព្វកិច្ចរបស់អង្គការអន្តរជាតិនៅក្រោមកិច្ចព្រមព្រៀងបង្កើតអង្គការ ឬសកម្មភាពណាមួយដែលពាក់ព័ន្ធនោះ កាតព្វកិច្ចនៅក្រោមអនុសញ្ញានេះត្រូវមានឧត្តមានុភាព។

*មាត្រា ៥*

*សេចក្តីប្រកាស លិខិតជូនដំណឹង និងលិខិតទំនាក់ទំនង*

១. លិខិតស្តីពីការបញ្ជាក់ ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរបស់អង្គការអន្តរជាតិ ត្រូវមានសេចក្តី ប្រកាសបញ្ជាក់ពីរាល់បញ្ហាដែលស្ថិតក្រោមអនុសញ្ញានេះ ហើយដែលសមត្ថកិច្ចពាក់ព័ន្ធនឹងបញ្ហាទាំងនេះ ត្រូវបានរដ្ឋជាសមាជិកអង្គការដែលក៏ជាភាគីនៃអនុសញ្ញាបានផ្ទេរមកឱ្យអង្គការ។

២. រដ្ឋជាសមាជិករបស់អង្គការអន្តរជាតិត្រូវធ្វើសេចក្តីប្រកាសបញ្ជាក់ពីរាល់បញ្ហាដែលស្ថិតក្រោមអនុសញ្ញានេះ ហើយដែលសមត្ថកិច្ចពាក់ព័ន្ធនឹងបញ្ហាទាំងនេះខ្លួនបានផ្ទេរទៅឱ្យអង្គការ នៅពេលដែលខ្លួនផ្តល់សច្ចានុម័ត ឬ ចូលជាសមាជិកអនុសញ្ញានេះ ឬនៅពេលដែលអង្គការដាក់លិខិតស្តីពីការបញ្ជាក់ ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការ (ដោយកំណត់យកពេលណាមួយដែលនៅចុងគេ)។

៣. បណ្តារដ្ឋភាគីនៃអនុសញ្ញា ហើយជារដ្ឋសមាជិកនៃអង្គការអន្តរជាតិដែលក៏ជាភាគីមួយនៃអនុសញ្ញានេះ ផងដែរនោះ នឹងត្រូវសន្មត់ថាមានសមត្ថកិច្ចលើរាល់បញ្ហាដែលស្ថិតក្រោមអនុសញ្ញានេះ ទោះបីជាការផ្ទេរសមត្ថកិច្ចពាក់ព័ន្ធនឹងបញ្ហាទាំងនេះ មិនត្រូវបានរដ្ឋទាំងនោះធ្វើការប្រកាស ជូនដំណឹង ឬទំនាក់ទំនងឱ្យដឹងច្បាស់តាមមាត្រា នេះក៏ដោយ។

៤. អង្គការអន្តរជាតិ និងរដ្ឋជាសមាជិករបស់ខ្លួនដែលជារដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវជូនដំណឹងដល់ស្ថាប័ន រក្សាទុកឯកសារនៃអនុសញ្ញានេះ ឱ្យបានជ្រាបអំពីរាល់ការប្រែប្រួលនៃការបែងចែកសមត្ថកិច្ច រាប់បញ្ចូលទាំងការផ្ទេរ សមត្ថកិច្ចថ្មីៗ ដែលបានបញ្ជាក់នៅក្នុងសេចក្តីប្រកាសក្រោមកថាខណ្ឌ ១ និង ២ ផងដែរ។

៥. រដ្ឋភាគីអនុសញ្ញាមានសិទ្ធិស្នើឱ្យអង្គការអន្តរជាតិ និងរដ្ឋជាសមាជិករបស់អង្គការអន្តរជាតិដែលក៏ជារដ្ឋ ភាគីអនុសញ្ញា

ផ្តល់នូវព័ត៌មានបញ្ជាក់ថាតើអ្នកណា (រវាងអង្គការអន្តរជាតិ និងរដ្ឋជាសមាជិកអង្គការ) ជាអ្នកមានសមត្ថកិច្ចពាក់ព័ន្ធនឹងវិវាទជាក់លាក់ដែលបានកើតឡើង។ អង្គការ និងរដ្ឋជាសមាជិកដែលពាក់ព័ន្ធត្រូវផ្តល់ព័ត៌មាន នេះនៅក្នុងរយៈពេលសមស្របមួយ។ អង្គការអន្តរជាតិ និងរដ្ឋជាសមាជិករបស់អង្គការអន្តរជាតិក៏មានសិទ្ធិផ្តួចផ្តើម ផ្តល់ព័ត៌មាននេះដោយខ្លួនឯងផងដែរ។

៦. សេចក្តីប្រកាស លិខិតជូនដំណឹង និងលិខិតទំនាក់ទំនងអំពីព័ត៌មាននៅក្រោមមាត្រានេះត្រូវបញ្ជាក់ពី ស្ថានភាព និងទំហំសមត្ថកិច្ចដែលបានផ្ទេរ។

*មាត្រា ៦*

*ភារកិច្ច និងការទទួលខុសត្រូវ*

១. ភាគីដែលមានសមត្ថកិច្ចនៅក្រោមមាត្រា ៥ នៃឧបសម្ព័ន្ធនេះត្រូវទទួលខុសត្រូវលើករណីមិនបាន បំពេញកាតព្វកិច្ច ឬករណីបំពានផ្សេងៗទៀតមកលើអនុសញ្ញានេះ។

៥. រដ្ឋភាគីអនុសញ្ញាមានសិទ្ធិស្នើឱ្យអង្គការអន្តរជាតិ ឬរដ្ឋជាសមាជិករបស់អង្គការអន្តរជាតិដែលក៏ជារដ្ឋភាគី អនុសញ្ញា ផ្តល់នូវព័ត៌មានបញ្ជាក់ថាតើអ្នកណាជាអ្នកមានការទទួលខុសត្រូវពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ដែលបានលើក ឡើង។ អង្គការ និងរដ្ឋជាសមាជិកដែលពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មាននេះ។ ភាគីដែលមិនផ្តល់ព័ត៌មាននេះនៅក្នុងរយៈពេលសមស្របទេ នឹងត្រូវទទួលខុសត្រូវរួម និងដាច់ដោយឡែកពីគ្នា។

*មាត្រា ៧*

*ការដោះស្រាយវិវាទ*

១. នៅពេល ឬក្រោយពេលដែលអង្គការអន្តរជាតិបានដាក់ លិខិតស្តីពីការបញ្ជាក់ ឬការចូលរួមក្នុង អនុសញ្ញាជាផ្លូវការរួច អង្គការអន្តរជាតិមានសិទ្ធិសរសេរលិខិតជាលាយលក្ខណ៍អក្សរជ្រើសរើសយកមធ្យោបាយមួយ ឬច្រើន

ដើម្បីដោះស្រាយវិវាទដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ ដូចមានចែងនៅក្នុងមាត្រា ២៨៧ កថាខណ្ឌ ១(ក) (គ) ឬ (ឃ) ។

២. ផ្នែកទី ១៥រួមទាំងវិសោធនកម្មទាំងឡាយ នឹងត្រូវអនុវត្តចំពោះរាល់ករណីវិវាទរវាងបណ្តាភាគីនៃ អនុសញ្ញានេះ ដែលក្នុងនោះមានភាគីជាអង្គការអន្តរជាតិចាប់ពីមួយឡើងទៅ។

៣. ក្នុងករណីដែលអង្គការអន្តរជាតិមួយ និងរដ្ឋជាសមាជិករបស់ខ្លួនមួយ ឬច្រើន គឺជាភាគីរួមនៃវិវាទ ឬជាភាគីមានផលប្រយោជន៍រួម នោះអង្គការនេះនឹងត្រូវចាត់ទុកថាបានទទួលយកនីតិវិធីតែមួយសម្រាប់ដោះស្រាយ វិវាទដូចគ្នានឹងរដ្ឋជាសមាជិកផងដែរ ប៉ុន្តែ ក្នុងករណីដែលរដ្ឋជាសមាជិកសម្រេចជ្រើសរើសយកតុលាការយុត្តិធម៌ អន្តរជាតិ (ICJ)ដោយផ្អែកលើមាត្រា ២៨៧ វិញ នោះអង្គការ និងរដ្ឋជាសមាជិកដែលពាក់ព័ន្ធ នឹងត្រូវចាត់ទុកថាបានទទួលយកដំណើរការមជ្ឈត្តកម្មតាមឧបសម្ព័ន្ធ ៧លើកលែងតែបណ្តាភាគីនៃវិវាទបានព្រមព្រៀងគ្នាផ្ទុយពីនេះ។

*មាត្រា ៨*

*ភាពអាចអនុវត្តបាននៃផ្នែកទី ១៧*

ផ្នែកទី ១៧រួមទាំងវិសោធនកម្មទាំងឡាយ នឹងត្រូវអនុវត្តចំពោះអង្គការអន្តរជាតិ លើកលែងតែទាក់ទងនឹងចំណុចខាងក្រោម ៖

(ក) លិខិតស្តីពីការបញ្ជាក់ ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរបស់អង្គការអន្តរជាតិ នឹងមិនត្រូវលើកយកមកពិចារណានៅក្នុងការអនុវត្តមាត្រា ៣០៨ កថាខណ្ឌទី (១) ទេ។

(ខ) (i) អង្គការអន្តរជាតិមានសមត្ថភាពពេញលេញពាក់ព័ន្ធនឹងការអនុវត្តមាត្រា៣១២ ដល់មាត្រា

៣១៥ ក្នុងកម្រិតដែលអង្គការមានសមត្ថកិច្ចនៅក្រោមមាត្រា ៥ នៃឧបសម្ព័ន្ធនេះទៅលើ កម្មវត្ថុនៃកិច្ចព្រមព្រៀង។

(ii) លិខិតស្តីពីការបញ្ជាក់ ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរបស់អង្គការអន្តរជាតិទៅលើវិសោធនកម្មមួយ ដែលកម្មវត្ថុទាំងមូលនៃវិសោធនកម្មនេះក្នុងចំណោមអង្គការ អន្តរជាតិមានសមត្ថកិច្ចក្រោមមាត្រា ៥ នៃឧបសម្ព័ន្ធនេះនឹងត្រូវបានចាត់ទុកជា លិខិតុបករណ៍ផ្តល់សច្ចានុម័ត ឬចូលជាសមាជិករបស់រដ្ឋជាសមាជិកនីមួយៗដែលជារដ្ឋ ភាគីអនុសញ្ញាសម្រាប់គោលបំណងនៃការអនុវត្តមាត្រា ៣១៦ កថាខណ្ឌ (១) (២) និង (៣) ។

(iii) លិខិតស្តីពីការបញ្ជាក់ ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរបស់អង្គការអន្តរជាតិនឹង មិនត្រូវលើកយកមកពិចារណានៅក្នុងការអនុវត្តមាត្រា ៣១៦ កថាខណ្ឌទី (១) និង (២) ដែលពាក់ព័ន្ធនឹងវិសោធនកម្មផ្សេងៗទៀតទាំងអស់នោះទេ។

(គ) (i) អង្គការអន្តរជាតិមិនអាចដកខ្លួនពីអនុសញ្ញានេះស្របតាមមាត្រា ៣១៧ បានទេប្រសិន

បើរដ្ឋសមាជិកអង្គការនេះគឺជារដ្ឋភាគីអនុសញ្ញា ហើយប្រសិនបើអង្គការនៅបន្តបំពេញបាន តាមគុណវុឌ្ឍិដែលមានចែងនៅក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ។

(ii) អង្គការអន្តរជាតិអាចដកខ្លួនពីអនុសញ្ញានេះបាន ប្រសិនបើអង្គការពុំមានរដ្ឋជាសមាជិក របស់ខ្លួនស្ថិតនៅជារដ្ឋភាគីអនុសញ្ញា ឬប្រសិនបើអង្គការពុំបំពេញបានតាមគុណវុឌ្ឍិដែល មានចែងនៅក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ។ ការដកខ្លួននេះនឹងមានប្រសិទ្ធភាពភ្លាមៗ តែម្តង។